# សាកលវិទ្យាល័យជាតិគ្រប់គ្រង

NATIONAL UNIVERSITY OF MANAGEMENT



# ប្រវត្តិឈ្មោះភូមិ

- សមរលាភ
- សមរខ្មែរ
- សមរចិន

បណ្ឌិត សេង ប៊ុនធឿន






ព.ស 2565-គ.ស 2021

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

ក្រសួងអប់រំ យុវជន និងកីឡា
MINISTRY OF EDUCATION, YOUTH AND SPORT
សាកលវិទ្យាល័យជាតិគ្រប់គ្រង
NATIONAL UNIVERSITY OF MANAGEMENT

លេខ: ០៧២/២១ ស.ជ.គ.

## លិខិតឧទ្ទេសនាម

មន្ត្រីរាជការ និងសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជាគណៈកម្មការនិពន្ធ និងត្រួតពិនិត្យលើស្នាដៃនៃការចូលរួមការរៀបរៀង និពន្ធ និងកែលម្អសៀវភៅកម្រិតឧត្តមសិក្សា ដែលមានចំណងជើងថា **"ប្រវត្តិភូមិសមរលោវ សមរខ្មែរ និងសមរចិន"៖**

ក. គណៈកម្មការនិពន្ធ ឬអ្នកនិពន្ធ

១. លោកបណ្ឌិត សេង ប៊ុនធឿន

ខ. គណៈកម្មការត្រួតពិនិត្យ ៖

១. ឯកឧត្តមបណ្ឌិត ហោ ប៉េង ប្រធាន

២. លោកបណ្ឌិត លី សុខហេង អនុប្រធាន

៣. លោកស្រី ប៉ុក ភារុន សមាជិក

គ. ការអនុញ្ញាតឲ្យបោះពុម្ពផ្សាយ ៖

ឯកឧត្តមបណ្ឌិត ហោ ប៉េង ជាសាកលវិទ្យាធិការ។

គណៈកម្មការ និងអ្នកនិពន្ធ ដូចមានរាយនាមខាងលើ មានភារកិច្ច និងអនុវត្តតាមលិខិតឧទ្ទេសនាមនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៨កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

*រាជធានីភ្នំពេញ* ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១

**សាកលវិទ្យាធិការ**

បណ្ឌិត ហោ_ប៉េង

អាសយដ្ឋាន: ផ្លូវ៩៦គ្រីស្តូហ្វ័ហូវ្ស សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ: (៨៥៥-១២) ៦៧៥ ៧៦៧/ ៨៩៣ ១៣១/ ៨៨៩ ៤៩៥
Address: St. 96 Christopher Howes, Sangkat Wat Phnom, Khan Daun Penh, Phnom Penh / Tel: (855-12) 675 767 / 893 131 / 889 495 Email: sengbunthoeun@num.edu.kh.

# បុព្វកថា

ដំណើរអភិវឌ្ឍនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងយុគសម័យទំនើបនេះ ជាមេរៀនដ៏ជោគជ័យបំផុតមួយដែលចាប់ឬសគល់ចេញពីការបញ្ចប់របបប្រល័យពូជសាសន៍ ការបញ្ចប់សង្គ្រាម ការផ្សះផ្សារជាតិ ការកសាងមូលដ្ឋានរឹងមាំនៃសន្តិភាពនិងស្ថេរភាព និងការអភិវឌ្ឍសេដ្ឋកិច្ច។ នៅក្រោយពេលដែលសន្តិភាពត្រូវបានកើតឡើងដោយបរិបូរណ៍នៅឆ្នាំ១៩៩៨ កម្ពុជាទទួលកំណើនសេដ្ឋកិច្ចខ្ពស់ គឺប្រមាណ៨%ក្នុងមួយឆ្នាំ។ លើសពីនេះទៀត អត្រានៃភាពក្រីក្រត្រូវបានកាត់បន្ថយពីប្រមាណ៥៣% នៅឆ្នាំ២០០៤ មកនៅទាបជាង១០% នៅឆ្នាំ២០១៩។ ដំណើរនៃការអភិវឌ្ឍជាតិជាសកម្មភាពដែលបន្តទៅមុខជាប់ជានិច្ច ហើយគោលនយោបាយថ្មីៗដែលមានលក្ខណៈអន្តរវិស័យគ្រប់ដណ្តប់ ក៏កំពុងលេចរូបរាងឡើង ដើម្បីតម្រង់ទិសកម្ពុជាឆ្ពោះទៅកាន់ប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ២០៣០ និងឈានឡើងជាប្រទេសមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០។ ការប្រែប្រួលឆាប់រហ័សនៃនិម្មាបនកម្មពិភពលោកនិងតំបន់ រួមទាំងទំនាក់ទំនងភូមិសាស្ត្រនយោបាយ បានផ្តល់កាលានុវត្តភាពសម្រាប់ការអភិវឌ្ឍឧស្សាហកម្មនៅកម្ពុជា ដែលត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាមូលដ្ឋានគ្រឹះនៃកំណើនសេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងបន្តពង្រឹងនិងអភិវឌ្ឍវិស័យអប់រំឆ្ពោះទៅរកការស្រាវជ្រាវ និងនវានុវត្តន៍ ដើម្បីពង្រឹងសមត្ថភាពនិងជំនាញរបស់ធនធានមនុស្សនៅកម្ពុជា ឱ្យស្របទៅនឹងបរិបទថ្មីនៃការអភិវឌ្ឍជាពិសេសការពង្រឹងសហគ្រិនភាពក្នុងការរៀបចំម៉ូដែលធុរកិច្ចថ្មីៗ។ ដើម្បីចាប់យកកាលានុវត្តភាពពីបដិវត្តន៍ឧស្សាហកម្មទី៤ និងសេដ្ឋកិច្ចឌីជីថលដែលកំពុងផុសផុលឡើង ប្រព័ន្ធអេកូឡូហ្ស៊ីដែលបង្កលក្ខណៈអំណោយផលដល់ការបង្កើតថ្មី នវានុវត្តន៍ ការស្រាវជ្រាវ និងអភិវឌ្ឍន៍ត្រូវតែមានការកែលម្អ។

បណ្ដាប្រទេសនៅទ្វីបអាស៊ីកំពុងនាំមុខក្នុងការវិនិយោគ លើការស្រាវជ្រាវនិងអភិវឌ្ឍ ដោយមានភាគហ៊ុនប្រមាណ៤៤% នៃការវិនិយោគទាំងមូលរបស់ពិភពលោក។ ប្រទេសចិនកំពុងបន្តកសាងហេដ្ឋារចនាសម្ព័ន្ធនៃការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ ក៏ដូចជាសមត្ថភាពមនុស្ស។ ផ្ទុយទៅវិញ ប្រទេសនៅទ្វីបអាមេរិកខាងត្បូង និងអាហ្វ្រិក កំពុងស្ថិតនៅឆ្ងាយពីការវិនិយោគនេះ ហើយជាលទ្ធផល ប្រទេសទាំងនោះក៏ពុំមានកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ដែរ។ ទុនវិនិយោគសរុបលើការស្រាវជ្រាវនិងអភិវឌ្ឍរបស់ប្រទេសនៅទ្វីបអាមេរិកខាងត្បូងនិងអាហ្វ្រិក មានប្រមាណ៥%នៃការវិនិយោគទាំងមូលរបស់ពិភពលោក ក្នុងពេលដែលតំបន់ទាំង២នេះមានប្រជាជនប្រមាណ២០%នៃប្រជាជនពិភពលោក។ ប្រទេសចំនួន៦ដែលមានលំដាប់ខ្ពស់ជាងគេនៅក្នុងការវិនិយោគ លើការស្រាវជ្រាវនិងអភិវឌ្ឍ រួមមានសហរដ្ឋអាមេរិក ចិន ជប៉ុន អាល្លឺម៉ង់ ឥណ្ឌា និងកូរ៉េខាងត្បូង ដែលស្មើនឹងប្រមាណ៧០%នៃទុនវិនិយោគសរុបរបស់ពិភពលោក។

តើចំណេះដឹង ផលិតផល និងសេវាកម្មថ្មីទាំងនេះកើតឡើងពីអ្វី? ហើយកើតឡើងដោយរបៀបណា? ព្រះរាជាណាចក្រកម្ពុជាកំពុងតែកសាងមូលដ្ឋានសម្រាប់ការត្រៀមខ្លួនទទួល និងប្រកួតប្រជែងក្នុងយុគសម័យបដិវត្តឧស្សាហកម្មទី៤ នៅក្នុងសេដ្ឋកិច្ចដែលផ្អែកលើពុទ្ធិ ហើយដែលប្រការនេះចាំបាច់តម្រូវឱ្យពលរដ្ឋកម្ពុជា ត្រូវក្លាយខ្លួនជាពលរដ្ឋឌីជីថល ពលរដ្ឋសកល និងពលរដ្ឋដែលប្រកបដោយការទទួលខុសត្រូវ ដែលមានសមត្ថភាពក្នុងការផលិត ចែកចាយ និងប្រើប្រាស់ពុទ្ធិដើម្បីទទួលមនុញ្ញផល និងរួមចំណែកក្នុងកំណើន។ ធនាគារពិភពលោកបានធ្វើការកត់សម្គាល់តាំងពីឆ្នាំ២០០២នូវបម្លាស់ប្តូរនៃមូលដ្ឋានសេដ្ឋកិច្ច ពីសេដ្ឋកិច្ចដែលពឹងផ្អែកលើកម្លាំងពលកម្ម និងធនធានអតិកម្ម (Labour and Resource Based Economy) ទៅកាន់សេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិ (Knowledge Based-

Economy) ដែលក្នុងន័យនេះ ពុទ្ធិគឺជាគន្លឹះនៃការអភិវឌ្ឍ។ អាស្រ័យហេតុនេះ នៅលើគន្លងដែលកម្ពុជាកំពុងធ្វើដំណើរឆ្ពោះទៅកាន់សេដ្ឋកិច្ចឌីជីថល សង្គមកម្ពុជាត្រូវតែមានសមត្ថភាពក្នុងការផលិត ជ្រើសរើស បន្សាំ បង្កើតមុខរបរ និងប្រើប្រាស់ពុទ្ធិ ដើម្បីរក្សានិរន្តរភាពនៃកំណើន និងកែលម្អជីវភាពរស់នៅ។ សមត្ថភាពទាំងនេះ អាចកើតឡើងនៅពេលពលរដ្ឋកម្ពុជាមានឱកាសក្នុងការទទួលបានបទពិសោធន៍ពីការស្រាវជ្រាវ ការបណ្ដុះគំនិតច្នៃប្រឌិត និងការស្វែងរកនវានុវត្តន៍។

កំណែទម្រង់វិស័យអប់រំ គឺជាការត្រួសត្រាយមាគ៌ាសម្រាប់ដំណើរឆ្ពោះទៅកាន់សង្គមប្រកបដោយពុទ្ធិ និងប្រជាពលរដ្ឋប្រកបដោយភាពរស់រវើក។ តាមរយៈមូលដ្ឋានអប់រំ សង្គមប្រកបដោយពុទ្ធិនឹងប្រមូលផ្ដុំបង្កើត និងចែករំលែក ទៅកាន់សមាជិកក្នុងសង្គមនូវសម្បទាអប់រំ ពិសេសគឺពុទ្ធិសម្បទា ក្នុងបុព្វហេតុនៃមនុស្សជាតិនិងឧត្ដមប្រយោជន៍នៃប្រទេស។ សង្គមប្រកបដោយពុទ្ធិ គឺពុំគ្រាន់តែជាសង្គមដែលសម្បូរព័ត៌មានប៉ុណ្ណោះទេ តែជាសង្គមដែលប្រជាពលរដ្ឋអាចធ្វើបរិវត្តកម្មពីព័ត៌មានទៅជា មូលធនប្រកបដោយប្រសិទ្ធភាព។ ការរីកចម្រើនទៅមុខជាលំដាប់នៃបច្ចេកវិទ្យានិងតំណភ្ជាប់ បានពង្រីកព្រំដែននៃការចូលទៅកាន់ និងការទទួលបានព័ត៌មានជាសកល ហើយដែលក្នុងន័យនេះ ការអប់រំនឹងបន្តវិវត្តទៅមុខនិងមានការផ្លាស់ប្ដូរ។ សង្គមមួយដែលមានអំណាន និងរបាប់ជាបុរេលក្ខខណ្ឌនៃជីវភាពប្រចាំថ្ងៃនៃប្រជាពលរដ្ឋ ពេលនោះបំណិននៃអំណាន និពន្ធ និងការគណនាលេខនព្វន្ត គឺជាចលករនៃការរៀនរបស់សិស្ស។ ធាតុដ៏ចម្បងមួយដែលស្ថិតនៅក្នុងការកសាងសង្គមដែលប្រកបដោយពុទ្ធិ គឺសៀវភៅសិក្សា ហើយការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សាជាប្រចាំ គឺជានវានុវត្តន៍នៃវិស័យអប់រំដែលនាំទៅរកការសិក្សាពេញមួយជីវិត ការអភិវឌ្ឍសម្បទាអប់រំ និងការចែករំលែកចំណេះដឹង។ មូលដ្ឋានអប់រំ ពិសេសគឺគ្រឹះស្ថានឧត្ដមសិក្សា

ត្រូវមានតួនាទីដែលប្រកបដោយការឆ្លើយតប ចំពោះតម្រូវការខាងលើនេះ។ សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំត្រូវបន្តសិក្សាជាប់ជានិច្ច តាមរយៈការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ហើយដែលសៀវភៅសិក្សាទាំងនេះនឹងក្លាយជាស្ពាន នៃទំនាក់ទំនងរវាងនវានុវត្តន៍នៃបច្ចេកវិទ្យា និងការរៀននិងបង្រៀននៅក្នុងថ្នាក់រៀន។

សង្គមដែលប្រកបពុទ្ធិ ក៏ជាសង្គមដែលបណ្តុះឱ្យមានរចនាសម្ព័ន្ធទន់នៃសេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិដែរ។ ឧទាហរណ៍ជាក់ស្តែងនៃបែបផែននេះរួមមាន Silicon Valley នៃសហរដ្ឋអាមេរិក សួនឧស្សាហកម្មវិស្វកម្មអាកាសយានយន្តនិងយានយន្តនៅទីក្រុង Munich ប្រទេសអាល្លឺម៉ង់ តំបន់ជីវបច្ចេកវិទ្យានៅក្រុង Hyderabad ប្រទេសឥណ្ឌា តំបន់ផលិតគ្រឿងអេឡិចត្រូនិកនិងសារគមនាគមន៍ ឌីជីថលនៅទីក្រុង Seoul ប្រទេសកូរេខាងត្បូង ក៏ដូចជាសួនឧស្សាហកម្មថាមពល និងឥន្ធនគីមីសាស្ត្រនៃប្រទេសប្រេស៊ីល ហើយក៏នៅមានទីក្រុងនៃប្រទេសជាច្រើនទៀតនៅលើពិភពលោក។ លក្ខណៈសម្បត្តិនៃទីក្រុងទាំងនេះគឺការប្រើប្រាស់និន្នាការនៃការអភិវឌ្ឍដែលជំរុញ និងតម្រង់ទិសដោយចំណេះដឹង ហើយដែលចំណេះដឹងទាំងនោះកើតចេញជាដំបូងពីការវិនិយោគទៅលើគ្រឹះស្ថានឧត្តមសិក្សា ស្ថាប័នស្រាវជ្រាវ មជ្ឈមណ្ឌលឧត្តមភាពនៃជំនាញជាន់ខ្ពស់ ការប្រកួតប្រជែងដោយគុណាធិបតេយ្យ និងជាពិសេសគឺការបណ្តុះវប្បធម៌អំណាននិងនិពន្ធសៀវភៅ។ ល្បឿននៃការរីកចម្រើនផ្នែកពុទ្ធិ និងបច្ចេកវិទ្យាកំពុងមានសន្ទុះលឿនជាងអ្វីដែលសិស្សនិងនិស្សិតអាចទទួលបានពីគ្រូ នៅគ្រឹះស្ថានសិក្សាដែលធ្វើឱ្យគោលដៅនៃការអប់រំនៅពេលបច្ចុប្បន្ននេះ មានការប្រឈមខ្លាំងជាងពេលណាទាំងអស់។ ឧទាហរណ៍ ក្នុងមួយឆ្នាំមានសៀវភៅជាង២,២លានចំណងជើង ត្រូវបានសរសេរនិងបោះពុម្ព ដែលក្នុងនោះប្រទេសចិនមាន

៤៤០ពាន់ ចំណែកឯសហរដ្ឋអាមេរិកមាន៣០៥ពាន់ និងប្រទេសរុស្ស៊ីមាន ១២០ពាន់ចំណងជើង។

ខណៈពេលបច្ចេកវិទ្យាកំពុងរីកចម្រើនជារៀងរាល់ថ្ងៃ មធ្យោបាយសម្រាប់អំណានក៏មានច្រើនជម្រើសសម្រាប់សិស្ស-និស្សិត និងសាធារណៈជនរួមមានការអានសៀវភៅ ការអានលើឧបករណ៍ អេឡិចត្រូនិក ការអានដោយប្រើទូរសព្ទវៃឆ្លាត និងការអានលើកុំព្យូទ័រ ដែលសុទ្ធសឹងជាមធ្យោបាយសំខាន់ៗ ដែលនាំអ្នកអានទាំងឡាយឱ្យសម្រេចគោលបំណងអានរបស់ខ្លួន។ ម្យ៉ាងវិញទៀត អំណានដោយប្រើមធ្យោបាយបច្ចេកវិទ្យាទំនើបចំណាយពេលតិច ងាយស្រួលអាន និងជួយដល់បរិស្ថានមួយកម្រិតទៀត។ នាពេលបច្ចុប្បន្ន សិស្ស-និស្សិត និងសាធារណៈជនកម្ពុជាដែលស្រឡាញ់អំណានកំពុងតែប្រើប្រាស់មធ្យោបាយអំណានទាំងនេះ។ បើយើងក្រឡេកមើលទៅប្រទេសជឿនលឿន ទោះបីជាបច្ចេកវិទ្យារីកចម្រើនខ្លាំងយ៉ាងណា អំណានតាមរយៈសៀវភៅនៅតែមានសន្ទុះដដែល។ ម្យ៉ាងវិញទៀតបច្ចេកវិទ្យាអានបែបទំនើបតាមរយៈឧបករណ៍ទំនើប អាស្រ័យលើលទ្ធភាពនៃធនធានអប់រំឌីជីថល និងមាតិកាឌីជីថលគ្រប់គ្រាន់ដែលបានផលិត និងបង្ហោះចែកចាយសម្រាប់អំណាន។

ក្នុងបរិបទកម្ពុជា ជាពិសេសក្នុងបរិការណ៍នៃការផ្ទុះរីករាលដាលនៃជំងឺកូវីដ-១៩ ក្រសួងអប់រំ យុវជន និងកីឡា បានជំរុញឱ្យមានបរិវត្តកម្មឌីជីថលនៅក្នុងអេកូស៊ីស្តែមនៃការអប់រំ ជាពិសេសការអប់រំ តាមប្រព័ន្ធអេឡិចត្រូនិក និងការអប់រំពីចម្ងាយដើម្បីលើកកម្ពស់អំណាន តាមរយៈការផលិតមាតិកាឌីជីថលដែលមានភាពចំរុះ ការកសាងសមត្ថភាពផ្នែកតំណភ្ជាប់និងវេទិកាឌីជីថល ការពង្រីកវិសាលភាពនៃមជ្ឈមណ្ឌលទិន្នន័យ និងការលើកកម្ពស់គុណភាពនៃការផលិតធនធានអប់រំឌីជីថល គួបផ្សំជាមួយការចែកសន្លឹក

កិច្ចការឱ្យសិស្សយកទៅរៀននៅផ្ទះ និងការចុះទៅជួបជាមួយសិស្សជាបណ្តុំនៅតាមសហគមន៍។ ក្នុងន័យលើកកម្ពស់អំណាន និងភាពសម្បូរបែបនៃធនធានសៀវភៅសិក្សា ឱ្យកាន់តែ មានប្រសិទ្ធភាពនិងភាពសក្តិសិទ្ធិ និងផ្តល់ឱកាសអំណានកាន់តែច្រើនថែមទៀតដល់សិស្សានុសិស្ស និស្សិត និងសាធារណៈជន ក្រសួងអប់រំ យុវជន និងកីឡាលើកទឹកចិត្តនូវចំណុចមួយចំនួនដូចខាងក្រោម៖

១. សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំ សូមបន្តនិងបង្កើនការបោះពុម្ពស្នាដៃបន្ថែមទៀត ដើម្បីធ្វើឱ្យធនធានសម្រាប់អំណានកាន់តែសម្បូរបែប ជាពិសេសធនធានអំណានជាខេមរភាសា

២. គ្រឹះស្ថានឧត្តមសិក្សា សូមផ្តល់លទ្ធភាពគ្រប់បែបយ៉ាង ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ និងនិស្សិតគ្រប់កម្រិតសិក្សាអាចចូលរួមអាន និងសិក្សាស្រាវជ្រាវតាមគ្រប់លទ្ធភាពជាមួយធនធានអំណាន ជាពិសេសការរៀបចំឱ្យមានពេលវេលាសម្រាប់សហសិក្សា និងអំណានក្នុងបណ្ណាល័យ

៣. សាស្ត្រាចារ្យតាមមុខវិជ្ជា និងអ្នកស្រាវជ្រាវតាមជំនាញឬវិស័យត្រូវរៀបចំដំណើរការរៀន បង្រៀន និងស្រាវជ្រាវដែលមានដាក់បញ្ចូលកិច្ចការស្វ័យសិក្សា សហសិក្សា ឬការស្រាវជ្រាវបណ្ណាល័យដែលតម្រូវឱ្យនិស្សិត ត្រូវអាននិងស្រាវជ្រាវជាមួយធនធានអំណាន

៤. គ្រឹះស្ថានឧត្តមសិក្សា និងមជ្ឈមណ្ឌលស្រាវជ្រាវ ត្រូវខិតខំឱ្យអស់លទ្ធភាពក្នុងការបង្កើតបណ្ណាល័យ មជ្ឈមណ្ឌលរក្សាឯកសារ ឬមជ្ឈមណ្ឌលអប់រំឌីជីថលជាដើម ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ និងនិស្សិតគ្រប់កម្រិតសិក្សាអាចទទួលបាន និង

ស្វែងរកប្រភពសម្រាប់អំណានកាន់តែសម្បូរបែប និងមានភាពបត់បែន ឆ្លើយតបតាមតម្រូវការអ្នកអាន

៥. និស្សិតគ្រប់កម្រិតសិក្សាត្រូវខិតខំនិងចំណាយពេលអាន និងចាត់ទុកវប្បធម៌ និងអកប្បកិរិយាអំណានជាផ្នែកមួយ នៃពេលវេលានិងភាពស៊ីវិល័យនៃជីវិតប្រចាំថ្ងៃ

៦. បងប្អូនជនរួមជាតិ ដែលជាមាតាបិតា ឬអ្នកអាណាព្យាបាល សូមជួយជំរុញនិងបង្កលក្ខណៈកាន់តែច្រើនថែមទៀត ជាពិសេសការលៃលកចំណាយនៅក្នុងគ្រួសារ សម្រាប់ការទិញសម្ភារៈសិក្សា សៀវភៅអាន និងឧបករណ៍សម្រាប់អំណានដល់កូនៗ ដែលចាត់ទុកជាការ វិនិយោគមួយដ៏សំខាន់ សម្រាប់បង្កើនចំណេះដឹង និងអនាគតរបស់ពួកគេ។

ដោយមានការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅឆ្នាំ២០២០ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ដែលហៅកាត់ថា "មូលនិធិ ស.គ.ន." និងហៅជាភាសាអង់គ្លេសថា The Research Creativity and Innovation Fund ដែលហៅកាត់ជាភាសាអង់គ្លេសថា "RCI Fund"។ គោលដៅចម្បងនៃមូលនិធិនេះ គឺរួមចំណែកលើកកម្ពស់វប្បធម៌នៃការស្រាវជ្រាវ បំផុសគំនិតច្នៃប្រឌិត និងជំរុញការធ្វើនវានុវត្ត ដើម្បីជាប្រយោជន៍ដល់វិស័យអប់រំ យុវជន និងកីឡា ដែលឆ្លើយតបទៅនឹងទីផ្សារពលកម្ម និងសាកលភាវូបនីយកម្ម។ មូលនិធិ ស.គ.ន. បានសម្រេចកំណត់ប្រធានបទ ជាអាទិភាពសម្រាប់ការគាំទ្រដោយមូលនិធិចំនួន៣ រួមមានឌីជីថលនីយកម្មសម្រាប់បដិវត្តឧស្សាហកម្ម ៤.០ (Digitalization for IR.4.0) ការស្រាវជ្រាវអនុវត្តលើវិស័យកសិកម្ម (Applied Agricultural Research) និងការស្រាវជ្រាវគរុកោសល្យសតវត្សទី២១ ($21^{st}$ Century Pedagogy Research)។

ដោយមានការធ្វើអាទិភាពូបនីយកម្ម លើទិសដៅនៃការប្រើប្រាស់ថវិកាមូលនិធិសម្រាប់ឆ្នាំ២០២០ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់ការគាំទ្រដល់ការរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សា (Text book) ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា។ គោលបំណងនៃការរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា គឺដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រីកសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូនដល់និស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ លើសពីនេះ ការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សាមានគោលដៅដូចខាងក្រោម ៖

១. ឆ្លើយតបជាបន្ទាន់ចំពោះការខ្វះខាតធនធានសិក្សា ដែលជាតម្រូវការសិក្សារបស់និស្សិត នៅកម្រិតឧត្តមសិក្សា
២. លើកកម្ពស់ទំនើបភាវូបនីយកម្ម និងឧត្តមានុវត្តន៍នៃការរៀន និងបង្រៀន និងការស្រាវជ្រាវនៅលើមុខវិជ្ជា កម្មវិធីសិក្សា ឬមុខជំនាញជាក់លាក់
៣. បង្កើនភាពស៊ីជម្រៅក្នុងការកសាងវិជ្ជាជីវៈ និងបទពិសោធន៍សម្រាប់ឋានៈសាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវ
៤. រួមចំណែកដល់ការកសាងភាពជាសហគមន៍វិជ្ជាជីវៈ ការចែករំលែកបទពិសោធន៍ និងវប្បធម៌នៃការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា។

ក្រសួងអប់រំ យុវជន និងកីឡា បានវាយតម្លៃខ្ពស់ចំពោះការបោះជំហានប្រកបដោយមនសិការវិជ្ជាជីវៈនៃគ្រឹះស្ថានឧត្តមសិក្សា និងបុគ្គលិកអប់រំទាំងអស់ក្នុងការរៀបចំ រៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដើម្បី

បង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រឹងសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូននិស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ សៀវភៅសិក្សាជាផ្នែកមួយនៃការទទួលស្គាល់គុណភាពអប់រំនៃគ្រឹះស្ថានឧត្តមសិក្សា និងជាធនធានសិក្សាដែលជាមូលដ្ឋានមួយដ៏សំខាន់ ក្នុងការគាំទ្រដល់ការបង្រៀននិងរៀន ហើយត្រូវមានបរិមាណគ្រប់គ្រាន់ ឆ្លើយតបទៅនឹងកម្មវិធីអប់រំ និងតម្រូវការសិក្សាស្រាវជ្រាវ។ ជាគោលការណ៍ គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ត្រូវមានសៀវភៅសិក្សាដែលប្រើជាគោលសម្រាប់មុខវិជ្ជានីមួយៗ។ ចំនួនសៀវភៅសិក្សាដែលគ្រប់គ្រាន់សម្រាប់ការស្រាវជ្រាវ និងការសិក្សារបស់និស្សិតត្រូវមានយ៉ាងតិចមួយចំណងជើងក្នុងមួយមុខវិជ្ជា ហើយត្រូវតម្កល់យ៉ាងតិច២ច្បាប់នៅក្នុងបណ្ណាល័យ ឬអាចរកបានតាមប្រព័ន្ធអេឡិចត្រូនិក។ ក្រសួងអប់រំ យុវជន និងកីឡា លើកទឹកចិត្តបន្ថែមទៀតជូនដល់គ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលបានស្នើសុំថវិកាមូលនិធិ ស.គ.ន រួច សូមចូលរួមបន្ថែមទៀតដើម្បីបង្កើនចំនួនចំណងជើងសៀវភៅ។ ចំណែកគ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលពុំទាន់បានដាក់ពាក្យស្នើសុំថវិកាមូលនិធិ ដើម្បីរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា សូមរួសរាន់ចូលរួម ដើម្បីជាគុណប្រយោជន៍ដល់តម្រូវការដ៏ទទូចនិងថ្លៃថ្លានៃនិស្សិតកម្ពុជាក្នុងការសិក្សា និងស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។

# សេចក្តីបញ្ជាក់
# នៃមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍

សៀវភៅសិក្សានេះ ជាលទ្ធផលនៃការស្នើសុំអនុវត្តថវិកាមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ក្នុងគម្រោងរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា។ សៀវភៅសិក្សានេះ ត្រូវបានរៀបរៀង និពន្ធ ឬកែលម្អដោយមានការធានាអះអាងថាជាស្នាដៃរបស់អ្នកនិពន្ធផ្ទាល់ និងបានឆ្លងកាត់ត្រួតពិនិត្យ ផ្តល់យោបល់ និងវាយតម្លៃដោយក្រុមប្រឹក្សាអប់រំ ក្រុមប្រឹក្សាស្រាវជ្រាវ ឬក្រុមប្រឹក្សាដែលមានតម្លៃស្មើនៃគ្រឹះស្ថានឧត្តមសិក្សា និងតាមរយៈកិច្ចសន្យាដែលបានធ្វើឡើង និងដែលបានតម្កល់ទុកនៅមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍។ រាល់ខ្លឹមសារ ការបកស្រាយ ឬរូបភាព ដែលមាននៅក្នុងសៀវភៅនេះ គឺជាជំហរនិងទស្សនៈផ្ទាល់របស់អ្នកនិពន្ធ ហើយពុំឆ្លុះបញ្ចាំង ឬជាតំណាងដល់មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ នៃក្រសួងអប់រំ យុវជន និងកីឡាឡើយ។

# ឧទ្ទិសស្នាដៃ

សូមឧទ្ទិសស្នាដៃនេះថ្វាយ និងជូន

ចំពោះព្រះវិញ្ញាណក្ខន្ធ និងវិញ្ញាណក្ខន្ធ ព្រះបរមរតនកោដ្ឋ អតីតព្រះមហាក្សត្រ វីរជនខ្មែរស្នេហាជាតិពិតប្រាកដគ្រប់ជំនាន់គ្រប់កាលសម័យដែលបានបូជាជីវិតចំពោះជាតិ សាសនា និងព្រះមហាក្សត្រ។

ចំពោះព្រះវិញ្ញាណក្ខន្ធវិញ្ញាណក្ខន្ធ ព្រះតេជគុណព្រះចៅអធិការ ព្រះឧបជ្ឈាយ៍គ្រប់ព្រះអង្គ លោក អាចារ្យ គណៈកម្មការវត្ត ព្រឹទ្ធាចារ្យ លោកគ្រូ អ្នកគ្រូ និងបុព្វការីជនជាពុទ្ធបរិស័ទចំណុះជើងវត្តសមរលាវ សមរមេត្រីទាំងអស់ដែលបានធ្វើពលិកម្មដើម្បីកិត្តិយសទឹកដីភូមិស្រុក បូរណភាពទឹកដី បង្ហាត់បង្រៀន ប្រៀនប្រដៅគ្រប់បែបយ៉ាងដល់កូនខ្មែរ និងរូបខ្ញុំព្រះករុណាខ្ញុំ។

ចំពោះវិញ្ញាណក្ខន្ធឯកឧត្តមបណ្ឌិត នៅ ស៊ុន អតីតប្រធានវិទ្យាស្ថានជាតិភាសាខ្មែរនៃរាជបណ្ឌិត្យ សភាកម្ពុជាដែលលោកបានដឹកនាំជ្រោមជ្រែងស្វែងរកការពិតអំពីប្រវត្តិឈ្មោះភូមិទាំងបី (សមរលាវ សមរខ្មែរ និងសមរចិន) ដើម្បីមានការទទួលស្គាល់ជាឯកឆន្ទពីក្រុមប្រឹក្សាជាតិភាសាខ្មែរនៃរាជបណ្ឌិត្យកម្ពុជា។

# ឧទ្ទិសស្នាដៃ

សូមឧទ្ទិសស្នាដៃនេះជូនចំពោះ

ព្រះវិញ្ញាណក្ខន្ធរបស់លោកឪពុក សេង អ៊ិន អ្នកម្ដាយ កាក់ ធួង បងប្រុស សេង សុធន់ )អេង( ដែលបានផ្ដល់កំណើត ចិញ្ចឹមបីបាច់ និងផ្ដល់ដំបូន្មានល្អដល់កូន និងប្អូនឲ្យធ្វើតែអំពើល្អ និងបានរៀនសូត្រ។

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំសូមថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួងអប់រំ យុវជន និងកីឡាដែលបានគាំទ្រ និងផ្តួចផ្តើមដល់ការស្រាវជ្រាវ តែងនិពន្ធសៀវភៅនេះរហូតទទួលបានជោគជ័យជាស្ថាពរ។

មូលនិធិមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ហៅកាត់ថា "មូលនិធិ ស.គ.ន" និងហៅជាភាសាអង់គ្លេសថា The Research Creativity and Innovation Fund ដែលហៅកាត់ជាភាសាអង់គ្លេសថា "RCI Fund" ដែលបានរួមចំណែកលើកកម្ពស់វប្បធម៌នៃការស្រាវជ្រាវ បំផុសគំនិតច្នៃប្រឌិត និងជំរុញការធ្វើនវានុវត្ត ដើម្បីជាប្រយោជន៍ដល់វិស័យអប់រំ យុវជន និងកីឡា និងផ្តល់មូលនិធិបោះពុម្ពសៀវភៅនេះទាំងស្រុង។

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំសូមថ្លែងអំណរព្រះគុណ អរគុណយ៉ាងជ្រាលជ្រៅប្រកបដោយកត្តញ្ញុតាធម៌ចំពោះៈបងស្រី សេង សុខហេង បងប្រុស សេង ឆេងលាង សេង ឆេងឡៃ(ធួក) បងស្រី សេង ម៉េងហ៊ាង ប្អូនស្រី សេង ស៊ាង ហៃ ដែលបានផ្តល់កំណើតចិញ្ចឹមបីបាច់ផ្តល់ដំបូន្មានល្អៗនិងលើកទឹកចិត្តដល់កូន ប្អូន បងឱ្យប្រព្រឹត្តិតែអំពើល្អ និងស្រឡាញ់ការសិក្សា។ បងប្រុស លឹម សុខន អតីតនាយកក្រឡាបញ្ជីនាយកអយ្យការងបច្ចុប្បន្នជាអនុប្រធានលេខាធិការដ្ឋាន សាលាដំបូងខេត្តតាកែវដែលបាននាំរូបខ្ញុំទៅរស់នៅជាមួយបានបន្តការសិក្សានៅសាលាបំពេញវិជ្ជាក្រៅម៉ោងនៅវិទ្យាល័យតាកែវ បច្ចុប្បន្នវិទ្យាល័យជាស៊ីម តាកែវ រហូតបានបញ្ចប់ការសិក្សាថ្នាក់វិទ្យាល័យដោយជោគជ័យ។

សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ថ្នាក់ដឹកនាំ និងសហការីដែលបានជួយជ្រោមជ្រែងក្នុងការចេញប្រកាសកែសម្រួលឈ្មោះភូមិទាំងពីរដែលបានសរសេរខុសឲ្យត្រឹមត្រូវ និងមានអត្ថន័យគ្រប់គ្រាន់ដូចដើមវិញ។

ក្រសួងអប់រំ យុវជន និង កីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលបានជួយឧបត្ថម្ភគាំទ្រមូលនិធិក្នុងការតែងនិពន្ធ និងបោះពុម្ពផ្សាយសៀវភៅសម្រាប់កម្មវិធីសិក្សានេះ។

ឯកឧត្តមបណ្ឌិត កុល ផេង អតីតទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ

យុវជននិងកីឡានិងជាបិតាស្ថានិកសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជាដែលតែងតែប្រៀនប្រដៅផ្ដល់ដំបូន្មានល្អៗ។

ឯកឧត្តមបណ្ឌិ ហោ ប៉េង សាកលវិទ្យាធិការនៃសាកលវិទ្យាល័យជាតិគ្រប់គ្រងចំពោះការជំរុញ និងលើកទឹកចិត្តយ៉ាងខ្លាំងដល់វិស័យស្រាវជ្រាវបោះពុម្ពផ្សាយដើម្បីបានជាស្នាដៃ និងប្រយោជន៍ដល់ភូមិស្រុក និងសង្គមជាតិទាំងមូល។

ឯកឧត្តមនាយឧត្តមសេនីយ៍សាស្ត្រាចារ្យបណ្ឌិតឯកមនៅសែន អតីតនាយករងខុទ្ទកាល័យសម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អនុប្រធានបណ្ឌិត្យសភានគរបាល និងជាប្រធាននាយកដ្ឋានបណ្ដុះបណ្ដាលនៃក្រសួងមហាផ្ទៃ។

ឯកឧត្តមឧត្តមសេនីយ៍ឯក ណុប នរិន្ទ អតីតជំនួយការសម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បច្ចុប្បន្នជា អគ្គនាយករង អគ្គនាយកដ្ឋានអន្តោប្រវេស្សន៍ និងជាប្រធានវិទ្យាស្ថានខ្មែរជំនាន់ថ្មី ជាពិសេសឯកឧត្តម ថាច់ វណ្ណៈ អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន និងជាទីប្រឹក្សាសម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃដែលជួយធ្វើកិច្ចការមួយចំនួនពាក់ព័ន្ធនឹងការស្រាវជ្រាវ តែងនិពន្ធសៀវភៅនេះឡើង។

ឯកឧត្តមបណ្ឌិត សន ពៅ អនុប្រធាន ឯកឧត្តមបណ្ឌិត ថោ គឿន អតីតអគ្គលេខាធិការរង ឯកឧត្តម ប៊ុត សុមេត អគ្គលេខាធិការរង និងលោក

លាង សុភាព ប្រធានផ្នែករដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុនៃ វិទ្យាស្ថានជាតិភាសាខ្មែរនៃរាជបណ្ឌិត្យសភាកម្ពុជាដែលបានចុះស្រាវជ្រាវរកការពិតនៅភូមិដ្ឋានផ្ទាល់ដើម្បីបានជាមូលដ្ឋានក្នុងការកែសម្រួលឈ្មោះភូមិសមរលោរ និងភូមិសមរខ្មែរឲ្យបានត្រឹមត្រូវវិញ។ លោក អ៊ុច បញ្ញា លោក រស់ សាន់តាណា លោក ជឹង ផេងស្រួយ លោក វង្ស គឹមសាន្ត ដែលបានជួយគាំទ្រ និងជាអ្នកជួយលើកទឹកចិត្តដើម្បីឱ្យកិច្ចការនេះឈានដល់ទីបញ្ចប់។

សូមកោតសរសើរដ៏ស្មោះចំពោះក្មួយប្រុស សេង វិធូរ អ៊ិន វុទ្ធី អ៊ិន ឡុង សេង វុត្ថា សេង ធារ៉ា អ៊ិន ថៃ (ឧុល) សេង សាកល សេង ឌី អ៊ូ វឌ្ឍនម៉េង ក្មួយស្រី ម៉ៅ ស៊ាងឡេង សេង ឧសភា សេង សៀកម៉េង អ៊ិន គាម អ៊ិន ស៊ីណា សេង សេរី សេង គន្ធា សេង ឡៃហួយ សេង ណារី សេង ថារី អ៊ូ វឌ្ឍននាថ ហ៊ ណារី និងក្មួយប្រសារទាំងអស់ ដែលបានខិតខំរៀន និងសាមគ្គីគ្នា។

សូមថ្លែងអំណរព្រះគុណ និងអរគុណចំពោះព្រះតេជគុណ ឡាក់ ហំ (ហ៊ីម)ព្រះចៅអធិការវត្តសមរលោរ លោក គឿក ជ្រុន ជាអតីតសិស្សសាលាបឋមសិក្សាសមរលោរ និងជាអតីតនាយកវិទ្យាល័យ ជា ស៊ីម តាកែវ លោកយុន សារ៉ាន់ ជាអតីតគ្រូបង្រៀននៃសាលាកម្រិតសិក្សាទី១(បឋម)សមរលោរ អនុវិទ្យាល័យព្រៃល្វា អនុវិទ្យាល័យស្រុកកំពង់ត្រឡាច និងក្លាយជានាយកអនុវិទ្យាល័យមហាសាមគ្គី (បច្ចុប្បន្នជាវិទ្យាល័យ ជា ស៊ីម) ស្រុកកំពង់ត្រឡាច (ខេត្តកំពង់ឆ្នាំង) លោក ឡាក់ គិមសាន អតីតនាយកវិទ្យាល័យសមរលោរ និងជាអតីតអភិបាលរងស្រុកព្រៃកប្បាស លោកស្រី រ៉េន មេឃុំពោធិ៍រំចាក

លោក ប្រាក់ សម្បត្តិ ជំទប់ទី១ឃុំពោធិ៍រំចាក លោក ឈឹម សុវណ្ណ នាយក លោក ឌុក ឌីកែន នាយករង លោកស្រី រី គន្ធឿន អតីតនាយិការង និងលោក គ្រូ អ្នកគ្រូនៃវិទ្យាល័យសមរលោរ លោក ឡាច ស្រ៊ី នាយកសាលាបឋមសិក្សា ហាតាកាស៊ីសមរមេត្រី លោក គន ភត នាយកសាលា បឋមសិក្សាសមរលោរ លោក មួយ គុនអេង ប្រធានភូមិសមរលោរ លោក សៅឈឿងលោក ហុក ខេង (គ្រូបង្រៀនចូលនិវត្តន៍) សេង សាកល ងន សីហា ហោ ស្រីទូច ប្រាក់ ច័ន្ទខេមរា ប្រាក់ ច័ន្ទសិលា(អតីតសិស្សវិទ្យាល័យសមរលោរ) លោក ឈុន លីពោរ លោក ប៊ុត សុឌី ជាអតីតនិស្សិតសាកលវិទ្យាល័យជាតិគ្រប់គ្រងដែលបាន ជួយជ្រោមជ្រែងដល់កិច្ចដំណើរការស្រាវជ្រាវ និងសរសេរសៀវភៅនេះរហូត បានចប់ជាស្ថាពរ។

សូមអរគុណជាអនេកប្បការចំពោះលោកស្រី ភន ង៉ែត ដែលបាន ផ្តល់ទឹកប្រាក់ចំនួន៣០០ដុល្លារអាមេរិកថ្លៃសរសេរបទភ្លេងនៃបទចម្រៀង ភូមិសមរលោរ ភូមិសមរខ្មែរ និងភូមិសមរចិន។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅលោក ឡុង សារិន សាស្ត្រាចារ្យ អក្សរសាស្ត្រខ្មែរ លោក ជឹង ផេងស្រួយ ប្រធានការិយាល័យរដ្ឋបាលបុគ្គលិក នៃសាលាដំបូងរាជធានីភ្នំពេញដែលបានចំណាយពេលវេលាដ៏តម្លៃជួយកែ សម្រួលអក្ខរាវិរុទ្ធក្នុងសៀវភៅនេះ។

សូមថ្លែងអំណរអរគុណប្រកបដោយក្តីរំភើបចំពោះឧត្តមភរិយា *ហែម ពេជ្របញ្ញា* និងបុត្រាជាទីស្រឡាញ់ *សេង ពេជ្រពុទ្ធិខេមរិន្ទ សេង ពេជ្រពុទ្ធិវ*

*ឡូន:* និង *សេង ពេជ្រពុទ្ធិវីរៈធន* ដែលជានិច្ចកាលតែងតែជាកម្លាំងចិត្តដល់ការស្រាវជ្រាវ និងបោះពុម្ពសៀវភៅនេះដោយជោគជ័យ

# អារម្ភកថា

សៀវភៅនេះត្រូវបានស្រាវជ្រាវ និងចងក្រងក្នុងគោលបំណងសំខាន់ៗមួយចំនួនដូចខាងក្រោម៖

ទី១-ដើម្បីសំដែងនូវកតញ្ញូតាធម៌ចំពោះព្រះសង្ឃ អ្នកភូមិ ម្ចាស់ស្រុក មាតាបិតា គ្រូបង្រៀន សហគមន៍ ក៏ដូចជាបុព្វបុរសយើង ដែលបានពុះពារគ្រប់បែបយ៉ាងកសាងសមិទ្ធផលជាច្រើនរួមមាន អគារសិក្សា វត្តអារាម ស្រះទឹក ស្ពានថ្នល់។ល។ ដល់កូនចៅជំនាន់ក្រោយ។

ទី២-ក្រោយថ្ងៃរំដោះ ៧មករា១៩៧៩ ពោលគឺបន្ទាប់ពីរដ្ឋាភិបាលខ្មែរក្រហមដួលរលំទៅខ្ញុំបានធំដឹងក្ដី ហើយចូលសិក្សា។ ជាមួយគ្នានេះ ចម្ងល់មួយក៏បានលេចឡើង...ហេតុអ្វីបានភូមិទាំងបីនេះត្រូវបានគេដាក់ ឈ្មោះថាសមរលាវ សមរខ្មែរ និងសមរចិន ហើយថែមទាំងមានទីតាំងនៅជាប់ៗគ្នាយ៉ាងដូច្នេះ?

៣-ចាប់ពីអំឡុងឆ្នាំ២០០១មក អក្សរឈ្មោះភូមិសមរលាវ សមរខ្មែរត្រូវបានសង្កេតឃើញថា មានសរសេរជាផ្លូវការលើលិខិតស្នាមរដ្ឋបាល ឯកសារអត្តសញ្ញាណប័ណ្ណ លិខិតអគ្រានុកូលដ្ឋានខុសពីសំណេរដើមទាំងស្រុងនាំឲ្យប្រាសចាកពីអត្ថន័យដែលចាស់ទុំធ្លាប់បាននិទានប្រាប់ ក៏ដូចជាការសរសេរមុនៗ និងការចេះដឹងពីលោកគ្រូអ្នកគ្រូរបស់ខ្លួន។ ខ្ញុំបានធ្វើការតស៊ូមតិដោយបានសួរនាំរឿងនេះ និងព្យាយាមសុំកែពីមន្ត្រីពាក់ព័ន្ធដើម្បីឲ្យមានការកែសម្រួលឲ្យបានត្រឹមត្រូវមកវិញ។ ខ្ញុំបានគិតថា ប្រសិនបើមិនបានមានទាមទារឲ្យមានការកែប្រែឈ្មោះភូមិទាំងបីនេះពីការសរសេរខុសឲ្យមកជា

ត្រឹមត្រូវវិញនោះទេ កូនចៅជំនាន់ក្រោយនឹងបាត់អត្តសញ្ញាណកម្មដែលជាឈ្មោះរបស់ខ្លួនមិនខាន។ សៀវភៅនេះ ក៏បានបញ្ចូលផងដែរនូវបញ្ហាផ្សេងៗមួយចំនួនដែលមានប្រវត្តិពាក់ព័ន្ធជាមួយនឹងភូមិទាំងបីនេះ។ ខ្ញុំសូមអភ័យទោសទុកជាមុនចំពោះការខ្វះខាត ឬលើសលស់នូវរាល់ព័ត៌មានដែលបានរៀបរាប់នៅក្នុងសៀវភៅនេះ។ ទន្ទឹមនឹងនេះ ខ្ញុំរីករាយនឹងទទួលយករាល់ការរិះគន់ដើម្បីស្ថាបនា កែលម្អគ្រប់បែបយ៉ាងសម្រាប់ការបោះពុម្ពលើកក្រោយៗទៀត។ **វានឹងបង្កើតបានជាវិប្បដិសារីដ៏ធំមួយ ប្រសិនបើយើងបន្តនៅស្ងៀមស្ងាត់ជាមួយនឹងកំហុសដែលយើងក៏បានដឹងដែរថា វាអាចនឹងផ្តល់ផលវិបាកយ៉ាងខ្លាំងដល់អនាគតរបស់យើង។**

*រាជធានីភ្នំពេញ* ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១

*អ្នកនិពន្ធ*

*បណ្ឌិត សេង ប៊ុនធឿន*

# ទំព័រប្រាប់រឿង


សេចក្ដីផ្ដើម ........................................................................1

ជំពូកទី១ ........................................................................15

កំណើតនៃប្រទេសកម្ពុជា ........................................................................15

១-ដើមកំណើតនគរភ្នំ ឬហ្វូណន ........................................................................15

ក-តាមការចងចាំរបស់អ្នកស្រុក ........................................................................15

ខ-តាមឯកសារប្រវត្តិសាស្ត្រ ........................................................................ 20

គ-អំពីទីតាំងភូមិសាស្ត្រ........................................................................21

២-ការទទួលឥទ្ធិពលឥណ្ឌា ........................................................................ 36

ក-ការទទួលឥទ្ធិពលឥណ្ឌាលើកទី១........................................................................ 36

ខ-ការទទួលឥទ្ធិពលឥណ្ឌាលើកទី២ ........................................................................ 40

៣-អរិយធម៌ខ្មែរសម័យនគរភ្នំ........................................................................ 43

ក-វិស័យសេដ្ឋកិច្ច ........................................................................ 46

ជំពូកទី២ ........................................................................49

អរិយធម៌អាស៊ីអាគ្នេយ៍-អំពីបណ្ដាប្រជាជាតិដែល ........................................................................49

រស់នៅជុំវិញអាណាចក្រខ្មែរ........................................................................49

១-ទំនាក់ទំនងរវាងខ្មែរ និងលាវ (សង្គ្រាមខ្មែរ-លាវ) ...................... 52
២-អំពីដើមកំណើតឈ្មោះភូមិសមរលាវសមរខ្មែរ សមរចិន.................71
៣-វត្តសមរលាវ............................................................................... 97
ខ-អំពីប្រវត្តិអាចារ្យវត្ត និងគណៈកម្មការអាចារ្យ..........................102
ឃ-អំពីសាលាហោត្រ័យ ..............................................................110
ង-អំពីព្រះវិហារ .........................................................................112
ច-អំពីក្លោងទ្វារវត្ត......................................................................113
៤-ទីតាំងភូមិសាស្ត្រ .......................................................................116
៥-អំពីការសិក្សាអប់រំ.....................................................................118
ក-ប្រវត្តិសាលាបឋមសិក្សាសមរលាវ..........................................120
ខ-អំពីគណៈគ្រប់គ្រងសាលាបឋមសិក្សា.....................................125
គ-អំពីអនុវិទ្យាល័យ និងវិទ្យាល័យសមរលាវ...............................129
៦-ដើមកំណើតភូមិសមរខ្មែរ និងភូមិសមរចិន ..............................173
៧-ជំនឿ សាសនា និងទំនៀមទម្លាប់ប្រពៃណី.................................191
៩-សេដ្ឋកិច្ច(បញ្ហាជីវភាពរស់នៅ).................................................219
១- ការផ្លាស់ប្តូរនៃសំណោរភូមិសមរលាវ និង ភូមិសមរ................. 223
២- ការសម្ភាសន៍អំពីប្រវត្តិនៃការសរសេរឈ្មោះភូមិសមរលាវ ......... 232

៣-ការប្រែប្រួលឈ្មោះទីតាំងមួយចំនួនដែលបានជួបប្រទះ ...........248

៤-ការប្រើប្រាស់សករាជ ........................................................ 256

លិខិតចំហក្តីស្រមៃរបស់ខ្ញុំ .......................................................278

ឯកសារគន្ថនិទ្ទេស ..................................................................288

ឧបសម្ព័ន្ធទី១ ........................................................................290

ឧបសម្ព័ន្ធទី២ ........................................................................291

ឧបសម្ព័ន្ធទី៣ ........................................................................292

ឧបសម្ព័ន្ធទី៤ ........................................................................293

ឧបសម្ព័ន្ធទី៥ ........................................................................310

ឧបសម្ព័ន្ធទី៦ ........................................................................312

ឧបសម្ព័ន្ធទី៧ ........................................................................315

ឧបសម្ព័ន្ធទី៨ ........................................................................316

ឧបសម្ព័ន្ធទី៩ ........................................................................317

.......................................................................................................317

ឧបសម្ព័ន្ធទី១០ ......................................................................318

# សេចក្ដីផ្ដើម

ប្រវត្តិរឿងរ៉ាវអ្វីមួយ ទីកន្លែងណាមួយ ព្រឹត្តិការណ៍ណាមួយ គេអាចនិយាយតៗគ្នាពីមាត់មួយទៅមាត់មួយពីមនុស្សម្នាក់ទៅមនុស្សម្នាក់ ពីមួយជំនាន់ទៅមួយជំនាន់បានយ៉ាងច្រើនឥតគណនា។ ប៉ុន្តែប្រសិនបើគេមិនបានសរសេរប្រវត្តិនានាទាំងនោះទុកជាលាយលក្ខណ៍អក្សរ ជាឯកសារត្រឹមត្រូវទេ វាគង់តែរលុបបាត់ទៅតាមពេលវេលា និងការស្លាប់របស់មនុស្សពីមួយជំនាន់ៗដោយជៀសមិនផុត។ ជាការពិតណាស់ ពាក្យសំដីផ្ទាល់មាត់ដែលមិនបានកត់ត្រា ឬថតជាសំឡេងទុកទេ វានឹងបាត់បង់ក្លាយជាអត់បានការ និងអាសារបង់ សមដូចពាក្យថា លាយលក្ខណ៍អក្សរបន្សល់ទុកជាតឹកតាង រីឯការនិយាយវានឹងហើរទៅបាត់ "Les écrits restent, les paroles s'envolent /The writing are remained, the speech blow away" ។ ការសរសេរបានជាឯកសារភស្តុតាងស្ថិតស្ថិរយូរអង្វែងមិនអាចប្រែក្រឡាស់បានឡើយ។

ផ្អែកតាមឧត្តមគតិនេះ សៀវភៅមួយក្បាលបានលេចជារូបរាងឡើងដោយបែងចែកជាបីវគ្គធំៗដូចតទៅ៖

ទី១-ការលើកយកប្រវត្តិកកើតទឹកដីនៃប្រទេសកម្ពុជា មកអធិប្បាយដោយសង្ខេបតាមបែបការនិយាយតៗគ្នារបស់អ្នកស្រុក និងការស្រាវជ្រាវបែបប្រវត្តិសាស្ត្រ។ ដ្បិតប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជាបង្ហាញថា ទឹកដីនៃប្រទេសកម្ពុជាមានដើមកំណើតចេញពីស្រុកព្រៃកប្បាស ឬបច្ចុប្បន្នស្រុកអង្គរបុរីនេះតែម្តង។

ទី២-ប្រវត្តិរឿងរ៉ាវ និងរបកគំហើញនៃភូមិទាំងបី ( សមរលោវ សមរខ្មែរ សមរចិន ) ដែលនាំឲ្យបុព្វបុរសក្នុងតំបន់នេះបានប្រសិទ្ធនាមភូមិទាំងបីរហូតមកដល់បច្ចុប្បន្ន។

ទី៣-ការវិភាគវែកញែកទាក់ទងនឹងការផ្លាស់ពីសំណេរដើមដែលត្រឹមត្រូវទៅជាការសរសេរដែលមានការខុសឆ្គង ហើយត្រូវបានទាមទារកែប្រែឲ្យបានត្រឹមត្រូវវិញ។

សៀវភៅនេះក៏អធិប្បាយខ្លះៗដែរអំពីជីវភាពរស់នៅ បញ្ហាសេដ្ឋកិច្ចនយោបាយ ជំនឿ ទំនៀមទម្លាប់ ប្រពៃណីរបស់អ្នកភូមិទាំងបីជាប្រយោជន៍ឲ្យអ្នកស្រាវជ្រាវបានដឹង និងស្គាល់អំពីការវិវត្តក្នុងសហគមន៍នេះពីមួយជំនាន់ទៅមួយជំនាន់ក៏ដូចជាមានគោលបំណងឲ្យអ្នកអានបានយល់អំពីប្រវត្តិនៃភូមិទាំងបីខាងលើ។ ក្នុងឧបសម្ព័ន្ធទី១០នៃសៀវភៅមានបទចម្រៀងមនោសញ្ចេតនាដែលបានរៀបរាប់អំពីអនុស្សាវរីយ៍នៃភូមិស្ថានទាំងនេះទុកជូនប្រិយមិត្តក្មេង ចាស់ ប្រុស ស្រីបានស្តាប់កែអផ្សុក និងរាំកំសាន្ត។

សូមរំលឹកបន្តិចទាក់ទងនឹងវាក្យស័ព្ទប្រវត្តិវិទ្យា និងប្រវត្តិសាស្ត្រ។ តាមសៀវភៅសិក្សាមុខវិជ្ជាប្រវត្តិវិទ្យារបស់សាកលវិទ្យាល័យជាតិគ្រប់គ្រងឲ្យនិយមន័យប្រវត្តិសាស្ត្រថា ជាវិទ្យាសាស្ត្រនៃការកត់ត្រារឿងរ៉ាវផ្សេងៗដែលកើតឡើងក្នុងអតីតកាលកន្លងហួសមកហើយ។ គ្រប់ព្រឹត្តិការណ៍ដែលកត់ត្រាសុទ្ធតែជារឿងពិតទាំងអស់។ រីឯប្រវត្តិវិទ្យាវិញគឺជាមុខវិជ្ជាសិក្សាអំពីប្រវត្តិសាស្ត្រ។ ជាការសិក្សាស្រាវជ្រាវ ស្វែងយល់នូវប្រវត្តិនានា ដែលបានកប់បាត់

ក្នុងអតីតកាលដែលកន្លងហួសដើម្បីធ្វើការចងក្រង និងផ្សព្វផ្សាយ។ ប្រវត្តិវិទ្យា ជាមុខវិជ្ជាសិក្សាអំពីប្រវត្តិសាស្ត្រ (ជាតិ អន្តរជាតិ ឬប្រវត្តិសាស្ត្រពិភពលោក)។ល។ ពាក្យប្រវត្តិវិទ្យាត្រូវបានអ្នកប្រាជ្ញ និងប្រវត្តិវិទូលើកឡើងជាទស្សនៈតាមការយល់ឃើញផ្សេងៗពីគ្នា។

តាមលោក **វ៉ុលទែរ** (Voltaire) ជាប្រវត្តិវិទូបារាំងដ៏ល្បីល្បាញបានផ្តល់ទស្សនៈថាប្រវត្តិវិទ្យា គឺជានិទានកថានៃហេតុការណ៍ទាំងឡាយដែលពិតផ្ទុយពីរឿងល្បើកដែលជានិទានកថា ស្តីពីហេតុការណ៍ ដែលមិនពិត[1]។ នេះជាទស្សនៈប្រាកដនិយម ដែលបានធ្វើឲ្យប្រវត្តិវិទូលើលោកទទួលស្គាល់រូបលោក។ ចំណែកលោក **ប៉ូល វ៉ាលេរី** (Paul Valéry) ដែលជាប្រវត្តិវិទូបារាំងមួយរូបទៀតបានបញ្ចេញមតិឲ្យពិភពលោកដឹងថា ប្រវត្តិវិទ្យាគឺជាវិទ្យាសាស្ត្រស្តីពីរឿងរ៉ាវទាំងឡាយ ដែលមិនកើតមានឡើងច្រំដែលៗ[2]។

តាមលោក ប៉ូល រឿងរ៉ាវដែលកើតឡើងច្រំដែលៗមិនចាំបាច់កត់ត្រាទុកជាប្រវត្តិសាស្ត្រទេ។ ម៉្យាងទៀតតើអ្វីទៅថារឿងរ៉ាវខុសគ្នា និងច្រំដែលៗនោះ។ ឧទាហរណ៍ កាលពីសម័យលង្វែក ខ្មែរដែល បានស្រឡាញ់មាសប្រាក់ចាញ់បោកសៀមដោយចូលទៅកាប់ឆ្ការ គាស់រំលើងមហាកំផែងព្រៃឫស្សីដ៏ក្រាស់ឃ្មឹក និងជារបងការពាររឹងមាំនៃបន្ទាយលង្វែករបស់ព្រះបាទ ចន្ទរាជាឬអង្គចន្ទទី១ ដោយខ្លួនឯងបន្ទាប់ពីឃើញមានប្រាក់ដួងជាច្រើនដែលទ័ព

---

[1] ជូ ច័ន្ទដារី ចាន់ ប៊ុន្នី ឌៀប សុផល ស្រ៊ុន ប៊ុណ្ណារិទ្ធ៖ ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ឆ្នាំ២០១០ ទំព័រ១

[2] ឯ-ដ-ទំព័រ១

សៀមបានបាចចូលទៅក្នុងព្រៃឫស្សីទាំងនោះជាចេតនាខ្ចីដៃខ្មែរប្រើដើម្បីបើកផ្លូវឲ្យកងទ័ពរបស់ខ្លួនវាយចូលព្រះរាជវាំងរបស់ព្រះរាជាខ្មែរបានដោយស្រួល។ ដោយសារតែប្រាក់ដួងរបស់សៀម រាស្ត្រខ្មែរជំនាន់នោះបានកាប់ឆ្ការទាល់តែរលាយក្លាយជាវាលលំហល្វឹងល្វើយ ទោះបីមានការហាមប្រាមពីព្រះមហាក្សត្ររបស់ខ្លួនក៏ដោយ។ នៅសម័យក្រោយៗមកនៃសង្គមខ្មែរ គ្មានទេប្រាក់ដួង ប៉ុន្តែវត្តមាន និងឥទ្ធិពលទឹកប្រាក់ ឬសម្ភារៈ និងរូបបិយប័ណ្ណផ្សេងៗ ក៏បានធ្វើឲ្យខ្មែរមួយចំនួនបាត់បង់មនសិការ និងឧត្តមគតិរបស់ខ្លួនដែរ។ តើនេះ អាចរាប់ថា ជាការកើតឡើងច្រំដែលៗនៃប្រវត្តិសាស្ត្របានដែរឬទេ? ដូច្នេះ ចំពោះយើងយល់ថាទស្សនៈនេះមិនមានលក្ខណៈគ្រប់ជ្រុងជ្រោយទេ។ ពីព្រោះរឿងរ៉ាវអ្វីក៏ត្រូវបានអ្នកប្រវត្តិសាស្ត្រធ្វើការកត់ត្រាទុកដែរ ថ្វីបើវាបានកើតឡើងច្រើនដងក៏ដោយ ក៏វាមិនកើតឡើងនៅពេលតែមួយជាមួយគ្នាក៏ដោយ។ ប្រវត្តិវិទូជនជាតិបារាំងមួយរូបទៀត ដែលពោរពេញទៅដោយមនោសញ្ចេតនាដ៏ជ្រាលជ្រៅ គឺលោក **ស៊ីសេរ៉ុង**(Cicéron) បានសរសេរថា ប្រវត្តិវិទ្យា ជាសក្ខីភាពនៃសតវត្សកន្លងទៅ ជាពន្លឺនៃសច្ចភាព ជាព្រលឹង នៃលំនឹក ជាម្ចាស់នៃជីវិត...[3]។ តើនេះជាការយល់ឃើញគ្រប់ជ្រុងជ្រោយឬទេ? ចំពោះស្មេរយល់ថា "ប្រវត្តិវិទ្យាគឺជាដំណឹងឯករាជ្យ ហើយគ្រប់ព្រឹត្តិការណ៍ដែលត្រូវបានកត់ត្រាមិនចំណុះនយោបាយ សេដ្ឋកិច្ច បុគ្គលណាម្នាក់ និង

[3] ដូ ច័ន្ទដារី ចាន់ ប៊ុន្នី ឌៀប សុផល ស្រ៊ុន ប៊ុណ្ណារិទ្ធ៖ ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ឆ្នាំ២០១០ ទំព័រ១

ច្បាប់ឡើយ[4]។ ប្រវត្តិសាស្ត្រអាចកើតឡើងច្រំដែលៗ។ ប្រជារាស្ត្រនៃប្រទេសមួយដែលស៊ីវិល័យ ត្រូវតែមានចំណេះដឹងខាងប្រវត្តិសាស្ត្រ។ អ្នកដឹកនាំល្អត្រូវស្គាល់ពីប្រវត្តិសាស្ត្រប្រទេសជាតិខ្លួនឯងឲ្យច្បាស់លាស់ ហើយចេះដឹកនាំយ៉ាងណាគេចឲ្យផុតពីរឿងរ៉ាវអាក្រក់ៗក្នុងអតីតកាលដើម្បីកុំឲ្យវាកើតឡើងម្តងទៀតនាំឲ្យមានផលវិបាកដល់មនុស្សជំនាន់ក្រោយ។ ប្រទេសមួយមានអ្នកដឹកនាំល្អ ជាភ័ព្វសំណាងរបស់ប្រជាពលរដ្ឋនៃប្រទេសនោះ”[5]។ ដើម្បីបាន ជាប្រយោជន៍ដល់អ្នកស្រាវជ្រាវផ្នែកសង្គម យើងសូមដកស្រង់ខ្លះៗនូវការយល់ឃើញប្រវត្តិវិទូមួយចំនួន។

**-ប្រវត្តិវិទ្យា ធ្វើឱ្យយើងជក់ចិត្ត** ៖ គឺជារឿងនិពន្ធដែលពិត មិនមែនជាលទ្ធផលនៃការស្រមៃរបស់អ្នកនិពន្ធណាម្នាក់ឡើយ[6]។

**-ប្រវត្តិវិទ្យាមានប្រយោជន៍** ៖ ប្រវត្តិវិទ្យា ពន្យល់យើងពីបច្ចុប្បន្នកាលដោយធ្វើការសិក្សាអតីតកាល។

**-ប្រវត្តិវិទ្យា បង្រៀនឱ្យយើងសុភាពរាបសា** ៖ ប្រវត្តិវិទ្យាបង្ហាញយើងថា ជនជាតិជាច្រើន បាននាំមកនូវវិភាគទានចំពោះអរិយធម៌របស់មនុស្សជាតិនៅពេលបច្ចុប្បន្ននេះ។ ប្រទេសជប៉ុនធ្លាប់ទទួលរងនូវការទម្លាក់គ្រាប់បែកបរមាណូពីសហរដ្ឋអាមេរិកនៅទីក្រុងហ៊ីរ៉ូស៊ីម៉ា( Hiroshima )និងក្រោយ

---

[4] ទស្សនៈផ្ទាល់របស់អ្នកនិពន្ធ។

[5] ដ-ដ

[6] ដួ ច័ន្ទដារី ចាន់ ប៊ុន្នី ឌៀប សុផល ស៊្រុន ប៊ុណ្ណារិទ្ធ៖ ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ឆ្នាំ២០១០ ទំព័រ១

មកបន្តិចនៅណាហ្កាសាគី (Nagasaki) បានធ្វើជនជាតិនៃប្រទេសនេះមិនចង់ឃើញសោកនាដកម្មរបៀបនេះកើតជាថ្មីទៀតឡើយ។ ករណីចុងក្រោយនេះ ជាទស្សនៈបុគ្គលប្រវត្តិវិទ្យាមិនប្រាកដជាធ្វើឲ្យមនុស្សទាំងអស់ពេញចិត្តគ្រប់រឿងរ៉ាវឡើយ ប្រសិនបើប្រវត្តិវិទ្យា ឬប្រវត្តិសាស្ត្រនោះ បាននិយាយពីរឿងរ៉ាវនៃគ្រួសារ ឬពូជសាសន៍អាក្រក់របស់ខ្លួននោះ។ គេតែងតែមិនចង់ឮ មិនចង់ស្តាប់នៃប្រវត្តិនានានោះជាដរាប។

យើងទាំងអស់គ្នាដែលរស់នៅសតវត្សទី២០ និងទី២១នេះ ជំពាក់គុណមនុស្សសម័យមុនយ៉ាងច្រើន ព្រោះមនុស្សទាំងនោះបានបង្កើតវត្ថុជាច្រើនទុកឱ្យយើងប្រើប្រាស់រហូតមកដល់សព្វថ្ងៃនេះ[7]។ នៅលើផ្ទាំងថ្មម៉ាបលើកខ្ពស់ផុតពីដីក្នុងបរិវេណវិទ្យាល័យ ហេង សំរិន ព្រៃល្វា ស្រុកព្រៃកប្បាស ខេត្តតាកែវបានរំលេចទាំងសងខាងនូវអក្សរពណ៌មាសលើថ្មម៉ាបពណ៌ខ្មៅម្ខាងមានខ្លឹមសារថា "**និយាយពីការរស់នៅក្នុងសម័យខ្មែរក្រហម គឺនិយាយពីការផ្សះផ្សា អប់រំកូនចៅឲ្យអត់ឱនអធ្យាស្រ័យគ្នា**" (Talking about experiences during the Khmer Rouge regime is to promote reconciliation and to educate children about forgiveness and tolorance)និងម្ខាងទៀតសរសេរថា "**រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺរៀនពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍**" (Learning about the

[7] ជ-ដ

history of Democratic Kampuchea is to prevent genocide[8] )។ ឃ្លាទាំងពីរខាងលើបានរំលឹកឲ្យខ្មែរជំនាន់ក្រោយចេះរស់នៅដោយការចេះអត់ឱនឲ្យគ្នា ចេះផ្សះផ្សាជម្លោះ និងចេះទប់ស្កាត់នូវអំពើឃោរឃៅយង់ឃ្នង់ក្នុងសង្គមជាតិកុំឲ្យកើតឡើងជាថ្មីម្តងទៀត ពោលគឺមិនបានប្រាប់យើងឲ្យចេះធ្វើការសងសឹកគ្នានោះទេ។ "...ថ្វីបើការរស់នៅយើងទាំងពីរនាក់មានមនោគមវិជ្ជា ការយល់ឃើញខុសគ្នាខ្លះក៏ពិតមែន យើងត្រូវគិតថា វាជាការយល់ឃើញបែបទស្សនៈប៉ុណ្ណោះចាំបាច់អ្វីទៅសម្លាប់គ្នាបង្កើតការឈឺចាប់ដល់មនុស្សជំនាន់ក្រោយធ្វើអ្វី? ថ្ងៃណាមួយសត្រូវរវាងយើងទាំងពីរអាចនឹងក្លាយជាមិត្តក៏ថាបាន ករណីកើតឡើងជាច្រើនពេលវេលាជាអ្នកដោះស្រាយ"។ ការចង់ឈ្នះ ចង់ចាញ់នឹងបង្កជាសង្គ្រាម ជាបក្ស ជាពួកឈ្លោះប្រកែក និងច្បាំងគ្នាយកត្រូវតែរៀងៗខ្លួនឥតឈប់ឈរ។

សូមអានប្រវត្តិសាស្ត្រខ្មែរចុងសម័យហ្វូណនបន្ថែម..ករណីព្រះបាទរុទ្រវរ្ម័ន ជាព្រះអនុជ និងព្រះបាទ គុណវរ្ម័ន ជាព្រះរៀម។ ជម្លោះរវាងក្សត្របង និងប្អូននេះ បានធ្វើឲ្យសម័យហ្វូណនរលំរលាយបាន។ ការសិក្សាប្រវត្តិសាស្ត្រ នាំឱ្យយើងក្តាប់បាននូវដំណាក់កាលនានា ដែលបុព្វបុរសយើងបានឆ្លងកាត់នូវប្រពៃណីជាតិដ៏ល្អនូវវប្បធម៌ជាតិដ៏ត្រចះត្រចង់និងដំណើរការវិវត្តនៃសង្គម ជាតិ និងពិភពលោករបស់យើងទាំងមូល។ ប្រវត្តិវិទ្យាជួយយើងឱ្យ

[8] មជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា វិទ្យាល័យ ហេង សំរិន ព្រៃល្វា ស្រុកព្រៃកប្បាស ខេត្តតាកែវ ឆ្នាំ២០១៧

ស្គាល់មិនត្រឹមតែអតីតកាលទេប៉ុន្តែឱ្យយើងស្គាល់បច្ចុប្បន្នកាលទៀតផង ព្រមទាំងបណ្តុះស្មារតីឱ្យយើងស្រឡាញ់ និងសាងមាតុភូមិនាពេលបច្ចុប្បន្ន ដើម្បីឱ្យសង្គមជាតិយើងស្គាល់ភាពរុងរឿងក្នុងអនាគតកាលផងដែរ។

**-ឯកសារនៃប្រវត្តិវិទ្យា**[9]

កេរដំណែល និងសក្ខីភាពស្តីពីអត្ថិភាព និងសកម្មភាពរបស់មនុស្ស ហៅថា*ឯកសារ*។ ឆ្អឹងមនុស្ស ឬសត្វ ឧបករណ៍ផ្សេងៗ សម្លៀកបំពាក់ វត្ថុសិល្បៈផ្សេងៗ អាវុធយុទ្ធភណ្ឌ អត្ថបទប្រវត្តិវិទ្យា។ គេចែកឯកសារទាំងនោះជាពីរផ្នែកគឺ***ឯកសារគ*** (Les documents muets/ The mute documents) និង**ឯកសារសរសេរ** "លាយលក្ខណ៍អក្សរ" (Ducuments écrits/ written documents)។

**១-ឯកសារគ** សំដៅលើឆ្អឹងមនុស្ស ឬសត្វ បំណែក ចាន ឆ្នាំង រូបគំនូរនានានៅតាមជញ្ជាំងថ្ម និងសំណល់គ្រាប់ធញ្ញជាតិផ្សេងៗ ឯកសារទាំងនេះផ្តល់ឱ្យយើងនូវព័ត៌មានមួយចំនួនស្តីពីអរិយធម៌របស់មនុស្សនឹងអាចនិយាយបានថា មនុស្សទាំងនោះមានមាឌ តូច ឬធំ មានការប៉ិនប្រសប់ ឬគ្មាន ជាសិល្បករ ឬមិនមែន គេបាញ់បានសត្វអ្វីខ្លះ និងយករុក្ខជាតិអ្វីខ្លះទៅធ្វើជាអាហារ?។ល។

**២-ឯកសារសរសេរ** ឯកសារជាលាយលក្ខណ៍អក្សរមានជាអាទិ៍៖

---

[9] ជូ ច័ន្ទដារី ចាន់ ប៊ុន្នី ឡៅ សុផល ស្រ៊ុន ប៊ុណ្ណារិទ្ធ៖ ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ឆ្នាំ២០១០ ទំព័រ១

សៀវភៅ ឬសិលាចារឹកដែលរៀបរាប់ អំពីហេតុការណ៍ផ្សេងៗក្នុងករណីដែល យើងអាចអានបាន។ យើងមិនអាចចងក្រងប្រវត្តិសាស្ត្របានពេញលេញទេ ប្រសិនបើពុំមានឯកសារសរសេរ[10]។ ការច្រងប្រវត្តិសាស្ត្រខ្មែរសម័យបុរាណ ប្រវត្តិវិទូ បុរាណវិទូបានពឹងផ្អែកលើឯកសារសរសេរដែលបានមកពីប្រភពផ្សេងៗដូចជា ក្រិច ឥណ្ឌា អារ៉ាប់ ចិន និងសិលាចារឹកដែល គេបានរកឃើញនៅក្នុងទឹកដីអតីតចក្រភពខ្មែរ។

លោក **ប៉ូល ប៉ែលីយូត៍** (Paul Pelliot) បានអានឯកសារនានាពីប្រភពចិន ហើយចាប់ពីឆ្នាំ១៩០២ មកមានការបកប្រែថ្មីមួយអំពី “ សារណាស្តីអំពីទំនៀមទម្លាប់នៅប្រទេសកម្ពុជា ” (Mémoires sur les coutumes du Cambodge) របស់លោក ជីវ តាក្វាន់។ ប្រសិនបើគិតមកដល់ឆ្នាំ២០២១ នេះរយៈពេលដែលលោកជីវតាក្វាន់បានមកធ្វើទស្សនកិច្ចនៅកម្ពុជាមានរយៈប្រហែល៧២៥ឆ្នាំមកហើយ។ សេចក្តីសង្កេតលើកំណត់ហេតុអំពីទឹកដី និងប្រពៃណីប្រទេសកម្ពុជា (真腊风土记) របស់លោក ជីវ តាក្វាន់ ដោយលោក អ៊ុក សុឡុង សមាជិកកិត្តិយសនៃសមាគមអ្នកប្រវត្តិសាស្ត្រកម្ពុជានៅប្រទេសស្វីស។ អត្ថបទសរសេរថានៅពេល លោកបានស្នាក់នៅទីក្រុងអង្គរនាចុងសតវត្សទី១៣(១២៩៦)នៃគ្រឹស្តសករាជលោក ជីវ តាក្វាន់ ដែលជាបញ្ញវន្តដ៏ហ្មត់ចត់ម្នាក់បានសរសេរកត់ត្រាដោយផ្ចិតផ្ចង់អំពីទឹកដី ពពួកសត្វរុក្ខជាតិ ព្រមទាំងប្រពៃណីនៃប្រទេសកម្ពុជា។ តមកគេបានចម្លងបោះពុម្ពឯក

[10] ឯ-ដ- ទំព័រ១

សាររបស់លោកហៅថា ហ្សេនឡា ហ្វេង ទុយជី (Zhenla feng tu ji) ជាច្រើន ដងរាប់រយឆ្នាំតាំងពីសតវត្សទី១៦មកម្ល៉េះ។ ប៉ុន្តែឯកសារនេះពុំមានគេដឹងឮ ច្រើនក្រៅពីប្រទេសចិនទេ សូម្បីតែខ្មែរយើងក៏ពុំបានដឹងដែរ។ អស់រយៈពេល បីសតវត្សកន្លងទៅទើបដល់សតវត្សទី១៩បានលោកវេជ្ជបណ្ឌិតបារាំង ជាអ្នក មានបច្ចេកទេសខាងភាសាចិនឈ្មោះ ហ្សង់ ព្យែរ រ៉េមុយហ្សាត (Jean Pierre Abel-Rémusat) បានយល់ថា ប្រទេសដែលចិនហៅថា **ចិនឡា** (ឯកសារ ដើម)ក្នុងឯកសារផ្សេងៗគឺជាប្រទេសកម្ពុជា។ លោកក៏បានបកប្រែអត្ថបទ ហ្សេនឡា ហ្វេងទុយជី (Zhenla feng tu ji) របស់លោក ជីវតាក្វាន់ទាំងមូល ទៅជាភាសាបារាំង ហើយបោះពុម្ពផ្សាយក្នុងឆ្នាំ១៨១៩។ ក្នុងឆ្នាំ១៩០២ អ្នកបច្ចេកទេស ខាងភាសាចិនម្នាក់ទៀត លោក ប៉ូល ប៉េលីយ៉ូត៍ (Paul Pelliot) ក៏បានបកប្រែឯកសារដូចគ្នានេះទៅភាសាបារាំងទៀត។ក្រោយមក លោក ប៉េលីយ៉ូត៍(Pelliot)បានកែប្រែអត្ថបទ បារាំងរបស់លោកដោយបន្ថែម កំណត់ពន្យល់ជាច្រើនទៀត។ប៉ុន្តែលោកមិនបានបង្ហើយអត្ថបទថ្មីនេះទេ ព្រោះ លោកបានទទួលមរណភាពក្នុងឆ្នាំ១៩៤៥។

លោក ហ្សក សឺដែស (Georges Coedès) និងលោក ប៉ូល ដឺម្យេវីល (Paul Demiéville) ក៏បានសរសេរកំណត់ពន្យល់បន្ថែមលើអត្ថបទដែល លោក ប៉េលីយ៉ូត៍ (Pelliot) ទុកចោលតាំងពីឆ្នាំ១៩២៤ហើយបានចាត់ការ បោះពុម្ពផ្សាយក្នុងឆ្នាំ១៩៥១។ ស្នាដៃចុងក្រោយរបស់លោក ប៉េលីយ៉ូត៍ (Pelliot)នេះត្រូវបានអ្នកប្រវត្តិសាស្ត្រខ្លះទៀតបកប្រែបន្តទៅភាសាអង់គ្លេស

និងអាល្លឺម៉ង់ជាដើម។ ឆ្នាំ១៩៦២លោក លី ធាមតេង បានទទួលបេសកកម្ម ខាងវប្បធម៌ដឹកនាំគណៈប្រតិភូអ្នកនិពន្ធខ្មែរទៅប្រទេសចិនហើយបានសុំ ចម្លងឯកសារ ហ្សេនឡា ហ្វេងទុយជី (Zhenla feng tu ji) ជាម៉ាយក្រូហ្វីម (micro film) ពីបណ្ណាល័យជាតិក្រុងប៉េកាំង។ ដោយលោកមិនអស់ចិត្តនឹង ការបកប្រែទៅភាសាបារាំងដែលលោកបានអានឯកសារលោក លី ធាមតេង ក៏ខំខ្នះខ្នែងបកប្រែពីអត្ថបទ ដែលលោកបានចម្លងពីប៉េកាំងទៅភាសាខ្មែរ ហើយបោះពុម្ពផ្សាយក្នុងឆ្នាំ១៩៧៣។ នៅពេលបានអានអត្ថបទបកប្រែទាំង អស់(ភាសាបារាំង អង់គ្លេស អាល្លឺម៉ង់)ខ្ញុំក៏មានមនោសញ្ចេតនាដូចលោក លី ធាមតេង ដែរ គឺមានការមិនពេញចិត្តក្នុងការបកប្រែ និងសេចក្ដីពន្យល់ច្រើន កន្លែង។ ឧទាហរណ៍ពាក្យ ហ្វ៊ូគុន (Fu cun 佛村) ដែលមានន័យថា **ភូមិព្រះ ពុទ្ធ** លោក សឺដែស (Coedès) បានកែពាក្យប្រែន័យដើមរបស់ ប៉ែលយ៉ូត៍ (Pelliot) ទៅជាក្រុង**ពោធិ៍សត្វ** ប៉ុន្តែក្រុង**ពោធិ៍សាត់** មិនត្រូវសរសេរជា **ពោធិ៍ សត្វ** ទេ ពីព្រោះក្រុង **ពោធិ៍សាត់** ក្លាយមកពីដើម **ពោធិ៍-រសាត់** ហើយគ្មាន ទាក់ទងអ្វីនឹងព្រះពុទ្ធទេ។ តាមយោបល់ខ្ញុំ ហ្វ៊ូគុន(Fu cun佛村)ប្រហែលជា ភូមិ**កំពង់ព្រះ**(មានន័យថាព្រះពុទ្ធ)នៅជិតភូមិឆ្នុកទ្រូតាមជាយទន្លេសាប។ ក្រុងពោធិ៍សាត់នៅចម្ងាយជាង២០គមពីទន្លេសាប ហើយលោក ជីវ តាក្វាន់ ធ្វើដំណើរតាមផ្លូវទឹកពុំអាចជួបប្រទះក្រុងពោធិ៍សាត់ឡើយ។

នេះគ្រាន់ជាឧទាហរណ៍មួយប៉ុណ្ណោះប៉ុន្តែនៅមានការភាន់ច្រឡំច្រើន កន្លែងទៀត។ ភរិយាខ្ញុំដែលជាបញ្ញវន្តចិនមានសញ្ញាបត្រពីសាកលវិទ្យាល័យ

ចិននិងសហរដ្ឋអាមេរិកក៏មានយោបល់ មិនពេញចិត្តដូចខ្ញុំដែរក្រោយពីបាន អានប្រៀបផ្ទឹមអត្ថបទភាសាអង់គ្លេស និងអត្ថបទដើមជាភាសាចិន។ ដោយ យើងខ្ញុំទាំងពីរនាក់មានជំនាញខាងជីវសាស្ត្រ ស្គាល់ពពួករុក្ខជាតិ និងពពួក សត្វផ្សេងៗច្បាស់លាស់ ហើយយើងជាជាតិចិន និងជាតិខ្មែរ យើងខ្ញុំយល់ថា ជាករណីយកិច្ចមួយដែលយើងត្រូវប្រែឯកសារលោក ជីវ តាក្វាន់ ទៅភាសា អង់គ្លេស និងភាសាខ្មែរ ដើម្បីជួយបំភ្លឺចំណុចមិនច្បាស់ផ្សេងៗដែលធ្វើឲ្យអ្នក អានយល់ច្រឡំអស់រយៈពេលជាងមួយសតវត្សមកហើយ។ យើងខ្ញុំចាប់ផ្ដើម ស្រាវជ្រាវរកប្រមូលឯកសារផ្សេងៗតាំងពីឆ្នាំ២០០១ ដោយមានបំណងថា នឹងបោះពុម្ពផ្សាយមុនគេបង្អស់នូវអត្ថបទបកប្រែចេញពីភាសាចិនដើម។ ប៉ុន្តែនៅពេលដែលយើងខ្ញុំកំពុងរៀបចំអត្ថបទសម្រេចដើម្បីបោះពុម្ព ស្រាប់ តែនៅឆ្នាំ២០០៧ មានសៀវភៅសរសេរជាភាសាអង់គ្លេសមួយបកប្រែពីឯក សារដើមជាភាសាចិនដោយលោក ភេធើ ហារីស(Peter Harris)។ ស្នាដៃបក ប្រែនេះរបស់លោក ភេធើ ហារីស (Peter Harris) ល្អប្រសើរ ហើយយើងខ្ញុំ សូមសរសើរដល់ការខ្នះខ្នែងរបស់លោកដោយរីករាយ។ យ៉ាងណាក៏យើងខ្ញុំ នៅតែមិនអស់ចិត្ត ហើយជឿជាក់ថា សៀវភៅបកប្រែរបស់យើងខ្ញុំដែលស្គាល់ ទំនៀមទម្លាប់ខ្មែរ និងចិនច្បាស់ យល់ន័យកន្លុកកន្លៀតរបស់ពាក្យផ្សេងៗ ស្គាល់ទឹកដីនិងបរិស្ថានប្រទេសកម្ពុជាគ្រប់គ្រាន់។ល។នឹងអាចជួយបំភ្លឺ បញ្ជាក់ដល់ចំណុចច្រើនទៀតដែលលោក ជីវ តាក្វាន់ បានកត់ទុក។ ខ្ញុំបាន កែប្រែបន្ថែមអត្ថបទខ្មែរសាជាថ្មី ហើយសៀវភៅបោះពុម្ពលើកទី២ ប្រហែល

នឹងបានចេញក្នុងខែមករាឆ្នាំ២០១៤ខាងមុខនេះ។ ខ្ញុំសង្ឃឹមថា ការប្រជុំពិភាក្សានេះនឹងអាចផ្តល់ព័ត៌មានថ្មីៗអំពីលោក ជីវ តាក្វាន់ និងហ្សេនឡាហ្វេងទុយជី(Zhenla feng tu ji) ហើយសូមជូនពរអង្គប្រជុំឲ្យបានសមិទ្ធផលយ៉ាងប្រសើរ។ **អ៊ុក សុឡុង** (ថ្ងៃ២៤ ខែធ្នូ ឆ្នាំ២០១៣) Rheinfelden, Switzerland។[11](ជីវ តាក្វាន់ ឬជីវ តាគួន) ដែលជាតារាងស្តីពីអរិយធម៌នៅចុងសម័យអង្គរ។ ទន្ទឹមនឹងនេះ អ្នកប្រាជ្ញដែលចេះភាសាសំស្ក្រឹត គឺលោក បាត និងប៊ែក ហ្គង (Barth et Bergaigne) បានចាប់ផ្តើមផ្សព្វផ្សាយ និងធ្វើការបកស្រាយសិលាចារឹកសំស្ក្រឹតនៅចម្ប៉ា និងកម្ពុជា។ ស្នាដៃលោក ហ្សក សឺដេស (George Coedès) ចាប់ផ្តើមនៅឆ្នាំ១៩០៤ និងបានបន្តឥតឈប់ឈរហូតមកដល់សព្វថ្ងៃ ដោយលោក ក្លូត ហ្សាក់ (Claude Jacques) នោះ អាចនឹងបង្កើតឯកសារដ៏អស្ចារ្យស្តីពីសិលាចារឹកនៃប្រទេសកម្ពុជា។ ប្រភពឥណ្ឌាក៏មានឯកសារសំខាន់ដល់ការបកស្រាយអរិយធម៌របស់ខ្មែរយើងដែរ។ តាមសេចក្តីអញ្ជើញរបស់លោក ហ្សក សឺដេស អ្នកប្រាជ្ញឥណ្ឌា

[11] នេះជាអត្ថបទរបស់លោក អ៊ុក សុឡុង សមាជិកកិត្តិយសនៃសមាគមអ្នកប្រវត្តិសាស្ត្រកម្ពុជានៅប្រទេសស្វីសនាថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ (Rheinfelden,Switzerland)ថ្លែងក្នុងសិក្ខាសាលារំលឹកខួប៧១៧ឆ្នាំនៃទស្សនកិច្ចរបស់លោក ជីវ តាក្វាន់ មកកាន់ចក្រភពខ្មែររៀបចំដោយសមាគមអ្នកប្រវត្តិសាស្ត្រកម្ពុជា និងវិទ្យាស្ថានអ៊ីនធីរេដ ថ្ងៃព្រហស្បតិ៍ទី២៦ ខែធ្នូ ឆ្នាំ២០១៣ កម្មវិធីពេលល្ងាច (ម៉ោង៦:៣០-៨:៣០)។ អ្នករៀបចំសិក្ខាសាលា៖ ឯកឧត្តមបណ្ឌិតសភាចារ្យ ស៊ន សំណាង អតីតប្រធានរាជបណ្ឌិត្យសភាកម្ពុជា និងប្រធានសមាគមអ្នកប្រវត្តិសាស្ត្រកម្ពុជា។

ដែលចេះភាសា សំស្ក្រឹតបានធ្វើការបកស្រាយឯកសារខ្មែរនៅក្នុងប្រទេស ឥណ្ឌាដូចជា លោក ភត្តចរិយ( K.Bhattacharya )បានស្រាវជ្រាវរកសាសនាព្រាហ្មណ៍នៅក្នុងប្រទេសកម្ពុជានាបុរាណសម័យជាដើម។

# ជំពូកទី១
# កំណើតនៃប្រទេសកម្ពុជា

## ១-ដើមកំណើតនគរភ្នំ ឬហ្វូណាន

### ក-តាមការចងចាំរបស់អ្នកស្រុក

យើញចំណងជើងនេះធ្វើឲ្យមានចម្ងល់មួយលេចឡើងភ្លាមថា សៀវភៅនេះនឹងរៀបរាប់អំពីប្រវត្តិភូមិសមរលាវ សមរខ្មែរ និងសមរចិន ទេ ចុះហេតុអ្វីក៏ចាំបាច់ទៅនិយាយបូរបាច់វែងឆ្ងាយអំពីដើមកំណើតប្រទេសកម្ពុជាទៅវិញ។ ចំពោះករណីនេះ យើងគ្រាន់តែសូមតភ្ជាប់បន្តិចរឿងរ៉ាវប្រវត្តិសាស្ត្រប្រទេសកម្ពុជាក្នុងក្របខណ្ឌនៃដើមកំណើតជាតិខ្មែរតែប៉ុណ្ណោះ។ មានប្រវត្តិវិទូភាគច្រើនយល់ស្របថា អង្គរបុរី ជាអតីតក្រុងវ្យាធបុរៈនៃទឹកដីខេត្តតាកែវបន្ទាប់ពីបាភ្នំនៃខេត្តព្រៃវែង ហើយភូមិសមរលាវ សមរខ្មែរ និងសមរចិន មានទីតាំងស្ថិតនៅក្នុងស្រុកព្រៃកប្បាសដែលជាស្រុកមួយនៃដើមកំណើតរបស់ប្រទេសកម្ពុជាដែរ។ កាលពីមុនមក អង្គរបុរី[12]គឺជាទឹកដីនៃនគរគោកធ្លកដែលស្ថិតនៅក្នុងភូមិសាស្ត្រស្រុកព្រៃកប្បាសដែរ។ដូច្នេះហើយបានជាវត្តមាននៃការធ្វើអត្ថាធិប្បាយអំពីដើមកំណើតរបស់ប្រទេសកម្ពុជា ជាផ្នែកមួយមិនអាចខ្វះបានសម្រាប់សៀវភៅនេះ។

---

[12] ឃុំនេះត្រូវបានប្រែក្លាយទៅជាស្រុកអង្គបុរីវិញតាមសេចក្តីសម្រេចលេខ១៧០សសរ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៨៨៤។

លោក សៅ ឈឿង[13]ជាអតីតគ្រូបង្រៀនសាលាបឋមសិក្សាសមរលោរស់នៅភូមិសមរខ្មែរ ឃុំពោធិរំចាក ស្រុកព្រៃកប្បាស ខេត្តតាកែវ បានមានប្រសាសន៍ថា តាមការពិពណ៌នារបស់លោកគ្រូម្នាក់ទៀតឈ្មោះ គីង វន្ថា ហៅ គីង ឡាំង រស់នៅភូមិអូរ ឃុំព្រៃកប្បាស ស្រុកព្រៃកប្បាស ខេត្តតាកែវ[14] និងអ្នកស្រុកនេះភាគច្រើនបានចងចាំ និងស្គាល់ថា ទឹកដីដែលពួកគេរស់នៅសព្វថ្ងៃនេះ ជាទីកន្លែងកំណើតរបស់ប្រទេសខ្មែរទាំងមូល។ លោកបានរៀបរាប់ថា កាលពីអតីតកាលទីតាំងប្រទេសកម្ពុជាលាតសន្ធឹងរហូតដល់ដែនដីកូសាំងស៊ីន(វៀតណាមខាងត្បូង)នោះ ហើយជាផ្ទៃសមុទ្រទាំងអស់[15]។ សម័យកាលនោះ មានកោះជាច្រើនដុះរកេតរកូតនៅក្នុងមហាសមុទ្រធំល្វឹងល្វើយ ដូចជាវត្តមានភ្នំទាំងឡាយនៅលើផែនដីនេះអញ្ចឹងដែរ។ ចលនាលំហូរសាគរនៃទន្លេមេគង្គបានហូរនាំដីល្បាប់មកចាក់បំពេញបន្តិចម្តងៗរហូតកើតបានជាដីកោះមួយយ៉ាងធំ ហើយមានដុះដើមធ្លក[16]នៅលើកោះនោះផងដែរទើបគេ

[13] លោកជាគ្រូបង្រៀនរបស់អ្នកនិពន្ធផ្ទាល់កាលពីឆ្នាំ១៩៨១-១៩៨២។ នៅពេលបង្រៀន លោកតែងតែចាប់ដៃសិស្សឲ្យចេះសរសេរតួអក្សរខ្មែរនឹងដីសធ្វើពីដីឥដ្ឋ និងចេះនិយាយកំប្លុកកំប្លែងឲ្យសិស្សចូលចិត្ត និងឆាប់ចងចាំអក្សរ និងលេខនិព្វន្ត។

[14] ភូមិអូរសព្វថ្ងៃមានទីតាំងនៅខាងត្បូងភូមិសមរខ្មែរមួយភូមិ។

[15] តាមពិតមិនមែនជាប់ត្រឹមនេះទេ ទឹកដីខ្មែរសម័យបុរាណខាងលិចចាប់នឹងប្រទេសភូមាបច្ចុប្បន្ន។

[16] កាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៦ លោកបណ្ឌិត សេង ប៊ុនធឿន សាកលវិទ្យាធិការរងបានដឹកនាំនិស្សិត និងអតីតនិស្សិតរបស់លោកនៃសាកលវិទ្យាល័យជាតិគ្រប់គ្រងរួមទាំងលោកជំទាវឧកញ៉ា អៀង គិមហុង និងមិត្តភក្ត្រពីរបីនាក់ទៀតសរុបចំនួន២៧០នាក់ទៅដាំដើមឈើនៅវិទ្យាល័យហ៊ុន សែន អង្គរបុរីចំនួន៦៥០ដើម។ក្នុងឱកាសនោះលោកបណ្ឌិតក៏បាននាំយកដើមធ្លកមួយដើមទៅដាំនៅក្នុងបរិវេណវិទ្យាល័យនេះផងដែរ។

ប្រសិទ្ធនាមកោះនោះថា កោះគោកធ្លក[17] ជារៀងរហូតមក។ បច្ចុប្បន្នទីតាំងនេះស្ថិតនៅក្នុងស្រុកអង្គរបុរី[18]ខេត្តតាកែវដែលកំពែងរាជធានីបុរាណនេះមានបរិមាត្រប្រមាណ៦.៤គម ទទឹងខ្នងទំនប់ប្រវែង៤ម នៅព័ទ្ធជុំវិញភូមិដ្ឋានបុរាណ ដែលបច្ចុប្បន្នមានភូមិចំនួនបីនៅខាងក្នុង គឺភូមិកំពង់ហ្លួង ឃុំអង្គរបុរី ភូមិអង្គរ និងភូមិកំពង់ពោធិ៍ ឃុំព្រៃកផ្ទោល ហើយនៅជាប់កំផែងប៉ែកខាងលិច ភូមិស្ទឹងកំបុត ជាប់ប៉ែកខាងជើង ភូមិសាមគ្គី ឃុំអង្គរបុរី[19]។ ចំណែកភូមិសាស្ត្រ មួយទៀតឈ្មោះ ទេពបាទេព (ភ្នំបា (ឃុំព្រៃកផ្ទោល ដែលស្ថិតនៅខាងក្រៅកំពែងទិសអាគ្នេយ៍ក៏ជាទីស្ថានឧបសម្ព័ន្ធប្រកបដោយស្លាកស្នាមបូជនីយដ្ឋានប្រវត្តិសាស្ត្រដ៏សំខាន់មួយដែរ[20]។ លោក សៅ ឈឿង បានរៀបរាប់ទៀតថា ចំណេរចីរកាលតមកកោះគោកធ្លកនេះចេះតែដុះធំឡើងៗ ហើយមានពួកមនុស្សនាំគ្នាមកតាំងទីលំនៅជាក្រុម ជាពួកផ្សេងៗគ្នា ប៉ុន្តែមិនចុះចូលរស់នៅលាយឡំគ្នាទេ ហើយមនុស្សទាំងអស់នោះគ្មានសម្លៀកបំពាក់នៅខ្លួនទេ ពីព្រោះមនុស្សជំនាន់នោះមិនទាន់ចេះត្បាញក្រណាត់ និងចេះដេរសម្លៀកបំពាក់នៅឡើយ។ នៅនឹងខ្លួនមនុស្សប្រុសសុទ្ធតែមានចាក់សាក់

---

[17] នៅខេត្តតាកែវទាំងមូលសម្បូរពាក្យ **គោក** ពាក្យ **ទួល** និងពាក្យ **អង្គ** ច្រើនកន្លែង ដូចជា គោក ក ញ្ចាប គោកអង្គង់ គោកពោធិ៍ ទួលសាំង អង្គ សង្កែ អង្គតាសោម។ល។

[18] ដូចបានជម្រាបហើយ ភូមិសាស្ត្រនេះ ជាអតីតទឹកដី នៃស្រុកព្រៃកប្បាស ខេត្តតាកែវ ហើយបំបែកទៅជាស្រុកអង្គរបុរីមួយទៀតនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៨៨៤។

[19] កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១នេះ លោកបណ្ឌិត សេង ប៊ុនធឿន សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យជាតិគ្រប់គ្រង និងភរិយាបានកសាងព្រះរូបព្រះបាទ ជ័យវរ្ម័នទី៧ មួយព្រះអង្គទៅតម្កល់ទុកជាប្រយោជន៍សាធារណៈនៅក្នុងបរិវេណនៃសារមន្ទីរអង្គរបុរីនេះ។

[20] ប្រភពព័ត៌មាន៖ លោក ទី សុផល គ្រូបង្រៀនប្រវត្តិវិទ្យានៅវិទ្យាស្ថានជាតិអប់រំ។ លោកជាអ្នកមានស្រុកកំណើតនៅស្រុកអង្គរបុរីនេះ។

(មន្តអាគមគាថា)។ ទាក់ទងនឹងលំនៅដ្ឋាន ពួកគេចេះសង់ខ្ទមនៅលើដីគោក ឬរស់ នៅក្នុងរូងភ្នំជាដើម។ មុខរបររកស៊ីរបស់ពួកមនុស្សសម័យនោះចេះបរបាញ់សត្វ ខ្លះរស់នៅមាត់ទឹកខ្លះប្រកបរបរនេសាទ។ កោះគោកធ្លក នេះ ស្ថិតនៅកណ្តាល សមុទ្ធធំល្វឹងល្វើយ មានទឹកព័ទ្ធជុំវិញប្រៀបដូចជាភ្នំ។ អ្នកស្រុកដាក់ឈ្មោះឲ្យទឹកដីនេះជាថ្មីទៀតថា នគរភ្នំ ឬទឹកដីភ្នំ។ កាលនោះមានអ្នកចំណូលស្រុកពីចាម ជ្វា បានមករស់នៅខ្លះៗនាតំបន់នេះដែរ ជាពិសេស ពួកជនជាតិចិនដែល ភាគច្រើនជាអ្នកទេសចរនិងជួញដូរបានមកដល់កោះគោកធ្លកនេះតាមសំពៅ ឬទូកជាមធ្យោបាយ ហើយហៅតំបន់ភ្នំនេះតាមអ្នកស្រុកថា នគរភ្នំ។




(រូបទី១)



ជីវភាពរស់នៅ និងឧបករណ៍ប្រើប្រាស់របស់មនុស្សក្នុងកាលសម័យបុរេប្រវត្តិ(រូបទី២)

## ខ-តាមឯកសារប្រវត្តិសាស្ត្រ

តាមប្រភពព័ត៌មានប្រវត្តិសាស្ត្ររបស់ចិនបាននិយាយថា ប្រទេសហ្វូ-ណាន[21] (FUNAN) សំដៅទៅលើអាណាចក្រភ្នំ គឺជារដ្ឋចំណាស់មួយនៅក្នុងឥណ្ឌូចិនដែលព័ត៌មាននេះត្រូវបានផ្តល់ឱ្យដោយជនជាតិចិនដែលបានធ្វើដំណើរមកដល់នគរភ្នំនៅរវាងដើមសតវត្សរ៍ទី៣នៃគ.ស.។

តាមលោក ប៉ូល ប៉េលីយ៉ូត៍ (Paul Pelliot)បាននិយាយថា អាណាចក្រភ្នំនេះត្រូវបានចាប់កំណើតឡើងនៅសតវត្សរ៍ទី១នៃគ.ស(ឆ្នាំ៥០)។ តាមកំណត់ត្រារាជវង្សចិននៅដើមសតវត្សរ៍ទី៣នៃគ.សមានអ្នកការទូតចិនបានធ្វើដំណើរមកដល់ទឹកដីនៃរដ្ឋនគរភ្នំ ដើម្បីធ្វើការផ្សព្វផ្សាយនូវអរិយធម៌ចិននៅលើទឹកដីអាស៊ីអាគ្នេយ៍ ហើយពេលជាមួយគ្នានេះ រដ្ឋនគរភ្នំក៏បានចាត់បញ្ជូនអ្នកការទូតទៅកាន់ប្រទេសចិនវិញផងដែរ[22]។ ទាំងអ្នកប្រវត្តិសាស្ត្រចិន និងអ្នកធ្វើដំណើរជនជាតិចិនដែលបានធ្វើការវិភាគនិងវែកញែកទៅលើព្រឹត្តិការណ៍នានានៃប្រទេសហ្វូណានរហូតមកដល់ដើមសតវត្សរ៍ទី៧បានបង្ហាញឱ្យដឹងថាប្រទេសហ្វូណានមានរដ្ឋជាចំណុះផ្សេងៗ ហើយក្នុងចំណោមរដ្ឋចំណុះទាំងនោះមានរដ្ឋដ៏សំខាន់ធំមួយ គឺរដ្ឋចេនឡា[23]។

---

[21] ឯកសារខ្លះហៅថា ហ្វូណាន ជាឈ្មោះសម័យកាលមួយដែលអ្នកប្រវត្តិវិទូចាប់រាប់ពីសតវត្សរ៍ទី១ដល់ទី៦ ប្រហែលជាឆ្នាំ៥២ ដល់ឆ្នាំ៥៥០នៃគ្រឹស្តសករាជ។

[22] ទំនាក់ទំនងរវាងខ្មែរ និងចិន អក្សរសិល្ប៍ខ្មែរក៏មាននិយាយផងដែរតាមរយៈរឿងធនញ្ជ័យដ៏ល្បីល្បាញ។

[23] ដួង ច័ន្ទដារី ចាន់ ប៊ុន្នី ឡៅប សុផល ស្រ៊ុន ប៊ុណ្ណារិទ្ធ៖ ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ឆ្នាំ២០១០ ទំព័រ២១

## គ-អំពីទីតាំងភូមិសាស្ត្រ

តើរដ្ឋខ្មែរដំបូងបង្អស់ដែលហៅថា ហ្វូណន ឬហ្វូណាននេះ បានកើតឡើងដោយស្ថានភាព ដូចម្ដេចកាលនៅដើមសតវត្សរ៍ទី១នៃគ.ស? តើខ្មែរបានទទួលឥទ្ធិពលអ្វីខ្លះពីឥណ្ឌាដែលអរិយធម៌ប្រទេសក្នុងអតីតកាលមានការរីកចម្រើនលូតលាស់រហូតដល់សម័យក្រោយៗ?តាំងពីមុនគ.ស ជនជាតិខ្មែរជាជនជាតិមួយដែលមានពូជអម្បូរជាមួយនឹងជនជាតិមនមានវប្បធម៌អារ្យធម៌របស់ខ្លួននាសម័យមុនក្លឹង(ឥណ្ឌា)ចូលមកដល់ទឹកដីនៃរដ្ឋនគរភ្នំគឺតាំងពីមុនពេលដែលរដ្ឋនគរភ្នំកើតឡើងម្ល៉េះ។

ដំបូងជនជាតិខ្មែរ-មន-គួយ-ព័រ-ស្អូច-ស្ទៀង-ខា-ព្នង-កាចក់-សំរ៉ែ-គ្រឹង-ម្រុំ។ល។ ដែលរស់នៅតាមតំបន់ព្រៃភ្នំក៏មិនទាន់បានទទួលនូវឥទ្ធិពលវប្បធម៌-អារ្យធម៌ពីឥណ្ឌានៅឡើយដែរ។ ទាក់ទងនឹងជនជាតិមន ខ្មែរ និងចាម លោកសសារុនបានសរសេរថាមន ចាម និងខ្មែរជាតិ ទាំងបីនេះសុទ្ធតែជាអ្នក ពូកែអួត។ មនអួតខ្លាំងជាងគេ **យកមេឃទ្រាប់អង្គុយ**។ បន្ទាប់មកចាម អួតថា **មួយចង្អាមដល់មេឃ**។ ជនជាតិពីរដំបូងសុទ្ធតែអស់ទឹកដីដូចគ្នា។រីឯខ្មែរ អួតតិចជាងគេ **កប់ពពកមកជ្រកអាចម៍ជន្លេន**។ហាមាត់និយាយទៅដល់ជិត មេឃដែរ ប៉ុន្តែប្រហែលដឹងខ្លួនទាន់ ថាដូចជាអួតពេក ទើបរត់មកជ្រកអាចម៍ជន្លេនវិញ។ មនរស់នៅជា មួយមន មិនដឹងថាអួតទេ ពីព្រោះមានផ្នត់គំនិតអួតដូចគ្នា។ ដូចគ្នាដែរចាមនិងចាម ខ្មែរនិងខ្មែរ។ ប៉ុន្តែទាំងបីសាសន៍នេះ រស់ នៅជាមួយគ្នាទើបចាម និងខ្មែរដឹងថា មន អួត ហើយ ខ្មែរដឹងថា ចាមអួត[24]។ សាកល្បងនាំគ្នាឆ្លុះបញ្ចាំងមើល តើការលើកឡើងនេះ

[24] ស សារុន៖ សាកល្បងសិក្សាអំពីសង្គមវិជ្ជាខ្មែរ ឆ្នាំ១៩៧៣ ទំព័រ៥១-៥២។

ខុសឬត្រូវ? តាមការ សិក្សាស្រាវជ្រាវរបស់លោក ហ្សក សឺដេស (George Coedèse) ជាអ្នកប្រាជ្ញដ៏ល្បីល្បាញខាងប្រវត្តិសាស្ត្រ និងអរិយធម៌ខ្មែរមានទស្សនៈថា ការហូរចូលនៃវប្បធម៌-អារ្យធម៌ក្លឹងនៅតំបន់ឥណ្ឌូចិននេះ បានបណ្តាលឱ្យកើតមានរដ្ឋជាច្រើន ជាពិសេស រដ្ឋខ្មែរនៅក្នុងភូមិភាគនេះ។ នៅពេលមានវត្តមាននៃពួកក្លឹង និងការធ្វើជំនួញជាមួយនឹងខ្មែរនេះហើយ ពួកគេបានសាបព្រោះ និងផ្សព្វផ្សាយនូវវប្បធម៌-អារ្យធម៌របស់ពួកគេមកលើជនជាតិខ្មែរជាហេតុធ្វើឱ្យសង្គមខ្មែរទទួលនូវសន្ទុះនៃវប្បធម៌-អារ្យធម៌ថ្មីមួយ គឺការខ្ចីនូវផ្នែកវប្បធម៌-អារ្យធម៌នានាខ្លះដែលខ្មែរខ្វះដើម្បីយកមកបំពេញរដ្ឋមួយឱ្យមានលក្ខណៈពេញលេញមានដូចជា របបនយោបាយ ការរៀបចំសង្គម សេដ្ឋកិច្ច យោធា និងរួមទាំងខាងផ្នែកសាសនា ជាដើម។ ដោយសារការទទួលនូវឥទ្ធិពលទាំងនេះហើយ ដែលជាមូលដ្ឋាននៃកំណើតរដ្ឋខ្មែរដំបូង។ ក្នុងការបង្កើតរដ្ឋនេះ អ្នកដឹកនាំខ្មែរនាដើមសតវត្សរ៍ទី១នៃគ.ស.ត្រូវការនូវមនោគមវិជ្ជាមួយគឺមនោគមវិជ្ជារាជានិយមដែលមានស្តេចចក្រវាទ្បសម្រាប់ជាការបង្រួបបង្រួមសង្គមតូចៗឱ្យក្លាយទៅជាចក្រភពមួយដែលមានព្រះរាជាដឹកនាំនគរ ហើយបានធ្វើឱ្យមានការលេចចេញជារដ្ឋមួយច្បាស់លាស់ឡើង។ ពាក្យថា ហ្វូណនដែលជាឈ្មោះអាណាចក្របុរាណនេះត្រូវបាត់បង់នៅក្នុងអំឡុងសតវត្សរ៍ទី៧ ហើយគេមិនបានដឹងច្បាស់ថា តើទីតាំងនៃអាណាចក្រភ្នំនេះស្ថិតនៅកន្លែងណាពិតប្រាកដ។

លោកកៅជូហ្កា (Cau Ju-Kua) បានសរសេរនៅដើមសតវត្សរ៍ទី១៣ ដោយពណ៌នាអំពីឈ្មោះ ចេនឡា ដែលមានអត្ថន័យត្រូវនឹងពាក្យថា កម្ពុជ។ ប៉ុន្តែគាត់ពុំបានដឹងអំពីន័យនៃពាក្យហ្វូណននេះទេ។ ចំពោះទីតាំងនៃនគរភ្នំមានទស្សនៈខ្វែងគ្នាច្រើនអំពីបញ្ហានេះ។




ផែនទីបង្ហាញទីតាំងនៃរដ្ឋនគរភ្នំសតវត្សរ៍ទី១ដល់ទី៧(រូបទី៣)

លោកម៉ាទួនលីន(MaDuanlinឬ Ma Tuanlin) ជាអ្នកប្រវត្តិសាស្ត្រជនជាតិចិនបានសរសេររៀបរាប់អំពីរដ្ឋហ្វូណាននៅអំឡុងសតវត្សទី១៣។

លោកនិយាយថា ហ្វូណាន គឺជាកោះមួយដែលមានចម្ងាយប្រហែល ៣០០០លី[25]នៅភាគអាគ្នេយ៍ពីនគរលីនយី(Linyi)ជានគរមួយនៅភាគខាងត្បូងប្រទេសចិន(នគរចម្ប៉ា)។ នៅសតវត្សទី១៩ពួកអឺរ៉ុបបានចាប់ផ្តើមធ្វើ

---

[25] ១លី=៥៧៦ម

ការសិក្សាអំពីហ្វូណននេះតាមរយៈឯកសារប្រវត្តិសាស្ត្រនៅប្រទេសចិន ដោយបានធ្វើការសន្និដ្ឋានថាហ្វូណនជាតំបន់មួយនៅតាមឆ្នេរតុងកឹង និង លាតសន្ធឹងទៅដល់ភូមា។

ចំណែកទស្សនៈរបស់លោក អេជៀង អៃម៉ូញេ (Étienne François Aymonier)ជនជាតិបារាំងបានសរសេរសៀវភៅនៅឆ្នាំ១៩០០ឲ្យដឹងថា ប្រទេសហ្វូណនមានទីតាំងចាប់ពីតំបន់តុងកឹងចុះមកភាគខាងត្បូងទៅដល់ ប្រទេសសៀមបច្ចុប្បន្ន[26]។ រីឯលោក ប៉ូល ប៉េលីយ៉ូត៍ ដែលបានធ្វើការសិក្សា តាមរយៈឯកសារចិនដែរ លោកបាននិយាយនៅឆ្នាំ១៩០៣ថា ហ្វូណនស្ថិត នៅតាមតំបន់ភាគខាងលើដងទន្លេមេគង្គរហូតមកដល់កូសាំងស៊ីននិងជា ផ្នែកនៃប្រទេសកម្ពុជា និងទៅដល់ឈូងសមុទ្រម៉ារតាបាន់(Matalabann) នៅភាគខាងលិចនៃឧបទ្វីបម៉ាឡាយូ។ យើងបានដឹងរួចមកហើយថា ហ្វូណន គឺជាឈ្មោះមួយដែលត្រូវបានកំណត់ហៅដោយចិន ហើយដែលពាក្យ នេះ ចិនហៅសម្រាប់សម្គាល់ចំពោះដើមកំណើតជាតិខ្មែរ។ លោក អេជៀង អៃម៉ូញេ (Étienne François Aymonier) បានធ្វើការសិក្សា និងគិត ពិចារណាអំពីពាក្យហ្វូណន បានរកឃើញថា ជាឈ្មោះមួយដែលចិនបាន កំណត់មែន។ លោក អ. ហ្សេរីនី (R.zerini) ជាអ្នកប្រាជ្ញជនជាតិអ៊ីតាលីបាន និយាយដែរថា ហ្វូណន គឺជាការកំណត់របស់ចិនសម្គាល់ថា ជាខ្មែរដែលមាន ទីតាំងនៅតំបន់បាណាម(ភ្នំ)មានន័យថាភ្នំ។ ក្រោយមកលោក លូី ហ្វីណូត (Lui Phinote) ជាអ្នកប្រាជ្ញបារាំងខាងសិលាចារឹកជានាយកសាលាបារាំង

[26] ដូ ច័ន្ទដារី ចាន់ ប៊ុន្នី ឡៅ សុផល ស្រ៊ុន ប៊ុណ្ណារិទ្ធ៖ ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ឆ្នាំ២០១០ ទំព័រ ២៣

ចុងបូព៌ាប្រទេស[27]បានបញ្ជាក់ថាហ្វូណានគឺជាកាកំណត់របស់ចិនសម្រាប់តំបន់មួយនៅឥណ្ឌូ- ចិន។ លោក ល្វី ហ្វីណូត (Lui Finote) ក៏មានយោបល់ដែរថា នគរភ្នំជារាជធានី ឬជាអាណាចក្រហើយដែលក្រោយមកត្រូវបានហៅថាអាណាចក្រភ្នំ[28]។ លោក ហ្សក សឺដេស (George Coedèse) ជាអ្នកប្រាជ្ញខាងសិលាចារឹក ជនជាតិបារាំងដែរ លោកធ្លាប់ធ្វើជានាយកសាលាបារាំងចុងបូព៌ាដែរនៅឆ្នាំ១៩៤៣ លោកបានពន្យល់ និងធ្វើសេចក្តីសន្និដ្ឋានថា បាភ្នំ[29] ជារាជធានីបុរាណរបស់នគរភ្នំមានឈ្មោះថា វ្យាធបុរៈ ដែលពាក្យ នេះសំដៅទៅលើភ្នំ (តំបន់ភ្នំ) ហើយត្រូវបានចិនហៅថា ហ្វូណាន។ ប៉ុន្តែ បើតាមអ្នកសិក្សាស្រាវ ជ្រាវក្រោយៗមកបានញ្ជាក់អះអាងថារាជធានីនគរភ្នំ គឺឋិតនៅឯស្រុកអង្គរបុរី[30] ខេត្តតាកែវឯនោះទៅវិញទេ[31]។ នេះជាអំណះអំណាងដែលសមហេតុផល ពីព្រោះនៅទីនេះមានដានប្រវត្តិសាស្ត្រជា

---

[27] កាលពីសម័យអាណានិគមបារាំងនៅឥណ្ឌូចិន បារាំងគេបានបង្កើតសាលាមួយសម្រាប់កូនចៅគេបានសិក្សារៀនសូត្រនៅអំឡុងពេលពួកគេមកបំពេញបេសកកម្មរយៈយូរនៅតំបន់ឥណ្ឌូចិននេះ។ សាលានេះមានទីតាំងនៅប្រទេសវៀតណាមភាគខាងត្បូង គេហៅជាភាសាបារាំងថា École française d' Extrême-Orient (EFEO)

[28] ជូ ច័ន្ទដារី ចាន់ ប៊ុន្នី ឡៅ សុផល ស៊្រុន ប៊ុណ្ណារិទ្ធ៖ ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ឆ្នាំ២០១០ ទំព័រ ២៣

[29] សព្វថ្ងៃជាស្រុកមួយរបស់ខេត្តព្រៃវែង ភាគខាងកើតឆៀងខាងជើងនៃស្ពានអ្នកលឿង។

[30] សូមសរសេរ និងអានថា អង្គរបុរី មិនមែនអង្គរបូរីទេ។ បច្ចុប្បន្ននេះតាមការសង្កេត មន្ត្រីមូលដ្ឋានមានការធ្វេសប្រហែសច្រើន មិនសូវចាប់អារម្មណ៍ដល់ការសរសេរឈ្មោះ ភូមិ ឃុំ ឬ ស្រុក ឲ្យបានត្រឹមត្រូវទេ។ ឧទាហរណ៍ អង្គរបុរី ទៅជា អង្គរបូរី ។ ប្រាសាទសម្បូរព្រៃគុហ៍ ទៅជា សម្បូរព្រៃគុក។ ភូមិសមរលាវ ទៅជា សម៉លាវ។ សមរខ្មែរ ទៅជា សម៉ខ្មែរ ។ល។

[31] ជូ ច័ន្ទដារី ចាន់ ប៊ុន្នី ឡៅ សុផល ស៊្រុន ប៊ុណ្ណារិទ្ធ៖ ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ឆ្នាំ២០១០ ទំព័រ ២៤

ច្រើនបន្សល់ទុកដល់សព្វថ្ងៃ។ តាមអ្នកប្រវត្តិសាស្ត្រចិនថាការគ្រាប់តាមខ្មែរមិនច្បាស់ពាក្យ ភ្នំ ទៅហ្វូណន រួចហើយក៏ក្លាយទៅជា ហ្វូណន ឬហ្វូណាន។ ដោយសារជនជាតិចិនត្រូវបានអ្នកស្រុកចាត់ទុកថា ជាអ្នកឆ្លាត ពូកែរកស៊ីជួញដូរក្លាយជាអ្នកមានលុយមានកាក់ច្រើន។ តាមប្រសាសន៍របស់ ឯកឧត្តមបណ្ឌិតសភាចារ្យ ស៊ន សំណាង ប្រធានសមាគមអ្នកប្រវត្តិសាស្ត្រកម្ពុជាកាលពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៦ ក្នុងបទសម្ភាសន៍ជាមួយលោក គី សុខលីម អគ្គនាយកសារព័ត៌មាន (គេហទំព័រ) ថ្មីៗ(ThmeyThmey) បានបញ្ជាក់ថា ជនជាតិចិនដែលមករស់នៅស្រុកខ្មែរឆ្លាតគឺជាការពិត ពីព្រោះជនជាតិចិនដែលធ្លាប់រស់នៅស្រុកទេសគាត់មានការលំបាកច្រើនជាងជនជាតិខ្មែរ[32]។ អ្នកលំបាកហ្នឹងហើយដែលខំប្រឹងកែច្នៃជីវភាពផ្ទាល់ខ្លួនឲ្យសម្បូរឡើងដែលមិនមានអំណោយផលពីធម្មជាតិទេ។ រីឯខ្មែរយើងពីមុនមក វាមាន អំណោយផលពីធម្មជាតិ។ ដីនៅមាត់ទន្លេហ្នឹងសម្បូរមានជីជាតិណាស់ ម្ល៉ោះហើយបារាំងគេសរសេរថា ជាជនជាតិខ្មែរមានទំយើពីធម្មជាតិ ដល់តែទំយើពេកទៅឲ្យមិនមានការខិតខំទេ ហើយដល់ចិនមិនមានទំយើពីធម្មជាតិទេ[33]។ ជនជាតិចិនចូលចិត្តរស់នៅទីកន្លែងណាសម្បូរទឹកដោះគោ និងទឹកឃ្មុំ។ ដូចជា

---

[32] ឯកឧត្តមបណ្ឌិត្យសភាចារ្យ ស៊ន សំណាង ប្រធានសមាគមអ្នកប្រវត្តិសាស្ត្រកម្ពុជាកាលពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៦ ក្នុងបទសម្ភាសន៍ជាមួយលោក គី សុខលីម អគ្គនាយកសាព័ត៌មាន (គេហទំព័រ) ថ្មីថ្មី(Thmey Thmey)។

[33]យើងឯកភាពថា ជនជាតិណាក៏ដោយ ជាសត្វានុម័តឲ្យតែធ្វើចំណាកស្រុកតែងតែខិតខំរកស៊ីជាងអ្នកម្ចាស់ស្រុក។ ឧទាហរណ៍៖ ជនជាតិវៀតណាមក៏មិនខុសពីចិនដែរ ពួកគេតែងតែខិតខំរកស៊ី ឬធ្វើការជាងខ្មែរម្ចាស់ស្រុកខ្លះផងដោយមិនរើសអើងមុខរបរ ឬចេះស្រវាស្រទេញធ្វើខ្លួនឲ្យមាននីត្យានុកូលជាដើម។ អ្នកមានស្រូវក្នុងជង្រុកមិនសូវភ័យព្រួយពីរឿងអត់ស្រូវដូចអ្នកដែលគ្មានស្រូវទេ។ មិនខុសគ្នាទេ ខ្មែរដែលរស់នៅក្នុងខេត្តកំណើតមិនសូវស្រវាស្រទិញរកស៊ីដូចខ្មែរចំណាកស្រុកទេ។

មាត់ទន្លេ(មាត់ទន្លេដីមានជីជាតិអាចបង្កបង្កើនផលបានផលច្រើន)។ ក្រុមចិនទាំងនេះបានចាប់ផ្ដើមរហូតក្លាយជាមានឥទ្ធិពលលើអ្នកស្រុកដើមដោយអន្លើ នាំឲ្យអ្នកស្រុកទាំងនេះលួចធ្វើត្រាប់សំឡេងចិនថា ហ្វូណនៗ ឬហ្វូណានរហូតមក។ ចំណេរក្រោយមក គេនាំគ្នាឈប់ហៅថា នគរភ្នំ បែរជានាំគ្នាស្គាល់ និងហៅថា ហ្វូណន ហើយត្រូវបានអ្នកសិក្សាកត់ត្រា និងស្គាល់ជារៀងរហូតថា ហ្វូណន ជាផ្លូវការមកដល់សព្វថ្ងៃនេះ។ លោកសាស្ត្រាចារ្យ បណ្ឌិត វ៉ង់ សុធារ៉ា (Prof. VONG Sotheara) ពាក្យថា Funan/Fou-nan 扶南 ហ្វូណនមិនគួរមកពីពាក្យចិនត្រាប់តាមខ្មែរថា វ្នំ ឬ ភ្នំ ដូចលោក ហ្សក សឺដេស ធ្លាប់ស្មាននោះទេ គឺវាមកពីពាក្យថាខ្មែរនៅទិសភាគខាងត្បូង ពាក្យចិនមានន័យថា ណាន 南។ ចំណែកពាក្យ ហ្វូ Fu 扶 ទំនងជាមកពីមានអ្នកកែអក្ខរាវិរុទ្ធ[34] ហ្វូ Fu 富ដែលមានន័យថា មហាសាល ឬអ្នកមានទ្រព្យច្រើន។ ពីព្រោះចិនតាំងពីដើមមកយល់ថាខ្មែរ ជាអ្នកមានភោគទ្រព្យច្រើន ហើយយួនក៏យល់ ដូច្នេះដែរ ទើបហៅខ្មែរថា កៅមៀនរហូតមក។ ដូច្នេះ តាមលោកបណ្ឌិត វ៉ង់ សុធារ៉ា ហ្វូ មានន័យថា អ្នកមាន រីឯ ណា ឬណាន មានន័យថាខាងត្បូង ដូច្នេះពាក្យ Fou-nan ហ្វូណានដើម គួរមានន័យថា អ្នកមាននៅភាគខាងត្បូង (Rich South)[35]។ ប្រជារាស្ត្រហ្វូណន ជាជនជាតិខេមរៈ ឬខ្មែរ។ ចិន-ខ្មែរដែលក្រោយមកចេះរស់នៅជាមួយគ្នានោះបានកោះប្រជុំគ្នា

[34] មូលហេតុដ៏សំខាន់មួយដែលនាំឲ្យសៀវភៅនេះលេចជារូបរាងឡើងគឺជាការតវ៉ាបែបប្រវត្តិសាស្ត្រ ដោយសារមានការសរសេរឈ្មោះភូមិសមរខ្មែរ សមរលាវ ទៅជាសរសេរថា សម៉(ខ្មែរ លាវ) ធ្វើឲ្យបាត់អស់រលីងនូវអត្ថន័យដើមនៃឈ្មោះភូមិនេះ។

[35] សាស្ត្រាចារ្យ វ៉ង់ សុធារ៉ា (Prof. VONG Sotheara)៖បច្ចុប្បន្នលោកជាប្រធានដេប៉ាតឺម៉ង់ប្រវត្តិវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ

ហើយបានលើកស្ត្រីខ្មែរម្នាក់ឲ្យឡើងសោយរាជ្យសម្បត្តិគ្រប់គ្រងរាជាណាចក្រនគរភ្នំដែលមានព្រះនាមតាមភាសាខ្មែរហៅថា សោមា[36] និងចិនថា លីវយី។ នៅពេលនោះមានព្រាហ្មណ៍ម្នាក់ឈ្មោះ ហ៊ុន ទៀន ជាជនជាតិក្លឹង (ឥណ្ឌា)មកពីប្រទេសឥណ្ឌាភាគអាគ្នេយ៍បានលើកទ័ពតាមផ្លូវសមុទ្រមកច្បាំងដណ្ដើមយកនគរហ្វូណន។ លុះច្បាំងឈ្នះលើពលរេហ៍របស់ព្រះនាងសោមា[37]ហើយក៏ឡើងសោយរាជសម្បត្តិ ដោយបានអភិសេកជាមួយព្រះនាងរាជនី សោមាជាព្រះមហេសី។ ទ្រង់ផ្លាស់ឈ្មោះព្រះនាង សោមា ថា លីវយីវិញ។ ចំពោះរឿងនេះខ្មែរយើងក៏មានរឿងនិទានផងដែរ ដែលបានចារនៅលើស្លឹករឹត គឺរឿងព្រះថោងនាង នាគ ត្រូវបានចាត់ទុកថា ជាបុព្វបុរសខ្មែរ។ តាមពង្សាវតារលាងរបស់ចិនឱ្យដឹងថា ព្រះបាទ ហ៊ុន ទៀន ឬ ព្រះបាទ កៅណ្ឌិន្យមានបុត្រមួយអង្គដែលសោយរាជ្យនៅលើភូមិភាគមួយដ៏ធំដោយមានក្រុងធំៗប្រាំពីរ[38]។ តាមប្រភពឯកសារដដែលនេះបាននិយាយទៀតថា ក្នុងនគរខ្មែរពេលនោះមានពួកនាហ្មឺនមន្ត្រីព្រមទាំងព្រះរាជវាំង។

[36] កាលពីសម័យសង្គមរាស្ត្រនិយម អនុវិទ្យាល័យមួយត្រូវប្រសិទ្ធនាមថាអនុវិទ្យាល័យសោមាដែលសព្វថ្ងៃក្លាយជាវិទ្យាល័យ ហេង សំរិន ព្រៃល្វា។ នៅសម័យនោះ ពេលសិស្សប្រឡងជាប់ ពួកគេអាចបន្តការសិក្សានៅវិទ្យាល័យព្រះ ឧទ័យ បច្ចុប្បន្នជាវិទ្យាល័យ ជា ស៊ីម តាកែវ។

[37] ឯកសារលោកគ្រូ សៅ ឈឿង។ ប៉ុន្តែ តាមឯកសារប្រវត្តិសាស្ត្រថា ជាបុត្រីរបស់ព្រះច័ន្ទ គឺសោមវង្ស។

[38] មកដល់ពេលនេះ គេមិនដឹងថា ទីក្រុងទាំងប្រាំពីរនេះមានឈ្មោះអ្វី និងនៅកន្លែងណាខ្លះទេ។

រីឯផ្នែកសង្គមវិញមានវណ្ណៈ៤[39] ដែលវណ្ណៈទាំង៤នេះពុំត្រូវបានគេអនុវត្តពេញលេញដូចជានៅប្រទេសឥណ្ឌាទេ។ក្នុងចំណោមស្ដេចសោយរាជ្យ តពីព្រះបាទ កៅណ្ឌិន្យ មានស្ដេចមួយអង្គនាម ហ៊ុន ប៉ានហួង[40]។

ការបន្តអនុវត្តនយោបាយដឹកនាំគ្រប់គ្រងរបស់រាជវង្សខ្មែរ គឺច្រើនធ្វើនយោបាយពង្រីកទឹកដី និងការប្រមូលក្រុមកុលសម្ព័ន្ធផ្សេងៗឱ្យមកនៅក្រោមការគ្រប់គ្រងនៃចក្រភពមួយ។ ស្ដេច ហ៊ុន ប៉ានហួង បានធ្វើការបង្រួបបង្រួមនគរមួយដ៏ធំដែលលាតសន្ធឹងលើភូមិភាគខាងក្រោមទន្លេមេគង្គភូមិភាគខាងជើងបឹងទន្លេសាបតាំងពីវាលទំនាបទន្លេមេគង្គផ្នែកកណ្ដាលរហូតដល់តំបន់ខាងជើងទន្លេចៅព្រះយ៉ា[41]ដែនដីតំបន់ជ្រោយម៉ាឡាយូ។ ក្រោយពីស្ដេចហ៊ុន ប៉ានហួង ដែលសោយរាជ្យបន្តគឺមានព្រះនាមថា ហ៊ុន ប៉ានប៉ាន[42]។ ស្ដេច ហ៊ុន ប៉ានប៉ានមានមេទ័ពម្នាក់ដ៏ខ្លាំងពូកែក្នុងការធ្វើសង្គ្រាមការពារទឹកដីនិងនគរឈ្មោះ ថា ហ្វាន់ ឆេម៉ាន់។ ស្ដេច ហ៊ុន ប៉ានប៉ាន សោយរាជ្យបានតែមួយរយៈក៏ចូលព្រះទិវង្គត គេក៏បានលើក ហ្វាន់ ចេម៉ាន់ ជាមេទ័ពឱ្យឡើងសោយរាជ្យជាស្ដេច ដែលតាមសិលាចារឹកវ៉ូកាញ់នៅកម្ពុជាក្រោមមានព្រះនាមក្នុងរាជ្យថា ស្រីមារៈឬ ព្រះបាទ អាទិត្យវរ្ម័ន។ ព្រះអង្គជាព្រះមហា

---

[39] ដួ ច័ន្ទដារី ចាន់ ប៊ុន្នី ឡៅប សុផល ស្រ៊ុន ប៊ុណ្ណារិទ្ធ៖ ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ឆ្នាំ២០១០ ទំព័រ ២៥។ វណ្ណៈទាំងបួនរួមមាន៖ ក្សត្រ ព្រាហ្មណ៍ វេស្សៈ និងសូទ្រ។ នៅកម្ពុជាគ្មានវណ្ណៈទេ។

[40] សូមអានសៀវភៅរបស់បណ្ឌិត សេង ប៊ុនធឿន រដ្ឋធម្មនុញ្ញ និងការផ្លាស់ប្ដូររបបនយោបាយ ឧបសម្ព័ន្ធទី៨

[41] ឈ្មោះទន្លេនេះ សព្វថ្ងៃគឺស្ថិតនៅពីមុខព្រះបរមរាជវាំងថៃនាទីក្រុងបាងកក។

[42] ដួ ច័ន្ទដារី ចាន់ ប៊ុន្នី ឡៅប សុផល ស្រ៊ុន ប៊ុណ្ណារិទ្ធ៖ ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ឆ្នាំ២០១០ ទំព័រ ២៦

ក្សត្រដំបូងគេបង្អស់របស់ខ្មែរដែលប្រើព្រះនាមថា **វរ្ម័ន**។

ពាក្យ **វរ្ម័ន** នេះត្រូវបានប្រើប្រាស់ជាថ្មីម្តងទៀតនៅឆ្នាំ១៩៩៣ និងឆ្នាំក្រោយមកទៀតដោយមានមនុស្សមកពីគណបក្សសាធារណរដ្ឋម្នាក់ឬពីរនាក់រិះគន់ព្រះអង្គ សម្តេចព្រះនរោត្តមសីហនុ ទ្រង់បានប្រកាសឲ្យរាជរដ្ឋាភិ-បាលដកវាក្យស័ព្ទនេះចេញពីព្រះនាមផ្លូវការរបស់ទ្រង់។ **វរ្ម័ន** មានន័យថា អ្នក ការពារ ឬអាវក្រោះហើយត្រូវបានប្រើស្ទើរតែគ្រប់ព្រះនាមព្រះមហាក្សត្រតាំងពីសម័យនគរភ្នំហូតមកដល់ចុងសម័យអង្គរគឺព្រះបាទជ័យវរ្ម័នទី៩។ ចាប់ពីព្រះបាទ ត្រសក់ផ្អែម មកគ្មានព្រះមហាក្សត្រអង្គណាមួយប្រើវាក្យស័ព្ទនេះទេ លើកលែងតែសម្តេចព្រះ នរោត្តម សីហនុ មួយព្រះអង្គប៉ុណ្ណោះ។ ប៉ុន្តែ ត្រូវបានលុបចោលវិញ បន្ទាប់ពីមានការស្នើឲ្យលុបរបស់ព្រះអង្គនោះ។ ទោះបីយ៉ាងនេះក្តី គេឃើញវាក្យស័ព្ទនេះជាថ្មីទៀត ក្នុងឱកាសអបអរសាទរខួបអនុស្សាវរីយ៍លើកទី៦០ឆ្នាំនៃបុណ្យឯករាជ្យជាតិថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០១៣នេះ ខណៈរាជរដ្ឋាភិបាលកម្ពុជាបានបោះពុម្ពក្រដាសប្រាក់២០០០រៀល(ថ្មី)មានព្រះឆាយាលក្ខណ៍របស់ព្រះអង្គហើយចារឹកអក្សរថា **ព្រះករុណា ព្រះបាទ សម្តេច ព្រះនរោត្តម សីហនុ វរ្ម័ន ព្រះបិតាឯករាជ្យជាតិ**។ នេះជាលើកទី១ហើយដែលត្រូវបានរាជរដ្ឋាភិបាលប្រើវាក្យស័ព្ទនេះបន្ទាប់ពីការយាងចូលព្រះទិវង្គត[43]។

នៅពាក់កណ្តាលទសវត្សរ៍ទី២ នៃសតវត្សរ៍ទី៣នៃគ.ស ស្តេច ហ្វាន់ចេម៉ាន់ ក៏ចូលទិវង្គតដែលតាមកំណត់ហេតុរបស់ចិនថា នៅចន្លោះឆ្នាំ២២៥

[43] សេង ប៊ុនធឿន៖ រដ្ឋធម្មនុញ្ញ និងការផ្លាស់ប្តូររបបនយោបាយនៅកម្ពុជា(ពីទសវត្សឆ្នាំ១៩៤០ដល់២០១៥)ទំព័រ៤៣

និង២៥០។ បន្ទាប់ពីនោះមក មានស្តេចមួយអង្គទៀតព្រះនាមថា ហ្វាន់ ស៊ីយ៉ុន បានឡើងសោយរាជ្យបន្ត។ តាមប្រភពឯកសារចិនបានឱ្យដឹងថា នៅក្នុង សម័យនោះ នគរភ្នំមានការទាក់ទងជាអន្តរជាតិយ៉ាងសកម្មតាមផ្លូវទូត និង ពាណិជ្ជកម្មជាមួយនឹងប្រទេសឥណ្ឌា និងប្រទេសចិន។ ជាមួយនឹងឥណ្ឌា នគរភ្នំបានបញ្ជូនអ្នកការទូតជាច្រើនលើកឱ្យទៅទាក់ទងនឹងរាជវង្ស មុរុណ្ឌ នៃប្រទេសឥណ្ឌា ហើយទៅប្រទេសចិនក្នុងសម័យសាមកុក[44]។

តាមពង្សាវតារ សាមកុក អាណាចក្រខ្មែរក្នុងរាជ្យព្រះបាទ អាទិត្យវ្ម័ន បានបញ្ជូនអ្នកការទូតខ្មែរទៅប្រទេសចិននៅឆ្នាំ២៤៣ដោយមាននាំយកនូវគ្រឿងបណ្ណាការពីរដ្ឋនគរភ្នំដើម្បីសុំចងសម្ព័ន្ធមិត្តជាមួយនឹងប្រទេសចិន[45]។ តាមប្រសាសន៍លោក សៅ ឈឿង បានឲ្យដឹងថា ក្នុងរជ្ជកាលព្រះមហាក្សត្រហ៊ុន ទៀន ប្រជារាស្ត្រខ្មែរចេះត្បាញសំពត់ ចេះស្លៀកពាក់ខោអាវ។ ប៉ុន្តែនេះគ្រាន់តែជាការចេះចាំតៗគ្នាប៉ុណ្ណោះ លោកតំណាលបន្តថា ប្រទេសកម្ពុជាកាលនោះបានផ្លាស់ប្តូរជាញឹកញាប់ដំបូងមានឈ្មោះថា កោះគោកធ្លក បន្ទាប់

---

[44] ជារឿងភាពយន្តចិនមួយរឿងដែលល្បីល្បាញ ទាំងតួអង្គ ទាំងទ្រឹស្តីទាំងភាសានិយាយត្រូវបានអ្នកនិយមខ្សែភាពយន្តនេះរំលឹក និងមានអ្នកខ្លះចូលចិត្តរើសដាក់ខ្លួនយកមកអនុវត្តតាមក្នុងសម័យនេះទៀតផង។

[45] ដួង ច័ន្ទដារី ចាន់ ប៊ុន្នី ឡៅ សុផល ស្រ៊ុន ប៊ុណ្ណារិទ្ធ៖ ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ឆ្នាំ២០១០ ទំព័រ ២៦

មកតក្កសីលា[46] បន្ទាប់មកឈ្មោះ ឥន្ទបត្តយសោធរៈ[47] ហើយក្រោយ មកទៀតផ្លាស់ថា មហានគរកម្ពុជាធិបតីសិរីឥន្ទបត្តកុរុរដ្ឋរាជធានី[48]។ តាមការរៀបរាប់របស់លោក ជុន ច័ន្ទបុត្រ អ្នកសារព័ត៌មាននៃវិទ្យុអាស៊ីសេរីជាភាសាខ្មែរ វិញបានឲ្យដឹងថា ទឹកដីនៅតាមដងទន្លេមេគង្គភាគខាងក្រោម ហើយនៅក្នុងដែនដីសណ្តនៃទន្លេនោះត្រូវបានពួកខ្មែរមួយក្រុមដែលមានជំនឿទៅលើសត្វនាគ ឬដែលជឿថា បុព្វបុរសដូនតារបស់ខ្លួនមានអំបូរមកពីពូជនាគរស់នៅតាំងពីយូរលង់ណាស់មកហើយ។ បើតាមឯកសារចិនលោក កាំង ថៃ (Kaing Thai) ដែលបានមកទស្សនា នគរភ្នំតាំងពីសតវត្សរ៍ទី៣នៃគ.ស បានរៀបរាប់ថា ប្រហែលជាក្នុងឆ្នាំ៥០នៃគ.ស.មានជនជាតិឥណ្ឌាម្នាក់ឈ្មោះ ហ៊ុន ទៀន បានធ្វើដំណើរមកពីប្រទេសឥណ្ឌា ឬមួយតាមកោះខាងត្បូងមកអាណាចក្រភ្នំ។ មូលហេតុដែលបណ្តាលឲ្យព្រាហ្ម ហ៊ុន ទៀន ធ្វើដំណើរមកកាន់នគរភ្នំនេះ ព្រោះយប់មួយនោះ ព្រះបាទ ហ៊ុន ទៀន បានយល់សុបិននិមិត្តឃើញថាទេវតាដែលរក្សាបីបាច់ព្រះអង្គបានធ្វើអំណោយធ្នូទិព្វមួយដល់ព្រះអង្គហើយបញ្ជាឲ្យព្រះអង្គជិះសំពៅដ៏ធំមួយ។ លុះព្រឹកឡើង ព្រះអង្គបានធ្វើដំណើរទៅកាន់ទេវស្ថានដើម្បីធ្វើសក្ការៈបូជាស្រាប់តែបានឃើញធ្នូទិព្វ

---

[46] ឯកសារលោកគ្រូ សៅ ឈឿង៖ ប្រវត្តិសាស្ត្រមិនបានបញ្ជាក់ដូច្នេះទេ ប៉ុន្តែក្នុងនាមអ្នកស្រាវជ្រាវត្រូវតែរក្សាពាក្យសំដីដើមរបស់ពួកគេ នេះជាការចេះដឹងរបស់អ្នកស្រុកតែប៉ុណ្ណោះ។ ប៉ុន្តែចំពោះពាក្យគោកធ្លក និងឥន្ទបត្តយសោធរធ្លាប់ការការនិយាយខ្លះៗ។ សរុបមក មួយចាភាសាអ្នកស្រុក មួយទៀតជាភាសាអ្នកស្រាវជ្រាវ។

[47] ឯ-ដ។

[48] ឯ-ដ

នោះដូចសុបិនមែន[49]។ បន្ទាប់មកព្រះអង្គធ្វើដំណើរតាមសមុទ្រទៅកាន់អាណាចក្រភ្នំតាមការណែនាំរបស់ទេវតាក្នុងការយល់សប្តនោះ។ មកដល់នគរភ្នំ ព្រះអង្គបានពើបប្រយុទ្ធជាមួយរាជនីនៃរដ្ឋនេះគឺព្រះនាង លីវយី ដែលបាននាំកម្លាំងទ័ពមកវាយលុកលើសំពៅរបស់ព្រះអង្គ[50]។ ដោយឫទ្ធានុភាពផ្ទុទិព្វ ព្រះអង្គក៏ទទួលបានជ័យជំនះលើព្រះនាង លីវ យី ដែលជាម្ចាស់ស្រុកដោយសារព្រះអង្គបានបាញ់សំពៅរបស់ព្រះនាងឲ្យធ្លាយពីម្ខាងទៅម្ខាង[51]។ ដោយឃើញព្រះបាទ ហ៊ុន ទៀន មានឫទ្ធានុភាពខ្លាំងពូកែដូច្នេះ ព្រះនាង លីវ យី ក៏ព្រមចុះចាញ់ព្រះអង្គ ហើយទ្រង់ក៏បានរៀបអភិសេកព្រះនាងជាអគ្គមហេសីតាំងពីពេលនោះមក។ ចំណែកសិលាចារឹកចាមនៅមីសឺង គ្រឹស្តសករាជ៦៥៨វិញ បានឲ្យដឹងថា ព្រះបាទ ហ៊ុន ទៀន ដែលចិនហៅនោះ ឈ្មោះកៅណ្ឌិន្យ។ ឯនាង លីវ យី វិញ ឈ្មោះ សោមា កូនព្រះច័ន្ទ។ ឯខាងព្រះរាជពង្សាវតារនៃព្រះរាជាណាចក្រកម្ពុជាវិញហៅព្រះនាមស្តេចនោះថាព្រះថោង និងនាង នាគ[52] ដែលបានបន្សល់ទុកនូវកេរដំណែល ប្រពៃណី ទំនៀមទម្លាប់ជាច្រើនក្នុងជីវភាពសង្គមខ្មែររហូតមកដល់សព្វថ្ងៃនេះថែមទៀតផង[53]។

---

[49] KHMER HISTORIES (History of Cambodia #...)៖ នាទីប្រវត្តិសាស្ត្រនៅអំឡុងឆ្នាំ២០១០ និង២០១១ និងត្រូវបានចាក់ផ្សាយឡើងក្នុងគ្រាបន្តបន្ទាប់មក។

[50] ឯ-ដ

[51] ឯ-ដ

[52] នាគមានន័យថា ទឹក ហើយដែលជនជាតិខ្មែរនិយមស្លៀកសំពត់ហូល ឬអាវហូលនោះ(មិនមែនផាមួងទេ)គឺសំដៅលើស្រុកខ្មែរនិយមសត្វនាគ ហើយក្រឡាហូលនេះ ជាស្រកានាគ។

[53] KHMER HISTORIES (History of Cambodia #...) ៖ នាទីប្រវត្តិសាស្ត្រនៅអំឡុងឆ្នាំ២០១០ និង២០១១ និងត្រូវបានចាក់ផ្សាយឡើងក្នុងគ្រាបន្តបន្ទាប់មក។

ដូច្នេះរួមសេចក្ដីមក គឺព្រះបាទ ហ៊ុន ទៀន ឬ កៅឌិន្យ ឬព្រះថោង និងនាង លីវយី ឬ នាង នាគ ឬសោមានេះឯង។ អ្នកប្រវត្តិសាស្ត្រស្គាល់ថា ពេលនោះ ហើយដែលព្រះថោង ឬ កៅឌិន្យ ឬ ហ៊ុន ទៀន ជាជាតិឥណ្ឌាបានយកទំនៀម ទម្លាប់ និងប្រពៃណីផ្សេងៗពីប្រទេសឥណ្ឌា មានសាសនា ភាសាអ្នកប្រាជ្ញ អក្សរច្បាប់ទំនៀមទម្លាប់ផ្សេងៗ ពិសេស គឺរបៀបរៀបចំ ឬគំនិតដឹកនាំ ប្រទេសតាមបែបរាជាធិបតេយ្យមកបន្ថែមឲ្យក៏ការបញ្ចូលគ្នានូវអ្វីៗដែល សង្គមខ្មែរមានរួចទៅហើយ ដូចជា ជំនឿលើព្រលឹងដូនតា គោរពមេបា អារក្ស អ្នកតា និងលទ្ធិមាតាធិបតេយ្យ យកមេជាធំដែលជាហេតុធ្វើឲ្យសង្គមខ្មែរនា សម័យនោះមានការរីកចម្រើនយ៉ាងឆាប់រហ័សបំផុត។ ចំពោះឈ្មោះនគរវិញ គឺប្រហែលជាពេលនោះមកហើយ ដែលមានឈ្មោះថា នគរភ្នំ ព្រោះតាមឯក សារចិនបាននិយាយច្បាស់ថា អធិរាជអាណាចក្រភ្នំ មានឋានន្តរនាមថា គូ ឡុង គឺក្រុងដែលសព្វថ្ងៃនេះមានន័យថា ស្ដេចសោយរាជ្យ។ ម៉្យាងទៀត តាម ការនិយមរបស់ជនជាតិចិន គេច្រើនប្រើឈ្មោះ ឬពាក្យតែមួយសម្រាប់ សម្គាល់ប្រទេសផង ប្រជារាស្ត្រមួយផង រាជធានីផង ឬក៏ឋានន្តរនាមរបស់ អ្នកដឹកនាំផង។ ករណីនេះ ក៏ឃើញមានដែរ ព្រះមហាក្សត្រនៅសម័យអង្គរ។ ដូចជាព្រះបាទឥន្ទ្រវរ្ម័នទី១ ឡើងសោយរាជ្យ ទីក្រុង ឬរាជធានីបានប្ដូរជានាម ឥន្ទ្របុរៈ ក្រោយមកនៅពេលព្រះរាជបុត្ររបស់ទ្រង់ឡើងគ្រងរាជ្យព្រះបាទយ សោវរ្ម័នទី១ រាជធានីរបស់ព្រះអង្គក៏បានប្ដូរឈ្មោះទៅជា យសោធបុរៈ និងឥ សានបុរៈ។ល។ ដូច្នេះ ពាក្យ ហ្វូណន ចិនប្រាកដជាហៅឋានន្តរនាមព្រះចៅ អធិរាជគឺស្ដេចក្រុងភ្នំ ហើយហ្វូណន ជាសំនៀងចិននៃពាក្យ ហ្វូណន ឬភ្នំ របស់ខ្មែរនេះឯង។ រីឯការដែលអធិរាជអាណាចក្រភ្នំមានឋានន្តរនាមស្ដេច ក្រុងភ្នំដូច្នេះគឺប្រហែលជាមកពីភ្នំជាទីកន្លែងដែលអធិរាជឡើងទៅជួបនឹង

ព្រះឥសូរ។ ឯកសារចិនបានរៀបរាប់ថា ព្រះអាទិទេពយាងចុះមកពីភ្នំមតាន[54]ជាញឹកញាប់ ព្រះអង្គបានយកទីនោះដើម្បីបញ្ចេញមហិទ្ធិឫទ្ធិរបស់ព្រះអង្គ ព្រះចៅអធិរាជទាំងឡាយបានទទួលពរជ័យពីព្រះអង្គ ហើយប្រជារាស្ត្រក៏បានសុខចម្រើនទៅតាមនោះផងដែរ។ ចំណែកខាងរាជធានីអាណាចក្រនគរភ្នំវិញមានឈ្មោះថា វ្យាធបុរៈប្រហែលស្ថិតនៅបាភ្នំមានចម្ងាយប្រហែល២០០គមពីសមុទ្ទ។ ក្នុងវង្វង់សតវត្សរ៍ទី១នៃគ្រឹស្តសករាជ ជនជាតិខ្មែរដែលតាំងពីយូរលង់ណាស់មកហើយធ្លាប់មានទំនាក់ទំនងជាមួយអ្នកដើរសមុទ្ទជាតិឥណ្ឌាភាគច្រើនជាអ្នកជំនួញ និងពួកព្រាហ្ម ក៏បានទទួលឥទ្ធិពលជាបន្តបន្ទាប់ពីពួកឥណ្ឌាទាំងនោះ គឺគ្មានអ្វីគួរឲ្យសង្ស័យឡើយ វប្បធម៌ និងសាសនារបស់អ្នកដឹកនាំខ្មែរ[55]។ ចំណែកប្រជាពលរដ្ឋទូទៅវិញ រហូតមកដល់សព្វថ្ងៃនេះហើយនៅតែមានជំនឿទៅលើព្រលឹងដូនតា គោរពបូជាអារក្សអ្នកតា ម្ចាស់ទឹក ម្ចាស់ដី ដែលជាជំនឿរបស់ខ្មែរដើមដដែល ទោះបីស្ថិតនៅក្រោមទង់ ឬរូបភាពព្រះពុទ្ធសាសនាក៏ដោយ។ ម៉្យាងទៀត ក៏ដោយសារការទទួលឥទ្ធិពលឥណ្ឌាដែលមានភាសាសំស្ក្រឹតជាយាន្តនេះហើយទើបបានជំរុញជនជាតិខ្មែរឲ្យចាប់ផ្តើមសម័យប្រវត្តិសាស្ត្ររបស់ខ្លួននាដើមសតវត្សរ៍ទី១នៃគ្រឹស្តសករាជនេះ។

[54] អានថា ម តាន

[55] KHMER HISTORIES (History of Cambodia #...) ៖ នាទីប្រវត្តិសាស្ត្រនៅអំឡុងឆ្នាំ២០១០ និង២០១១ និងត្រូវបានចាក់ផ្សាយឡើងក្នុងគ្រាបន្តបន្ទាប់មក។

## ២-ការទទួលឥទ្ធិពលឥណ្ឌា

### ក-ការទទួលឥទ្ធិពលឥណ្ឌាលើកទី១

ការធ្វើដំណើរដែលចេះតែរីកចម្រើនឡើងជាលំដាប់របស់ជនជាតិឥណ្ឌាមកកាន់តំបន់សុវណ្ណភូមិនេះ ដើមហេតុសំខាន់ គឺការមកធ្វើជំនួញជួញដូរខាងសេដ្ឋកិច្ច។ពីដើមឡើយពួកឈ្មួញឥណ្ឌាទិញមាសពីតំបន់ស៊ីបេរីដែលពួកគោចរធ្វើដំណើរដោយរទេះពីឆ្ងាយៗមកលក់ឲ្យ ឆ្លងកាត់តំបន់បាក់ទ្រីយ៉ាន។ប៉ុន្តែប្រហែលជាពីរសតវត្សរ៍មុនគ.ស.ដោយមានការរំជើបរំជួលក្នុងចំណោមជនជាតិផ្សេងៗនៅភូមិភាគអាស៊ីកណ្តាលបានធ្វើឲ្យផ្លូវនេះត្រូវកាត់ផ្តាច់ធ្វើគមនាគមន៍តទៅទៀតលែងកើត។

ក្រោយមក គឺនៅក្នុងអំឡុងសតវត្សរ៍ទី១នៃគ.ស. ពួកឥណ្ឌាក៏ធ្វើដំណើរបែរទៅទិសខាងលិច ហើយបានទិញនិងដឹកជញ្ជូនមាសពីពិភពរ៉ូម៉ាំង ក្នុងនោះមានទាំងកាក់មាសដែលគេបានរំលាយ ហើយបោះជារូបិយ៍វត្ថុជាប្រាក់ ដាក់ឲ្យប្រើប្រាស់ក្នុងពិភពរ៉ូម៉ាំងថែមទៀតផង។ ប៉ុន្តែមិនយូរប៉ុន្មាន ព្រះចៅ វេស្ប៉ា )Vespa( ឆ្នាំ៦៩-៧៩ នៃគ.ស.នៃចក្រភពរ៉ូម៉ាំងនេះ បានចេញប្បញ្ញត្តិហាមឃាត់មិនឲ្យនាំមាសចេញដែលជាប្រការបង្ខំឲ្យពួកឥណ្ឌាស្វែងរកប្រភពទិញមាសពីកន្លែងដទៃផ្សេងទៀត។

ទីបំផុត ពួកនេះក៏បានធ្វើដំណើរបែរមករកតំបន់សុវណ្ណភូមិ[56]។ ការធ្វើដំណើរស្វែងមករកមាសតំបន់សុវណ្ណភូមិនេះបានត្រូវសម្រួលដោយកត្តា

---

[56] ដែនដីសុវណ្ណភូមិឬទឹកដីសុវណ្ណភូមិមានន័យថា **ដែនដីមាស** ត្រូវបានអ្នកប្រវត្តិសាស្រ្តនិងជនជាតិខ្មែរស្គាល់ថាជាទឹក ដីខ្មែរនាអតីតកាល ប្រហែលជាពាក្យនេះពិរោះហើយមានន័យល្អបានជា ប្រទេសថៃយកទៅដាក់ឈ្មោះជាព្រលានយន្តហោះរបស់ខ្លួនថា “ អាកាសយានដ្ឋានសុវណ្ណភូមិ / Su-varnabhumi Airport” (សម្រាប់ការហោះហើរអន្តរជាតិ)

ជាច្រើនដូចជាការរីកចម្រើនខាងផ្នែកនាវាចរណ៍សមុទ្ទ នៅពេលនោះ គេអាចរកឃើញបច្ចេកទេសធ្វើសំពៅធំៗ មាំៗ ដែលអាចផ្ទុកទំនិញ និងមនុស្សចំនួនរហូតដល់ទៅ៧០០នាក់។ ការរកឃើញភាពឆ្លាស់គ្នានៃខ្យល់រដូវដោយអ្នកបើកសំពៅជនជាតិក្រិចបានជំរុញឲ្យមានភាពទៀងទាត់ក្នុងការធ្វើដំណើរ និងញុំាងការរកមាសនៅតំបន់សុវណ្ណភូមិនេះកាន់តែមានសន្ទុះកើនឡើង។ ម៉្យាងទៀត ក្នុងពេលជាមួយគ្នានេះដែរ ព្រះពុទ្ធសាសនាក៏កាន់តែរីកចម្រើន ហើយសាសនានេះបានលុបបំបាត់ចោលប្រព័ន្ធវណ្ណៈក្នុងសង្គមដែលជាហេតុនាំឲ្យពួកឥណ្ឌាលែងខ្លាចបាត់ភាពបរិសុទ្ធនៅក្នុងឈាមក្នុងពូជសាសន៍របស់ខ្លួន ហើយធ្វើការទាក់ទងដោយទូលាយជាមួយជនបរទេស។ ក្រោយមកពួកឈ្មួញឥណ្ឌាទាំងនោះបានមកបោះទីតាំងដោយបានបង្កើតជាហាងលក់ទំនិញឬសាខាគ្រឹះស្ថានជំនួញរបស់ខ្លួនក្នុងដែនដីសុវណ្ណភូមិនេះហើយជាបន្តបន្ទាប់បានប្រើប្រាស់គ្រឹះស្ថានទាំងនោះជាមជ្ឈមណ្ឌលផ្សព្វផ្សាយនយោបាយ សាសនារបស់ខ្លួន នាំឲ្យជះឥទ្ធិពលយ៉ាងខ្លាំងទៅលើរដ្ឋរាសី គឺជនជាតិម្ចាស់ស្រុក[57]។ មិនត្រឹមតែប៉ុណ្ណោះទេដើម្បីពង្រឹ និងពង្រីកឥទ្ធិពលរបស់ខ្លួន ពួកនេះបានរឹតចំណងចងស្ពានមេត្រី រៀបចំអាពាហ៍ពិពាហ៍ចម្រុះជាមួយពួករដ្ឋរាសីម្ចាស់ស្រុកដើម្បីបង្កើតចំណងទាក់ទងជាគ្រួសារយ៉ាងជិតស្និទ្ធថែមទៀតផង។ ជាក់ស្ដែង គឺអាពាហ៍ពិពាហ៍បែបនេះហើយដែលបានបង្កើតឡើងនូវសន្តតិវង្សដំបូងបង្អស់របស់ព្រះរាជាចក្រកម្ពុជាយើងនេះ។ អ្នកស្នងរាជបន្តពីព្រះបាទ កៅឌិន្យ គឺកូនចៅរបស់ព្រះអង្គ ក្នុងនោះមានព្រះបាទ ហ៊ុន ប៉ានហួន ដែលព្រះរាជាមួយអង្គខ្លាំងពូកែ មានកលល្បិចក្នុង

[57] ឯ-ដ

ការធ្វើសង្គ្រាមពង្រឹងអំណាចកណ្តាល ហើយវាយពង្រីកអាណាចក្រឲ្យធំទូលាយ។ ស្តេចអង្គនេះ សោយព្រះទិវង្គតក្នុងព្រះជន្ម៩០ព្រះវស្សានៅដើមសតវត្សរ៍ទី៣នៃគ្រិស្តសករាជ។ ព្រះរាជបុត្ររបស់ព្រះអង្គព្រះនាម ប៉ានប៉ាន ត្រូវបានជ្រើសតាំងឲ្យឡើងស្នងរាជ្យបន្តពីព្រះអង្គ។

ប៉ុន្តែព្រះរាជាអង្គថ្មីនេះ បានប្រគល់កិច្ចការរដ្ឋទាំងអស់ទៅឲ្យមេទ័ពម្នាក់នាម ស្រីមារៈ មើលកិច្ចការជំនួស។ ព្រះអង្គសោយរាជ្យបានតែបីឆ្នាំក៏សោយទិវង្គតទៅ។ ពួកនាម៉ឺនសព្វមុខមន្ត្រីក៏ជ្រើសមន្ត្រីម្នាក់ឲ្យឡើងសោយរាជ្យបន្ត[58]។ ជាទូទៅ ព្រះរាជាខ្មែរតែងតែមានព្រះនាមបី គឺទីមួយ ព្រះនាមកំណើតទីពីរ ព្រះនាមគ្រងរាជ្យ និងទីបីព្រះមរណៈនាម គឺនាមពេលដែលព្រះមហាក្សត្រសោយព្រះទិវង្គតទៅ។ ព្រះបាទស្រីមារៈជាស្តេចសឹកដ៏ខ្លាំងពូកែ ព្រះអង្គបានធ្វើសង្គ្រាមតាមផ្លូវទឹកផង តាមផ្លូវគោកផង ហើយពង្រឹងអំណាចរបស់ព្រះអង្គលើដែនដីភាគខាងក្រោម គឺកម្ពុជាក្រោមសព្វថ្ងៃភាគកណ្តាលនៃទន្លេមេគង្គ ហើយរឹបជាក់ជាចំណុះនូវរដ្ឋតូចៗភាគខាងជើងជ្រោយម៉ាឡាយូដើម្បីត្រួតពិនិត្យ និងទីសំចតទាំងឡាយចន្លោះឈូងសមុទ្របឹងហ្កាល់ និងឈូងសមុទ្រសៀម។ ព្រះអង្គសោយទិវង្គតក្នុងពេលព្រះអង្គបំពេញបេសកកម្មមួយនៅប្រទេសម៉ាឡេស៊ី។ ក្មួយរបស់ព្រះអង្គព្រះនាមឆានឆាន ដែលប្រហែល ជាមាននាមក្នុងរាជ្យថា ភរនិន្ទ្រវរ្ម័ន បានជ្រែករាជ្យដោយធ្វើគត់រាជទាយាទគឺព្រះរាជបុត្រច្បងរបស់ព្រះបាទ ស្រីមារៈ ហើយឡើងសោយរាជ្យខ្លួនព្រះអង្គ។ ព្រះអង្គសោយរាជ្យបានម្ភៃឆ្នាំ។ នៅក្នុងរាជ្យរបស់ព្រះអង្គ ទ្រង់បានរឹតចំណងការទូតជាមួយរាជវង្សឥណ្ឌា មុរុណ្ឌ។ នៅឆ្នាំ២៤៣ ព្រះអង្គបាន

---

[58] ឯ-ដ

បញ្ជូនរាជទូតទៅប្រទេសចិន ដើម្បីនាំជង្វាយជាអ្នកភ្លេង និងផលិតផលផ្សេងៗទៀតទៅថ្វាយស្តេចក្រុងចិន។ គឺនៅក្នុងរាជ្យស្តេចឆានឆាននេះហើយដែលបានកសាងសិលាចារិកខ្មែរចាស់ជាងគេជាភាសាសំស្ក្រឹតក្នុងដែនសាមន្តរដ្ឋមួយរបស់អាណាចក្រភ្នំដែលគេរកឃើញនៅរមណីយដ្ឋានវ៉ូកាញ់ក្នុងតំបន់ញ៉ាត្រាងប្រទេសវៀតណាមសព្វថ្ងៃនេះ។ ប្រហែលនៅក្នុងឆ្នាំ២៥០ ព្រះអង្គឆានឆានត្រូវបានធ្វើគត់ដោយព្រះរាជបុត្រពៅរបស់ព្រះបាទស្រីមារៈ។ ដោយយកលេសថា សងសឹកមេទ័ពម្នាក់របស់ព្រះអង្គ ឆានឆាន មានឈ្មោះថា អសុជ័យ ដែលតាមឯកសារចិនថាស៊ីយ៉ុនហ្វាន់ស៊ីយ៉ុនបានធ្វើគត់ព្រះរាជទាយាទគឺព្រះរាជបុត្រពៅរបស់ព្រះបាទស្រីមារៈហើយប្រកាសខ្លួនថាស្តេចឡើងសោយរាជ្យជាក្រុងភ្នំ។ ព្រះបាទ ហ្វាន់ស៊ីយ៉ុន ជា ស្តេចស្រឡាញ់សន្តិភាពទ្រង់បានយកព្រះទ័យទុកដាក់នឹងព្រះរាជភារកិច្ចរបស់ព្រះអង្គយ៉ាងខ្លាំង[59]។ ដើម្បីរក្សាកិត្យានុភាពរបស់ព្រះអង្គ ទ្រង់បានប្រើប្រាស់ការទូតច្រើនជាងកម្លាំងទ័ព។ ព្រះអង្គបានរក្សាចំណងទាក់ទងជាប្រក្រតីជាមួយព្រះរាជវាំងមុរុណ្ឌ។ ពីឆ្នាំ២៦៨ដល់ឆ្នាំ២៨៧ ព្រះអង្គបានបញ្ជូនរាជទូតទៅកាន់ប្រទេសចិន។ មួយចំណែកទៀត ជាមួយអាណាចក្រចំប៉ាដែលស្ថិតនៅភាគខាងកើតនគរភ្នំ។ ព្រះអង្គបានរឹតចំណងទាក់ទងយ៉ាងជិតស្និទ្ធរហូតដល់គេជឿថាប្រហែលជាព្រះអង្គបានពង្រីកអធិរាជភាពរបស់ព្រះអង្គលើប្រទេសចំប៉ានោះថែមទៀតផង[60]។

---

[59] KHMER HISTORIES (History of Cambodia #...) ៖ នាទីប្រវត្តិសាស្ត្រនៅអំឡុងឆ្នាំ២០១០ និង២០១១ និងត្រូវបានចាក់ផ្សាយឡើងក្នុងគ្រាបន្តបន្ទាប់មក។

[60] KHMER HISTORIES (History of Cambodia #...) ៖ នាទីប្រវត្តិសាស្ត្រនៅអំឡុងឆ្នាំ២០១០ និង២០១១ និងត្រូវបានចាក់ផ្សាយឡើងក្នុងគ្រាបន្តបន្ទាប់មក។

## ខ-ការទទួលឥទ្ធិពលឥណ្ឌាលើកទី២[61]

ការទទួលឥទ្ធិពលឥណ្ឌាលើកទីពីរ គ្មានឯកសារអ្វីទាំងអស់ ទោះបីសិលាចារឹកឬឯកសារចិនបានបញ្ជាក់ប្រាប់យើងចំពោះអ្វីដែលកើតមានឡើងក្នុងអំឡុងខាងដើមសតវត្សរ៍ទី៤នៃគ្រឹស្តសករាជឡើយ។ រហូតដល់ឆ្នាំ៣៥៧ អាណាចក្រភ្នំត្រូវគ្រប់គ្រងដោយព្រះរាជាមួយអង្គព្រះនាម ឆានតាន ដែលចិនឲ្យឈ្មោះថា ធៀន ឈូឆានតាន គឺឥណ្ឌាឈ្មោះឆានតាន។ ឆានតានជាឋានន្តរនាមរបស់ពួកឥណ្ឌូទ្វីប។ ជាពិសេស រាជវង្សកុសណៈប្រហែលជាត្រូវភៀសខ្លួនចេញពីប្រទេសឥណ្ឌា ភាគខាងត្បូងកន្លែងដែលខ្លួនធ្លាប់កាន់កាប់មួយរយៈពេលគឺព្រះរាជាមួយព្រះអង្គព្រះនាមព្រះបាទសមុទ្ទគុប្ប។

ទ្រង់វាយលុករំដោះយកតំបន់នោះនៅឆ្នាំ៣៣៥-៣៧៥។ ក្នុងរាជរបស់ព្រះអង្គព្រះបាទឆានតាន មានទំនាក់ទំនងល្អជាមួយប្រទេសចិន ដោយព្រះអង្គបានសួយជាដំរីផ្សាំងទៅថ្វាយអធិរាជចិនថែមទៀតផង។តាមឯកសារខ្លះបានបញ្ជាក់ថាក្សត្រអង្គនេះមានព្រះនាមក្នុងរាជថា ស្រុតវរ្ម័ន ដែលគេបានថ្វាយព្រះរហ័សនាមថា អ្នកការពារ[62]។ ក្នុងរជ្ជកាលរបស់ព្រះអង្គសាសនាព្រាហ្មណ៍គណៈឥសូរមានការរីកចម្រើនយ៉ាងខ្លាំង។

ប៉ុន្តែខាងព្រះពុទ្ធសាសនាមហាយានវិញ ក៏នៅមានសាសនិកអ្នកជឿនិងគោរពយ៉ាងច្រើនដែរ[63]។របៀបរបបរៀបចំផ្នែកនយោបាយនិងខាងសង្គម

---

[61] KHMER HISTORIES (History of Cambodia #...) ៖ នាទីប្រវត្តិសាស្ត្រនៅអំឡុងឆ្នាំ២០១០ និង ២០១១ និងត្រូវបានចាក់ផ្សាយឡើងក្នុងគ្រាបន្តបន្ទាប់មក។

[62] KHMER HISTORIES (History of Cambodia #...) ៖ នាទីប្រវត្តិសាស្ត្រនៅអំឡុងឆ្នាំ២០១០ និង២០១១ និងត្រូវបានចាក់ផ្សាយឡើងក្នុងគ្រាបន្តបន្ទាប់មក។

[63] ឯ-ដ

នៅអាណាចក្រភ្នំត្រូវចម្លងយកតាមរូបភាពប្រទេសឥណ្ឌាមិនត្រឹមតែប៉ុណ្ណោះ ទេព្រះអង្គថែមទាំងបានអញ្ជើញពួកព្រាហ្មណ៍យ៉ាងច្រើនពីប្រទេសឥណ្ឌា ដោយផ្ដល់កិត្តិយសយ៉ាងខ្ពង់ខ្ពស់ដល់ពួកនេះដើម្បីឲ្យពួកគេជួយរៀបចំ សាសនាផ្សេងៗ ការអប់រំ និងខាងសង្គមថែមទៀតផង។ ក្រោយពីព្រះអង្គ យាងសោយទិវង្គតទៅព្រះរាជបុត្រព្រះអង្គ ទ្រង់ឡើងគ្រងរាជស្នងព្រះអង្គ ដែលមានព្រះនាមក្នុងរាជថាស្រេស្ថវរ្ម័ន។ ព្រះរាជាអង្គនេះបានបញ្ជាឲ្យយក សារការទូតនិងដង្វាយទៅថ្វាយអធិរាជក្រុងចិននៃរាជវង្សវិន ជាច្រើនលើក គឺ នៅគ.ស.៤៣៤-៤៣៥ និង៤៣៨។ ម៉្យាងទៀត ដើម្បីរក្សាចំណងមិត្តភាពល្អ ជាមួយប្រទេសចិននេះព្រះបាទ ស្រេស្ថវរ្ម័ន ក្នុងឆ្នាំ៤៣១-៤៣២ បានប្រកែក មិនព្រមជួយប្រទេសចំប៉ាក្នុងការដណ្ដើមយកខេត្តតុងកឹងរបស់ចិន[64]។

ពង្សាវតារចិនរាជវង្ស ស៊ី ខាងត្បូងបាននិយាយថា ប្រហែល១០ឆ្នាំ ក្រោយការកំណត់៤៣១-៤៣២ ស្ដេចសោយរាជ្យនៅអាណាចក្រភ្នំ គឺព្រះ បាទ ជ័យវរ្ម័ន ដែលមានត្រកូល កៅឌិន្យ គ.ស.៤៨០-៥១៤។ ព្រះអង្គជា ព្រះមហាក្សត្រនគរភ្នំដែលមានចំណងទាក់ទងការទូតយ៉ាងប្រពៃបំផុតជា មួយនឹងប្រទេសចិនរហូតដល់ព្រះចៅអធិរាជចិន ទ្រង់ថ្វាយព្រះឋានន្តរនាម ថា មេទ័ពសន្តិភាពភាគខាងត្បូងអធិរាជក្រុងភ្នំ។ ក្នុងរាជព្រះបាទ កៅឌិន្យ ជ័យវរ្ម័ន នេះមានព្រះភិក្ខុពីរព្រះអង្គនៃអាណាចក្រភ្នំ គឺព្រះសង្ឃបាល និងមន្ត្រសេន បាននិមន្តទៅប្រទេសចិនដើម្បីជួយបកប្រែគម្ពីរផ្សេងៗពីភាសា សំស្ក្រឹតទៅជាភាសាចិនហើយគឺនៅក្នុងរាជព្រះអង្គនេះដែរគឺក្នុងគ.ស.៥០៣ ព្រះអង្គបានចាត់ព្រះសង្ឃព្រះនាម នាគសេន ឲ្យនាំព្រះពុទ្ធរូបធ្វើអំពីផ្កាថ្ម

[64] ឯ-ដ

ចេតីយ៍ធ្វើអំពីភ្លុក និងវត្ថុផ្សេងៗទៀតទៅថ្វាយអធិរាជចិននៃរាជវង្សសុង។ ដោយសារសំអាងលើឯកសារចិន ដែលចែងពីសេចក្ដីរាប់អានរបស់ព្រះចៅក្រុងចិនមានចំពោះព្រះបាទ កៅឌិន្យជ័យវរ្ម័ន នេះគេអាចសន្មតរជ្ជកាលរបស់ព្រះអង្គជាសម័យរុងរឿងបំផុតនៃប្រវត្តិសាស្ត្រអាណាចក្រភ្នំ។ ព្រះអង្គសោយទិវង្គតនៅគ.ស.៥១៤[65]។ តាមរាជបវេណីក្រោយពីព្រះអង្គ កៅឌិន្យ ជ័យវរ្ម័ន សុគតទៅ គឺត្រូវរាជទាយាទព្រះនាម គុណវរ្ម័ន ជាបុត្ររបស់ព្រះអគ្គមហេសីព្រះនាមកុលព្រះភាវត្តី ឡើងស្នងរាជ្យស្នងព្រះអង្គ។ ប៉ុន្តែនៅឆ្នាំ៥១៤ដដែលនេះ ព្រះបាទ រុទ្រវរ្ម័ន ជាព្រះជេដ្ឋា[66]របស់គុណវរ្ម័នដែលជាបុត្ររបស់ស្នំម្នាក់បានធ្វើគតគុណវរ្ម័នជាប្អូនដើម្បីដណ្ដើមយករាជសម្បត្តិសោយ។

ព្រះបាទ រុទ្រវរ្ម័ន នេះជាស្ដេចចុងក្រោយនៃអាណាចក្រភ្នំ។ ព្រះអង្គបានបញ្ជូនរាជទូតជាច្រើនដងនៅចន្លោះគ.ស.៥១៧និង៥៣៥ទៅកាន់ប្រទេសចិន។ រាជទូតអាណាចក្រភ្នំម្នាក់បាននាំសួយជាសត្វរមាសមួយទៅថ្វាយស្ដេចក្រុងចិននៅឆ្នាំ៥៣៩ បានទូលព្រះអង្គថា មានព្រះកេស គឺសក់ព្រះមួយសរសៃប្រវែងបីម៉ែត្រ។

លុះទ្រង់ជ្រាបដំណឹងនេះហើយ ព្រះចៅអធិរាជ លាង ឧទី បានបញ្ជាព្រះអង្គ ឆេយុនប៉ាវ ឲ្យនិមន្តមកអាណាចក្រភ្នំដើម្បីនាំយកព្រះកេសនោះទៅប្រទេសចិន។ បើតាមពង្សាវតាររាជវង្ស លាង ព្រះពុទ្ធសាសនាក្នុងសម័យនោះរុងរឿងណាស់ពីព្រោះឯកសារនោះបាននិយាយថាមានគណបេសកកម្មចិនមួយបានបញ្ជូនមកអាណាចក្រភ្នំនៅចន្លោះគ.ស.៥៣៥ និង៥៤៥ ដើម្បី

[65] KHMER HISTORIES (History of Cambodia #...) ៖ នាទីប្រវត្តិសាស្ត្រនៅអំឡុងឆ្នាំ២០១០ និង២០១១ និងត្រូវបានចាក់ផ្សាយឡើងក្នុងគ្រាបន្តបន្ទាប់មក។

[66] ជេដ្ឋា /ព្រះរៀម /បង /ព្រះរាម

សុំឲ្យអធិរាជអាណាចក្រភ្នំបញ្ជូនទៅប្រទេសចិននូវអ្នកប្រាជ្ញ និងគម្ពីរខាងព្រះពុទ្ធសាសនា។ គួរកត់សម្គាល់ថា ការដែលព្រះបាទ រុទ្រវរ្ម័ន ឡើងសោយរាជដោយខុសទំនងបែបនេះហើយបានបណ្ដាលឲ្យអាណាចក្រភ្នំត្រូវរឹករេរកើតចលាចលរហូតដល់ត្រូវរលំរលាយជាស្ថាពរនៅពាក់កណ្ដាលទី២នៃសតវត្សរ៍ទី៦នោះឯង[67]។

## ៣-អរិយធម៌ខ្មែរសម័យនគរភ្នំ

កំពង់ផែសំខាន់របស់អាណាចក្រនគរភ្នំគឺអូរកែវ[68]។ស្ថិតនៅភាគខាងត្បូងភ្នំបាខេ ក្នុងដែនដីកម្ពុជាក្រោមសព្វថ្ងៃលើតំបន់ស្ថានីយ៍ប្រវត្តិសាស្ត្រយុគថ្មរំលីងដែលអ្នកដើរសមុទ្រជាតិឥណ្ឌាបានស្គាល់ជាយូរណាស់មកហើយ។ កំពង់ផែនេះមិនមែនគ្រាន់តែទទួលសំពៅធំៗពីប្រទេសចិន ម៉ាឡាយូ និងឥណ្ឌាប៉ុណ្ណោះទេ ព្រមទាំងទទួលនាវាសមុទ្ទពីចក្រភពរ៉ូម៉ាំងស្ថិតត្រង់ព្រំប្រទល់សមុទ្ទក្រហមថែមទៀតផង។ នៅកំពង់ផែអូកែវ គេបានរកឃើញត្រាអក្សរ សំស្ក្រឹត មេដាយមាស មានចុះកាលបរិច្ឆេទឆ្នាំ១៥២ មានរូបសំណាកព្រះចៅ អង្គសូណាំង និងចម្លាក់ផ្សេងៗមកពីសមុទ្ទ មេឌីទែរ៉ានេទៀតផង។ បើតាមឯកសារចិនបានបញ្ជាក់ឲ្យដឹងថា ភូមិខ្មែរព័ទ្ធជុំវិញ ដោយកំពែងធ្វើអំពីដី មានគូទឹក និងស្រះធំៗព័ទ្ធជុំវិញដែលមានចិញ្ចឹមក្រពើជាច្រើនផង។ នៅក្នុង បរិវេណភូមិមានស្រះទឹកសម្រាប់ប្រើរួមគ្នា ផ្ទះសង់អំពីឈើ បន្ដើតខ្ពស់

---

[67] ឯ-ដ

[68] KHMER HISTORIES (History of Cambodia #...) ៖ នាទីប្រវត្តិសាស្ត្រនៅអំឡុងឆ្នាំ២០១០ និង ២០១១ និងត្រូវបានចាក់ផ្សាយឡើងក្នុងគ្រាបន្តបន្ទាប់មក។

ផុត ពីដីហើយប្រក់ស្លឹក[69]។ មនុស្សរស់ក្នុងសម័យអាណាចក្រភ្នំមានសម្បុរខ្មៅ សក់រួញអង្គាសដីច្រើនលែងខ្លួនទទេ។ អ្នកស្រុកជម្មតា ស្លៀកសារ៉ុង ឬសំពត់អំ បោះដើរជើងទទេ។ អ្នកមាន និងមន្ត្រីស្លៀកសំពត់សំឡុយ ឬចងក្បិន សំពត់ ចរបាប់ មានពាក់ស្បែកជើងផង។មនុស្សសម័យនោះទាំងអស់និយមចោះត្រចៀក ដើម្បីពាក់ក្រវិលរយ៉ាទំហុ ក្រសាល់ត្រចៀក។ គេចូលចិត្តល្បែងប្រជល់ មាន់ ប្រជល់ជ្រូក ហើយមានការប៉ិនប្រសប់ក្នុងសិប្បកម្មតម្បាញវៃអំបោះ និងជាងចម្លាក់ប្រាក់ស្ពាន់ ជំនាញជាងទង គ្រឿងអលង្ការមាសថែមទៀតផង។ មនុស្សនៅអាណាចក្រនគរភ្នំត្រង់ណាស់ គ្មានចិត្តលោភលន់ ហើយមិនចេះលួចទេ។ បើមានទំនាស់ ឬក្តីក្តាំគ្នាកើតឡើង គេប្រើប្រាស់វិធីអស្ចារ្យដើម្បីរកសេចក្តីពិត[70](រកយុត្តិធម៌)។ កាលណាមានបាត់របស់អ្វីមួយ គេយកបាយពំនូតទៅដាក់នៅចំពោះព្រះភក្ត្រទេវតា រួចគេបួងសួងសុំឲ្យព្រះអង្គបង្ហាញមនុស្សទុច្ចរិត។ ស្អែកឡើង គេយកបាយពំនូតនោះទៅឲ្យមនុស្សសង្ស័យបរិភោគ។ អ្នកដែលបានប្រព្រឹត្តត្រូវបរិភោគ[71]។ អ្នកដែលបានប្រព្រឹត្តបទល្មើសនឹងមានឈាមហូរជាក់ស្តែង។ រីឯអ្នកសុច្ចរិតវិញ អាចហូបបាយនោះបានដោយស្រួល។ ម៉្យាងវិញទៀត បើមានជនជាប់ចោទពីបទផ្សេងៗគេឲ្យជននោះអត់បាយបីថ្ងៃរួចតម្រូវឲ្យជននោះលូកយក

[69] ឯ-ដ

[70] ឯ-ដ

[71] ឯ-ដ

របស់ផ្សេងៗមានពងមាន់ឬ ជញ្ជៀន មាសចេញពីផ្ទាំង ឬខ្ទះទឹកកំពុងពុះ ឬក៏ត្រូវកាន់ផ្លែពូថៅ ឬដែកដែលដុតឡើងក្រហមដើរប្រាំពីរជំហាន។ បើមានកំហុសមែន ដៃជននោះនឹងរលាករលួយ។ ផ្ទុយទៅវិញ បើមិនបានប្រព្រឹត្តខុស គ្មានហ្មងសៅអ្វីទាំងអស់។ នៅអាណាចក្រនគរភ្នំ គេមិននិយមធ្វើគុកដាក់មនុស្សទេ។ បើកាលណាមានកំហុសស្រាលគេពិន័យជននោះតែបើមានកំហុសធ្ងន់ធ្ងរ គេយកមនុស្សនោះទៅឲ្យក្រពើ ឬសត្វសាហាវស៊ីតែម្តង[72]។ ក្នុងរយៈពេលបីថ្ងៃ បើសត្វនោះមិនស៊ីទេ គេចាត់ទុកថា អ្នកនោះគ្មានកំហុសហើយដោះលែងឲ្យរួចខ្លួន។ ដោយ សារបានទទួលឥទ្ធិពលពីឥណ្ឌាដល់ទៅពីរដង គឺដើមសតវត្សរ៍ទី១ និងសតវត្សរ៍ទី៥ របបនយោបាយអាណាចក្រភ្នំ គឺរាជានិយមបែបឥណ្ឌា។ មហារាជ្យមាននាមជាស្តេចក្រុងភ្នំ ឬក្រុងហ្វូណន។ សោយរាជ្យលើអាណាចក្រដែលមានសាមន្តរដ្ឋ ឬរដ្ឋចំណុះជាច្រើន ក្នុងនោះមានទាំងសាមន្តរដ្ឋចេនឡាទៀតផង។ ព្រះរាជាគង់ក្នុងព្រះរាជវាំងដែលមានតំណាក់ច្រើនជាន់មានរបងជុំវិញ ក្នុងពេលប្រទានសវនាការ។ ព្រះអង្គគង់ផ្ទាល់ព្រះទែនផ្តេក ជង្គង់ឆ្វេង បញ្ឈរជង្គង់ស្តាំដូចកាយវិការរូបចម្លាក់ស្តេចគម្លង់សព្វថ្ងៃ(ដាក់រូបព្រះគម្លង់)។ មានពានមាស និងជើងមាស ដុតឈើក្រអូបដាក់លើកំរាលពីខាងមុខ ហើយមានព្រះរូបព្រះរាជសង្ហាតម្កល់នៅចំចន្លោះកណ្តាលនៃពានមាសនោះផង។ ព្រះរាជាទ្រង់យាងទៅណាមកណា

[72] ឯ-ដ

ដោយដំរី ដោយមានក្បួនដង្ហែអឹកធឹកពីនាម៉ឺនសព្វមុខមន្ត្រីស្រីស្នំបរិពារផង។ ពន្ធដារត្រូវបង់ជាមាស ប្រាក់ គុជ ឬគ្រឿងក្រអូបផ្សេងៗ។ សង្គមអាណាចក្រភ្នំ ជាសង្គម មេនិយមគឺគេទុកស្ត្រីជាធំក្នុងគ្រួសារផងក្នុងសង្គមផង ការកសាងគ្រួសារគឺស្ត្រីដណ្តឹងប្រុស[73]។

## ក-វិស័យសេដ្ឋកិច្ច

ខាងវិស័យសេដ្ឋកិច្ចវិញ សម័យនគរភ្នំមានឈ្មោះថា ថ្កុំថ្កើងណាស់ កសិកម្មមានការរីកចម្រើនដោយសារមានជោគជ័យក្នុងនយោបាយទឹករហូតដល់ឯកសារចិនកត់ត្រាថា គេព្រួសមួយឆ្នាំគេច្រូតបានបីរដូវ។

## ខ-វិស័យពាណិជ្ជកម្ម

ខាងពាណិជ្ជកម្ម ក្រៅពីកំពង់ផែអូរកែវ ដែលជាកំពង់ផែអន្តរជាតិតែមួយគត់ទទួលនាវាផ្ទុកទំនិញធំៗ។ អាណាចក្រនគរភ្នំមានបច្ចេកទេស ធ្វើនាវា ធំៗដែលតាមឯកសារចិនបានបញ្ជាក់ថា សំពៅមានប្រវែង៣០ម៉ែត្រ ដែលមានក្បាល និងកន្សៃមានរាងជាក្បាល និងកន្ទុយត្រីទៀតផង។ ខាងវិស័យអប់រំមានការរីកចម្រើនច្រើន ពីព្រោះឯកសារចិនបានឲ្យដឹងថា អាណាចក្រភ្នំមានសៀវភៅ និងកន្លែងរក្សាទុកបណ្ណាសារ។ ភាសាខ្មែរជាភាសានិយាយទូទៅ និងភាសាសំស្ក្រឹត ជាភាសាផ្លូវការ[74]។

---

[73] ឯ-ដ

[74] ឯ-ដ

## គ-វិស័យសាសនា

នគរភ្នំបានកាន់សាសនាធំៗមកពីឥណ្ឌា គឺព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនា។ ជំនឿលើអារក្សអ្នកតាជាជំនឿរបស់នគរភ្នំ ហើយនគរភ្នំជឿជាមួយគ្នា។ ចំណែកការទុកដាក់សពវិញមានពិធីបូជាព្រះសពព្រះមហាក្សត្រ គឺមានរយៈពេល៧ថ្ងៃក្រោយពីពេលចូលទិវង្គតសពត្រូវត្រូវរុំយ៉ាងស្អាត ហើយដង្ហែទៅមាត់ទន្លេដែលមានតូរ្យតន្ត្រីប្រគុំ និងរបាំសក្ការៈកំដរផង[75]។ ពិធីរំលាយព្រះសពគឺត្រូវដាក់លើគំនរអុសបូជាផ្ទាល់ រីឯព្រះអដ្ឋិធាតុយកទៅកម្កល់ទុកក្នុងកោដ្ឋមាស។ ចំពោះព្រះអដ្ឋិគេយកទៅបាចក្នុងទឹកទន្លេ ឬសមុទ្ទ។ សពពួកមន្ត្រីធំៗ ត្រូវបូជាក្នុងរយៈពេលបីថ្ងៃក្រោយពេលស្លាប់ ហើយអដ្ឋិធាតុត្រូវដាក់ក្នុងកោដ្ឋប្រាក់ ឬទម្លាក់ក្នុងទឹកទន្លេ។ ចំណែកជនធម្មតាវិញពិធីទុកដាក់សពនេះមានបួនបែបគឺ៖ បូជាដោយភ្លើង ឬកប់ក្នុងដី ឬបោះចោលក្នុងទឹក ឬដាក់ហាលចោលកណ្តាលវាលទុកឲ្យសត្វបរិភោគជាចំណី។ ឯការកាន់ទុក្ខ គឺគេកោរសក់ និងកោរពុកមាត់[76]។

## ឃ-វិស័យស្ថាបត្យកម្ម និងចម្លាក់

ក្រៅពីប្រាសាទដែលសាងសង់ដោយលុងភ្នំ គ្មានប្រាសាទណាមួយនៅគង់វង្សល្អទេ។ គេសន្និដ្ឋានថា ប្រាសាទទាំងឡាយនៅក្នុងសម័យនោះ ក

[75] ឯ-ដ

[76] ឯ-ដ

សាងដោយឥដ្ឋ ហើយគេបានរកឃើញខឿនសំណង់ផ្សេងៗធ្វើអំពីឥដ្ឋនៅកំពង់ផែអូរកែវ និងនៅអង្គរបុរី។ ខាងសិល្បៈបដិមាគេបានរកឃើញទេវរូប និងទេវរូបជាច្រើននៅតំបន់ភ្នំដា ស្រុកព្រៃកប្បាស[77] ខេត្តតាកែវ។ ដូចជាព្រះពុទ្ធរូបនៅវត្តរំលក រូបព្រះវិស្ណុ ព្រះពលរាម ព្រះកល់កិន ព្រះគិស្នាគោវនៈ។ ស្នាដៃទាំងអស់នោះនៅមានលក្ខណៈជាឥណ្ឌានៅឡើយ។ ពោលគឺរូបទាំងនោះមានរាងជាត់ៗ កាច់ចង្កេះ ឬចន្ទល់ទ្រថែមទៀតផង[78]។ ជារួមយើងឃើញថា ការលើកឡើងអំពីប្រវត្តិកកើតនៃប្រទេសកម្ពុជានៅក្នុងសៀវភៅនេះគឺជាការរំលឹកឲ្យដឹងថាតើរឿងរ៉ាវអ្វីខ្លះដែលបានកើតឡើងនាសម័យនោះ និងជំនឿទំនៀមទម្លាប់អ្វីខ្លះដែលប្រជាពលរដ្ឋខ្មែរយើងនៅប្រកាន់ខ្ជាប់រហូតមកដល់សព្វថ្ងៃនេះ ជាពិសេស ការជឿទៅលើព្រលឹងបុព្វបុរសដូនតា ឬសាសនាដោយប្រៀបធៀបជាមួយសង្គមខ្មែរនិយាយជារួម និងដោយឡែកអ្នកភូមិទាំងបីដែលជាកម្មវត្ថុនៃការសិក្សានេះ។

---

[77] សព្វថ្ងៃស្ថិតក្នុងស្រុកអង្គរបុរី ខេត្តតាកែវ។

[78] KHMER HISTORIES (History of Cambodia #...) ៖ នាទីប្រវត្តិសាស្ត្រនៅអំឡុងឆ្នាំ២០១០ និង ២០១១ និងត្រូវបានចាក់ផ្សាយឡើងក្នុងគ្រាបន្តបន្ទាប់មក។

# ជំពូកទី២
# អរិយធម៌អាស៊ីអាគ្នេយ៍-អំពីបណ្ដាប្រជាជាតិដែលរស់នៅជុំវិញអាណាចក្រខ្មែរ[79]

លោក សេង ឌីណា អ្នកកាសែតវិទ្យុបារាំងអន្តរជាតិបានរៀបរាប់ថា យើងបាននិយាយរួចហើយអំពីអរិយធម៌សម័យនគរភ្នំ ជាមួយគ្នានេះយើងសូមភ្ជាប់ព័ត៌មានខ្លះជាមួយនឹងអរិយធម៌ នៃអាស៊ីអាគ្នេយ៍ចេតនាបង្ហាញដល់ប្រិយមិត្តអ្នកអានអំពីបណ្ដាប្រជាជាតិដែលរស់អាណាចក្រខ្មែរ។ នៅចន្លោះសតវត្សទី៩ដល់ពាក់កណ្ដាលសតវត្សទី១៥នៃគ្រឹស្តសករាជ អាណាចក្រខ្មែរជាមហាអំណាចមួយដ៏ធំនៃតំបន់អាស៊ីអាគ្នេយ៍ដោយកាន់កាប់ទឹកដីមួយយ៉ាងធំគ្របដណ្ដប់ទឹកដីនៃប្រទេសកម្ពុជា ថៃ ឡាវ និងប៉ែកខាងត្បូងនៃប្រទេសវៀតណាមបច្ចុប្បន្ន។ នៅខាងកើតអាណាចក្រខ្មែរ គេឃើញមានចាមនៅនគរចំប៉ា។ ពួកចាមមានដើមកំណើតមកពីម៉ាឡេស៊ី ឬជ្វាដែលបានមកបោះទីតាំងនៅតាមបណ្ដោយឆ្នេរប៉ែកខាងកើតតំបន់ឥណ្ឌូចិនហើយបានបង្កើតទៅជារដ្ឋមួយឡើងនៅចន្លោះសតវត្សទី២ទៅសតវត្សទី១មុនគ.ស[80]។ នគរចំប៉ាបានចាប់កំណើតមុននគរភ្នំ ឬហ្វូណានទៅទៀត។ ប៉ុន្តែគិតចាប់តាំងពីសតវត្ស៍ទី៣មក នគរចំប៉ាមានការរីកចម្រើនខ្សោយជាងនគរហ្វូណាន ជា

---

[79] សេង ឌីណា៖ ប្រវត្តិសាស្ត្រពិភពលោក អរិយធម៌អាស៊ីអាគ្នេយ៍ អំពីបណ្ដាប្រជាជាតិដែលរស់នៅជុំវិញអាណាចក្រខ្មែរ ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោង៧៖០០នាទីយប់។

[80] ឯ-ដ

ពិសេសក្នុងផ្នែកបច្ចេកទេសក្នុងការធ្វើសឹកសង្គ្រាម។ នគរចំប៉ា និងនគរខ្មែរ គឺជាគូប្រជែងនឹងគ្នា ហើយតែងតែធ្វើសង្គ្រាមនឹងគ្នាជារឿយៗ ក៏ប៉ុន្តែសង្គ្រាមធំជាងគេ ដែលកំណត់ជោគវាសនា និងកែប្រែប្រវត្តិសាស្រ្តរបស់ពួកចាម គឺសង្គ្រាមទល់នឹងនគរអណ្ណាម ឬដាយវៀត។ នគរអណ្ណាមមានទីតាំងស្ថិតនៅខាងជើងនគរចំប៉ា ក៏ប៉ុន្តែចាប់តាំងពីសតវត្សទី១មុនគ្រឹស្តសករាជរហូតដល់សតវត្សទី១០នៃគ.សនៅក្នុងរយៈពេលជាង១០០០ឆ្នាំ អាណ្ណាមស្ថិតនៅក្រោមការកាន់កាប់របស់ចិន។ ពេលគឺអាណ្ណាមគ្រាន់តែជាអាណាខេត្តមួយប៉ុណ្ណោះរបស់ចិនហើយពេលខ្លះចិនបានហៅអាណ្ណាមថាណាវវៀតរហូតដល់ឆ្នាំ៩៣៩ពួកអាណ្ណាមបានទាមទារឯករាជ្យបង្កើតទៅជានគរដាច់ពីចិនក៏ប៉ុន្តែមិនយូរប៉ុន្មាន នគរថ្មីនេះនៅតែធ្លាក់ទៅជានគរចំណុះរបស់ចិនវិញដដែល។ ចិនដែលចាប់ពីឆ្នាំ៩៦០ដល់ឆ្នាំ១២៧៩ស្ថិតនៅក្រោមការគ្រប់គ្រងរបស់រាជវង្សសុង ។នៅក្នុងការព្យាយាមរើបំរះពីនឹមអាណានិគមរបស់ចិន ពួកអាណ្ណាមតែងតែបានងើបឡើងបះបោរធ្វើសង្គ្រាមទល់នឹងកងទ័ពចិនជារឿយៗ។ ក្រៅពីការធ្វើសង្គ្រាមជាមួយចិនទៅទិសខាងជើង ទៅទិសខាងត្បូងឯណោះវិញពួកអាណ្ណាម និងពួកចាមក៏តែងតែធ្វើសង្គ្រាមឈ្លានពានគ្នាទៅវិញទៅមកឥតឈប់ឈរដែរ។ នៅខាងលិចអាណ្ណាម និងភាគខាងជើងនគរខ្មែរមានប្រជាជនមួយទៀតគឺលាវ។ លាវធ្លាប់ជានគរឯករាជ្យមួយនៅខាងជើងនគរហ្វូណន ប៉ុន្តែបន្តិចម្តងៗប្រទេសលាវត្រូវធ្លាក់ទៅក្រោមការត្រួតត្រារបស់ខ្មែរដោយដំបូងត្រឹមជានគរចំណុះ ហើយបន្ទាប់មកទៀតនៅក្នុងសម័យអង្គរដែនដីនៃអាណាចក្រលាវត្រូវបានអាណាចក្រខ្មែរវាតទីកាន់កាប់ទាំងស្រុងរហូតដល់សតវត្សទី១៤ទើប ប្រទេសលាវចាប់ផ្តើមលេចរូបរាងសាជាថ្មីឡើងវិញ។ ក៏ប៉ុន្តែ លាវស្ថិតនៅតែជាប្រទេសទន់ខ្សោយមួយដោយទទួលរងនូវការគំរាម

កំហែងជាប្រចាំពីសំណាក់ប្រទេសជិតខាង។ នៅខាងលិចអាណាចក្រខ្មែរឯណោះវិញ[81] មានប្រទេសមួយដែលគេហៅថា ស្រុកមន មានទីតាំងនៅត្រង់ប្រទេសភូមា និងថៃសព្វថ្ងៃ។ កាលពីសម័យដើម ស្រុកមន និងស្រុកខ្មែរមានព្រំប្រទល់ជាប់គ្នាត្រង់ប្រទេសភូមា និងថៃបច្ចុប្បន្ន។ ចំណែកឯប្រទេសថៃវិញនៅមិនទាន់មានរូបរាងទេនៅពេលនោះ។ នៅក្នុងសិលាចារឹក គេឃើញមានការកត់ត្រាពីវត្តមានរបស់ពួកថៃ ឬសៀមនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ប្រហែលជាចាប់តាំងពីសតវត្សរ៍ទី១២មក។ ពួកថៃ ឬសៀមកាលពីមុនរស់នៅក្នុងខេត្តយូណាន់ ប្រទេសចិន ហើយបានចាប់ផ្តើមធ្វើអន្តោប្រវេសន៍ចាក់ចុះមកទិសខាងត្បូងបន្តិចម្តងៗដោយចាប់ផ្តើមតាំងពីសតវត្សរ៍ទី៩។ ពីដំបូងគេឃើញពួកថៃ ឬសៀមបានចុះមកតាំងទីលំនៅ ៗត្រង់ប្រទេសលាវសព្វថ្ងៃ និងនៅឈៀងម៉ៃ។ ចំនួនពួកសៀម ឬថៃនៅប៉ែកខាងជើងនៃខេត្តអាស៊ីអាគ្នេយ៍មានកាន់តែច្រើនឡើងៗហើយពួកគេក៏បានបង្កើតទៅជានគរតូចៗមួយចំនួនដូចជា សុខោទ័យ ឈៀងសែន ឈៀងម៉ៃ ស្រែមួយលានអយុធ្យាជាដើម។ ក៏ប៉ុន្តែ ពីដំបូងនគរទាំងអស់នេះគឺជានគរទន់ខ្សោយដោយស្ថិតនៅក្រោមឥទ្ធិពលរបស់អាណាចក្រខ្មែរ[82]។ នៅពេលអាណាចក្រខ្មែរចាប់ផ្តើមធ្លាក់ចុះ

---

[81] ក្រោយពីបានស្តាប់យ៉ាងយកចិត្តទុកដាក់ ខ្ញុំបានតាំងសំណួរមួយទៅអ្នកស្រាវជ្រាវ និងធ្វើអត្ថាធិប្បាយលោក សេង ឌីណា៖ ប្រវត្តិសាស្ត្រពិភពលោក អរិយធម៌អាស៊ីអាគ្នេយ៍ អំពីបណ្តាប្រជាជាតិដែលរស់នៅជុំវិញអាណាចក្រខ្មែរ ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោង៧៖០០នាទីយប់តាមរយៈបណ្តាញសង្គមហ្វេសប៊ុករបស់កលោកថា តើឃ្លានេះជាការភ័ន្តច្រឡំ ឬយ៉ាងណា? លោកបានឆ្លើយបញ្ជាក់មកខ្ញុំថា ..ខាងកើត..រលោកមានភ័ន្តច្រឡំ តាមពិតត្រូវអានថា **នៅខាងលិចអាណាចក្រខ្មែរឯណោះវិញ** ទៅវិញទេ។

[82] សេង ឌីណា៖ ប្រវត្តិសាស្ត្រពិភពលោក អរិយធម៌អាស៊ីអាគ្នេយ៍ អំពីបណ្តាប្រជាជាតិដែលរស់នៅជុំវិញអាណាចក្រខ្មែរ ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោង៧៖០០នាទីយប់។

ខ្សោយនៅចុងសម័យអង្គរ នគររបស់ពួកថៃ ឬសៀមក៏បានពង្រឹងប្រទេសរបស់ខ្លួនបន្តិចម្តងៗឲ្យទៅជានគរ ដែលមានអធិបតេយ្យភាពពេញលេញដោយចាប់ផ្តើមពីសុខោទ័យនៅអំឡុងសតវត្សរ៍ទី១៣ បន្ទាប់មកទៀត នៅក្នុងសតវត្សរ៍ទី១៤។ ក្រោយពីស្តេចរាមកំហែងចូលទិវង្គត សុខោទ័យត្រូវធ្លាក់ចុះដុនដាប ហើយត្រូវធ្លាក់ក្រោមការត្រួតត្រារបស់នគរសៀមមួយទៀតគឺអយុធ្យា ៗនេះហើយដែលបានពង្រីកអំណាចនៃនគរសៀម ហើយក៏ជាគូប្រជែងដ៏ធំបំផុតរបស់អាណាចក្រខ្មែរនៅចុងសម័យអង្គរ។ ងាកទៅប៉ែកខាងសមុទ្ទឯណោះវិញនៃប៉ែកខាងត្បូងនៃអាណាចក្រខ្មែរ គេឃើញមានអាណាចក្រដ៏ធំមួយ គឺអាណាចក្រស្រីវិជ័យរបស់ពួកម៉ាឡេ ដែលមានទីតាំងធំនៅលើកោះស៊ូម៉ាត្រា ក៏ប៉ុន្តែមានដែនដីគ្របដណ្តប់ទៅដល់កោះជ្វា កោះបង់នេវ៉ូ[83] និងម៉ាឡាកានៅចុងខាងត្បូងនៃឧបទ្វីបម៉ាឡេ។ ពោលគឺពាសពេញនៃប្រទេសម៉ាឡេស៊ី ឥណ្ឌូនេស៊ី និងប្រ៊ុយណេសព្វថ្ងៃ។ នៅអំឡុងសតវត្សទី១៣ អាណាចក្រក្រុងវិជ័យបានធ្លាក់ចុះទន់ខ្សោយរហូតទៅជានគរចំណុះឲ្យអាណាចក្រខ្មែរ ហើយក្រោយមកទៀតក្លាយទៅជានគរចំណុះរបស់សុខោទ័យរបស់សៀម។ នៅដើមសតវត្សទី១៥ អាណាចក្រស្រីវិជ័យត្រូវដួលរលំដោយបែកខ្ញែកទៅជានគរតូចៗផ្សេងៗដាច់ពីគ្នា។

**១-ទំនាក់ទំនងរវាងខ្មែរ និងលាវ (សង្គ្រាមខ្មែរ-លាវ)**

មុននឹងចូលដល់សាច់រឿងត្រូវនឹងចំណងជើងខាងលើ យើងសូមបញ្ជាក់ពាក្យថា លាវ ឬឡាវបន្តិច។ ពាក្យសម្គាល់ជាទូទៅនៅក្នុងភាសាខ្មែរ

[83] ចម្លងតាមសំឡេងដើមនៃការអត្ថាធិប្បាយរបស់វិទ្យុបារាំងអន្តរជាតិ(RFI ) ថ្ងៃទី២១ ខែមីនា ឆ្នាំ ២០១៧។

សម្រាប់សម្គាល់ជនជាតិឡាវនៅក្នុងប្រទេស ពាក្យ ឡាវ ឬ លាវ។ នៅក្នុងសម័យសង្គមរាស្ត្រនិយម គេប្រើពាក្យ លាវ រីឯពាក្យ ឡាវ គឺគេប្រើប្រាស់ចាប់តាំងពីសម័យកាលខ្មែរក្រហមរហូតមកដល់សព្វថ្ងៃដោយការគ្រាប់សូរដោយត្រង់ៗពីភាសាឡាវ។ សព្វថ្ងៃនេះ ពាក្យ ឡាវ នៅក្នុងភាសាខ្មែរគេប្រើសម្រាប់សម្គាល់ឈ្មោះប្រទេស ក៏ដូចជាជនជាតិដែលជាពលរដ្ឋនៅក្នុងប្រទេសនោះ ដូចជា ជនជាតិឡាវ ប្រទេសឡាវ ជាដើម។ សព្វថ្ងៃពាក្យ លាវ ជាទូទៅគេប្រើនៅក្នុងភាសានិយាយ។ រីឯពាក្យថា ឡាវ វិញ គេប្រើនៅក្នុងភាសាផ្លូវការ។ ទោះជាយ៉ាងណា យើងបានឮសូរជនជាតិឡាវ នៅក្នុងប្រទេសកម្ពុជាហៅខ្លួនឯងថាលាវ ជាជាងហៅឡាវ[84]។ ប្រសិនបើគេនិយាយអំពីទំនាក់ទំនងរវាងខ្មែរនិងលាវយើងអាចរៀបរាប់បានច្រើនសន្ធឹកណាស់ក្នុងប្រវត្តិសាស្ត្រនៃប្រទេសភូមិផងមួយនេះ។ សម្រាប់បច្ចុប្បន្នកាលនេះក្នុងបណ្ដាខេត្តភាគឥសាន្ត និងភាគខាងជើងនៃប្រទេសកម្ពុជាមានព្រំប្រទល់ជាប់ប្រទេសឡាវ គឺខេត្តស្ទឹងត្រែងជាប់ប្រទេសឡាវជាមួយនឹងខេត្តចំប៉ាសាក់ និងខេត្តអាតាពើ។ ខេត្តរតនគិរីជាប់ប្រទេសឡាវជាមួយនឹងខេត្តអាតាពើខេត្តព្រះវិហារជាប់ខេត្តចំប៉ាសាក់ និងប្រទេសថៃ។ រីឯខេត្តមណ្ឌលគិរីជាប់ប្រទេសវៀតណាម។

ទោះបីយ៉ាងណាក្ដី យើងនឹងដកស្រង់យកតែវគ្គខ្លះមកអត្ថាធិប្បាយតែប៉ុណ្ណោះ។ក្នុងរាជនៃផែនដីរបស់ព្រះលំពង្សរាជាពីគ.ស១៣៤៦ ដល់គ.ស ១៣៥១ និយាយពីការកកើតរដ្ឋសៀម និងលាវ។

---

[84] សារព័ត៌មានគរធំប្រចាំថ្ងៃ ឆ្នាំទី២១ លេខ៩៣៤ ចេញផ្សាយថ្ងៃសៅរ៍ទី០៥ ខែកញ្ញា ឆ្នាំ២០១៥ ទំព័រ១៤។

លាវ ឬឡាវ សរសេរជាភាសាអង់គ្លេសថា Laos ឬ Laos People´s Democratic Republic (Lao PDR)។ ប្រទេសនេះមានព្រំប្រទល់ជាប់ភូមា ចិន វៀតណាម ថៃ និងកម្ពុជា។

អត្ថបទមហាបុរសខ្មែរបានរៀបរាប់ថា ព្រះលំពង្សរាជា ជាព្រះរាជបុត្រច្បងរបស់ព្រះបាទ សុទ្ធានរាជា ទ្រង់ឡើងសោយរាជស្នងព្រះវររាជបិតាក្នុងឆ្នាំខាល ទោស័ក ព.ស១៨៩០ គ.ស ១៣៤៦ ម.ស ១២៦៨ ច.ស ៧០៨ ក្នុងព្រះជន្មាយុ៥៤ព្រះវស្សា[85]។...នេះនឹងស្រដីទៅខាងស្យាម( Siam )ប្រទេសគឺប្រទេសសៀមនោះវិញ[86]។

ការដូរឈ្មោះពីសៀមទៅថៃ៖ឆ្នាំ១៩៣២...នាថ្ងៃទី២៤ខែមិថុនាព្រលឹមស្រាងៗ ជនានុជននៃរាជធានីបាងកក បានជួបប្រទះនឹងភាពស្រឡាំងកាំងភ្ញាក់ផ្អើលយ៉ាងខ្លាំងដោយពុំទាន់យល់នូវព្រឹត្តិការណ៍មួយដ៏ចម្លែកដែលទើបតែនឹងកើតមានឡើងកាលពីក្នុងរាត្រីកន្លងទៅហើយ។ មហាជនមានការភាន់ភាំងខ្លាំងណាស់ទៅទៀត ព្រោះមុនព្រឹត្តិការណ៍នេះនៅរដ្ឋធានីបាងកកគេពុំបានសង្កេតឃើញហេតុ ឬអ្វីដែលគួរឲ្យកត់សម្គាល់ ជាពិសេសក៏ទេដែរ។ ស្ថានការណ៍នយោបាយក្នុងប្រទេសសៀមទាំងមូលហាក់ដូចជាស្ងប់ស្ងាត់គួរជាទីកក់ក្តៅចំពោះមជ្ឈដ្ឋានរដ្ឋាភិបាល។

ព្រះចៅប្រាជាធិប៉ុក ( Prajadhipok ) ព្រះមហាក្សត្រសៀម ទ្រង់ទុកព្រះទ័យខ្លាំងណាស់ រហូតទ្រង់ចាកចេញពីព្រះរាជធានីទៅគងប្រថាប់នៅនា

---

[85] អេង សុត ៖ មហាបុរសខ្មែរ ភាគ១ និងភាគ២ ទំព័រ១៤ ឆ្នាំ១៩២៩

[86] អេង សុត ៖ មហាបុរសខ្មែរ ភាគ១ និងភាគ២ ទំព័រ១៥ ឆ្នាំ១៩២៩

មាត់សមុទ្រក្នុងព្រះរាជដំណាក់ហួហ៊ីន ដែលព្រះអង្គធ្លាប់យាងមកកម្សាន្ត រាល់រដូវក្តៅ។ មុនថ្ងៃនេះមួយថ្ងៃ គឺថ្ងៃទី២៣ ខែមិថុនា ព្រះអង្គម្ចាស់ ណាខន សាវ៉ាន់ ជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃទទួលបន្ទុកដឹកនាំរាជរដ្ឋាភិបាលជំនួសព្រះចៅនៅពេលដែលព្រះចៅគង់ប្រថាប់នៅមាត់សមុទ្រឯណោះបានដឹងល្ងិចល្ងៀងបន្តិចបន្តួចដែរថា គម្រោងការក្បត់មួយកំពុងតែត្រូវគេរៀបចំនៅរាជធានីបាងកក តែអ្នកអង្គម្ចាស់ទុកព្រះទ័យពេករហូតដល់មិនយកចិត្តទុកដាក់ចាប់អារម្មណ៍ទៅលើដំណឹងនេះបន្តិចឡើយ។ តែការទុកចិត្តរបស់ព្រះចៅរាជាធិប៉ុកក្តីឬរបស់អ្នកអង្គម្ចាស់ណាខនសាវ៉ាន់ ក្តី ឬក៏ភាពស្ងប់ស្ងាត់ឥតសៅហ្មងតាមដងវិថីនានាក្នុងក្រុងបាងកកក្តី សុទ្ធសឹងជាការភូតភរកុហកទាំង អស់។ ការពិតគឺព្រឹកនេះហើយដែលបដិវត្តន៍មួយជាប្រវត្តិសាស្ត្រត្រូវបានផ្ទុះឡើង។ឯប្រវត្តិសាស្ត្រប្រជាជាតិសៀមផ្ទុយពីឆន្ទៈរបស់ព្រះរាជវង្សចក្រីក៏ចាប់ផ្តើមបើកទំព័រប្រវត្តិសាស្ត្រថ្មីមួយទៀត ស្របទៅតាមចលនាទូទៅនៃប្រទេសទាំងឡាយក្នុងភូមិភាគអាស៊ីប៉ែកអាគ្នេយ៍។ កងពលថ្មើរជើងប្រដាប់ដោយអាវុធគ្រប់ដៃ កងទ័ពសេះ មានកងកាំភ្លើងធំ និងរថក្រោះទំនើបច្រើនគ្រឿងគាំទ្រផង កំពុងតែឡោមព័ទ្ធព្រះរាជវាំង មន្ទីរតុលាការជាន់ខ្ពស់ ព្រមទាំងគ្រប់ទីស្តីការរដ្ឋមន្ត្រីសំខាន់ៗទាំងប៉ុន្មាន។ ចំណែកឯអ្នកអង្គម្ចាស់មួយចំនួនជាសមាជិកនៃព្រះរាជវង្សានុវង្ស និងជាអ្នកជិតជិតនឹងព្រះចៅផងបានត្រូវកងទ័ពចាប់យកជាឈ្លើយ។ រដ្ឋប្រហារមួយទើបនឹងបានសម្រេចឡើងនៅរាជធានីបាងកកដែលជាស្នាដៃនៃអ្នកនយោបាយបញ្ញវន្តរួមគ្នាជាមួយនឹងនាយទាហាន និងមន្ត្រីរដ្ឋការមួយចំនួនបង្កបង្កើតជាអង្គការនយោបាយមួយក្រុមតូចដែលមានសមាជិក៥៣នាក់មានឈ្មោះថា គណបក្សប្រជារាស្ត្រ (Parti Du Peuple)។ ៣ ឬ៤ម៉ោងក្រោយមកគេបានបាចសាចខិតប័ណ្ណតាមដង

វិធីនានាក្នុងក្រុងបាងកក។ សេចក្តីក្នុងខិតប័ណ្ណនេះ ចោទប្រកាន់ព្រះមហាក្សត្រសៀមថា បានបណ្តោយព្រះរាជវង្សានុវង្សដណ្តើមប្រមូលយកអំណាចអស់ក្នុងជួររាជរដ្ឋាភិបាល ហើយបានចោទប្រកាន់រាជរដ្ឋាភិបាលទៀតថាបានប្រមាថប្រជារាស្ត្រដោយចាត់ទុកប្រជារាស្ត្រជាបាវបម្រើ ជាទាសករ ឬជាសត្វតិរច្ឆានពុំមានឋានៈ ជាមនុស្សឡើយ។ ឯកសារដដែលនេះ បាននិយាយពីការរៀបចំបង្កើតឲ្យមានរដ្ឋសភាមួយដែលនឹងប្រមូលផ្តុំអ្នកចេះដឹងជ្រៅជ្រះក្នុងកិច្ចការស្ថាបនាជាតិ ព្រមទាំងធ្វើការអញ្ជើញ(យាង)ព្រះចៅឲ្យទទួលរបបមួយថ្មីដែលមានរដ្ឋធម្មនុញ្ញជាស្ថាប័នធានារ៉ាប់រង។ ខិតប័ណ្ណនេះ បញ្ចប់ដោយការបញ្ជាក់យ៉ាងច្បាស់នូវកម្មវិធីនយោបាយមួយដែលមានទាំងអស់៦ខ។

១-សេរីភាព និងសមភាពប្រជារាស្ត្រក្នុងវិស័យនយោបាយ តុលាការ និងជំនួញ ត្រូវតែមានការធានារ៉ាប់រងពេញលេញ។

២-សន្តិភាព និងសេចក្តីស្ងប់ស្ងាត់ត្រូវតែមានការទទួលរ៉ាប់រង ការពារជូនដល់បុគ្គលគ្រប់រូបគ្មាននរណាធ្វើទុក្ខធ្វើទោសនរណា។

៣-នយោបាយសេដ្ឋកិច្ចមានលក្ខណៈជាតិសុទ្ធសាធ ត្រូវតែស្ថាបនាឡើងដើម្បីធានារ៉ាប់រងជូនដល់ពលរដ្ឋគ្រប់រូបនូវការងារមួយអាចចិញ្ចឹមជីវិតបានដោយផ្តល់កម្រៃគ្រប់គ្រាន់។

៤-បុគ្គលម្នាក់ៗត្រូវមានសិទ្ធិស្មើៗគ្នា គ្មានក្រុមណាត្រូវមានអភ័យឯកសិទ្ធិលើក្រុមណាមួយឡើយ។

៥-ប្រជារាស្ត្រ ត្រូវតែមានសេរីភាពពេញលេញ លើកលែងតែសេរីភាពណា ដែលមានលក្ខណៈផ្ទុយនឹងចំណុចទាំង៤ខាងលើ។

៦-ប្រជារាស្ត្រត្រូវតែបានទទួលនូវការអប់រំមួយដែលមានលក្ខណៈ

ពេញលេញគ្រប់គ្រាន់ជាដាច់ខាត។

ចំណុចសំខាន់ៗនៃការទាមទាររបស់ពួកអ្នកដឹកនាំធ្វើរដ្ឋប្រហារនេះត្រូវបានព្រះចៅ ប្រាជាធិប៉ុក (King Prajadhipok) យល់ព្រមទាំងអស់។ ហេតុនេះហើយបានជានៅពាក់កណ្តាលអាធ្រាត្រថ្ងៃទី២៥ ខែមិថុនា ព្រះចៅ និងបរិពារបានយាងត្រឡប់មកកាន់ព្រះរាជវាំងនៅក្រុងបាងកកវិញ។

ប៉ុន្តែរបបផ្តាច់ការនៃរាជានិយមក៏ត្រូវរំលំហើយ ដោយជំនួសមកវិញនូវរបបរាជានិយមថ្មីមួយទៀតដែលមានលក្ខណៈសភានិយមពឹងផ្អែកលើរដ្ឋធម្មនុញ្ញជាមូលដ្ឋានក៏ត្រូវបានគេស្ថាបនាឡើងជំនួសរបបចាស់សក្តិភូមិចាប់តាំងពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៣២នេះតទៅ។

គួររំលឹកដែរ ថៃបានប្តូរឈ្មោះពី**សៀម**មក**ថៃ** នៅឆ្នាំ១៩៣៩ គឺបន្ទាប់ពីព្រឹត្តិការណ៍នេះរយៈពេល៧ឆ្នាំក្រោយមក[87]។ ប្រទេសសៀមកាលពីដើមឡើយជាប្រទេសចំណុះក្រុងកម្ពុជាធិបតី។លុះមករាជ្យព្រះបាទ បុទុមសូរ្យវង្ស (ព្រះរាជាសៀម) ដោយទ្រង់យល់ឃើញថា ពញារោង នោះជា សម្តេចព្រះជេដ្ឋាផ្ទាល់ព្រះអង្គ ទ្រង់ក៏លើកប្រទេសចំណុះនោះឲ្យឡើងជាប្រទេសឯករាជ្យមួយ និងឲ្យមានទីក្រុងឈ្មោះសុខោទ័យ។ ក្នុងគ្រានោះ ពញារោងមានបុណ្យ មានអំណាចណាស់ ព្រះអង្គបានប្រាប់ប្រាមស្រុកជិតឆ្ងាយទាំងនោះឲ្យចុះចូលក្នុងអំណាចព្រះអង្គ។ ព្រះអង្គបានលើកស្រុកសុខោទ័យឡើង

[87] អត្ថបទហ្វេសប៊ុក៖ ការដូរឈ្មោះពីសៀមទៅថៃ៖ថ្ងៃទី២៤ ខែមិថុនាឆ្នាំ១៩៣២។ តាមវិទ្យុបារាំងអន្តរជាតិជាភាសាខ្មែរកាលពីយប់ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១៧បានផ្សាយថា ស្លាកអក្សរស្តីរដ្ឋប្រហារទម្លាក់រាជានិយមផ្តាច់ការទៅជារាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ដែលគេតម្កល់ទុកនៅកណ្តាលទីក្រុងបាងកកនោះត្រូវបានគេផ្លាស់ចេញ។ តាមសកម្មជនប្រជាធិបតេយ្យរបស់ថៃបានចោទប្រកាន់ថា នេះជាស្នាដៃរបស់អ្នករាជានិយមជ្រុលនិយម ។ ប៉ូលីសថៃបានប្រតិកម្មនឹងសកម្មភាពនេះថា ខ្លួនមិនបានដឹងថា អ្នកណាជាអ្នកធ្វើរឿងនេះទេ ហើយថាខ្លួនកំពុងធ្វើការស៊ើបអង្កេតអំពីបញ្ហានេះ។

ជានគរធំជាប្រទេសឯករាជ្យមួយ។...គ្រាក្រោយពីនោះមកទើបមានស្តេចលាវខាងស្រុកជាងរ៉ាយជាយោនក[88]ប្រទេសមួយដែលច្បាំងចាញ់គេ ហើយកៀរគ្រួលាវលើកចុះមកនៅក្នុងដែនដីសៀម។ ស្តេចលាវនេះ កាលបានប្រាប ប្រាម ព្រះរាជត្រកូល ពញារោង និងព្រះរាជវង្សានុវង្សទាំងនោះឲ្យចុះចូលព្រះអង្គហើយ ក៏ចុះមកតាំងទីបន្ទាយនៅស្រុកកំពែងពេជ្រ ហើយស្រុកនោះជានគរធំ ហើយប្រែភេទកៀសខ្លួនប្រើសំដីជាភាសាសៀមវិញ។ព្រះរាជវង្សនៃស្តេចជាង រ៉ាយនេះ សោយរាជ្យបានបួនតំណវង្សទើបមានរាស្ត្រម្នាក់ឈ្មោះ សែន តុំ បានកូនស្តេច លាវ ជាភរិយា។ ឈ្មោះនេះមានបុណ្យណាស់បានមកដណ្តើមរាជ្យពួកស្តេចលាវ **ជាងរ៉ាយ** នេះហើយសោយរាជ្យក្នុងដែនដីសៀមនោះ។ ស្តេចជ្រែករាជ្យនេះបានកសាងព្រះនគរជាថ្មី ដាក់នាមទីក្រុងនោះថាជាក្រុងទេពបុរី ហើយតាំងខ្លួនឯងជាស្តេចទ្រង់នាមជាព្រះសិរីជ័យជាងសែន។ ព្រះអង្គសោយរាជ្យបាន២០ឆ្នាំក៏អស់បុណ្យទៅ[89]។ នៅពីខាងជើងទឹកដីដែលពួកខ្មែរ (ឬ កម្ពុជ) រស់នៅមានប្រជាជនផ្សេងទៀត ដែលមិនសូវជាស៊ីវិល័យរស់នៅដែរពួកលាវដើមចាប់ពីខោនរហូតដល់ព្រំប្រទល់ខេត្តយុនណាន់ (Yunnan province)ប្រទេសចិន។ រឿងព្រេងរបស់លាវនិយាយថា ពួកវិប្រជា[90]នៅប្រទេសលាវ មានដើមកំណើតចេញមកពីបុព្វបុរសរួមតែមួយ។ ពាក្យថា វិប្រជាលាវនេះ មិនមែនសំដៅយកតែប្រជាជនលាវសព្វថ្ងៃប៉ុណ្ណោះ

---

[88] ជាប្រទេសដើមរបស់ព្រះបាទមិសិន្ទ គឺប្រទេសក្រើក្រ។ ប៉ុន្តែ ខ្មែរបុរាណហៅប្រទេសលាវខាងលិចថា យោនកប្រទេសដែរ។

[89] អេង សុត៖ ឯកសារមហាបុរសខ្មែរ ភាគ១-២ ទំព័រ១៤-១៥

[90] ក្រុមមនុស្សដែលមានការរៀបចំមិនទាន់គ្រប់សព្វ។

ទេ គឺរាប់បញ្ចូលទាំងប្រជាជនដែលរស់នៅក្នុងអាងទន្លេមេណាម[91]ខាងលើផងដែរ មុនពេលដែលពួកថៃមកដល់ពួកមួងនៅតុងកឹង ពួកម៉ង់ ពួកចារជី ឬពួកធួក មុនពេលជ័យជម្នះរបស់ពួកង៉ាមណន់ ឬអាណាមព្រមទាំងរដ្ឋសានមុនពេលពួកសានដែលមានដើមកំណើតថៃមកដល់។ តាមរឿងព្រេងទាំងនោះ មេៗរបស់ពួកគេមានឋានៈជាកូន ដែលមាននៅបន្តរហូតដល់សព្វថ្ងៃនៅលាវ ក៏ដូចជានៅថៃ និងកម្ពុជាផងដែរ គឺជាឋានៈមន្ត្រីថ្នាក់ទាប[92]។ ទំនាក់ទំនងធំមួយរវាង លាវ និងខ្មែរ គឺទាក់ទងនឹងការប្រជល់ដំរីនេះឯង។ តាមប្រវត្តិសាស្ត្រឲ្យដឹងថា នៅឆ្នាំ១៥៧២ ពេលដែលព្រះរាជាលាវនៃនគរឡានឆាង(Lan Xang[93]) ព្រះនាម **ព្រះចៅ ស៊ីសាតនា គណៈហុក** បានបបួលព្រះរាជាខ្មែរព្រះបាទ **ព្រះបរមរាជាទី៤** ដើម្បីជល់ដំរីគ្នាដាក់ព្រះនគរជាក្រយាតំណាំង។ ប្រសិនបើដំរីនគរណាចាញ់នគរនោះនឹងក្លាយជានគរចំណុះរបស់ដំរីដែលឈ្នះ។ ដោយ មិនព្រមចាញ់ប្រៀបព្រះរាជាលាវ ព្រះរាជាខ្មែរក៏ព្រមទទួលយកការបបួល ភ្នាល់ជល់ដំរីនេះតាមការសន្យាតទៅ។ ដំរីនគរលាវមានមាឌធំ កំពស់រហូតដល់៨ហត្ថ រីឯដំរីខ្មែរមានមាឌតូច។ ជាអកុសលពេលប្រជល់នេះ ដំរីលាវបានចាញ់ដំរីខ្មែរ ហើយនាម៉ឺនលាវចំនួន០២នាក់ត្រូវ

---

[91] ទន្លេនេះមានប្រភពមកពីទីបេ មានប្រវែង៤៣៥០គម ហើយបានហូរកាត់៥ប្រទេសគឺប្រទេសភូមា ប្រទេសថៃ ប្រទេសឡាវ ប្រទេស កម្ពុជា និងប្រទេសវៀតណាម។ នៅប្រទេសកម្ពុជាគេស្គាល់ថាទន្លេមេគង្គមានប្រវែង៥០០គម។

[93] " **Laos** traces its **History** to the Kingdom of Lan Xang(Million Elephants), founded in the 14th century, by a Lao prince Fa Ngum, who with 10. 000. Khmer troops, took over Vientane…in 1520. Photisarath came to throne and moved the Capital from Luong Prabang to Vientiane to avoid a Burmese invasion(Laos Wikipedia, https://en.m.wikipedia.org›wiki›Laos) (October 29, 2017)

បានព្រះមហាក្សត្រខ្មែរព្រះរាជានុញ្ញាតឲ្យវិលត្រឡប់ទៅប្រទេសលាវវិញ ដើម្បីទូលព្រះរាជាលាវអំពីលទ្ធផលនៃការបញ្ចល់ដំរីនេះ។ រីឯរាស្ត្រលាវចំនួន ១០០០(មួយពាន់)នាក់នោះ ត្រូវចាប់ទុកជាឈ្លើយទាំងអស់។ មិនដូចការ សន្យានោះទេ ក្រោយពេលដឹងថា ដំរីរបស់ខ្លួនបានចាញ់ដំរីខ្មែរ ព្រះរាជាលាវ បានលើកទ័ពទាំងខាងជើងទឹក និងជើងគោកមកធ្វើការវាយលុកលើនគរខ្មែរ។ ខាងជើងគោក កងទ័ពលាវបានវាយនៅត្រង់ខេត្តអាសន្ទុក (ភ្នំសន្ទុក ខេត្តកំពង់ធំ) សព្វថ្ងៃ និងតាមជើងទឹក កងទ័ពលាវបានវាយប្រហារខ្មែរនៅចម្ងាយ ៣៥គីឡូម៉ែត្រខាងជើងរាជធានីភ្នំពេញ។ ទោះបីយ៉ាងណាក៏ដោយកងទ័ពលាវទាំងពីរសមរភូមិ ត្រូវបានខ្មែរវាយឲ្យបរាជ័យទាំងអស់។ រាស្ត្រលាវទាំង ១០០០នាក់នោះ មួយចំនួនព្រះរាជាខ្មែរឲ្យទៅរស់នៅភាគខាងត្បូងខ្លះ ភាគខាងលិចខ្លះ ហើយខ្លះទៀតឲ្យទៅរស់នៅខេត្តគោកសេះ ត្រង់តំបន់ដែលព្រះ **បរមរាជាទី៤** ទ្រង់បានប្រទានឈ្មោះថា **បានលាវឈៀងរ៉ាយ** ប្រែថា ស្រុកលាវឈៀងរ៉ាយ ដែលបានក្លាយមកជា **ស្រុកបារាយណ៍** ខេត្តកំពង់ធំសព្វថ្ងៃនេះ។ ខ្លះទៀតឲ្យទៅរស់នៅបាភ្នំ និងមួយចំនួនឲ្យទៅរស់នៅវត្តភ្នំ[94]ដើម្បីថែដំរី ដែលខ្មែរហៅថា លាវបាក់ទូកជារៀងរហូតមក។ នៅឆ្នាំ១៥៧៤ ក្នុងបំណងសងសឹក លាវបាន លើកទ័ពមកកម្ពុជាម្តងទៀត តែដោយពេលនោះមានភ្លៀងធ្លាក់យ៉ាងខ្លាំង ហើយពួកភូមាបាននាំទ័ពសៀមចូលមកវាយលាវផង កងទ័ពលាវក៏ដកថយពីកម្ពុជាអស់ទៅ[95]។ នៅឆ្នាំ១៧៣០ លាវដែលរស់

[94] ភ្នំដូនពេញ ឬវត្តភ្នំនៃរាជធានីភ្នំពេញសព្វថ្ងៃនេះ។

[95] KHMER HISTORIES (History of Cambodia #...) ៖ នាទីប្រវត្តិសាស្ត្រនៅអំឡុងឆ្នាំ២០១០ និង២០១១ និងត្រូវបានចាក់ផ្សាយឡើងក្នុងគ្រាបន្តបន្ទាប់មក។

នៅ**បាភ្នំ**[96]បានធ្វើការបេះបោរ ហើយបានសម្លាប់ជនជាតិយួន[97]ជាច្រើននៅទីនោះ។ទីបំផុតយួនបានចូលធ្វើ អន្តរាគមន៍នៅភាគខាងត្បូងប្រទេសកម្ពុជានៅឆ្នាំ១៧៣១។ បន្ទាប់ពីចប់ការបង្រ្កាបនេះ យួនបានយកខេត្តពីររបស់ខ្មែរតែម្តងគឺខេត្តមេស (My-Tho/ Me-Sa) និងខេត្តលង់ហោ (Ving Long)[98] ទៅបាត់ជាថ្នូរនឹងការជួយខ្មែរ។ ប្រវត្តិសាស្ត្រឲ្យដឹងថា ទឹកដីកម្ពុជាភាគខាងត្បូងចំនួន២១ខេត្ត ត្រូវបានរដ្ឋាភិបាលបារាំងកាត់ឲ្យយួនកាលពីថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៤៩ដោយ មិនបានសួរខ្មែរអ្វីមួយម៉ាត់(សូមមើលឧបសម្ព័ន្ធទី៦)។ រីឯទឹកដីខ្មែរប៉ែកខាងលិចក៏ត្រូវបាត់បង់ជាស្ថាពរទៅជារបស់សៀមអស់ចំនួន១២ខេត្តរហូតមកដល់សព្វថ្ងៃនេះ(សូមមើលឧបសម្ព័ន្ធទី៧)។

ដោយសារតែព្រឹត្តិការណ៍យ៉ាងដូច្នេះ ហើយមានការបាត់បង់ទឹកដីរបស់ដូនតាពួកគេដូចជម្រាបជូនខាងលើនេះផង ទើបប្រជារាស្ត្រខ្មែរមួយចំនួនធំតែងតែមានការព្រួយបារម្ភចំពោះការបាត់បង់ទឹកដីពីសំណាក់ប្រទេសជិតខាងទាំងពីរជាបន្តទៅទៀតដូចការលោយបាត់បង់ពីផែនទីនៃប្រទេសចំប៉ា។ សូមរំលឹកដែរថា ទឹកដីភាគកណ្តាលនៃប្រទេសវៀតណាមបច្ចុប្បន្នជាអតីតទឹកដីរបស់ចាម(ចំប៉ា)ទាំងអស់។ ពោលគឺក្នុងអំឡុង២០ឆ្នាំក្រោយមកពោលគឺនៅឆ្នាំ១៦៩២ ស្តេចចាមឈ្មោះ **បាត្រាញ់** បានប្រកែកមិនព្រមលើកសួយសារអាករទៅថ្វាយស្តេចយួនបន្តទៅទៀតដូចមុនៗ ស្តេចយួនក៏បញ្ជាឲ្យ

---

[96] តាមពិតលាវនៅបាភ្នំនេះ គេសំដៅលើជនជាតិលាវដែលរស់នៅភូមិខ្សែត្រ ឃុំខ្សែត្រ ស្រុកកំពង់ត្របែក ខេត្តស្វាយរៀងនេះហើយ។

[97] ហៅតាមឯកសារប្រវត្តិសាស្ត្រ។

[98] Michael Vickerry: History of Cambodia, 2001-2002, page 154

លើកទ័ពមកវាយ ហើយបានចាប់ស្តេចចាមអង្គនេះធ្វើគត់តាំងពីពេលនោះមកហើយយួនបានរឹបផ្តាច់យកប្រទេសចំប៉ាទាំងមូលទុកជាសម្បត្តិយួនរហូតមក។ រីឯរាជវង្សចាម នៅបឹងរីបឹងរាំង បាននាំបរិវារចំនួន៥០០០នាក់ មកសុំជ្រកកោននឹងព្រះបាទ **ជ័យជេដ្ឋា អង្គស៊ូ** ព្រះអង្គទ្រង់សណ្តោសឲ្យទៅនៅត្បូងឃ្មុំខ្លះ ស្ទឹងត្រង់ខ្លះ ជ្រោយចង្វារខ្លះ ព្រែកប្រាខ្លះតាំងពីពេលនោះមក[99]។ ខេត្តញ៉ាត្រាង ឬញ៉ាចាង (Nha Trang) ជាអតីតខេត្តរបស់ចាមក្នុងចំណោមខេត្ត៥(ប្រាំ)ដែលត្រូវបានដាយវៀតលេបយកទាំងមូលនៅឆ្នាំ១៧៩៣[100]។

ទាក់ទងនឹងការបាត់បង់ទឹកដីនៃនគរចំប៉ានេះ សម្តេចព្រះអរិយវង្សបណ្ឌិត ឃី សុវណ្ណរតនាសាកលវិទ្យាធិការស្តីទីនៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ និងជាព្រះគ្រូចៅអធិការវត្តមង្គលវ៉ន ហៅវត្តស្វាយដង្គុំ សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញសម្តេចបានគូសបញ្ជាក់អំពីមូលហេតុនៃការបាត់បង់ពីផែនទីនៃប្រទេសចំប៉ានេះខណៈព្រះអង្គយាងទៅទស្សនកិច្ចនៅប្រទេសវៀតណាមដោយសង្កត់ធ្ងន់ថាប្រទេសចំប៉ាមានប្រវត្តិសាស្ត្រចាប់ផ្តើមនៅគ.ស.២៨០ ជាអាណាចក្រមួយមានវប្បធម៌ ប្រពៃណី និងអារ្យធម៌ដ៏រុងរឿង ហើយបានបន្សល់ទុកស្នាកស្នាមភស្តុតាងជាប្រាសាទបុរាណ រូបចម្លាក់ ក្បូរក្បាច់រចនា ប្រពៃណី ទំនៀមទម្លាប់ និងរបាំ រហូតមកដល់សព្វថ្ងៃ។ ក្នុងកំឡុងប្រវត្តិសាស្ត្ររបស់ខ្លួនអាណាចក្រចំប៉ាបានផ្លាស់ប្តូររាជធានីជាបន្តបន្ទាប់ពីភាគខាងជើងមកភាគកណ្តាល និងខាងត្បូងដែលបង្ហាញពីភាពចុះ

---

[99] KHMER HISTORIES (History of Cambodia #...) ៖ នាទីប្រវត្តិសាស្ត្រនៅអំឡុងឆ្នាំ២០១០ និង២០១១ និងត្រូវបានចាក់ផ្សាយឡើងក្នុងគ្រាបន្តបន្ទាប់មក។

[100] ហ្វេសប៊ុករបស់លោក Sophal Historian សាស្ត្រាចារ្យប្រវត្តិវិទ្យាចុះថ្ងៃទី១៥ ខែមេសាឆ្នាំ២០១៧។

ខ្សោយអំណាចរហូតបាត់បង់ប្រទេសទាំងស្រុងពីផែនទីពិភពនៅឆ្នាំ១៨៣២ ឈ្មោះរាជធានីបុរាណទាំងនោះនិងទីតាំងបច្ចុប្បន្នគឺ:១. ឥន្ទ្របុរៈ (ដាណាំង) ២. សិង្ហបុរៈ (ស្រុកចាគាវ ខេត្តក្វាងណាំ) ៣.វិជ័យ(ខេត្តគុយញ៉ុន) ៤.អារ្យរុ (ខេត្តនិញ ធួន) ៥. កៅឋារៈ (ខេត្តញ៉ាចាង) ៦.បណ្ឌុរង្គៈ (ខេត្តផាន់រ៉ាង)។ តាមរយៈការសិក្សាស្រាវជ្រាវកន្លងមក និងទៅសិក្សាស្រាវជ្រាវដល់ទីតាំងផ្ទាល់នៅវៀតណាមភាគកណ្ដាលពីថ្ងៃទី៣១ ខែមីនាដល់ថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៩ ព្រះអង្គយល់ឃើញថា ចំប៉ាបាត់បង់ប្រទេសទាំងស្រុងបណ្ដាលមកពីមូលហេតុមួយចំនួនដូចខាងក្រោម៖

១- បែកបាក់ និងច្បាំងគ្នាឯងក្នុងចំណោមជនជាតិចំប៉ានេះតែម្ដង

២-ភាពចុះខ្សោយនៃអំណាចកំពូល ពោលគឺរដ្ឋបាលកណ្ដាលនៃមហាក្សត្រចំប៉ា(ចាម)

៣-ការទន្ទ្រានវាតទីទឹកដីពីអាណាចក្រដាយវៀត

៤-ស្ដេចចំប៉ា(ចាម)បានកាត់ទឹកដីជាបន្តបន្ទាប់ពេលរៀបការជាមួយព្រះអង្គម្ចាស់ក្សត្រដាយវៀត។ ឧទាហរណ៍ នៅឆ្នាំ១៣០៦ ព្រះបាទជយសិង្ហវរ្ម័នទី៣ (ចេមឹន) ពេលរៀបការជាមួយព្រះអង្គម្ចាស់ក្សត្រីដាយវៀតព្រះនាមហ្វៀន ចឹន បានកាត់ខេត្តចំប៉ា(ចាម)ពីរ គឺ: ខេត្តធួន (បច្ចុប្បន្ន ខេត្តគងជី) និងខេត្តហ៊ា(បច្ចុប្បន្នខេត្តធឺធានហ្វេ)។ ខេត្តហ៊ាទៅឲ្យស្ដេចដាយវៀតព្រះនាមចឹន អាញ់តុង

៥-ការវាយប្រហារពីកោះជ្វាច្រើនលើកច្រើនសារ

៦-ស្តេចចំប៉ា(ចាម)ច្រើនរជ្ជកាលមានការធ្វេសប្រហែសភ្លេចខ្លួន មិនបានរៀបចំពង្រឹងអាណាចក្ររបស់ខ្លួនឲ្យបានរឹងមាំ[101]។

[101] សម្តេចព្រះអរិយវង្ស បណ្ឌិត ឃី សុវណ្ណរតនា ព្រះសាកលវិទ្យាធិការស្តីទីនៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ និងជាព្រះគ្រូចៅអធិការវត្តមង្គលវ័ន ហៅវត្តស្វាយដង្គំ សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ។ គេហទំព័រហ្វេសប៊ុកថ្ងៃព្រហស្បតិ៍ ទី៤ ខែមេសា ឆ្នាំ២០១៩។


Indrapura
Amaravati
Vijaya
Aryaru
Kauthara
Panduranga
indrapura
simhampura
vijaya
Eatran
Kauthara
Panduranga




តាមលោក សេង ឌីណាបាននិយាថា នៅទីចុងបំផុត គឺនគរចំប៉ាដែលត្រូវទទួលបរាជ័យដោយត្រូវនគរអាណ្ណាមចូលកាន់កាប់បានទាំងស្រុងនៅឆ្នាំ ១៤៧៤ទៅវិញ។ នៅពេលនគរចំប៉ាបានដួលរលំហើយ ពួកចាមក៏បាននាំគ្នា

រត់ខ្ចាត់ខ្ចាយចេញពីនគរ ហើយភាគច្រើននាំគ្នាទៅជ្រកកោននៅក្នុងអាណាចក្រខ្មែរ ហើយខ្លះទៀតទៅរស់នៅម៉ាឡាកាប្រទេសម៉ាឡេស៊ីបច្ចុប្បន្ន[102]។

សូមបែរមកបន្តនិយាយពីជនជាតិលាវតទៅទៀត តាមការស្រាវជ្រាវរកឃើញថា មានញាតិសន្តានបងប្អូនជនជាតិលាវមួយចំនួនបាន និងកំពុងរស់នៅក្នុងទឹកដីខ្មែរក្នុងតំបន់ផ្សេងៗគ្នា ហើយដែលពួកគាត់ទាំងនោះ បានក្លាយមកជាជនជាតិខ្មែរអស់ទៅហើយ ក្នុងនោះមានក៏មានភូមិមួយឈ្មោះភូមិខ្សែត ឃុំខ្សែត ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀងដែរ។ ឡាវនៅស្វាយរៀង គេហៅខ្លួនឯងថាឡាវខ្សែត្រ បើតាមយោងតាមសំដីជនជាតិឡាវឃុំ ខ្សែត្រ ពាក្យថា ខ្សែត្រ មកពីពាក្យថា ក្សេត្រ ដែលមានន័យថា ស្តេច។ ពួកគាត់បកស្រាយថា ឡាវពួកគាត់មានជាប់ប្រវត្តិជាមួយក្សត្រ គឺព្រះចៅ ហ្វាងងុម នៃប្រទេសឡាវ។ ដោយហេតុនេះហើយ ទើបពួកគាត់ហៅខ្លួនឯងថា ឡាវក្សេត្រ។ ប៉ុន្តែក្រោយៗមកដោយពាក្យថា ក្សែត្រ ស្រួលបញ្ចេញសំឡេង ជាងក្សត្រ ពួកគាត់ក៏ហៅពួកគាត់ថា ឡាវក្សែត្រតរៀងមក។ ចំពោះការពន្យល់ទីពីរវិញ ក្សែត្រ គឺសំដៅទៅលើក្សេត្រមានន័យទាក់ទងនឹងស្រែ ដោយហេតុថា ពួកគាត់ជាឡាវធ្វើស្រែដូច្នេះហើយទើបពួកគាត់ហៅខ្លួនឯងថា ឡាវ ខ្សែត្រ។ ក្រៅពីនេះ គឺជាឈ្មោះឃុំដែលមានជនជាតិឡាវរស់នៅដោយពួកគាត់តំណាលថា កាលពីដំបូងជនជាតិឡាវមកតាំងទីលំនៅតំបន់នេះតែមួយភូមិទេ ភូមិនោះហៅថាភូមិខ្សែត្រ ហើយដោយចំនួនកូនចៅឡាវកើនច្រើនឡើងៗ ទើបពួកគាត់

[102] សេង ឌីណា៖ ប្រវត្តិសាស្ត្រពិភពលោក អរិយធម៌អាស៊ីអាគ្នេយ៍ អំពី បណ្តាប្រជាជាតិដែលរស់នៅជុំវិញអាណាចក្រខ្មែរ ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោង៧៖០០នាទីយប់។

បំបែកជាច្រើនភូមិរហូតបង្កើតបានជាឃុំមួយដូចសព្វថ្ងៃនេះ[103]។ ទាក់ទងនឹងប្រជាពលរដ្ឋខ្មែរដែលកំពុងរស់នៅឃុំខ្សែត្រនេះអ្នកនិពន្ធបានជួបសម្ភាសន៍ផ្ទាល់ជាមួយកូនចៅអ្នកឃុំនេះតែម្តង ដែលជានិស្សិតជំនាន់ទី២៥ ផ្នែកធនាគារ និងហិរញ្ញវត្ថុ នៅសាកលវិទ្យាល័យជាតិគ្រប់គ្រងឈ្មោះ រិនផន ឆៃថានិត ដែលមានខ្លឹមសារដូចខាងក្រោម៖

-ស្នេរ៖តើលោកធ្លាប់បានដឹងប្រវត្តិសាស្ត្រអំពីជនជាតិលាវដែលកំពុងរស់នៅក្នុងភូមិខ្សែត្រនេះឬទេ?

-រិនផន ឆៃថានិត ៖ បាទបានដឹងខ្លះដែរ តែមិនច្បាស់លាស់ទេ។

-ស្នេរ៖ តើលោកធ្លាប់សង្កេតឃើញប្រជាពលរដ្ឋនៃភូមិខាងលើមានទំនៀមទម្លាប់រស់នៅខុសប្លែកអ្វីគួរឲ្យចាប់អារម្មណ៍ដែរឬទេ?

-រិនផន ឆៃថានិត ៖ បាទមិនមានអ្វីប្លែកពីប្រជាពលរដ្ឋនៃភូមិនានាជិតខាងទេ។ ពួកគាត់រស់នៅធម្មតាៗមិនមានការចាប់អារម្មណ៍អ្វីឡើយ។

-ស្នេរ ៖ ចុះភាគច្រើននៃប្រជាពលរដ្ឋភូមិនេះកាន់សាសនាអ្វីដែរ។

-រិនផន ឆៃថានិត ៖ ពួកគាត់កាន់សាសនាព្រះពុទ្ធ។

-ស្នេរ ៖ តាមយោបល់លោកតើខ្សែត្រមានន័យដូចម្តេច?

-រិនផន ឆៃថានិត៖ មិនដឹងទេបាទ។

-ស្នេរ ៖ តាមការសង្កេតរបស់លោក តើអ្នកភូមិក្សែត្រសព្វថ្ងៃបានដឹងថា ពួកគាត់មានកំណើតពីជនជាតិលាវ ឬទេ?

[103] សារព័ត៌មាននគរធំ ប្រចាំថ្ងៃ ឆ្នាំទី២១ លេខ៩៣៤ ចេញផ្សាយថ្ងៃសៅរ៍ទី០៥ ខែកញ្ញា ឆ្នាំ២០១៥ ទំព័រ១៤។

-រិនផន ឆៃថានិត៖ ដូចជាអ្នកខ្លះបានដឹងខ្លះៗដែរថា ដូនតាជាលាវ ប៉ុន្តែមិនបានចាត់ទុកខ្លួនឯងជាលាវទេ គឺជាខ្មែរទាំងអស់គ្នាតែម្តង។

លោក និត ភីរុន ជានិស្សិតរបស់ខ្ញុំម្នាក់ទៀត សិក្សាផ្នែកអក្សរសាស្ត្រអង់គ្លេស ជំនាន់ទី២៥ នៃសាកលវិទ្យាល័យជាតិគ្រប់គ្រងមានកំណើតមកពីភូមិព្រៃស្មៀង ឃុំស្វាយតាយាន ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង បានឲ្យដឹងថា ជីតារបស់គាត់មានដើមកំណើតនៅឃុំខ្សែត្រដែរ កាលពីលោកតានៅរស់នៅឡើយ លោកតែងតែតំណាលថា ពិតជាមានបងប្អូនប្រជាពលរដ្ឋនៅភូមិឃុំខាងលើមានដើមកំណើតជាជនជាតិលាវប្រាកដមែន ហើយបង្កើតកូនចៅរស់នៅដល់បច្ចុប្បន្ននេះ។ ពួកគាត់និយាយទំនាក់ទំនងគ្នារបៀបជាលាវនៅឡើយ។

លោក ទន់ ឆាយ ជានិស្សិតរបស់ខ្ញុំដែរ សិក្សាផ្នែកគ្រប់គ្រង ជំនាន់ទី២៤ នៃសាកលវិទ្យាល័យជាតិគ្រប់គ្រងមានកំណើតនៅភូមិឫស្សីដោច ឃុំរាជមន្ទីរ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀងបានឲ្យដឹងថា កាលពីលោករៀននៅវិទ្យាល័យ ហ៊ុន សែន កំពង់រោទិ៍ មិត្តភក្តិរបស់លោកខ្លះក៏បានដំណាលថាមាតាបិតារបស់គាត់(មិត្តភក្តិ)តែងតែបង្ហាត់បង្រៀនពួកគាត់ឲ្យចេះនិយាយភាសាលាវដែរ តែលោកមិនបានដឹងពីប្រវត្តិរឿងរ៉ាវពីអតីតកាលអ្វីទេ។ លោកបន្តថា អ្នកភូមិខាងលើចេះរបរធ្វើតម្បាញកន្ទេលកញ្ចូតលក់។

បន្ថែមលើលទ្ធផលនៃព័ត៌មានដែលបានរៀបរាប់ខាងលើនេះ យើងសូមបង្ហាញបន្តិចអំពីជនជាតិលាវ និងថៃដែលរស់នៅប្រទេសកម្ពុជាសព្វថ្ងៃ។ តាមការកត់សម្គាល់របស់សារព័ត៌មាននគរធំ ជនជាតិលាវមានច្រើនក្រុម ជនពួក ច្រើនកន្លែង។ អត្ថបទអត្ថាធិប្បាយថា ឡាវហ្លួងជាឡាវដែលរស់នៅខេត្តស្ទឹងត្រែង រតនគិរី និងមណ្ឌលគិរី មានប្រវត្តិចេញមកពីភាគខាងត្បូង

នៃប្រទេសឡាវ ហើយឡាវភួន មានប្រវត្តិចេញមកពីតំបន់មួយនៃប្រទេសឡាវដែលនៅជិតព្រំដែនចិន និងវៀតណាម(ភាគខាងជើង) និងឡាវញ៉ មានប្រវត្តិចេញមកពីនគរឡានឆាងក្រុងហ្លួងព្រះបាង។ ឡាវខ្សែត[104]មានប្រវត្តិទាក់ទងនឹងព្រះចៅហ្វាងងុម តែឡាវដាច់សង្រែក មានប្រវត្តិមិនច្បាស់លាស់ទេ។...ភាសារបស់ជនជាតិឡាវនៅកម្ពុជាមានលក្ខណៈជាគ្រាមភាសាខុសៗគ្នាពីតំបន់មួយទៅតំបន់មួយទៀត។ ភាពខុសគ្នានេះទាក់ទងទៅនឹងទំនាក់ទំនងដ៏យូរលង់ជាមួយនឹងមជ្ឈដ្ឋានដែលនៅជុំវិញសហគមន៍របស់ពួកគាត់[105]។

តាមប្រសាសន៍របស់អ្នកភូមិសំណាយ បានឲ្យដឹងថាឡាវនៅទីនេះ និងឡាវនៅឯប្រទេសនិយាយស្តាប់គ្នាមិនបានទេ។ ដូចជាករណី ឡាវនៅស្វាយរៀង ប្រើពាក្យសួរគ្នាថា ប៉ៃដាវ នៅបន្ទាយមានជ័យឡាវញ៉ថា ប៉ៃសៃ ឡាវភួនថា ប៉ៃកាលើ រីឯឡាវនៅខេត្តរតនគិរី និងស្ទឹងត្រែងថា ប៉ៃបិ។ ភាពខុសគ្នាខាងវចនស័ព្ទនៃគ្រាម ភាសានីមួយៗ បង្ហាញការវិវត្តរបស់ភាសាតាមរយៈប្រវត្តិនៃប្រភពដើមព្រមទាំងការផ្លាស់ប្តូរកន្លែងរស់នៅជាបន្តបន្ទាប់របស់ដូនតា[106]។

ចំណែកភូមិសមរលាវ ភូមិសមរខ្មែរ ភូមិសមរចិន[107] ជាភូមិដែលស្ថិតក្នុងចំណោមភូមិទាំង១១នៃឃុំពោធិ៍រំចាក ស្រុកព្រែកប្រសព្វ ខេត្តតាកែវ។ តើ

---

104 ឡាវរស់នៅភូមិខ្សែត ភូមិខ្សែត ឃុំខ្សែត ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង។

105 សារព័ត៌មានគរជំ ប្រចាំថ្ងៃ ឆ្នាំទី២១ លេខ៩៣៣ ចេញផ្សាយថ្ងៃសុក្រទី០៤ ខែកញ្ញា ឆ្នាំ២០១៥ ទំព័រ១៤។

106 ឯ-ដ។

107 ភូមិនេះមិនមានឈ្មោះក្នុងបញ្ជីរដ្ឋបាលដែនដីឃុំពោធិ៍រំចាកទៀតទេ។

មានជនជាតិលាវ កំពុងរស់នៅក្នុងភូមិសមរលាវរហូតដល់សព្វថ្ងៃនេះ ឬទេ? ចម្លើយគឺមិនមានទេសូម្បីតែម្នាក់។ប៉ុន្តែនៅក្នុងភូមិសមរលាវនេះក៏មាន អ្នកតា **យាយលាវ** ដែលអ្នកភូមិមានជំនឿហើយធ្វើការគោរពប្រតិបត្តិតែរាល់ថ្ងៃមានទីតាំងនៅក្នុងវត្តសមរលាវនេះស្រាប់តែម្តង។នៅក្នុងឃុំពោធិ៍រំចាក មានទីតាំង ដូចខាងក្រោម៖

-ខាងកើតទល់នឹង ឃុំ កំពង់រាប ស្រុកព្រែកប្បាស និង ឃុំព្រែកស្តី ស្រុកកោះធំ ខេត្តកណ្តាល

-ខាងលិចទល់នឹង ឃុំ កំពែង ស្រុកព្រែកប្បាស

-ខាងត្បូងទល់នឹង ឃុំព្រែកប្បាស ស្រុកព្រែកប្បាស

-ខាងជើងទល់នឹងឃុំចំប៉ា និងឃុំបានកាម ស្រុកព្រែកប្បាស ខេត្តតាកែវ។

ឈ្មោះភូមិទាំង១១គឺ

១- ភូមិ សមរលាវ
២- ភូមិ សមរខ្មែរ
៣- ភូមិ ថ្នល់បត់
៤- ភូមិ គោកកញ្ជាប
៥- ភូមិ គរ
៦- ភូមិ ក្តីតាហុក
៧- ភូមិ អង្គសង្កែ
៨- ភូមិ ក្រសាំង
៩- ភូមិ ស្វាយសំរោង
១០- ភូមិ គោកអង្គង់ និង
១១- ភូមិ ព្រៃតាពង

## ២-អំពីដើមកំណើតឈ្មោះភូមិសមរលាវសមរខ្មែរ សមរចិន

ដូចអ្នកប្រិយមិត្តអានបានជ្រាបហើយថា អ្នកស្រាវជ្រាវគ្មានសិទ្ធិអ្វី ឬនឹងមានចេតនាសរសេរតាមការនឹកឃើញ ឬអារកាត់សេចក្តីតាមបំណងខ្លួន

ឯងនោះទេ ពោលគឺបានត្រឹមតែរៀបរាប់នូវព័ត៌មានដែលប្រមូលបានពីអ្នកស្រុក និងចាស់ទុំទាំងឡាយតែប៉ុណ្ណោះ។ ការស្វែងយល់អំពីការកកើតភូមិសមរលាវនេះ កាលណានិយាយពីភូមិសមរលាវ យើងមិនអាចកាត់ចេញនូវឈ្មោះភូមិសមរខ្មែរ ភូមិសមរចិនទេ ពីព្រោះភូមិទាំងបីមានប្រវត្តិជាប់ទាក់ទងគ្នា។

តាមប្រសាសន៍របស់លោកគ្រូ សៅ ឈឿង បានឲ្យដឹងថា ភូមិទាំងបីនេះ មិនមែនកើតឡើងតាំងពីការកើតប្រទេសកម្ពុជានោះទេ។ ប៉ុន្តែនេះជាការចងចាំការនិយាយ និងចេះដឹងតៗគ្នាមកតែប៉ុណ្ណោះ។ លោកដំណាលថា...ប្រហែលជាឃើញទឹកដីខ្មែរធំទូលាយ ហើយប្រជារាស្ត្រមានចំនួនតិចតួចនៅឡើយ ជនជាតិលាវបានបើកការឈ្លានពានមកលើទឹកដីនេះជាបន្តបន្ទាប់។ លាវវាយដណ្តើមយកព្រំប្រទល់ជាប់គ្នារហូតមកដល់ភូមិមួយសព្វថ្ងៃហៅថាភូមិសមរលាវ។ ព្រះបាទ ហ៊ុន ទៀន[108] បានប្តឹងផ្តល់មហាប្រទេសចិនថា លាវបានឈ្លានពានទឹកដីខ្មែរនៅសល់តែ១៤គីឡូ ម៉ែត្រទៀតដល់ខ្សែក្រវាត់ការ ពារទីក្រុងហើយ។ ពេលនោះចិនបានលើកទ័ពមកដល់ភូមិមួយហៅថា ភូមិសមរចិន។ រីឯទ័ពខ្មែរ នៅភូមិសមរខ្មែរសព្វថ្ងៃ។ ទាក់ទងនឹងអាវុធយុទ្ធភ័ណ្ឌសម្រាប់ធ្វើការប្រយុទ្ធគ្នានាសម័យនោះគឺមាន៖ ដំបងគុន ដាវ លំពែង ស្នា ធ្នូបាញ់ដោយគ្រាប់ព្រួញ។ ទីលានប្រយុទ្ធនៅចន្លោះភូមិទាំងពីរ

[108] តាមការសន្និដ្ឋានមិនមែនព្រះបាទ ហ៊ុន ទៀន ទេ ប៉ុន្តែអាចជាព្រះរាជាអង្គណាមួយក្នុងសម័យលង្វែក។

គឺភូមិសមរលាវ និងភូមិសមរខ្មែរ ហើយមានត្រពាំង[109]ប្រយុទ្ធដូចជា ត្រពាំងព្រីង ត្រពាំងរកា ត្រពាំងប្រវ៉ាស់ ត្រពាំងក្រហូច ត្រពាំងកោះស្នា[110]។ ពេលប្រយុទ្ធគ្នារវាងខ្មែរ និងលាវ ចិនចាំជួយនិងចាំមើល។ នៅពេលការប្រយុទ្ធគ្នាចប់ ចិនឲ្យខ្មែរ និងលាវ ចូលទៅយកសាកសពនៃពលទាហានរៀងៗខ្លួន។ ប្រសិនបើពលលាវស្លាប់ឲ្យយកសាកសពទៅកប់នៅទួលស្រះតាអែ ហើយបើពលខ្មែរស្លាប់ឲ្យយកសាកសពទៅកប់នៅទួលស្រះតាទៀម។ នៅទួលបញ្ចុះសពមានធ្វើស្តូបមួយៗសម្រាប់គោរពវិញ្ញាណក្ខន្ធ រីឯការប្រយុទ្ធគ្នារវាងខ្មែរ និងលាវ ខ្មែរឈ្នះលាវ ហើយបានដេញទ័ពលាវឲ្យរត់ផុតភូមិសមរលាវដល់ត្រពាំងមានជ័យ ឬត្រពាំងជ័យខាងជើងភូមិសមរលាវដែលមានឈ្មោះថាត្រពាំងជ័យ[111] និងត្រពាំងឈ្នះ (នៅក្នុងស្រែមួយជាប់គ្នានឹងត្រពាំងជ័យនេះដែរ) ហើយនៅចន្លោះត្រពាំងទាំងពីរមានត្រពាំងមួយទៀតគឺត្រពាំងប្រើយ៍។ ភូមិសមរចិនមាន ត្រពាំងអណ្តូង ឬស្រះអណ្តូង ភូមិសមរខ្មែរមានស្រះតៀម

---

[109] ត្រពាំងនៅទីនេះ អ្នកស្រុកនេះឲ្យអត្ថន័យស្មើនឹងស្រះ ឬគេហៅថា បៀ ឬ កាឡូ។ ឧទាហរណ៍ អ្នកស្រុកនេះទម្លាប់និយាយថា កូនទៅឃ្វាលគោ កុំមុជទឹកបៀ ឬទឹកកាឡូ ខ្លាចលង់ទឹកស្លាប់..ជាដើម។

[110] ជាទីកន្លែងលាងអាវុធយុទ្ធភ័ណ្ឌ មានដូចជា ស្នា ព្រួយរបស់កងទ័ព។

[111] ត្រពាំងនេះ ជាស្រែជម្រៅធាប់ដក់ទឹក និងមិនងាយរីងស្ងួត។ ដោយមានវិវត្តនៃស្រុកទេសដីស្រែនានាត្រូវបានបែងចែកជាកម្មសិទ្ធិប្រជារាស្ត្រ ហើយសព្វថ្ងៃទីតាំងនេះត្រូវបានបណ្ឌិត សេង ប៊ុនធឿនទិញកាន់កាប់ធ្វើជាកម្មសិទ្ធិរួចទៅហើយរហូតដល់បច្ចុប្បន្ន។

និងស្តួប[112] និងភូមិសមរ-លាវមានទួលតាអែ ឬស្រះតាអែ។ តាមលោកគ្រូ សៅ ឈឿង ភូមិទាំងបីសុទ្ធតែមាននយោបាយទឹកសម្រាប់ប្រជារាស្ត្រប្រើប្រាស់ និងស្រោចស្រពដំណាំរបស់ពួកគេរៀងៗខ្លួន។ លោកបញ្ជាក់ថាភូមិសមរចិនមានស្រះអណ្តូង (មានទីតាំងនៅខាងត្បូងផ្លូវជាប់ព្រែកទទឹងថ្ងៃកាត់តាមភូមិសមរចិនខាងត្បូងផ្ទះលោក ស៊ុយ គិន ឬខាងត្បូងឆៀងខាងកើតផ្ទះលោកយាយ សួន សែ មាតារបស់លោក ហ៊ាន ចំរើន) ភូមិសមរខ្មែរមានស្រះតៀម និងភូមិសមរលាវមានស្រះតាអែ។ តាមពិតទីនេះ(មានទួលមានស្រះ) ជាសម្បត្តិគរុភ័ណ្ឌទេ ប៉ុន្តែដោយទីនេះមិនការពុះ ឬបូជាសពរបស់អ្នកភូមិដូចមុនៗទៀតដែរនោះ ម៉្យាងដោយមានការឧស្សាហ៍ព្យាយាមអ្នកភូមិបីគ្រួសារដែរបាននាំគ្នាកាប់ស្ការធ្វើជាចំការកម្មសិទ្ធិឬអាស្រ័យផលរហូតមកដល់សព្វថ្ងៃ។ ចំណែកខាងទីទួលត្រូវបានកាប់ស្ការអាស្រ័យផលដោយគ្រួសារលោកតា(កុង)ព្រីងយាយហ៊ី ដើម្បីដាំដំណាំដោះស្រាយជីវភាពប្រចាំថ្ងៃតាំង ពីទសវត្សឆ្នាំ៨០មក។ លោកតាទើបតែធ្វើមរណៈកាលទៅនៅថ្ងៃ ១៣រោច ខែផល្គុន ឆ្នាំមមីរ ត្រូវនឹងថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៥កន្លងទៅនេះក្នុងជន្មាយុ៩០ឆ្នាំ។ ចំណែកខាងស្រះទឹកវិញ ត្រូវបានកុង ម៉ែ លោកយាយ ជី ជាបិតាមាតាលោក ជាលឹម និងភរិយាឈ្មោះ សុខ ទូច ត្រូវជាកូនប្រសារបានជីកស្តារ លើកជាទួលអាស្រ័យផលដាំដំណាំរហូតមកដែរ។

---

112 អ្នកស្រុកអាចរកឃើញនៅត្រង់ដំបូកមួយអគារសិក្សាផ្នែកខាងជើងនៃសាលាបឋមសិក្សាតាកាហាស៊ីសព្វថ្ងៃនេះ។ មានជំនឿថា អ្នកស្រុកមិនហ៊ានរំលាយទួលដំបូកនេះចោលទេ។

ស្រះនេះពីដើមសម្បូរត្រីណាស់ អ្នកភូមិបានដឹងថា មានមច្ឆាជាតិស្ទើរគ្រប់ប្រភេទ ដូចជា ត្រី កង្កែប កំពឹស ពស់ អណ្ដើក កន្ធាយ។ល។ ឪពុករបស់ខ្ញុំធ្លាប់និទានប្រាប់ថា ក្នុងស្រះនេះមានអន្ទង់ច្រើនណាស់ ហើយស៊ីតែខ្មោច ចាប់ពីពេលនោះមក ខ្ញុំឈប់ហូបសាច់អន្ទង់រហូតមក។ ក្រោយរបបខ្មែរដួលរលំទៅ អ្នកភូមិតែងតែនាំគ្នាធ្វើនេសាទក្នុងស្រះនេះដោយប្រើឧបករណ៍បុរាណដូចជាអង្រុតឈ្នាងស្នង[113] ស្នូរ សន្ទូច មង អួន សំណាញ់ ជាលក្ខណៈគ្រួសារមិនដែលខកខានឡើយពីមួយឆ្នាំទៅមួយឆ្នាំ ជាពិសេសរដូវទឹកសម្រក (រដូវប្រាំង)។ ទួលស្រះតាអែ អ្នកស្រុកបាននិយាយតៗគ្នាថា មានខ្មោចលងច្រើនខ្លាំងណាស់ ពីព្រោះទីទួលនេះត្រូវបានកប់ខ្មោចស្ទើរសុះអស់ផ្ទៃដីទៅហើយ។ ខ្មោចលងមិនចាំបាច់តែពេលយប់ទេដែលលងដុតចង្កៀងផ្លុងៗនោះ សូម្បីតែពេលថ្ងៃក៏អ្នកស្រុកមិនហ៊ានចូលទៅក្នុងព្រៃដ៏ក្រាស់នេះផង ពីព្រោះអាចមានខ្មោចបំពេរកូនទាំងថ្ងៃទម្លាក់សំឡេងពីដើមឈើទាលខ្ពស់ៗចុះមកដីទាំងថ្ងៃក្រឡែត។ តាមប្រសាសន៍របស់លោក សេង ឆេងលាង បច្ចុប្បន្ន (២០២១) អាយុ៦១ឆ្នាំបាននិទានប្រាប់នូវអ្វីដែលលោកចងចាំកាលពីនៅក្មេងៗ(អាយុប្រហែល១៣ ឬ១៤ឆ្នាំ)ថា មានពេលមួយនោះ គេបូជាសពកុង[114] ទាន ស្វាមីយាយពៀ (បិតារបស់ឧបាសិកា ស្រួច ជាបិតាក្មេកឧបាសកនូ)។ ខណៈដែលសពកំពុងតែឆេះមិនទាន់សុះនៅឡើយ លោកចេញទៅបត់

---

[113] តំបន់ខ្លះហៅឧបករណ៍នេះថា ឈិប។

[114] ភាសាខ្មែរតែទម្លាប់កូនចៅកាត់ចិនហៅថា កុង ខ្មែរយើងហៅ តា ជីតា។

ជើងធំក្រោមដើមព្រីងមួយដើមនៅក្បែរនោះ (ជំនាន់នោះគ្មានបង្គន់អនាម័យអ្វីទេ)ស្រាប់តែសំឡេងកុងទាន ស្រែកឲ្យគាត់ថា ហ្អែង អាចម៍[115]អញ្ជឹងហ្អេ? ឮតែប៉ុណ្ណេះ លោករត់អត់ងាកក្រោយទេ មិនទាន់ទាំងជុះហើយផង sic គឺសំឡេងហ្នឹងកុងទានសុទ្ធតែម្តង។ម្តងទៀតលោក(ឆេងលាង)ថា លោកចូលព្រៃតាអែទាំងថ្ងៃ ស្រាប់តែខ្មោចលងលោកឲ្យឃើញតែខ្លួនទេ បាត់ក្បាលអស់តែម្តង។ លោកថាខ្មោចលងហ្នឹងមិនមែនបេះតែថាទេគឺលងៗមែនតែម្តង។ ....ល្បីយូរៗទៅគ្រាន់តែដើមឫស្សីកកិតគ្នាដោយសារខ្យល់បក់ហើយ ឮសូរសំឡេងង៉េតង៉តៗហ្នឹង ក៏នាំគ្នាគិតថាជាសំឡេងខ្មោចលងដែរក៏មិនដឹង។

ទាក់ទងនឹងទីទួលកប់ខ្មោចមួយនេះ(ទួលតាអែ)កាលពីលោកឧបាសក សេង អ៊ន[116] នៅមានជន្មាយុនៅឡើយ (មុនឆ្នាំ២០០៥) លោកជាសមាជិកម្នាក់នៃគណៈកម្មការវត្តសមរលោវបានដំណាលថា លោកបានពិភាក្សាគ្នាជាមួយសមាជិកដទៃនៃគណៈកម្មការវត្តសមរលោវដោយស្នើថា ប្រសិនបើមានចាស់ទុំណាម្នាក់ដែលរស់នៅខាងកើតផ្លូវ ឬក្នុងភូមិប៉ែកខាងកើត(ផ្លូវជាប់របងវត្ត)បានធ្វើមរណៈកាលទៅត្រូវតែយកទៅបញ្ចុះលើទួលតាអែនេះ។ ផ្ទុយទៅវិញ ប្រសិនបើអ្នករស់នៅខាងលិចផ្លូវ ឬក្នុងភូមិប៉ែកខាងលិចបានស្លាប់ត្រូវយកទៅកប់ ឬបញ្ចុះនៅទួលខ្មោចខាងលិចភូមិ ប៉ែកខាង

---

[115] អ្នកនិពន្ធសូមប្រើប្រាស់ពាក្យពេចន៍ជាភាសានិយាយរបស់អ្នកស្រុក។

[116] លោកបានធ្វើមរណកាលថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៥វេលាម៉ោង២ និង៣០នាទីរសៀលក្នុងជន្មាយុ៧៦ឆ្នាំ។

ជើង(ទួលខ្មោច) ពីព្រោះប្រសិនបើអ្នករស់នៅភាគខាលិច ហើយយកសព មកបញ្ចុះខាងកើតភូមិនាំឲ្យក្មេងៗខ្លាច(ខ្លាចខ្មោច) និងផ្ទុយទៅវិញ។ លោក បន្តថា អ្នករស់នៅក្នុងភូមិ ប៉ែកខាងលិច ក្មេងប៉ែកខាងកើតភូមិមិនដែល ស្គាល់មុខអ្នកស្លាប់ទេ ដូច្នេះនាំឲ្យពួកគេខ្លាចពេលយកសពទៅកប់ខាងលិច ភូមិ[117]។ល។ ឈ្មោះទីតាំងទួលនៃតំបន់ទាំងអស់ខាងលើសុទ្ធតែត្រូវបានអ្នក ស្រុកហៅរហូតមកដល់បច្ចុប្បន្ននេះ។ ដូចការអះអាងពីខាងលើស្រាប់សព្វថ្ងៃ នេះ គ្មានប្រជារាស្ត្រណាម្នាក់នៅក្នុងភូមិ សមរលាវបានអះអាងខ្លួនឯងថា ជា ជនជាតិលាវ ឬមានជាប់សាច់សារលោហិតជាលាវទេ គឺនៅសល់តែ ស្លាកស្នាមសម្គាល់ថា អ្នកតាយាយលាវ ដែលមានទីតាំងជារោងស្ថិតនៅជាប់ របងខាងជើងពីក្រោយសាលាធម្មសភាក្នុងវត្តសមរលាវនេះតែប៉ុណ្ណោះ[118]។ ប្រជារាស្ត្រភូមិសមរលាវបច្ចុប្បន្នបានចាត់ទុកខ្លួនឯងថា ជាកូនកាត់ចិនតាម រយៈការគោរពជូនតាចិនរបស់ខ្លួននៅរដូវប្រពៃណីចិន និងការហៅគ្នារបៀប ចិន។ តាមការស្រាវជ្រាវពេលចប់សង្គ្រាម កងទ័ពចិនចូលមកប្រទេសខ្មែររស់

[117] ប្រភពព័ត៌មាន៖ លោក សេង សាកល បានស្តាប់ការនិទានរបស់លោកតាឧសបាសក សេង អ៊ិន ផ្ទាល់ត្រចៀក។

[118] ស្ថិតនៅក្នុងទីវត្តសមរលាវខាងក្រោយសាលាធម្មសភា(សាលាឆាន់)សព្វថ្ងៃ។ ផ្តួចផ្តើមធ្វើអាស្រម និងដាក់រូបជាថ្មីដោយបណ្ឌិត សេង ប៊ុនធឿន សហការជាមួយព្រះចៅអធិការវត្ត ព្រះតេជគុណ ឡាក់ ហ៊ីម។

នៅជាមួយគ្នាជាភាគរៈ ស្រឡាញ់គ្នា រៀបការជាមួយគ្នា បង្កាត់ពូជចិន[119] ខ្មែរ រហូតដល់សព្វថ្ងៃនេះ ភូមិទាំងនេះភាគច្រើនមានសែស្រឡាយជាកូនចៅចិន ពីព្រោះកុងទួតជាចិនឆៅ កុងចិនឆៅ ឪពុកចិនឆៅ។ល។ ពូជកូនកាត់ខ្មែរចិន។ ភូមិសមរលាវមានដើមកំណើតជាងបួនសតវត្សរ៍មកហើយ នេះបើគិតត្រឹមឆ្នាំ១៥៧២មកដល់បច្ចុប្បន្នមានអាយុប្រហែលជា៤៥០ឆ្នាំគិតត្រឹមឆ្នាំដែលមាន ព្រឹត្តិការណ៍ប្រដល់ដំរីកើតឡើង។ ប៉ុន្តែក្នុងលិខិតមួយរបស់អ្នកនិពន្ធសរសេរទៅសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានរៀបរាប់ថា ភូមិទាំងបីនេះមានអាយុជិតបួនរយឆ្នាំទៅហើយ (ឧបសម្ព័ន្ធទី១) ហើយមានឈ្មោះពិតប្រាកដថា ភូមិសមរលាវ គឺជាទីលានចម្បាំងរវាងកងទ័ពខ្មែរ លាវ និងចិន។ ការខុសគ្នានូវចំនួនឆ្នាំនេះមកពីអ្នកនិពន្ធមានការប្រញាប់ប្រញាល់ពេកក្នុងការតាក់តែងលិខិតទៅកាន់សម្តេចក្រឡាហោម សខេងខណៈពេលដែលលោកទើបតែត្រូវបានព្រះមហាក្សត្រប្រទានគោរមងារជា**សម្តេចក្រឡាហោម**នេះ ដោយមិនបានគិតគូរកាលបរិច្ឆេទច្បាស់លាស់ ផងទេ។ ថ្ងៃផ្ញើលិខិតនេះទៅលោកក៏មានអមទាំងលិខិតជូនពរ និងអបអរសាទរ**សម្តេចក្រឡាហោម**មួយច្បាប់ផងដែរ។

ទោះបីយ៉ាងណាក៏ដោយ ប្រសិនបើយើងនិយាយថា ភូមិទាំងបីមានអាយុជិត៤០០ឆ្នាំ ក៏ប្រហែលជាមិនខុសដែរទេ ពីព្រោះ លាវដែលត្រូវទៅរស់

---

[119] តាមឯកឧត្តមបណ្ឌិត្យសភាចារ្យ ស៊ន សំណាង ចិនដែលចូលមករស់នៅស្រុកខ្មែរ(ចិនចំណាកស្រុក)ភាគច្រើនជាជនជាតិប្រុសៗ។

នៅខេត្តភាគខាងត្បូងនោះមិនមែនទៅរស់នៅកវែកកផ្ទាំងកើតបានជាភូមិភ្លាមៗទេ ក្រោយពីព្រឹត្តិការណ៍ដល់ដំរីនោះ។ យ៉ាងហោចណាស់ ក៏ត្រូវ៥ទៅ១៥ឆ្នាំ ឬច្រើនជាងនេះក៏ថាបានដែរ ទើបអាចបន្សាំខ្លួនជាមួយជនជាតិខ្មែរម្ចាស់ស្រុកបាន ហើយបង្កើតបានភូមិដាច់ដោយឡែកពីគ្នាដូចការរៀបរាប់ខាងលើនេះ។ ព្រឹទ្ធាចារ្យ សៅ ស៊ុំ[120]កាលពីលោកនៅមានជន្មាយុនៅឡើយបាននិទានប្រាប់លោកយាយឧបាសិកា កាក់ ធួង ថា "លោកបានដឹងតៗគ្នាមកថា ទីតាំងនៅក្នុងភូមិសាស្ត្រខាងលើសម្បូរទៅដោយព្រៃ និងដើមឈើធំៗជាច្រើន។ ប្រជារាស្ត្រភូមិនេះ កាលនោះមានតែផ្ទះមួយ ឬពីរប៉ុណ្ណោះ តែដោយសារនៅប្រទេសយើងមានច្រើនជនជាតិចម្រុះគ្នា ទើបបណ្ដាលឲ្យមានសង្គ្រាមប្រកាន់ពូជសាសន៍រវាងគ្នាដូចជាទ័ពខ្មែរ លាវ និងចិន ជាដើម។ ភូមិសមរលាវ ជាទីសមរភូមិរបស់លាវ ភូមិសមរខ្មែរ ជាសមរភូមិរបស់ខ្មែរ និងដូចគ្នាដែរ ភូមិសមរចិន"។ ភូមិទាំងបីនេះមានទីតាំងព្រំប្រទល់ជាប់គ្នារាងដូចត្រីកោណ គឺភូមិសមរលាវស្ថិតនៅភាគខាងជើង ភូមិសមរខ្មែរស្ថិតនៅភាគខាងត្បូងអមសងខាងផ្លូវពីភូមិឫស្សីថ្មី ឃុំចំប៉ា ចុះទៅភូមិនានាទៀត និងភូមិសមរចិនមានទីតាំងស្ថិតនៅភាគខាងកើតនៃភូមិសមរខ្មែរ។ ចំណេរតៗមក ភូមិនីមួយៗកាន់តែមានប្រជារាស្ត្រច្រើនឡើងៗ ហើយកាន់តែមានទំហំធំឡើងៗដែរ។ សម្ដេចព្រះសង្ឃរាជ ជួន ណាត ជោតញ្ញាណោ បានមានព្រះរាជបន្ទូល

[120] លោកបានធ្វើមរណកាលក្នុងជន្មាយុ៨៣ឆ្នាំ នាឆ្នាំ១៩៩៩។

តាមវិទ្យុជាតិក្នុង ទសវត្សឆ្នាំ៦០ប្លាយទាក់ទងនឹងប្រវត្តិភូមិខ្លះនៅក្នុងស្រុកព្រៃកប្បាស ខេត្តតាកែវ។ សម្តេចមានព្រះបន្ទូលថា គេដេញចាប់ហ្លួង គឺមានប្រភពចេញមកពីសមរភូមិទាំងបី (សមរលាវ សមរចិន និង សមរខ្មែរ) បន្តទៅភូមិក្រវែលទៀត ដែលក្លាយទៅជា ក្រវែលទាក និងភ្ជាប់មកភូមិបានញយក្លាយមកជាភូមិបានយ[121] សព្វថ្ងៃភូមិនេះស្ថិតនៅក្នុងឃុំអង្កាញ់ ស្រុកអង្គរបុរី ខេត្តតាកែវ និងជាចុងក្រោយហ្លួងត្រូវគេចាប់បាននៅត្រង់ភូមិ បានហ្លួង[122] ឃុំចំប៉ា ស្រុកព្រៃកប្បាស ខេត្តតាកែវសព្វថ្ងៃនេះ។ ទាក់ទងនឹងពាក្យ ហ្លួង នេះមានភូមិមួយទៀតឈ្មោះថា ភូមិកំពង់ហ្លួង ស្ថិតនៅក្នុង ឃុំអង្គរបុរី ស្រុកអង្គរបុរី ខេត្តតាកែវដែរ គឺស្ថិតនៅក្នុងទីប្រជុំជននៃសាលាស្រុកអង្គរបុរីបច្ចុប្បន្ន។ តាមប្រសាសន៍របស់លោកយាយឧបាសិកា កាក់ ធួង ដដែល លោកយាយឧបាសិកា សៅ ស៊ាង (យាយស៊ាង)ជន្មាយុ៩៩ឆ្នាំ ដែលបានទទួលអនិច្ចកម្មនាឆ្នាំ២០១០កន្លងទៅនេះ បានមានប្រសាសន៍ថា តាមលោកយាយដឹងត១

[121] មានវិទ្យាល័យមួយក្នុងភូមិសាស្ត្រខាងលើឈ្មោះ វិទ្យាល័យបានយ(អានថា បា-នយ)។

[122] ឃើញបង្គោលគីឡូម៉ែត្រទៅរកភូមិនេះសរសេរថា **បានលួង** សរសេរនេះមិនត្រូវទេ គួរកែសម្រួលទៅជា **បានហ្លួង** វិញ ពីព្រោះវាអាចបាត់បង់អត្ថន័យដែលអ្នកស្រុកចង់បាន។ **ហ្លួង=ស្តេច=ព្រះរាជា** ហើយប្រសិនបើភូមិនេះ សរសេរថា បានលួង ក៏គួរតែកែវិញដែរ លួង នេះមានន័យថា **លួងលោម**។ គីឡូម៉ែត្រឈ្មោះ**ភ្នំជីសូរ្យ**ក៏ដូចគ្នាដែរ សរសេរនៅត្រង់កាច់ជ្រុងថ្នល់ទទឹងបត់ទៅរកផ្សារបត់រកា ត្រឹមត្រូវ ប៉ុន្តែនៅលើបង្គោលគីឡូម៉ែត្រសរសេរថា **ភ្នំសូរ** លើផ្លូវតែមួយសោះ។ ប្រសិនបើចង់សំដៅទៅលើអ្នកកសាងប្រាសាទភ្នំនេះ គឺព្រះបាទ **សូរ្យវរ្ម័នទី១** ដូច្នេះគួរគប្បី សរសេរយ៉ាងដូច្នេះវិញ។ ប៉ុន្តែប្រសិនចង់សរសេរដោយសំដៅទៅលើព្រះនាមព្រះ **ឥសូរ** ក៏បានដែរ សំខាន់គឺយកមួយណាឲ្យឯកភាពគ្នា ចៀសវាងលើវិធីតែមួយសរសេរបានពីររបៀបអញ្ចឹង។

គ្នាមកថា ភូមិសមរលោវនេះ បានកើតឡើងជាយូរយារណាស់មកហើយ។ តាំងពីលោកយាយធំដឹងក្តីមក ភូមិនេះមានផ្ទះមិនច្រើនដូចសព្វថ្ងៃនេះទេ។ ចាស់ៗបានរស់នៅយ៉ាងសុខដុមរមនា ហើយវត្តសមរលោវទៀតសោតក៏បានកើតឡើងតាំងពីយូរមកហើយដែរ។ លោកយាយក៏កើតមិនទាន់នឹងការបង្កើតវត្តនេះដែរ។

ក្នុងអត្ថបទមួយស្តីពីប្រវត្តិឈ្មោះភូមិសមរលោវរបស់លោក សេង សាកល[123] បានគូសបញ្ជាក់ថា លោកបានធ្វើការសិក្សាស្រាវជ្រាវតាមរយៈការសាកសួរព័ត៌មានពីព្រឹទ្ធាចារ្យ និងអ្នកភូមិដែលកំពុងរស់នៅក្នុងភូមិនោះបានឲ្យដឹងថា ភូមិសមរលោវមានប្រវត្តិកកើតតាំងពីយូរយារណាស់មកហើយ តែពុំមាននរណាម្នាក់បានដឹងអំពីកាលបរិច្ឆេទនេះពិតប្រាកដឡើយ។

ដូចប្រសាសន៍ព្រឹទ្ធាចារ្យសៅស៊ុំ ដែរ លោកយាយឧបាសិកា កាក់ ធួង មានជន្មាយុ៨៦ឆ្នាំបានប្រាប់ឲ្យដឹងថា អ្នកភូមិនេះតាំងពីដើមយូរលង់ណាស់មកហើយភាគច្រើននៃអ្នកភូមិសុទ្ធតែជាបងប្អូននឹងគ្នាដែលមានសែស្រឡាយជាប់សាច់ឈាមគ្នាតៗមកច្រើនជំនាន់រហូតមកដល់សព្វថ្ងៃនេះ។ នៅពេលជួបសម្ភាសន៍ជាមួយអ្នកនិពន្ធ លោកយាយបានព្យាយាមរៀបរាប់នឹងការសួរដេញដោលដោយលើកឧទាហរណ៍គ្រួសារលោកយាយផ្ទាល់។

---

[123] លោក សេង សាកល ជានិស្សិតបរិញ្ញាបត្រ នីតិសាស្ត្រ សិក្សាពីឆ្នាំ២០១១ ដល់២០១៤ និងឆ្នាំ ២០១៤ ដល់២០១៧ ជានិស្សិតបរិញ្ញាបត្រភាសាអង់គ្លេសនៅសាកលវិទ្យាល័យជាតិគ្រប់គ្រង។ លោកបានស្រាវជ្រាវព័ត៌មាននេះយ៉ាងសង្ខេបនៅពេលដែលសាស្ត្រាចារ្យតម្រូវឲ្យធ្វើកិច្ចការ (Assignment) កាលពីលោកសិក្សាមុខវិជ្ជាប្រវត្តិវិទ្យានៅថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន។

ក្នុងវ័យ៨៦ឆ្នាំ ភ្នែកពាក់វ៉ែនតា ដៃម្ខាងកាន់ត្បាល់បុកស្លាក្បែរអក កំបោរ មាត់ទំពារស្លាម្លូរ បណ្ដើរដែល មានបបូរមាត់ប្រឡាក់ទឹកមាត់ស្លាឡើង ពណ៌ក្រហមផង លោកយាយអង្គុយសញ្ជឹងគិតមួយសន្ទុះហើយបានមាន ប្រសាសន៍ដោយស្មារតីចងចាំថា ជីតា(កុង)របស់គាត់ឈ្មោះ កុង[124] ហាស់ យាយឈ្មោះយាយ ញឹម។ លោកបានគ្នាជាប្ដីប្រពន្ធបន្សល់ទុកនៅកូនប្រុស ស្រីចំនួន៦រូប ក្នុងនោះមានទី១ ឈ្មោះ កុង ងន ប្រពន្ធឈ្មោះ យាយ កាន ទី ២ ឈ្មោះ កុង អាន់ ប្រពន្ធឈ្មោះយាយស៊ាត ទី៣ ឈ្មោះយាយ លន ប្ដីឈ្មោះ កុង យុន ទី៤ ឈ្មោះយាយ ទន(ហៅ ហម) ប្ដីឈ្មោះកុង ហ៊ាន(ហៀន) ទី៥ ឈ្មោះកុង ស៊ន ប្រពន្ធឈ្មោះយាយ អាំង និងទី៦ ឈ្មោះយាយ មុជ ប្ដីឈ្មោះ កុង ទុយ។ លោកយាយ កាត់ ធួង បន្តថា ក្នុងចំណោមឈ្មោះបុព្វការីជនខាង លើ គឺយាយ ទន (ហម) និងកុង ហ៊ាន(ហៀន) ត្រូវជាមាតាបិតារបស់គាត់ ដែលមានកូនចំនួន៨រូប ប្រុស៥រូប និងស្រី៣រូប។ ក្នុងនោះមាន៖ ទី១ ឈ្មោះ កុង ទួន(ស្លាប់) ភរិយាឈ្មោះយាយ វ៉ាន់ (ស្លាប់) ទី២ ឈ្មោះ កុងទួង (ស្លាប់) មានភរិយាឈ្មោះ យាយ សែ (នៅមានជន្មាយុ) និងយាយ ស៊ុយ (នៅមានជន្មាយុ) ទី៣ ឈ្មោះ កុង ឌួង(ស្លាប់) ភរិយាឈ្មោះយាយ អ៊ាវ(នៅ មានជន្មាយុ) ទី៤ គឺរូបលោកយាយផ្ទាល់ឈ្មោះ កាក់ធួង (បានទទួលអនិច្ច

---

[124] ភូមិសមរលាវ ប្រជារាស្ត្រនាំគ្នាប្រើភាសាហកគ្នាបៀបជាកូនចៅកាត់ចិនទាំងអស់ដូចជា កុង យាយ (មិនឮហៅថា ម៉ា ទេ) កូវ(ប្អូនស្រីរបស់ប៉ា) ទ្រា (សាច់ថ្លៃ) អ៊ី(ប្អូនស្រីរបស់ម្ដាយ) គឹម(ភរិយារបស់ ប្អូនប្រុសម្ដាយ) គូ(ប្អូនប្រុសរបស់ ម្ដាយ) ស៊ឹម សោ នឹង(បងថ្លៃស្រី-ប្រុស)។ល។

កម្មថ្ងៃ៥កើត ខែទុតិយាសាឍ ឆ្នាំច សំរិទ្ធ ស័ក ព.ស២៥៦២ត្រូវនឹងថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៨ វេលាម៉ោង៤និង១៥នាទីល្ងាច) មានស្វាមីឈ្មោះកុង សេង អ៊ន[125] (មរណៈ ភាពនៅថ្ងៃសៅរ៍ ទី២៧ ខែសីហា ឆ្នាំ២០០៥ ត្រូវនឹង ថ្ងៃ៧រោជ ខែស្រាពណ៍ ឆ្នាំរកា សប្តស័ក ពស ២៥៤៩ វេលាម៉ោង២ និង២៥ នាទីរសៀល) ទី៥ ឈ្មោះលោកយាយ ធូ (បានទទួលអនិច្ចកម្មនៅថ្ងៃអង្គារ៍ ១៤រោជ ថ្ងៃកោរ ខែផល្គុន ឆ្នាំមមែ សប្តស័ក ព.ស ២៥៥៩ត្រូវនឹងទី៥ ខែ មេសា ឆ្នាំ២០១៦ វេលាម៉ោង១ រំលងអធ្រាត្រ) ស្វាមីឈ្មោះកុង មូល (នៅ មានជន្មាយុ) ទី៦ ឈ្មោះកុង នូ (នៅមានជន្មាយុ) ភរិយាឈ្មោះយាយ ស្រួច (ស្លាប់) និងយាយ ស្រ៊ន(ស្លាប់) ទី៧ ឈ្មោះ កុង ឈាង(ស្លាប់) ភរិយា យាយ សះ (នៅមានជន្មាយុ) និងទី៨ ឈ្មោះយាយ យាង(នៅមានជន្មាយុ) ស្វាមី កុង គួយ(នៅមានជន្មាយុ)។ ដោយឡែក លោកយាយមានស្វាមី ឈ្មោះកុង សេង អ៊ន នោះបានបន្សល់ទុកកូនចំនួន៧នាក់ ប្រុស៤ និងស្រី៣ នាក់ ព្រមទាំងចៅចំនួន២៤នាក់ និងចៅទួតចំនួន១៥នាក់។ រីឯកុង ហ៊ាន (ហៀន) ជាកូនរបស់កុង កាក់ យាយ ហែម ដែលជាម្តាយឪពុកបង្កើតរបស់ លោកយាយមានបងប្អូនចំនួន៤រូបទៀតដូចជា ទី១ឈ្មោះយាយ ព្រីង មាន កុងទ្រី ជាស្វាមី ទី២ ឈ្មោះយាយ អ៊ឹម កុង ហ៊ាម ទី៣ ឈ្មោះ កុង ងៀង យាយ ឃី និងទី៤ ឈ្មោះកុង ទុប យាយ ពេន។ ចំនួនសមាជិកខាងលើដើម្បីបញ្ជាក់

[125] បិតាបង្កើតរបស់អ្នកនិពន្ធសៀវភៅ(សេង ប៊ុនធឿន) បានធ្វើមរណៈកាលនៅឆ្នាំ២០០៥ ក្នុងជន្មាយុ៧៦ឆ្នាំ។

ឲ្យឃើញថា ភូមិសមរលោវ មានពូជពង្សវង្សត្រកូល ជាញាតិវង្សមិនឆ្ងាយពីគ្នាទេ ប៉ុន្តែគ្រួសារនេះ ចេះតែបំបែកជាសាខាញាតិធំឡើងៗរហូតបានជាសមាជិកដ៏ច្រើនដូចសព្វថ្ងៃនេះ។ (សូមមើលបន្ថែមតារាងខាងក្រោម)។


កុង ហាស់
យាយ ញឹម
កុង ងន
យាយ កាន
កុង អាន់
យាយ ស៊ាន
យាយ លន
កុង យុន
យាយ ទន(ហម)
កុង ហៀន(ហ៊ាន)
កុង ស៊ិន
យាយ អាំង
យាយ មុជ
កុង ទុយ
កុង ទូន
យាយ វ៉ាន់
១-ហ៊ាន ទី (ស្លាប់)
២-ហ៊ាន គិ (សុន)
៣-ហ៊ាន គូ (ឈុំ)
៤-ហ៊ាន គីម (លាង)
កុងទូង យាយ សែ
យាយ ស៊ុយ
-ហ៊ាន លឹម(គីមស្រ៊ាង)
-ហ៊ាន ចំរើន ( សេងលីម)
កុង ខូង
យាយ និវ
១-ហ៊ាន ជាវ(គន់)
២-ហ៊ាន គីមលី(សេងលី)
៣-ហ៊ាន អេង(ម៉ាង)
៤-ហ៊ាន ឈន(ចិន)
៥-ហ៊ាន ឈី(កេង)
៦-ហ៊ាន ភន/ទូច(យូ)
៧-ហ៊ាន ចាយ(អ៊ី)
៨-ហ៊ាន យី(ធី)
៩-ហ៊ាន លឹម(សៀកម៉េង)
១០-ហ៊ាន កប(លី)
យាយ ធូង
កុង និន
១-សេង សុធន់/អេង (សុភី)
២-សេង សុខហេង
(មុន)
៣-សេង ឆេងលាង
(គីម)
៤-សេង ឆេងឡៃ(ចូក)
(សាមឿន)
៥-សេង ម៉េងហ៊ាង
(មាន/ហ៊ី)
៦-សេង ប៊ុនធឿន
(ស្រីពេជ្រ)
៧-សេង ស៊ាងហៃ(មិត្ត)
យាយ ធូ
កុង មូល
១-គង់ ធី (ផល្លី)
២-គង់ ណាត្រី (តៃអ៊ី)
៣-គង់ សេងលី (គីមលី)
៤-គង់ ចុល (ចុន/ចន្ទា)
៥-គង់ សេងលឹម
(ចំរើន)
៦-គង់ សារឹម(ផល)
៧-គង់ ធីម (មួយគា)
៨-គង់ សារី (វណ្ណា)
កុង ទូ យាយ ស្រូច
យាយ ស្រេន
១-ហ៊ាន ស្រ៊ូ
២-ហ៊ាន ស្រៀន
៣-ហ៊ាន ប៉ុក
៤-ជាវ ស៊ាវហៃ(ស៊ី)
៥-ជាវ ម៉េងហេង(ណារី)
៦-ជាវ ហុកម៉េង(កេសាវ៉ា)
៧-ទូ ស្រីមៅ(ផន)
៨-ទូ សេដា(វៃ)
៩-ទូ ស៊ីលា(យ៉ន)
កុង ឈាង
យាយ សះ
១-ហ៊ាន ឡៃហ៊ាង(វ៉ាន់)
២-ហ៊ាន លាងអ៊ី(ហុង)
៣-ហ៊ាន ប៊ុនហៅប្រុយ
(សារ៉េន)
៤-ហ៊ាន ម៉េងលាង (ចន្ទា)
៥-ហ៊ាន គីមឡេង(ថេន)
៦-ហ៊ាន ម៉េងលី (ស្រីនោ)
៧-ហ៊ាន ដានី(គីមហេង)
៨-ហ៊ាន វាសនា(ចំរុង)
យាយ យាង
កុង គួយ
១-លន ច័ន្ទបុល
(ហុក)
២-លន កា (ប្រេង)
៣-លន យឹម (ខុម)
៤-លន មួយគា (ធីម)
៥-លន កាន(ដារី)

ឈ្មោះដូចបានរៀបរាប់ខាងលើនេះ ខ្លះមិនបានរស់នៅក្នុងភូមិជាមួយគ្នាតទៅទៀតទេ ពោលគឺពួកគាត់ក៏ដូចជាគ្រួសារ កូនចៅបានរស់នៅដោយទីទៃពីគ្នាអាស្រ័យដោយការរៀបចំគូស្រករទៅតាមស្វាមីភរិយាទៅតាមស្ថានភាពជីវភាពតាមបណ្ដាខេត្តខណ្ឌនានាក្នុងព្រះរាជាចក្រកម្ពុជាទាំងមូលដូចជាភ្នំពេញ កំពង់ចាម កំពង់ធំ ខេត្តកណ្ដាល ក្រចេះ ស្ទឹងត្រែង បាត់ដំបង។ល។ លោកយាយបានឲ្យដឹងទៀតថា គាត់ធ្លាប់បានដឹងពីបារាំងដើរទារពន្ធដារពីសំណាក់រាជការបារាំងនៅសម័យអាណានិគមនិយមបារាំង។

ប៉ុន្តែលំបាកយ៉ាងណាក៏មិនស្មើនឹងការរស់នៅក្នុងសម័យប៉ុលពតបីឆ្នាំប្រាំខែនិងម្ភៃខែនោះដែរ។ តាមរយៈប្រវត្តិសាស្ត្រខ្មែរសម័យលង្វែក វត្តមាននៃជនជាតិលាវដែលមានទំនាក់ទំនងជាមួយខ្មែរបានសន្និដ្ឋានថា ភូមិសមរលាវប្រហែលជាកើតឡើងនៅក្នុងសម័យលង្វែកគឺក្រោយពេលដែលលាវមានរឿងរ៉ាវជាមួយខ្មែររឿងដល់ដំរីនេះឯង។ ពេលនោះអាចមានគ្រួសារលាវខ្លះអណ្ដែតត្រសែតមករស់នៅក្នុងតំបន់ដាច់ស្រយាលពីរាជធានីក៏ថាបាន។ រឿងរ៉ាវខាងលើបានពិពណ៌នាអំពីព្រឹត្តការណ៍នានាក្នុងរជ្ជកាល**ព្រះបរមរាជាទី៤**[126]ស្រាប់។ កាលនោះបន្ទាប់ការចាញ់ភ្នាល់ដំរីហើយ លាវមួយក្រុមត្រូវព្រះរាជាខ្មែរឲ្យរស់នៅថែដំរីនៅវត្តភ្នំ គេហៅថា លាវបាក់ទូក មួយក្រុមទៀតបញ្ជូនទៅបាភ្នំ ខេត្តគោកសេះ និងមួយក្រុមទៀត ឲ្យទៅរស់នៅភាគខាងត្បូង

---

[126] ព្រះអង្គជាព្រះរាជបុត្ររបស់ព្រះបាទ ច័ន្ទរាជា ឬអង្គច័ន្ទទី១។

នៃប្រទេសកម្ពុជា[127]។ ក្រុមចុងក្រោយនេះហើយដែលគេបានសន្និដ្ឋានថា បណ្តាលឲ្យមានគ្រួសារជនជាតិលាវខ្លះ(មួយ ឬពីរគ្រួសារ) អណ្តែតរសាត់ទៅដល់ភូមិមួយគឺភូមិសមរលាវ ហើយបានបន្សល់ទុកដោយអ្នកតាយាយលាវជាភស្តុតាងក្នុងវត្តសមរលាវ[128]រហូតដល់សព្វថ្ងៃនេះ។ ចំណែកជនជាតិលាវជំនាន់នោះមានប្រាកដមែន ប៉ុន្តែមិនច្រើនណាស់ទេ អាចមានមួយគ្រួ ឬពីរគ្រួ ឬយ៉ាងណានោះគ្មានណាដឹង និងឯកសារណាមកបញ្ជាក់ឡើយ។ តាមការនិទានតៗគ្នាថា នៅសម័យនោះមានអ្នកចំណូលជាជនជាតិចិន ខណៈដែលជនជាតិខ្មែរបានតាំងទីលំនៅរាយប៉ាយនៅក្នុងតំបន់នេះរួចទៅហើយ។ ជាមួយគ្នានេះ ក៏មានជនជាតិលាវមួយចំនួនតូចបានធ្វើចំណូលស្រុកដែរ។ ការរួមរស់ជាមួយគ្នារវាងជនជាតិផ្សេងគ្នា រមែងតែមានទំនាស់ ឬជម្លោះកើតឡើងជៀសមិនរួច។ នៅផ្នែកខាងដើមនៃសៀវភៅនេះយើងបានប្រើប្រាស់ពាក្យថា សង្គ្រាមរវាងខ្មែរ លាវ និង ចិន។ ពាក្យថា សង្គ្រាមអាចកើតឡើងពីខ្មែរដែលជាម្ចាស់ស្រុកបានមករស់នៅទីនេះមុនគេ ក្រោយមកមានជនជាតិលាវមួយចំនួនតូចជាអ្នកចំណូលថ្មីមករស់នៅជិតនោះដែរ ហើយទន្ទឹមនឹងនោះក៏មានជនជាតិចិន។ សុភាសិតខ្មែរពោលថា "ចានក្នុងរាវរឿងអ្វីមិនប៉ះទង្គិច" បងប្អូនបង្កើតផងនៅមានជម្លោះ ចុះទម្រាំជាតិសាសន៍ផ្សេង

[127] ក្រុមនេះហើយដែលត្រូវបានគិតថា ជាក្រុមបង្កើតបានសមាជិកនៃភូមិសមរលាវ ឃុំពោធិ៍រំចាក ស្រុកព្រៃកប្បាស ខេត្តតាកែវ។

[128] ដូចការរៀបរាប់របស់លោកគ្រូ ហុក ខេង ស្រាប់។

គ្នា? គ្រាដំបូងប្រហែលពួកនេះមិនសូវស៊ីចង្វាក់គ្នាក្នុងការរស់នៅ ឬរបៀបជាប្រកាន់ជាតិសាសន៍រៀងៗខ្លួនផងទើបធ្វើឲ្យមានសង្គ្រាម[129]ដណ្តើមទីកន្លែងគ្នាកាន់កាប់តែម្តងទៅ។ ប៉ុន្តែយើងមិនដឹងថា ការដណ្តើមទីគ្នារស់នៅនេះមានទ្រង់ ទ្រាយធំប៉ុណ្ណា ហើយជនជាតិលាវអាចមានរបៀបច្រើនក្នុងការដណ្តើមទីតាំងរស់នៅនេះគឺដណ្តើមយកកន្លែងធ្វើផ្ទះ[130]។ល។ក្នុងន័យនេះចិនខ្មែរ លាវអាច មិនមែនការច្បាំងគ្នាយកប្រទេសដូចការនិទានរបស់លោក សៅឈឿង បានរៀបរាប់ខាងលើនោះផងក៏ថាបានថ្វីបើមានឈ្មោះទីកន្លែងដែលជាឈ្មោះ តំបន់ពិតប្រាកដក៏ដោយ។ ប៉ុន្តែចំពោះករណីថា ព្រះករុណា ហ៊ុនទៀន ទ្រង់ឃើញលាវវាយចូលមកនៅសល់តែ១៤គីឡូម៉ែត្រទៀតជិតដល់ខ្សែក្រវាត់ក្រុងហើយទើបទ្រង់ប្តឹងទៅមហាអំណាច ចិនឲ្យជួយនោះ តាមការសន្និដ្ឋាន អាចប្រហែលជារឿងនិទានច្រើនជាង។ ទោះបីយ៉ាងណា វាអាចគ្រាន់តែជារូប ភាពឈ្លោះប្រកែកគ្នារវាងគ្រួសារ និងគ្រួសារ ឬសហគមន៍តូចមួយ និងសហគមន៍។ យើងសូមលើកយកបទពិសោធន៍ជាឧទាហរណ៍មកធ្វើអធិប្បាយខ្លះកាលពីរូបខ្ញុំនៅក្មេងពីសម័យមុន (ជំនាន់ទសវត្សឆ្នាំ៨០ ពេលដែលរូបខ្ញុំ[131]ផ្ទាល់នៅជាក្មេងឃ្វាលគោនៅឡើយ) ពេលចេញទៅឃ្វាលគោក្រុមខ្ញុំតែងតែប្រកាន់គ្នា អ្នកនេះមកពីភូមិនេះ អ្នកនោះមកពីភូមិនោះ ពេល

[129] ការប្រើពាក្យពេចន៍ ពីព្រោះសំដៅលើ សមរ=សមរភូមិ

[130] មានទីតាំងឃាយលាវខាងក្រោយសាលាឆាន់វត្តសមរលាវជាស្លាកស្នាមប្រវត្តិសាស្ត្រ

[131] អ្នកនិពន្ធសៀវភៅនេះ។

ទៅដល់ព្រៃ ឬវាលស្រែ គ្នាយើងបានជួបគ្នាចំអែចំអន់គ្នាលេងជាការសប្បាយ ប៉ុន្តែរហូតប្រែក្លាយជាខឹង និងអាក់អន់ចិត្តគ្នាបន្តិចបន្តួច ថ្ងៃបន្តបន្ទាប់មក ពួកយើងបបួលគ្នាបង្កើតទី(សមរភូមិ)បាញ់គ្នាដោយដំពាមកៅស៊ូធ្វើជាល្បែងកំសាន្ត ហើយនាំគ្នាហៅឈ្មោះភូមិតែម្តង ដូចជា ពួកសមរលាវ ពួកសមរចិន ឬក្រុមភូមិសមរខ្មែរ។ ក្រុមយុវជនភូមិសមរលាវ សមរខ្មែរ សមរចិនរួមគ្នាបានមួយក្រុមទៅបាញ់គ្នាជាមួយក្មេងឃ្វាលគោមកពីភូមិកំពែង ភូមិចំណោមភូមិព្រៃផ្តៅភូមិព្រៃរបងជាដើម ។ល។ ដែលពួកគាត់បានផ្តុំគ្នាជាក្រុមពួកដើម្បីជួយប្រយុទ្ធគ្នាតទល់នឹងពួកយុវជនសមរលាវ យុវជនសមរចិន និងសមរខ្មែរ។ នេះជាប្រភេទជម្លោះដណ្តើមទីតាំងគ្នាយកវាលឲ្យគោស៊ីស្មៅ។ ប៉ុន្តែចាស់ៗ និងអាជ្ញាធរមិនបានចាប់អារម្មណ៍អំពីរឿងនេះទេ ដឹងតែក្មេងៗឃ្វាលគោនាំគ្នាលេងសប្បាយនឹងគ្នា។..រហូតដល់មានការប្រកាប់ប្រចាក់គ្នាបានជារបួសស្នាមរៀងៗខ្លួនទៅទើបចាស់ៗនិង អាជ្ញាធរមូលដ្ឋានលោកចាប់អារម្មណ៍ និងផ្តើមមានវិធានការទប់ស្កាត់ឈប់ឲ្យមានរឿងហ្នឹងកើតឡើងទៀត។ បច្ចុប្បន្នអ្នកភូមិស្រុកនេះមិនមានការបញ្ចេញចេញគោទៅស៊ីស្មៅតាមវាលស្រែដូចមុនៗទៀតទេសូម្បីតែដឹកគោ(បណ្តើរគោ)ឲ្យស៊ីស្មៅតាមភ្លឺស្រែដែលមានស្រូវក្នុងស្រែនោះក៏មិនមានដែរ អ្នកភូមិចិញ្ចឹមគោតែងតែច្រូតស្មៅឲ្យគោ ឬទិញដើមស្រូវ (ស្រូវស្វិត ឬច្រូតស្រូវមិនស្វិត) ឲ្យគោស៊ីតែម្តង។

សរុបសេចក្តីមកជម្លោះនៃភូមិទាំងបីខាងលើមិនមែនជាប្រភេទជម្លោះដណ្តើមទឹកដីធំដុំនោះទេ។ ប្រសិនបើគិតថាជនជាតិទាំងបី(ខ្មែរ លាវ

ចិន)ខាងលើ ឈ្លោះគ្នាដណ្ដើមទឹកដីទ្រង់ទ្រាយធំដូចសង្គ្រាមរវាងប្រទេស និងប្រទេសនោះ តើទឹកដីខ្មែរមាននៅទីតាំងណាទៅ? ហើយបើចិនមកវាយយកទឹកដីខ្មែរទាំងមូលមែន តើគេចូលតាមណាបើជុំវិញសុទ្ធតែដីខ្មែររួចទៅហើយនោះ?ដូច្នេះពាក្យ សមរលាវ សមរចិន សមរខ្មែរ អាចជាពាក្យអ្នកស្រុកដែលហៅគ្នា ឬបង្អាប់គ្នា ហើយក៏ចេះតែហៅតៗគ្នាចំណោរចីរកាលមកបង្កើតបានជាភូមិដូចសព្វថ្ងៃនេះទៅ។ សូមបញ្ជាក់ថា ក្នុងប្រវត្តិសាស្ត្រយើងមិនធ្លាប់មានចិនធ្វើសង្គ្រាមជាមួយខ្មែរទេ ប្រសិនបើមានក៏មាននៅក្នុងអក្សរសិល្ប៍ខ្មែរទៅវិញ ដូចជាក្នុងរឿងធនញ្ជ័យ ជាដើម។ តាមការកត់សម្គាល់របស់ខ្ញុំ វត្តមានជនជាតិចិននៅលើទឹកដីខ្មែរ គឺមានលក្ខណៈជាគ្រួសារ ជាអ្នករកស៊ីចិនចាកចោលស្រុកទេស ពនេចរដើរផ្សងព្រេង ក្រោយមកដោយមើលឃើញពួកនេះពូកែរកស៊ី(ខំប្រឹងរកស៊ី)ជាងខ្មែរ ឆ្លាតវៃ ហើយភាគច្រើន សម្បុរសជាងខ្មែរ មានរូបឆោមលោមពណ៌ស្អាតផង ដើម្បីបានទឹកដីរស់នៅផងមនោសញ្ចេតនាស្នេហាផង(ខ្មែរស្រឡាញ់ចិន ចិនស្រឡាញ់ខ្មែរ) ក៏រៀបការជាមួយគ្នាកើតបានជាកូនពូនជាចៅតៗមក។ បច្ចុប្បន្ននេះ ចិនមិនមានព្រំប្រទល់ជាប់ខ្មែរយើងទេគឺព្រំដែនប្រទេសចិនបានជាប់នឹងប្រទេសឡាវ(លាវ)ឯណោះ។ នៅក្នុងទឹកដីខេត្តតាកែវមានទីកន្លែងដែលមានឈ្មោះលាវនេះប្រាំកន្លែង៖

ទី១ ភូមិសមរលាវ ឃុំពោធិ៍រំចាក ស្រុកព្រៃកប្បាស

ទី២ ភូមិកំពង់លាវ ឃុំកំពង់រាប ស្រុកព្រៃកប្បាស

ទី៣ ភូមិក្រាំងលាវ ឃុំរវៀង ស្រុកសំរោង

ទី៤ ភូមិក្រាំងលាវ ឃុំក្រាំងលាវ ស្រុកបាទី

និងទី៥ ស្ពានលាវលង់ ស្ថិតនៅភូមិខ្នារោង ឃុំពារាម ព្រំប្រទល់ភូមិដូង ឃុំដូង ស្រុកបាទី។ តាមការស្រាវជ្រាវ និងផ្ទៀងផ្ទាត់ប្រវត្តិសាស្ត្រ ភូមិសមរលាវទំនងជាកើតនៅចុងសម័យលង្វែក គឺនៅក្រោយពេលការយាងចូលព្រះទិវង្គតរបស់ព្រះបាទ ច័ន្ទរាជា ឬអង្គច័ន្ទទី១ ព្រះរាជបុត្ររបស់ទ្រង់ឡើងគ្រងរាជសម្បត្តិបន្ត ព្រះបរមមិន្ទរាជា ឬព្រះបរមរាជាទី៤ ព្រះរាជាលាវមកបបួលព្រះរាជាខ្មែរជល់ដំរីតែម្តង[132]។ ទសវត្សក្រោយៗមកក៏មានវត្តមានជនជាតិលាវរស់នៅរាយប៉ាយតាមភូមិស្រុកខេត្តទូទាំងព្រះរាជាណាចក្រកម្ពុជាដូចការអត្ថាធិប្បាយខាងលើ។

សូមពិនិត្យទៅលើអត្ថន័យនៃពាក្យ សមរ [ស:ម:រ:] សមរលាវ សមរខ្មែរ សមរចិន អាចមានន័យថា **សេចក្តីនឹករលឹកគ្នា**[133]។ នៅក្នុងកិច្ចប្រជុំអនុម័ត ទទួលស្គាល់ភូមិសមរលាវ សមរខ្មែរឡើងវិញកាលពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ នោះ ក្រុមប្រឹក្សាជាតិភាសាខ្មែរ ឯកឧត្តមបណ្ឌិត នៅ

[132] ការយល់ឃើញនេះអាចត្រូវ ពីព្រោះតាមពិតកាលពីសម័យបារាំងចូលស្រុកខ្មែរអ្នកភូមិនេះត្រូវបារាំងយកពន្ធគ្រប់តែគ្នា ហើយរត់គេចបារាំងមិនចង់ជួបមុខបារាំង និងខឹងសម្បារនឹងបារាំងមិនខុសពីអ្នកភូមិក្រាំងលាវនៅខេត្តកំពង់ឆ្នាំងនោះឡើយ។

[133] សូមស្តាប់បទចម្រៀងរបស់អ្នកនិពន្ធក្នុង Yout ube Channel :Seng Bt hoeun បទរាំវង់សមរលាវ សារ៉ាវ៉ាន់ភូមិយើង ដើមត្នោតភូមិអូន រលួសចេញផ្កា ថ្កាល់ខួចមន្តស្នេហ៍ សំឡីកប្បាស បុណ្យភ្ជុំឆ្នាំនេះ។

ស៊ុន[134] អតីតអនុប្រធានអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាជាតិភាសាខ្មែរបានរំលឹកអង្គប្រជុំថាឈ្មោះ ភូមិខាងលើអាចមានន័យថា **សេចក្ដីនឹករលឹកគ្នា** ក៏បាន។ ភូមិនេះមិនត្រឹមតែមានអត្ថន័យថា ជាសមរភូមិរបស់ជនជាតិទាំងបីដូចបានរៀបរាប់ខាងលើទេ ប៉ុន្តែវាអាចមានន័យថា ជា**ការនឹករលឹកគ្នា** របស់ជនជាតិទាំងបីក៏ថាបាន។ ប្រសាសន៍នេះត្រូវបានគាំទ្រដោយព្រះតេជគុណបណ្ឌិត សុខ ប៊ុនធឿន ព្រះចៅអធិការវត្តនន្ទមុនី ខណ្ឌមានជ័យ រាជធានីភ្នំពេញ និងឯកឧត្តម ឈន អៀម អតីតរដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា និងជាទីប្រឹក្សាក្រុមប្រឹក្សាជាតិភាសាខ្មែរ។ អ្នកភូមិទាំងបីមានចរិតស្លូតបូត ឧស្សាហ៍ព្យាយាម ចេះស្រឡាញ់ជួយយកអាសារគ្នា និងចេះជួយទុក្ខធុរៈគ្នាណាស់ដែលគួរយកជាគំរូបានទៀតផង ជាពិសេសយុវជនជំនាន់មុន និងបច្ចុប្បន្ននេះតែម្ដង។ ឆ្លៀតឱកាសនេះ ខ្ញុំសូមសំដែងការកោតសរសើរយ៉ាងខ្លាំងដល់ពួកគេ( យុវជនភូមិទាំងបី) ជាអតីតសិស្សវិទ្យាល័យ អនុវិទ្យាល័យសមរលាវនេះ ដែលជានិច្ចកាលចេះសាមគ្គីគ្នា ស្គាល់ទុក្ខធុរៈគ្នា ស្គាល់ខ្ពស់ស្គាល់ទាប ស្គាល់សិស្សច្បង និងសិស្សប្អូន។ ពួកគេតែងតែរៃអង្គាសប្រាក់គ្នាដើម្បីរៀបចំកម្មវិធីជួបជុំក្នុងពិធីអបអរសាទរចូលឆ្នាំខ្មែរ និងការរាំកំសាន្តជារៀងរាល់ឆ្នាំយ៉ាងសប្បាយរីករាយ។ យើងអាចរាប់ឈ្មោះយុវជនដែលសកម្ម

[134] ឯកឧត្តមបណ្ឌិតត្រូវបានតែងតាំងជាប្រធានជាក្រុមប្រឹក្សាជាតិភាសាខ្មែរមានឋានៈស្មើអនុរដ្ឋលេខាធិការតាមព្រះរាជក្រឹត្យលេខនស/រកត/០៨១៧/៦៩២ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ តែជាអកុសល្យលោកបានទទួលមរណៈភាពកាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៧ ដោយរោគាពាធ។

ក្នុងការងាររៀបចំពិធីផ្សេងៗសម្រាប់ភូមិស្រុកនេះបានខ្លះដូចជា លោក ទុយ រឿនងនសីហា ឌុច រ័ទ្ធី ស៊ុំ គីមសាន ខិៈ ស្រ៊ុយ ស្រេង សុជាតិ ផាត់ ចន្ថា ចន ប៊ុនថា អ៊ុំ សុខា កញ្ញា សុខ គឹមសួ លោក សេង សាកល ឌុច រដ្ឋា កញ្ញា ប្រាក់ ច័ន្ទខេមរា ហោ ស្រីទូច គន រតនា អ៊ី ផល្លី ឈាង ចាន់នឿន ផៃ លីណា លោក ងន ចាន់ថូ ឌុច ភារ៉ា នី ធារ៉ា គន រ៉ាឆេន មាង មាន កញ្ញា ងនចន្ថា ប្រាក់ ច័ន្ទសិលា ឈាង ចន្នី ឡាច ស្រីលក្ខណ៍ ។ល។ ពួកគេ គួរតែចាត់ទុកថា ជាយុវជនគំរូក្នុងភូមិស្រុក ហើយរាល់ការរៀបចំម្តងៗតែងតែទទួលបានការលើកទឹកចិត្ត សាមគ្គី និងគាំទ្រយ៉ាងខ្លាំងពីព្រះចៅអធិការវត្តពីអ្នកភូមិនិងមិត្តភ័ក្រ្តឯទៀតៗដែលបានរៀបចប់។ ខ្ញុំសូមលើកទឹកចិត្តយ៉ាងខ្លាំងក្លាចំពោះប្អូនៗ ក្មួយៗ គ្រប់ជំនាន់ដែល ជានិច្ចកាលមិនប្រកាន់បក្សពួក ឬនិន្នាការនយោបាយ ឬឆ្លៀតកេងយកប្រយោជន៍ឲ្យក្រុមណាមួយ។ ផ្ទុយទៅវិញ ពួកគាត់តែងតែរក្សាខ្ជាប់ខ្ជួននូវប្រពៃណីដ៏ល្អនេះទុកជារៀងដរាបអស់ពីមួយជំនាន់ទៅមួយជំនាន់ដើម្បីអនុស្សាវរីយ៍ នៃសាមគ្គីភាព មិត្តភាព និងភាពសប្បាយរីករាយរបស់ពួកគាត់។ កម្មភាពផ្សេងៗទៀត អ្នកភូមិសមរលោរ សមរខ្មែរ សមរចិន តែងតែរួមសាមគ្គីគ្នាធ្វើកិច្ចការសង្គម ដូចជាជួសជុលផ្លូវ ជីកប្រឡាយទឹក ឬធ្វើសង្គហៈជួយសង្គ្រោះចាស់ជរា ឬទុរគ៌តជន ជាដើម។ ជាក់ស្តែង កាលពីសុក្រថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៦ នេះ តាមគំនិតផ្តួចផ្តើមរបស់លោក ឡាំ ង

នលី និងអ្នកស្រី ស៊ុយ គឹមហេង[135] គណៈកម្មការអាចារ្យវត្ត ព្រះសង្ឃ និងប្រជាពុទ្ធបរិស័ទភូមិសមរលោវទាំងមូលបានមូលមតិគ្នារៃអង្គាសប្រាក់ អង្ករ និងសម្ភារៈមួយចំនួនរួមជាមួយនឹងការបរិច្ចាកអង្ករមួយបាវពីព្រះចៅអធិការ វត្តជ្រយ ភូមិជ្រយ ឃុំចំប៉ា ស្រុកព្រៃកប្បាសផង សរុបបានអង្ករចំនួន២០០គីឡូក្រាមនិងថវិកាចំនួន៦៨០០០០រៀលយកទៅប្រគេនព្រះចៅអធិការ និងព្រះសង្ឃដែល មានការខ្វះខាតកំពុងគង់នៅវត្តប៉ាក់ណាម ភូមិប៉ាក់ណាម ឃុំត្រពាំងជ្រៃ ស្រុកកោះធំ ខេត្តកណ្ដាល នេះជាសកម្មភាពរបស់អ្នកភូមិដែលគួរឲ្យកោតសរសើរបំផុត។ កាលពីថ្ងៃពុធ ១រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២ ត្រូវនឹងថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៨ កន្លងទៅនេះ លោក ឡាំ ងនលី និងអ្នកស្រី ស៊ុយ គឹមហេង បានដាំបង្គោលតភ្លើងបែបសហគមន៍ចាប់ព្រំប្រទល់ភូមិជម្ពិតនិងភូមិសមរលោវប៉ែកខាងជើងពង្រាយរហូតដល់មុខផ្ទះលោកមេឃុំ ស្រីរ៉េនបន្តកាត់មុខផ្ទះរបស់អ្នកកណ្ដាលភូមិ ដើម្បីធ្វើឲ្យភ្លឺជាប្រយោជន៍ទូទៅ ដល់អ្នកភូមិផង និងអ្នកធ្វើដំណើរឆ្លងកាត់ផង។

មុនឆ្នាំ១៩៧០វត្តសមរលោវមានព្រះសង្ឃមិនក្រោម២០អង្គទេ

[135] លោក ឡាំ ងនលី និងភរិយា ស៊ុយ គឹមហេង ព្រមទាំងគ្រួសារជាអ្នកបានបរិច្ចាកនូវថវិកាដើម្បីបូជាក្នុងព្រះពុទ្ធសាសនាយ៉ាងច្រើនដរាបមក។ លោកបានកសាងអគារសិក្សាមួយខ្នងស្ថិតក្នុងសាលាបឋមសិក្សាជ្រយជម្លូពេជ្រ និងជាអ្នកផ្ដួចផ្ដើមកសាងព្រះវិហារនៅវត្តជ្រយនេះរហូតបានហើយរួចរាល់ជាស្ថាវរកាលពីកន្លងទៅ។ ក្លោងទ្វារថ្មី ( ខាងក្នុង )នៃក្លោងទ្វារផ្លូវចូលវត្តបី(វត្តជ្រយជម្លូរពេជ្រ វត្តសមរលោវ វត្តសមរមេត្រី )ក៏លោកមានសទ្ធាអ្នកកសាងដែរ។ សូមបញ្ជាក់ថា វត្តជ្រយជម្លូរពេជ្រ ពីមុនគេសរសេរថា វត្តជ្រោយជម្លូរពេជ្រ។

ហើយមានតែសម័យកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះ ដែលទីវត្តនេះត្រូវបានប្រែក្លាយទៅជាសហករណ៍ដូចវត្តសមរខ្មែរដែរ ក្រៅពីនេះ ជារោងជីលេខ១ (ជីធម្មជាតិធ្វើពីលាមកមនុស្ស) ច្បារបន្លែ ផ្ទះកម្មាភិបាលខ្មែរក្រហម និងអ្នកមានវណ្ណៈខ្ពស់នារបបនោះ។



អ្នកភូមិសមរលោរលេងល្បែងប្រជាប្រិយនៅឳកាសចូលឆ្នាំខ្មែរប្រពៃណីជាតិ(រូបទី៤)



អ្នកភូមិសមរលាវលេងល្បែងប្រជាប្រិយនៅឪកាសចូលឆ្នាំខ្មែរប្រពៃណីជាតិ(រូបទី៥)



អ្នកភូមិសមរលាវលេងល្បែងប្រជាប្រិយនៅឱកាសចូលឆ្នាំខ្មែរប្រពៃណីជាតិ (រូបទី៦)

## ៣-វត្តសមរលាវ

ទាក់ទងនឹងវត្តសមរលាវ ព្រះតេជគុណព្រះចៅអធិការ ឡាក់ ហំ ហៅ ហ៊ីម បានមានដីកាថា វត្តសមរលាវមានបណ្ដោយប្រវែង២១០ម$^{២}$ និងទទឹងមានប្រវែង១៨០ម$^{២}$និងផ្ទៃដីសរុបមានទំហំ៣៧,៨០០ម$^{២}$។ សាលាធម្មសភាមានទំហំ២៣១ម$^{២}$សាងសង់ក្នុងឆ្នាំ១៩៦៥ ដំណាលគ្នានឹងពហុកីឡដ្ឋានអូឡាំពិករាជធានីភ្នំពេញដែរ។ តាមការស្រាវជ្រាវរបស់លោកគ្រូ ហុក ខេង ហៅគ្រូ ជ្រឹង បានឲ្យដឹងថា តាំងពីការកើតរហូតមក អារាមនេះមានរបងព័ទ្ធជុំ

វិញលម្អទៅដោយក្លោងទ្វារមានចារឹកអក្សរថាវត្តសមរលាវ។ នៅប្របនឹងរបង ក្លោងទ្វារចូលទៅកាន់ទីវត្តខាងឆ្វេងដៃ( ធ្វើដំណើរពីទិសខាងជើង )គេឃើញ មានស្រះទឹកមួយយ៉ាងធំដែលអាចរក្សាទឹកទុកសម្រាប់ប្រើប្រាស់មិនត្រឹមតែ ប្រជារាស្ត្រភូមិសមរលាវមួយប៉ុណ្ណោះទេ ប៉ុន្តែសម្រាប់ប្រជារាស្ត្រភូមិជិតខាង ទៀតផងនាវដូវប្រាំង។ ក្រៅពីស្រះទឹក ទីវត្តក៏រំលេចទៅដោយកុដិ ព្រះវិហារ និងសាលាធម្មសភា ជាពិសេស មានមហាកុដិមួយត្រូវបានប្រសិទ្ធនាមថា កុដិ ហោត្រ័យ ឬសាលាបាលី ( សូមមើលរូបថតនៅក្របខាងមុខ )។ វត្តសមរលាវ មានអាយុមិនខុសពីការកកើតភូមិប៉ុន្មានទេ។ ក្នុងបរិវេណវត្តនេះ មានរោង អ្នកតាមួយកន្លែងមានទីតាំងនៅមាត់ស្រះប៉ែកខាងកើតជាប់របងវត្ត និង អ្នកតាភូមិមួយកន្លែងទៀតមានទីតាំងនៅតាមឆ្លាមុខផ្ទះធៀងខាងជើង គេហដ្ឋាន កុង លិន យាយ គៀត (មាតារបស់លោក លឹម សុខន បច្ចុប្បន្នជា អនុប្រធានលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តតាកែវ )។

សូមបញ្ជាក់ថា គ្រប់ពិធីមង្គលការកូនប្រុសស្រីនៃអ្នកភូមិសមរលាវ ( កូនចៅម្ចាស់ស្រុក ) នៅពេលចាប់ផ្តើមហែកូនកំលោះចូលរោងការ ឬកាលពី សម័យបុរាណ គឺមុនពិធីកាត់សក់បង្កក់សិរី ត្រូវដង្ហែកូនកំលោះអមដោយភ្ញៀវ ខាងប្រុសជិតឆ្ងាយកាន់ជំនូនគ្រប់ដៃទៅធ្វើពិធីប៉ាយ( ពិធីគោរព )បន់ស្រន់សុំ សេចក្តីសុខផ្សេងៗនៅចំពោះមុខរោង( ខ្ទម )អ្នកតាទាំងពីរនេះដែលមានដុំថ្ម ជានិមិត្តរូបអ្នកតារបស់អ្នកភូមិ។ ចំណែកអ្នកតាយាយលាវមិនមានទម្លាប់ ទទួលសំណែនរបស់កូនចៅអ្នកភូមិនៅពេលរៀបមង្គលការទេ គឺអ្នកភូមិ ឬ

ព្រះសង្ឃបាននឹកនាដល់លោកយាយសម្រាប់តែពិធីបុណ្យផ្សេងៗប៉ុណ្ណោះ ដូចជា បុណ្យផ្កា បុណ្យភ្ជុំបិណ្ឌ បុណ្យកឋិន បុណ្យចូលឆ្នាំថ្មី។ល។ ជាពិសេស ពេលកូនចៅអ្នកភូមិមានជំងឺក្ដៅខ្លួន ឬឈឺជំងឺអ្វីផ្សេងៗ គេតែងតែបន់ស្រន់សុំសេចក្ដីសុខពីលោកយាយ និងដូចគ្នាដែរ អ្នកភូមិមិនដែលភ្លេចបន់ស្រន់សុំសេចក្ដីសុខសប្បាយ ឬសុំកុំឲ្យមានភ្លៀងរំខានពិធីរបស់គេទេ ក្នុងករណីអ្នកភូមិមកសុំទីវត្តអារាមធ្វើពិធីបុណ្យគ្រួសារម្ដងៗ[136]។ អ្នកស្រុកដែលតែងតែគោរពបានហៅ រោងយាយលាវៗតរហូតមកដល់សព្វថ្ងៃនេះ។ លោកគ្រូ ហុក ខេង បានបញ្ជាក់ថា ពីមុនថ្មីត្បិតតែរូបសំណាកយាយលាវ ជាដុំថ្មមួយដុំក៏ពិតមែនតែលោកយាយនៅតែមានឥទ្ធិពលទៅលើបុគ្គលខ្លះដែលធ្លាប់តែមានជំនឿលើបារមីរបស់លោកយាយ។ ជារឿយៗ លោកយាយតែងតែធ្វើឲ្យមានការឈឺចាប់ដូចជា៖ ចុកពោះ ក្ដៅខ្លួន ឬឈឺក្បាល ជាដើម ចំពោះបុគ្គលណាដែលធ្វើឲ្យប៉ះទង្គិចដល់លោកយាយ។ ទោះបីយ៉ាងណា គេអាចនិយាយអង្វរករឲ្យលោកយាយជួយឲ្យបាត់ឈឺបានដោយបន់ថ្វាយឬសែនតែបាយដំណើប និងប្រហុកដុតតែប៉ុណ្ណោះ។ អ្នកភូមិសមរលាវមិនមានជីវភាពក្រលំបាកខ្លាំង ឬភាគច្រើននោះទេ។ ប៉ុន្តែក៏គ្មាននរណាម្នាក់មានជីវភាពធូរធារខ្លាំងដែរ។ ក្រៅពីធ្វើស្រែចំការ ពួកគាត់មិនមានមុខរបរធំដុំទេ គឺមានការធ្វើសិប្បកម្ម

[136] ដោយមានការស្រាវជ្រាវអំពីប្រវត្តិនៃវត្តនេះលោកបណ្ឌិត សេង ប៊ុនធឿន បានសាងសង់ទីតាំង អគតដ្ឋាន( លំនៅ )របស់លោកយាយលាវនេះ សម្រាប់ទុកជាភស្តុតាងប្រវត្តិសាស្ត្រនៃទីតាំងវត្ត និងភូមិនេះ។ សូមរកស្ដាប់ចម្រៀងបទ រលួសចេញផ្កា និងបទដើមត្នោតភូមិអូន។

ម៉ាស៊ីនកិនស្រូវខ្នាតតូច ឡើងត្នោត ចិញ្ចឹមសត្វ លក់ ដូរបន្តិចបន្តួច និងរកស៊ីតូចតាចលក្ខណៈគ្រួសារប៉ុណ្ណោះ។ រហូតមកដល់បច្ចុប្បន្ននេះវត្តសមរលោវមានព្រះចៅអធិការចំនួន១១អង្គរួចហើយ។

## ក-ព្រះនាមព្រះចៅអធិការវត្តសមរលោវ

អ្នកនិពន្ធមិនបានស្រាវជ្រាវរកឃើញព្រះនាមព្រះចៅអធិការវត្តមុនៗទាំងអស់ទេ(ព្រះចៅអធិការទី១ដល់ទី៤) គឺរកឃើញចាប់ពីលេខរៀងទី៥មកតែប៉ុណ្ណោះដែលមានព្រះនាមខាងក្រោមនេះ ៖

១-ព្រះចៅអធិការទី១ មិនស្គាល់

២-ព្រះចៅអធិការទី២ មិនស្គាល់

៣-ព្រះចៅអធិការទី៣ មិនស្គាល់

៤-ព្រះចៅអធិការទី៤ មិនស្គាល់

៥-ព្រះចៅអធិការទី៥ ព្រះសព ចាប អ៊ុំ

៦-ព្រះចៅអធិការទី៦ ព្រះសព ឡឹក

៧-ព្រះចៅអធិការទី៧ ព្រះសព ប៉ិច សុខ អនិច្ចធម្មឆ្នាំ១៩៦៧ ក្នុងជន្មាយុ៩១ព្រះវស្សា

៨-ព្រះចៅអធិការទី៨ ព្រះសព ប្រាក់ ហុង[137] (ហៅ យ៉ង ឬលោកតាយ៉ង) អនិច្ចធម្មឆ្នាំ១៩៧៦ ក្នុងជន្មាយុ៧៦ព្រះវស្សា

---

[137]ព្រះអដ្ឋិធាតុព្រះអង្គសព្វថ្ងៃតម្កល់នៅក្នុងព្រះចេតិយ៍ខាងជើងឈៀងខាងលិចព្រះវិហារវត្តសមរលោវ

៩-ព្រះចៅអធិការទី៩ ព្រះសព ឯក ព្រហ្ម(១៩៧៩-១៩៨៩)[138] អនិច្ចធម្មឆ្នាំ១៩៨៩ ក្នុងជន្មាយុ៨៦ព្រះវស្សា

១០-ព្រះចៅអធិការទី១០ ព្រះសព សួស ជុំ (១៩៨៩-២០១៣) អនិច្ចធម្មឆ្នាំ២០១៣ ក្នុងជន្មាយុ៨៨ព្រះវស្សា

១១-ព្រះចៅអធិការទី១១ ព្រះតេជគុណ ឡាក់ ហំ(២០១២-បច្ចុប្បន្ន)។ ព្រះតេជគុណ សួស ជុំ បានសុគតនៅថ្ងៃ៦កើត ខែចែត្រ ឆ្នាំម្សាញ់ ត្រូវនឹងថ្ងៃទី១៦ ខែមេសា ឆ្នាំ២០១៣ ក្នុងព្រះជន្មាយុ៨៨ព្រះវស្សា។ ព្រះសពព្រះអង្គសព្វថ្ងៃតម្កល់នៅក្នុងព្រះចេតិយ៍ខាងលិចព្រះវិហារវត្តសមរលាវ។ ព្រះអង្គស្រឡាញ់អ្នកស្រុកជាពុទ្ធស័ទ និងកូនចៅអ្នកស្រុកណាស់ ចង់ឲ្យតែកូនអ្នកស្រុករៀនសូត្រចេះដឹង។ ក្នុងភូមិស្រុកចំណុះជើងវត្តសមរលាវប្រសិនបើមានព្រឹទ្ធាចារ្យណាមានជំងឺជាទម្ងន់ព្រះអង្គតែងតែនិមន្តទៅសួរសុខទុក្ខគ្រប់តែគ្នា។ ព្រះអង្គមិនស្អប់អ្នកក្រស្រឡាញ់អ្នកមាន មិនប្រកាន់បក្ស ពួក និងប្រកាន់ខ្ជាប់នូវផ្លូវកណ្តាល(មជ្ឈិមាបដិបទា)។ លើសពីនេះទៀតព្រះអង្គជាព្រះចៅអធិការមួយអង្គមានការរាក់ទាក់ កាយវិការស្និទ្ធស្នាលជាមួយភ្ញៀវជិតឆ្ងាយដូចព្រះតេជគុណឯក ព្រហ្ម អតីតព្រះចៅអធិការទី៩ដែរ បន្ថែមពីលើនេះទៀត ចាស់ៗចំណុះជើងវត្តបានសសើរថា ព្រះចៅអធិការវត្តសមរលាវទី៨ មានព្រហ្មវិហារធម៌ និងចរិយាធម៌ដ៏គួរឲ្យគោរពស្ងប់ស្ងៃងផង

[138] ព្រះអដ្ឋិធាតុព្រះអង្គសព្វថ្ងៃតម្កល់នៅក្នុងព្រះចេតិយ៍ខាងជើងឈៀងខាងលិចព្រះវិហារវត្តសមរលាវសព្វថ្ងៃ។

ដែរ។ អំពើដ៏ល្អប្រពៃនៃព្រះតេជគុណអតីតព្រះចៅអធិការបានក្លាយជាគំរូសម្រាប់ព្រះចៅអធិការបច្ចុប្បន្ន និងក្រោយៗទៅទៀត។

## ខ-អំពីប្រវត្តិអាចារ្យវត្ត និងគណៈកម្មការអាចារ្យ

តាំងពីចាប់ផ្តើមកសាងវត្តសមរលាវមានលោកអាចារ្យ និងគណៈកម្មការពីមួយជំនាន់ទៅមួយជំនាន់។

### ខ-១-អាចារ្យ និងគណៈកម្មការអាចារ្យជំនាន់ព្រះចៅអធិការទី៧

១-កុង សួន ភូមិចេក

២-កុង ដៅ ភូមិសមរលាវ

៣-កុង អ៊ុំ ភូមិចេក

៤-កុង ឈឹត ភូមិសមរលាវ

៥-កុង នៅ ភូមិពោធិសាក់

៦-កុង អាន់ ភូមិសមរលាវ

៧-កុង ជុំ ភូមិជ្រយអង្គាសដី

៨-កុង ជាប ភូមិសមរចិន

៩-កុង អាត់ ភូមិសមរលាវ

### ខ-២-លោកអាចារ្យវត្ត និងគណៈកម្មការអាចារ្យចាប់ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ២០១៩

១-កុង ឃឹម អាចារ្យទី១ ភូមិគោកកញ្ចាប

២-កុង ហ៊ន អាចារ្យទី២ ភូមិជង្ហិត

| | | |
|---|---|---|
| ៣-កុង យឹម | អាចារ្យទី៣ | ភូមិសមរលាវ |
| ៤-កុង ថាន់ | ប្រធាន | ភូមិគោកកញ្ចាប |
| ៥-កុង ម៉ែ | អនុប្រធាន | ភូមិសមរលាវ |
| ៦-កុង អ៊ិន [139] | សមាជិក | ភូមិសមរលាវ |
| ៧-កុង ឃួន | សមាជិក | ភូមិសមរលាវ |
| ៨-កុង ផេង | សមាជិក | ភូមិសមរលាវ |

**ខ-៣-លោកអាចារ្យវត្ត និងគណៈកម្មការអាចារ្យចាប់ពីឆ្នាំ១៩១៩ ដល់ឆ្នាំ២០២១**

| | | |
|---|---|---|
| ១-កុង ពេជ លាប | អាចារ្យទី១ | ភូមិចេក |
| ២-កុង ថៃ ឆេង | អាចារ្យទី២ | ភូមិដង្ហិត |
| ៣-កុង បែន សារឿង | អាចារ្យទី៣ | ភូមិដង្ហិត |
| ៤-កុង សៅ ស៊ុន | ប្រធាន | ភូមិសមរលាវ |
| ៥-កុង ប្រាក់ ផៃ | អនុប្រធាន | ភូមិសមរលាវ |
| ៦-កុង ហុក ខេង | សមាជិក | ភូមិសមរលាវ |
| ៧-កុង លី ឡូយ | សមាជិក | ភូមិបន្ទាយរវៀង |
| ៨-កុង ប៊ី ស៊ិន | សមាជិក | ភូមិសមរលាវ |
| ៩-កុង អ៊ឹម ឈង | សមាជិក | ភូមិសមរលាវ |
| ១០-កុង ឡាក់ គួយ | សមាជិក | ភូមិសមរលាវ |

[139] បិតាអ្នកនិពន្ធសៀវភៅនេះ។

១១-កុង ឃាង គ្រេង សមាជិក ភូមិពោធិសាក់
១២-កុង មាស ហ៊ឹម សមាជិក ភូមិសមរលាវ
១៣-កុង ជា លឹម សមាជិក ភូមិសមរលាវ

**គ-សាលាធម្មសភា(សាលាឆាន់)**

សាលាធម្មសភានៃវត្តសមរលាវមានទំហំទទឹង១០ម៉ែត្រ បណ្តោយ ១៨ម៉ែត្រកសាងនៅឆ្នាំ១៩៦៥ដោយព្រះតេជគុណឯក ព្រហ្ម ព្រះចៅអធិការវត្តទី៩។ អាស្រ័យដោយអាយុកាលបានញ៉ាំងឲ្យអគារនៃសាលា ធម្មសភានេះមានសភាពចាស់ទ្រុឌទ្រោមខ្លាំងសរសរខាងក្រោមពុកផុយដោយអន្លើ កន្លែងផ្សេងៗនៃសំណង់មានស្នាមប្រេះស្រាំជាច្រើនរាប់មិនអស់ ទើបព្រះតេជគុណ ឡាក់ហំ (ហៅហ៊ុម) ព្រះចៅអធិការទី១១ ជាព្រះចៅអធិការបច្ចុប្បន្នបាន លើកគម្រោងវាយចោល និងកសាងជាថ្មីឡើងវិញ។ មុននឹងអនុវត្តគម្រោងការវាយសំណង់ចាស់កសាងថ្មីនេះ ព្រះអង្គតែងតែធ្វើការស្ទាបស្ទង់មតិពុទ្ធបរស័ទចំណុះជើងវត្ត គណៈកម្មការអាចារ្យ សហគមន៍គ្រប់ជ្រុងជ្រោយ ដកស្រង់យកយោបល់ភាគច្រើនភាគតិចជាដរាប។ វេលាមួយវេលាម៉ោង៧ និង ៤១នាទីយប់ នាថ្ងៃ១៥រោច ខែកត្តិក ឆ្នាំមមីរ ឆស័ក ព.ស ២៥៥៨ ត្រូវនឹង ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤ ព្រះតេជគុណ ឡាក់ ហំ បានទូរស័ព្ទមកខ្ញុំព្រះករុណា(សេង ប៊ុនធឿន) ផ្ទាល់ដើម្បីសួរយោបល់ទាក់ទងនឹងការវាយអគារ សាលាធម្មសភាចាស់នេះ។ ខ្ញុំនៅចាំបានព្រះអង្គមានសង្ឃដីកាថា ប្រសិនបើ អាត្មាចង់វាយសាលាធម្មសភា(សាលាឆាន់)នេះ ហើយកសាងថ្មីឡើងវិញឲ្យ

ធំជាងមុនតើបងគិតយ៉ាងណាដែរ? ខ្ញុំបានទូលព្រះអង្គថា ខ្ញុំព្រះករុណាខ្ញុំមិនមានមតិយោបល់អ្វីទេ!សំខាន់ព្រះអង្គសួរនាំស្ទាបស្ទង់មតិយោបល់ពុទ្ធបរិស័ទចំណុះជើងវត្តចុះ?ព្រះអង្គមានដីកាថាអាត្មាបានស្ទាបស្ទង់មតិយោបល់ញាតិញោមមួយចំនួនធំហើយ ៗលោកក៏មិនជំទាស់អ្វីដែរ ពោលគឺមានមតិឯកភាពគ្នាអស់ហើយ។ ប៉ុន្មានឆ្នាំមុន(មុនការសន្ទនា) ខ្ញុំព្រះករុណាខ្ញុំធ្លាប់បានឮអំពីគម្រោងការរបស់ព្រះអង្គនេះដែរ ខ្ញុំព្រះករុណាខ្ញុំសង្កេតឃើញអគារសាលាធម្មសភាចាស់កាលនោះ នៅមានសភាពរឹងមាំនៅឡើយ។ ប៉ុន្តែពេលនេះ អគារនេះមានសភាពចាស់ទ្រុឌទ្រោមប្រាកដមែន។ ដូច្នេះសម្រេចតាមទឹកព្រះទ័យរបស់ព្រះអង្គ និងពុទ្ធបរស័ទយើងទៅចុះ តែខ្ញុំព្រះករុណាខ្ញុំក៏បារម្ភខ្លាចតែអគារធ្វើថ្មីមានរាងរៅមិនសមដូចអគារចាស់ទេ។ ដូច្នេះ មុននឹងរុះរើ ឬវាយអគារចាស់នេះចោល គួរថតរូបទុកទាំងអស់។ ស្នាដៃជាងជំនាន់មុនធ្វើទម្លាក់នាគ ឬចម្លាក់ផ្សេងៗសក្តិសមណាស់ទាំងក្បាច់រចនាទាំងមាឌ(ទំហំ) ក្បាល ដងខ្លួន និងទាំងកន្ទុយ មើលទៅរស់រវើកហាក់ដូចមានជីវិតពិតៗ។ ចំណែកក្បឿងវិញ សូម្បីតែពណ៌ក៏ស្ទើរតែមិនស្លក មិនហើផង ពោលគឺនៅតែក្រហមងៅដដែល។ ដូច្នេះក្បឿងគួរទម្លាក់ចុះថ្នមៗកុំឲ្យបែក ប្រសិនបើអាចរក្សាយកក្បឿងចាស់នេះទៅប្រក់កន្លែងណាផ្សេងវិញក៏ខុសដែរ។ ជាងនេះទៅទៀត ដើម្បីឲ្យសំណង់ថ្មីនេះរក្សាបាននូវគុណភាព និងសោភ័ណភាពល្អ គួរតែជួលស្ថាបត្យករ( Architecture )ឲ្យគេគូរប្លង់ឲ្យបានត្រឹមត្រូវ ហើយធ្វើជាស្រ៊ីឌី( 3D )យកទៅបង្ហាញពុទ្ធបរិស័ទ និងពន្យល់

លោកឲ្យយល់ច្បាស់ និងយល់ព្រមជាមុនសិន ទើបដំណើរការសាងសង់ជាក្រោយក៏មិនយឺតពេលដែរ។ មុននឹងបញ្ចប់ ព្រះអង្គក៏មានប្រគល់ការគូរប្លង់មកខ្ញុំ ចំណែកព្រះអង្គដឹងតែរកជាងសាងសង់។

ខ្ញុំក៏បានទទួលយកកិច្ចការនេះទៅពិគ្រោះយោបល់ជាមួយស្ថាបត្យករដើម្បីគូរឲ្យទៅជាប្លង់មួយយ៉ាងស្អាត(សូមមើលរូបទី៨)ដែលប្លង់នេះព្រះតេជគុណព្រះចៅអធិការវត្តក៏បានជួយឧបត្ថម្ភថវិកាមួយភាគដែរ។ ប្លង់អគារនៃសាលាធម្មសភានេះ ត្រូវបានគូរឡើងមិនឲ្យខុសពីរូបរាងអគារដើមប៉ុន្មានទេ គ្រាន់តែមានប្រវែង វែងជាមុន ធំជាងមុន ខ្ពស់ជាងមុន មានរានសម្រាប់លាងចានស្លាបព្រាឆ្នាំង និងរានហាល[140]នៅខាងក្រោមមាន បន្ទប់ជាន់ផ្ទាល់ដី និងក្រាលឥដ្ឋកន្សែង ឬការ៉ូស្អាតក្រៃលែង។ អគារថ្មីមានទទឹងប្រវែង១៨ម៉ែត្រ បណ្តោយ ប្រវែង៣១ម៉ែត្រ។

អស់រយៈពេលជាងពីរឆ្នាំសាលាធម្មសភាថ្មីនេះបានដំណើរការសាងសង់រួចរាល់ក្រោមការដឹកនាំផ្ទាល់របស់ព្រះចៅអធិការវត្តព្រះនាម ឡាក់ ហំ ត្រូវបានធ្វើបុណ្យឆ្លងនិងដាក់ឲ្យសម្ពោធជាផ្លូវការក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត ពេជ្រ សោភ័ណ រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបច្ចុប្បន្នជារដ្ឋមន្ត្រីអមនាយករដ្ឋមន្ត្រីរយៈពេលបីថ្ងៃចាប់ពីថ្ងៃ៤-៥-៦កើត

140 តាមបុរាណផ្ទះខ្មែរមានប្រាំល្វែង ល្វែងច័ន្ទ ល្វែងជ័យ ល្វែងឈ្នាង ល្វែងកំសាន្តនិងល្វែងហាល(រានហាល)។ ចាស់ៗខ្មែរយើងពីដើម លោកសាងសង់លំនៅដ្ឋានមិនសូវចោលក្បូនខ្នាត និងម៉ូតទេ។ ប៉ុន្តែវាអាស្រ័យលើធនធានដែរ។ ប្រសិនជាមានទ្រព្យសម្បត្តិគ្រប់គ្រាន់លោកធ្វើទាំងគ្រប់ល្វែងតែម្តង។

ខែពិសាខឆ្នាំរកានព្វស័កព.ស ២៥៦១ ត្រូវនឹងថ្ងៃទី២៩-៣០ ខែមេសា និងថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៧។ ពេលនោះហើយដែលខ្ញុំបានជួបផ្ទាល់ និងសំដែងការគោរពចំពោះលោកគ្រូឌួងឆែម ហៅ ឈុំ និងលោកយាយ កែវ សារុំ ដែលលោកបានទទួលមេដាយកិត្តិយសក្នុងការកសាងសមិទ្ធផលរួម។

តាមការពិនិត្យឲ្យល្អិតល្អន់ទៅវវាងប្លង់ (Plan d´achitecte) និងសំណង់ដាក់ស្តែងដែលសមិទ្ធិដាក់ស្តែងដ៏ធំធេង និងជាប្រវត្តិសាស្រ្តនេះមិនបានដូចក្នុងប្លង់មួយរយភាគរយទេពោលគឺមានការកែប្រែផ្នែកខ្លះៗខុសពីប្លង់គំនូរដូចជាអគារមានថែមធ្នឹងដែកប្រក់ស័ង្កសីនៅស្លាបសងខាង(ពីចំហៀង)នៃអគារ(១)ទម្លាក់ឡាំងតូរ៉ែងជាងមុនដើម្បីបានកន្លែងធំគូររូប(២) ក៏ដូចគ្នាដែរ មានដាក់រនាំងទ្វារដែកបាំងកំដៅព្រះអាទិត្យ(៣)ការបុកគ្រឹះ និងចាក់ពិដាន(៤) ការលាបពណ៌។ល។



សាលាធម្មសភាចាស់វត្តសមរលាវ (រូបទី៧)



ប្លង់សាលាធម្មសភាថ្មីវត្តសមរលោរ (រូបទី៨)



សាលាធម្មសភាថ្មីវត្តសមរលោរ(រូបទី៩)




អាស្រមលោក យាយ លាវ (រូបទី១០)

### ឃ-អំពីសាលាហោត្រ័យ

នៅក្នុងវត្តសមរលាវក្រៅពីកុដិសំខាន់ៗរបស់ព្រះចៅអធិការវត្តក៏មាន ចេតិយ៍មួយសម្រាប់ដាក់អដ្ឋិធាតុរួមរបស់ពុទ្ធបរិស័ទចំណុះជើងវត្ត ចេតិយ៍ អតីតព្រះសពព្រះចៅអធិការ និងជាពិសេសមានហោត្រ័យមួយផងដែរ។ តាមព្រះតេជគុណព្រះចៅអធិការវត្តបច្ចុប្បន្ន ឡាក់ ហំ ហៅហ៊ីម ព្រះចៅ

អធិការមុនៗ និងពុទ្ធបរិស័ទជិតឆ្ងាយបានមានព្រះថេរដីកាថា ហោត្រ័យនេះ ជាស្នាមព្រះហស្តរបស់ព្រះតេជគុណឯក ព្រហ្ម អតីតព្រះចៅអធិការវត្តទី៩។ ប៉ុន្តែកាលពីព្រះអង្គកសាងនេះហោត្រ័យនេះព្រះអង្គឯកព្រហ្ម មានព្រះឋានៈ ជាគ្រូសូត្រឆ្វេងនៅឡើយ។ព្រះអង្គបន្ថែមថា អគារហោត្រ័យនេះ ប្រហែលជា កសាងនៅទសវត្សឆ្នាំ៤០។បច្ចុប្បន្នព្រះអង្គបានផ្តួចផ្តើមស្នើសុំឲ្យមានការចុះ បញ្ជីអគារហោត្រ័យនេះក្នុងបញ្ជីបេតិកភណ្ឌជាតិ(ធ្វើពិធីថ្ម) ឬជាវត្ថុបុរាណ (ធ្វើពីឥដ្ឋឬឈើ)ផងដែរ(រូបថតក្របខាងមុខ) ដោយមានវត្តមានលោក យើត ឡាយ ប្រធានការិយាល័យធម្មការ និងសាសនា និងលោកអ៊ុំសារឿន ប្រធានការិយាល័យវប្បធម៌ និងវិចិត្រសិល្បៈស្រុកព្រៃកប្បាស ខេត្តតាកែវមក ត្រួតពិនិត្យអគារនេះកាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៨ ដើម្បីរៀបចំធ្វើ សំណើសុំទៅមន្ទីរ ឬក្រសួងធ្វើការវាយតម្លៃនិងសម្រេច។ ស្មេរមិនដឹងពីការ ទទួលបានតម្រុយយ៉ាងណាទេបានជានៅថ្ងៃទី២ខែកុម្ភៈឆ្នាំ២០១៨តាមរយៈ បណ្តាញសង្គមហ្វេសប៊ុករបស់លោក គន ភត នាយកសាលាបឋមសិក្សា សមរលាវរំលេចដោយរូបថតអគារហោត្រ័យនេះនៅចន្លោះព្រៃឈើព័ទ្ធជុំវិញ ដ៏ខៀវស្រងាត់ចារឹកជាអក្សរថា“អាយុកាលជិត១០០ឆ្នាំហើយ។ ឥឡូវត្រៀម ខ្លួនចូលជាវត្ថុបុរាណមិនបានឈានដល់បេតិកភណ្ឌទេ”។

នៅតាមជណ្តើរខាងក្នុងឡើងទៅលើគេឃើញមានចារឈ្មោះអ្នកកសាងជ ណ្តើររួមមាន៖ ១-ឧបាសិកាអ៊ុន៥០រុ០០;២-គ្រូសូត្រ នៅនងកែ ៥០រុ០០; ៣-

ឧបាសក យង ហម ១០០រុ០០; ៤-តេងស្នួន១០០រុ០០; ៥-លន ជី ១០០រុ០០; ៦-ហ៊ាម អ៊ឹម១០០រុ០០; ៧- ចឹក តាម់(តាំ)១០០រុ០០[141]។

## ខ-អំពីព្រះវិហារ

តាំងពីអតីតកាលមកម្ល៉េះ វត្តសមរលាវមានកុដិ មានសាលាធម្មសភា មានព្រះវិហារ ប៉ុន្តែសំណង់ខ្លះមានខូចខាតទៅវិញដោយពេលវេលា ដោយគុណភាពសំណង់ ដោយការរុះរើរបស់ព្រះចៅអធិការពីមួយជំនាន់ទៅមួយជំនាន់ និងដោយការបំផ្លិចបំផ្លាញរបស់ពួក ប៉ុល ពត ជាដើម។ តាមដីកាព្រះចៅអធិការបច្ចុប្បន្ន ព្រះតេជគុណឡាក់ហំ(ហ៊ុម)បានឲ្យដឹងថា ព្រះវិហារនេះមាបណ្តោយប្រវែង ២៣ម និងទទឹងប្រវែង១៣ម ផ្ទៃក្រឡាចំនួន២៣១ម$^{២}$ សាងសង់ក្នុងអំឡុងមុនអគារហោត្រ័យផងដឹកនាំមកសាងដោយអតីតព្រះចៅអធិការវត្តទី៧ព្រះតេជគុណ ប៊ិច សុខតែត្រូវបំផ្លាញក្នុងរបបខ្មែរក្រហមសល់តែខឿននិងសរសរ ហើយត្រូវបានកសាងឡើងវិញជាស្ថាពរនៅឆ្នាំ១៩៨៥ នៅលើទីតាំងនៃខឿនដដែលដោយព្រះតេជគុណព្រះចៅអធិការទី១០ ព្រះនាម សួស ជុំ។ វេលាក្រោយៗមកព្រះវិហារនេះក៏ចេះតែរបកថ្នាំឬ ខូចខាតទៅតាមពេលវេលា និងអាយុកាល ហើយតែងតែត្រូវបានជួសជុលដោយព្រះចៅអធិការក្រោយៗមកទៀត។ ជាក់ស្តែងនៅចុងឆ្នាំ២០១៧នេះ បន្ទាប់ពីសាលាឆាន់មួយត្រូវបានសាងសង់រួចរាល់ ព្រះតេជគុណព្រះចៅអធិការទី១១បានចាប់ផ្តើមជួសជុលព្រះវិហារនេះសាជាថ្មីបន្តទៀតដោយធ្វើការៈ ដូរក្បឿង ប្តូររូបកេន្នរ ចាក់ប្លង់

[141] តម្លៃលុយរៀលសម័យសង្គមរាស្ត្រនិយមរបស់សម្តេចព្រះបរម រតនកោដ្ឋ នរោត្តម សីហនុ។

សេពីលើប្តូរជើងទៀនលើខឿនខាងលើ-ក្រោម និងក្លោងទ្វារចូលបីច្រកពីកើត ពីជើង និងពីត្បូង។ ជាមួយគ្នានេះ ព្រះអង្គក៏បានដឹកនាំសាងសង់ដងទង់មួយគូរទៀត ចំណាយអស់ទឹកប្រាក់ចំនួន១០០០០ដុល្លារគត់ ជាសទ្ធារជ្រះថ្លារបស់ឧបាសក ជា ចាន់ថា ហៅថន និងឧបាសិកា ហង្ស សុផល ចំនួន៨០០០ដុល្លារ និងថវិកាព្រះចៅអធិការ ឡាក់ ហំ ចំនួន២០០០ដុល្លារ។ កាលពីសម័យខ្មែរក្រហម មនុស្សវ័យកណ្តាលដែលជាអ្នកភូមិបួនប្រាំនាក់បានយកញញួរធំឡើងវាយផ្ទឹមព្រះវិហារនេះចោល និងអ្នកផ្សេងទៀតបានកំទេចព្រះពុទ្ធរូបក្នុងព្រះវិហារចោលតាមបញ្ជារបស់អង្គការអាវខ្មៅដែលសុទ្ធតែជាទមិឡទាំងអស់។ លុះក្រោយថ្ងៃរំដោះ ៧មករា ឆ្នាំ១៩៧៩ អ្នកភូមិដដែលក៏បាននាំគ្នាខ្នះ ខ្នែងជួសជុលកែលម្អព្រះវិហារនេះ និងស្ថាបនាព្រះពុទ្ធរូបឡើងវិញដើម្បីបានជាទីគោរពសក្ការៈនៃពុទ្ធបរិស័ទចំណុះជើងវត្តតរៀង មក។

## ច-អំពីក្លោងទ្វារវត្ត

វត្តសមរលាវមានច្រកចូលពីទិសខាងជើងសម្រាប់ពុទ្ធបរិស័ទចេញពីភូមិចូលវត្ត។ វត្តនេះនៅទិសខាងត្បូងមានព្រំប្រទល់ជាប់នឹងសាលាបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យសមរលាវតែម្តង ហើយភូមិសិក្សាទាំងបីមានក្លោងទ្វារពីរ គឺតាមច្រកចូលបឋមសិក្សាមួយ និងវិទ្យាល័យមួយទៀត។ ក្លោងទ្វារទាំងពីរជាអំណោយរបស់អ្នកគ្រូ យុន សុខចេង ហៅអ្នកគ្រូ មុំ។ ចំណែកក្លោងទ្វារវត្តពីទិសខាងកើតឆៀងខាងជើងជាក្លោងទ្វារធំរបស់វត្ត

សម្រាប់ទទួលភ្ញៀវពន្លឺគ្រប់ទិសទីពីទីជិតឆ្ងាយទាំងអស់។ ពីដើមឡើយក្លោងទ្វារនេះស្ថិតនៅប៉ែកខាងកើត ឆៀងខាងជើងស្របនឹងផ្លូវចូលភូមិសមរលាវ។ រូបខ្ញុំផ្ទាល់ធ្លាប់ប្រគេនយោបល់ថា ព្រះអង្គព្រះចៅអធិការថា ក្លោងទ្វារវត្តសមរលាវសព្វថ្ងៃតូច និងទាបណាស់ ដើម្បីឲ្យមានសោភ័ណភាព និងខ្ពស់ល្អគួរធ្វើឡើងវិញយកគំរូតាមអង្គឯកភាពមាគ៌ាចូលប្រាសាទអង្គរធំដោយចាក់ដីលុបស្រះវត្តប៉ែកខាងជើងមួយផ្នែកជាមុនសិន។ល។ ប៉ុន្មានឆ្នាំចុងក្រោយមកក៏ឮពាក្យចរចាមអារាមថា មានការស្រឡាញ់ក្លោងទ្វារមួយចំកណ្តាលស្រះទឹកមុខវត្តនេះពីកើតទៅលិចសង់ស្ពានកាត់ចូលវត្តតែម្តង។

ប៉ុន្តែផែនការនេះត្រូវបានប្តូរទៅវិញ ពីព្រោះបើធ្វើដូច្នេះទីវត្តមិនអាចអនុគ្រោះឲ្យរៀបចំបានស្អាតទេ។ ព្រះតេជគុណព្រះចៅអធិការ ឡាក់ ហំ ហៅ ហ៊ីម ដែលវេលាបន្តបន្ទាប់មកបានដឹងថា លោកយាយឧបាសិកា កែវ សារុំ ក៏យល់ស្របឲ្យលុបស្រះមួយចំណែកខាងជើងចំនួន១០ទៅ២០ម៉ែត្រដែរ ហើយបើកច្រកធ្វើក្លោងទ្វារចូលវត្តតាមដីថ្មីនេះ ដាច់ដោយឡែកពីផ្លូវចូលភូមិរបស់ពុទ្ធបរិស័ទ។ គំនិតនេះក្រោយមក ក៏មានការយល់ព្រមពីព្រះចៅអធិការ ហើយចាប់ផ្តើមចាក់ដីបំពេញផ្នែកមាត់ស្រះខាងជើង ស្តារស្រះទាំងមូល ចាក់បេតុងធ្វើចំណោតយ៉ាងស្អាតគួរជាទីពេញចិត្ត។ លោកយាយឧបាសិកា កែវ សារុំ បានចូលបច្ច័យចំនួន១០០០០ដុល្លារដើម្បីធ្វើផ្លូវចូលវត្ត លោក ឡាំ ងនលី និងអ្នកស្រី ស៊ុយ គឹមហេង បានចូលរួម៥០០០ ដុល្លារអាមេរិក។ ជាថ្មីម្តងទៀតដើម្បីសោភ័ណភាពនៃអារាមនេះខ្ញុំបានថ្វាយបង្គំ និងពិភាក្សាម្តងជាពីរ

ផងជាមួយព្រះចៅអធិការអំពីកសាងសង់ក្លោងទ្វារថ្មី។ ក្រោយពីជជែកជាមួយព្រះអង្គព្រះចៅអធិការអស់ពេលច្រើនម៉ោងដោយពន្យល់ហេតុផលចប់សព្វគ្រប់អំពីរូបរាងរចនាបថក្លោងទ្វារថ្មីរួចមក ព្រះអង្គក៏បានប្រគល់ការគូរប្លង់ដែលលើកឡើងដោយខ្ញុំព្រះករុណានេះជាថ្មីម្តងទៀត។

គោរពសំណូមពរនេះ ខ្ញុំបានពឹងពររកនិស្សិតដែលចេះខាងប្លង់ឲ្យជួយគូរតែគេចេះតែប្រកែកមិនទទួលជួយសោះ។ ទីបំផុតទៅ ខ្ញុំបានលើកទឹកចិត្តឲ្យនិស្សិតរបស់ខ្ញុំឈ្មោះ អំ បូរិន ដែលរៀនខាងសំណង់ និងចេះរចនាប្លង់ (Design) ហើយក៏រៀននៅសាកលវិទ្យាល័យជាតិគ្រប់គ្រងផងដែរខិតខំគូរប្លង់ក្លោងទ្វារនេះតាមគំនិតរប៉ុរបស់ខ្ញុំដោយយកគំរូរចនាបថក្លោងទ្វារចូលប្រាសាទបាយ័ន(សូមមើលឧបសម្ព័ន្ធទី៩ រូបភាពក្លោងទ្វារ និងសូមទស្សនារូបភាពវីដេអូចម្រៀងនៃបទ ដើមត្នោតភូមិអូននៃឧបសម្ព័ន្ធទី១០)។ ពេលគូររួចរាល់ហើយក៏ខំទៅពន្យល់ការពារប្លង់នេះចំពោះព្រះភ័ក្ត្រព្រះចៅអធិការ ហើយសន្យាថា ចំពោះអង្គឯកភាព(យក្ស និងទេវតាកូសមុទ្ទទឹកដោះ)នេះ ខាងក្រុមគ្រួសារកូនក្មួយខ្ញុំព្រះករុណាជាអ្នកទទួលផែននៃការសាងសង់ទៅចុះ។ ព្រះអង្គបានទទួល និងសុំយកទៅឆ្លងយោបល់គណៈកម្មការវត្ត គណៈកម្មការអាចារ្យជាមុនសិនពីព្រោះព្រះអង្គមិនអាចសម្រេចកិច្ចការតែមួយអង្គឯងកើតទេ។ ពេលរង់ចាំចម្លើយនេះ យើងក៏បានទទទួលពាក្យសរសើរផង និងរិះគន់ផងទៅលើប្លង់នេះតាមបែបប្រជាធិបតេយ្យ មានអ្នកខ្លះថាប្លង់នេះល្អណាស់ អ្នកក៏ថា ប្លង់នេះអាចនឹងស្អាតពេកមិនសក្តិសមនឹងវត្ត ខ្លះក៏ថាប្លង់

នេះជាប្លង់នៃសម្បត្តិបេតិកភ័ណ្ឌពិភពលោក យើងមិនអាចធ្វើបានទេ។ល។ ទោះបីយ៉ាងណា នៅក្នុងអំឡុងខែតុលា ឆ្នាំ២០២០ ព្រះតេជគុណ ឡាក់ ហំ ហៅ ហ៊ីម ក៏បានទូរស័ព្ទប្រាប់មកថា ប្លង់នេះ គណៈកម្មការ និងអាចារ្យ មិនឯកភាពយកមកសាងសង់ទេ ហើយលោកសម្រេចចិត្តយកតាមគំរូក្លោងទ្វារវត្ត សីហរតនារាម នៅក្នុងស្រុកដូនកែវ ខេត្តតាកែវសព្វថ្ងៃនេះទៅវិញ ជាមួយនឹងការទទួលសាងសង់ពីឯកឧត្តម ហ៊ឺ រ៉ុង និងលោកជំទាវ ឃិន ចាន់ថូ រួចហើយដែរ[142]។

ជារឿងៗ ព្រះចៅអធិការវត្ត ឡាក់ ហ៊ីម បានរំលឹកដោយមោទនភាព និងថ្លែងនូវសេចក្តីសរសើរនិងអរគុណជាអនេកចំពោះកម្លាំងសាមគ្គីរបស់ពុទ្ធបរិស័ទចំណុះជើងវត្ត និងពុទ្ធបរិស័ទពីទីជិតឆ្ងាយគ្រប់ទិសទី។ ព្រះអង្គឆ្លៀតរំលឹកឈ្មោះអ្នកមានសទ្ធាជ្រះថ្លាមួយចំនួនដែរដូចជា លោកយាយឧសិកា ស៊ាង លោកយាយឧសិកា កែវ សារុំ លោកយាយឧសិកា ម៉ាក់លី លោកយាយឧសិកា ស្វាយ សេន លោកតាឧសក ឌួង ឆែម (ឈុំ) លោកតាឧសក ឈុន ញ៉ឹក លោកតាឧសក ឡាំ ងនលី និងសប្បុរសជនជាច្រើនរូបទៀតដែលមិនបានលើកឈ្មោះទីនេះ។

## ៤-ទីតាំងភូមិសាស្ត្រ

ភូមិសមរលាវមានទីតាំងស្ថិតនៅក្នុងឃុំពោធិ៍រំចាក ស្រុកព្រៃកប្បាស

[142] ប្រភពពីព្រះតេជគុណ ឡាក់ ហំ ហៅ ហ៊ីម ព្រះចៅអធិការវត្តសមរលាវ។

ខេត្តតាកែវ ហើយមានព្រំប្រទល់ខាងកើតជាប់ទឹកដី(វាលស្រែ)នៃភូមិដូងខ្ពស់ ភូមិក្តីតាហុក និងភូមិគ ខាងត្បូងប៉ែកខាងកើតជាប់ទឹកដី(វាលស្រែ)នៃភូមិគោកកញ្ចាប ភូមិសមរចិន ភូមិសមរខ្មែរ ខាងលិចជាប់នឹងអូរមួយឈ្មោះថា អូរចំណោម ទឹកដីភូមិអង្គជ្រូក ឃុំកំពែង ភូមិព្រៃរបង ភូមិព្រៃផ្តៅ ឃុំព្រៃផ្តៅ និងខាងជើងទល់ភូមិចេក និង ភូមិបន្ទាយរវៀង (ដង្ហិត) នៃឃុំចំប៉ា ស្រុកព្រៃកប្បាស។ ប្រជារាស្ត្រក្នុងភូមិមានចំនួន១៨៣គ្រួសារ សរុបស្មើនឹង៦២៥នាក់ ប្រុស៣០៧នាក់ ស្រី៣១៨នាក់ ក្នុងនោះមនុស្សចាស់ចាប់ពីអាយុ៦០ឆ្នាំឡើងមានចំនួន៨៥នាក់ ប្រុស៤៥នាក់ ស្រី៤០នាក់ គិតជាភាគរយស្មើនឹង១៣,៦០%។ ដោយឡែកក្មេងៗអាយុក្រោម១៨ឆ្នាំមាន២៧៥នាក់ ប្រុស១៤៣នាក់ ស្រី១៣២នាក់[143] សុទ្ធតែស្ថិតនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សាទាំងអស់ លើកលែងតែកុមារតូចៗអាយុក្រោម៥ឆ្នាំស្ថិតនៅក្នុងបន្ទុកអាណាព្យាបាល និងឪពុកម្តាយ[144]។ មើលតាមផែនទីហ្គូហ្គល ម៉ាប(Google Map) ពីរាជធានីភ្នំពេញទៅដល់ភូមិសមរលោវចំត្រង់ពីមុខក្លោងទ្វារចូលទៅកាន់បរិវេណវត្តតែម្តងមានចម្ងាយផ្លូវប្រមាណ៧០.០៦គីឡូម៉ែត្រ។

ប៉ុន្តែប្រសិនបើធ្វើដំណើរតាមផ្លូវជាតិលេខ១ កាត់តាមស្រុកកោះធំ ឃុំកំពង់រាប មានចម្ងាយប្រមាណ៧២.៤៣ គីឡូម៉ែត្រ ហើយបើធ្វើដំណើរតាម

---

[143] ស្ថិតិនៅឆ្នាំ២០១៣ ដែលមានការជួយប្រមែប្រមូលព័ត៌មានយ៉ាងសកម្មពីលោកគ្រូចូលនិវត្តន៍ម្នាក់ឈ្មោះ ខេង ហៅគ្រូ ជ្រឹង រស់នៅភូមិសមរលោវ។

[144] ប្រភពព័ត៌មានឆ្នាំ២០១៥។

ផ្លូវជាតិលេខ២វិញពីភ្នំពេញកាត់តាមប្រាសាទនាងខ្មៅ ឬថ្នល់ទទឹងកាត់តាមសាលាស្រុកសំរោង(ផ្សារបត់រកា) ទៅភ្នំជីសូរ្យ ផ្សារសៃរ៉ា ភូមិឫស្សីថ្មី ឃុំចំប៉ា មានចម្ងាយ ៧០.០៨ គីឡូម៉ែត្រ ឬលើសនេះបន្តិចបន្តួច។

## ៥-អំពីការសិក្សាអប់រំ

ទាក់ទងនឹងការសិក្សាអប់រំវិញ ភូមិសមរលោវ សមរខ្មែរ និងសមរចិន តាំងពីសម័យមុនៗ ជាពិសេស សម័យសង្គមរាស្ត្រនិយមមានកូនអ្នកស្រុកជាច្រើនបានទទួលការបណ្តុះបណ្តាលរៀនសូត្រទទួលបានចំណេះវិជ្ជាជ្រៅជ្រះ ហើយចូលបម្រើការងារជាគ្រូបង្រៀន រាជការតាមស្ថាប័នផ្សេងៗរហូតក្លាយជាឥស្សរជនជាច្រើន។ ប៉ុន្តែពួកគេមួយចំនួនត្រូវបានសម្លាប់ និងស្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ រីឯអ្នកនៅរស់រានមានជីវិតក្រោយពីរបបនេះមានដូចជា លោក គឿក ជ្រុន លោក មាស ផន លោក យុន សារ៉ាន់[145] លោក សេងសុធន់[146](អេង)លោក ឈីវ ទីម[147] លោក ឈា តាំងស៊ន ជាដើម។ អ្នក

[145] លោកបានទទួលមរណភាពនៅថ្ងៃចន្ទ ១២កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ពស ២៥៦៥ ត្រូវនឹងថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១ក្នុង ជន្មាយុ៧២ឆ្នាំដោយរោគាពាធនៅគេហដ្ឋានរបស់លោកក្នុងក្រុងខេត្តកំពង់ឆ្នាំង។

[146] លោកបានធ្វើមរណកាលនៅថ្ងៃចន្ទ ១០កើត ខែចេត្រ ឆ្នាំច ឆស័ក ព.ស.២៥៣៨ ត្រូវនឹងថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៩៥ ដោយរោគាពាធ។ លោកជាបងប្រុសបង្កើតលោក សេង ប៊ុនធឿន អ្នកនិពន្ធសៀវភៅនេះ។

[147] លោកបានធ្វើមរណកាលនៅថ្ងៃពុធ ៤រោច ខែមិគសិរ ឆ្នាំមមីរ ឆស័ក ពស ២៥៥៨ ត្រូវនឹងថ្ងៃទី ១០ ខែធ្នូ ឆ្នាំ២០១៤ លោកជាគ្រូបង្រៀនអ្នកនិពន្ធសៀវភៅនេះផ្ទាល់កាលពីថ្នាក់ទី២ និងទី៤ នាឆ្នាំ ១៩៨២ និង១៩៨៤ បឋមសិក្សាសមរលោវ។

ភូមិសមរលោវនេះមិនខុសពីប្រជារាស្ត្រខ្មែរទូទាំងប្រទេសប៉ុន្មានទេពួកគេបានឆ្លងកាត់សម័យរាជានិយមសម័យបារាំងឈ្លានពានត្រួតត្រាសង្គមរាស្ត្រនិយមរបស់សម្តេចព្រះ នរោត្តម សីហនុ សាធារណរដ្ឋខ្មែររបស់លោកសេនាប្រមុខលន់ នល់ កម្ពុជាប្រជាធិបតេយ្យ(ខ្មែរក្រហម)សាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា។ ចេញពីរបបពីរចុងក្រោយនេះ ខ្ញុំឃើញមានស្ត្រីតែពីរនាក់ប៉ុណ្ណោះដែលបានរៀនចប់ទទួលបានសញ្ញាបត្រថ្នាក់មធ្យមសិក្សាកម្រិតៗពីរ (បាក់ ឌុប) គឺលោកស្រី ភន ង៉ែត[148]និងលោកស្រីហ៊ាមកឿន បានបន្តការសិក្សានៅវិទ្យាល័យព្រៃល្វា ស្រុកព្រៃកប្បាស ខេត្តតាកែវ។ សម័យអ៊ុនតាក់ (United Nation Transitional Authority in Cambodia/ UNTAC) ក្នុងសម័យព្រះរាជាណាចក្រកម្ពុជា ឬសម័យតេជោសែន[149]។

នៅសម័យក្រោយៗមក សិស្សស្រីជាច្រើនបានចូលរៀនបានជ្រៅជ្រះ ប្រឡងជាប់បាក់ឌុប ប្រឡងជាប់ជាគ្រូបង្រៀន និងបន្តការសិក្សាចូលរៀនមហាវិទ្យាល័យមានការងារធ្វើស្មើរតែគ្រប់គ្នាដូចសិស្សប្រុសឲ្យតែអ្នកខិតខំ

---

[148] បច្ចុប្បន្នលោកស្រីមានគ្រួសារមានបុត្រាបុត្រីនៅភូមិស្ពោ ឃុំស្ពោ ស្រុករតនៈមណ្ឌល ខេត្តបាត់ដំបង។ ស្មោះសូមអរគុណលោកស្រីណាស់ដែលបានជួយបរិច្ចាកថវិកាចំនួន៣០០ដុល្លារអាមេរិកក្នុងការជួលធ្វើបទភ្លេង និងច្រៀងបទ ភូមិសមរលោវ(សូមមើលឧបសម្ព័ន្ធទី១០)

[149] សម្តេចអគ្គសេនាបតី តេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា (សូមអានសៀវភៅ រដ្ឋធម្មនុញ្ញ និងការផ្លាស់ប្តូររបបនយោបាយនៅកម្ពុជារបស់លោកបណ្ឌិតសេង ប៊ុនធឿន)

រៀនសូត្រ និងចង់រៀនបន្តសុទ្ធតែបានចូលសាកលវិទ្យាល័យ និងរកការងារបានធ្វើស្ទើរតែគ្រប់គ្នាដែរ។

## ក-ប្រវត្តិសាលាបឋមសិក្សាសមរលាភ

សាលាបឋមសិក្សាសមរលាភចាប់បដិសន្ធិឡើងនៅឆ្នាំ១៩៥៥ ដែលមានអគារពីរខ្នងស្មើនឹងប្រាំមួយបន្ទប់ និងទីចាត់ការមួយ។ សាលានេះត្រូវបានប្រសិទ្ធនាមថា *បឋមសិក្សាសមរលាភ* ស្ថិតនៅក្នុងបរិវេណវត្តសមរលាភ ភាគខាងត្បូងនៃភូមិសមរលាភ ឃុំពោធិ៍រំចាក ស្រុកព្រៃកប្បាស។ សាលារៀនមានក្រឡាផ្ទៃ៨២០៨ម៉ែត្រការ៉េ។

សាលានេះមានទីធ្លាសម្រាប់សិស្សានុសិស្ស រត់លេងកំសាន្តនៅពេលចេញលេងសម្រាប់សួនច្បារដាំផ្កាដាំបន្លែនិងហាត់កីឡាមាន២៦៤ម៉ែត្រ ការ៉េ អគារសិក្សាមានផ្ទៃ៣៣៦ម៉ែត្រការ៉េ។ សាលានេះមានចាប់ពីថ្នាក់ទី១២ដល់ថ្នាក់ទី៧[150]។នៅឆ្នាំ១៩៦៩ព្រះសង្ឃគង់នៅក្នុងវត្តសមរលាភបានដឹកនាំពុទ្ធបរិស័ទកសាងអគារសិក្សាមួយខ្នងទៀត តែមិនបានសម្រេចតាមបំណងប្រាថ្នាទេ។ សាលានេះធ្លាប់មានកិត្តិនាមល្បីល្បាញតាំងពីសម័យសង្គមរាស្ត្រនិយម ត្បិតសិស្សានុសិស្សដែលបានសិក្សានៅទីនេះធ្លាប់ជាសិស្សពូកែ និងតស៊ូរៀនសូត្ររហូតដល់ថ្នាក់ឧត្តមសិក្សាជាវេជ្ជបណ្ឌិត វិស្វករ (បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត) និងខ្លះទៀតបន្តការសិក្សានៅបរទេសទៀត

[150] កាលសម័យនោះ ប្រព័ន្ធអប់រំខ្មែរ គេរាប់ពីលេខខ្ពស់មកទាបដូចប្រព័ន្ធអប់រំប្រទេសបារាំងដែរ។

ផង ។តាំងពីសម័យដើមរហូតមកដល់សម័យព្រះរាជាណាចក្រកម្ពុជាទី២ នេះ ក៏មានកូនចៅអ្នកស្រុកបានរៀនសូត្រក្លាយជាមន្ត្រីរាជការជាគ្រូបង្រៀន នៅក្រសួងស្ថាប័នរដ្ឋ ឯកជន ក្រុមហ៊ុន អង្គការនានាជាច្រើន ។ល។ នៅថ្ងៃទី ១៨ ខែមីនាឆ្នាំ១៩៧០ សាលារៀនសមរលាវត្រូវបានបិទទ្វារដូចសាលានានា ទូទាំងប្រទេសដែរដោយសាររដ្ឋប្រហាររបស់លោកសេនាប្រមុខ លន់ នល់ បានទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ចេញពីព្រះតំណែងប្រមុខរដ្ឋ ។

ចាប់ពីឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៩ សាលាបឋមសិក្សាបានក្លាយជារណ្តៅជីលាមកមនុស្សសត្វរបស់អ្នកដឹកនាំកម្ពុជាប្រជាធិបតេយ្យ (ប៉ុល ពត) ទៅវិញ ។ ឆ្នាំ១៩៧៩-១៩៨០ សាលាបឋមសិក្សាសមរលាវ ត្រូវបានបើកទ្វារឡើងវិញ ។ កូនចៅអ្នកស្រុកបាននាំគ្នាចូលបន្តការសិក្សាតាមកម្រិតពីសម័យ លន់ នល់ និងចាប់ផ្តើមសិក្សាសម្រាប់អ្នកមិនទាន់ចេះអក្សរពីថ្នាក់ទី១ដល់ថ្នាក់ទី៤ ។ សាលានេះបន្ទាប់មកពីបានចាស់ទ្រុឌទ្រោម ពុកខូចខាតទៅតាមពេលវេលាអស់ទៅ ។ ព្រះតេជគុណឯកព្រហ្ម ជាព្រះចៅអធិការវត្តបានដឹកនាំពុទ្ធបរិស័ទចំណុះជើងវត្តជួសជុល និងកសាងសាលានេះបានពីរខ្នងមានចំនួនប្រាំបីបន្ទប់ និងទីចាត់ការមួយ ។ " *ខ្ញុំគិតថា ប្រសិនបើមានសាលារៀន អនុវិទ្យាល័យ វិទ្យាល័យនៅជិតផ្ទះ កូនចៅយើងនឹងបានចូលរៀនគ្រប់ៗគ្នា ជាពិសេសកូនចៅស្រីៗ* " ។ នេះជាប្រសាសន៍លោកយាយឧសបាសិកា កែវ សារុំ ជាពុទ្ធសាសនូបត្ថម្ភក៏ដ៏ស្មោះត្រង់មួយរូបចំពោះព្រះពុទ្ធសាសនា ។ លោកយាយ និងក្រុមគ្រួសារក៏ដូចជាពុទ្ធបរិស័ទជើងវត្តដទៃៗដែរតែងជាអ្នក

ចូលរួមឧបត្ថម្ភគាំទ្រ ជាអ្នកផ្តួចផ្តើមធ្វើបុណ្យកឋិនទានដើម្បីប្រមូលបច្ច័យចូលរួមកសាង មានជាអាទិ៍ បន្ទប់សិស្សថ្នាក់មតេយ្យសិក្សា ជាដើម។

ជំនាន់ព្រះតេជគុណ សួស ជុំ ព្រះចៅអធិការទី១០ លោកយាយក៏បានចូលរួមកសាងអគារសាលាអនុវិទ្យាល័យ បច្ចុប្បន្នវិទ្យាល័យអគារទទឹងថ្ងៃរហូតរួចរាល់ជាស្ថាពរហើយមកដល់ព្រះតេជគុណព្រះចៅអធិការទី១១ ទន្ទឹមនឹងនេះ លោកយាយក៏បានចូលបច្ច័យកសាងសាលាធម្មសភាថ្មីចំនួន ៥០០០ដុល្លារ ផ្ទះបាយ(រោងចុងភៅ) ក្នុងវត្តសព្វថ្ងៃលោកយាយចេញសោហ៊ុយទាំងស្រុង បូករួមនិងការចំណាយចាក់ដីលុបស្រះផ្នែកខាងជើងធ្វើក្លោងទ្វារថ្មីលោកយាយក៏បានជួយថវិកា១០០០០ដុល្លារ(មួយម៉ឺនដុល្លារ)។ លោកយាយបានឲ្យដឹងថា តាំងពីព្រះចៅអធិការមុនៗ លោកយាយបានចូលរួមទោះតិចក្តីច្រើនក្តីតាមកម្លាំងសទ្ធានៃក្រុមគ្រួសារតាំងពីដើមរៀងមក។ ពោលគឺតាំងពីព្រះសពព្រះតេជគុណ ឯក ព្រហ្ម នៅគង់ព្រះជន្មមកម្ល៉េះ សូមរំលឹកបន្តិចដែរអំពីព្រះអង្គបន្តិច។

អតីតព្រះចៅអធិការវត្តសមរលោវមួយអង្គនេះ ត្រូវបានពុទ្ធបរិស័ទក្នុងតំបន់ចាត់ទុកដូចជាអ្នកប្រាជ្ញដែរ។ ក្រៅពីមានសម្ផស្សល្អស្អាត ស្នាមញញឹមទឹកព្រះទ័យទូលាយ ព្រះអង្គក៏មានចំណេះដឹងផ្នែកអក្សរសាស្ត្រ ភាសាបាលីសំស្ក្រឹតជ្រៅជ្រះ(បញ្ចប់ការសិក្សាថ្នាក់ឌីប្លូមសាលាបាលីណាស់។ តាមព័ត៌មាននិយាយតៗគ្នារបស់ចាស់ៗបានឲ្យដឹងថា នៅពេលសំដែងព្រះធម៌ទេសនា ព្រះអង្គមានដីកាពីរោះណាស់ សាច់ធម៌មានអត្ថន័យធម៌ជ្រាលជ្រៅ

ក្បោះក្បាយ ជាពិសេស ក្នុងករណីសំដែងធម៌ទេសនាសង្គាយនាត្រៃពីរ ឬបី គឺចោទឆ្លើយគ្នាម្តងៗ ពិបាករកបំណាស់[151]ណាឲ្យស្មើនឹងព្រះអង្គណាស់ហើយ ក៏មិនសូវមានព្រះធម្មឹកណាមួយហ៊ានធ្វើគូឆ្លងឆ្លើយ (មហាថេរ និងអនុថេរ) ជាមួយព្រះអង្គ ដែរដោយស្រួលៗដែរ។ ចំណែកសមិទ្ធផលក្នុងវត្តជាស្នាមព្រះហស្តវិញព្រះអង្គបានបន្សល់ទុកនូវមហាកុដិមួយដ៏ស្គឹមស្កៃដែលមានកំពូលប្រាំខុសពីកុដិនានាក្នុងវត្តនេះ ឬអាចនិយាយក្នុងព្រះជាណាចក្រកម្ពុជាផង។ គេហៅមហាកុដិ នេះថាសាលាបាលីឬហោត្រ័យ( (រូបភាពក្នុងក្របសៀវភៅខាងមុខ)។ ក្រៅពីនោះ ព្រះអង្គបានដឹកនាំកសាង ព្រះវិហារដែលពួកខ្មែរក្រហមបំផ្លាញចោលនោះឡើងវិញ។

កាលពីខ្ញុំនៅរៀនសាលាបឋមសិក្សានោះពីឆ្នាំ១៩៨០ដល់១៩៨៤ សិស្សានុសិស្សតែងតែបានចូលរួមការចែកនំចំណីអំពីព្រះអង្គផ្ទាល់។ ក្រោយពីដឹងថា សិស្សានុសិស្សចូលរៀននៅក្នុងសាលាបឋមសិក្សាជុំគ្នាវិញ ហើយព្រះតេជគុណតែងតែឲ្យគ្រូរៀបចំសិស្សានុសិស្សទាំងអស់ជាជួរ ហើយនាំគ្នាឡើងដើរចូលទៅក្នុងកុដិកន្លែងដែលព្រះអង្គកំពុងគង់ចាំហើយស្រេចជាមួយនឹងនំក្រៀប)ខែចូលឆ្នាំ)ស្វាយទុំ(រដូវស្វាយទុំ)នំអន្សម (រដូវភ្ជុំបិណ្ឌ (ម្នាក់មួយៗទាល់តែអស់ពីឃ្លាំង។ ព្រះអង្គជាបុគ្គលប្រកបដោយការព្យាយាមម៉ឹងម៉ាត់ម៉ត់ចត់។ តាមប្រសាសន៍លោក ឡាក់ គួយ អតីតប្រធានភូមិសមរលោវ បានមានប្រសាសន៍ថា ព្រះតេជគុណ ឯក ព្រហ្ម ម៉ឹងម៉ាត់ណាស់ កាលពីព្រះ

[151] ដៃគូ ឬគូប្រគួត។

អង្គកសាងសាលាធម្មសភាអំឡុងឆ្នាំ១៩៦៥ដែលត្រូវបានវាយចោល និង កំពុងកសាងឡើងវិញនេះ រួមទាំងកុដិហោត្រ័យផង ព្រះអង្គប្រើជាងបូកស៊ីម៉ង់តែម្នាក់គត់[152]។ គ្មាននរណាប៉ះពាល់ក្រៅពីជាងម្នាក់នេះឡើយ ពីព្រោះជាងនោះ លោកបូកស៊ីម៉ង់ស្អាតណាស់។ អ្វីដែលធ្វើឲ្យគាត់ចាំមិនភ្លេចនោះគឺព្រះអង្គឲ្យជាងបូកជញ្ជាំងនៅពេលយប់ដោយបញ្ចាំងភ្លើងដាក់។ ព្រះកាយវិកាទាំងនេះហើយបានជាធ្វើឲ្យពុទ្ធបរិស័ទចំណុះជើងវត្តសមរលាវមានការសោកស្តាយនឹករលឹកព្រះអង្គ[153]តែគ្រប់២គ្នា។

ក្រោយឆ្នាំ១៩៧៩ លោក យុន សារ៉ាន់ ជាអ្នកផ្តួចផ្តើមគំនិតសហការជាមួយពុទ្ធបរិស័ទចំណុះជើងវត្តទាំងមូលរៀបចំទីវត្តសមរលាវនេះឡើងវិញ និងជាពិសេសបានអញ្ជើញព្រះគ្រូ ឯក ព្រហ្ម ជាអតីតព្រះសង្ឃកាលពីសម័យសង្គមរាស្ត្រនិយមឲ្យសាងព្រះផ្នួសឡើងវិញ។ នៅក្នុងពេលរៀបចំពិធីបុណ្យព្រះសពព្រះតេជគុណ ឯក ព្រហ្ម នាឆ្នាំ១៩៨៩ទៀតសោត ក៏លោកបានដើរតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំកិច្ចផ្សេងៗដែរ។

ក្នុងពិធីបុណ្យរំលាយព្រះសពព្រះអង្គ គណៈកម្មការបុណ្យបាននិមន្ត

---

[152] គាត់ឈ្មោះជាង ខាន់ ជាឪពុករបស់លោកគ្រូ ហុក ខេង ហៅជ្រឹង គាត់ក៏បានចូលរួមចំណែកផ្តល់ព័ត៌មានច្រើនក្នុងការស្រាវជ្រាវសរសេរសៀវភៅនេះដែរ។ ជាមរតក ជាង ខាន់(កុង ខាន់) មានចៅម្នាក់ដែលជាកូនរបស់លោកគ្រូ ជ្រឹង មានវិជ្ជាខាងសំណង់យ៉ាងចំណាប់ចំនួនណាស់ដែរ។

[153] ដើម្បីបានជាទីសក្ការៈ ញាតិញោមសាច់សារលោហិតព្រះអង្គបានសាងព្រះចេតិយ៍មួយទុកជាកន្លែងតម្កល់ព្រះអដ្ឋិធាតុ និងគោរពសក្ការៈ បូជាតទៅ ដែលមានទីតាំងស្ថិតនៅខាងជើងឆៀងខាងលិចនៃព្រះវិហារ។

សម្តេចព្រះមហាឃោសនន្ទដារ៉ៃ យ៉ាវ[154] ជាព្រះធម្មឋឹកសំដែងព្រះធម៌ទេសនាយ៉ាងអធឹកអធម។

**ខ-អំពីគណៈគ្រប់គ្រងសាលាបឋមសិក្សា**

សាលាបឋមសិក្សាសមរលាវបានបង្កើតឡើងអំឡុងទសវត្សឆ្នាំ ១៩៥០ហើយដឹកនាំដោយនាយកចំនួនបួនរូបរួមមាន[155]៖

នាយកទី១-លោក កាំង លាងសេង (លោកមានស្រុកកំណើតមកពីភូមិក្រាំងស្លា) នាយកទី២-លោក កុយ ឆេម[156](មានស្រុកកំណើតនៅភូមិក្បាលពោធិ៍)នាយកទី៣-លោក ប្រាក់ សំអុន ហៅគ្រូ យុន[157]និងនាយកទី៤-លោក ឈា ប៊ុនហេង

**គិតត្រឹមឆ្នាំ១៩៧៩មកដល់បច្ចុប្បន្ននេះ មានចំនួន៥នាក់រួមមាន៖**

នាយកទី៥-លោក មាស ផន ពីឆ្នាំ១៩៧៩ ដល់១៩៨៥ មានបុគ្គលិក៦នាក់ ស្រី០នាក់ មានសិស្សចំនួន២៤៨នាក់។ សិស្សមកពីភូមិខាងក្រៅមានចំនួន៨០%។ លោកនាយករូបនេះនិយាយភាសាបារាំង និង

---

[154] ព្រះអង្គប្រសូត្រឆ្នាំ១៩២៩ និងអនិច្ចធម្មនៅឆ្នាំ២០០៧ នៅសហរដ្ឋអាមេរិក។ ព្រះអង្គមានដើមកំណើតនៅភូមិចុងថ្នល់ខាងជើងទីរួមខេត្តតាកែវ។

[155] ផ្តល់ព័ត៌មានដោយលោក គឿក ជ្រុន អតីតសិស្សសាលាបឋមសិក្សាសាលាសមរលាវដែលសិក្សានាទសវត្សឆ្នាំ១៩៥០។

[156] លោកមានស្រុកកំណើតនៅភូមិក្បាលពោធិ៍ ស្រុកទ្រាំង ខេត្តតាកែវ ត្រូវជាស្វាមីអ្នកស្រី ហ៊ុយ គឹមរ៉ុង ប្អូនស្រីរបស់លោក ហ៊ុយ គីម ដែលមានភរិយាឈ្មោះ យន់ ជ រស់នៅភូមិដង្ហិតត្រូវជាមាតាបិតារបស់លោកឧកញ៉ា ហ៊ុយ ហ៊ាង រស់នៅក្រុងដូនកែវសព្វថ្ងៃ។

[157] ជាអតីតព្រះសង្ឃមានដើមកំណើតនៅភូមិជ្រយ។

អង់គ្លេសយ៉ាងរអិល។

នាយកទី៦-លោក ស៊ាង សារី (ហៅ ហ៊ង) ពីឆ្នាំ១៩៨៥ ដល់ ១៩៩៣ មានបុគ្គលិក៧នាក់ ស្រី២នាក់ មានសិស្សចំនួន២៨៥នាក់។ សិស្ស មកពីភូមិខាងក្រៅមានចំនួន៨២%។

នាយកទី៧-លោក កុយ សយ ពីឆ្នាំ១៩៩៣ ដល់១៩៩៦ មាន បុគ្គលិក៨នាក់ ស្រី២នាក់ មានសិស្សចំនួន២៩៥នាក់។ សិស្សមកពីភូមិខាង ក្រៅមានចំនួន៩០%។

នាយកទី៨-លោក ហ៊ាង ជុំ ពីឆ្នាំ១៩៩៦ ដល់២០១២ មានបុគ្គលិក ១១នាក់ ស្រី២នាក់ មានសិស្សចំនួនសរុប២២០នាក់ស្រី៩៨នាក់។

នៅឆ្នាំ១៩៩៧ទទួលបានអំណោយជាអគារសិក្សាថ្មីចំនួន០២ខ្នង។ មួយខ្នងជាអំណោយរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន[158] និងមួយខ្នង ទៀតជាអំណោយរបស់សហគមន៍មាតាបិតា ព្រះសង្ឃ និងអាជ្ញាធរដែនដី។ កាលពីឆ្នាំសិក្សា១៩៩៤-១៩៩៥ សិស្សសាលាបឋមសិក្សាថ្នាក់ទី៦បាន ប្រឡងជាប់ចូលរៀនថ្នាក់ទី៧មានចំនួនច្រើនលើសគេ។ ជាលទ្ធផលទទួល បានចំណាត់ថ្នាក់លេខ១ប្រចាំស្រុកព្រៃកប្បាស។ ប្រវត្តិសាស្ត្ររបស់សាលា សិស្ស៣០នាក់ ប្រឡងជាប់៣០នាក់ស្មើនឹង៩៦,៧៧% ក្នុងសម័យឯកឧត្តម

[158] ក្នុងកាលៈទេសៈកំពុងសាងសង់នោះ ព្រះចៅអធិការវត្តព្រះនាម សួស ជុំ ព្រះអង្គព្រះអង្គបានទិញ ឈើមកបន្ថែម ផ្លាន និងផ្ទោងឲ្យញឹកត្រឹមត្រូវទៅតាមលក្ខណៈបច្ចេកទេសដើម្បីឲ្យដំបូលនៃអគារនេះ កាន់តែរឹងមាំទ្វេឡើង។

អ៊ឹង ហួត[159] ជារដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡាដែលឯកឧត្តមមានវិធានការពង្រឹងគុណភាពអប់រំ។ ក្នុងឆ្នាំសិក្សានោះដែរ មាន៩សាលា បេក្ខជនប្រឡងធ្លាក់ទាំងអស់ក្នុងចំណោម៣២សាលាបឋមសិក្សាទូទាំងស្រុកព្រៃកប្បាស។ ឆ្នាំបន្តបន្ទាប់ក្រោយមក សាលាបឋមសិក្សាសមរលាវចេះតែមានកេរ្តិ៍ឈ្មោះបោះសំឡេងល្បីល្បាញក្លាយជាសាលាគំរូទូទាំងខេត្តតាកែវ។ ក្នុងពេលជាមួយគ្នានេះសាលាចាប់ផ្តើមទទួលគណៈប្រតិភូជាតិ និងអន្តរជាតិ។ ប្រតិភូថ្នាក់ជាតិមានដូចជា សាលានានាក្នុងខេត្ត និងក្នុងប្រទេស(កំពង់ស្ពឺ កំពង់ចាម សៀមរាប) និងថ្នាក់អន្តរជាតិមានពីឥណ្ឌូនេស៊ី និងជប៉ុន ព្រមទាំងអង្គការនានាទៀតផង។ នាយកទី៩- លោក គន ភត ចាប់ពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១២។ ពេលទទួលបានឋានៈនេះភ្លាម លោកនាយកបានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយព្រះសង្ឃ សហគមន៍ និងសប្បុរសជនជិតឆ្ងាយដើម្បីសុំជំនួយឧបត្ថម្ភកសាងរបង បង្គន់អនាម័យ រូបចម្លាក់សត្វនៃឆ្នាំទាំង ១២ ចាក់សាបក្នុងទីធ្លាសាលា។ សាលានេះក្លាយជាសាលាកុមារមេត្រីកម្រិតអភិវឌ្ឍន៍ដែលក្រសួងអប់រំ យុវជន និងកីឡាចង់បាន។ ក្នុងឆ្នាំសិក្សា២០១៤-២០១៥ មានគ្រូសរុបចំនួន៦នាក់ មានស្រី២នាក់ពីថ្នាក់ទី១ដល់ថ្នាក់ទី៧។ ក្នុងនោះក៏មានសាលាមតេយ្យមួយខ្នងផងដែរ។ បច្ចុប្បន្នសាលាមាន

[159] លោកធ្លាប់ត្រូវបានរដ្ឋសភាបោះឆ្នោតឲ្យធ្វើជានាយករដ្ឋមន្ត្រីទី១ម្តងក្នុងរយៈពេលចន្លោះពីខែ កក្កដា ឆ្នាំ១៩៩៧ដល់ការបោះឆ្នោតជាតិនីតិកាលទី២ ឆ្នាំ១៩៩៨ បន្ទាប់ពីព្រឹត្តិការណ៍បង្ហូរឈាមទម្លាក់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ពីនាយករដ្ឋមន្ត្រីទី១ ព្រះប្រធានគណបក្សហ្វ៊ុនស៊ិនប៉ិច ថ្ងៃទី៥-៧ ខែកក្កដា ឆ្នាំ១៩៩៧។

សិស្សានុសិស្សចំនួន២២៩នាក់ស្រី១០៤នាក់។នៅពេលជួបសម្ភាសន៍លោកនាយក គន ភត បានឲ្យដឹងថា លោកមានចក្ខុវិស័យច្បាស់លាស់ ក្នុងការដឹកនាំដោយសហការយ៉ាងជិតស្និទ្ធជាមួយប្រជាពលរដ្ឋជាមាតាបិតា ក្នុងការកំណត់ទិសដៅសិក្សាប្រកបដោយសមត្ថភាពពេញលេញធ្វើឲ្យសិស្សមានទាំងចំណេះដឹង សីលធម៌ និងគុណធម៌រស់នៅល្អដើម្បីរួមចំណែកអភិវឌ្ឍសង្គមជាតិឲ្យរីកចម្រើនថែមទៀត។រីឯក្នុងបេសកកម្មការងារលោកនឹងដឹកនាំគ្រប់គ្រង និងបំពេញការងារគ្រប់ផ្នែកក្នុងអង្គភាពប្រកបដោយគុណភាព និងប្រសិទ្ធភាព។ អនុវត្តតាមការណែនាំ ច្បាប់លិខិតបទដ្ឋាន បទបញ្ជាផ្សេងៗរបស់ក្រសួងអប់រំ យុវជន និងកីឡា។ លើកកម្ពស់កិត្តិយស កេរ្តិ៍ឈ្មោះទឹកដីកំណើត។ បន្តទុកស្នាដៃ និងជាគំរូដល់អ្នកជំនាន់ក្រោយៗ។ រក្សាកេរ្តិ៍ឈ្មោះឥទ្ធិពល និងកិត្តិយសរបស់សហគមន៍របស់បុព្វបុរស យើងដែលសាងសង់និងបន្សល់ទុកមកដល់សព្វថ្ងៃនេះ។ ក្រៅពីសមិទ្ធផលទាំងឡាយដូចបានរៀបរាប់មកនេះ លោកនាយកបានអរគុណផងដែរចំពោះសប្បុរសជនដែលបានកសាងរូបសត្វទាំង១២តំណាងឲ្យឆ្នាំ រូបចម្លាក់សម្តេចព្រះសង្ឃរាជ ជួនណាត កសាងដោយលោក ហ៊ាន ចំរើន និងភរិយាលោកស្រី គង់ សេងលីមព្រមទាំងបុត្រ និងរូបព្រះពុទ្ធដែលតម្កល់ទន្ទឹមគ្នា កសាងដោយលោក ឈាសៀកលន និងភរិយា លោកស្រីព្រមទាំងបុត្រ។ ជាមួយគ្នានេះ ដើមឈើទាំងឡាយដែលលោកបណ្ឌិត សេង ប៊ុនធឿន បានដឹកនាំនិស្សិតដាំនៅក្នុងបរិវេណសាលានេះ លោកថែទាំបានយ៉ាងល្អដូចព្រះចៅអធិការ ឡាក់ ហំ ហៅ

ហ៊ុម និងព្រះសង្ឃវត្តសមរលាវដែរ ពោលគឺលោកខំស្រោចទឹកទាំងរដូវប្រាំងវស្សាទាល់តែដើមឈើបានរស់ និងលូតលាស់ស្រស់បំព្រងក្លាយជាម្លប់ដ៏ត្រឈឹងត្រឈៃទាំងអស់។

## គ-អំពីអនុវិទ្យាល័យ និងវិទ្យាល័យសមរលាវ

### គ.១. បុព្វហេតុ

ដោយមើលឃើញពីសារសំខាន់នៃការសិក្សានិងការលំបាករបស់សិស្សានុសិស្សដែលបានបញ្ចប់ការសិក្សានៅថ្នាក់បឋមសិក្សា ត្រូវបន្តការសិក្សានៅអនុវិទ្យាល័យដែលស្ថិតនៅឆ្ងាយពីផ្ទះក៏ដូចជាដើម្បីចូលរួមលើកកម្ពស់ការអប់រំនៅក្នុងមូលដ្ឋាន និងដើម្បីកាត់បន្ថយការបោះបង់ការសិក្សារបស់សិស្ស ទើបព្រះសង្ឃ និងគណៈកម្មការវត្តសមរលាវ ព្រមទាំងប្រជាពលរដ្ឋបានមូលមតិគ្នាជាឯកច្ឆ័ន្ទស្នើសុំបង្កើតអនុវិទ្យាល័យមួយសម្រាប់ឲ្យសិស្សានុសិស្ស ក្នុងសហគមន៍បានបន្តការសិក្សា។

នៅឆ្នាំ១៩៩៨ អនុវិទ្យាល័យមួយដែលមានឈ្មោះថា អនុវិទ្យាល័យសមរលាវត្រូវបានបង្កើតឡើង និងដាក់ឲ្យសិស្សានុសិស្សបានចូលសិក្សាជាបណ្តោះអាសន្ន។ ដើម្បីឆ្លើយតបនឹងការកើនឡើងនៃសិស្សានុសិស្សក្នុងតំបន់ពីឆ្នាំទៅមួយឆ្នាំ អតីតព្រះចៅអធិការវត្ត សួស ជុំ លោកគ្រូសូត្រស្តាំឡាក់ហំ និងគណៈកម្មការអាចារ្យ បានខ្នះខ្នែងស្នើសុំទៅថ្នាក់លើដើម្បីសុំបង្កើតជាវិទ្យាល័យតាមសំណូមពររបស់មាតាបិតា និងសហគមន៍មូលដ្ឋាននេះ។ លុះ

មកដល់ឆ្នាំ១៩៩៩ ទើបក្រសួងអប់រំយុវជន និងកីឡា បានចេញប្រកាស[160] ទទួលស្គាល់ជាផ្លូវការ។

តាមប្រសាសន៍របស់លោក ឡាច ស្រ៊ី នាយកសាលាបឋមសិក្សាហាតាកាស៊ីសមរមេត្រី ដែលមានទីតាំងជាប់វត្តសមរមេត្រីបានឲ្យដឹងថា ទាំងរូបលោក និងមន្ត្រីអប់រំផ្សេងទៀតបានតាមដានយ៉ាងជិតដិតថាក្នុងដំណើរការសុំបង្កើតជាវិទ្យាល័យនេះ បន្ទាប់ពីមានការពិនិត្យល្អិតល្អន់លើសំណើសុំបង្កើតរបស់សហគមន៍ តម្រូវការចាំបាច់ និងពីបែបបទគរុកោសល្យរបស់មន្ត្រីបច្ចេកទេសអប់រំគ្រប់លំដាប់ថ្នាក់រួចហើយក៏មានការជួយជ្រោមជ្រែងមួយផ្នែកពីលោក សេង ប៊ុនធឿន កាលនោះលោកជាជំនួយការឯកឧត្តមបណ្ឌិត កុល ផេងទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

### គ.២.ទីតាំង

អនុវិទ្យាល័យសមរលាវស្ថិតនៅក្នុងភូមិសមរលាវ ឃុំពោធិ៍រំចាក ស្រុកព្រៃកប្បាស ខេត្តតាកែវ។ ខាងជើងជាប់ជាមួយសាលាបឋមសិក្សាសមរលាវ ខាងត្បូងជាប់នឹងផ្លូវលំ និងដីកសិកម្មរបស់ប្រជាពលរដ្ឋ ខាងលិចជាប់ដីប្រជាពលរដ្ឋ និងដីវត្តសមរលាវ និងខាងកើតជាប់នឹងផ្លូវ។ អនុវិទ្យាល័យសមរលាវមានទំហំផ្ទៃដី សរុបចំនួន១០,០០២ ម៉ែត្រការ៉េ ដែលក្នុងនោះ ពីជើងទៅត្បូងមានប្រវែង៦១,៣៦ម៉ែត្រ និងពីកើតទៅលិចមានប្រវែង១៦៣ម៉ែត្រ។

---

[160] ប្រកាសលេខ:៥៦អយកប្រកស្តីពីការទទួលស្គាល់អនុវិទ្យាល័យសមរលាវចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៩៩

## គ.៣.ការវិវត្តរបស់អនុវិទ្យាល័យសមរលាវ

### គ.៣.១.ឆ្នាំសិក្សា ១៩៩៨ - ១៩៩៩

ក. **អំពីការសិក្សា**

អនុវិទ្យាល័យសមរលាវបានបើកដំណើរការឲ្យសិស្សានុសិស្សចូលរៀនក្នុងឆ្នាំសិក្សា១៩៩៨-១៩៩៩ ដែលពេលនោះមាន០២ថ្នាក់និងមានសិស្សសរុបចំនួន៤២នាក់ក្នុងនោះស្រីមានចំនួន២៤នាក់ហើយបុគ្គលិក អប់រំសរុបមានចំនួន០៧នាក់ ស្រី០១នាក់ ដោយបានផ្ទេរមកពីវិទ្យាល័យ ហេង សំរិនព្រៃល្វាចំនួន០៣នាក់ និងមកពីអនុវិទ្យាល័យព្រែកប្បាសចំនួន០៤នាក់។ ក្នុងឆ្នាំសិក្សានោះពុំទាន់មាននាយកសាលាទេ គឺមានត្រឹមតែគណៈគ្រប់គ្រងសាលាតែប៉ុណ្ណោះ ដែលពេលនោះលោក ឡាក់ គិមសាន ជាគណៈគ្រប់គ្រងនិងលោក ឈឹម សុវណ្ណ ជាលេខា។

**ខ. អំពីការសាងសង់**

ក្នុងឆ្នាំសិក្សា១៩៩៨-១៩៩៩ អនុវិទ្យាល័យសមរលាវពុំទាន់មានអគារសិក្សានៅឡើយ គឺបានខ្ចីអគារ សិក្សាចំនួនមួយខ្នងរបស់សាលាបឋមសិក្សាសមរលាវដើម្បីដាក់ឲ្យសិស្សបានចូលសិក្សាជាបណ្តោះអាសន្ន។ លុះមកដល់ចុងឆ្នាំ១៩៩៨ ទើបព្រះចៅអធិការវត្តសមរលាវ ព្រះនាម សួស ជុំ (ហៅត្រី)បានធ្វើការដឹកនាំកសាងអគារសិក្សាចំនួនមួយខ្នងស្មើនឹងប្រាំបន្ទប់អស់ទឹកប្រាក់ចំនួន៤៥,៧១០,៧០០រៀល។ ថវិកាកសាងអគារសិក្សានេះ

មានប្រភពមកពីពុទ្ធបរិស័ទនៅសហរដ្ឋអាមេរិកចំនួន៧៥១០ដុល្លារ លោកយាយឧបាសិកា កែវ សារុំ[161] ចំនួន១១៦១ដុល្លារ រួមទាំងពុទ្ធបរិស័ទចំណុះជើងវត្តសមរលាវ។

## គ.៣.២. ឆ្នាំសិក្សា១៩៩៩ - ២០០០

### ក. អំពីការសិក្សា

ក្នុងឆ្នាំសិក្សានេះ មានបុគ្គលិកអប់រំចំនួន០៧នាក់ ស្រីចំនួន០១នាក់ ដែលមានលោកឡាក់ គិម សាន ជានាយក និងលោក ឈឹម សុវណ្ណ ជាលេខាធិការ។ សិស្សសរុបក្នុងឆ្នាំនេះមានចំនួន១០០នាក់ ស្រី៤០នាក់ ដែលក្នុងនោះបានបែងចែកជា០៣ថ្នាក់គឺ ថ្នាក់ទី៧ចំនួន០២ថ្នាក់ មានសិស្ស៦៣នាក់ ស្រី២៣នាក់ និងថ្នាក់ទី៨ ចំនួន០១ថ្នាក់ មានសិស្ស៣៧នាក់ ស្រី១៧នាក់។

### ខ. អំពីការសាងសង់

ក្នុងឆ្នាំសិក្សានេះបានកសាងអគារទីចាត់ការមួយខ្នងស្មើនឹងបីបន្ទប់ ដែលមួយបន្ទប់សម្រាប់ធ្វើជាទីចាត់ ការមួយទៀតជាបណ្ណាល័យ និងមួយបន្ទប់ទៀតជាសាលប្រជុំគ្រូបង្រៀនដោយប្រើប្រាស់ថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា អស់ទឹកប្រាក់ចំនួន៧៩, ០០០, ០០០ រៀល។

## គ.៣.៣. ឆ្នាំសិក្សា ២០០០ -២០០១

---

[161] លោកយាយឧបាសកមានសទ្ធាជ្រះថ្លានឹងព្រះពុទ្ធសាសនាខ្លាំងណាស់ តាំងពីរូបខ្ញុំបានធំដឹងក្តីមក បានឃើញវត្តមានលោកយាយឧបាសិកា និងក្រុមគ្រួសារលោកបានបរិច្ចាកទ្រព្យធនយ៉ាងច្រើនក្នុងបុព្វហេតុព្រះពុទ្ធសាសនានៅគ្រប់ទីកន្លែង ជាពិសេសវត្តសមរលាវនេះតែម្តង។

**ក.អំពីការសិក្សា**

ក្នុងឆ្នាំសិក្សានេះមានបុគ្គលិកអប់រំចំនួន០៩នាក់ ស្រីចំនួន០១នាក់ ដែលមានលោក ឡាក់ គិមសាន ជានាយក និងលោក ឈឹម សុវណ្ណ ជាលេខាធិការ។ សិស្សសរុបក្នុងឆ្នាំនេះមានចំនួន ១៨០នាក់ ស្រី៧៣នាក់ ដែលក្នុងនោះបានបែងចែកជា០៥ ថ្នាក់គឺ៖

-ថ្នាក់ទី៧ ចំនួន ០២ថ្នាក់មានសិស្ស ៩០ នាក់ ស្រី ៣៦នាក់

-ថ្នាក់ទី៨ ចំនួន ០២ថ្នាក់ មានសិស្ស ៥៨ នាក់ ស្រី ២៣នាក់

និង -ថ្នាក់ទី៩ ចំនួន ០១ថ្នាក់ មានសិស្ស ៣២ នាក់ ស្រី ១៤នាក់ ។

**លទ្ធផលប្រឡងរបស់សិស្ស៖**

-ថ្នាក់ទី៧សិស្សប្រឡងជាប់ចំនួនៈ ៧៧នាក់ ក្នុងនោះស្រី ៣១នាក់

-ថ្នាក់ទី៨សិស្សប្រឡងជាប់ចំនួនៈ ៤០នាក់ ក្នុងនោះស្រី ១៣នាក់

-ថ្នាក់ទី៩សិស្សប្រឡងជាប់ចំនួនៈ ២៥នាក់ ក្នុងនោះស្រី ១២នាក់

**ខ. អំពីការសាងសង់**

អគារសិក្សាមួយខ្នងស្មើប្រាំបន្ទប់ដែលបំពាក់ដោយក្តារខៀន តុ កៅអី បានបីបន្ទប់ស្ថិតនៅខាងកើតអគារទីចាត់ការ និងបង្គន់អនាម័យមួយខ្នង០២បន្ទប់ ព្រមទាំងអណ្តូងទឹកមួយត្រូវបានកសាងឡើងដោយប្រើប្រាស់ថវិកាមូលនិធិសង្គម។ ក្រៅពីនេះដោយប្រើប្រាស់ថវិកាបដិភាគ១០% របស់មូលដ្ឋានជាមួយនឹងថវិកាមូលនិធិសង្គម បានកសាងរបងប្រវែង២៦០ម៉ែត្រ បង្គោលទង់ជាតិ ចាក់ដីបំពេញតាមបន្ទប់ និងទិញតុ កៅអី ក្តារខៀនសម្រាប់

ពីរបន្ទប់ដែលនៅខ្វះ។

### គ.៣.៤. ឆ្នាំសិក្សា២០០១ - ២០០២

### ក. អំពីការសិក្សា

ក្នុងឆ្នាំសិក្សានេះមានបុគ្គលិកអប់រំចំនួន១០នាក់ ស្រីចំនួន០១នាក់ ដែលមានលោក ឡាក់គិមសាន ជានាយក និងលោក ឈឹម សុវណ្ណ ជានាយករងស្តីទី។ សិស្សសរុបក្នុងឆ្នាំនេះមានចំនួន២៣៨នាក់ ស្រី១០៣នាក់ ដែលក្នុងនោះបានបែងចែកជា០៥ថ្នាក់គឺ៖

-ថ្នាក់ទី៧ចំនួន២ថ្នាក់ មានសិស្ស១២១នាក់ ស្រី៥៩នាក់

-ថ្នាក់ទី៨ ចំនួន២ថ្នាក់ មានសិស្ស៧៧នាក់ ស្រី៣១នាក់ និង

-ថ្នាក់ទី៩ ចំនួន១ថ្នាក់ មានសិស្ស៤០នាក់ ស្រី១៣នាក់ ។

**លទ្ធផលប្រឡងរបស់សិស្ស៖**

-ថ្នាក់ទី៧សិស្សប្រឡងជាប់ចំនួនៈ ៩៨នាក់ ក្នុងនោះស្រី ៣៩ នាក់

-ថ្នាក់ទី៨សិស្សប្រឡងជាប់ចំនួនៈ ៦៨នាក់ ក្នុងនោះស្រី ២៦ នាក់

-ថ្នាក់ទី៩សិស្សប្រឡងជាប់ចំនួនៈ ៣១នាក់ ក្នុងនោះស្រី ១២ នាក់

សិស្សថ្នាក់ទី៩បានប្រឡងជាប់សិស្សពូកែថ្នាក់ស្រុកមានចំនួន៥នាក់ៈ ១.ផៃ សុភា ២.រី រិទ្ធ ៣.គឿក ជ្រុន ស្រីង៉ែត ៤. ទុយ គា ៥. ឃួន សារិទ្ធ។ ក្នុងចំណោមទាំងនោះ អ្នកដែលបានប្រឡងជាប់សិស្សពូកែថ្នាក់ខេត្តចំនួន០២នាក់ គឺ ផៃ សុភា និង រី រិទ្ធ ព្រមទាំងបានប្រឡងជាប់សិស្សពូកែថ្នាក់ជាតិម្នាក់ គឺ ឈ្មោះ ផៃ សុភា ដែលបានជាប់ចំណាត់ថ្នាក់លេខ៩ ផ្នែករូបវិទ្យា។

**ខ. អំពីការសាងសង់**

បានចាក់បេតុងពីខាងមុខអគារទីចាត់ការព្រមទាំងបានធ្វើដំបូលចំរឹង ដែក ដែលថវិកាបានមកពីសប្បុរសជន និងពុទ្ធបរិស័ទរួមជាមួយថវិការបស់សាលារៀន។

**គ.៣.៥. ឆ្នាំសិក្សា២០០២ - ២០០៣**

**ក.អំពីការសិក្សា**

ក្នុងឆ្នាំសិក្សានេះមានបុគ្គលិកអប់រំចំនួន១៤នាក់ ស្រីចំនួន០៣នាក់ ដែលមានលោក ឡាក់ គិម សាន ជានាយក និងលោក ឈឹម សុវណ្ណ ជានាយករង។ សិស្សសរុបក្នុងឆ្នាំនេះមានចំនួន៣២៤នាក់ ស្រី១៣៥នាក់ ដែលក្នុងនោះបានបែងចែកជា០៧ថ្នាក់ គឺ៖

-ថ្នាក់ទី៧ចំនួន ៣ថ្នាក់មានសិស្ស ១៦២នាក់ ស្រី ៦៩នាក់

-ថ្នាក់ទី៨ ចំនួន ២ថ្នាក់ មានសិស្ស ៩៤នាក់ ស្រី ៣៩នាក់ និង

-ថ្នាក់ទី៩ ចំនួន ២ថ្នាក់ មានសិស្ស ៦៧នាក់ ស្រី ២៦នាក់។

**លទ្ធផលប្រឡងរបស់សិស្ស៖**

-ថ្នាក់ទី៧សិស្សប្រឡងជាប់ចំនួនៈ ១៤២នាក់ ក្នុងនោះស្រី ៥៨ នាក់

-ថ្នាក់ទី៨សិស្សប្រឡងជាប់ចំនួនៈ ៨១នាក់ ក្នុងនោះស្រី ៤០ នាក់

-ថ្នាក់ទី៩សិស្សប្រឡងជាប់ចំនួនៈ ៥៤នាក់ ក្នុងនោះស្រី ២៦ នាក់

**ខ. អំពីការសាងសង់**

ក្នុងឆ្នាំសិក្សានេះ មិនមានរបាយការណ៍សាងសង់អ្វីធំដុំទេ។

## គ.៣.៦. ឆ្នាំសិក្សា២០០៣ - ២០០៤

## ក.អំពីការសិក្សា

ក្នុងឆ្នាំសិក្សានេះមានបុគ្គលិកអប់រំចំនួន១៤នាក់ ស្រីចំនួន០៤នាក់ ដែលមានលោក ឡាក់ គិម សាន ជានាយក និងលោក ឈឹម សុវណ្ណ ជានាយករង[162]។ សិស្សសរុបក្នុងឆ្នាំនេះមានចំនួន ៣៥៤នាក់ ស្រី១៤២នាក់ ដែលក្នុងនោះបានបែងចែកជា០៨ ថ្នាក់គឺ៖

-ថ្នាក់ទី៧ចំនួន ៣ថ្នាក់ មានសិស្ស ១៣៥នាក់ ស្រី៥៣នាក់

-ថ្នាក់ទី៨ ចំនួន ៣ថ្នាក់ មានសិស្ស ១៣៥នាក់ ស្រី៥១នាក់ និង

-ថ្នាក់ទី៩ ចំនួន ២ថ្នាក់ មានសិស្ស ៨៤នាក់ ស្រី៣៨នាក់។

**លទ្ធផលប្រឡងរបស់សិស្ស៖**

-ថ្នាក់ទី៧សិស្សប្រឡងជាប់ចំនួនៈ ១១៨នាក់ ក្នុងនោះស្រី៤១នាក់

-ថ្នាក់ទី៨សិស្សប្រឡងជាប់ចំនួនៈ ១០៧នាក់ ក្នុងនោះស្រី៤១នាក់

-ថ្នាក់ទី៩សិស្សប្រឡងជាប់ចំនួនៈ ៧៦នាក់ ក្នុងនោះស្រី៣៣នាក់

## ខ.អំពីការសាងសង់ ក៏ដូចគ្នាដែរ

ក្នុងឆ្នាំសិក្សានេះ យើងមិនទទួលបានរបាយការណ៍សាងសង់អ្វីធំដុំទេ។

## គ.៣.៧.ឆ្នាំសិក្សា២០០៤-២០០៥

---

[162] ប្រកាសលេខៈ ៨៦៧ អយក.ប្រក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៣

## ក.អំពីការសិក្សា

ក្នុងឆ្នាំសិក្សានេះមានបុគ្គលិកអប់រំចំនួន១៤នាក់ ស្រីចំនួន០៤នាក់ ដែលមានលោក ឡាក់ គិម សាន ជានាយក និងលោក ឈឹម សុវណ្ណ ជានាយករង។ សិស្សសរុបក្នុងឆ្នាំនេះមានចំនួន៣៦៥នាក់ ស្រី១២៨នាក់ ដែលក្នុងនោះបានបែងចែកជា០៨ ថ្នាក់គឺ៖ -

ថ្នាក់ទី៧ចំនួន ៣ថ្នាក់មានសិស្ស ១៤០នាក់ ស្រី ៧២នាក់ -

ថ្នាក់ទី៨ ចំនួន ៣ថ្នាក់ មានសិស្ស ១១៨នាក់ ស្រី ៤១នាក់ និង -

ថ្នាក់ទី៩ ចំនួន២ថ្នាក់ មានសិស្សចំនួន១០៧នាក់ ស្រី៤១នាក់។

**លទ្ធផលប្រឡងរបស់សិស្ស៖**

-ថ្នាក់ទី៧សិស្សប្រឡងជាប់ចំនួនៈ ១២៧នាក់ ក្នុងនោះស្រី៦៣នាក់

-ថ្នាក់ទី៨សិស្សប្រឡងជាប់ចំនួនៈ ១០២នាក់ ក្នុងនោះស្រី៣៦នាក់

-ថ្នាក់ទី៩សិស្សប្រឡងជាប់ចំនួនៈ ៨៤នាក់ ក្នុងនោះស្រី២៩នាក់

## ខ. អំពីការសាងសង់

លោកឱ្ងង ឆែម (ហៅ គ្រូឈុំ[163] ) និងអ្នកស្រី អ៊ុយ អ៊ាត បានកសាងអាងទឹកចំនួនពីរដោយចំណាយទឹកប្រាក់អស់ចំនួន១៦០ដុល្លារអាមេរិក។ លោកជាអតីតគ្រូបង្រៀននៅសាលាបឋមសិក្សាសមរលោវតាំងពីសម័យ

[163] លោកក៏ជាអ្នកឧបត្ថម្ភគាំទ្រការកសាងសមិទ្ធនានាក្នុងវត្តសមរលោវម្នាក់ទៀតដែលមានឈ្មោះបោះសំឡេងតាំងពីអតីតកាលមកដែរ។

សង្គមរាស្ត្រនិយម។ ដោយប្រទេសជាតិជួបសង្គ្រាមរាំងជល់ លោកក៏បានទៅរស់នៅសហរដ្ឋអាមេរិករហូតមក។ លោកមានដើមកំណើតនៅភូមិចេក ឃុំចំប៉ា ស្រុកព្រៃកប្បាស ខេត្តតាកែវ។ ក្មេងៗស្រករក្រោយមិនសូវបានស្គាល់រូបលោក និងក្រុមគ្រួសារទេ ប៉ុន្តែឮតែឈ្មោះ។ លោកជាសកម្មជនអប់រំ និងពុទ្ធសាសនូបត្ថម្ភមួយរូបដែលហាក់មិនដែលមើលរំលងនឹងការសាងសង់សមិទ្ធិនានាទាំងសាលារៀន និងវត្តអារាមឡើយ។

## គ.៣.៨. ឆ្នាំសិក្សា២០០៥ - ២០០៦

## ក. អំពីការសិក្សា

ក្នុងឆ្នាំសិក្សានេះមានបុគ្គលិកអប់រំចំនួន១៤នាក់ ស្រីចំនួន០២នាក់ ដែលមានលោក ឈឹម សុវណ្ណ ជានាយករង[164] និងជាគណៈគ្រប់គ្រង លោក ហៀង គុណ ជាលេខាធិការ។ សិស្សសរុបក្នុងឆ្នាំនេះមានចំនួន៣៧៨នាក់ ស្រី១៧៩នាក់ ដែលក្នុងនោះបានបែងចែកជា០៨ថ្នាក់គឺ៖

-ថ្នាក់ទី៧ចំនួន ៣ថ្នាក់មានសិស្ស១៤៧នាក់ ស្រី៧៩នាក់

-ថ្នាក់ទី៨ ចំនួន ៣ថ្នាក់ មានសិស្ស១២៧នាក់ ស្រី៦៣នាក់ និង

-ថ្នាក់ទី៩ ចំនួន ២ថ្នាក់ មានសិស្ស១០៤នាក់ ស្រី៣៧នាក់។

**លទ្ធផលប្រឡងរបស់សិស្ស៖**

-ថ្នាក់ទី៧សិស្សប្រឡងជាប់ចំនួនៈ ១២៥នាក់ ក្នុងនោះស្រី ៦២នាក់

-ថ្នាក់ទី៨សិស្សប្រឡងជាប់ចំនួនៈ ១០០នាក់ ក្នុងនោះស្រី ៤៦នាក់

---

[164] ខណៈនោះលោក ឡាក់ គិមសាន ត្រូវបានតែងតាំងជាអភិបាលរងស្រុកព្រៃកប្បាស។

-ថ្នាក់ទី៩សិស្សប្រឡងជាប់ចំនួនៈ ៨១នាក់ ក្នុងនោះស្រី ២១នាក់

**ខ. អំពីការសាងសង់**

ក្នុងឆ្នាំ២០០៥ ឯកឧត្ដមបណ្ឌិត កុល ផេង ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ព្រះតេជគុណ សួស ជុំ អតីតព្រះចៅអធិការទីវត្តសមរលាវ ឧបាសក សេង អ៊ិន និងឧបាសិកា កាក់ ធួង និងលោក សេង ប៊ុនធឿន សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យជាតិគ្រប់គ្រងបានសាងរូបព្រះបាទជ័យវរ្ម័នទី៧ នៅខាងលិចបង្គោលទង់ជាតិ[165]សម្រាប់ទុកគោរពបូជានៅក្នុងវិទ្យាល័យសមរលាវដោយចំណាយអស់ថវិកាចំនួន៥០៥១ដុល្លារ (ធ្វើពីរដង)។ នៅចុងឆ្នាំ២០០៥ បានសាងសង់អគារសិក្សាមួយខ្នងមួយជាន់ស្មើនឹងប្រាំបីបន្ទប់ ប៉ុន្តែពុំទាន់បានរួចរាល់នៅឡើយ។

**គ.៣.៩.ឆ្នាំសិក្សា២០០៦-២០០៧**

**ក.អំពីការសិក្សា**

ដោយសារចំនួនសិស្សមានការកើនឡើង ព្រមទាំងមានការសំណូមពរយ៉ាងទទូចពីសំណាក់ មាតាបិតាសិស្ស និងសហគមន៍ ទើបអនុវិទ្យាល័យសមរលាវបានក្លាយជាវិទ្យាល័យសមរលាវ ក្រោមការប្រកាសបើកឲ្យដំណើរ

---

165 កាលពីកសាងព្រះរូបនេះដាដំបូងត្រូវតម្កល់នៅចន្លោះសួនច្បារខាងអណ្ដូងឯណោះទេ ប៉ុន្តែក្រោយមកត្រូវបានរំកិលមកខាងលិចបង្គោលទង់ជាតិ ដោយកសាងខឿនថ្មី និងមានធ័ត្រួត៩ជាន់ដូចសព្វថ្ងៃនេះ។ រូបចម្លាក់នេះសាងសង់បានល្អណាស់ដោយយករចនាបថដូចព្រះរូបដែលគេឃើញនៅក្នុងសារមន្ទីរជាតិរាជធានីភ្នំពេញអញ្ចឹងដែរ។សូម្បីតែអក្សរសរសេរនៅជុំវិញបល័ង្ក ប្រវត្តិ និងពាក្យពេជន៍របស់ព្រះមហាក្សត្រអង្គនេះបានមានបន្ទូលក៏ជាខ្លឹមសារដើមដែរ។

ការសិក្សាចាប់ពីបវេសនកាលឆ្នាំសិក្សា២០០៦ -២០០៧ ពីឯកឧត្តម បណ្ឌិត កុល ផេង រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងបានប្រកាសទទួលស្គាល់ជាផ្លូវការលេខៈ៨៩៤ អយក.ប្រក ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០០៦។ ក្នុងឆ្នាំសិក្សានេះមានបុគ្គលិកអប់រំចំនួន១៥នាក់ ស្រីចំនួន៣នាក់ ដែលមានលោក ឈឹម សុវណ្ណ ជានាយករង និងលោក ប៊ុត ទៀន ជានាយកស្តីទី។ សិស្សសរុបក្នុងឆ្នាំនេះមានចំនួន៥២៤នាក់ ស្រី២៤៩នាក់ ដែលក្នុងនោះបានបែងចែកជា១១ថ្នាក់ គឺ៖

-ថ្នាក់ទី៧ចំនួន ៤ថ្នាក់មានសិស្ស ២០៧នាក់ ស្រី ១១២នាក់

-ថ្នាក់ទី៨ចំនួន ៣ថ្នាក់ មានសិស្ស ១៣១នាក់ ស្រី ៦៦នាក់

-ថ្នាក់ទី៩ចំនួន ២ថ្នាក់ មានសិស្ស ១០៣នាក់ ស្រី ៤៧នាក់

-ថ្នាក់ទី១០ចំនួន២ថ្នាក់ មានសិស្ស ៨៣នាក់ ស្រី ២៤នាក់

**លទ្ធផលប្រឡងរបស់សិស្ស៖**

-ថ្នាក់ទី៧សិស្សប្រឡងជាប់ចំនួនៈ ១៨០នាក់ ក្នុងនោះស្រី ៨១នាក់

-ថ្នាក់ទី៨សិស្សប្រឡងជាប់ចំនួនៈ ១០៧នាក់ ក្នុងនោះស្រី ៩០នាក់

-ថ្នាក់ទី៩សិស្សប្រឡងជាប់ចំនួនៈ ៧៣នាក់ ក្នុងនោះស្រី ២៣នាក់

-ថ្នាក់ទី១០សិស្សប្រឡងជាប់ចំនួនៈ ៥២នាក់ ក្នុងនោះស្រី ១៥នាក់

**ខ. អំពីការសាងសង់**

ក្រោមការដឹកនាំរបស់ព្រះតេជព្រះគុណ ឡាក់ ហំ (ហៅហ៊ឹម) គ្រូ

សូត្រស្តាំវត្តសមរលោរ បានកសាងបង្ហើយនូវអគារសិក្សាមួយខ្នង មួយជាន់ស្មើនឹងប្រាំបីបន្ទប់ឲ្យរួចរាល់ជាស្ថាពរដោយបានចំណាយថវិកាអស់ចំនួន ៣១០០០ដុល្លារ។

## គ.៣.៩. ឆ្នាំសិក្សា២០០៧-២០០៨

### ក. អំពីការសិក្សា

ក្នុងឆ្នាំសិក្សានេះមានបុគ្គលិកអប់រំចំនួន១៧នាក់ ស្រីចំនួន០៣នាក់ លោក ឈឹម សុវណ្ណ ជានាយករង និងលោក ប៊ុត ទៀន ជានាយក។ សិស្សសរុបក្នុងឆ្នាំនេះមានចំនួន៥៨២នាក់ ស្រី២៥៨នាក់ ដែលក្នុងនោះបានបែងចែកជា១៤ថ្នាក់ គឺ៖

-ថ្នាក់ទី៧ ចំនួន ៤ថ្នាក់មានសិស្ស១៧០នាក់ ស្រី៨១នាក់

-ថ្នាក់ទី៨ ចំនួន ៤ថ្នាក់ មានសិស្ស១៨០នាក់ ស្រី៩០នាក់

-ថ្នាក់ទី៩ ចំនួន ២ថ្នាក់ មានសិស្សចំនួន១០៧នាក់ ស្រី៤៩នាក់

-ថ្នាក់ទី១០ចំនួន៣ថ្នាក់ មានសិស្ស ៧៣នាក់ ស្រី ២៣នាក់

-ថ្នាក់ទី១១ចំនួន១ថ្នាក់ មានសិស្ស ៥២នាក់ ស្រី ១៥នាក់

**លទ្ធផលប្រឡងរបស់សិស្ស៖**

-ថ្នាក់ទី៧សិស្សប្រឡងជាប់ចំនួនៈ ១៣៩នាក់ ក្នុងនោះស្រី ៥៩នាក់

-ថ្នាក់ទី៨សិស្សប្រឡងជាប់ចំនួនៈ ១៥៣នាក់ ក្នុងនោះស្រី ៧២នាក់

-ថ្នាក់ទី៩សិស្សប្រឡងជាប់ចំនួនៈ ៧១នាក់ ក្នុងនោះស្រី ២៧នាក់

-ថ្នាក់ទី១០សិស្សប្រឡងជាប់ចំនួនៈ ៥៥នាក់ ក្នុងនោះស្រី ១៩នាក់

-ថ្នាក់ទី១១សិស្សប្រឡងជាប់ចំនួនៈ ៤៣នាក់ ក្នុងនោះស្រី ១១នាក់

**ខ -អំពីការសាងសង់**

ពុំមានការសាងសង់អ្វីជាធំដុំទេ។

**គ.៣.១០. ឆ្នាំសិក្សា២០០៨ - ២០០៩**

**ក. អំពីការសិក្សា**

ក្នុងឆ្នាំសិក្សានេះមានបុគ្គលិកអប់រំចំនួន២៤នាក់ស្រីចំនួន០៤នាក់ ដែលមានលោក ប៊ុត ទៀន ជានាយកនិងលោក ឈឹម សុវណ្ណ ជានាយករង។ សិស្សសរុបក្នុងឆ្នាំនេះមានចំនួន៥៨៣នាក់ស្រី ២៤០នាក់ ដែលក្នុងនោះ បានបែងចែកជា១៣ថ្នាក់គឺ៖

-ថ្នាក់ទី៧ ចំនួន៣ថ្នាក់មានសិស្ស ១០៣នាក់ ស្រី៤៨នាក់

-ថ្នាក់ទី៨ ចំនួន៣ថ្នាក់ មានសិស្ស១៤៣នាក់ ស្រី៦១នាក់

-ថ្នាក់ទី៩ ចំនួន២ថ្នាក់ មានសិស្សចំនួន ១៥៤នាក់ ស្រី៧២នាក់

-ថ្នាក់ទី១០ចំនួន២ថ្នាក់ មានសិស្ស ៧៥នាក់ ស្រី២៨នាក់

-ថ្នាក់ទី១១ចំនួន១ថ្នាក់ មានសិស្ស ៥៧នាក់ ស្រី២០នាក់

-ថ្នាក់ទី១២ចំនួន១ថ្នាក់ មានសិស្ស ៥១នាក់ ស្រី១១នាក់

**លទ្ធផលប្រឡងរបស់សិស្ស៖**

-ថ្នាក់ទី៧សិស្សប្រឡងជាប់ចំនួនៈ ៨៩នាក់ ក្នុងនោះស្រី ៤៣នាក់

-ថ្នាក់ទី៨សិស្សប្រឡងជាប់ចំនួនៈ ១២៧នាក់ ក្នុងនោះស្រី ៥៧នាក់

-ថ្នាក់ទី៩សិស្សប្រឡងជាប់ចំនួនៈ ១១៦នាក់ ក្នុងនោះស្រី ៥៤នាក់

-ថ្នាក់ទី១០សិស្សប្រឡងជាប់ចំនួនៈ ៦៨នាក់ ក្នុងនោះស្រី ២៥នាក់

-ថ្នាក់ទី១១សិស្សប្រឡងជាប់ចំនួនៈ ៥០នាក់ ក្នុងនោះស្រី ១៩នាក់

-ថ្នាក់ទី១២សិស្សប្រឡងជាប់ចំនួនៈ ៤៦នាក់ ក្នុងនោះស្រី ១០នាក់

**ខ. អំពីការសាងសង់**

ពុំមានការសាងសង់អ្វីជាធំដុំទេ។

**គ.៣.១១.ឆ្នាំសិក្សា២០០៩ - ២០១០**

**ក. អំពីការសិក្សា**

ក្នុងឆ្នាំសិក្សានេះមានបុគ្គលិកអប់រំចំនួន ២២នាក់ ស្រីចំនួន ០៦នាក់ ដែលមានលោក ប៊ុត ទៀន ជានាយក និងលោកឈឹម សុវណ្ណ ជានាយករង។ សិស្សសរុបក្នុងឆ្នាំនេះមានចំនួន៥៨៣នាក់ ស្រី២៤០នាក់ ដែលក្នុងនោះ បានបែងចែកជា១៤ថ្នាក់ គឺៈ

-ថ្នាក់ទី៧ ចំនួន ៣ថ្នាក់មានសិស្ស ១១៩នាក់ ស្រី ៥៨នាក់

-ថ្នាក់ទី៨ ចំនួន ២ថ្នាក់ មានសិស្ស ៩១នាក់ ស្រី ៤៣នាក់

-ថ្នាក់ទី៩ ចំនួន ៣ថ្នាក់ មានសិស្សចំនួន ១៣៤នាក់ ស្រី ៥៧នាក់

-ថ្នាក់ទី១០ចំនួន៣ថ្នាក់ មានសិស្ស ១២០នាក់ ស្រី ៤៩នាក់

-ថ្នាក់ទី១១ចំនួន២ថ្នាក់ មានសិស្ស ៦០នាក់ ស្រី ២២នាក់

-ថ្នាក់ទី១២ចំនួន១ថ្នាក់ មានសិស្ស ៥៤នាក់ ស្រី ២០នាក់

**លទ្ធផលប្រឡងរបស់សិស្សៈ**

-ថ្នាក់ទី៧សិស្សប្រឡងជាប់ចំនួនៈ ១០៣នាក់ ក្នុងនោះស្រី ៤៩នាក់

-ថ្នាក់ទី៨សិស្សប្រឡងជាប់ចំនួនៈ ៧៤នាក់ ក្នុងនោះស្រី ៣៥នាក់

-ថ្នាក់ទី៩សិស្សប្រឡងជាប់ចំនួនៈ ១០២នាក់ ក្នុងនោះស្រី ៤៧នាក់

-ថ្នាក់ទី១០សិស្សប្រឡងជាប់ចំនួនៈ ១០០នាក់ ក្នុងនោះស្រី ៤៩ នាក់

-ថ្នាក់ទី១១សិស្សប្រឡងជាប់ចំនួនៈ ៥៤នាក់ ក្នុងនោះស្រី ២២នាក់

-ថ្នាក់ទី១២សិស្សប្រឡងជាប់ចំនួនៈ ៥១នាក់ ក្នុងនោះស្រី ១៩នាក់

**ខ-អំពីការសាងសង់**

នៅឆ្នាំ២០១០គ្រូសូត្រស្តាំវត្តសមរលោវ ព្រះនាម ឡាក់ ហំ ព្រមទាំងគណៈកម្មការ និង សាលារៀនបានកសាងបង្គន់អនាម័យមួយខ្នងស្មើពីរបន្ទប់ អស់ទឹកប្រាក់ជាងពីរលានរៀល ដោយសាលាបានជួយចំនួន៥០០.០០០រៀល ។

**គ.៣.១២. ឆ្នាំសិក្សា២០១០ - ២០១១**

**ក-អំពីការសិក្សា**

ក្នុងឆ្នាំសិក្សានេះមានបុគ្គលិកអប់រំចំនួន ២៤នាក់ ស្រីចំនួន ០៦នាក់ ដែលមានលោក ប៊ុត ទៀន ជានាយក និងឈឹម សុវណ្ណ ជានាយករង។ សិស្សសរុបក្នុងឆ្នាំនេះមានចំនួន ៥៩១នាក់ ស្រី២៥៥នាក់ ដែលក្នុងនោះបានបែងចែកជា១៥ថ្នាក់ គឺៈ

-ថ្នាក់ទី៧ ចំនួន ៣ថ្នាក់មានសិស្ស ១៤២នាក់ ស្រី ៥០នាក់

-ថ្នាក់ទី៨ ចំនួន ២ថ្នាក់ មានសិស្ស ១០៧នាក់ ស្រី ៥០នាក់

-ថ្នាក់ទី៩ ចំនួន ២ថ្នាក់ មានសិស្សចំនួន ៧៧នាក់ ស្រី ៣៦នាក់

-ថ្នាក់ទី១០ចំនួន៣ថ្នាក់ មានសិស្ស ១០៩នាក់ ស្រី ៤៨នាក់

-ថ្នាក់ទី១១ចំនួន៣ថ្នាក់ មានសិស្ស ១០១នាក់ ស្រី ៤៩នាក់

-ថ្នាក់ទី១២ចំនួន២ថ្នាក់ មានសិស្ស ៥៥នាក់ ស្រី ២២នាក់

**លទ្ធផលប្រឡងរបស់សិស្សៈ**

-ថ្នាក់ទី៧សិស្សប្រឡងជាប់ចំនួនៈ ១១០នាក់ ក្នុងនោះស្រី ៤០នាក់

-ថ្នាក់ទី៨សិស្សប្រឡងជាប់ចំនួនៈ ៩៦នាក់ ក្នុងនោះស្រី ៤៤នាក់

-ថ្នាក់ទី៩សិស្សប្រឡងជាប់ចំនួនៈ ៥៥នាក់ ក្នុងនោះស្រី ២៥នាក់

-ថ្នាក់ទី១០សិស្សប្រឡងជាប់ចំនួនៈ ៨៥នាក់ ក្នុងនោះស្រី ៣៧នាក់

-ថ្នាក់ទី១១សិស្សប្រឡងជាប់ចំនួនៈ ៩០នាក់ ក្នុងនោះស្រី ៤៥នាក់

-ថ្នាក់ទី១២សិស្សប្រឡងជាប់ចំនួនៈ ៥១នាក់ ក្នុងនោះស្រី ២០នាក់

សិស្សថ្នាក់ទី១២ម្នាក់ឈ្មោះ ឈឹម ឈូរិទ បានប្រឡងជាប់សិស្សពូកែថ្នាក់ខេត្ត ដោយបានទទួលចំណាត់ថ្នាក់លេខ៤ ហើយបានបន្តទៅប្រឡងថ្នាក់ជាតិតែពុំជាប់ថ្នាក់ជាតិទេ។

**ខ. អំពីការសាងសង់**

នៅឆ្នាំ២០១០គ្រូសូត្រស្តាំវត្តសមរលោរ ព្រះនាម ឡាក់ ហំ ព្រមទាំងគណៈកម្មការ និង សាលារៀន
បានកសាងបង្គន់អនាម័យមួយខ្នងស្មើពីរបន្ទប់អស់ទឹកប្រាក់ជាងពីរលានរៀល ដោយសាលាបានជួយចំនួន៥០០.០០០រៀល។

**គ.៣.១៣. ឆ្នាំសិក្សា២០១១ - ២០១២**

**ក. អំពីការសិក្សា**

ក្នុងឆ្នាំសិក្សានេះមានបុគ្គលិកអប់រំចំនួន២៣នាក់ ស្រីចំនួន០៧នាក់ ដែលមានលោក ប៊ុត ទៀន ជានាយក និងលោក ឈឹម សុវណ្ណ ជានាយករង។ សិស្សសរុបក្នុងឆ្នាំនេះមានចំនួន ៥៥៧នាក់ស្រី ២៣៨នាក់ ដែលក្នុងនោះបានបែងចែកជា ១៣ថ្នាក់ គឺៈ

-ថ្នាក់ទី៧ ចំនួន ៣ថ្នាក់មានសិស្ស ១១៥នាក់ ស្រី ៤៤នាក់

-ថ្នាក់ទី៨ ចំនួន ៣ថ្នាក់ មានសិស្ស ១១៤នាក់ ស្រី ៤២នាក់

-ថ្នាក់ទី៩ ចំនួន ២ថ្នាក់ មានសិស្សចំនួន ៩៦នាក់ ស្រី ៤៤នាក់

-ថ្នាក់ទី១០ចំនួន១ថ្នាក់ មានសិស្ស ៥៥នាក់ ស្រី ២៦នាក់

-ថ្នាក់ទី១១ចំនួន២ថ្នាក់ មានសិស្ស ៨៥នាក់ ស្រី ៣៧នាក់

-ថ្នាក់ទី១២ចំនួន២ថ្នាក់ មានសិស្ស ៩២នាក់ ស្រី ៤៥នាក់

**លទ្ធផលប្រឡងរបស់សិស្ស៖**

-ថ្នាក់ទី៧សិស្សប្រឡងជាប់ចំនួនៈ ៩២នាក់ ក្នុងនោះស្រី ៣៦នាក់

-ថ្នាក់ទី៨សិស្សប្រឡងជាប់ចំនួនៈ ៩៤នាក់ ក្នុងនោះស្រី ៣៨នាក់

-ថ្នាក់ទី៩សិស្សប្រឡងជាប់ចំនួនៈ ៧៥នាក់ ក្នុងនោះស្រី ៣៣នាក់

-ថ្នាក់ទី១០សិស្សប្រឡងជាប់ចំនួនៈ ៤១នាក់ ក្នុងនោះស្រី ១៩នាក់

-ថ្នាក់ទី១១សិស្សប្រឡងជាប់ចំនួនៈ ៨០នាក់ ក្នុងនោះស្រី ៣៦នាក់

-ថ្នាក់ទី១២សិស្សប្រឡងជាប់ចំនួនៈ ៩២នាក់ ក្នុងនោះស្រី ៤៥នាក់

សិស្សថ្នាក់ទី១២ម្នាក់ឈ្មោះ ហោ ស្រីទូច បានប្រឡងជាប់សិស្សពូកែថ្នាក់ខេត្ត ដោយបានទទួលចំណាត់ថ្នាក់លេខ២ ផ្នែកអក្សរសាស្ត្រខ្មែរ ហើយបានបន្តទៅប្រឡងថ្នាក់ជាតិតែពុំជាប់ថ្នាក់ជាតិទេ។

**ខ.អំពីការសាងសង់**

នៅឆ្នាំនេះមិនមានការសាងអ្វីជាដុំកំភួនទេ។

**គ.៣.១៤. ឆ្នាំសិក្សា ២០១២-២០១៣**

**ក.អំពីការសិក្សា**

ក្នុងឆ្នាំសិក្សានេះមានបុគ្គលិកអប់រំចំនួន២២នាក់ ស្រីចំនួន៨នាក់ ដែលមានលោក ប៊ុត ទៀន ជានាយក លោក ឈឹម សុវណ្ណ ជានាយករង និងអ្នកគ្រូ រី គន្ធឿន ជានាយិការង។ សិស្សសរុបក្នុងឆ្នាំនេះមានចំនួន ៥៤០នាក់ ស្រី ២៣៦នាក់ ដែលក្នុងនោះបានបែងចែកជា១៣ថ្នាក់គឺ៖

-ថ្នាក់ទី៧ ចំនួន ៤ថ្នាក់មានសិស្ស ១៥៤នាក់ ស្រី ៧៣នាក់

-ថ្នាក់ទី៨ ចំនួន ២ថ្នាក់ មានសិស្ស ៩៣នាក់ ស្រី ៣៦នាក់

-ថ្នាក់ទី៩ ចំនួន ២ថ្នាក់ មានសិស្សចំនួន ៩៦នាក់ ស្រី ៣៩នាក់

-ថ្នាក់ទី១០ចំនួន២ថ្នាក់ មានសិស្ស ៧៦នាក់ ស្រី ៣៣នាក់

-ថ្នាក់ទី១១ចំនួន១ថ្នាក់ មានសិស្ស ៤១នាក់ ស្រី ១៩នាក់

-ថ្នាក់ទី១២ចំនួន២ថ្នាក់ មានសិស្ស ៨០នាក់ ស្រី ៣៦នាក់

**លទ្ធផលប្រឡងរបស់សិស្ស៖**

-ថ្នាក់ទី៧សិស្សប្រឡងជាប់ចំនួនៈ ១២៧នាក់ ក្នុងនោះស្រី ៦៧នាក់

-ថ្នាក់ទី៨សិស្សប្រឡងជាប់ចំនួនៈ ៧៥នាក់ ក្នុងនោះស្រី ៣១នាក់

-ថ្នាក់ទី៩សិស្សប្រឡងជាប់ចំនួនៈ ៨៥នាក់ ក្នុងនោះស្រី ៣៤នាក់

-ថ្នាក់ទី១០សិស្សប្រឡងជាប់ចំនួនៈ ៧១នាក់ ក្នុងនោះស្រី ៣០នាក់

-ថ្នាក់ទី១១សិស្សប្រឡងជាប់ចំនួនៈ ៣៧នាក់ ក្នុងនោះស្រី ១៨នាក់

-ថ្នាក់ទី១២សិស្សប្រឡងជាប់ចំនួនៈ ៧៧នាក់ ក្នុងនោះស្រី ៣៥ នាក់សិស្សពូកែបានប្រឡងជាប់ថ្នាក់កម្រងចំនួន៣នាក់ ដែលក្នុងនោះថ្នាក់ទី ១២ ម្នាក់គឺឈ្មោះ ពុត រស្មី និង ថ្នាក់ទី៩ ពីរ នាក់ គឺសិស្សឈ្មោះ ហោ សៀកនី និង ឈឹម សាកល។

**ខ.អំពីការសាងសង់**

លោកបណ្ឌិត សេង ប៊ុនធឿន បានឲ្យកុំព្យូទ័រមួយគ្រឿងម៉ាកដែល( Dell) ស្មើនឹងតម្លៃ ៦០០ ដុល្លារអាមេរិក។

**គ.៣.១៥.ឆ្នាំសិក្សា២០១៣-២០១៤**

**ក.អំពីការសិក្សា**

ក្នុងឆ្នាំសិក្សានេះមានបុគ្គលិកអប់រំចំនួន២២នាក់ ស្រីចំនួន៨នាក់ ដែលមានលោក ប៊ុត ទៀន ជានាយក លោក ឈឹម សុវណ្ណ ជានាយករង និង អ្នកគ្រូ រី គន្ធឿន ជានាយិការង។ សិស្សសរុបក្នុងឆ្នាំនេះមានចំនួន៥៣២នាក់

ស្រី ២៣៤នាក់ ដែលក្នុងនោះបានបែងចែកជា១៣ថ្នាក់គឺ៖

-ថ្នាក់ទី៧ ចំនួន ៣ថ្នាក់មានសិស្ស ១១៧នាក់ ស្រី ៥១នាក់

-ថ្នាក់ទី៨ ចំនួន ៣ថ្នាក់ មានសិស្ស ១២៨នាក់ ស្រី ៦៧នាក់

-ថ្នាក់ទី៩ ចំនួន ២ថ្នាក់ មានសិស្សចំនួន ៧៦នាក់ ស្រី ៣១នាក់

-ថ្នាក់ទី១០ចំនួន២ថ្នាក់ មានសិស្ស ៨៨នាក់ ស្រី ៣៥នាក់

-ថ្នាក់ទី១១ចំនួន២ថ្នាក់ មានសិស្ស ៧៤នាក់ ស្រី ៣១នាក់

-ថ្នាក់ទី១២ចំនួន១ថ្នាក់ មានសិស្ស ៤០នាក់ ស្រី ១៩នាក់

**លទ្ធផលប្រឡងរបស់សិស្ស៖**

-ថ្នាក់ទី៧សិស្សប្រឡងជាប់ចំនួនៈ ៩៤នាក់ ក្នុងនោះស្រី ៤៣នាក់

-ថ្នាក់ទី៨សិស្សប្រឡងជាប់ចំនួនៈ ១០៦នាក់ ក្នុងនោះស្រី ៥៩នាក់

-ថ្នាក់ទី៩សិស្សប្រឡងជាប់ចំនួនៈ ៦៦នាក់ ក្នុងនោះស្រី ២៧នាក់

-ថ្នាក់ទី១០សិស្សប្រឡងជាប់ចំនួនៈ ៧៣នាក់ ក្នុងនោះស្រី ២៩នាក់

-ថ្នាក់ទី១១សិស្សប្រឡងជាប់ចំនួនៈ ៥៤នាក់ ក្នុងនោះស្រី ២១នាក់

-ថ្នាក់ទី១២សិស្សប្រឡងជាប់ចំនួនៈ ១៧នាក់ ក្នុងនោះស្រី ១២នាក់

សិស្សថ្នាក់ទី១២ម្នាក់ឈ្មោះ គន គឹមអន បានប្រឡងជាប់សិស្សពូកែថ្នាក់ខេត្ត។

**ខ.អំពីការសាងសង់**

ដោយមានការដឹកនាំពីសំណាក់ព្រះចៅអធិការវត្តសមរលាវ ព្រះនាម ឡាក់ ហំ ទើបចុងឆ្នាំ២០១៤ វិទ្យាល័យសមរលាវ បានចាក់បេតុងតាមផ្លូវចូលរួចរាល់ជាស្ថាពរ ដោយប្រើប្រាស់ថវិកាបដិភាគរវាងសាលា និងថវិកាវត្ត។

**គ.៣.១៦.ឆ្នាំសិក្សា២០១៤ - ២០១៥**

**ក. អំពីការសិក្សា**

ក្នុងឆ្នាំសិក្សានេះមានបុគ្គលិកអប់រំចំនួន២២នាក់ ស្រីចំនួន៩នាក់ ដែលមានលោក ប៊ុត ទៀន ជានាយក លោក ឈឹម សុវណ្ណ ជានាយករង និង អ្នកគ្រូ រី គន្ធឿន ជានាយិការង។ សិស្សសរុបក្នុងឆ្នាំនេះមានចំនួន ៥៧៤នាក់ ស្រី ២៦១នាក់ ដែលក្នុងនោះបានបែងចែកជា ១៥ថ្នាក់ គឺ៖

-ថ្នាក់ទី៧ ចំនួន ៣ថ្នាក់មានសិស្ស ១២៥នាក់ ស្រី ៦៤នាក់

-ថ្នាក់ទី៨ ចំនួន ៣ថ្នាក់ មានសិស្ស ១១៦នាក់ ស្រី ៥០នាក់

-ថ្នាក់ទី៩ ចំនួន ៣ថ្នាក់ មានសិស្សចំនួន ១១៤នាក់ ស្រី ៦២នាក់

-ថ្នាក់ទី១០ចំនួន២ថ្នាក់ មានសិស្ស ៧២នាក់ ស្រី ២៩នាក់

-ថ្នាក់ទី១១ចំនួន២ថ្នាក់ មានសិស្ស ៧៥នាក់ ស្រី ២៩នាក់

-ថ្នាក់ទី១២ចំនួន២ថ្នាក់ មានសិស្ស ៧២នាក់ ស្រី ២៧នាក់

**លទ្ធផលប្រឡងរបស់សិស្ស៖**

-ថ្នាក់ទី៧សិស្សប្រឡងជាប់ចំនួន១០២នាក់ ក្នុងនោះស្រី៥៦នាក់

-ថ្នាក់ទី៨សិស្សប្រឡងជាប់ចំនួន៩៥នាក់ ក្នុងនោះស្រី៤៣នាក់

-ថ្នាក់ទី៩សិស្សសរុបចំនួន៩០នាក់ ក្នុងនោះស្រី៥៤ នាក់(ប៉ុន្តែ ប្រឡងជាប់ឡើងថ្នាក់បានមានតែ៧៥នាក់ ស្រី៤៨)

-ថ្នាក់ទី១០សិស្សប្រឡងជាប់ចំនួន៤៨នាក់ ស្រី២១នាក់

-ថ្នាក់ទី១១សិស្សប្រឡងជាប់ចំនួន៦៥នាក់ ស្រី២៣នាក់

-ថ្នាក់ទី១២សិស្សសរុបមានប្រឡងជាប់ចំនួន៥២នាក់ ក្នុងនោះស្រី ១៨នាក់។ ប៉ុន្តែមានតែ៣២ ស្រី៩នាក់ដែលប្រឡងជាប់សញ្ញាបត្រមធ្យម សិក្សាទុតិយភូមិ។ ក្នុងនោះទទួលបាននិទ្ទេស ឌី (D) ១១ នាក់ស្រី៥នាក់។ គួររំលឹកថា ក្នុងឆ្នាំសិក្សាឆ្នាំ២០១៣-២០១៤ ឆ្នាំសិក្សាឆ្នាំ២០១៤-២០១៥ និងឆ្នាំសិក្សាឆ្នាំ២០១៥-២០១៦ ជាសម័យកែទម្រង់ក្រោមការដឹកនាំរបស់

ឯកឧត្តមបណ្ឌិត ហង់ ជួនណារ៉ុន ជារដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ហើយដែលទទួលបានការគាំទ្រពេញទំហឹងពីសម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី និងមាតាបិតាសិស្សទូទៅ។

**ខ.អំពីការសាងសង់**

ដោយប្រប្រាស់ថវិកាS I G(៤០០ដុល្លារ)រួមជាមួយថវិការបស់វត្ត ទើបឆ្នាំសិក្សានេះ វិទ្យាល័យសមរលាវបានធ្វើក្រាលការ៉ូក្នុងបន្ទប់ទីចាត់ការ រួចរាល់ ជាស្ថាពរ។

លោក សេង ប៊ុនធឿន បានដឹកនាំ និស្សិតនៃសាកលវិទ្យាល័យជាតិគ្រប់គ្រង និង សិស្សានុសិស្ស ព្រមទាំងលោកគ្រូ អ្នកគ្រូ ដាំកូនឈើបានមួយចំនួននៅពីខាងជើងផ្លូវចូល វិទ្យាល័យសមរលាវ ។

**គ.៣.១៧.ឆ្នាំសិក្សា២០១៥-២០១៦**

**ក.អំពីការសិក្សា**

ក្នុងឆ្នាំសិក្សានេះមានបុគ្គលិកអប់រំចំនួន២៥នាក់ ស្រីចំនួន១២នាក់ ដែលមានលោក ប៊ុត ទៀន ជានាយក លោក ឈឹម សុវណ្ណ ជានាយករង និង អ្នកគ្រូ រី គន្ធឿន ជានាយិការង។ សិស្សសរុបក្នុងឆ្នាំនេះមានចំនួន៥២៤នាក់ ស្រី២៦៦នាក់ ដែលក្នុងនោះបានបែងចែកជា ១៣ថ្នាក់គឺ៖

-ថ្នាក់ទី៧ ចំនួន ៣ថ្នាក់មានសិស្ស ១២១នាក់ ស្រី ៧០នាក់

-ថ្នាក់ទី៨ ចំនួន ៣ថ្នាក់ មានសិស្ស ១១១នាក់ ស្រី ៦៤នាក់

-ថ្នាក់ទី៩ ចំនួន ២ថ្នាក់ មានសិស្សចំនួន ៨៧នាក់ ស្រី ៣៤នាក់

-ថ្នាក់ទី១០ចំនួន២ថ្នាក់ មានសិស្ស ៧៨នាក់ ស្រី ៤៥នាក់

-ថ្នាក់ទី១១ចំនួន១ថ្នាក់ មានសិស្ស ៥៦នាក់ ស្រី ២២នាក់

-ថ្នាក់ទី១២ចំនួន២ថ្នាក់ មានសិស្ស ៧១នាក់ ស្រី ២៦នាក់

**លទ្ធផលប្រឡងរបស់សិស្ស៖**

-ថ្នាក់ទី៧សិស្សប្រឡងជាប់ចំនួនៈ ១១១នាក់ ក្នុងនោះស្រី ៦៨នាក់

-ថ្នាក់ទី៨សិស្សប្រឡងជាប់ចំនួនៈ ១០២នាក់ ក្នុងនោះស្រី ៦២នាក់

-ថ្នាក់ទី៩សិស្សប្រឡងជាប់ចំនួនៈ ៦៥នាក់ ក្នុងនោះស្រី ៣៣នាក់

-ថ្នាក់ទី១០សិស្សប្រឡងជាប់ចំនួនៈ ៧៤នាក់ ក្នុងនោះស្រី ៤៤នាក់

-ថ្នាក់ទី១១សិស្សប្រឡងជាប់ចំនួនៈ ៥១នាក់ ក្នុងនោះស្រី ២០នាក់

-ថ្នាក់ទី១២សិស្សប្រឡងជាប់ចំនួនៈ ៤០នាក់ ក្នុងនោះស្រី ១៨នាក់ ក្នុងនោះសិស្សទទួលបាននិទ្ទេស B មានពីរនាក់ និង សិស្សនិទ្ទេស C ចំនួន ៧នាក់ រួមមាន៖

ទី១-ហោ សៀកនី ភេទស្រី មកពីភូមិសមរលាវ ឃុំពោធិ៍រំចាក

ទី២-ជុំ មួយហ៊ាង ភេទស្រី មកពីភូមិសមរលាវ ឃុំពោធិ៍រំចាក

និទ្ទេសស៊ី( C )ចំនួន៤នាក់រួមមានៈ

ទី១-ឈឹម សាកល ភេទប្រុសមក ពីភូមិថ្នល់បត់ ឃុំពោធិ៍រំចាក

ទី២-ឌុច ភារៈ ភេទប្រុស មកពីភូមិសមរលាវ ឃុំពោធិ៍រំចាក

ទី៣-ម៉ៅ ម៉ាលីស ភេទប្រុស មកពីភូមិសមរខ្មែរ ឃុំពោធិ៍រំចាក

ទី៤-ហ៊ុម គោ ភេទប្រុស មកពីភូមិសមរលាវ ឃុំពោធិ៍រំចាក

ទី៥-ហាក់ គុន្ធី ភេទស្រី មកពីថ្នល់បត់ ឃុំពោធិ៍រំចាក

ទី៦-ចាន់ គន្ធា ភេទស្រី មកពីភូមិដង្ហិត ឃុំចំប៉ា

ទី៧-ស្រេង គុងហៃ ភេទប្រុស មកពីសមរលោរ ឃុំពោធិ៍រំចាក

**ខ. អំពីការសាងសង់**

ដោយប្រើប្រាស់ថវិកា អេស អាយ ជី / S I G )៤00ដុល្លារ) រួមជាមួយថវិការបស់វត្តទើបឆ្នាំសិក្សានេះវិទ្យាល័យសមរលោរបានធ្វើក្រាលការ៉ូក្នុងបន្ទប់ទីចាត់ការរួចរាល់ជាស្ថាពរ។ ថវិកាS I Gបានធ្វើទ្វារដែកបានចំនួន0២បន្ទប់ និង ទិញកុំព្យូទ័របានចំនួន០១គ្រឿង ដោយចំណាយថវិកាសរុបចំនួន៥១0ដុល្លារអាមេរិក។

**គ.៣.១៨.ឆ្នាំសិក្សា២០១៦-២០១៧**

**ក. អំពីការសិក្សា**

ក្នុងឆ្នាំសិក្សានេះមានបុគ្គលិកអប់រំចំនួន២៩នាក់ ស្រីចំនួន១២នាក់ ដែលមានលោក ប៊ុត ទៀន ជានាយក លោក ឈឹម សុវណ្ណ ជានាយករង និង អ្នកគ្រូ រី គន្ធឿន ជានាយិការង។ សិស្សសរុបក្នុងឆ្នាំនេះមានចំនួន៥៧៦ នាក់ ស្រី ៣0៣ នាក់ ដែលបានបែងចែកជា១៤ថ្នាក់គឺ៖

-ថ្នាក់ទី៧ ចំនួន ៤ថ្នាក់មានសិស្ស ១៦៣នាក់ ស្រី ៨៧នាក់

-ថ្នាក់ទី៨ ចំនួន ៣ថ្នាក់ មានសិស្ស ១១៥នាក់ ស្រី ៨៧នាក់

-ថ្នាក់ទី៩ ចំនួន ២ថ្នាក់ មានសិស្សចំនួន ៩៨នាក់ ស្រី ៥២នាក់

-ថ្នាក់ទី១0ចំនួន២ថ្នាក់ មានសិស្ស ៧១នាក់ ស្រី ៣៥នាក់

-ថ្នាក់ទី១១ចំនួន១ថ្នាក់ មានសិស្ស ៧៣នាក់ ស្រី ៣៩នាក់

-ថ្នាក់ទី១២ចំនួន២ថ្នាក់ មានសិស្ស ៥៦នាក់ ស្រី ២០នាក់

**លទ្ធផលប្រឡងរបស់សិស្ស៖**

-ថ្នាក់ទី៧សិស្សប្រឡងជាប់ចំនួនៈ ១៤៨នាក់ ក្នុងនោះស្រី ៨០នាក់

-ថ្នាក់ទី៨សិស្សប្រឡងជាប់ចំនួនៈ ៩២នាក់ ក្នុងនោះស្រី ៥៥នាក់

-ថ្នាក់ទី៩សិស្សប្រឡងជាប់ចំនួនៈ ៧៧នាក់ ក្នុងនោះស្រី ៤១នាក់

-ថ្នាក់ទី១០សិស្សប្រឡងជាប់ចំនួនៈ ៧៦នាក់ ក្នុងនោះស្រី ៣២នាក់

-ថ្នាក់ទី១១សិស្សប្រឡងជាប់ចំនួនៈ ៦៨នាក់ ក្នុងនោះស្រី ៣៧នាក់

-ថ្នាក់ទី១២សិស្សប្រឡងជាប់ចំនួនៈ ២៣នាក់ ក្នុងនោះស្រី ១១នាក់

**ខ. អំពីការសាងសង់**

ដោយប្រើថវិកា SIG ឆ្នាំ២០១៧ យើងបានធ្វើទ្វារដែកចំនួន០២ បន្ទប់បន្ថែមទៀត ដោយចំណាយថវិកាអស់ចំនួន២១០ដុល្លារ និងដោយមានការចូលរួមវិភាគទានពីសំណាក់អតីតសិស្សានុសិស្សនៃវិទ្យាល័យសមរលោរ បានទិញតុសិស្សបានចំនួន២០តុ តុគ្រូបានចំនួន ០៨តុ និង កៅអីបានចំនួន ០៩កៅអី។ ក្រៅពីនេះតាមរយៈក្រុមការងារគណបក្សប្រជាជនកម្ពុជាចុះជួយឃុំពោធិ៍រំចាក បានជួយកសាងបង្គន់អនាម័យបានចំនួន០១ខ្នងមានពីរបន្ទប់ ព្រមទាំងបានជួយភ្ជាប់បណ្តាញទឹកស្អាតសម្រាប់ប្រើប្រាស់ក្នុងវិទ្យាល័យ ដោយចំណាយថវិកាអស់ចំនួន ៦ ៥០០ ០០០ រៀល។

**គ.៣.១៨.ឆ្នាំសិក្សា២០១៧-២០១៨**

**ក. អំពីការសិក្សា**

លោក ឈឹម សុវណ្ណ ត្រូវបានតែងតាំងឲ្យបំពេញភារកិច្ចជានាយកស្តីទីនៃវិទ្យាល័យសមរលោវតាមលិខិតបង្គាប់ការលេខ៥៣១អយកត.បុប ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨ ដែលចុះហត្ថលេខាដោយលោក ឡោ វីរិទ្ធិ ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តតាកែវ។ ក្នុងឆ្នាំសិក្សានេះមានបុគ្គលិកអប់រំចំនួន២៨នាក់ ស្រីចំនួន១២នាក់ ដែលមានសិស្សសរុបក្នុងឆ្នាំនេះមានចំនួន៥៥០ នាក់ ស្រី ២៩១ នាក់ ដែលបានបែងចែកជា១៦ថ្នាក់គឺ

-ថ្នាក់ទី៧ ចំនួន ៤ថ្នាក់មានសិស្ស ១៣៥នាក់ ស្រី ៦៣នាក់

-ថ្នាក់ទី៨ ចំនួន ៤ថ្នាក់ មានសិស្ស ១៣៨នាក់ ស្រី ៧៦នាក់

-ថ្នាក់ទី៩ ចំនួន ២ថ្នាក់ មានសិស្សចំនួន ៧៥នាក់ ស្រី ៤៧នាក់

-ថ្នាក់ទី១០ចំនួន២ថ្នាក់ មានសិស្ស ៧២នាក់ ស្រី ៣៨នាក់

-ថ្នាក់ទី១១ចំនួន២ថ្នាក់ មានសិស្ស ៦៥នាក់ ស្រី ៣០នាក់

-ថ្នាក់ទី១២ចំនួន២ថ្នាក់ មានសិស្ស ៦៥នាក់ ស្រី ៣៧នាក់

**លទ្ធផលប្រឡងរបស់សិស្ស៖**

-ថ្នាក់ទី៧សិស្សប្រឡងជាប់ចំនួនៈ ១៣១នាក់ ក្នុងនោះស្រី ៦២នាក់

-ថ្នាក់ទី៨សិស្សប្រឡងជាប់ចំនួនៈ ១៣៤នាក់ ក្នុងនោះស្រី ៧៥នាក់

-ថ្នាក់ទី៩សិស្សប្រឡងជាប់ចំនួនៈ ៧១នាក់ ក្នុងនោះស្រី ៤៧នាក់

-ថ្នាក់ទី១០សិស្សប្រឡងជាប់ចំនួនៈ ៧០នាក់ ក្នុងនោះស្រី ៣៨នាក់

-ថ្នាក់ទី១១សិស្សប្រឡងជាប់ចំនួនៈ ៦០នាក់ ក្នុងនោះស្រី ២៨នាក់

-ថ្នាក់ទី១២សិស្សប្រឡងជាប់ចំនួនៈ ៥២នាក់ ក្នុងនោះស្រី ២៩នាក់ ក្នុងនោះនិទ្ទេស ប៊ី ( B ) ចំនួន២នាក់រួមមាន៖

ទី១-ងិន ដេនីន ភេទប្រុស មកពីភូមិថ្នល់បត់ ឃុំពោធិ៍រំចាក

ទី២-ថន វណ្ណារ៉ា ភេទប្រុស មកពីភូមិគោកកញ្ចាប ឃុំពោធិ៍រំចាក

និងនិទ្ទេសស៊ី( C )ចំនួន៤នាក់រួមមានៈ

ទី១-ចាន់ សីហា ភេទប្រុស មកពីភូមិអូរ ឃុំព្រៃកប្បាស

ទី២-ឈីវ សំណាង ភេទប្រុស មកពីភូមិសមរលាភ ឃុំពោធិ៍រំចាក

ទី៣-ម៉ុល ណារី ភេទស្រី មកពីភូមិដង្ហិត ឃុំចំប៉ា និង

ទី៤-ស្រ៊ា យឿន ភេទប្រុស មកពីភូមិសមរលាភ ឃុំពោធិ៍រំចាក[166] ។

**ខ. អំពីការសាងសង់**

ដោយប្រើថវិកា SIF និង PB ឆ្នាំ២០១៨ យើងបានធ្វើការជួសជុលតុចំនួន៣០ ក្រាលការ៉ូក្នុងទីចាត់ការ និងបណ្ណាល័យ រៀបចំសួនច្បារ ទិញធុងសំរាមដាក់តាមបន្ទប់ និងក្នុងទីធ្លាសាលា ទិញរូបថត និងរៀបបាវចនាជាតិគ្រប់បន្ទប់ទាំង២១បន្ទប់ ទិញជីបាន៣០រថយន្ត បង្កប់លូទឹកបានចំនួន៧លូ រៀបចំប្រព័ន្ធទឹកស្រោច ស្រពសួនច្បារ( ថវិការបស់បរិស្ថានរួមនឹងS I F ដើម្បីតម្លើងពន្លឺសូឡា ម៉ូទ័រ ទឹក) ដោយចំណាយថវិកាអស់ចំនួន៩,០០០,០០០រៀល។ អតីតសិស្ស និងសប្បុរសជនបានទិញតុសិស្សបានចំនួន៣០តុ តុគ្រូបានចំនួន០៨តុ និង កៅអីបានចំនូន១៩កៅអី។ ក្រៅពីនេះតាមរយៈក្រុមការងារគណបក្សប្រជាជនកម្ពុជាចុះជួយឃុំពោធិ៍រំចាកបានជួយធ្វើទ្វារបង្អួចដែកចំនួន២១បន្ទប់ដោយចំណាយថវិកាអស់ចំនួន៩,២៥០,០០០រៀល។

ក្រៅពីនេះ អ្នកគ្រូ យុន សុខចេង ហៅអ្នកគ្រូ មុំ[167] បានជួយកសាង

[166] ប្រភពព័ត៌មានពីលោក ឌុក ឌីកែន នាយករងវិទ្យាល័យសមរលាភថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៨។
[167] អ្នកគ្រូបច្ចុប្បន្នបង្រៀននៅវិទ្យាល័យសមរលាភ មានទីលំនៅភូមិសែវ៉ា ឃុំព្រៃផ្ដៅ ស្រុកព្រៃកប្បាស ខេត្តតាកែវ

ក្លោងទ្វារសាលាឡើងវិញទាំងស្រុងដោយចំណាយទឹកប្រាក់អស់ចំនួន ១៣,០០០,០០០រៀល។

**គ.៣.១៩.ឆ្នាំសិក្សា២០១៧-២០១៨**

**ក. អំពីការសិក្សា**

ក្នុងឆ្នាំសិក្សានេះមានបុគ្គលិកអប់រំចំនួន៣០នាក់ ស្រីចំនួន១៣នាក់ មានលោក ប៊ុត ទៀន ជានាយក លោក ឈឹម សុវណ្ណ ជានាយករង។ សិស្សសរុបក្នុងឆ្នាំ នេះមានចំនួន៦១៣នាក់ ស្រី៣២៣នាក់ ដែលក្នុងនោះបានបែងចែកជា១៦ថ្នាក់ គឺ

-ថ្នាក់ទី៧ ចំនួន ៤ថ្នាក់មានសិស្ស ១៤៦នាក់ ស្រី ៧៣នាក់

-ថ្នាក់ទី៨ ចំនួន ៤ថ្នាក់ មានសិស្ស ១៥៣នាក់ ស្រី ៨៣នាក់

-ថ្នាក់ទី៩ ចំនួន ២ថ្នាក់ មានសិស្សចំនួន ៩៣នាក់ ស្រី ៥៥នាក់

-ថ្នាក់ទី១០ចំនួន២ថ្នាក់ មានសិស្ស ៨១នាក់ ស្រី ៤១នាក់

-ថ្នាក់ទី១១ចំនួន២ថ្នាក់ មានសិស្ស ៧១នាក់ ស្រី ៣៤នាក់

-ថ្នាក់ទី១២ចំនួន២ថ្នាក់ មានសិស្ស ៦៩នាក់ ស្រី ៣៧នាក់

**លទ្ធផលប្រលងរបស់សិស្ស៖**

-ថ្នាក់ទី៧សិស្សប្រឡងជាប់ចំនួនៈ១៣៥នាក់ ស្រី៦៣នាក់

-ថ្នាក់ទី៨សិស្សប្រឡងជាប់ចំនួនៈ ១៣៨នាក់ ស្រី ៧៦នាក់

-ថ្នាក់ទី៩សិស្សប្រឡងជាប់ចំនួនៈ ៧១នាក់ ស្រី៤៧នាក់

-ថ្នាក់ទី១០សិស្សប្រឡងជាប់ចំនួនៈ ៧២នាក់ ស្រី៣៨នាក់

-ថ្នាក់ទី១១សិស្សប្រឡងជាប់ចំនួនៈ ៦៥នាក់ ស្រី៣០នាក់

-ថ្នាក់ទី១២សិស្សប្រឡងជាប់ចំនួនៈ ៥២នាក់ ស្រី២៩នាក់។

**ខ. អំពីការសាងសង់**

បានចាក់ដីក្នុងទីធ្លាសាលាចំនួន៣០ឡាន ដាក់លូបង្ហូរទឹកខាងមុខសាលារៀនចំនួន ប្រាំល្វែរ (ថវិកា PB2018)។ រៀបចំប្រព័ន្ធទឹក និង ម៉ូទ័រស្វ័យប្រវត្តិមួយគ្រឿង ព្រមទាំងបានបំពាក់អំពូល ពន្លឺ សូឡាបានចំនួនប្រាំពីរដើមឧបត្ថម្ភដោយក្រសួងបរិស្ថាន។

**គ.៣.២០.ឆ្នាំសិក្សា ២០១៨-២០១៩**

**ក. អំពីការសិក្សា**

ក្នុងឆ្នាំសិក្សានេះមានបុគ្គលិកអប់រំចំនួន ៣០នាក់ ស្រីចំនួន ១៣ នាក់ ដែលមាន លោក ឈឹម សុវណ្ណ ជានាយកស្តីទី និងលោក ឌុក ឌីកែន ជានាយករង។ សិស្សសរុប ក្នុងឆ្នាំនេះមានចំនួន ៦០៦នាក់ ស្រី ៣២៤នាក់ ដែលក្នុងនោះបានបែងចែកជា ១៦ថ្នាក់គឺ

-ថ្នាក់ទី៧ ចំនួន ៤ថ្នាក់មានសិស្ស ១៥២នាក់ ស្រី ៧៣នាក់
-ថ្នាក់ទី៨ ចំនួន ៣ថ្នាក់ មានសិស្ស ១១៤នាក់ ស្រី ៦១នាក់
-ថ្នាក់ទី៩ ចំនួន ២ថ្នាក់ មានសិស្សចំនួន ១៣០នាក់ ស្រី ៧២នាក់
-ថ្នាក់ទី១០ចំនួន២ថ្នាក់ មានសិស្ស ៧៧នាក់ ស្រី ៥២នាក់
-ថ្នាក់ទី១១ចំនួន២ថ្នាក់ មានសិស្ស ៧១នាក់ ស្រី ៣៧នាក់
-ថ្នាក់ទី១២ចំនួន២ថ្នាក់ មានសិស្ស ៦២នាក់ ស្រី ២៩នាក់

**លទ្ធផលប្រលងរបស់សិស្ស៖**

-ថ្នាក់ទី៧សិស្សប្រឡងជាប់ចំនួនៈ ១២៧នាក់ ក្នុងនោះស្រី ៦៩នាក់
-ថ្នាក់ទី៨សិស្សប្រឡងជាប់ចំនួនៈ ៩៣នាក់ ក្នុងនោះស្រី ៤៩នាក់
-ថ្នាក់ទី៩សិស្សប្រឡងជាប់ចំនួនៈ ១១៩នាក់ ក្នុងនោះស្រី ៧០នាក់

-ថ្នាក់ទី១០សិស្សប្រឡងជាប់ចំនួនៈ ៦៦នាក់ ក្នុងនោះស្រី ៤៥នាក់
-ថ្នាក់ទី១១សិស្សប្រឡងជាប់ចំនួនៈ ៦០នាក់ ក្នុងនោះស្រី ៣១នាក់
-ថ្នាក់ទី១២សិស្សប្រឡងជាប់ចំនួនៈ ៤៦នាក់ ក្នុងនោះស្រី ២៥នាក់

**ខ. អំពីការសាងសង់**

នៅក្នុងឆ្នាំសិក្សានេះយើងបានកសាងសមិទ្ធផលដូចជា៖

-បានកសាងក្លោងទ្វារវិទ្យាល័យសាជាថ្មី ដោយចំណាយថវិកាអស់ ៣០០០ដុល្លា ដែលជាអំណោយរបស់អ្នកគ្រូ យុន សុខចេង (ហៅ អ្នកគ្រូម៉ុម) នៅសៃវ៉ា

-បានធ្វើទ្វារដែក បង្អួចដែកដាក់ទាំង២១បន្ទប់ ដោយចំណាយថវិកាអស់ចំនួន៩២៤០០០០រៀល ដែលជាអំណោយរបស់ឯកឧត្តម ហេង សួរ ប្រធានក្រុមការងារចុះជួយឃុំពោធិ៍រំចាក

-បានបំពាក់កុំព្យូទ័រចំនួន២០គ្រឿងសម្រាប់បង្រៀនសិស្សដែលជាអំណោយរបស់ឯឧត្តម ហេង សួរ ប្រធានក្រុមការងារចុះជួយឃុំពោធិ៍រំចាក

-បានក្រាលការ៉ូ និងធ្វើធ្នើដាក់ឯកសារ ក្នុងបន្ទប់ទីចាត់ការ និងបន្ទប់បណ្ណាល័យ

-បានធ្វើរោងសម្រាប់ឲ្យសិស្សដាក់កង់ម៉ូតូ ដែលជាអំណោយរបស់លោក ឡាំ ងនលី និងអ្នកស្រី ស៊ុយ គឹមហេង។

**គ.៣.១៩.ឆ្នាំសិក្សា២០១៩-២០២០**

**ក. អំពីការសិក្សា**

ក្នុងឆ្នាំសិក្សានេះមានបុគ្គលិកអប់រំចំនួន ៣០នាក់ ស្រីចំនួន១៣នាក់ ដែលមានលោក ឈឹមសុវណ្ណ ជានាយក និងលោកឌុក ឌីកែន ជានាយករង។

សិស្សសរុបក្នុងឆ្នាំនេះមានចំនួន  ៦១៦ នាក់ ស្រី ៣៤១ នាក់ ដែលក្នុងនោះ បានបែងចែកជា ១៥ថ្នាក់ គឺ

-ថ្នាក់ទី៧ ចំនួន ៣ថ្នាក់មានសិស្ស  ១៣៩នាក់ ស្រី ៧០នាក់

-ថ្នាក់ទី៨ ចំនួន ៣ថ្នាក់ មានសិស្ស ១៣១នាក់ ស្រី ៧៣នាក់

-ថ្នាក់ទី៩ ចំនួន ២ថ្នាក់ មានសិស្សចំនួន ១៩៦នាក់ ស្រី ៥០នាក់

-ថ្នាក់ទី១០ចំនួន៣ថ្នាក់ មានសិស្ស ១១៩នាក់ ស្រី ៧០នាក់

-ថ្នាក់ទី១១ចំនួន២ថ្នាក់ មានសិស្ស ៧១នាក់ ស្រី ៤៧នាក់

-ថ្នាក់ទី១២ចំនួន២ថ្នាក់ មានសិស្ស ៦០នាក់ ស្រី ៣១នាក់

**លទ្ធផលប្រឡងរបស់សិស្ស៖**

-ថ្នាក់ទី៧សិស្សប្រឡងជាប់ចំនួនៈ ១២៧នាក់ ក្នុងនោះស្រី ៦៩នាក់

-ថ្នាក់ទី៨សិស្សប្រឡងជាប់ចំនួនៈ ៩៣នាក់ ក្នុងនោះស្រី  ៤៩នាក់

-ថ្នាក់ទី៩សិស្សប្រឡងជាប់ចំនួនៈ ១១៩នាក់ ក្នុងនោះស្រី ៧០នាក់

-ថ្នាក់ទី១០សិស្សប្រឡងជាប់ចំនួនៈ ៦៦នាក់ ក្នុងនោះស្រី ៤៥នាក់

-ថ្នាក់ទី១១សិស្សប្រឡងជាប់ចំនួនៈ ៦០នាក់ ក្នុងនោះស្រី  ៣១នាក់

-ថ្នាក់ទី១២សិស្សប្រឡងជាប់ចំនួនៈ ៤៦នាក់ ក្នុងនោះស្រី  ២៥នាក់

**ខ. អំពីការសាងសង់**

-បានធ្វើដំបូលតាកឆ្មៀងអពីដែកនៅខាងមុខអាគារទីចាត់ការដោយប្រើប្រាស់ថវិការ OB

-បានធ្វើកន្លែងលាងសម្អាតដៃមួយកន្លែង នៅខាងមុខអាគារទីចាត់ការជាអំណោយរបស់

ព្រះតេជគុណឡាក់ហំ ចៅអធិការវត្តសមរលាវ បដិភាគជាមួយថវិកាសាលា។

## គ.៣.១៩.ឆ្នាំសិក្សា២០១៩-២០២០

### ក. អំពីការសិក្សា

ក្នុងឆ្នាំសិក្សានេះមានបុគ្គលិកអប់រំចំនួន៣២នាក់ ស្រីចំនួន១៣នាក់ ដែលមានលោក ឈឹម សុវណ្ណ ជានាយក និង លោក ឌុក ឌីកែន ជានាយករង ។ សិស្សសរុបក្នុងឆ្នាំ នេះមានចំនួន៦១៩ នាក់ ស្រី ៣៤៦ នាក់ ដែលក្នុងនោះបានបែងចែកជា១៦ថ្នាក់គឺ

-ថ្នាក់ទី៧ ចំនួន ៣ថ្នាក់មានសិស្ស ១២៩នាក់ ស្រី ៦៣នាក់

-ថ្នាក់ទី៨ ចំនួន ៣ថ្នាក់ មានសិស្ស ១១៦នាក់ ស្រី ៥៩នាក់

-ថ្នាក់ទី៩ ចំនួន៣ថ្នាក់ មានសិស្សចំនួន១១២នាក់ ស្រី៦៧នាក់

-ថ្នាក់ទី១០ចំនួន២ថ្នាក់ មានសិស្ស ៩០នាក់ ស្រី ៥២នាក់

-ថ្នាក់ទី១១ចំនួន៣ថ្នាក់ មានសិស្ស ១១០នាក់ ស្រី ៦១នាក់

-ថ្នាក់ទី១២ចំនួន២ថ្នាក់ មានសិស្ស ៦២នាក់ ស្រី ៤៤នាក់

### ខ. អំពីការសាងសង់

បានចាក់សាប(បេតុង)នៅតាមទីធ្លាខាងមុខអាគារសិក្សា និង អគារទីចាត់ការដោយបានថវិកាមកពីសប្បុរស់ជននានា ព្រះតេជគុណ ឡាក់ ហំ ចៅអធិការវត្តសមរលោវ និង បដិភាគជាមួយថវិកាសាលា។

### ខ-១-សកម្មភាពដាំដើមឈើ និងកសាងរបស់លោក បណ្ឌិត សេង ប៊ុនធឿន អ្នកនិពន្ធសៀវភៅនេះ

-ថ្ងៃទី២៥ ខែឧសភា ២០១៣ លោកបណ្ឌិត សេង ប៊ុនធឿន សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យជាតិគ្រប់គ្រងបានដឹកនាំនិស្សិតសាកល

វិទ្យាល័យជាតិគ្រប់គ្រងប្រមាណ៧០នាក់មកដាំកូនឈើចំនួន១៩៤ដើម (កូនគគីរ ឈើទាល បេង លៀងរាជ និងនាងនួន)ក្នុងបរិវេណសាលា។

-ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៤ ៖ លោកបណ្ឌិត សេង ប៊ុនធឿន បានដឹកនាំនិស្សិតនៃសាកលវិទ្យាល័យជាតិគ្រប់គ្រង និងសិស្សានុសិស្ស ព្រមទាំងលោកគ្រូ អ្នកគ្រូ ដាំកូនឈើបានចំនួន២៨០ដើមនៅបរិវេណសាលាបឋមសិក្សាហាតាកាស៊ីសមរមេត្រីបរិវេណសាលាបឋមសិក្សា សមរលោរ អនុវិទ្យាល័យ វិទ្យាល័យសមរលោរ និងក្នុងវត្តសមរលោរ។

-ថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៥ ៖ លោកបណ្ឌិត សេង ប៊ុនធឿន បានដឹកនាំនិស្សិតនៃសាកលវិទ្យាល័យជាតិគ្រប់គ្រង និងសិស្សានុសិស្ស ព្រមទាំងលោកគ្រូ អ្នកគ្រូ ដាំកូនឈើបានចំនួន២១៧ដើមបន្ថែមទៀតនៅក្នុងបរិវេណសាលាបឋមសិក្សាតាកាហាស៊ីសមរមេត្រី បឋមសិក្សាសមរលោរ អនុវិទ្យាល័យ និងវិទ្យាល័យសមរលោរ ភូមិសមរលោរ ឃុំពោធិ៍រំចាក និងបរិវេណសាលាបឋមសិក្សា និងវត្តជ្រយជម្លូរពេជ្រស្ថិតក្នុងភូមិជ្រយ ឃុំចំប៉ា ស្រុកព្រៃកប្បាស ខេត្តតាកែវ។

-ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៦ ៖ លោកបណ្ឌិត សេង ប៊ុនធឿន បានដឹកនាំនិស្សិតនៃសាកលវិទ្យាល័យជាតិគ្រប់គ្រង និងគ្រូបង្រៀនផងចំនួន៨៧នាក់ទៅដាំដើមឈើនៅវិទ្យាល័យកំពង់ពពិល ភូមិទួលអំពិល ឃុំកំពង់ពពិល ស្រុកពារាំង ខេត្តព្រៃវែងចំនួន១២៣ដើម(ការរៀបចំរបស់សាកលវិទ្យាល័យ)។

-ថ្ងៃទី១៥ខែមិថុនា ឆ្នាំ២០១៦ ៖ លោកបណ្ឌិត សេង ប៊ុនធឿនបានដឹកនាំនិស្សិតនៃសាកលវិទ្យាល័យ និងគ្រូបង្រៀនផងចំនួន៨៧នាក់ទៅដាំដើមឈើនៅវិទ្យាល័យស៊ីសុវត្ថិចំនួន០៤ដើម(មានទីតាំងស្ថិតនៅខាងជើង

តារាងបាល់ទាត់នៃវិទ្យាល័យ ហើយជាការរៀបចំរបស់សាកលវិទ្យាល័យជាតិគ្រប់គ្រង)។

-ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៦៖ លោកបណ្ឌិត សេង ប៊ុនធឿន បានដឹកនាំនិស្សិតនៃសាកល វិទ្យាល័យជាតិគ្រប់គ្រង អ្នកស្ម័គ្រចិត្តដោយមានការសហការពីលោក ហូ វណ្ឌី អគ្គលេខាធិការនៃ សម្ព័ន្ធទេសចរណ៍ជាតិកម្ពុជារួមដំណើរដោយលោកជំទាវឧកញ៉ា អឿង គឹមហុង លោកឧត្តមសេនិយ៍ ឈិន ច័ន្ទដារ៉ាវុធ និងលោកជំទាវ មាស ច័ន្ទធីតា ចំនួន២៧០នាក់ ព្រមទាំងមានការស្វាគមន៍ពីលោក ឌឹម គឹមសាន អភិបាលស្រុកអង្គរបុរី លោក កង ឥន្ទ្រីយ៍ ប្រធានមន្ទីរទេសចរណ៍ខេត្តតាកែវ លោក សាន លីម អនុប្រធានការិយាល័យអប់រំ យុវជន និងកីឡាស្រុកអង្គរបុរី លោក អ៊ី យ៉ុង នាយកវិទ្យាល័យ ហ៊ុន សែន អង្គរបុរី ព្រមទាំងលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សចំនួនជាង២៥០នាក់ផ្សេងទៀតបានដាំកូនឈើបានចំនួន៥២៥ដើម ក្នុងនោះលោកបានដាំដើមធ្លកមួយដើម ដើម្បីទុកជាប្រវត្តិសាស្ត្រនៅក្នុងបរិវេណវិទ្យាល័យនេះថែមទៀតផង។ ជាមួយគ្នានេះនៅថ្ងៃដដែលនោះ លោកបណ្ឌិតក៏បានទិញ២០០ដើម (គគីរ១០០ដើមពីខេត្តព្រៃវែង និងដើមឈើ ទាល១០០ដើមពីស្ថានីយ៍បណ្ដុះកូនឈើ ហ៊ុន សែនភ្នំជីសូរ្យ)ផ្សេងទៀតមកដាំនៅក្នុងបរិវេណសាលាបឋមសិក្សាតាកាហាស៊ីសមរមេត្រី បឋមសិក្សាសមរលោរ អនុវិទ្យាល័យ និងវិទ្យាល័យ សមរលោរ ភូមិសមរលោរ ឃុំពោធិ៍រំចាក និងបរិវេណសាលាបឋមសិក្សា និងវត្តជ្រយជម្លូរពេជ្រស្ថិតក្នុងភូមិជ្រយ ឃុំចំប៉ា ស្រុកព្រៃកប្បាស ខេត្តតាកែវជំនួសបំពេញដើមឈើដែលងាប់នារដូវប្រាំងកន្លងទៅ។ ចំពោះប្រភេទឈើទាំងនោះមានដូចជាបេង នាងនួន ឈើទាល គគីរ ម៉ៃសាក់ កកោះ ក្រញូង លៀងរាជ្យ។ល។

-ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៦ ៖ លោកបណ្ឌិត សេង ប៊ុនធឿន បាន ដឹកនាំនិស្សិតនៃសាកលវិទ្យាល័យជាតិគ្រប់គ្រងទៅដាំដើមឈើ( ឈើទាល និងគគីរ )នៅវិទ្យាល័យ ហ៊ុន សែន វាលរេញ ភូមិវាលមាស ឃុំវាលរេញ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ៣០៦ដើម។

-ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៧ ៖ លោកបណ្ឌិត សេង ប៊ុនធឿន បាន ឆ្លៀតឱកាសទៅលេងស្រុកកំណើតជាមួយភរិយា និងបុត្រាបាននាំដឹកនាំព្រះតេជគុណព្រះសង្ឃ ភិក្ខុ សាមណេរដោយ មានការចូលរួមពីព្រះចៅអធិការវត្ត ផងបានធ្វើការដាំដើមនាងនួន( ដើមនាងនួននេះបណ្តុះនៅគេហដ្ឋានខ្លួនឯងឯរាជធានីភ្នំពេញបានចំនួន១៣ដើម) ឈើទាល១៣ដើម និងគគីរ៣ដើម សរុបចំនួន២៩ដើមក្នុងទីតាំងខាងក្រោយសាលាធម្មសភា និងតាមបណ្តោយខាងក្រោយកុដិព្រះសង្ឃហែជាជួរបន្តគ្នាទៅទិសខាងត្បូងដែលនៅទីនោះតាមលោកបណ្ឌិតនឹងប្រែក្លាយកន្លែងនេះឲ្យទៅជាសួនលម្អជុំវិញអាស្រមលោកយាយលាវ ហើយធ្វើការរំកឹលបង្គន់អនាម័យនៅកណ្តាលដីនេះទៅនៅក្បែររបងវិញ។ ជាមួយគ្នានោះ លោកបណ្ឌិត សេង ប៊ុនធឿន ក៏បានជាវរូបចម្លាក់លោកយាយលាវចេញថ្លៃឈ្នួលជួលជាងសាងសង់អាស្រមលោកយាយលាវឲ្យមានរូបរាងច្បាស់លាស់សម្រាប់អ្នកស្រុកបានគោរពបូជាតទៅដោយសុំឲ្យព្រះតេជគុណព្រះចៅអធិការវត្តចេញសម្ភារៈតែប៉ុណ្ណោះ។

-ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៧ ៖ លោកបណ្ឌិត សេង ប៊ុនធឿន បាន ដឹកនាំនិស្សិតនៃសាកលវិទ្យាល័យជាតិគ្រប់គ្រងទៅដាំដើមឈើ( ឈើទាល បេង ក្រញូង នាងនួន និងគគីរ។ល។)នៅវិទ្យាល័យសម្តេចឪ ស្រុកសំរោង ខេត្តតាកែវ ១២៥១ដើម។ ក្នុងនោះនៅវិទ្យាល័យសម្តេចឪ ស្រុកសំរោង ខេត្តតាកែវ ៦៦០ដើម វិទ្យាល័យ ហ៊ុន សែន អង្គបុរី ស្រុកអង្គបុរី១០០ដើម បឋម

សិក្សា និវត្តសមរលោវ ៥៧០ដើម សាលាបឋមសិក្សាតាកាហាស៊ីសមរមេត្រី ៣៥ដើម។

-ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៧៖ លោកបណ្ឌិត សេង ប៊ុនធឿន រួមដំណើរដោយឯកឧត្តម ត្រឹង លីម ទីប្រឹក្សាអមរាជបណ្ឌិតសភាកម្ពុជាបានដឹកនាំនិស្សិតនៃសាកលវិទ្យាល័យជាតិគ្រប់គ្រងទៅដាំដើមឈើ(ឈើទាល បេង ក្រញូង នាងនួន និងគគីរ។ល។)ចំនួន៤៥៦ដើមនៅទីតាំងចំនួនបីកន្លែងក្នុងស្រុកឧដុង្គ ខេត្តកំពង់ស្ពឺរួមមាន៖ ទី១ វិទ្យាល័យឧដុង្គ ស្ថិតនៅភូមិក្រាំងពន្លៃ ឃុំវាំងចាស់ ១៥០ដើម ទី២ វត្តឈូកស ភូមិឈូកស ឃុំព្រះស្រែ ចំនួន២០០ដើម និងទី៣ វត្តសុវណ្ណទេពហៅវត្តផ្គរចំនួន១០៦ដើម។

-ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៨ ៖ លោកបណ្ឌិត សេង ប៊ុនធឿន បានដឹកនាំនិស្សិត និងបុគ្គលិកនៃសាកលវិទ្យាល័យជាតិគ្រប់គ្រងចំនួន៣១នាក់ និងនិស្សិតរួមទាំងលោកគ្រូ អ្នកគ្រូមកពីសាកលវិទ្យាល័យសាំងហ្គាពួរប៉ូលីតិចនិក[168] (Singapore polytechnic/SP) ចំនួន៣១នាក់ផងដែរដោយមានការចូលរួមពីលោក អ៊ុង វ៉ាន់ឌី នាយកសាលាបឋមសិក្សាសោភ័ណគិរី នាយករង លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ដើម្បីដាំដើមឈើទាលចំនួន

[168] កម្មវិធីផ្លាស់ប្តូរនិស្សិត និងអនុវត្តគម្រោងដោយមានការសហការជាមួយ Singapore Polytechnic/SP និងសាកលវិទ្យាល័យជាតិគ្រប់គ្រងបានអនុវត្តគម្រោងរួមគ្នាឈ្មោះថា Learning Express Program/ Learning by Doing ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី ១៩ ដល់ថ្ងៃទី៣០ ខែ មីនា ឆ្នាំ២០១៨ និស្សិតមកពីមកពីប្រទេសសឹង្ហបុរី (Singapore) ៣១នាក់ និងសាកលវិទ្យាល័យជាតិគ្រប់គ្រង៣១នាក់ដែរ។ នេះកម្មវិធីហូម ស្តេយ(Homestay)ពីថ្ងៃទី២១ដល់ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៧ នៅភូមិអណ្តូងឫស្សី ឃុំស្រែថ្មី ស្រុករលាប្អៀរ ខេត្តកំពុងឆ្នាំង ផងដែរ។

១០២ដើមនៅក្នុងបរិវេណសាលាខាងលើស្ថិតនៅភូមិអណ្តូងឫស្សី ឃុំស្រែថ្មី ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។

-ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៨ ៖ ក្នុងនាមសាកលវិទ្យាល័យជាតិគ្រប់គ្រងលោកបណ្ឌិត សេង ប៊ុនធឿន ត្រូវបានចាត់ឲ្យចូលរួមកម្មវិធីដាំកូនឈើចំនួនជាង៦០,០០០ដើមរួមដំណើរដោយ លោក ប៊ុត សុឌី អតីតនិស្សិតរបស់លោកផងនៅសួនឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា«តេជោសែនឫស្សីត្រឹប»ស្ថិតនៅក្នុងឃុំឆែប២ ស្រុកឆែប ខេត្តព្រះវិហារក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

-ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៨ ៖ លោកបណ្ឌិត សេង ប៊ុនធឿន បានទិញដើមឈើទៅដាំបន្ថែមនៅវិទ្យាល័យសម្តេចឪ ស្រុកសំរោង ខេត្តតាកែវ ២៣៨ដើមទៀត។

-ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៨ ៖ លោកបណ្ឌិត សេង ប៊ុនធឿន រួមដំណើរបានដឹកនាំនិស្សិតស្ម័គ្រចិត្តបន្ទប់៧ស៊ី(c )សិក្សាថ្ងៃសៅរ៍-អាទិត្យឆ្នាំសិក្សា២០១៧-២០១៨នៃសាកលវិទ្យាល័យជាតិគ្រប់គ្រងចំនួន៣២នាក់ដោយមានការចូលរួមពីលោកនាយករង នាយិកា លោកគ្រូ អ្នកគ្រូសិស្សានុសិស្សចំនួនប្រមាណ២០០នាក់ចូលរួមដាំដើមឈើ (បេង ក្រញូង ឈើទាល និងគគីរ) ចំនួន៥១៦ដើម ក្នុងនោះនៅវិទ្យាល័យ ហ៊ុន សែន តាគោក ភូមិសំរោង ឃុំល្វា ចំនួន២៤៦ដើម អនុវិទ្យាល័យទួលសំរោង ភូមិស្វាយបាង ឃុំកំពង់សឹង ចំនួន២០០ដើម និងអនុវិទ្យាល័យទួលសំពៅ ភូមិគោកសំពៅ ឃុំក្រាំងស្វាយ ស្រុកព្រះស្តេច ខេត្តព្រៃវែងចំនួន៧០ដើម។ ជាមោទនភាព និស្សិតរបស់ខ្ញុំបានស្វះស្វែងរកសម្ភារៈជាប៊ិច សៀវភៅសរសេរ សាប៊ូ

ដើម្បីធ្វើអំណោយដល់សិស្សានុសិស្សទាំងអស់ដោយម្នាក់ៗទទួលបាន សៀវភៅសរសេរ១ក្បាល ប៊ិច២និងសាប៊ូពីរកញ្ចប់ពីក្រុមហ៊ុនជីបម៉ុងផងដែរ។ រីឯជ័យលាភីលេខ១ប្រចាំឆ្នាំ១៤នាក់បន្ថែមស្បែកជើងកីឡាម្នាក់១គូផងដែរ។ ឆ្លៀតឱកាសនេះ បាននាំនិស្សិតទៅទទួលទានអាហារថ្ងៃត្រង់ និងកំសាន្តនៅរមណីយដ្ឋានឈើកាច់(បាភ្នំ)យ៉ាងសប្បាយរីករាយ។

-ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៩ ៖ លោកបណ្ឌិត សេង ប៊ុនធឿន បានធ្វើសំណេះសំណាលជាមួយក្មួយសិស្សថ្នាក់ទី១២ចំនួន៥១នាក់ និងប្រគេនដើមឈើដល់ព្រះតេជគុណ ឡាក់ ហំ ហៅ ហ៊ីម ព្រះចៅអធិការវត្តដើម្បីដាំបន្ថែមនៅក្នុងបរិវេណវត្ត វិទ្យាល័យសមរលោរ ចំនួន៥៥ដើមទៀត។

-ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ៖ លោកបណ្ឌិត សេង ប៊ុនធឿន បានដឹកនាំនិស្សិតសាកលវិទ្យាល័យជាតិគ្រប់គ្រងចំនួន១២៥នាក់ ដាំដើមឈើនៅក្នុងបរិវេណវត្តព្រះបារមីគោតម ស្ថិតនៅក្នុងភូមិគោកអង្គង់ ឃុំពោធិ៍រំចាក ចំនួន៣០០ដើម។ វត្តពោធិឯក ស្ថិតនៅក្នុងភូមិព្រៃកប្បាស ឃុំព្រៃកប្បាស ចំនួន៥៥០ដើម សាលាបឋមសិក្សាឬស្សីថ្មី ភូមិឬស្សីថ្មី ឃុំចំប៉ា ចំនួន១២០ដើម ស្រុកព្រៃកប្បាស ខេត្តតាកែវ ចំនួន៩៧០ដើម ក្នុងនោះមានឈើទាលបេង គគីរ។ល។

-ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២០ ៖ លោកបណ្ឌិត សេង ប៊ុនធឿន បានដឹកនាំនិស្សិតសាកលវិទ្យាល័យជាតិគ្រប់គ្រងចូលរួមដាំដើមឈើផ្ទាល់ទេ ដោយសារតែមានមេរោគកូវីដ-១៩(COVI D-19)រាតត្បាត។ ប៉ុន្តែលោកបានទិញកូនឈើចំនួន៦៨០ដើមដាំនៅក្នុងបរិវេណវិទ្យាល័យសម្តេចឪ ដែលស្ថិតនៅក្នុងឃុំសំរោង១០០ដើម សាលាបឋមសិក្សាបត់រកា ឃុំសំរោង ស្រុកសំរោង១០០ដើម លើភ្នំជីសូរ្យ(ផ្លូវចុះរថយន្តពីកំពូលភ្នំមកជើងភ្នំ)២០០

ដើម និងយកទៅដាំបន្ថែមនៅវិទ្យាល័យហ៊ុន សែនអង្គរបុរី ស្រុកអង្គរបុរីចំនួន ២៨០ដើម។

-ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២១ ៖ សកម្មភាពដាំដើមឈើឆ្នាំទី៩ ជាការដាំកូនឈើគម្រប់ទី១០០០០ដើម(មួយម៉ឺនដើម)។ ដោយសារតែកូវីដ-១៩(COVI D-19)រាតត្បាត លោកបណ្ឌិត សេង ប៊ុនធឿន មិនបានដឹកនាំនិស្សិតចូលរួមដាំដើមឈើផ្ទាល់ដូចឆ្នាំមុនៗទេ។ ប៉ុន្តែមានកម្មវិធីប្រគល់កូនឈើជូនសហគមន៍ជានិមិត្តរូបប្រព្រឹត្តិទៅក្រោមអធិបតីភាពដ៏ខ្ពស់ខ្ពស់ឯកឧត្តមបណ្ឌិត ហោ ប៉េង សាកលវិទ្យាធិការនៃសាកលវិទ្យាល័យជាតិគ្រប់គ្រង លោក ឈន ឈុនឡេង ប្រធានក្រុមប្រឹក្សាភិបាល លោក អ៊ុយ ប៊ុនតារា អគ្គនាយក នៃក្រុមហ៊ុន E-School Cambodia លោក កែវ ហ៊ានជាន ប្រធានសមាគមនិស្សិតសាកលវិទ្យាល័យជាតិគ្រប់គ្រង។ អរគុណក្រុមហ៊ុន កូនឈើចំនួន៣១៤៦ដើមត្រូវបានផ្តល់ដោយក្រុមហ៊ុន E-School Cambodia ទាំងអស់គាំទ្រសម្រាប់ ។

កម្មវិធីបានក្នុងនោះ៖

១-វិទ្យាល័យសំរោងពន្លៃ ភូមិពន្លៃ ឃុំពន្លៃ ស្រុកអង្គរបុរី ចំនួន១០០ ដើម

២-បឋមសិក្សា កោះទ្រា ភូមិកោះទ្រា ឃុំពន្លៃ ស្រុកអង្គរបុរី ចំនួន ១០០ដើម

៣-វត្តសំបួរសាគរ ភូមិព្រៃផ្ដៅ ក ឃុំព្រៃផ្ដៅ ចំនួន៩៤០ដើម

៤-សាលាបឋមសិក្សាអង្គជុំ និងវត្តអង្គជុំ ភូមិកំហែង ឃុំព្រៃផ្ដៅ ចំនួន ១៧០០ដើម

៥-អនុវិទ្យាល័យសែនជ័យព្រៃផ្តៅ ភូមិកំហែង ឃុំព្រៃផ្តៅ ចំនួន៥៥៤ ដើម ស្រុកអង្គរបុរី ខេត្តតាកែវ។

និងទី៦-ថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២១នេះ លោក ឈន ឈុនឡេង ប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន E-School Cambodia ក៏បាន ជួយកូនឈើចំនួន៦៧៣ដើមបន្ថែមទៀតយើទៅដាំនៅទីកន្លែងសាធារណៈ នានាក្នុងភូមិសាស្ត្រឃុំរាយប៉ាយ ស្រុកកងមាស ខេត្តកំពង់ចាម។

**ខ-២-ការកសាងព្រះរូបព្រះករុណា ព្រះបាទ ជ័យវរ្ម័នទី៧**

-ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៥ ៖ ឯកឧត្តមបណ្ឌិត កុល ផេង លោក ជំទាវ កឹម ផល្លា ព្រះតេជគុណ សួស ជុំ អតីតព្រះចៅអធិការវត្តសមរលាវ លោកតាឧសបាសក សេង អ៊ិន និងលោកយាយឧសបាសិកា កាក់ ធួង លោក សេង ប៊ុនធឿន និងលោកស្រី ហែម ពេជ្របញ្ញា ជាភរិយាព្រមទាំងបុត្របានក សាងព្រះរូបព្រះបាទ ជ័យវរ្ម័នទី៧ តម្កល់ទុកនៅក្នុងបរិវេណវិទ្យាល័យសមរ លាវ ភូមិសមរលាវ ឃុំពោធិ៍រំចាក ស្រុកព្រៃកប្បាស ខេត្តតាកែវ ទុកសម្រាប់ គោរពបូជា និងជាអនុស្សាវរីយ៍។

-ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១១ ៖ លោកបណ្ឌិត សេង ប៊ុនធឿន និង លោកស្រី ហែម ពេជ្របញ្ញា ជាភរិយាព្រមទាំងបុត្រ រួមជាមួយអតីតមិត្តភក្ត្រ វិទ្យាល័យរួមជំនាន់ បានកសាងព្រះរូបព្រះបាទ ជ័យវរ្ម័នទី៧ តម្កល់ទុកនៅ ក្នុងបរិវេណវិទ្យាល័យ ហេង សំរិន ព្រៃល្វា ភូមិព្រៃល្វា ឃុំព្រៃល្វា ស្រុក ព្រៃកប្បាស ខេត្តតាកែវអស់ទឹកប្រាក់ចំនួន៤៥០០ដុល្លារអាមេរិកទុកសម្រាប់ គោរពបូជា និងជាអនុស្សាវរីយ៍។

-ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៧ ៖ លោកបណ្ឌិត សេង ប៊ុនធឿន និង លោកស្រី ហែម ពេជ្របញ្ញា ជាភរិយាព្រមទាំងបុត្រ បានកសាងព្រះរូប

ព្រះបាទ ជ័យវរ្ម័នទី៧ តម្កល់ទុកនៅក្នុងបរិវេណសាលាបឋមសិក្សាហាតាកាស៊ីសមរមេត្រី ភូមិសមរខ្មែរ ឃុំពោធិ៍រំចាក ស្រុកព្រៃកប្បាស ខេត្តតាកែវទុកសម្រាប់គោរពបូជា និងជាអនុស្សាវរីយ៍។

-ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ៖ លោកបណ្ឌិត សេង ប៊ុនធឿន និងលោកស្រី ហែម ពេជ្របញ្ញា ជាភរិយាព្រមទាំងបុត្របានកសាងព្រះរូបព្រះបាទ ជ័យវរ្ម័នទី៧ តម្កល់ទុកនៅក្នុងបរិវេណសារមន្ទីរអង្គរបុរី ភូមិកំពង់ហ្លួង ឃុំអង្គរបុរី ស្រុកអង្គរបុរី ខេត្តតាកែវ ទុកសម្រាប់គោរពបូជា និងជាអនុស្សាវរីយ៍ដោយមានវត្តមានស្វាគមន៍យ៉ាងកក់ក្ដៅពីសំណាក់លោក ឌឹម គឹមសាន អភិបាលស្រុក លោក រស់ រ័ត្ន អភិបាលរង លោក ជា សម្បត្តិ ប្រធានសារមន្ទីរ ព្រមទាំងមានមន្ត្រីរាជការជាច្រើនរូបទៀត។ សូមបញ្ជាក់ថា បល័ង្កនៃព្រះរូបនេះ ជាថ្មម៉ាបនៃភ្នំព្រះវិហារផ្ដល់ជូនដោយ លោកស្រី កុសល ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់រដ្ឋបាលសាធារណៈនៅសាកលវិទ្យាជាតិគ្រប់គ្រងរបស់លោក។

ចាប់តាំងពីឆ្នាំ២០១៣ រហូតដល់ខែកក្កដា ឆ្នាំ២០២១នេះ លោកបណ្ឌិត សេង ប៊ុនធឿន ភរិយាព្រមទាំងបុត្របានដឹកនាំកសាងបានព្រះបាទជ័យវរ្ម័នទី៧ បានបួនព្រះរូបតម្កល់ទីសាធារណៈបានបួនកន្លែង និងដឹកនាំផ្ទាល់នូវការដាំឈើគ្រប់ប្រភេទសរុបមានចំនួន១០៨៣៩ដើមគត់(មួយម៉ឺនប្រាំបីរយសាមសិបប្រាំបួនដើមគត់)។ នេះមិនរាប់បញ្ចូលដល់សកម្មភាពរបស់លោកបណ្ឌិតបានដឹកនាំនិស្សិតសាកលវិទ្យាល័យជាតិគ្រប់គ្រងទៅចូលរួមដាំដើមឈើដែលចំណាយថវិកាទាំងស្រុងដោយផ្សារអ៊ីអន (Aeon Mall) របស់ជប៉ុនរយៈពេលបីឆ្នាំជាប់គ្នា (ឆ្នាំ២០១៤-២០១៥ និង២០១៦) នៅបរិវេណជុំវិញផ្សារអ៊ីអនជាប់ស្ថានទូតរូស្ស៊ី(២០១៤) ក្នុងសួនសត្វភ្នំតាម៉ៅ

(២០១៥ និង២០១៦) មួយឆ្នាំៗចំនួន៧០០០ដើម សរុបបីឆ្នាំស្មើនឹង ២១០០០ដើម ជាមួយសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាដែលរៀបចំដោយរាជបណ្ឌិតកម្ពុជាចំនួន៦០,០០០ដើម ផ្សេងទៀតដូចបានរៀបរាប់ខាងផង។

ឆ្លៀតឱកាសនេះ លោកបណ្ឌិតសូមសំដែងការកោតសរសើរ និងថ្លែងអំណរអរគុណជាអនេកប្បការចំពោះសមណនិស្សិត និស្សិត ប្រិយមិត្តរបស់លោក លោកគ្រូ អ្នកគ្រូ និង អ្នកពាក់ព័ន្ធទាំងអស់ដែលបានចូលរួមយ៉ាងសកម្មក្នុងសកម្មភាពដាំដើមឈើកន្លងមកនេះ។



សកម្មភាពដាំដើមធ្លកនៅក្នុងវិទ្យាល័យ ហ៊ុន សែន អង្គរបុរី(រូបទី១១)

សូមស្តាប់បទចម្រៀង ក្សត្រីគោកធ្លកអង្គរបុរី ក្នុង **Chhanel YouTube (Seng Bunthoeun)**



រូបថតរួមគ្នារបស់ប្រតិភូពីរាជធានីភ្នំពេញ និងអាជ្ញាធរមូលដ្ឋាន(រូបទី១២)




ដើមធ្លកនេះពេលដាំទើបតែមាន៥សន្លឹកឡើយ(រូបទី១២)

បណ្ឌិត សេង ប៊ុនធឿន ឯ.ឧ ត្រឹង លីម នាយកវិទ្យាល័យឧដុង្គ និស្សិត និង សិស្ស(រូបទី១៣)

(រូបទី១៥)


សកម្មភាពនិស្សិតកំពុងយកកូនឈើចេញពីរថយន្តទៅកាន់គោលដៅ វិទ្យាល័យសម្តេចឪ ស្រុកសំរោង ខេត្តតាកែវ(រូបទី១៤)


បណ្ឌិត សេង ប៊ុនធឿន នាយិកា មាតា ភរិយា និងបុត្រា បុត្រី លោក ហូ វណ្ណឌី (រូបទី១៥)

## ៦-ដើមកំណើតភូមិសមរខ្មែរ និងភូមិសមរចិន

## ៦ភូមិសមរខ្មែរ ឬសមរមេត្រី.១.

ភូមិសមរខ្មែរមានអាយុមុនការកកើតវត្តសមរមេត្រីបន្តិចបន្តួច ហើយបានកើតចេញពីព្រឹត្តិការណ៍ដូចបានរៀបរាប់ស្តីពីការកកើតភូមិសមរលាវខាងលើ។ ភូមិសមរខ្មែរ គឺជាទីលានចម្បាំងមួយក្នុងចំណោមសមរភូមិទ័ពខ្មែរ លាវ និងចិន។ ភូមិសមរខ្មែរមានទីតាំងខាងកើតជាប់នឹងភូមិសមរចិន និងភូមិគោកកញ្ចាប ខាងត្បូងជាប់នឹងភូមិថ្នល់បត់ ខាងលិចជាប់នឹងភូមិអង្គជ្រូក( ឃុំកំពែង ) និងខាងជើងជាប់នឹងភូមិសមរលាវ។ ជាថ្មីម្តងទៀត ភូមិសមរខ្មែរ ជាទីសមរភូមិរបស់ខ្មែរ និងភូមិសមរចិន ជាទីសមរភូមិរបស់ចិន រីឯភូមិសមរលាវ ជាសមរភូមិរបស់លាវ។ ភូមិទាំងបីនេះ (សមរលាវ សមរខ្មែរ និងសមរចិន )មានទីតាំងព្រំប្រទល់ជាប់គ្នាស្ថិតនៅក្នុងឃុំពោធិរំចាក ស្រុកព្រៃកប្បាស ខេត្តតាកែវ។ ភូមិសមរខ្មែរមានផ្ទៃដីទាំងអស់៩៥,៣៥ហិកតា។ លោកមេភូមិបានឲ្យដឹងថា ភូមិសមរខ្មែរមានប្រជារាស្ត្រក្នុងមានចំនួន១៩៦គ្រួសារ សរុបស្មើនឹង៨៥៥នាក់ ប្រុស៤១៥នាក់ ស្រី៤៤០នាក់ ក្នុងនោះមនុស្សចាស់ចាប់ពីអាយុ៦០ឆ្នាំឡើងមានចំនួន១០១នាក់ ប្រុស៣៦នាក់ ស្រី៦៥នាក់ គិតជាភាគរយស្មើនឹង៦៤,៣៥%។ ដោយឡែក ក្មេងៗអាយុក្រោម១៨ឆ្នាំមាន២៨៦នាក់ ប្រុស១៥៤នាក់ ស្រី១៣២នាក់ សុទ្ធតែស្ថិតនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សាទាំងអស់ លើកលែងតែកុមារតូចៗត្រឹមអាយុ៥ឆ្នាំចុះស្ថិតនៅក្នុងបន្ទុកអាណាព្យាបាល និងឪពុកម្តាយមានចំនួន១១១នាក់ ប្រុស

៦៣នាក់ ស្រី៤៨នាក់[169]។ ចំពោះជីវភាពរស់នៅរបស់ប្រជាពស្ត្រភូមិសមរខ្មែរ មិនខុសពីជីវភាពរស់នៅពីអ្នកភូមិសមរលាវទេ។

ក-សាលាបឋមសិក្សាសមរខ្មែរ

ភូមិសមរខ្មែរមានសាលាបឋមសិក្សាមួយមានបីអគារ។ បច្ចុប្បន្ន មានសិស្ស២៥៨នាក់ចំនួន១៣២ស្រី[170]។ សាលារៀននេះមានតួនាទីសំខាន់ណាស់ក្នុងការអប់រំបណ្តុះបណ្តាលកូនចៅប្រជាពលរដ្ឋដែលមានអាយុត្រូវចូលរៀនប្រវត្តិសាលាបានប្តូរឈ្មោះទៅជាសាលាបឋមសិក្សាមេត្រី និងចុងក្រោយសាលានេះត្រូវបានផ្លាស់ប្តូរទៅជាសាលាបឋមសិក្សាតាកាហាស៊ីសមរមេត្រីនៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០០៤។ សាលាបឋមសិក្សាតាកាហាស៊ីសមរមេត្រីមានផ្ទៃដី១៣០៤០ម២។ សាលារៀននេះស្ថិតនៅ ភូមិសមរខ្មែរ ឃុំពោធិ៍រំចាក ស្រុកព្រៃកប្បាស ខេត្តតាកែវ។ សិស្សានុសិស្សដែលចូលរៀនសាលានេះមកពីភូមិសមរខ្មែរ សមរចិន[171] សមរខ្មែរ ភូមិអង្គជ្រូក ភូមិថ្នល់បត់ និងភូមិអូរខាងលិច(ភូមិអណ្តូង)។

ប្រជាពលរដ្ឋសរុបមកពីភូមិទាំងបី(ភូមិសមរខ្មែរ អង្គជ្រូក និងថ្នល់បត់) មាន១៨០២នាក់ ស្រី៩១៧នាក់(២០១៤-២០១៥) សិស្សសរុប២៥៨នាក់ ស្រី ១៣២នាក់ គ្រូសរុប៦នាក់ ស្រី៣នាក់។ តាមឯកសារសរសេរ

---

169 ប្រភពព័ត៌មានពីលោក ស្រី ហ៊ត ប្រធានភូមិសមរខ្មែរ ឆ្នាំ២០១៥

170 ប្រភពព័ត៌មានពីលោក ឡាច ស្រ៊ុ នាយកសាលាបឋមសិក្សាហាតាកាស៊ី ឆ្នាំ២០១៥

171 ភូមិនេះសព្វថ្ងៃក្រសួងមហាផ្ទៃមិនបានចាត់បញ្ចូលជាភូមិរដ្ឋបាលមូលដ្ឋានទៀតទេ គឺគេបញ្ចូលជាមួយភូមិសមរខ្មែរតែមួយវិញ។

ជាប់នឹងសាបរបស់សាលាថា សាលារៀនសមរមេត្រីផ្តើមកសាងឡើងតាំងពីឆ្នាំ១៩៥៤។

តាមលោក ឈា ងួន ជាអតីតសិស្សសាលានេះបានផ្តល់សេចក្តីពន្យល់ដូចខាងក្រោមទាក់ទងនឹងប្រព័ន្ធអប់រំនៅសម័យបារាំង និងសង្គមរាស្ត្រនិយមដូចខាងក្រោម៖

| ល.រ | ឈ្មោះ | | សង្គមចាស់ (មុនឆ្នាំ ១៩៧០) | បច្ចុប្បន្ន |
|---|---|---|---|---|
| ១ | កុមារដ្ឋាន | Enfantain | ថ្នាក់ទី១២ | ថ្នាក់ទី១ |
| ២ | បរិវេចនដ្ឋាន | Cours Elémentaire | ថ្នាក់ទី១១ | ថ្នាក់ទី២ |
| ៣ | អាទិកដ្ឋាន | Cours Complémentaire | ថ្នាក់ទី១០ | ថ្នាក់ទី៣ |
| ៤ | មជ្ឈឹមដ្ឋានទី១ | Cours Moyen 1 | ថ្នាក់ទី៩ | ថ្នាក់ទី៤ |
| ៥ | មជ្ឈឹមដ្ឋានទី២ | Cours Moyen 2 | ថ្នាក់ទី៨ | ថ្នាក់ទី៥ |
| ៦ | ឧត្តមដ្ឋាន | Cours Supérieur | ថ្នាក់ទី៧ | ថ្នាក់ទី៦ (បញ្ចប់ថ្នាក់បឋមសិក្សា) |

ឧត្តមដ្ឋាន(ជាថ្នាក់ទី៧ពីសង្គមស្មើនឹងថ្នាក់ទី៦បច្ចុប្បន្នជាថ្នាក់សិស្សត្រូវប្រឡងបញ្ចប់ថ្នាក់បឋមសិក្សាឆ្លងចូលអនុវិទ្យាល័យ)[172]។ លោកបញ្ជាក់ថា ប្រហែលជាបង្កើតឡើងនៅឆ្នាំ១៩៤៨-១៩៤៩ ហើយមានអគារ១ខ្នង ៤ បន្ទប់ធ្វើពីបេតុង ប្រក់ស័ង្កសី (ដំបូលបែបអាមេរិកកាំង)។

ទាក់ទងនឹងបញ្ហានេះ លោក ហាស់ គ្រេង ជាសមាជិកគណៈកម្មការវត្តសមរមេត្រីម្នាក់ដែរនោះបានមានប្រសាសន៍ថា មុននឹងកើតបានសាលាដែលមានដំបូលបែបអាមេរិកាំងនេះ អគារមួយខ្នងទៀតមានជញ្ជាំងរៀបឥដ្ឋកម្ពស់មួយម៉ែត្របន្តបិទបាំងដោយជញ្ជាំងស្លឹកប្រក់ក្បឿងស្ថិតខាងត្បូងព្រះវិហារសព្វថ្ងៃ។ លោក ឈា ងួនក៏បានឲ្យដឹងបន្ថែមទៀតថា ក្នុងបរិវេណវត្តនិងសាលានេះមានដើមគគីរ ដើមឈើទាលធំៗខ្ពស់ៗ ហើយមានសត្វស្លាបជាច្រើនយកធ្វើជាជម្រកដូចជា សត្វរនាល ស្មោញ ក្រសា ។ល។ ចំពោះនាយកនៃសាលាបឋមសិក្សានេះរួមមាន៖

១-លោកគ្រូ តុប សេងហាក់ (ស៊)នាយកសាលាទី១

២-លោកគ្រូ លឹម សុវណ្ណ នាយកសាលាទី២(អតីតស្វាមីរបស់អ្នកស្រី ហម រស់នៅភូមិអូរ)

៣-លោក ឯម ហម នាយកសាលាទី៣។ ប៉ុន្តែលោកកាន់ការបានតែមួយឆ្នាំសាលានេះក៏រំលាយចោល ហើយសិស្សានុសិស្សត្រូវផ្លាស់មករៀននៅសាលាបឋមសិក្សាសមរលោវិញ។

[172] ប្រភពព័ត៌មាន៖ លោក ឈា ងួន អតីតសិស្សសាលាបឋមសិក្សាសមរមេត្រី ឆ្នាំ២០១៨

៤-លោក អ៊ុម គួយ នាយកសាលាទី៤ ពី១៩៧៩- ២០០៩

៥-លោក ឡាច ស្រ៊ី នាយកសាលាទី៥ ពី២០០៩

- បច្ចុប្បន្នតាមការស្រាវជ្រាវ អ្នករៀននៅសាលាបឋមសិក្សាសមមេត្រីនេះតាំងពីសង្គមចាស់[173]រហូតមកដល់សម័យក្រោយៗមកមានតែលោក ឈា អេង (ហៅងឹម) ដែលរៀនបានខ្ពង់ខ្ពស់រហូតជាប់ក្លាយជាវេជ្ជបណ្ឌិតផ្នែកចក្ខុធ្វើការនៅមន្ទីរពេទ្យព្រះអង្គឌួង និងម្នាក់ទៀតឈ្មោះ អ៊ុំ វិចិត្រ ជាមន្ត្រីជាន់ខ្ពស់បម្រើការនៅក្រសួង សុខាភិបាល និងបង្រៀននៅសាលាភូមិន្ទរដ្ឋបាល។

ឆ្នាំ១៩៧០ដល់១៩៧៩របបលន់ នល់ និងខ្មែរក្រហមសាលាត្រូវបិទទ្វារ។ ឆ្នាំ១៩៧៩ដល់២០០២ សាលារៀនទីតាំងក្នុងវត្ត អគារសិក្សា៣ខ្នងទ្រុឌទ្រោម។ ខែមករា ឆ្នាំ២០០៣ លោក សេង ប៊ុនធឿន នាយកខុទ្ទកាល័យក្រសួងអភិវឌ្ឍន៍ជនបទបានធ្វើទំនាក់ទំនងជាមួយក្រសួងអប់រំ យុវជន និងកីឡា បានសង់សាលារៀនមួយខ្នង៤បន្ទប់ និងបង្គន់៤បន្ទប់ ចាប់ពីពេលនោះហើយ ដែលសាលាត្រូវបានប្តូរទីតាំងពីក្នុងវត្តមកកន្លែងសព្វថ្ងៃនេះ។ កាលនោះលោក ឡាច ស្រ៊ី នាយករង ដែលមានលោក អ៊ុម គួយ ជានាយកសាលាបានសហការជាមួយលោក សេង ប៊ុនធឿន ជានាយកខុទ្ទកាល័យនៃក្រសួងអភិវឌ្ឍន៍ជនបទ និងជាជំនួយការឯកឧត្តមបណ្ឌិត កុល ផេង ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ឲ្យជួយពន្លឿនរឿងនេះ

[173] សំដៅដល់សង្គមរាស្ត្រនិយមរបស់សម្តេចព្រះនរោត្តម សីហនុ ១៩៥៥ ដល់១៩៧០។

ទទួលបានជោគជ័យក្រោយរយៈពេលតែពីរសប្តាហ៍ប៉ុណ្ណោះបន្ទាប់ពីមន្ទីរ អប់រំ យុវជន និងកីឡា ខេត្តចុះហត្ថលេខាលើពាក្យសុំសាងសង់សាលារៀន។

ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៣ សាលារៀនបានចាប់ដំណើរការសាងសង់។ នៅឆ្នាំនេះដដែលលោកវេជ្ជបណ្ឌិត នួន សុផាត បច្ចុប្បន្នជាប្រធានពេទ្យបង្អែកស្រុកព្រៃកប្បាស ខេត្តតាកែវ បានទំនាក់ទំនងជាមួយសមាគមតាកាហាស៊ីរ៉ូតារីក្លឹប និងសមាគមស្ទូរ៉ូបទីមីស្តអន្តរជាតិ ជប៉ុនដើម្បីសង់អគារ១ខ្នងទៀតមាន៥បន្ទប់ បង្គន់អនាម័យ៤បន្ទប់ ក្លោងទ្វារ និងរបងសាលាខាងមុខ ដោយធ្វើពិធីបញ្ចុះបឋមសីលានៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៣ និងបញ្ចប់ការសាងសង់នៅខែសីហា ឆ្នាំ២០០៤ និងសម្ពោធដាក់ប្រើប្រាស់ជាផ្លូវការក្រោមអធិប- តីភាពរបស់លោក ពេជ្រ សាខន អតីតអភិបាលស្រុកព្រៃកប្បាស។

នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៤ សុំដាក់សុំប្តូរឈ្មោះសាលារៀនពីសាលាបឋមសិក្សាសមរមេត្រីមកជាសាលាបឋមសិក្សាតាកាហាស៊ីសមរមេត្រីទៅឯកឧត្តមបណ្ឌិតកុល ផេង ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួង អប់រំ យុវជន និងកីឡា។

នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ ២០០៤ ធ្វើពិធីសម្ពោធអគារសិក្សាទាំងពីរខ្នងក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត កុល ផេង ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងតំណាងទូតជប៉ុនដោយលោកតាកាហាស៊ី។

នៅឆ្នាំ២០០៥ ជប៉ុនបានជួយ ម៉ាស៊ីនបូមទឹក១គ្រឿង ធ្វើបងលួស បន្ថែម ធ្វើបង្គោលទៀងខ្សែពួរ និងសម្ភារៈសិក្សាដល់សិស្ស។

ឆ្នាំ២០០៦ ជប៉ុនបានផ្តល់សាឡុងឈើ១សម្រាប់ដាក់ក្នុងទីចាត់ការ បង់ថ្ម១០ដាក់ក្រោមដើមឈើ ម៉ាស៊ីនភ្លើង១គ្រឿង ម៉ាស៊ីហ្វូតូកូបពី១គ្រឿង។

ឆ្នាំ២០០៧សមាគមស្ម៉ូទីមីស្តអន្តរជាតិជប៉ុនបានសង់អគារសិក្សា១ ខ្នង២បន្ទប់សម្រាប់មត្តេយ្យសិក្សាថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ ពិធីសម្ពោធ អគារនេះក្រោមអធិបតីភាពលោក ពូ វណ្ណថន អភិបាល ស្រុក ព្រៃកប្បាស និងលោកស្រីអ៊ីកេដា ជាប្រធានសមាគម។

ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ជប៉ុនបានកសាងសួនច្បារអនុស្សាវរីយ៍ អ៊ីកេដា និងអាងច្រោះទឹកស្អាតជូនសាលាប្រើប្រាស់។

ឆ្នាំ២០០៨ ពិធីសម្ពោធឲ្យប្រើប្រាស់ក្រោមអធិបតីភាពលោក ស្រី បេន អភិបាលខេត្តតាកែវ លោក ម៉ី ស៊ន អភិបាលស្រុកព្រៃកប្បាស មន្ត្រីស្ថានទូតជប៉ុន និងប្រតិភូជប៉ុន។

ថ្ងៃទី២៤ ខែកញ្ញាឆ្នាំ២០០៩ លោក អ៊ុម គួយ ផ្ទេរការងារនាយកជូន លោក ឡាច ស្រ៊ី បណ្តោះអាសន្ន រង់ចាំការស្នើសុំ និងតែងតាំងជានាយកផ្លូវការដោយលោកចូលនិវត្តន៍នាខែមករា ឆ្នាំ២០១០ ប៉ុន្តែជាអកុសល លោក បានទទួលមរណភាពនៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៩។ ការិយាល័យអប់រំស្រុក ព្រៃកប្បាសក៏ប្រញាប់ប្រញាល់រៀបចំការបោះឆ្នោតជ្រើសរើសនាយកសាលា សាថ្មី។ ដោយមានការគាំទ្រជាពិសេសពីសហគមន៍លោក ឡាច ស្រ៊ី ជា

នាយករងទទួលបានសំឡេងគាំទ្រច្រើនក្នុងការបោះឆ្នោតនាថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១០ និងត្រូវតែងតាំងជាផ្លូវការនៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១០ដោយការិយាល័យ អប់រំ យុវជន និងកីឡាស្រុកព្រែកប្បាស។

-ថ្ងៃទី៣១ ខែសីហា ២០១០ ដល់ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ លោក ឡាច ស្រ៊ី នាយកសាលាត្រូវបានសមាគមជប៉ុនឲ្យទៅធ្វើទស្សនកិច្ចនៅស្រុកតាកាហាស៊ី(ប្រទេសជប៉ុន)។

-ឆ្នាំ២០១១ ជប៉ុនជួយតុវាយប៉េងប៉ុង និងបង់ថ្ម២ឈុត សម្រាប់សិស្សានុសិស្ស។

-ឆ្នាំ២០១២សមាគមតាកាហាស៊ីរ៉ូតារីក្លឹបឧបត្ថម្ភម៉ាស៊ីនព្រីធ័រ១គ្រឿង កុំព្យូទ័រ១គ្រឿង និងសៀវភៅរឿងខ្លីដាក់ក្នុងបណ្ណាល័យ។

-ថ្ងៃទី៥ ខែកុម្ភៈឆ្នាំ២០១៣ លោកបណ្ឌិត សេង ប៊ុនធឿន សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យជាតិគ្រប់គ្រងបានរៀបចំ និងចាក់ដីបំពេញទីលានបាល់ទាត់ និងទីលានបាល់ទះក្នុងបរិវេណសាលា។

-ថ្ងៃទី២៥ ខែឧសភា ២០១៣ លោកបណ្ឌិត សេង ប៊ុនធឿន សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យជាតិគ្រប់គ្រងបានដឹកនាំនិស្សិតសាកលវិទ្យាល័យជាតិគ្រប់គ្រងប្រមាណ៧០នាក់មកដាំកូនឈើចំនួន១៩៤ដើម (កូនគគីរ ឈើទាល បេង លឿងរាជ និងនាងនួន)ក្នុងបរិវេណសាលា។

-ខែធ្នូ ឆ្នាំ២០១៣ ជប៉ុន បានចាក់ដីបន្ថែមលើទីលានបាល់ទាត់ឲ្យខ្ពស់ផុតពីផ្ទៃទឹក។

-ខែមករា ឆ្នាំ២០១៤ លោកបណ្ឌិត សេង ប៊ុនធឿនសាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យជាតិគ្រប់គ្រងបានធ្វើអំណោយសម្លៀកបំពាក់កីឡាចំនួន១៣កំប្លេសម្រាប់ទៅប្រកួតជម្រើសជើងឯកបាល់ទាត់កុមារីថ្នាក់ខេត្ត។

-ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៤ ជប៉ុនមកសម្ពោធទីលានបាល់ទាត់ក្រោមអធិបតីភាពលោក កាតអូកា ប្រធានសមាគមតាកាហាស៊ីរ៉ូតារីក្លឹប និងនាំសិស្សទាត់បាល់។

-ខែតុលា ឆ្នាំ២០១៤ គ្រូ សៅ ឈឿង ជួយទូរ១សម្រាប់ដាក់សៀវភៅក្នុងបណ្ណាល័យ។

-ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៤ លោកបណ្ឌិត សេង ប៊ុនធឿន សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យជាតិគ្រប់គ្រងបាននាំលោកគ្រូអ្នកគ្រូនិងសិស្សានុសិស្ស១២០នាក់ទៅធ្វើទស្សនកិច្ចសិក្សានៅព្រះបរមរាជវាំងព្រះវិហារព្រះកែវមរកត និងសារមន្ទីរជាតិកម្ពុជា។

-ថ្ងៃទី២៤ខែកញ្ញា ឆ្នាំ២០១៧ លោកបណ្ឌិត សេង ប៊ុនធឿន សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យ ជាតិគ្រប់គ្រង លោកស្រី ហែម ពេជ្របញ្ញា ព្រមទាំងបុត្របានកសាងព្រះរូប ព្រះបាទ ជ័យវរ្ម័នទី៧ តម្កល់ទុកក្នុងទីធ្លាសាលារៀននេះជាសម្បត្តិវប្បធម៌ និងសាធារណៈ។

**ខ.វត្តសមរខ្មែរ ឬសមរមេត្រី**

លោក សៅ ឈឿង[174] បានស្រាវជ្រាវប្រវត្តិនេះតាមរយៈលោកតា ទិត

[174] កើតនៅភូមិសមរខ្មែរ ឃុំ ពោធិ៍រំចាក ស្រុកព្រៃកប្បាស ខេត្តតាកែវ។

ម៉ាន ដែលរស់នៅភូមិសមរខ្មែរ ឃុំពោធិ៍រំចាក ស្រុកព្រៃកប្បាស ខេត្តតាកែវ បានឲ្យដឹងថា វត្តសមរខ្មែរ ឬមេត្រីកកើតតាំងពីឆ្នាំ១៨៤៣មកម្ល៉េះ។ ប៉ុន្តែ តាមលោក ប៉ុន មោក សមាជិកគណៈកម្មការវត្តសមរខ្មែរ ឬមេត្រីបានមាន ប្រសាសន៍ថា វត្តនេះបានកកើតឡើងតាំងពីឆ្នាំ១៨៤៦ទៅវិញ។ ហើយមាន ព្រះចៅអធិការវត្ត ចំនួន៨អង្គរួចមកហើយ៖

-ព្រះចៅអធិការទី១ ព្រះនាម លោកតា ឌុច។

-តាមលោក សៅឈឿងកាលពីឆ្នាំ១៨៤៣ កន្លែងនេះ ជាទីទួលខ្ពស់ មានដើមស្រម៉ដុះនៅទីទួលនោះ និងក៏ជាទីតាំងនៃសមរភូមិរបស់ខ្មែរផង។ ក្រោយមកលោកឌុចបានបួសជាភិក្ខុ។ ព្រះសង្ឃនេះបានកសាងអាស្រម តូច មួយសម្រាប់ស្នាក់នៅធ្វើធម៌វិបស្សនាកម្មដ្ឋាន និងបង្សុកូលដល់ សពយុទ្ធជន ខ្មែរដែលពលីក្នុងសម័យសង្គ្រាមខ្មែរជាមួយលាវ។ លោកតាឌុច បានគង់នៅ អាស្រម នេះអស់រយៈពេលបីឆ្នាំលោកតាក៏បានលាកចាកសិក្ខាបទ ហើយ រៀបការភរិយាទៅ។

-ព្រះចៅអធិការទី២ ព្រះនាមលោកតា ឡុញ។ ព្រះអង្គក៏បន្តគង់នៅ ក្នុងអាស្រមនេះជាបន្ត មកទៀត។ ព្រះតេជគុណអង្គនេះ ក៏បានផ្តួចផ្តើមគិត គូរជាមួយពុទ្ធបរិស័ទក្នុងភូមិ និងភូមិជិតខាងកែប្រែអាស្រមនេះទៅជា វត្ត មានឈ្មោះថា វត្តសមរខ្មែរ តាំងពីឆ្នាំ១៨៤៦ រហូតមក។ នៅក្នុងពេលនោះ ដែរ មានមន្ត្រីរាជការម្នាក់ជួយខ្នះខ្នែង ឧបត្ថម្ភគាំទ្រកសាងកុដិមួយ និងព្រះ វិហារមួយសម្រាប់ព្រះសង្ឃគង់នៅវត្តសមរខ្មែរ និងទីតាំងសមរភូមិប្រយុទ្ធ

របស់ខ្មែរផង។

-ព្រះចៅអធិការទី៣ ព្រះនាមលោកតា សាន់ ពីឆ្នាំ១៨៦៩ ដល់ឆ្នាំ ១៨៩១។

-ព្រះចៅអធិការទី៤ ព្រះនាមលោកតា ប៉ា ពីឆ្នាំ១៨៦៩ ដល់ឆ្នាំ ១៩១៣។

-ព្រះចៅអធិការទី៥ ព្រះនាមលោកតា ទេព ឌី ពីឆ្នាំ១៩១៣ ដល់ឆ្នាំ ១៩៥៦។ ព្រះចៅ អធិការអង្គនេះ បានកសាងសាលាធម្មសភាធំមួយ កសាង សាលាបឋមសិក្សាមួយខ្នង ហើយស្នើសុំគ្រូបង្រៀនបានគ្រប់ចំនួន ទើបកែ ប្រែឈ្មោះពីវត្តសមរខ្មែរទៅជាវត្តសមរមេត្រីវិញ។ ប៉ុន្តែឈ្មោះភូមិសមរខ្មែរត្រូវ បានរក្សាដដែលរហូតមក។ លោក សៅ ឈឿង បានបញ្ជាក់ទៀតថា លុះដល់ ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ប្រទេសខ្មែរកើតសង្គ្រាមដោយសាររដ្ឋប្រហារ របស់លោកសេនាប្រមុខ លន់ នល់ ទម្លាក់សម្តេចព្រះនរោត្តម សីហនុ ព្រះវរ រាជបិតាជាតិខ្មែរ ព្រះបរមរតនកោដ្ឋពីរាជបល្ល័ង្កស្ថានភាពវត្តសមរមេត្រីគ្មាន អ្វីប្រែប្រួលទេ គឺនៅដដែល។ ទោះបីយ៉ាងណា ទឹកចិត្តប្រជារាស្ត្រខ្មែរពេល នោះមានការរំជើបរំជួលណាស់។ រហូតដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ របបសាធារណរដ្ឋខ្មែររបស់លោក លន់ នល់ ត្រូវបានផ្តួលរំលំទៅវិញដោយ របប ប៉ុល ពត។ ប្រជារាស្ត្រក្នុងភូមិស្រុកនេះសង្ឃឹមថា នឹងបានឃើញព្រះ វត្តមានសម្តេចព្រះនរោត្តមសីហនុ វិញហើយពីព្រោះពួកនេះឃោសនាថា គេ បានរំដោះស្រុកពី លន់ នល់ យកទៅ ថ្វាយសម្តេចឪ។មិនដូចការសង្ឃឹមទេ

ពួកគេបានប្រែក្លាយទីវត្តទាំងមូលឲ្យក្លាយទៅជាសហករណ៍[175]។

នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ប្រទេសកម្ពុជាត្រូវរំដោះចេញពីរបបឃាតករអាវខ្មៅដែលគ្រាន់តែរយៈពេល០៣ឆ្នាំ៨ខែ និងម្ភៃថ្ងៃប៉ុណ្ណោះ របបនេះធ្វើឲ្យមនុស្សស្លាប់អស់ប្រមាណជា១លាន៧សែននាក់[176]។

-ព្រះចៅអធិការទី៦ ព្រះនាមលោកតា ភ ឌុក[177] ពីឆ្នាំ១៩៨៣ ដល់ឆ្នាំ១៩៨៦ ព្រះអង្គបានកសាងព្រះវិហារមួយសង់ពីឈើប្រក់ក្បឿង។ -ព្រះចៅអធិការទី៧ ព្រះនាមលោកតា ស្រី ព្រុំ ពីឆ្នាំ១៩៨៧ រហូតដល់ឆ្នាំ២០១៦។ ព្រះអង្គបានកសាងកុដិថ្មមួយ និងរុះរើព្រះវិហារសង់ពីឈើប្រក់ក្បឿងចេញ ហើយសាងសង់ជំនួសវិញនូវព្រះវិហារសង់ពីថ្មថ្មីមួយឡើងរួចជាស្ថាពរ។ -ព្រះចៅអធិការទី៨ ព្រះតេជគុណ អឿន វិចិត្រ ពីខែមិថុនា ឆ្នាំ២០១៦ រហូតមកសព្វថ្ងៃ។ តាមលោកអាចារ្យ ប៉ុន មោក វត្តនេះមានទីតាំងស្ថិតនៅប៉ែកនីរតីនៃសាលាស្រុកព្រៃកប្បាស។ ប្រសិនបើគិតពីផ្សារព្រៃល្វា( សាលាស្រុកព្រៃកប្បាស )រហូតមកដល់ទីវត្តមានចម្ងាយប្រមាណជា៩គីឡូម៉ែត្រ។ វត្តនេះ

---

[175] សម័យនោះ ពាក្យ សហករណ៍ ត្រូវបានគេស្គាល់ថា ជាកន្លែងធ្វើបាយ រួមរបស់ប្រជាជន។ ហើយវត្តសមរមេត្រី ក៏ដូចជាវត្តសមរលោរ និងវត្តនានាក្នុងប្រទេសកម្ពុជាដែរ សុទ្ធតែត្រូវបានប្រែក្លាយជា សហករណ៍ ទាំងអស់។ លើសពីនេះ ជាកន្លែងច្បារដំណាំ ជាកន្លែងធ្វើជីធម្មជាតិ ជាផ្ទះកម្មាភិបាលរបស់អង្គការខ្មែរក្រហម ជាកន្លែងធ្វើទារុណកម្ម ឬជាកន្លែងធ្វើឃាតមនុស្សតែម្តង។ល។

[176] អ្នកខ្លះនិយាយថា ប្រជាជនខ្មែរបានស្លាប់ក្នុងរបបខ្មែរក្រហមមានចំនួនជាបីលាន ប្រាំបីសែននាក់។

[177] ព្រះអង្គបានចូលព្រះទិវង្គតនៅថ្ងៃ ត្រូវនឹងថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១២

មានផ្ទៃដីសរុបចំនួន៤.១៣ហិកតា ក្នុងនោះដីសម្រាប់សាលារៀនចំនួន ១.២០ហិកតា និងស្រះទឹកមួយមានទំហំ០.៦៥ហិកតា។ លោកតាអាចារ្យ បានតំណាលថា លោកតា ឌុច បានបង្កើតទីវត្តនេះនៅលើទីទួលមួយកន្លែង មានដើមស្រម៉ធំមួយ។ ដំបូងបង្អស់គ្រាន់តែជាទីអាស្រមវិបស្សនាកម្មដ្ឋាន ត្បិតជាទីដែល ស្ងប់ស្ងាត់ល្អ។ បន្ទាប់ពីព្រះអង្គ ឌុច បានលាចាកសិក្ខាបទការ ថៃទាំអាស្រមនេះធ្លាក់លើព្រះតេជគុណមួយអង្គព្រះនាម ឡុញ ហើយបាន ប្រែក្លាយទីនេះ ទៅជាវត្ត ដោយមានមន្ត្រីរាជការម្នាក់ជាអ្នកខ្នះខ្នែងជួយ ជ្រោមជ្រែងកសាងបានកុដិមួយខ្នង ព្រះវិហារមួយតូចល្មម។ ដើម្បីជាការតប ស្នងគុណបំណាច់ចំពោះមន្ត្រីរាជការរូបនោះ ទាំងព្រះសង្ឃ និងគ្រហស្ថ ក៏ បាននាំគ្នាដាក់ឈ្មោះវត្តថ្មីនោះថា វត្តសម៉មន្ត្រី។ ចំណេរតមកដោយការសរ សេរមិនច្បាស់លាស់ ក៏ដូចធ្វើឲ្យស៊ីចង្វាក់គ្នានឹងឈ្មោះភូមិសមរខ្មែរដែល ជាសមរភូមិផងដែរ វត្តនេះក៏ត្រូវបានប្រែក្លាយថា វត្តសមរមេត្រីរហូតដល់សព្វ ថ្ងៃនេះ។ ទោះបីយ៉ាងណា**មេត្រី**មានន័យស្រឡាញ់ ស្នេហាប្រតិព័ទ្ធ[178]។

## គ-ប្រវត្តិអាចារ្យ និងគណៈកម្មការវត្ត

### គ-១-ពីឆ្នាំ១៩៥៥ ដល់ឆ្នាំ១៩៧០

**១**-លោកអាចារ្យ ឯក ឈឹម

២-គណៈកម្មការ ឆែម សួន

៣-គណៈកម្មការ ង៉ុយ ឌឹម

---

178 ក្រសួងអប់រំ យុវជន និងកីឡា៖ ភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣ ទំព័រ៣

**គ-២-ពីឆ្នាំ១៩៨៣ ដល់ឆ្នាំ១៩៩០**

១-លោកអាចារ្យ មឿង ជុំ

២-លោកអាចារ្យ សែម

៣-លោកអាចារ្យ ចន

៤-គណៈកម្មការ មឿង ទូច

៥-កុង សុខ ដឺ

៦-កុង មឿង ទួន

៧-កុង អ៊ូ ណាយ

៨-កុង គាំ ម៉ៅ

**គ-៣-ពីឆ្នាំ១៩៩០ ដល់ឆ្នាំ១៩៩៦**

១-លោកអាចារ្យ ទូច ស៊ាង

២-កុង ប៊ុន ម៉ោក

៣-កុង គួន សយ

៤-គណៈកម្មការកុង ស៊ុយ ណោង

៥-កុង ឈឹម ឡៃ

៦-កុង អ៊ូ ណាយ

**គ-៤-ពីឆ្នាំ១៩៩៦ ដល់ឆ្នាំ២០១៩**

១-លោកអាចារ្យកុង ប៊ុន ម៉ោក

២-កុង គួន សយ

៣-កុង ខៀវ ថាក់

៤-គណៈកម្មការកុង សៅ យ៉ន

៥-កុង ស៊ុយ គិន

៦-កុង ហាស់ ក្រេង

៧-កុង ស្រី ហ៊ិត

៨-កុង ឈឹម សម្បត្តិ

៩-កុង ថោង ណោង

១០-កុង អន ធឿន

**គ-៥-ពីឆ្នាំ២០១៩ ដល់បច្ចុប្បន្ន**

១-លោកអាចារ្យកុង សាយ ឡឿន

២-កុង ប៉ុន ម៉ោក កុង គួន សយ

៣-កុង ខៀវ ថាក់

៤-គណៈកម្មការកុង ស៊ុយ គិន

៥-កុង សៅ យ៉ន

៦-កុង ហាស់ ក្រេង

៧-កុង ស្រី ហ៊ិត

៨-កុង ឈឹម សម្បត្តិ

៩-កុង មុំ មឿន។

**ឃ.សាលាធម្មសភា**

សាលាធម្មសភាវត្តសមរមេត្រីត្រូវបានកសាងឡើងក្នុងអំឡុងពេលនៃព្រះចៅអធិការទី៤ព្រះតេជគុណ ប៉ា ពីឆ្នាំ១៨៦៩ ដល់ឆ្នាំ១៩១៣ មានផ្ទៃក្រឡា៨៤០ម៉ែត្រការ៉េក្នុងនោះបណ្តោយមាន៣០ម៉ែត្រ និងទទឹងមាន២៨ម៉ែត្រ។ លោក ឡាច ស្រ៊ី នាយកសាលាបឋមសិក្សាហាតាកាស៊ីសមរមេត្រីបានឲ្យដឹងថាដំបូងឡើយសាលាធម្មសភាកសាងឡើងដែលមានដំបូលប៉ិតចំនួន៩ខ្នង ។លោកបន្តទៀតថាលោកតាមឿង ជុំ( កុងជុំ ) រស់នៅភូមិថ្នល់បត់ដែលជាអាចារ្យវេលាការដ៏ល្បីប្រចាំតំបន់នេះបានមានប្រសាសន៍ប្រាប់លោកកាលពីលោកនៅមានជន្មាយុនៅឡើយ កាលនោះលោកតាមានអាយុបាន១២ឆ្នាំឃើញសាលាធម្មសភានេះកើតឡើងរួចហើយ ៗមានដំបូលប៉ិតដល់ទៅ៩ឯណោះដោយធ្វើពីឈើប្រក់ក្បឿង។ តាមលោក ឡាច ស្រ៊ី បានមានបន្ថែមថាមកដល់សព្វថ្ងៃនេះសាលាធម្មសភាមានអាយុជាងមួយសតវត្សហើយ។ ជណ្តើរឡើងខាងមុខកសាងនៅឆ្នាំ១៩៦៦ ដោយលោក គង់ ស៊ុន លោកមានទីលំនៅភូមិឫស្សីថ្មី ឃុំចំប៉ា លោកជាបិតារបស់លោកយាយ គង់ ជាន[179]នៅភូមិឫស្សីថ្មី។ រីឯជណ្តើរខាងក្រោយប៉ែកខាងជើង កសាងដោយលោក នេត្រ ប៊ិន ជាតំណាងរាស្ត្ររបស់សង្គមរាស្ត្រនិយមនៃសម្តេចព្រះបរមរតនកោដ្ឋនរោត្តម សីហនុ[180]។ តាំងពីដើមមកសាលាធម្មសភានេះមានជណ្តើរចុះតែ

---

[179] លោកយាយត្រូវជាភរិយារបស់កុង ស្រ៊ា ហើយជាបងប្អូនបង្កើតរបស់កុង គីម កុង ស្រូយ កុង មូល កុង មាន( ជាជីមាន )។ ជំនាន់នោះ ជី មានន័យថាជារាជការ..ឌីផែនទី។

[180] ព័ត៌មានបន្ថែមដោយលោកតាអាចារ្យ ប៊ុន មោក សមាជិកគណៈកម្មការអាចារ្យវត្តសមរមេត្រី។

មួយធំចំកណ្តាលប៉ុន្តែទើបតែក្រោមការដឹកនាំរបស់ព្រះតេជគុណ អឿងវិចិត្រ ទើបព្រះអង្គមានការរុះរើ កែឲ្យទៅជាមានជណ្តើរពីរវិញ បែរមកខាងមុខដូចគ្នាតែមានធ្វេង និងស្តាំ។

### ង-ព្រះវិហារ

តាមលោក ឡាច ស្រ៊ី ព្រះវិហារវត្តសមរមេត្រីត្រូវបានកសាងចំនួនបីលើកមកហើយគិតត្រឹមឆ្នាំ១០៧៩មក។ លើកទីមួយធ្វើពីឈើប្រក់ក្បឿងជញ្ជាំងក្តារ លើកទី២ធ្វើពីឈើប្រក់ក្បឿងជញ្ជាំងឥដ្ឋ និងលើកទី៣ ធ្វើពីថ្មដូចសព្វថ្ងៃ ហើយត្រូវបានធ្វើបុណ្យឆ្លងកាត់ឫសសីមាយ៉ាងអធឹកអធមក្រោមអធិបតីភាពឯកឧត្តមឧត្តមសេនីយ៍បណ្ឌិត **ហ៊ុន ម៉ាណែត** នាថ្ងៃអាទិត្យ ១០កើត ខែពិសាខ ឆ្នាំរោង ចត្វាស័ក ព.ស.២៥៥៦ ត្រូវនឹងថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១២។ គួររំលឹកថា ព្រះវិហារនេះមានអាយុប្រហាក់ប្រហែលនឹងសាលាធម្មសភាដែរ ប៉ុន្តែកាលនោះមានតែសសរ ដំបូល គ្មានជញ្ជាំងទេ។ ព្រះវិហារមានបណ្តោយមាន១៣ម៉ែត្រ និងទទឹងមាន៩.៨ម៉ែត្រ និងផ្ទៃក្រឡា១២៧.៤ម៉ែត្រការ៉េ។ ទាក់ទងនឹងសមិទ្ធផលថ្មី ដើម្បីសុវត្ថិភាពផង និងសោភ័ណភាពទីវត្តផងកាលពីថ្ងៃពុធ ៣កើត ខែភទ្របទ ឆ្នាំចសំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៨ ព្រះចៅអធិការទី៨ ព្រះតេជគុណ អឿន វិចិត្រ បានសម្រេចព្រះទ័យកសាងរបងជុំវិញបរិមាត្រវត្តទាំងមូលក្នុងមួយចន្លោះប្រវែង៣ម៉ែត្រកម្ពស់២កន្លះម៉ែត្រចំណាយទឹកប្រាក់អស់ ១,០០០,០០០រៀលប៉ុណ្ណោះសល់ប៉ុន្មាន ជាថវិកាវត្តទាំងអស់។

## ៦.២.ដើមកំណើតឈ្មោះភូមិសមរចិន

ភូមិនេះមានប្រវត្តិមិនខុសពីប្រវត្តិភូមិសមរលាវ និងភូមិសមរខ្មែរ ប៉ុន្មានទេ ប៉ុន្តែ បច្ចុប្បន្នឈ្មោះភូមិសមរចិនមិនមានឈ្មោះក្នុងរដ្ឋបាលនៃឃុំពោធិ៍រំចាកទេ។ ពោលគឺគេបញ្ចូលនៅក្នុងភូមិសមរខ្មែរតែម្តងទោះបីយ៉ាងនេះក្តីអ្នកស្រុកនៅតែស្គាល់។ ទាក់ទងនឹងព័ត៌មានដែលប្រមូលបាន ខ្ញុំមានសេចក្តីត្រេកអរណាស់ និងអរគុណជាអនេកចំពោះលោកគ្រូ សៅ ឈឿង ដែលលោកខិតខំនិទានប្រវត្តិរឿងរ៉ាវនៃភូមិទាំងបី ដែលលោកបានចងចាំពីការនិយាយតៗគ្នា ឬជាការតំណាលរបស់ចាស់ៗតាំងពីយូរយារមកហើយ។ នេះជាពន្លឺប្រវត្តិសាស្ត្រមួយដែលជួយឲ្យស្មេរអាចយកជាមូលដ្ឋានដើម្បីប្រៀបធៀបគ្នារវាងព័ត៌មាននានាទាក់ទងនឹងនៃភូមិខាងលើ។

តាមការពិត ទឹកដីទាំងអស់ជាទឹកដីរបស់ខ្មែរ ប៉ុន្តែនៅវេលាណាមួយនោះ អាចមានជនជាតិចិន និងលាវ មួយ ឬពីរគ្រួសារមករស់នៅលាយឡំគ្នានៅទីនេះដែរ។ អ្នកចំណូលថ្មី និងម្ចាស់ស្រុកមករស់នៅជាមួយគ្នាតែងតែជួបនូវភាពរកាំរកូសមានការរើសអើងគ្នាហើយក៏ក្លាយទៅជាមានជម្លោះនឹងគ្នាបន្តិចបន្តួច ជួនកាលក្លាយទៅជាជម្លោះធំរហូតបែងចែកភូមិ ចែកដី ចែកទីគ្នារស់នៅដើម្បីសេចក្តីសុខរៀងៗខ្លួន។ យើងដឹងហើយថា ទឹកដីនេះជាទឹកដីរបស់ខ្មែរ ចុះហេតុអ្វីក៏មានវត្តមានចិន និងលាវនេះមកពីណា? ជាទូទៅអ្នកចំណាកស្រុក(ចិនយួន ។ល។) ជាជនជាតិពូកែធ្វើចំណាកស្រុកដើររកស៊ីមិនសូវចេះខ្មាស់អៀន ធ្វើការមិនសូវខ្លាចហត់ មិនសូវរើសអើងមុខរបរធ្វើអ្វីៗ

ដើម្បីជីវិត ជាពិសេស ជនជាតិវៀតណាមចូលមករកស៊ី និងរស់នៅស្រុកខ្មែរ ឬជនជាតិខ្មែរយើងទៅរស់នៅស្រុកគេ(ប្រទេសបារាំង អាមេរិក អូស្ត្រាលី)អញ្ចឹងដែរ។ ធម្មតាអ្នកចំណូលថ្មីតែងតែខិតខំរកស៊ីជាងអ្នកស្រុកកំណើតតែងតែមានភ័យខ្លាចគេដេញត្រឡប់ទៅវិញ ឬប្រការផ្សេងៗ ពីព្រោះអ្នកចំណាកស្រុក ប្រសិនបើមិនខំរកនឹងដាច់ពោះស្លាប់ ឬមិនខំយកចិត្តយកថ្លើមអ្នកឲ្យរស់នៅដោយសុខស្រួលទេ ពួកគេអាចអស់ទីជម្រកដោយការផ្លាស់ចេញ ឬដេញឲ្យតរឡប់ទៅស្រុកកំណើតដើមវិញក៏ថាបាន។ រីឯអ្នកស្រុកកំណើតកើតជានៅទីនេះតែម្តងមិនសូវព្រួយបារម្ភអំពីការអត់អាហារហូប ឬបាត់បង់លំនៅដ្ឋានអ្វីទេ ត្បិតពួកគេមានដីធ្លីស្រាប់ហើយ។ សូមបញ្ជាក់ថា ភូមិសមរចិនមិនមានវត្តអារាមទេ ពីព្រោះភូមិនេះ មានទីតាំងជាប់នឹងភូមិសមរខ្មែរ ហើយប្រជាពលរដ្ឋមិនមានចំនួនច្រើននៅឡើយ។

## ៧-ជំនឿ សាសនា និងទំនៀមទម្លាប់ប្រពៃណី

ព្រះពុទ្ធសាសនា ជាសាសនាមួយដែលប្រជារាស្ត្រនៅទីនោះបានគោរព និងជឿជាក់យ៉ាងមុតមាំ។ តាំងពីដើមមក ប្រជារាស្ត្រស្ទើរតែ១០០% មានជំនឿលើព្រះពុទ្ធសាសនា។ ទើបតែសម័យដល់បច្ចុប្បន្ននេះ ប្រជារាស្ត្រអាចមានការកែប្រែចិត្តទៅជឿលើសាសនាផ្សេងៗមួយចំនួនតូចដោយកត្តាជីវភាពខ្វះខាត និងការពន្យល់ឃោសនាបញ្ចុះបញ្ចូលពីមជ្ឈដ្ឋានផ្សេងៗផង។ អ្នកភូមិទាំងបីជាពិសេសភូមិសមរចិន និងសមរលាវទំនៀមទម្លាប់

ប្រពៃណីចិនទោះបីមិនបានអនុវត្តពេញលេញយ៉ាងណាក៏ដោយ ក៏អ្នកស្រុកមិនបានបោះបង់ចោលដែរ។ ប្រជាពលរដ្ឋភូមិសមរលាវ ភូមិសមរចិន និងសមរខ្មែរភាគខ្លះ បានគោរពយ៉ាងខ្ជាប់ខ្ជួន និងប្រណិបតន៍ជារៀងរាល់ឆ្នាំថ្មីបើកិច្ចការជំនឿពីដូនតារបស់ខ្លួន។ ឧទាហរណ៍ នៅរដូវសែនលោកខែ ឬភ្ជុំចិន (អ្នកភ្នំពេញ)អ្នកភូមិទាំងនោះហៅខែសែនក្បាលទឹក រដូវចូលឆ្នាំចិនអ្នកភូមិទាំងនោះហៅថា សែនមាយ[181]។ គ្រប់រដូវកាលទាំងពីរខាងលើ អ្នកភូមិសមរលាវ សមរចិនទាំងអស់ និងសមរខ្មែរមួយចំនួនធំតែងតែសែនដូនតា វេចនំអន្សម នំគម ជាប្រចាំ។ កូនចៅអ្នកភូមិនោះ តែងតែហៅគ្នាជារបៀបកូនកាត់ចិន ថ្វីបើពួកគាត់មិនចេះភាសាចិនមួយម៉ាត់ ឬមិនដឹងដឹងច្បាស់ថាគាត់ជាចិនអម្បូរអ្វីក៏ដោយ ដូចជា ហៅថា កុង(តា)ប៉ា(ឪ/ពុក) ហ៊ា ចែ(បងប្រុស បងស្រី)ចឹក(មា/មនុស្សប្រុសប្អូនប៉ា)ទ្រាគូ ធំ អ៊ី គឹម ស៊ឹម អ៊ឹម កូវ(ប្អូនស្រីប៉ា) ជាដើម។ នៅរដូវកាលមួយទៀតដែលកូនចៅចិនហៅថា ឆេង ម៉េង(រដូវពូនផ្នូរ ឬសែនផ្នូរ ឬចេតិយ៍)អ្នកស្រុកនោះហៅថា ធឹងម៉ឹង។ល។ រហូតដល់អ្នកស្រុកនោះនាំគ្នាបង្គាប់គ្នាថា បើចង់បានកូនក្រមុំអ្នកសមរលាវទាល់តែកូនកំលោះចេះប៉ាយ(ចេះរបៀបគោរពម្ចាស់ទឹកម្ចាស់ដីឡើងអ្នកតាតាមប្រពៃណីចិន)ទើបគេលើកកូនឲ្យ[182]។ តាមអ្នកស្គាល់ប្រពៃណីចិនច្បាស់លាស់ថា

---

[181] មាយបូជា

[182] បច្ចុប្បន្នមិនរើសកូនប្រសារដោយឈរលើគោលការណ៍នេះទៀតទេ កូនកំលោះ ចង់បានកូនក្រមុំនៅភូមិសមរលាវ ឲ្យតែមានចំណេះ ចេះធ្វើស្រែភ្លឺ កុំផឹកស្រាអ៊ូទីន្ទ ឡូឡា លេងល្បែង សេពគ្រឿង

របៀបប៉ាយ របៀបគោរពរបស់អ្នកភូមិសមរលាវ ជាទំនៀម របស់ចិនហៃណាំ តែអ្នកភូមិសនរលាវខ្លួនឯង មិនបានដឹងច្បាស់អំពីរឿងនេះទេ។ អ្នកភូមិជានិច្ចកាលមិនដែលបំភ្លេចការគោរពព្រលឹង ឬវិញ្ញាណក្ខន្ធដូនតា ឬបុព្វបុរសរបស់ខ្លួននៅគ្រប់ខែមន្តសន្តិរដូវខាងលើនេះម្តងណាឡើយ។ ពួកគេតែងតែប្រារព្ធ និងរៀបចំពិធីសែនដូនតាទៅតាមធនធាន និងប្រពៃពីបុរាណតៗមកដល់សព្វថ្ងៃ។ អ្នកភូមិទាំងបីនេះប្រហែលជាដូចប្រជារាស្ត្រខ្មែរទូទៅដែរ ចូលចិត្តធ្វើធ្វើនំបញ្ចុក( សម្លរការី សម្លរប្រហើរ ទឹកត្រីផ្អែម) បបរខ្ទក់ បបរគ្រឿង បាញ់ឆៃវ បាញ់កាញ់ នំគ្រក់ គុយទាវម្ជូរជ្រលក់ទឹកត្រីជាអាហារ។ចំពោះព្រះពុទ្ធសាសនា ប្រជាពលរដ្ឋបានគោរពបូជា ធ្វើបុណ្យធ្វើទានយ៉ាងសស្រាក់សស្រាំ កសាងវត្តអារាម កុដិ ព្រះវិហារ និងហេដ្ឋារចនាសម្ព័ន្ធវត្តបានយ៉ាងខ្ជាប់ខ្ជួន។ ទាក់ទងនឹងទំនៀមទម្លាប់អាពាហ៍ពិពាហ៍ក៏ត្រូវបានកាត់ចោលពិធីខ្លះៗចេញដោយសង្ខេបតាមពេលវេលាដូចនៅទីនានាទូទាំងព្រះរាជាណាចក្រកម្ពុជាសម័យទំនើបដែរ ពោលគឺមិនអភិរក្សដូចពីបុរាណកាលនោះទេ។ ដូចជា សម័យបុរាណការរៀបមង្គលការមានរយៈពេលបីយប់បីថ្ងៃសង្ខេបមកនៅត្រឹមមួយយប់មួយថ្ងៃ។ រីឯពីធីបុកលក្ខណ៍ ពេលខ្លះក៏ត្រូវរៀបចំប្រារព្ធ ឬមិនប្រារព្ធអាស្រ័យផងដែរលើធនធាននៃគ្រួសារនីមួយៗ។

ពិធីបុណ្យតាមព្រះពុទ្ធសាសនា អ្នកភូមិទាំងនេះមិនដែលមើលរំលង

---

ញៀនដែលសង្គមមិនរាប់អាន និងចេះគោរពម៉ែឪ ចាស់ទុំ ហើយកូនក្រមុំនោះមិនជាប់គេទៅ គេលើកឲ្យហើយ។

ទេ ផ្ទុយទៅវិញ ពួកគាត់បានចូលរួមយ៉ាងសកម្មក្នុងពិធីបុណ្យទាំងនោះមានជាអាទិ៍៖ បុណ្យភ្ជុំបិណ្ឌ បុណ្យកឋិនទាន បុណ្យចូលឆ្នាំខ្មែរ បុណ្យផ្កាសាមគ្គី បុណ្យដារលាន បុណ្យភូមិ[183] បុណ្យឡើងសាលា បុណ្យឆ្លង បុណ្យចញ្ចុះសីមា និងបុណ្យសព ជាដើម។ល។ សុទ្ធតែត្រូវបានប្រារព្ធតាមគន្លងព្រះពុទ្ធសាសនាទាំងអស់។ (រូបថតពិធីបំបួសនាគ សិរិបញ្ញោ សេង ប៊ុនធឿន ឆ្នាំ ២០០២)។



មាតា បិតា កុមារា សេង សាកល ក្នុងថ្ងៃបំបួសសាមណេ សេង ប៊ុនធឿន(រូបទី១៦)

[183] ពិធីបុណ្យនេះនឹងមានការពន្យល់នៅផ្នែកខាងចុងសៀវភៅនេះ។



បិតា និងបងស្រីធំរបស់លោក សេង ប៊ុនធឿន ថ្ងៃបំបួសនាគ(រូបទី១៧)



ពិធីហែនាគ សេង ប៊ុនធឿន ទៅបំបួស វត្តសមរលោរ(រូបទី១៨)



ពីឆ្វេងទៅស្តាំ៖១-មេធាវី នាង វិចិត្រ ២-លោកជំទាវ ឡាប ផល្លីហេង បូ ៣-សេង ប៊ុនធឿន
៤-ឯកឧត្តម ហេង បូ ៥-ឯកឧត្តម កែវ ហុកលី(រូបទី១៩)



នាគ សេង ប៊ុនធឿន និងក្រុមភ្លេងបុរាណ(រូបទី២០)



នាគ សេង ប៊ុនធឿន នៅចំពោះព្រះភក្ត្រព្រះគ្រូឧបជ្ឈាក្នុងពិធីបំបួស(រូបទី២១)



លោក តាំង ណាំស្រុន ព្រះតេជ. ឡាក់ ហំ សម្តេចព្រះពោធិវាំង នួន ង៉ែត ព្រះភិក្ខុ សេង ប៊ុនធឿន ឧបាសក សេង អ៊ិន ឧបាកសក ស្រ៊ា(រូបទ២២)



ភិក្ខុ សេង ប៊ុនធឿន និងអតីតព្រះចៅអធិការ សួស ជុំ(រូបទី២៣)



សម្តេចព្រះពោធិវាំង នួន ង៉ែត និងភិក្ខុ សេង ប៊ុនធឿន(រូបទី២៤)

ប្រជារាស្ត្រតំបន់នេះស្រឡាញ់ជាតិ(គោរពរាជរដ្ឋាភិបាល) សាសនា និងព្រះមហាក្សត្ររបស់គេខ្លាំងណាស់។ យើងអាចនិយាយបានថា ជាអ្នកស្រឡាញ់របបរាជានិយមយ៉ាងច្រើនលើសលប់។ អ្នកភូមិចូលចិត្តសិល្បៈតន្ត្រី របាំ ល្ខោនបាសាក់ អាយ៉ៃ ចាប៉ី។ ជាពិសេស ប្រសិនបើវង្សល្ខោនបាសាក់ណាសំដែងល្អមើលពួកគាត់នាំគ្នាអង្គុយទស្សនាល្ខោននេះរហូតទាល់តែភ្លឺតែម្តង ជាពិសេស ក្រុមសិល្បៈរបស់ ភី សុគន្ធី ស្រុកបាទី ខេត្តតាកែវ។ ក្រុមល្ខោននេះល្បីល្បាញណាស់ ប្រសិនបើគ្មានជំងឺ កូវីដ-១៩ យាយីទេ ក្រុមនេះ គ្មានរាត្រីណាមួយទាំង៣៦៥ថ្ងៃបានទំនេរគេងផ្ទះទេ ពោលគឺសំដែង៣៦៥ថ្ងៃលើ ៣៦៥ថ្ងៃ ហើយប្រសិនបើយើងចង់បានក្រុមគាត់យកទៅសំដែងកំដរបុណ្យទានផ្សេងៗត្រូវកក់គាត់មួយឆ្នាំមុនទើបជួលបាន។ គួររំលឹកថា នៅក្នុងទសវត្សឆ្នាំ៨០ ភូមិសមរខ្មែរបានបង្កើតក្រុមល្ខោនបាសាក់មួយវង់ដឹក នាំដោយលោក គ្រូ សេង។ កាលនោះក្រុមល្ខោននេះមានឈ្មោះបោះសំឡេងគួរសមអ្នកស្រុកជិតឆ្ងាយឧស្សាហ៍ជួលទៅសំដែងក្នុងពិធីបុណ្យផ្សេងៗដែរ។ ប៉ុន្តែក្រោយៗមក ក៏បែកខ្ញែកគ្នារំសាយក្រុមសិល្បៈល្ខោននេះបាត់រូបរាងទៅ។ ក្រៅពីនេះ អ្នកស្រុកមួយចំនួនតូច ក៏ចេះលេងភ្លេងប្រពៃណី ភ្លេងអារក្ស ផ្លៃយ៉ាំ ឬពិណពាទ្យផងដែរ ជាដើម។ ក្នុងសម័យតេជោសែន ជាសម័យទំនើបនេះ ក្រៅពីសិល្បៈបុរាណ យុវជនក្នុងតំបន់នេះ ក៏បានចូលចិត្តរាំរែកតាមសម័យទំនើប និងការសប្បាយផ្សេងៗទៅតាមបំណងប្រាថ្នា ដូចជា រាំវង់

រាំក្បាច់ សារ៉ាវ៉ាន់ ឡាំលាវ ម៉ាឌីហ្សុន បទញាក់ កន្ត្រាក់អារម្មណ៍[184]។ល។

**៨-បញ្ហានយោបាយ**

យើងមិនចាំបាច់អធិប្បាយតាំងពីសម័យអាណានិគមនិយមបារាំង សម័យឯករាជ្យ សម័យសង្គមរាស្ត្រនិយម សម័យ លន់ ណុល ទេ គឺនិយាយមត្រឹមតែសម័យរបបកម្ពុជាប្រជាធិបតេយ្យ(ប៉ុល ពត) ភូមិសមរលាវ ភូមិសមរខ្មែរ ភូមិសមរចិនក៏មិនខុសពីភូមិស្រុកនានានៃប្រទេសកម្ពុជាដែរ។ ក្នុងសម័យនេះ ក្មេងអាយុពី១ឆ្នាំដល់៤ឆ្នាំ[185] ត្រូវដាក់ឲ្យស្ថិតនៅក្នុងមណ្ឌលកុមារ(Children Center) ដាច់ចេញពីមាតាបិតា។ ចាប់ពីអាយុ៤ឆ្នាំដល់១២ឆ្នាំអង្គការឲ្យក្រុមកុមារនេះដើរប្រមូលសំរាមឲ្យបាន១៥គីឡូក្រាមក្នុងមួយថ្ងៃដើម្បីធ្វើជីធម្មជាតិ។ អាយុលើសពីនេះជាយុវជនកងចល័តធ្វើការឆ្ងាយៗពីមាតាបិតា។ រីឯមនុស្សចាស់ពេញកម្លាំងជាកងស្រួចបានសេចក្តីថា ក្រុមធ្វើការសេកម្ម ជាអ្នកមានកម្លាំងខ្លាំងក្លា។ នៅសម័យនោះ ប្រធានភូមិ ឬគណៈកងមានអត្តចរិកផ្តាច់ការ ម៉ឺងម៉ាត់ ច្បាស់លាស់ណាស់ ចង់ឲ្យអ្នកណាស្លាប់ក៏

---

[184] អ្នកនិពន្ធបានខិតខំតាក់តែងបទចម្រៀងដូចបានរៀបរាប់ខាងលើនេះដោយចំណាយថវិកាផ្ទាល់ខ្លួនជាច្រើនដើម្បីទុកជាអនុស្សាវរីយ៍ផង សម្រាប់ទុកជាកេរដំណែលឲ្យយុវជនបានរាំកម្សាន្តផង ជាពិសេស ដើម្បីឲ្យអ្នកស្តាប់ផងទាំងឡាយបានស្គាល់ឈ្មោះភូមិសមរលាវ សមរខ្មែរ និងសមរចិន ហើយចង់មកទស្សនាតំបន់នេះ។ សូមចូលរួមថែទាំបរិស្ថានស្អាតដើម្បីស្វាគមន៍ភ្ញៀវជិតឆ្ងាយមកលេងភូមិស្រុករបស់យើងទាំងអស់គ្នា។

[185] កាលសម័យនោះ ខ្ញុំមានអាយុប្រហែល៤ឆ្នាំ។ ពួកអង្គការឲ្យខ្ញុំប្រមូលសំរាម។ ខ្ញុំនៅចាំបានថា គេធ្វើដែកធឹកជំនួស ដែកកេះ។ ជ័របីដុង យកទៅរោលភ្លើង ធ្វើឡេវអាវ ហើយយកសំបកកាទុសគ្រាប់កាំភ្លើងដើម្បីសម្រាប់ឡេវអាវនោះ។ល។

បានដែរ។ ក្នុងភូមិសមរលោវក៏មានជាស្ត្រី បុរសមួយចំនួនតូចអនុវត្តបទបញ្ជារបស់អង្គការយ៉ាងខ្ជាប់ខ្ជួន មានសំដីកាចផ្តាស់ផ្តើមគួរឲ្យស្អប់ខ្ពើមណាស់។ អង្គការខ្មែរក្រហមនៅភូមិទាំងបី តែងតែអនុវត្តយ៉ាងតឹងរ៉ឹង។ ជារៀងរាល់ថ្ងៃសមាជិកគ្រួសារណានីមួយៗមិនអនុញ្ញាតឲ្យជួប ឬឃើញមុខគ្នាទេនៅពេលថ្ងៃនោះ។ លើកលែងតែគ្រួសារដែលជាសមាជិកអង្គការផ្ទាល់តែម្តង។ ខ្ញុំនៅចាំបានថា ដើម្បីកូនៗជាទីស្រឡាញ់ អ្នកម្តាយខ្ញុំ ពេលត្រឡប់មកពីធ្វើការវិញតែងតែបានមានក្តាម ខ្យង ចាប់ត្រី ដែលលាក់ទុកក្នុងថ្នក់សំពត់យកមកដុតធ្វើកូន។ គ្រួសារខ្លះធ្លាប់ដាំបាយនឹងកំសៀវទឹកនៅក្នុងមុងឲ្យកូនហូប ហើយហាមកូនកុំទំពារឮខ្លាំងពេកខ្លាចអង្គការស្តាប់ឮ ហើយមិនមានការអុជចង្កៀងបំភ្លឺអ្វីឡើយ គឺត្រូវរាវនឹងដៃហូបទាំងអស់។ ពេលខ្លះទៀតលួចគាស់មើមដំឡូងបានហើយដុតយកមកឲ្យកូនហូបទាំងកណ្តាលរាត្រីស្ងាត់។ សូម្បីតែសំបកដំឡូង ដែលបកហូបរួចហើយហ្នឹងក៏ត្រូវបោះចោលក្នុងកន្លែងសុវត្ថិដែរ ពីព្រោះខ្លាចគិញ[186]របស់អង្គការស៊ើបការដឹងថាយើងលួចលាក់ហូបម្ហូបចំណីជាឯកជន គេចោទយើងថា ក្បត់អង្គការ ហើយក៏ជាកម្មវត្ថុនៃការសម្លាប់ចោលដែរ។ ប្រៀបធៀបមកដល់សម័យនេះ វាទៅ ជាគួរឲ្យចង់សើចទៅវិញ មានថ្ងៃមួយប្រធានសហករណ៍[187]ភូមិសមរលោវប្រកាសពេលកំពុងហូបបាយល្ងាចប្រហែលជាម៉ោង៧ ឬ៨យប់ សហករណ៍ក្រោមសាលាឆាន់ថា នៅយប់

---

[186] អ្នកស៊ើបការណ៍។

[187] ប្រធានសហករណ៍។

នេះ អង្គការសូមអញ្ជើញម៉ែៗ ជាពិសេស អ្នកមានផ្ទៃពោះវិលមកសហករណ៍វិញនៅវេលាម៉ោង១០យប់កុំបីខាន។ ស្រ្តីវ័យចំណាស់ (ទាំងម្តាយ ខ្ញុំ-ម្តាយគេ) បាននាំគ្នាអញ្ជើញត្រឡប់ទៅសហករណ៍វិញតាមការផ្តល់ព័ត៌មាននេះ។ តាមពិតនៅរាត្រីនោះ អង្គការ[188]គេហៅទៅហូបលៀសហាលសោះ។ ទីណាក៏ដូចទីណាអង្គការបានផ្តាច់ទាំងស្រុងនូវមនោសញ្ចេតនាគ្រួសារ ម្តាយ ឪពុក និងកូន ប្អូន និងបង ប្រពន្ធប្តី ជីដូនជីតា និងចៅគួរឲ្យសង្វេកណាស់។ តើនរណាខ្លះដែលមិនស្តីបន្ទោសរបបដឹកនាំពួកអាវខ្មៅនេះនោះ ទឹកចិត្តធំធេងគ្មានអ្វីប្រៀបផ្ទឹមបានរបស់អ្នកម្តាយ ឪពុក និងកូន។ កាលជំនាន់នោះ ករណីខ្ញុំស្ទើរតែរាល់រាត្រី ដោយសារតែលោកឪពុក និងអ្នកម្តាយរបស់ខ្ញុំជាសមាជិកកងស្រួច(អ្នកធ្វើការយ៉ាប់ខ្លាំង)របស់អង្គការ លោកត្រូវបានអនុញ្ញាតឲ្យចូលភូមិ និងមកដល់ផ្ទះនៅពេលរាត្រី។ ខ្ញុំតែងតែអង្គុយរង់ចាំមើលផ្លូវអ្នកមានគុណទាំងពីរយ៉ាងយប់ជ្រៅជាមួយធម្មជាតិស្ងាត់ជ្រងំជា មួយនឹងសត្វមៀមកញ្ច្រាវ ក្លែងស្រាក ដែលទំនៅលើដើមជ្រៃមុខផ្ទះទម្លាក់សំឡេងគួរឲ្យព្រឺក្បាល (តាមចាស់និយាយ សត្វនេះជាពពួកសត្វយកព្រលឹង)។ ដើម្បីកូនជាទីស្រឡាញ់ ពេលមកដល់ផ្ទះជួបកូនៗ ម្តាយឪពុកថ្ងៃខ្លះបានបង្ខំចិត្តប្រព្រឹត្តិខុសនឹងវិន័យអង្គការ ទោះបីដឹងហើយថា ប្រសិនបើអង្គការបានរកឃើញពួក

[188] នៅសម័យកម្ពុជាប្រជាធិបតេយ្យ ពាក្យ **អង្គការ** សំដៅដល់ អ្នកដឹកនាំ ឬថ្នាក់លើ។ អង្គការពេលនោះមានន័យស្មើនឹងអាជ្ញាធរ ឬរដ្ឋអំណាច។ សូមអានឧបសម្ព័ន្ធទី៤នៃសៀវភៅរដ្ឋធម្មនុញ្ញ និងការផ្លាស់ប្តូររបបនយោបាយរបស់លោកបណ្ឌិត សេង ប៊ុនធឿន ទំព័រ៣១១ និង៣១៣។ល។

គាត់នឹងនាំយកទៅកសាង[189] ឬសម្លាប់ផ្តាច់ផ្តិលជីវិតចោលក៏ដោយ។ រឿងរ៉ាវក្នុងសម័យខ្មែរក្រហមក្មេងៗខ្លះប្រហែលជាគិតថាប្រឌិតហើយមើលទៅ។ ព្រឹត្តិការណ៍មួយទៀតដែលខ្ញុំនៅចងចាំដែរ គឺករណីយកអ្នកភូមិសមរលាវម្នាក់ឈ្មោះ លន់[190] ត្រូវបានបាញ់សម្លាប់យ៉ាងសា-ហាវនាកណ្តាលអគ្រាតនៅចិញ្ចើមផ្លូវចូលទៅទួលតាអែ[191] និងការសម្លាប់មនុស្សដែលធ្វើដំណើរមកពីភ្នំព្រៃហូរញ្ចៅពីរនាក់ទៀតនៅវេលាម៉ោងជាង៥ល្ងាចនៅត្រង់ទីចំការមួយខាងកើតវត្តសមរលាវចម្ងាយប្រហែលជាងមួយរយម៉ែត្រ។ ករណីនេះមិនដឹងជាពួកគាត់បានប្រព្រឹត្តិទោសកំហុសអ្វីឲ្យពិតប្រាកដនោះទេ។ កម្មាភិបាល ឬកងឈ្លបខ្មែរក្រហមនៃភូមិសមរលាវគ្រានេះបានធ្វើឲ្យអ្នកភូមិម្នាក់ៗមានការភ័យខ្លាចរហូតបាក់ស្បាត។ កាលនោះរូបខ្ញុំផ្ទាល់បានដឹង និងឃើញគេបណ្តើរ អ្នកទាំងនោះ។ ចំពោះលោក លន់ បានទាំងឃើញគេចងស្លាបសេកដៃទាំងពីររបស់លោកមកក្រោយ ហើយបណ្តើរទៅកន្លែងបាញ់សម្លាប់ដូចមាន់ទា ឬគោក្របី។ សម័យកាលនោះរូបខ្ញុំមានអាយុនៅក្មេងនៅឡើយ[192]គឺប្រហែល

---

[189] **កសាង** មានអត្ថន័យស្មើនឹងណែនាំ ស្តីបន្ទោស។

[190] លោកជាមនុស្សស្លូតបូត មានចំណេះដឹងជ្រៅជ្រះ។ កូនស្រីទោលរបស់គាត់កំពុងរស់នៅរាជធានីភ្នំពេញ។

[191] ទីនេះបច្ចុប្បន្នត្រូវព្រះចៅអធិការវត្ត ឡាក់ ហំ ប្តឹងទាមទារមកជាកម្មសិទ្ធិវត្តសមរលាវមួយផ្នែកធំវិញហើយ។

[192] ផ្តល់ព័ត៌មានបន្ថែមដោយលោក កាក់ នូ អ្នកភូមិសមរលាវ។ សព្វថ្ងៃលោកកំពុងរស់នៅស្រុកលើកដែក ខេត្តកណ្តាល។ លោកជាមនុស្សតែម្នាក់គត់ដែលនៅរស់រានមានជីវិតក្នុងពេលជម្លៀសទៅកាន់ខេត្តភាគខាងលិចប្រទេសកម្ពុជា។ សមាជិកគ្រួសារ(ប្រពន្ធ កូនប្រុសពីរនាក់ កូនស្រីពីរនាក់)ត្រូវបាន

៤-៥ប្រាំឆ្នាំប៉ុណ្ណោះ។ ពួកខ្មែរក្រហមបានអនុវត្តនយោបាយសម្លាប់មនុស្ស ដូចសម្លាប់សត្វតិរច្ឆានអញ្ចឹងដែរ។ ជានិច្ចកាលនៅសម័យកម្ពុជាប្រជាធិបតេយ្យនេះ ឪពុកម្ដាយណាក៏ដូចតែគ្នាដែរ ឲ្យតែមានចំណីណាឆ្ងាញ់ប្លែក លោកតែងតែនឹកទៅដល់កូន លោកបានលួចលាក់យកមកធ្វើកូនដែលកំពុងរង់ចាំនៅឯផ្ទះមិនដែលលស់ថ្ងៃ។ ភ្ជាប់នឹងបញ្ហានេះ ខ្ញុំសូមរំលឹកករណីផ្ទាល់ខ្លួនបន្តិច លោកឪពុករបស់ខ្ញុំផ្ទាល់ ស្ទើរតែរាល់ពេលហូបបាយ លោកតែងតែទៅឈរមើលខ្ញុំហូបបាយជាមួយគេដើម្បីកុំឲ្យខ្ញុំខ្លាចគេ។ លោកចង់ដឹងថា តើខ្ញុំ[193]ហូបបាយហើយ ឬនៅ ហូបទាន់គេ ឬអត់។ល។ ប្រធានភូមិ ឬមេសហករណ៍ជំនាន់នោះ គេធ្វើចរិកដូចគេមិនដែលបានធ្វើធំ ឬដូចជីវិតអមតៈ។ល។

ទីបំផុតទៅពួកគេបានរត់ចោលភូមិស្រុកអស់រលីងបន្ទាប់ពីថ្ងៃរំដោះ ៧មករា ឆ្នាំ១៩៧៩។ ប្រវត្តិសាស្ត្រ ខ្មែរបង្ហាញថា កុំតែមានថ្ងៃ៧មករា ឆ្នាំ១៩៧៩នេះ ម្ល៉េះខ្មែរអាចផុតពូជផងក៏ថាបាន ក្រោយពីរបបខាងលើដួលនៅទសវត្សឆ្នាំ១៩៨០ រដ្ឋអំណាចថ្មី ពោលគឺរបបសាធារណរដ្ឋប្រជាមានិត្យកម្ពុជា បានចែកកម្លាំងពលកម្មទៅតាមអាយុគេបង្កើតក្រុមសាមគ្គី[194] ហៅថា

---

ស្លាប់ដោយដាច់ក្បូនធ្លាក់ទៅក្នុងជ្រោះនៅពេលត្រូវជម្លៀសគេចចេញពីកងទ័ពវៀតណាមនាចុងឆ្នាំ ១៩៧៨។

193 នៅសម័យនោះ ខ្ញុំ(អ្នកនិពន្ធសៀវភៅនេះ)តែងតែខ្លាចគេណាស់ អញ្ចឹងហើយបានជាលោកឪពុករបស់ខ្ញុំតែងតែទៅឈរមើលខ្ញុំ ពីព្រោះខ្លាចខ្ញុំហូបបាយមិនទាន់គេ។

194 អ្នកស្រុកនេះ កាលជំនាន់នោះ គេស្រឡាញ់គ្នាណាស់ គ្រួសារនីមួយៗនាំគ្នាចិញ្ចឹមជ្រូក គោ មាន់ទា ហើយគេកាប់ជ្រូកចែកសាច់គ្នាហូប ៗអស់អញ្ចឹងទៅដល់វេនគ្រួសារមួយទៀត។ អ្នកស្រុកនីមួយៗចេះយកអធ្យាស្រ័យគ្នាណាស់។ កាលពីដើមគ្រួសារណាមានធុរៈត្រូវលើកផ្ទះ(សង់ផ្ទះ) ធ្វើបុណ្យអ្វីៗ គេ

មជ្ឈការ ឬការប្រមូលផ្តុំអំណាច។ វិស័យសេដ្ឋកិច្ច ជាសេដ្ឋកិច្ចផែនការ គេលក់ស្រូវជូនរដ្ឋតាមទ្រឹស្តីលក់ស្រូវជូនរដ្ឋគឺស្នេហាជាតិ។ ស្រុកយើងពេលនោះ នៅមានសង្គ្រាមស៊ីវិលរវាងខ្មែរ និងខ្មែរដោយភាគីខ្មែរទាំងបួន(សាធារណរដ្ឋប្រជាមានិតុកម្ពុជា ហ៊្វុនស៊ិនប៉ិច មូលីណាកា និងខ្មែរក្រហម) នៅវាយប្រយុទ្ធគ្នាតាមព្រំដែននៅឡើយ។ ក្រោយថ្ងៃរំដោះ និងបន្តបន្ទាប់មក យុវជនយើងមានសំណាងណាស់ ពួកគេមានឱកាសរៀនសូត្រ ជ្រើសរើសការងារជ្រើសរើសគូរស្រករបានដោយសេរី។

បច្ចុប្បន្ននេះ ប្រទេសកម្ពុជាអនុវត្តរបបនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស។ តាមការសង្កេត អ្នកស្រុកភូមិទាំងបីសុទ្ធតែបានយល់ដឹង ចេះវិភាគរកខុសត្រូវអំពីនយោបាយស្រុកទេសគួរឲ្យកោតសរសើរ។ ទោះបីយ៉ាងណាក៏ដោយ ក្រុមសកម្មជនគណបក្សនានាចេះអត់ឱនឲ្យគ្នាទៅវិញទៅមកណាស់ ហើយព្យាយាមមិនឲ្យមានប៉ះទង្គិចគ្នាផ្នែកពាក្យសំដី និងអំពើហិង្សានយោបាយផ្សេងៗដែលប្រឆាំងគ្នាកើតឡើងទេ។

ប្រវត្តិសាស្ត្របានបង្រៀនពួកគាត់ឲ្យស្នេហាជាតិ ស្រឡាញ់មាតុភូមិស្រឡាញ់ឯករាជ្យភាព សន្តិភាព និងបូរណភាពទឹកដី។ អ្នកភូមិចេះរាប់អានគ្នា ស្រឡាញ់គ្នាណាស់ លើកលែងតែជំនាន់ខ្មែរក្រហមធ្វើឲ្យមនុស្សខ្លះ(ម្នាក់ឬពីរនាក់)ប៉ុណ្ណោះដែលលង់លក់នឹងភាពកាចសាហាវយង់ឃ្នង់ ហើយខិតខំ

---

ទៅជួយពេញៗផ្ទះ។ គេហង្គាននីមួយៗគេដាំបន្លែបាន គេចែកគ្នាហូប គេសុំគ្នាត្រង់ៗ។ ប៉ុន្តែ បច្ចុប្បន្ននេះអ្នកស្រុកបានផ្លាស់ប្តូរទម្លាប់ខាងលើច្រើនហើយ។

អនុវត្តតាមបញ្ជារបស់អង្គការអាវខ្មៅកុំឲ្យខ្វោះ។ គួរបញ្ជាក់ថា តាមវិទ្យុបារាំងអន្តរជាតិ (Radio France Internationale/ RFI) ដែលបានផ្សាយកាលពីថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ឲ្យដឹងថា នៅថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៥ លោក ឈា តាំងស៊ន[195] សកម្មជនគណបក្សនយោបាយត្រូវបានស្នងការនគរបាលខេត្តតាកែវចាប់ខ្លួន និងបញ្ជូនទៅតុលាការខេត្តភ្លាមៗដោយចោទប្រកាន់[196]លោកពីបទធ្វើការញុះញង់ដើម្បីឲ្យមានការរើសអើងពូជសាសន៍តាមមាត្រា៤៩៦ នៃក្រមព្រហ្មទណ្ឌនិងត្រូវពិន័យជាប្រាក់៣,០០០,០០០រៀល(បីលានរៀល)។ លោកមេធាវី សំ សុគង់ បានឲ្យដឹងថា កូនក្តី របស់លោកបានធ្វើការទាញយកឯកសារពីក្នុងហ្វេសប៊ុក(Facebook)មួយស្តីពីយុទ្ធសាស្ត្រវៀតណាមយកមកចម្លងទុកជាឯកសារ ហើយត្រូវបានផ្សព្វផ្សាយដោយមិត្តភក្តិជាសកម្មជនគណបក្សរបស់គាត់ម្នាក់ទៀត។លោក ឈា តាំងស៊ន ជាអតីតគ្រូបង្រៀនបឋមសិក្សា អនុវិទ្យាល័យសមរលោវ ហើយលោកជាកូនចៅអ្នកភូមិ

---

[195] យើងសម្រេចចិត្តយកករណីនេះមកសរសេរនៅទីនេះដោយឈរលើមូលហេតុពីរយ៉ាង៖

១-លោកជាអ្នកមានកំណើតភូមិសមរលោវ និងបច្ចុប្បន្នលោកកំពុងរស់នៅភូមិសមរចិន ដែលជាទីតាំងភូមិធ្វើការស្រាវជ្រាវ និងចង ក្រង។ ថ្វីដ្បិតតែភូមិសមរចិននេះ មិនត្រូវបានរាប់ថាជាភូមិមួយដោយឡែកពីភូមិសមរខ្មែរក៏ដោយ។ ប៉ុន្តែអ្នកស្រុកនៅតែហៅ និងស្គាល់ក្នុងការទំនាក់ទំនងនៃជីវភាពរស់នៅក្នុងទីតាំងនេះដដែល។

២-យើងបានដឹងហើយថា ការសិក្សាប្រវត្តិវិទ្យា គឺជាការជៀសវាងរឿងរ៉ាវប្រវត្តិសាស្ត្រ(អតីតកាល)កើតឡើងច្រំដែលម្តងទៀត ដូច្នេះស្មោះពិតជាមិនចង់ឃើញមានបញ្ហាដដែលកើតជាថ្មីលើទឹកដីភូមិកំណើតនេះម្តងទៀតឡើយ។

[196] វិទ្យុបារាំងអន្តរជាតិ (Radio France Internationale/ RFI) បានផ្សាយកាលពីថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥

សមរលោវ និងកំពុងរស់នៅភូមិសមរចិន។ ករណីខាងលើត្រូវបានបញ្ចប់ក្នុងរយៈពេលតែ៤៨ម៉ោងប៉ុណ្ណោះ។ នេះជាសារមួយដល់អ្នកប្រើប្រាស់បណ្ដាញសង្គមគ្រប់ប្រភេទនាពេលបច្ចុប្បន្ននេះដែលគប្បីមានការប្រុងប្រយ័ត្ន ដោយធ្វើការផ្ទៀងផ្ទាត់ព័ត៌មានឲ្យបានច្បាស់លាស់មុននឹងបង្ហោះ ឬចែកចាយដើម្បីចៀសវាងការភ័ន្តច្រឡំផ្សេងៗ។ អាជ្ញាធរ ឬរាជរដ្ឋាភិបាលតែងតែធ្វើអ្វីៗគ្រប់យ៉ាងដើម្បីជាតិ សាសនា ព្រះមហាក្សត្រ កុំថាឡើយប្រទេសជិតខាងសូម្បីតែមហាអំណាច ឬបស្ចិមប្រទេសក៏ដោយចុះក៏។

ជាឧទាហរណ៍ ក្នុងអំឡុងឆ្នាំ២០០៧-២០០៨ បន្ទាប់ពីកម្ពុជាបានយកប្រាសាទព្រះវិហារទៅដាក់បញ្ចូលជាសម្បត្តិបេតិកភ័ណ្ឌពិភពលោកនៅអង្គការយូណេស្កូ(UNESCO)ប្រទេសថៃមិនសប្បាយចិត្តហើយ បានរករឿងឈ្លោះទាស់ទែងនឹងខ្មែរជាម្ចាស់ស្រុកដោយតវ៉ាថា ដីនៅជើងភ្នំប្រាសាទជាកម្មសិទ្ធិរបស់ខ្លួន។ ដោយមិនបណ្ដោយឲ្យរដ្ឋាភិបាលថៃរបស់លោកនាយករដ្ឋមន្ត្រីអាភីស៊ីត វិចារជីវ៉ា (Abhisit Vejjajiva)ជំនាន់នោះធ្វើព្យុះធ្វើភ្លៀងបានតទៅទៀតរដ្ឋាភិបាលកម្ពុជាដែលមានសម្ដេចតេជោ ហ៊ុន សែន ជានាយករដ្ឋមន្ត្រីបានប្ដឹងទៅតុលាការយុត្តិធម៌អន្តរជាតិទីក្រុងឡាអេ(Hays) នៅប្រទេសហូឡង់(Holland) ដើម្បីសុំឲ្យតុលាការនេះបកស្រាយសាលក្រមដែលខ្លួនធ្លាប់ឈ្នះកាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៦២នៃអតីតរបស់សម្ដេចព្រះនរោត្ដម សីហនុ។ ទីបំផុត នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៣ តុលាការនេះបានប្រកាសសាលដីការបស់ខ្លួនឲ្យខ្មែរឈ្នះម្ដងទៀតនូវផ្ទៃដីទាំងឡាយ

ដែលថៃអះអាងថាជារបស់ខ្លួន មិនតែប៉ុណ្ណោះតុលាការថៃមទាំងប្រកាសឲ្យរដ្ឋាភិបាលថៃដកកងទ័ពរបស់ខ្លួនចេញពីតំបន់ជម្លោះនោះឲ្យអស់ទៀតផង។

ប្រាកដណាស់ ការព្រួយបារម្ភអំពីការបាត់បង់ទឹកដីរបស់ជនជាតិខ្មែរមួយចំនួននោះមិនមែនទើបតែកើតឡើងទេ ឬអាចនិយាយថា ជនជាតិខ្មែរយើង ទឹកដីរបស់ពួកគេមួយផ្នែកធ្លាប់ត្រូវបានប្រទេសជិតខាងរឹបលេបយកជាកម្មសិទ្ធិ(សូមមើលឧបសម្ព័ន្ធទី៦ និងទី៧)។ ហេតុដូច្នេះហើយបានជាយើងតែងតែឃើញមានការប្រទូស្តសារាយគ្នារវាងអ្នកដឹកនាំ និងរាស្ត្រ ឬខ្មែរអ្នកគាំទ្រក្រុមម្ខាងៗជាហូរហែ។ សូម្បីតែសម័យបារាំងត្រួតត្រាខ្មែរ (១៨៦៣-១៩៥៣) ក៏មានករណីដូចការចោទប្រកាន់ខាងលើដែរ ពុំនោះសោតម្ល៉េះមិនមានការបន្សល់ទុករបស់ព្រះភិរម្យភាសាអ៊ូ ហៅ ង៉ុយ នូវកេរតំណែលដ៏មានសារសំខាន់ដើម្បីរំលឹកកូនខ្មែររហូតសព្វថ្ងៃនេះដែរ។ ខាងក្រោមជាការការស្រង់កំណាព្យច្បាប់ល្បើកថ្មី (១៨៦៥-១៩៣៦)របស់ព្រះភិរម្យត្រង់ឃ្លាថា៖

ត្បិតមនុស្សឥឡូវ យកខុសធ្វើត្រូវ
យកឆ្គួតធ្វើជា អំពើអាក្រក់
ឡិកឡក់លីលា ព្រហើនពានពារ
អាងមាសអាងប្រាក់។
អាងព្រើលអាងប្រាជ្ញ អាងកោងអាងកាច
អាងកាប់អាងចាក់ អាងជើងអាងដៃ

អាងវាយអាងធាក់ អាងគុកច្រវាក់
អាងម៉ាស៊ីនកាត់ក (ទំព័រ១)។
ចេះច្បាប់បារាំង កុំភ្លេចសង្ឃុំ
កតញ្ញូឧន្ដី កុំធ្មើងហួសមាឌ
ភ្លេចញាតិប្រុសស្រី ជំនុំកាត់ក្ដី
យកឧបបេក្ខា(ទំព័រ៤)។
លោកបានរំលឹកនៅក្នុងឃ្លាបន្ទាប់ទៀតថា
ជាតិខ្មែរប្រែខុស ស្រីក្លែងជាប្រុស
ប្រុសក្លែងជាថ្វា យកប្ដីប្រពន្ធ
មិនស្គាល់មីងមា បុណ្យទានការងារ
កាប់គ្នាឥតក្រែង។
លូង់ឬកធ្វើចេះ គោចងត្រដោកសេះ
ប្រុសៗជុះស្នែង ស្រីពាក់អាវខ្លី
ប្រុសពាក់អាវវែង សារុងហៀរកែង
ធ្វើឯងអ្នកគ្រាន់ ។

បន្ថែមពីលើនេះទៀត សាច់រឿងភូមិតិរិច្ឆានរបស់លោក ឌឹក គាម និង លោក ជឿក អំ ឆ្នាំ១៩៦៤-៦៥ក៏បានរំលឹកអំពីសកម្មភាពរបស់អាណានិគមបារាំងធ្វើបាបខ្មែរផងដែរ[197]នៅភូមិក្រាំងលាវ ស្រុករលាប្អៀ ខេត្តកំពង់ឆ្នាំងនាឆ្នាំ១៩២៥។ យើងមិនអាចនិយាយថា គ្រប់ការដឹកនាំរដ្ឋសុទ្ធតែល្អឥតខ្ចោះនោះទេ តែងតែមានគុណសម្បត្តិ និងគុណវិបត្តិ។ ចំពោះរាជរដ្ឋាភិបាល

[197] អ្នកព្រះភិរម្យភាសាអ៊ូហៅ ង៉ុយ(១៨៦៥-១៩៣៦៖)ច្បាប់ល្បើកថ្មី ទំព័រ២៩-៣០ និងរឿងភូមិតិរិច្ឆានរបស់លោក ឌឹក គាម ជឿក អំ ឆ្នាំ១៩៦៤-៦៥

បច្ចុប្បន្ន ក៏មិនព្រងើយកន្តើយជាមួយរាល់ចំណុចអវិជ្ជមាន និងអសកម្មផ្សេង ៗដែរ។

ជាក់ស្តែងសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានព្រមានអាជ្ញាធររឿងបើកដៃឲ្យបរទេសចូលមកនេសាទលើផ្ទៃសមុទ្រខ្មែរ[198]។ លោកថ្លែងប្រាប់យ៉ាងដូច្នេះក្នុងពិធីផ្ទេរតំណែងលោកឈិត សុខុន អភិបាលខេត្តព្រះសីហនុ ដែលត្រូវដាក់ឲ្យចូលនិវត្តន៍ និងជំនួសដោយលោក យន់ មីន ត្រូវចូលកាន់តំណែងកាលពីថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥។ ការថ្លែងនេះ ក្រោយពីលោករដ្ឋមន្ត្រីក្រសួងមហា ផ្ទៃបានសង្កេតឃើញថា ការងារគ្រប់គ្រងផ្ទៃសមុទ្ទដែលមានគ្រប់សមត្ថកិច្ចពាក់ព័ន្ធទាំងទាហាន ទាំងប៉ូលីស រដ្ឋបាលជលផល និងអាជ្ញាធរខេត្តនៅមានបញ្ហាជាច្រើនជាពិសេសការបើកដៃឲ្យមានជនអន្តោប្រវេសន៍ខុសច្បាប់មកធ្វើការនេសាទក្នុងដែនទឹកកម្ពុជា។ ករណីអាជ្ញាធរបើកដៃឲ្យជនបរទេសធ្វើនេសាទលើផ្ទៃសមុទ្រនេះ សម្តេចក្រឡាហោមបានព្រមានមន្ត្រីពាក់ព័ន្ធដោយសង្កត់ធ្ងន់ថាមន្ត្រីនគរបាលព្រំដែនទឹកបានទាញយកប្រយោជន៍ផ្ទាល់ខ្លួនពីការអនុញ្ញាតឲ្យមានការនេសាទខុសច្បាប់ជាជាងគិតគូរពីបញ្ហាសន្តិសុខតាមដែនទឹក។ ខ្ញុំដឹងរឿងហ្នឹង មិនមែនមិនដឹងទេ Sic។..រធ្វើសំបុត្រឲ្យគេចាប់ត្រីហើយអន្តោ-ប្រវេសន៍ខុសច្បាប់ហើយ ឲ្យខ្ញុំដោះស្រាយ អ្នកណាចាប់ អ្នកនោះដោះស្រាយទៅ ខ្ញុំអត់ដោះស្រាយទេ។ អញ្ចឹងមានន័យថា លោកឯងកំពុងប្រព្រឹត្ត

[198] ភ្នំពេញប៉ុស្តិ៍ ថ្ងៃអង្គារ៍ ទី៨ ខែកញ្ញា ឆ្នាំ២០១៤(ព័ត៌មានជាតិ) ទំព័រ៤

បទល្មើសហើយ។ រឿងលម្អសមុទ្រមិនព្រមការពារសន្តិសុខ តែបែរជាការពារ ឈ្មួញរកស៊ីប្រយ័ត្នណា?[199]។ សម្តេចក្រឡាហោម ស ខេង ក្នុងឋានៈជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃតែងតែបានប្រកាសហាមប្រាមដល់ចៅហ្វាយខេត្តដែលមានព្រំប្រទល់ជាប់នឹងប្រទេសជិតខាងមិនថា ឡាវ វៀតណាម និង ថៃទេឲ្យបញ្ឈប់ជាបន្ទាន់នូវការដួលដីឲ្យប្រទេសជិតខាងធ្វើស្រែ។ ក្នុងឪកាសជួបសំណេះសំណាលជា មួយបងប្អូនជនរួមជាតិខ្មែរដែលកំពុងរស់នៅសហរដ្ឋអាមេរិក កាណាដា បារាំង និងអាល្លឺម៉ង់នៅបុរីញូវយកកាលពីរសៀលថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៥ មុនចូលរួមកិច្ចប្រជុំកំពូលរបស់អង្គការសហប្រជាជាតិស្តីពីរបៀបវារៈនៃការអភិវឌ្ឍន៍ក្រោយឆ្នាំ២០១៥ សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន បានមានប្រសាសន៍ថា ប្រទេសកម្ពុជាមិនមែនជាប្រទេសរបស់អ្នកកាន់អំណាចមួយក្រុមណាមួយនោះទេ គឺជាប្រទេសរបស់ប្រជាជនកម្ពុជាទាំងអស់ រាប់ទាំងបងប្អូនខ្មែរដែលកំពុងរស់នៅក្រៅប្រទេសផង។ ដូច្នេះ សូមបញ្ឈប់ការលាបពណ៌ដាក់គ្នា ពោលគឺកុំខ្វល់ពីអតីកាលវាជាអ្វី ហើយមានតែការសន្ទនាចរចាគ្នាទេ ទើបអាចបញ្ចប់សង្គ្រាម និងជម្លោះខាងនយោបាយ[200]។ តាមប្រសាសន៍នេះ សម្តេចនាយករដ្ឋមន្ត្រីលោកចង់ឃើញខ្មែរចេះរួបរួមគ្នា ជាជាងបន្តលាបពណ៌គ្នាទៅវិញទៅមកថា

---

[199]ឯ-ដ-ទំព័រ៤

[200] សារព័ត៌មានគរជំ ប្រចាំថ្ងៃ ឆ្នាំទី២១ លេខ៩៥២ ចេញផ្សាយថ្ងៃសៅរ៍ទី២៦ ខែកញ្ញា ឆ្នាំ២០១៥ ទំព័រ១-២។

ខ្មែរនេះ ឬខ្មែរនោះ។

ជាមួយគ្នានេះសម្តេចតេជោហ៊ុនសែន តែងតែប្រតិកម្មនឹងការរំលោភបំពានពីបរទេសមិនដូចការចោទដូចមជ្ឈដ្ឋានផ្សេងៗទេ។ជាក់ស្តែង កាលពីថ្ងៃទី១ ខែសីហា ឆ្នាំ២០១៦កន្លងទៅ ក្នុងផេកហ្វេសប៊ុក(facebook) សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី ដែលជាភាសាអង់គ្លេសមានឈ្មោះថា Samdech Hun Sen, Cambodian Prime Minister បានសរសេរថា កាលពីម្សិលមិញ នៅពេលខ្ញុំបានចូលរួមផ្តល់ពានរង្វាន់ដល់ជ័យលាភីក្នុងកម្មវិធី "ខ្ញុំជាយុវជនគំរូកម្ពុជា" លើកទី៦ មានអ្នកលេង Facebook ឈ្មោះ Phạm Đức Hiển (ផាម ឌុ៉ក ហៀង) បានចូលមកខំមិន(Comment)ក្នុងផេក (Page) ខ្ញុំថា (លោក ហ៊ុន សែន ក្បត់វៀតណាម)។ កាលពីយប់មិញខ្ញុំបាន Comment ឆ្លើយតបទៅបុគ្គលនោះវិញ។ តែ មកទល់ថ្ងៃនេះ បុគ្គលនោះបានលុប Commentខ្លួនចោលអស់រួមទាំងមតិយោបល់ប្រជាពលរដ្ឋខ្មែរផងដែរ។ ខ្ញុំសូមផូស (Post) ចម្លើយទាំងស្រុងរបស់ខ្ញុំជូនជនរួមជាតិដូចខាងក្រោម។ហេតុអ្វីបានជាលោកនិយាយថាខ្ញុំក្បត់វៀតណាម? តើវៀតណាមជាឪពុកខ្ញុំ ឬជាមហាក្សត្រខ្ញុំឬ? លោកត្រូវដឹងថាអ្នកដែលខ្ញុំត្រូវស្មោះត្រង់គឺជាតិខ្មែររបស់ខ្ញុំ ព្រះមហាក្សត្រកម្ពុជាជាទីសក្ការៈរបស់ខ្ញុំ និងភរិយាជាទីស្រឡាញ់របស់ខ្ញុំ។ វៀតណាមមិនមែន ជាចៅហ្វាយរបស់ខ្ញុំដែលខ្ញុំត្រូវស្មោះត្រង់នោះទេ។ បើលោកជាជនជាតិវៀតណាមរស់នៅកម្ពុជាស្របច្បាប់ត្រូវគោរពច្បាប់កម្ពុជា បើរស់នៅមិនស្របច្បាប់ត្រូវចាកចេញពីកម្ពុជា និងបើរស់

នៅវៀតណាមសុំស្រឡាញ់មេដឹកនាំវៀតណាមទៅ។ ខ្ញុំជាមេដឹកនាំកម្ពុជាដែលមានឯករាជ្យ អធិបតេយ្យភាពដែលត្រូវទំនាក់ទំនងជាមួយមេដឹកនាំវៀតណាមដោយស្មើភាពនិងស្មើសិទ្ធិ។ សុំលោកបញ្ជូនសារនេះជូនមេដឹកនាំវៀតណាមផងបើលោកជាជនជាតិវៀតណាមត្រឹមត្រូវមែនព្រោះ ខ្ញុំស្គាល់ច្បាស់ចរិតមេដឹកនាំវៀតណាមតែងគោរពនូវឯករាជ្យ អធិបតេយ្យភាពរបស់កម្ពុជាខុសពីអាម៉ីអាថោង ដូចលោកនេះឯង sic។ មិនយូរប៉ុន្មានមានជនជាតិវៀតណាមម្នាក់ទៀតឈ្មោះ ង្វៀន វ៉ាន់តៃ (Nguyen Van Tai)បានចូលទៅក្នុងគណនេយ្យហ្វេសប៊ុកសម្ដេចតេជោ ហ៊ុន សែន ម្ដងទៀត ដោយបានសរសេរវាយប្រហារសម្ដេចទាក់ទិននឹងសមុទ្ទចិនភាគខាងត្បូង។ ហើយដែលសម្ដេចបានវាយបកទៅវិញថា ខ្ញុំសូមកោតសរសើរដែលលោកចេះភាសាខ្មែរ ភាសាវៀតណាម និង ភាសាអង់គ្លេស។ ដោយសារខ្ញុំមិនមែនជាជនជាតិវៀតណាមខ្ញុំមិនអាចឆ្លើយតបជាភាសាវៀតណាមបានទេ តែខ្ញុំសូមឆ្លើយជាភាសាខ្មែរនិងភាសាអង់គ្លេស។ ជាការប្រសើរហើយប្រសិនបើលោកយល់ថា សមុទ្ទចិនភាគខាងត្បូងមិនគួរត្រូវបានទាក់ទាញកម្ពុជា និងឡាវឲ្យចូលពាក់ព័ន្ធដូចដែលលោកបានលើកឡើងការជ្រើសរើសរបៀបដោះស្រាយរវាងចិន និងវៀតណាមយ៉ាងណានោះ គឺជាសិទ្ធិសម្រេចរបស់មេដឹកនាំវៀតណាម។ លោកចង់ជ្រើសរើសផ្លូវសង្គ្រាមនិងផ្លូវសន្តិភាពគឺជាសិទ្ធិរបស់វៀតណាមផ្ទាល់។ អ្វីដែលខ្ញុំចង់និយាយទៅកាន់លោក គួរគោរពនូវការសន្យារបស់លោកដែលថាមិនពាក់ព័ន្ធឡាវ ជាពិសេសកម្ពុជា លើបញ្ហាសមុទ្ទចិនខាងត្បូង។ ខ្ញុំសង្ឃឹម

ថា មេដឹកនាំវៀតណាមនឹងទទួលបាននូវការឆ្លើយតបរបស់ខ្ញុំនេះ ហើយអប់រំពលរដ្ឋវៀតណាមកុំឲ្យរំខានដល់ខ្ញុំតទៅទៀត ព្រោះរយៈពេលកន្លងទៅនេះ មានជនជាតិវៀតណាមមួយចំនួនបានចូលមកនិយាយមិនត្រឹមត្រូវចំពោះខ្ញុំ លើទំព័រហ្វេសប៊ុករបស់ខ្ញុំ ក៏ដូចជាប្រជាជនកម្ពុជារបស់ខ្ញុំ ហើយខ្ញុំក៏សូមបញ្ជាក់សារជាថ្មីថា ខ្ញុំជាមេដឹកនាំកម្ពុជាដែលមានឯករាជ្យអធិបតេយ្យភាព និងបូរណភាពទឹកដីដែលស្មើភាព និងស្មើសិទ្ធិជាមួយប្រទេសទាំងអស់រាប់ទាំងជាមួយនឹងវៀតណាមផងដែរ។ ខ្ញុំសូមគូសបញ្ជាក់បន្ថែមថាខ្ញុំមិនមែនជាអាយ៉ងរបស់វៀតណាមដែលត្រូវបម្រើវៀតណាម លើបញ្ហាដែលជាផលប្រយោជន៍របស់វៀតណាម ហើយខ្ញុំមិនមែនជាចៅហ្វាយរបស់វៀតណាមដែរ ខ្ញុំក៏មិនត្រូវឲ្យវៀតណាមមកបម្រើផលប្រយោជន៍នយោបាយរបស់កម្ពុជានោះដែរ។ ជម្លោះអធិបតេយ្យក្នុងសមុទ្ទចិនខាងត្បូង គួរតែត្រូវបានដោះស្រាយដោយសន្តិវិធីរវាងចិន និងវៀតណាមជាជាងការដោះស្រាយតាមសង្គ្រាមដូចដែលលោកបានលើកឡើងក្នុងហ្វេសប៊ុកខ្ញុំSic។

ក្នុងនាមអ្នកស្រាវជ្រាវ ខ្ញុំយល់ឃើញថា ទោះបីយ៉ាងណាក៏ដោយ យើងមិនត្រូវចាត់ទុកវៀតណាមជាសត្រូវនោះទេ។ ការនេះវានឹងនាំឲ្យកើតមាននូវការប្រកាន់ពូជសាសន៍ និងការស្អប់ខ្ពើមគ្នារវាងសាសន៍ទាំងពីរនេះមិនអាចបញ្ចប់បាន ជាលទ្ធផលអាចបង្កឲ្យមានការលាបពណ៌គ្នារវាងអ្នកស្រឡាញ់ និងអ្នកស្អប់ដោយចៀសមិនរួច។ ជាមួយគ្នានេះដែរ តាមរយៈនេះ ខ្ញុំសូមអំពាវនាវដល់ប្រទេសទាំងឡាយក្នុងពិភពលោកនេះ ល្មមដល់ពេល

ឈប់ការឈ្លានពានគ្នាទៅ ជាពិសេស ប្រទេសមានការអភិវឌ្ឍខ្លាំងនៅជិតប្រទេសខ្សោយ ប្រសិនបើគេនៅតែចិញ្ចឹមចិត្តរំលោភបំពានទៅលើប្រទេសទន់ខ្សោយជាលទ្ធផលប្រវត្តិសាស្ត្រនឹងធ្វើឲ្យមនុស្សជំនុស្សក្រោយថាប្រទេសណាមួយនោះជាអ្វី។ល។ចៀសមិនរួចទេ។ វាមានតែការទម្លាក់ចោលមហិច្ឆតាឈ្លានីស និងវាតទីផ្សេងៗចោលទៅ(ប្រសិនបើមាន) ហើយប្តូរមកវិញនូវការរាប់ស្មើមុខស្មើមាត់គ្នាក្នុងឋានៈជាប្រទេសជិតខាងល្អ ដែលជាប្រភពតែមួយគត់នៃសេចក្តីសុខសន្តិភាព ភាពសុខដុមរម្យនាសម្រាប់ប្រទេសភូមិផងរបងជាមួយ។ សូមចងចាំថា ប្រសិនបើយើងលួច ឬប្រើវិធីសាស្ត្រលួចយកទ្រព្យរបស់គេបាននាពេលនេះ ថ្ងៃក្រោយ កូនចៅគេនៅតែចងចាំហើយក៏មិនសប្បាយចិត្តដែរ។

## ៩-សេដ្ឋកិច្ចបញ្ហាជីវភាពរស់នៅ))

បើនិយាយពីជីវភាពសេដ្ឋកិច្ចវិញ ប្រជារាស្ត្រប្រកបរបរធ្វើស្រែចំការលក់ដូរសាច់បន្លែបង្ការ ម្ហូបចំណី ធ្វើនំលក់(នំក្រូច នំកង ដាល់អំបុក នំក្រៀប...) ចំណីឲ្យរស់មួយថ្ងៃទៅមួយថ្ងៃ ហើយរកធ្វើមានធ្វើបាននោះក៏មិនដែរ ឬអ្នកខ្លះនៅរដូវប្រូតកាត់ផលហើយ ពួកគេចេញទៅរកស៊ីនៅរាជធានីនិងនៅតាមខេត្តផ្សេងៗ ជាដើម។ ប្រជារាស្ត្រនៅក្នុងភូមិទាំងបី ភាគច្រើនជាកសិករ ប្រកបរបរកសិកម្មដែលក្នុងនោះ៦% មានមុខរបរបួមផ្សំបន្ថែមទៀតដូចជាលក់ចាប់ហួយ ម៉ាស៊ីនកិនស្រូវ(ខ្នាតតូច) ជាដើម។ យុវជន យុវនារីដែលពេញកម្លាំងក្រៅពីមកបន្តការសិក្សានៅរាជធានីភ្នំពេញ និងទីកកន្លែង

ផ្សេងៗ ពួកគេបានធ្វើចំណាកស្រុក ដូចជាទៅធ្វើការនៅទីឆ្ងាយៗក្នុងព្រះរាជាណាចក្រ ទៅប្រទេសថៃ ម៉ាឡេស៊ី និងប្រទេសកូរ៉េ ។ល។ ប្រជារាស្ត្រភូមិសមរលាវត្រូវបានអ្នកភូមិនានាសង្កេតឃើញថា ជាអ្នកឧស្សាហ៍ព្យាយាមធ្វើស្រែចំការទាំងវស្សា និងប្រាំង។ ប្រព័ន្ធប្រឡាយទឹកភាគច្រើនជីកតាំងពីជំនាន់ ប៉ុល ពត ហើយជំនាន់ក្រោយៗមក ប្រព័ន្ធព្រែកប្រឡាយទាំងនោះ ត្រូវបានធ្វើការស្តារឡើងវិញដើម្បីយកទឹកស្រោចស្រពការធ្វើកសិកម្ម។ ការភ្ជួររាស់ដាស់ដី ច្រូតកាត់ អ្នកភូមិធ្វើដោយម៉ាស៊ីនស្ទើរ១០០ភាគរយហើយសព្វថ្ងៃនេះ។ ប៉ុន្តែគ្រួសារខ្លះក៏នៅតែចិញ្ចឹមគោដដែល។ យើងសង្កេតឃើញដីស្រែចំការមួយចំនួនក៏អាចប្រឈមមុខនឹងការខូចគុណភាព ដោយសារកសិករបានប្រើប្រាស់ជីគីមីច្រើនហួសហេតុពេកពីមួយឆ្នាំទៅមួយឆ្នាំ។ ការនេះ ប្រជាកសិករយើងគួរតែស្វែងយល់ពីការប្រើប្រាស់ពូជស្រូវ ពូជដំណាំ ជីធម្មជាតិ ឬបច្ចេកទេសថែទាំដីធ្លីឲ្យបានត្រឹមត្រូវ ជាដើម។ យើងសូមកោតសរសើរប្រជាកសិករខ្លាំងណាស់ ថ្វីបើផលកសិកម្មរបស់គាត់មិនសូវទទួលបានតម្លៃគាប់ប្រសើរសក្តិសមនឹងការប្រឹងប្រែងយ៉ាងណាក្តី ក៏ពួកគាត់នៅតែព្យាយាមធ្វើយ៉ាងទៀងទាត់មិនដែលខកខានមួយរដូវកាលណាទេ។ អ្នកភូមិសមរលាវ ភូមិសមរខ្មែរ និយាយាយដោយទ្បែក និងជារួមក្នុងឃុំពោធិ៍រំចាកទាំងមូលមានមោទនភាព និងថ្លែងអំណរគុណជាខ្លាំងចំពោះអាជ្ញាធរមូលដ្ឋានតាំងពីឆ្នាំ២០១៤-១៥ មកម្ល៉េះ បានប្រឹងប្រែងសហការជាមួយក្រុមហ៊ុនឯកជនដើម្បីវិនិយោគស្តារប្រឡាយសំខាន់ៗមួយចំនួនផ្គត់ផ្គង់ទឹកដល់ការធ្វើ

ស្រែចំការរបស់ពួកគាត់ ហើយកាត់យកផលស្រូវ ឬបង់ប្រាក់ព្រមព្រៀងគ្នា។

**១០-គមនាគមន៍**

ទឹកដីស្រុកព្រៃកប្បាសនិយាយជារួម និងដោយឡែកឃុំពោធិ៍រំចាក មានផ្លូវគមនាគមន៍ឆ្លងកាត់ខ្វាត់ ខ្វែងពីឃុំមួយទៅឃុំមួយ(ស្រុកព្រៃកប្បាស មាន១៣ឃុំ) ពីភូមិមួយទៅភូមិមួយ(ឃុំពោធិ៍រំចាក)ដែលសម្រួលឲ្យប្រជារាស្ត្រតំបន់នេះបានធ្វើដំណើរទាក់ទងគ្នាយ៉ាងស្រួលរហូតដល់ទីប្រជុំជននានា ជាពិសេសរាជធានីភ្នំពេញ។ ទាក់ទងនឹងផ្លូវចូលពីក្លោងទ្វារភូមិឫស្សីថ្មីដល់វត្តសមរលោវ វត្តសមរមេត្រីមានចម្ងាយប្រមាណជា៤ទៅ៥គីឡូម៉ែត្រ។ ប៉ុន្តែបើគិតពីភូមិឫស្សីនេះឆ្លងកាត់តាមភូមិជម្ពូព្រឹក្ស ជ្រយ ដង្ហិត បន្ទាយរវៀង (ទឹកដីឃុំចំប៉ា)ភូមិសមរលោវ ភូមិសមរចិន ភូមិសមរខ្មែរ ភូមិថ្នល់បត់ (ទឹកដីឃុំពោធិ៍រំចាក)ភូមិពោធិសាក់(ពោធិ៍ចាក់សាក់)ភូមិអូរ ភូមិអំពិលរៀង[201] ភូមិព្រៃព្រាំ និងភូមិទួលពោធិ៍(ទឹកដីឃុំព្រៃកប្បាស)នៃផ្លូវបំបែកវត្តព្រៃកប្បាសនេះមានចម្ងាយផ្លូវប្រវែង១២គីឡូម៉ែត្រ។ ទោះបីយ៉ាងណាក្តី តាំងពីថ្ងៃរំដោះ ៧ មករា ១៩៧៩មកម្ល៉េះ ផ្លូវនៃភូមិសាស្ត្រភូមិសមរលោវ សមរខ្មែរ និងសមរចិន(ឃុំពោធិ៍រំចាក)មិនធ្លាប់មានការជួសជុលជាដុំកំភួនអ្វីទេ។ ពោលគឺផ្លូវទាំងអស់នោះបានស្អាតល្អតែមួយវស្សា ឬពីរវស្សាប៉ុណ្ណោះ ដោយអាជ្ញាធរដែនដីសហការជាមួយប្រជាពលរដ្ឋសហគមន៍ និងព្រះចៅអធិការវត្តបើកការ

[201] ភូមិកំណើតរបស់លោកជំទាវ នព្វ ស៊ីណាវ៉ា ភរិយារបស់ឯកឧត្តមនាយឧត្តមសេនិយ៍ ប៉ុល សារឿន អតីតអគ្គមេបញ្ជាការកងយុទ្ធពល ខេមរភូមិន្ទកម្ពុជា។

ជួសជុលស្ទើរតែរៀងរាល់ឆ្នាំ ជាពិសេស នៅក្នុងរដូវភ្ជុំបិណ្ឌ រដូវកឋិនទាន និង ចូលឆ្នាំខ្មែរ។

កាលពីអំឡុងឆ្នាំ២០០១-២០០២ លោក សេង ប៊ុនធឿន អតីតនាយកខុទ្ទកាល័យក្រសួងអភិវឌ្ឍន៍ជនបទបានស្នើឲ្យគម្រោងមួយជួសជុលក្រាលគ្រួសក្រហមពីភូមិឫស្សីថ្មី ឃុំចំប៉ា រហូតទៅដល់ភូមិទួលពោធិ ឃុំព្រៃកប្បាស មានចម្ងាយប្រវែង១២គីឡូម៉ែត្រដែរ។ កាលនោះផ្លូវនោះបានដំណើរការយ៉ាងលឿន ដោយបានចាក់ដីបង្ហាប់រួចរាល់បម្រុងនឹងក្រាលដីក្រហមទៅហើយ ស្រាប់តែគេប្រាប់ដំណឹងថា គម្រោងនេះអស់ថវិកាហើយ ជាហេតុនាំឲ្យផ្លូវនេះត្រូវទុកចោលឲ្យវិលទៅរកសភាពដើមវិញរហូតមក។

តាងនាមប្រជាពលរដ្ឋក្នុងតំបន់ សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តមបណ្ឌិត ពេជ សោភ័ន រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជារដ្ឋលេខាធិការប្រចាំការក្រសួងការងារ និងបណ្តុះបណ្តាល វិជ្ជាជីវៈ និងជាសហប្រធានក្រុមការងារគណបក្សប្រជាជនស្រុកព្រៃកប្បាស ឯកឧត្តម ហេង សួរ ជារដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានក្រុមការងារគណបក្សប្រជាជន ឃុំពោធិ៍រំចាកដែលបានធ្វើអន្តរាគមន៍ជួយស្តាបនាផ្លូវនេះដែលជូនដំណឹងដោយលោកមេឃុំពោធិរំចាក។ ផ្អែកតាមសេចក្តីជូនដំណឹងដែលចុះហត្ថលេខាដោយលោក ស្រី រ៉េន មេឃុំពោធិ៍រំចាក នាថ្ងៃ៩រោច ខែមាឃ ឆ្នាំរការ នព្វស័ក ព.ស២៥៦១ ត្រូវនឹងថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៨ ផ្សព្វផ្សាយឲ្យប្រជាពលរដ្ឋបានដឹងអំពីបទដ្ឋានផ្លូវពីភូមិក្តីតាហុក

ទៅភូមិសមរខ្មែរចាប់ពីភូមិថ្នល់បត់រហូតទៅដល់ភូមិឫស្សីថ្មី ឃុំចំប៉ា ទល់ផ្លូវជាតិ( ពីផ្សារសែរ៉ាដល់ផ្សារព្រៃល្វា/ទីរួមស្រុកព្រៃកប្បាស ) ៖

១-ទទឹងចាប់ពីអ័ក្ស ឬពាក់កណ្តាលចំនួន៨ម៉ែត្រម្ខាង

២-ការងាររុះរើ វាយកំទេច ឬរំកិលរបង អង្គភាពវិស្វកម្មពន្យារពេលចំនួន១៥ថ្ងៃចាប់ថ្ងៃជូនដំណឹងនេះតទៅ។ តាមរយៈសេចក្តីជូនដំណឹងនេះប្រជាពលរដ្ឋដែលនៅអមសងខាង ឬជាប់ផ្លូវមានបេតិសោមនស្សរីករាយក្រៃលែង ហើយសស្រាក់សស្រាំខិតខំពង្រីកផ្លូវ រំកឹលរបងតាមផែនការភ្លាមៗមិនបង្អង់យូរឡើយ។ ជាលទ្ធផល ផ្លូវនេះនឹងត្រូវបានពង្រីកបានយ៉ាងធំសម្រាប់ត្រៀមការចាក់បេតុង ឬចាក់កៅស៊ូ។ ប៉ុន្តែក្រោយពេលបង្ហាប់រួចតាមគម្រោងថា ផ្លូវនេះនឹងត្រូវក្រាលបេតុង ឬចាក់កៅស៊ូមានទំហំនៅតែតូចស្រដៀងនឹងផ្លូវចាស់ ពោលគឺខ្នងលើមានប្រមាណជាង៦,៤ម៉ែត្របន្តិចបន្តួចប៉ុណ្ណោះដោយរក្សាទុកចំណីផ្លូវនៅតែធំដដែល។ ជាមួយគ្នានេះ សូមប្រជាពលរដ្ឋតាមដងផ្លូវត្រូវចូលរួមរក្សាទំហំផ្លូវដែលបានពង្រីករួចហើយនេះឲ្យធំដដែលដោយកុំធ្វើរបងចូលក្នុងផ្លូវដែលខំពង្រីករួចហើយនោះឲ្យសោះ ពុំនោះសោតអាជ្ញាធរមូលដ្ឋាននឹងមានវិធានការម៉ឺងម៉ាត់ចំពោះអ្នកធ្វើរបងរំលោភចូលផ្លូវ។

## ១- ការផ្លាស់ប្តូរសំណេរភូមិសមរលាវ និង ភូមិសមរខ្មែរ

### ក.អត្ថន័យនៃពាក្យ ស ម រ

ផ្អែកលើខ្លឹមសារនៃការស្រាវជ្រាវទាក់ទងនឹងឈ្មោះភូមិទាំងបីខាង

លើពាក្យថា **សមរភូមិ** ត្រូវបានខ្មែរជំនាន់នោះ (ជំនាន់នៃការកកើតភូមិ) យល់យ៉ាងច្បាស់អំពីអត្ថន័យនៃពាក្យនេះ។ វចនានុក្រមខ្មែរ (Khmer Dictionary) ដែលបោះពុម្ពដោយនគរធំឆ្នាំ២០១០ទំព័រ១២៦៦ បានចារិកថា **សមរ** (១) [ ស: ម: រ: ស: ម៉: រ:] ន. (បា.សំ.)សង្គ្រាមទ័ព។ **សមរ** (២) [ ស: ម៉: ] ន. (សំ.ស្មរ.ស្មរណ) ការរលឹក, ការចងចាំ, ដំណើរនឹកឃើញមិនចេះភ្លេច, សេចក្តីស្រឡាញ់អស់ពីចិត្ត។ គុ. ជាទីស្រឡាញ់អស់ពីចិត្ត,ដែលស៊ូស្លាប់ស៊ូរស់ជាមួយគ្នា(ប្រើក្នុងពាក្យកាព្យចំពោះតែលើស្ត្រី)។ ឧទាហរណ៍ សមរថ្លៃ សមរមេត្រី ឱ្ងសមរ កែវសមរ មាស សមរ។ល។ ព. កា.) ហៃកែវសមរមិត្រ ចូរកុំគិតពីក្តីក្រ ព្រោះយើងប្រព្រឹត្តល្អ តំណរសុខមុខតែមាន[202]។ (សូមអាន និងស្តាប់បទចម្រៀងក្នុងឧបសម្ព័ន្ធទី១០) តាមសម្តេចព្រះសង្ឃរាជ ជួន ណាត អានថា សៈម៉ មានន័យថា ជាទីតាំងប្រយុទ្ធរបស់សត្រូវ **សមរភូមិ**។ រីឯ ពាក្យថា ភូមិ មានន័យថា ទីកំណើត ស្រុកកំណើត ឬភូមិកំណើត។ **ភូមិសមរលាវ** ជាសមរភូមិរបស់លាវ ភូមិ**សមរខ្មែរ** ជាសមរភូមិរបស់ខ្មែរ និងដូចគ្នាដែរ **ភូមិសមរចិន** ឬអាចថា ជាការនឹករលឹក ការស្រឡាញ់រាប់អានគ្នា ការមិនបំភ្លេចគ្នា ការស៊ូស្លាប់ ស៊ូរស់ជាមួយគ្នានៃខ្មែរ លាវ ចិន ឬនៃអ្នកភូមិទាំងបី។

តាមផែនទីភូមិសាស្ត្ររបស់ស្រុកព្រៃកប្បាសដែលគូស និងបោះពុម្ព

---

[202] វចនានុក្រមខ្មែរ (Khmer Dictionary) រោងពុម្ពនគរធំ ឆ្នាំ២០១០ទំព័រ១២៦៧។

ប្រើប្រាស់ឡើងវិញជាផ្លូវការនាឆ្នាំ២០០៦ សរសេរថា សមរលាវ [ S a ma r - l e a v ] សមរខ្មែរ [ S a ma r k h me r ] ។ ចំពោះភូមិ សមរចិនគ្មានការ កត់ត្រាក្នុងដែនដីរដ្ឋបាលទៀតទេមានតែការហៅការស្គាល់ឈ្មោះរបស់អ្នក ស្រុកនេះប្រចាំថ្ងៃតែប៉ុណ្ណោះ។

ភូមិសមរលាវ =សមរ+លាវ

ភូមិសមរខ្មែរ =សមរ+ខ្មែរ

ភូមិសមរចិន =សមរ+ចិន

សមរលាវ ( Samarleav/ Laos battle field)

សមរខ្មែរ (Samarkhmer/ Khmer battle field)

សមរមេត្រី (Samarmetrey/ Friendly or Remembrance battle field)

សមរចិន (Samarchin /Chinese battle field)។

តាមអត្ថន័យនេះ ភូមិខាងលើជាសមរភូមិនៃជនជាតិទាំងបី( លាវ ខ្មែរ និងចិន) ឬទីកន្លែងដែលមានសេចក្តីនឹករលឹក[203]គ្នារវាងជាតិសាសន៍ទាំងបី ក៏ថាបាន។ ភូមិសមរចិនមានប្រជារាស្ត្រតិចជាងគេ។ ភូមិនេះមិនមានវត្ត អារាម ឬសាលារៀនទេ។ អាជ្ញាធរបានបញ្ចូលភូមិនេះ ជាមួយភូមិសមរខ្មែរ ទៅហើយ។ បញ្ហាមួយទៀត ខ្ញុំយល់ថា យើងមិនគួររំលាយភូមិនេះជាមួយភូមិ ណាមួយទៀតទេ។ ពីព្រោះប្រសិនបើគិតឲ្យវែងឆ្ងាយបន្តិច វាជាតំបន់អនុ ស្សាវរីយ៍ ឬអាចនិយាយថា ជាភូមិប្រវត្តិសាស្ត្រក៏ថាបាន។ ទាក់ទងនឹងសំ

[203] ឯ-ដ-ទំព័រ១២៦៧។

ណោរនៃភូមិទាំងបីនេះ គេ(អ្នកស្រុក)បានសរសេរតាំងពីបុរាណកាល ចារឭលើថ្ម សរសេរក្រោមរូបគំនូរ និងលើក្រាំងផ្សេងៗ ថា ភូមិសមរលាវ ភូមិសមរខ្មែរ និងភូមិសមរចិន។ ការនេះមានអត្ថន័យគ្រប់គ្រាន់ ហើយប្រជារាស្ត្រគ្រប់ជំនាន់ យល់បានដែរ។

## ខ.ការផ្លាស់ប្តូរនៃសំណោរពីសមរ ទៅជា សម៉

នៅសុខៗស្រាប់តែសំណោរឈ្មោះភូមិ **សមរ**លាវ ភូមិ **សមរ**ខ្មែរ មានការសរសេរខុសទៅជាសរសេរថាភូមិ**សម៉**លាវ ភូមិ**សម៉**ខ្មែរនៅលើលិខិតស្នាមរដ្ឋបាល និងអត្តសញ្ញាណប័ណ្ណទៅវិញ។ ប៉ុន្តែ សំណោរទាំងនេះ ខុសតែក្នុងក្របខណ្ឌរដ្ឋបាលនៃអាជ្ញាធរដែនដីទេ ចំពោះក្លោងទ្វារវត្ត ក្លោងទ្វារសាលា និងបញ្ជីស្នាមផ្សេងៗក្របខណ្ឌសាលារៀនគ្រប់ភូមិសិក្សានៅរក្សាភាពត្រឹមត្រូវដដែលទាំងសមរលាវ និងសមរខ្មែរ ឬសមរមេត្រី។ ខ្ញុំបានតាមដានរឿងនេះយ៉ាងយកចិត្តទុកដាក់បំផុតដោយសួរនាំរកមូលហេតុផ្សេងៗ និងព្យាយាមសុំឲ្យអាជ្ញាធរធ្វើអន្តរាគមន៍ដើម្បីកែតម្រូវវិញ? តាមមន្ត្រីមូលដ្ឋានឲ្យដឹងថា លោកបានដឹង ហើយក៏បានសុំទៅថ្នាក់លើដើម្បីធ្វើការកែប្រែដែរ ប៉ុន្តែមិនបានសម្រេចសោះ។ ការសរសេរខុសនេះ បានធ្វើឲ្យយុវជន និងអ្នកសិក្សាជាច្រើនមានការរកាំចិត្ត។ ឈ្មោះភូមិសមរលាវ សមរខ្មែរ សមរចិនជាឈ្មោះដែលត្រូវបានដាក់តាំងពីបុរាណកាលនៃការកកើតភូមិមកម្ល៉េះ ហើយសុទ្ធតែមានអត្ថន័យ និងអាចទុកជាប្រវត្តិសាស្ត្របាន ពោលគឺមិនមែនហៅ ឬដាក់ឈ្មោះតាមតែការនឹកឃើញនោះទេ។

អាស្រ័យហេតុនេះ ប្រសិនបើឈ្មោះទាំងនេះត្រូវប្តូរសំណោរ វាពិតជាគួរឲ្យសោកស្តាយណាស់។ យើងមិនត្រូវបណ្តោតបណ្តោយឲ្យឈ្មោះនេះ

បាត់បង់ ឬប្រែក្លាយខុសខ្លឹមសារដើមទេ ផ្ទុយទៅវិញយើងត្រូវតែរួមគ្នាថែរក្សា និងអភិរក្សកេរដំណែលនៃមនុស្សជំនាន់មុនឲ្យបានគង់វង្សនិងមានកេរឈ្មោះល្អជានិច្ចអង្វែងតទៅ។

កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៤ ខ្ញុំបានជជែកជាមិត្តភាពជាមួយអ្នកគ្រូ រី គន្ធឿន[204]តាមបណ្តាញសង្គមហ្វេសប៊ុក(Facebook)ថា នៅពេលខ្ញុំទៅដល់ឃុំពោធិ៍រំចាក ប្រសិនបើមានគេនិយាយអ្វីមិនល្អអ្នកភូមិសមរលាវ ខ្ញុំមិនចង់ឮទេ(ខ្ញុំអ្នកភូមិសមរលាវ)។ ករណីខ្ញុំទៅដល់ស្រុកព្រៃកប្បាស ហើយមានអ្នកពីឃុំពោធិ៍រំចាក ខ្ញុំក៏ដូច្នេះដែរ(ខ្ញុំអ្នកឃុំពោធិ៍រំចាក)។ ដូចគ្នាដែរនៅពេលខ្ញុំទៅដល់ខេត្តតាកែវ មានអ្នកនិយាយកោតសរសើរដល់អ្នកស្រុកព្រៃកប្បាស ខ្ញុំមានអារម្មណ៍រំភើប ពីព្រោះខ្ញុំជាអ្នកស្រុកព្រៃកប្បាស)។ ក្នុងន័យនេះ ខ្ញុំទៅដល់រាជធានីភ្នំពេញ មានគេនិយាយពីខេត្តតាកែវ ខ្ញុំចាប់អារម្មណ៍(ខ្ញុំជាអ្នកខេត្តតាកែវ)។ ពេលខ្ញុំចូលរួមប្រជុំនៅបរទេស ឬជាមួយបរទេស ហើយអង្គប្រជុំគេបានកោតសរសើរពីប្រជាពលរដ្ឋ ឬអ្នកដឹកនាំខ្មែរ ពីអង្គរវត្ត ។ល។ ខ្ញុំពិតជាមានមោទនភាពក្រៃលែង និងញញឹមបិទមាត់មិនជិតឡើយ។ ខ្ញុំតែងតែនិយាយលេងជាមួយនិស្សិត ឬសហការីរបស់ខ្ញុំថា ប្រសិនបើគេមិនចូលចិត្តយើង ៗកុំព្យាយាមស្អប់គេវិញឲ្យសោះ។ ប៉ុន្តែយើងត្រូវតែស្រឡាញ់ ចេះសាមគ្គី ចេះជួយអាសារ និងចេះថែរក្សាភូមិកំណើតស្រុកទេសរបស់យើង តើនេះជាទស្សនៈស្រុកកំណើត ឬមាតុភូមិនិយមចង្អៀតចង្អល់ឬ? ឬក៏វាជាជាតិនិយមជ្រុល? មិនមែនជាគំនិតចង្អៀតចង្អល់ ហើយក៏មិនមែនជាជាតិ

---

[204] លោកស្រីជាកូនស្រីបង្កើតរបស់លោកមេឃុំ ស្រី រ៉ន និងជានាយិការរងវិទ្យាល័យសមរលាវ។

និយមជ្រុលដែរ។ យើងមិនចង់ឃើញអ្នកណាម្នាក់យកអ្វីជារបស់យើង ឬធ្វើអ្វីខុសមកលើយើងទេ។

នៅលើលោកនេះ អ្នកណាក៏ស្រឡាញ់ភូមិកំណើតរបស់ខ្លួនដែរ ប៉ុន្តែគ្រាន់តែកាលៈទេសៈខ្លះបានជំរុញឲ្យបុគ្គលមួយចំនួនរបូតធ្លាក់អស់នូវករណីខាងលើទៅវិញ។ ការសរសេរឈ្មោះភូមិសមរលោវ ឬសមរខ្មែរ ឬសមរចិនមិនត្រឹមត្រូវ យើងចង់មានការកែប្រែឲ្យទៅជាត្រឹមត្រូវដើម្បីឲ្យមានន័យគ្រប់គ្រាន់ដូចអ្វីដែលអតីតកាលធ្លាប់មាន។ ប្រាកដណាស់ មានយុវជន អ្នករៀនសូត្របញ្ញវន្តក្មេងៗជាច្រើនបានមកពិគ្រោះយោបល់ជា មួយខ្ញុំអំពីរឿងនេះជាច្រើន ..ខ្ញុំទាល់គំនិត មិនដឹងជាត្រូវនិយាយត្រឹមថ្នាក់ណាទើបបញ្ហានេះត្រូវបានកែតម្រូវ វិញទេ។ ពីព្រោះខ្ញុំធ្លាប់លើករឿងនេះទៅជួបអ្នកពាក់ព័ន្ធរួចអស់ហើយដែរ។ នៅពេលខ្ញុំសួរទៅលោកមេភូមិ ៗឆ្លើយថាឃុំ សួរទៅឃុំ ៗថាស្រុក សួរទៅស្រុក ៗថាខេត្ត។ល។ ម្តងថានគរបាលអត្តសញ្ញាណប័ណ្ណ ម្តងថាខាងគណៈកម្មាធិការរៀបចំការបោះឆ្នោត(គជប)ថ្នាក់ឃុំ ជាដើមដែលជាអ្នកនាំឲ្យមានការសរសេរខុសដូចសព្វថ្ងៃនេះ។ តាមការសង្កេតរបស់ខ្ញុំ ករណីខាងលើនេះមន្ត្រីមូលដ្ឋានក៏លោកមានការលំបាកណាស់ដែរ ពីព្រោះកំហុសឆ្គងនេះអាចផ្តើមចេញពីកំហុសអចេតនាសុទ្ធសាធ ហើយក្លាយទៅជា**ទម្លាប់** ប្រើប្រាស់ទាំងមិនបានចាប់អារម្មណ៍ដល់។ ក្រោយពីមានការសួរនាំ សើរើ ទើបដឹងទៀតថា អ្វីៗវាហួសពេលអស់ទៅហើយ។ នៅពេលដឹងការនេះភ្លាម ក្នុងនាមអាជ្ញាធរដែនដីគួរតែសរសេរលិខិតផ្លូវការទៅថ្នាក់លើតាមឋានានុក្រម (សាលាស្រុក សាលាខេត្ត) ដើម្បីសុំការកែប្រែឲ្យដូចដើមវិញភ្លាមៗជាការស្រេច។ ខ្ញុំចាប់ផ្តើមស្រាវជ្រាវព័ត៌មាន និងស្វះស្វែងរកអន្តរាគមន៍ដោយរំពឹងថា បញ្ហានេះនឹងត្រូវបានធ្វើការកែសម្រួលបាន។ ដោយយល់ឃើញថា

ព័ត៌មានដែលឆ្លើយបញ្ជាក់មកវិញសុទ្ធតែស្រពិចស្រពិលនោះ ខ្ញុំក៏សម្រេចចិត្តធ្វើកិច្ចការនេះជាផ្លូវការតែម្ដង ហើយ ទោះបីមិនបានលទ្ធផលក៏ត្រូវតែធ្វើដែរ ពីព្រោះមិនអាចទុកឈ្មោះនេះឲ្យបន្តសរសេរខុសជារៀងរហូតអញ្ចឹងទេ នាំឲ្យមនុស្សជំនាន់ក្រោយនៃភូមិទាំងបីនេះមុខជាបន្ទោសថា យើង(មនុស្សបច្ចុប្បន្ន)នេះ ជាអ្នកបណ្ដោតបណ្ដោយឲ្យមានកំហុសនេះកើតឡើង។ អ្វីដែលជាកេរមរតករបស់មនុស្សជំនាន់មុនរបស់ដូនតាយើង មិនគួរធ្វើឲ្យបាត់បង់ឡើយ។ វាជាវិប្បសារីមួយរបស់យើងជាកូនចៅជំនាន់ក្រោយ។

នៅពេលដែលខ្ញុំធ្វើកិច្ចការនេះ អ្នកខ្លះនិយាយកំប្លែងជាមួយខ្ញុំថា រឿងអញ្ចឹងៗក៏រវល់ដែរ កុំទៅខ្វល់ វាទៅជាអ្វីទៅៗ។ ខ្ញុំយល់ផ្ទុយពីគាត់ដោយចចែសថា ចុះប្រសិនបើខ្ញុំសរសេរ ឬក៏ហៅឈ្មោះលោកខុសឧទាហរណ៍លោកឈ្មោះ **ផុន សុខ** ហើយគេសរសេរថា **ផន់ សុក** តើលោកព្រមទេ? រិទ្ធិច័ន្ទថា គេសរសេរថា រឹត **ចាន់ថា** និងឬ **សម វីរៈ** សរសេរថា **សំ វីរក្ស** តើលោកព្រមទេ? គ្រាន់តែលិខិតអញ្ជើញលោកចូលរួមមង្គលការសរសេរឈ្មោះលោកខុសផង លោកអាចអន់ចិត្តបាត់ទៅហើយ? នេះមិនទាន់គិតដល់ចេតនាផ្លាស់ប្ដូរ ឈ្មោះរបស់លោកផង..ស្វាត់ឈឹង!។ ក្រោយពីការស្រាវជ្រាវល្អិតល្អន់មក ទើបខ្ញុំដឹងថាឈ្មោះភូមិទាំងពីរដែលសរសេរខុសនេះត្រូវបានកត់ត្រាបញ្ចូលក្នុងប្រកាសរបស់ក្រសួងមហាផ្ទៃតាំងពីឆ្នាំ២០០២ម្ល៉េះ(សូមមើលឧបសម្ព័ន្ធទី១)។ ការលុប ឬបាត់បង់វាស្រួល ប៉ុន្តែទាមទារយកមកវិញទេដែលពិបាកនោះ។ បានសេចក្ដីថា ប្រសិនបើចង់ឲ្យមានការកែតម្រូវ ឬមាននីតិសម្បទាវិញ វាទាល់តែមានប្រកាសរបស់រដ្ឋមន្ត្រីសាមីក្រសួងមហាផ្ទៃវិញ ទើបអាចទៅរួច។ ខ្ញុំមានការរកាំចិត្តណាស់ចំពោះរឿងនេះ ហើយនៅតែនឹកស្ដាយថា មិនគួរឲ្យមានរឿងនេះកើតឡើងចំពោះភូមិកំណើតជាទីស្រឡាញ់

របស់ខ្ញុំសោះ។

នៅថ្ងៃទី១៥ខែមិថុនាឆ្នាំ២០១៥ឯកឧត្តមសខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវបានព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូងជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាបានប្រទានបរមងារដ៏ខ្ពង់ខ្ពស់ជា **សម្តេចក្រឡាហោម**។

ខ្ញុំបានសរសេរលិខិតពីរគោរពជូនទៅសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៥។ ទី១ ជាលិខិតជូនពរសម្តេច និងទី២ ជាលិខិតសុំទោសសម្តេចដើម្បីសុំអន្តរាគមន៍អំពីបញ្ហានេះ(សូមមើលឧបសម្ព័ន្ធទី១)។

ប្រសិនបើយើងមើលប្រវត្តិសាស្ត្រខ្មែរឃើញថា ភូមិសមរលាវ ភូមិសមរខ្មែរ និងភូមិសមរចិន មានអាយុកាលជាង៤០០ឆ្នាំដោយចាប់រាប់តាំងពីក្រោយឆ្នាំ១៦២០ នៅក្រោយពេលដែលព្រះរាជាលាវបានបបួលព្រះរាជាខ្មែរដល់ដំរីក្នុងរាជស្តេចព្រះបរមិន្ទរាជា គឺនៅក្រោយវត្តមានលាវចូលមកដល់ទឹកដីខ្មែរនៃព្រឹត្តិការណ៍បញ្ចល់ដំរី។ នៅក្រោយពេលបញ្ចល់នេះ ដំរីខ្មែរបានឈ្នះដំរីរបស់ប្រទេសលាវ នាំឲ្យព្រះមហាក្សត្រខ្មែរអនុវត្តកិច្ចសន្យានៃមេដឹកនាំទាំងពីរដែលថា ប្រសិនបើដំរីនគរណាចាញ់ នគរនោះនឹងក្លាយជាចំណុះ។ ដូច្នេះ ជនជាតិលាវទាំងមួយពាន់នាក់ដែលហែរដំរីមកដល់នេះ ត្រូវឃាត់ឲ្យនៅបម្រើខ្មែរទុកតែនាម៉ឺនពីរនាក់ឲ្យទៅថ្វាយដំណឹងដល់ព្រះមហាក្សត្ររបស់ខ្លួនតែប៉ុណ្ណោះ។ យើងមិនដឹងច្បាស់ទេថាពាក្យ **លាវ** ដែលក្រោយមកបានតាំងទីលំនៅហើយឈ្មោះថា ភូមិសមរលាវនេះ ជា**លាវ** ដែលត្រូវបញ្ជូនមកភាគខាងត្បូងដោយព្រះរាជាខ្មែរ ឬក៏ជា**លាវ** ដែលបានចេញចូលប្រទេសខ្មែរ

តាមសំពៅសម័យនោះក្នុងបុព្វហេតុពាណិជ្ជកម្មដែរ។ ទោះបីយ៉ាងណាក៏ដោយ រហូតមកដល់បច្ចុប្បន្ននេះ អ្នកភូមិសមរលាវទាំងអស់សុទ្ធតែជាខ្មែរ ឬខ្មែរកាត់ចិន(កូនចៅចិន) ហើយមិនមានប្រជារាស្ត្រណាម្នាក់អះអាងថា ខ្លួនជាលាវ ឬដឹងថាទំនៀមទម្លាប់ជនជាតិលាវត្រូវគោរពដូចម្ដេចផងទេ លើកលែងតែព័ត៌មានទទួលបានពីលោកគ្រូ ហុក ខេងហៅ ជ្រឹង ដែលជាគ្រូបឋមសិក្សាសមរលាវម្នាក់ដែលបានចូលនិវត្តន៍ទើបដឹងថា នៅក្នុងវត្តសមរលាវមាន រោង(ខ្ទម)យាយលាវមួយកន្លែង។ លោកបានបញ្ជាក់ទៀតថា ប្រសិនបើមានកូនអ្នកស្រុកណាក្ដៅខ្លួន គេនិយមបន់ស្រន់សុំឲ្យលោកយាយលាវជួយឲ្យជាសះស្បើយ ហើយពេលបានជាសះស្បើយហើយ គេសែន(ថ្វាយបំណន់)តែប្រហុកជុត និងបាយដំណើបតែប៉ុណ្ណោះ។

ស្រដៀងគ្នានេះដែរ លោក គៀក ជ្រុន អតីតសិស្សបឋមសិក្សាសមរលាវ បានបញ្ជាក់ថា ភូមិសមរលាវត្រូវសរសេរថា **ស ម រ លា វ** មិនមែន **សម៉លាវ** ទេ។ កាលនៅរៀនគ្រូរបស់លោកឈ្មោះ ពេជ្រ សាអ៊ុំ[205] បានពន្យល់ថា ភូមិសមរលាវ ជាសមរភូមិរបស់លាវ ភូមិសមរខ្មែរជា សមរភូមិរបស់ខ្មែរ និងភូមិសមរចិន ជាសមរភូមិរបស់ចិន។ នៅរបងវត្តសមរលាវប៉ែកខាងជើងជាប់សាលាឆាន់មានដើមពោធិ៍ងាប់មួយដើម ពេលសិស្សធ្វើពលកម្មសាលា ព្រះតេជគុណ ប្រាក់ សុខ ហៅ យ៉ង ជាព្រះគ្រូសូត្រស្ដាំ បានប្រើសិស្សឲ្យទៅកាប់គាស់ ឫសដើមពោធិ៍ដែលងាប់នោះ។ ពេលជីកដីទៅ គេបានឃើញឆ្អឹងខ្មោច។ ព្រះតេជគុណ ប្រាក់ យ៉ង បានដីកាប្រាប់សិស្សនៅពេលនោះថា នេះជាឆ្អឹងខ្មោចលាវ។ កន្លែងហ្នឹងជាសមរភូមិលាវ។ ព្រះអង្គបានប្រាប់ឲ្យពួកសិស្ស

---

[205] លោកបានជួបផ្ទាល់ជាមួយគាត់នៅខេត្តព្រះវិហារ ហើយដឹងថា លោកមានតួនាទីជាអតីតសមាជិកក្រុមប្រឹក្សាខេត្តព្រះវិហារ។

ទៅរកបាយដំណើប និងប្រហុកដុតមកសែនព្រេនឲ្យគេនៅទីនេះ។

បែរមកនិយាយអំពីលិខិតទាំងពីរនេះវិញ វាត្រូវបានលោកឧត្តមសេនីយ៍ឯកណុបនរិទ្ធ ជាអ្នកនាំយកទៅកាន់ខុទ្ទកាល័យសម្តេចក្រឡាហោម ហើយក៏ជាក័ព្វសំណាងដែរ ដែលនៅទីនោះខ្ញុំបានស្គាល់និងរាប់អានមិត្តម្នាក់ ឯកឧត្តម ថាច់ វណ្ណៈ ជាជំនួយការសម្តេចក្រឡាហោម ស ខេង ម្នាក់ទៀត បន្ទាប់ពីបានយល់អំពីបំណង ប្រាថ្នារបស់ខ្ញុំហើយ លោកបានខំជួយតាមដានលិខិតនេះយ៉ាងចិត្តទុកដាក់ និងទទួលខុសត្រូវខ្ពស់ណាស់រហូតទទួលបានលទ្ធផលគួរជាទីគាប់ចិត្តនិងមោទនភាពបំផុត។ ចំពោះលិខិតទី១ ខ្ញុំមិនបានទទួលត្រឡប់វិញពីសម្តេចក្រឡាហោមវិញទេ។ ប៉ុន្តែលិខិតទី២ ដែលសុំឲ្យសម្តេចជួយធ្វើអន្តរាគមន៍សរសេរឈ្មោះភូមិទាំងបីតាមសំណេរដើមវិញជាសំ-ណេរត្រឹមត្រូវនោះក្រសួងបានចាត់ការជាបន្ទាន់។ យោងតាមស្មារតីនៃលិខិតនេះ ក្រសួងបានចេញលិខិតមួយច្បាប់លេខ១៥៤១សជណ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ដោយស្នើឯកឧត្តមបណ្ឌិត្យសភាចារ្យ ព្រុំ ម៉ុល ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរជួយពិនិត្យ និងសិក្សាស្រាវជ្រាវចំពោះការផ្លាស់ប្តូរសំណេរឈ្មោះភូមិពី "សម៉រលាវ"មក "សមរលាវ"ឲ្យបានត្រឹមត្រូវដើម្បីក្រសួងមហាផ្ទៃមានមូលដ្ឋានគ្រប់គ្រាន់និងច្បាស់លាស់ក្នុងការពិនិត្យនិងសម្រេច។ (សូមមើលឧបសម្ព័ន្ធទី៥)។

## ២- ការសម្ភាសន៍អំពីប្រវត្តិនៃការសរសេរឈ្មោះភូមិសមរលាវ

ក្នុងនាមជាស្ថាប័នជំនាញខាងភាសាខ្មែរ អ្នកប្រាជ្ញមួយក្រុមនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ ត្រូវបានចាត់ឲ្យចុះទៅបំពេញបេសកកម្មនៅភូមិសមរលាវ ភូមិសមរខ្មែរ និងភូមិសមរចិននាថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៥ ដើម្បីស្វែងរកការពិតស្រាវជ្រាវតាមរយៈការសួរដេញដោលរកប្រវត្តិរឿងរ៉ាវដែល

កើតឡើងនៅក្នុងតំបន់តែម្តង។ ការជួបជុំជាមួយព្រះចៅអធិការវត្តសមរលាវ ព្រឹទ្ធាចារ្យដែលមានវ័យចំណាស់ៗនៅក្នុងវត្តសមរលាវ ឃុំពោធិ៍រំចាក ស្រុកព្រៃកប្បាស ខេត្តតាកែវតាមលិខិតបញ្ជាបេសកកម្មលេខ៣០៣ /១៥ កជភខ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ដឹកនាំដោយឯកឧត្តមបណ្ឌិត នៅ ស៊ុន អនុប្រធានប្រចាំការក្រុមប្រឹក្សាជាតិភាសាខ្មែរ ឯកឧត្តមបណ្ឌិត សន ពៅ អគ្គលេខាធិការក្រុមប្រឹក្សាជាតិភាសាខ្មែរ ឯកឧត្តមបណ្ឌិត ថៅ គឿន អគ្គលេខាធិការរងក្រុមប្រឹក្សាជាតិភាសាខ្មែរ ឯកឧត្តម ប៊ុត សុម៉េត អគ្គលេខាធិការរងក្រុមប្រឹក្សាជាតិភាសាខ្មែរ និងលោក លាង សុភាព ប្រធានផ្នែករដ្ឋបាលបុគ្គលិក និងហិរញ្ញវត្ថុ នៃក្រុមប្រឹក្សាជាតិភាសាខ្មែរ។ ក្នុងឱកាសនោះ ក្រុមការងារបានសួរនាំអ្នកចូលរួមទាំងអស់ម្នាក់ម្តងៗដូចតទៅ៖

១-លោក សៅ ស៊ិន អាយុ៧៥ឆ្នាំ ជាប្រធានគណៈកម្មការវត្តសមរលាវបានមានប្រសាសន៍ថា ទាក់ទងនឹងឈ្មោះភូមិសមរលាវនេះ តាំងពីលោកធំដឹងក្តីបានចូលរៀនជាមួយគ្រូជាព្រះសង្ឃ ហើយចេះអក្សរពេលណាឃើញតែឈ្មោះ ភូមិសមរលាវនេះ គេសរសេរតែ ស ម រ លា វ អញ្ចឹង។

២-លោក មួយ គុនអេង ជាប្រធានភូមិសមរលាវបានមានប្រសាសន៍បំភ្លឺថា តាំងពីធំដឹងក្តី និងចូលបម្រើការងារមក ភូមិសមរលាវ គឺសរសេរថា ស ម រ លា វ ទើបតែប្រហែលនៅឆ្នាំ២០០១-២០០២មក ស្រាប់ តែមានការកែប្រែសរសេរខុសពីសំណេរដើមខាងលើទៅជាសរសេរថា សម៉រលាវ វិញ។ លោកខំនិយាយជាមួយ មន្ត្រីធ្វើអត្តសញ្ញាណប័ណ្ណតែគេមិនស្តាប់លោកសោះ រហូតមក ដល់សព្វថ្ងៃខុសច្រើនទៅៗ។

៣-លោក សៅ ឈឿង[206] អាយុ៧១ឆ្នាំ និង៤-លោក ហុក ខេង ៦៥ ឆ្នាំបានរៀបរាប់ដូចអ្វីដែលលោកបានធ្វើអត្ថាធិប្បាយរួចហើយនៅផ្នែកខាងលើនៃសៀវភៅនេះ។

៥-លោក សុខ ឈួន[207] ៦៧ឆ្នាំ ប្រជាពលរដ្ឋម្នាក់ទៀតបានមានប្រសាសន៍ថា លោកប្រាកដណាស់ គ្រូបង្រៀនជាព្រះសង្ឃ លោកឲ្យសរសេរឈ្មោះភូមិ ស ម រ លា វ តែអញ្ចឹងគឺមិនដែលសរសេរថា សម៉រលាវ ដូចសព្វថ្ងៃនេះទេ។ លោកធ្លាប់ត្រូវរំពាត់ពីព្រះគ្រូដោយសារការសរសេរខុសដូចសព្វថ្ងៃនេះ។

៦- លោក ប៊ី ស៊ន ជាសមាជិកគណៈកម្មការវត្តសមរលាវនេះបានការពារថា ឈ្មោះភូមិសមរលាវដែលសរសេរសព្វថ្ងៃនេះថា សម៉លាវ នេះ គឺមិនត្រឹមត្រឹមទេ។

៧-លោក ប្រាក់ សម្បត្តិ ជាសមាជិកក្រុមប្រឹក្សាឃុំពោធិ៍រំចាកមួយរូបក្នុងចំណោមសមាជិកក្រុមប្រឹក្សាចំនួន៧រូបបានគូសបញ្ជាក់ថា លោកខិតខំសុំឲ្យមានការកែប្រែឈ្មោះភូមិពី ស ម៉ លា វ ដែលខុសនេះមកជា ស ម រ លា វ ដែលត្រឹមត្រូវណាស់តាំងពីថ្នាក់ឃុំ ថ្នាក់ស្រុក(អភិបាលស្រុក) និងថ្នាក់ខេត្តទៀត។ ប៉ុន្តែមិនទទួលបានជោគជ័យទេ(មិនដឹងលោកមានលិខិតជាលាយលក្ខណ៍អក្សរ ឬក៏តាមវិធីណាទេ) ហើយក៏មិនដឹងថា ត្រូវធ្វើយ៉ាងម៉េចទៀតដែរ។ ករណីនេះ មិនមែនត្រឹមតែភូមិសមរលាវមួយតែ គឺភូមិសមរខ្មែរក៏ខុស

[206] លោកបានជួយកិច្ចការស្រាវជ្រាវសៀវភៅនេះយ៉ាងច្រើនទាក់ទងនឹងប្រវត្តិភូមិទាំងបី។

[207] លោកបានជាប់ឆ្នោតជាជំទប់ទី២នៃឃុំពោធិ៍រំចាកនៃការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤ប្រព្រឹត្តិទៅនាថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៧ ហើយនិងបាត់បង់ទៅវិញ បន្ទាប់ពីសាលដីកាលេខ៣៤០ (ធ)ស្តីពីការរំលាយគណបក្សសង្គ្រោះជាតិ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧

ដែរ។ លោកបន្ថែមទៀតថា ភូមិមួយទៀត គឺភូមិអង្គរវាយ [ អង្គ វាយ មិនមែនអានថា អង្គរ វាយ ទេ] ក៏សរសេរខុសពីអ្វីដែលជារបស់ម្ចាស់ស្រុកដែរ គឺប្រែពីសរសេរថា អង្គរវាយ ទៅជា **អង់រវាយ**។ ការនេះបានធ្វើឲ្យអ្នកស្រុកខ្លះលោកខឹងសម្បារ និងធ្វើការតវ៉ាដូចភូមិរបស់យើងដែរ តែមិនដឹងជាទៅនិយាយជាមួយអ្នកណា។ លោក ប្រាក់ សម្បត្តិ បានស្នើដោយទទូចសុំឲ្យថ្នាក់លើជួយកែប្រែការសរសេរឲ្យបានត្រឹមត្រូវដូចលោកបណ្ឌិត សេង ប៊ុនធឿន ស្នើសុំនេះផង ពីព្រោះលោកពិបាកឆ្លើយនឹងប្រជាពលរដ្ឋណាស់ ជាពិសេសជាមួយសិស្សសាលា។

៨-លោក ឡាច ស្រ៊ី នាយកសាលាបឋមសិក្សាតាកាហាស៊ីសមរមេត្រី បានសំដែងការភ្ញាក់ផ្អើលថា លោកមិនដឹងថា ការសរសេរឈ្មោះខុសបែបនេះចេញមកពីណា លោកសង្កេតឃើញការប្រែប្រួលនេះ កើតឡើងប្រហែលនៅឆ្នាំ២០០១ ឬ ២០០២។ លោកស្នើសុំថ្នាក់លើជួយកែសម្រួលពីការសរសេរដូចសព្វថ្ងៃឲ្យដូចសំណេរដើមវិញ។ លោកបានសំដែងការលំបាកនៅចំពោះមុខគណៈប្រតិភូថា ឥឡូវនេះ បញ្ជីឈ្មោះសិស្សនៅសាលារៀនសរសេរថា សមរខ្មែរ សមរលោរ ប៉ុន្តែនៅពេលបញ្ជាក់ពីទីកន្លែងកំណើតសរសេរថា សម៉ខ្មែរ សម៉លោរ ទៅវិញនៅលើទំព័រក្រដាសតែមួយ។ល។

៩-លោក ឈឹម សុវណ្ណ នាយករងវិទ្យាល័យសមរលោរបានសំដែងការឯកភាពជាមួយលោក ឡាច ស្រ៊ី ដែរ។ លោកជាមន្ត្រីអប់រំម្នាក់ដែលបានដឹង និងចង់ឲ្យមានការកែប្រែពីការសរសេរខុសមកត្រូវដូច មន្ត្រីអប់រំជានានាដែរ។

១០-លោក ឡាក់ គួយ អាយុ៧៣ឆ្នាំ អតីតមេភូមិសមរលោរនេះបាន រំលឹក កាលពីលោកនៅរៀនជា មួយព្រះគ្រូលោកតាសុខ[208] ថ្នាក់កុមារដ្ឋាន ពេលនោះលោកបានសរសេរភូមិសមរលោរនេះនឹង"""គឺ ស ម៉ រ លា រ ជាលទ្ធ ផលព្រះគ្រូបានចាប់ដៃគាត់លំអុកនឹងតុឲ្យឈឺជាមួយសង្ឃដីកាថា កុំសរសេរ អញ្ចឹងឈ្មោះភូមិនេះត្រូវសរសេរថា ស ម រ លា រ ទើបត្រឹមត្រូវ។ លោកបញ្ជាក់ ថា លោកដឹងថា ការសរសេរឈ្មោះ ភូមិរបស់គាត់ គឺខុសហើយ ប៉ុន្តែលោក មិនដឹងទៅនិយាយជាមួយអ្នកណា។

១១-លោក ស្រី ហ៊ត អាយុ៦៨ ឆ្នាំ ជាមេភូមិសមរខ្មែរ លោកបាន សំណូមពរទៅគណៈប្រតិភូស្រាវ ជ្រាវនេះថា ប្រសិនបើថ្នាក់លើកែប្រែសុំឲ្យ ជួយកែប្រែ ភូមិសមរខ្មែរផង គឺកុំឲ្យមានសរសេរថា សម៉ខ្មែរដូចសព្វថ្ងៃនេះ ទៀតមិនត្រឹមត្រូវទេ។

១២-ឆ្លើយតបនឹងប្រសាសន៍របស់ឯកឧត្តមបណ្ឌិត នៅ ស៊ុន ដែល បានលើកឡើងថា តើវត្តសមរលោរនេះធ្លាប់មានឯកសារណាចារជាប្រវត្តិរឿង រ៉ាវរក្សាទុករហូតដល់សព្វថ្ងៃនេះដែរឬ ទេ? ព្រះតេជគុណ ឡាក់ ហំ ព្រះចៅ អធិការវត្តសមរលោរបច្ចុប្បន្នមានព្រះសង្ឃដីកាថា អាត្មាក្មេង ស្រករក្រោយទេ មកដល់ពេលនេះអាត្មាបួសបាន២០វស្សាហើយ។ តាំងពីបានទទួលតំណែង ជាចៅអធិការមក អាត្មាមិនធ្លាប់ឃើញឯកសារណាមួយនិយាយពីប្រវត្តិនៃវត្ត សមរលោរនេះទេ។ ព្រះអង្គបញ្ជាក់ថា អាត្មាធ្លាប់បានស្តាប់ចាស់ៗនិយាយថា កាលពីសម័យសង្គមរាស្ត្រនិយមសម្តេច ព្រះសង្ឃរាជ ជួន ណាត ធ្លាប់បាន

[208] អតីតព្រះចៅអធិការវត្តសមរលោរទី៧។

យាងនិមន្តមកសំដែងព្រះធម៌ទេសនាក្នុងពិធីបុណ្យឆ្លងចេតិយ៍ កុង ពេជ្រ[209] ហើយខណៈពេលនោះមានគេសួរអំពីប្រវត្តិឈ្មោះភូមិសមរលាវ ភូមិសមរខ្មែរ និងភូមិសមរចិន។ សម្ដេចបានមានព្រះរាជបន្ទូលថា ឈ្មោះនេះ សំដៅដល់សមរភូមិនៃជនជាតិបី (ខ្មែរ ចិន លាវ)ឈ្លោះគ្នា។ ដូច្នេះត្រូវសរសេរថា ស ម រ (ខ្មែរ ចិន និងលាវ) នេះឯង។ ឆ្លើយតបចំពោះមតិលើកឡើងខាងលើ ឯកឧត្តមបណ្ឌិត នៅ ស៊ុន បានបញ្ជាក់ថា ឈ្មោះភូមិនៅប្រទេសយើងឥឡូវឃើញមានការកែប្រែច្រើនណាស់ វត្តក៏ដូចគ្នាដែរ។ ការដូរទាំងនេះមិនឈរលើមូលដ្ឋានអ្វីទេ។ ចំពោះឈ្មោះភូមិស្រុកភាគច្រើន គឺដាក់ឈ្មោះទៅតាមរុក្ខជាតិតាមដើមឈើ ជាដើម។ ដូចជា ភូមិដូង ភូមិចេក ភូមិព្រៃផ្ដៅ ភូមិត្នោត ភូមិល្វា ភូមិស្នោ ភូមិរការ។ល។ ទោះបីយ៉ាងណា វាមិនមែនទាំងអស់ទេ។ ទាក់ទងនឹងសំណូពររបស់បងប្អូនថា ឲ្យជួយប្ដូរឈ្មោះភូមិសមរលាវ ដែលសរសេរជាផ្លូវការសព្វថ្ងៃថា សម៉លាវ ជាការខុសឆ្គងនេះ ឯកឧត្ដមមិនហ៊ានកែជូនភ្លាមទេ ហើយក៏មិនមែនជាសមត្ថកិច្ចរបស់លោកដែរ។ តួនាទីរបស់ក្រុមការងារឯកឧត្ដមនេះបានតែមកស្រាវជ្រាវរកការពិតហើយធ្វើសេចក្ដីរាយការណ៍តែប៉ុណ្ណោះ។ ចំពោះខ្ញុំជឿ និងឯកភាពតាមបងប្អូន និងព្រះតេជគុណទាំងស្រុង។

ក្នុងឱកាសនោះដែរ ឯកឧត្ដមបណ្ឌិត សន ពៅ អគ្គលេខាធិការនៃក្រុមប្រឹក្សាជាតិភាសាខ្មែរបានសង្កត់ធ្ងន់ថា ទី១- គឺប្រវត្តិសាស្ត្រ ទី២-ផ្អែកលើផែនទី ទី៣-រុក្ខជាតិ និងទី៤-ម្ចាស់ស្រុក(ចុះសួរផ្ទាល់ជាមួយអ្នកស្រុកក្នុងតំបន់)។ ប្រសិនបើអ្នកស្រុក ធ្លាប់ប្រើយ៉ាងម៉េច វាត្រូវទៅតាមហ្នឹងហើយ។

---

[209] ចេតិយ៍នេះមានទីតាំងនៅក្នុងភូមិបន្ទាយរវៀង(បន្ទាយរវាង)ខាងជើងសមរលាវប្រហែលជាង ៣០០ម៉ែត្រ។

លោកបណ្ឌិត សន ពៅ បានសង្កត់ធ្ងន់ថា ការស្នើសុំតវ៉ាមិនមែនមានតែលោកបណ្ឌិត សេង ប៊ុនធឿន ម្នាក់នោះទេ គឺអាចមានច្រើន ប៉ុន្តែ គ្រាន់តែអ្នកខ្លះនិយាយទៅគេឮ ហើយអ្នកខ្លះនិយាយទៅគេមិនឮ sic ។

ផ្អែកតាមរបាយការណ៍នៃចុះស្រាវជ្រាវដល់ទីកន្លែងរបស់គណៈប្រតិភូនៃក្រុមប្រឹក្សាជាតិភាសាខ្មែរមក កិច្ចប្រជុំមួយបានប្រព្រឹត្តទៅកាលពីថ្ងៃពុធ ទី២៣ ខែកញ្ញា ឆ្នាំ២០១៥ ហើយសម្រេចដូចម្ចាស់សំណើ(សេង ប៊ុនធឿន)ចង់បានដែរ(សូមអានឧបសម្ព័ន្ធទី១)។

តាមការសម្ភាសន៍ដោយឡែក មិនខុសគ្នាប៉ុន្មានថា លោក ឈា តាំងស៊ិន ជាគ្រូបង្រៀនចូលនិវត្តន៍បានកើត និងរស់នៅក្នុងភូមិសមរលោរ ហើយបច្ចុប្បន្នកំពុងរស់នៅក្នុងភូមិសមរចិន[210]បានមានប្រសាសន៍ថាភូមិសមរលោរ សមរខ្មែរ និងសមរចិននេះ បានន័យថា ជាសមរភូមិរបស់ជនជាតិទាំងបី ដែលលោកធ្លាប់បានឮការបកស្រាយរបស់សម្តេចព្រះសង្ឃរាជ ជួន ណាត តាមវិទ្យុជាតិកាលពីទសវត្សឆ្នាំ៦០ជាងរៀងរាល់ថ្ងៃសុក្រនៃសប្តាហ៍។ លោកបានបញ្ជាក់ថា លោកបានទាន់(បានស្គាល់)ចាងហ្វាងសាលាបឋមសិក្សាសមរលោរបីនាក់ដូចប្រសាសន៍លោក កៀក ជ្រុន ដែរកាលពីមុនប្រទេសមានរដ្ឋប្រហារទម្លាក់សម្តេចឪឆ្នាំ១៩៧០។

លោក កៀក ជ្រុន អាយុ៧០ឆ្នាំ ជាអតីតសិស្សសាលាបឋមសិក្សាសមរលោរម្នាក់ទៀត និងក៏ជាអតីតនាយកវិទ្យាល័យជាស៊ីមតាកែវក្នុងទសវត្សឆ្នាំ១៩៩០ បាននិយាយថា សាលាបឋមសិក្សាសមរលោរត្រូវបានបង្កើតឡើង

[210] ក្នុងក្របខណ្ឌរដ្ឋបាលថ្នាក់ក្រោមជាតិ ភូមិនេះមិនរាប់ថាភូមិក្នុងបញ្ជីទៀតទេ។

អំឡុងទសវត្សឆ្នាំ១៩៥០ លោកបានចូលរៀនអំឡុងឆ្នាំ ដែលប្រទេសខ្មែរប្រារព្ធពីធីបុណ្យពាក់កណ្តាលសាសនា(ព្រះពុទ្ធសាសនាព.ស២៥០០)។

ចាងហ្វាងទី១ គឺលោក កាំង លាងសេង (លោកមានស្រុកកំណើតនៅភូមិក្រាំងស្លា[211]) ចាងហ្វាងទី២-លោក កុយ ឆេម (លោកមានស្រុកកំណើតនៅភូមិក្បាលពោធិ៍[212])ចាងហ្វាងទី៣-លោក ប្រាក់ សំអុន ហៅគ្រូឃុន[213](លោកមានស្រុកកំណើតនៅភូមិជ្រោយ)និង

ចាងហ្វាងទី៤-លោក ឈា ប៊ុនហេង ហៅ មាង[214] (លោកជាអ្នកភូមិសមរលាភ)។

លោក គឿក ជ្រុន សង្កត់ធ្ងន់ថា នៅខាងត្បូងភូមិសមរលាភមានព្រៃកោះស្នា និងស្រះតៀម គឺស្រះត្រៀម មានន័យថា ត្រៀមប្រយុទ្ធ។ លោកនៅចាំបានថា ក្នុងសម័យកាលដែលសិស្សានុសិស្សជីកដី ហើយបានប្រទះឃើញឆ្អឹងខ្មោច ព្រះអង្គ ប្រាក់ សុខ ហៅ យ៉ង បានប្រាប់ថា ជាខ្មោចលាភ។ កាលសម័យនោះ ព្រះតេជគុណ ឯក ព្រហ្ម មានតួនាទីជាព្រះគ្រូសូត្រឆ្វេង និងជាសមុហ៍ គឺជាលេខាធិការរបស់អនុគណស្រុកព្រៃ កប្បាស។ ព្រះតេជគុណ ឯក ព្រហ្ម ពូកែ ល្បីរន្ទឺខាងទេសនាណាស់។

លោក យុន សារ៉ាន់ អាយុ៦៧ឆ្នាំ ជាអតីតគ្រូបង្រៀននៃសាលាកម្រិតសិក្សាទី១(បឋម)សមរលាភក្នុងទសវត្សឆ្នាំ១៩៨០ ប្តូរទៅបង្រៀននៅអនុ

[211] ស្ថិតនៅឃុំស្នោ ស្រុកព្រៃកប្បាស។ នេះជាភូមិកំណើតរបស់លោកបណ្ឌិត សារិន ឆាក អ្នកនិពន្ធសៀវភៅព្រំដែននៃប្រទេសកម្ពុជា។

[212] ស្ថិតនៅក្នុងឃុំ ស្រុកបុរីជលសារ ខេត្តតាកែវ។

[213] ជាអតីតព្រះសង្ឃមានដើមកំណើតនៅភូមិជ្រយ។

[214] លោកជាឪពុកមាបង្កើតរបស់លោក ឈា តាំងស៊ន។

វិទ្យាល័យព្រៃល្វា នៅឆ្នាំ១៩៨២ប្តូរទៅបង្រៀននៅអនុវិទ្យាល័យស្រុកកំពង់ត្រឡាច និងក្លាយជានាយកអនុវិទ្យាល័យមហាសាមគ្គី (បច្ចុប្បន្នវិទ្យាល័យ ជា ស៊ីម) ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង។ លោកជាអតីតសិស្សពូកែនៅអនុវិទ្យាល័យសូរ្យវ៉ន្នទី១(កំពែង)ឃុំកំពែង និងមកដល់វិទ្យាល័យព្រះសោមា(ព្រៃល្វា) លោកក៏នៅតែរក្សាតំណែងជាសិស្សពូកែដដែល ហើយលោកជាអ្នកមានកំណើតនៅភូមិសមរលោវដែរ។ ទាក់ទងនឹងឈ្មោះភូមិដែលត្រូវបានក័ន្តប្រែពីសរសេរថា **ស ម រ លា វ** ទៅជា **ស ម៉ រ លា វ** លោកប្រាប់ទាំងអារម្មណ៍ក្រោធបន្តិចថាលោកបានស្តាប់ដោយផ្ទាល់ត្រចៀកនូវការបកស្រាយរបស់សម្តេចព្រះសង្ឃរាជ ជួន ណាត ដែលសួរដោយចាងហ្វាងសាលាបឋមសិក្សាឈ្មោះ ឈា ប៊ុន ហេង ហៅ មាង។ សម្តេចព្រះសង្ឃរាជបានមានព្រះបន្ទូលថា ទីនេះជាសមរភូមិទ័ព ខ្មែរ លាវ និងចិន។

លោក យុន សារ៉ាន់ បន្ថែមថា ភូមិនេះ ជាអតីតសមរភូមិ មិនមែនដាក់ឈ្មោះផ្អែកទៅលើដើមសម៉ ឬស្រម៉ អ្វីទេ។ លោកបន្តថា ឈ្មោះ សមរ នេះ ជាឈ្មោះផ្លូវការ សូម្បីតែអ្នកភូមិនេះរៀនចប់ទៅក៏គេសរសេរលើសញ្ញាបត្រថា សមរ ដែរ សូមកុំផ្លាស់ប្តូរស្រែកតែចិត្តឲ្យសោះ។

លោក ឡាក់ គិមសាន ជាអតីតនាយកអនុវិទ្យាល័យសមរលាវ និងជាអតីតអភិបាលរងស្រុកព្រៃ កប្បាសផងដែរ កាលពីលោកនៅសិស្សនៅឡើយអាយុប្រហែលជា១២ ឬ១៣ឆ្នាំ ក្នុងឆ្នាំសិក្សា១៩៥៤-៥៥ ដែលបច្ចុប្បន្នលោកមានជន្មាយុ៧២ឆ្នាំទៅហើយនោះ បានបញ្ជាក់អំពីឈ្មោះភូមិសមរលាវនេះថា ភូមិនេះបានមកពីពាក្យ សមរភូមិ គេសរសេរថា ស ម រ មិនសរសេរថា សម៉ ទេ។ តាមលោក លោក ឡាំ ងនលី អាយុ៦៦ឆ្នាំ(កូនរបស់លោកយាយឧបាសិកា ឡេង ស៊ាង )ជាមួយនឹងការកោតសរសើរអ្នកផ្តួចផ្តើមធ្វើអាស្រម

លោកយាយលាវបានបញ្ជាក់ថា ឈ្មោះភូមិសមរលាវនេះមិនមានវណ្ណយុត្តិសញ្ញាបន្តក់ពីរ( )នោះទេ ហើយលោកក៏បានបញ្ចេញសេចក្តីសរសើរលោកបណ្ឌិត សេង ប៊ុនធឿន ដែល ចេះនឹកស្រាវជ្រាវចងក្រងប្រវត្តិភូមិទាំងបីនិងធ្វើអាស្រមលោកយាយលាវតម្កល់នៅក្នុងវត្តឲ្យមានរូបរាងច្បាស់ លាស់ជាការបង្ហាញដល់ក្មេងៗជំនាន់ក្រោយបានដឹង និងគោរពបូជា។ តាមលោក រោងយាយលាវនេះ មិនស្ថិតនៅត្រង់កន្លែងហ្នឹងទេ គឺស្ថិតនៅក្បែររបង និងក្លោងទ្វារចេញ ហើយលោកយាយប្រកាន់ណាស់ ប្រសិនបើពុទ្ធបរិស័ទណាលួចយកម្ហូមអាហារចេញពីវត្ត លោកយាយនឹងធ្វើឲ្យឈឺពោះ ក្តៅខ្លួនភ្លាម។ រីឯសំណែនសម្រាប់លោកយាយគឺដូចលោក ហុកខេង ហៅ ជ្រឹង និងអ្នកស្រុកពោលដែរ គឺមានតែប្រហុកដុត និងបាយ ដំណើប លោកយាយព្រមហើយ។

ដូចគ្នានឹងលោក ឡាំ ងនលី ដែរ លោក ឡុញ គ្រី(ហៅ ប្រាច)អាយុ ៦៧ឆ្នាំបានកោតសរសើរដល់អ្នកផ្តួចផ្តើមធ្វើអាស្រមរបស់លោកយាយលាវ ហើយថាភូមិសមរលាវគេមិនដែរសរសេរ ដាក់បន្តក់ពីរ(មុសិកទន្ត)ទេ គឺគេសរសេរដូចតែក្លោងទ្វារវិទ្យាល័យសព្វថ្ងៃអញ្ចឹង។

លោក មួយ គុនអេង ជាមេភូមិសមរលាវ ចាស់វស្សាបានថ្លែងថាការសរសេររបស់មន្ត្រីមូលដ្ឋាននេះវាខុសហើយ ប៉ុន្តែលោកមិនដឹងកែប្រែដូចម្តេចទេ ពីព្រោះថ្នាក់លើគេបានយកករណីខុសនេះចុះក្នុងសៀវភៅក្រសួងទៅហើយ។ បន្ទាប់ពីបានឮដូច្នេះភ្លាម ខ្ញុំក៏រឹងរិតតែតឹងតែងក្នុងចិត្តថែមទៀតដោយមានអារម្មណ៍សោកស្តាយចំពោះពាក្យថា **ស ម រ ភូមិ** ត្រូវបានសរសេរខុសដូច្នេះ? ខ្ញុំបានសង្កេតឃើញនៅក្នុងលិខិតស្នាមរដ្ឋបាល មានជាអាទិ៍ សំបុត្រកំណើត អត្តសញ្ញាណប័ណ្ណជាពិសេសសម្រាប់យុវជនក្មេងៗ។ ករណីនេះ

ម្ដងជាពីរដង ខ្ញុំបានព្យាយាមជួបលោក ស្រី រ៉េន[215] ជាមេឃុំពោធិ៍រំចាកបីអាណត្តិជាប់គ្នា(២០០២-២០២១)។ លោកបានប្រាប់ថា លោកបានដឹងពីរឿងហ្នឹងដែរ ហើយលោកក៏បានទាក់ទងទៅសាលាស្រុកឲ្យជួយអន្តរាគមន៍ផងដែរ។ ក្នុងនាមលោកជាប្រមុខនៃអាជ្ញាធរមូលដ្ឋានលោកក៏មានការពិបាកខ្លាំងណាស់ចំពោះរឿងដឹងហើយកែមិនបានភ្លាម។

គួររំលឹកដែរ សូម្បីតែឈ្មោះឃុំ **ពោ ធិ៍ រំ ចា ក** ក៏ពីមុន(ទសវត្សរ៍៨០) ត្រូវបានគេសរសេរថា **ពោ រុំ ចា ក** ដែរ ទើបតែសព្វថ្ងៃនេះទេដែលឃុំនេះត្រូវបានសរសេរថា **ពោ ធិ៍ រំ ចា ក** ។ យើងមិនបកស្រាយករណីឃុំពោធិ៍រំចាកនេះទេ។ សរុបសេចក្ដីមក ខ្ញុំយល់អំពីការលំបាករបស់អាជ្ញាធរមូលដ្ឋាន ក្រៅពីការងារសន្តិសុខសណ្ដាប់ធ្នាប់ សាធារណៈក្នុងឋានៈជាអ្នករដ្ឋបាលលោកត្រូវមានគោលការណ៍ (Principle of Administrator)សំខាន់ៗច្រើនណាស់ក្រៅពីកិច្ចការចំពោះមុខ និងគោរពបទដ្ឋានច្បាប់នានាជាប្រចាំរួមមាន៖

ទី១-អព្យាក្រឹតភាព (Neutrality)៖ អ្នករដ្ឋបាលមិនត្រូវមាននិន្នាការប្រកាន់បក្សពួកនិយមឡើយ។ ត្រូវធ្វើកិច្ចការសព្វសារពើទៅតាមតួនាទី និងភារកិច្ចរបស់ខ្លួនដោយគោរពតាមគោលការណ៍ច្បាប់កំណត់។

ទី២-អចិន្ត្រៃយ៍ភាព (Permanance) ៖ អ្នករដ្ឋបាលត្រូវធ្វើការងារជាប្រចាំដោយគោរពពេលវេលាធ្វើការងារឱ្យបានទៀងទាត់។

ទី៣-តម្លាភាព (Transparency)៖ ភាពថ្លាភ្លឺច្បាស់ធ្វើអ្វីមួយមានហេតុផលត្រឹមត្រូវ។

---

[215] លោកជាមេដឹកនាំមូលដ្ឋានម្នាក់ដែលមានប្រជាប្រិយភាព ស្គាល់កាលៈទេសៈ និងសុខទុក្ខប្រជាពលរដ្ឋ។

ទន្ទឹមនឹងនេះអ្នករដ្ឋបាលក៏ត្រូវមានលក្ខណៈសម្បត្តិ និងចំណេះដឹង (Qualified Administrator)សំខាន់ៗមួយចំនួនផងដែរ ដូចជា៖

១-ឧស្សាហ៍ព្យាយាម និង អំណត់ (Commitment)

២-តាមដានការងារជាប្រចាំ (Work observation)

៣-ឈ្វេងយល់ការងារនៅក្នុងអង្គភាព (Work seeking out)

៤-ចេះដកស្រង់បទពិសោធន៍ (Experience exchange)

៥-ពង្រីកចំណេះដឹង (ខិតខំរៀនសូត្របន្ថែម) (Knowledge extension)

៦-សាកល្បងធ្វើការងារថ្មី... (New work experiment)សមត្ថភាព (Capacity)

៧-វិជ្ជាជីវៈ (Professional)

៨-ការទទួលខុសត្រូវ (Responsibility)

៩-មនសិកា (Conscience)

អ្នកដឹកនាំមូលដ្ឋានឃុំ-សង្កាត់សុទ្ធតែចេញពីការសំដែងឆន្ទៈរបស់រាស្ត្រតាមរយៈការបោះឆ្នោតទាំង អស់។ ដូច្នេះលោកគ្មានជម្រើសណាផ្សេងក្រៅពីខិតខំបម្រើរាស្ត្រ សមូហភាព និងសហគមន៍ដោយសុទ្ធចិត្តឡើយ។

សូមត្រឡប់មកនិយាយពីគណៈប្រតិភូក្រុមប្រឹក្សាជាតិភាសាខ្មែរបន្តទៅទៀត បន្ទាប់ពីចុះស្រាវជ្រាវស្វែងរកការពិតនៅក្នុងភូមិទាំងបីខាងលើរួចមកគណៈប្រតិភូបានធ្វើសេចក្តីរាយការណ៍ពិស្តារមួយជូនអង្គប្រជុំក្រុមប្រឹក្សាជាតិភាសាខ្មែរបានស្តាប់ និងអនុម័តលើសំណើរបស់ក្រសួងមហាផ្ទៃនេះ។ សមាជិក សមាជិកា អង្គពិភាក្សាភាគច្រើនលើសលប់សុទ្ធសឹងតែជាបណ្ឌិត

ជាអ្នកមានបទពិសោធន៍ អាចថាជាប្រាជ្ញខាងអក្សរសាស្ត្រធំៗ ភាសាវិទូ បុរាណវិទូ ព្រះសង្ឃ មានជាអាព្រះតេជគុណធម្មចារោ យស់ ហ៊ុត[216] ព្រះតេជគុណ ព្រះសំវរវិជ្ជាបណ្ឌិត សុខ ប៊ុនធឿន ព្រះចៅងធិការវត្តនន្ទមុនី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ (សមាជិកគណៈប្រតិភូដែលចុះស៊ើបអង្កេតដល់មូលដ្ឋានទាំងអស់) ឯកឧត្តម សូ មុយឃាង ឯកឧត្តម ឈន អៀម ឯកឧត្តមបណ្ឌិតសភាចារ្យ ខៀវ ថវិកា ឯកឧត្តមបណ្ឌិត ច័ន្ទ សំណព្វ អនុប្រធានរាជបណ្ឌិត្យសភាកម្ពុជា និងមានឯកឧត្តម លោកជំទាវ អស់លោកជាបណ្ឌិតប្រមាណជាង៥០រូបផ្សេងទៀតក្រោមការដឹកនាំប្រជុំរបស់ឯកឧត្តមបណ្ឌិត្យសភាចារ្យតិច សំណាង អនុប្រធានទី១ អចិន្ត្រៃយ៍នៃក្រុមប្រឹក្សាជាតិភាសាខ្មែរនិងជាទីប្រឹក្សាជាតិភាសាខ្មែរនៃរាជបណ្ឌិត្យសភាកម្ពុជា។ នៅក្នុងអង្គពិភាក្សានោះ សមាជិកអង្គប្រជុំបានបញ្ចេញមតិខុសៗគ្នា។ ប៉ុន្តែមានការគាំទ្រមកខាងម្ចាស់សំណើភាគច្រើនទាក់ទងនឹងឈ្មោះភូមិសមរលោរ សមរខ្មែរ សមរចិននេះ។ ខ្ញុំបាទដែលជាម្ចាស់ដើមរឿង ក៏ត្រូវបានអង្គប្រជុំអញ្ជើញអនុញ្ញាតឲ្យចូលរួមស្តាប់ និងការពារដែរនោះត្រូវបានឯកឧត្តមបណ្ឌិត្យសភាចារ្យប្រគល់នាទីឲ្យមានមតិការពារ។

ក្នុងនាមជាម្ចាស់បញ្ហា ជាអ្នកភូមិសមរលោរ ខ្ញុំព្រះករុណា ខ្ញុំបាទមានមហាកិត្តិយសខ្លាំងណាស់ និងសេចក្តីរំភើបមោទនភាពក្រៃលែងបានរ៉ាយរ៉ាប់ពីសារបានទាំងអស់ទាក់ទងនឹងភូមិទាំងបីខាងលើជូនអង្គប្រជុំ។ នេះជាប្រវត្តិសាស្ត្រសម្រាប់រូបខ្ញុំព្រះករុណាខ្ញុំបាទដែលបានដើរតួនាទីយ៉ាងសំខាន់

---

[216] ព្រះអង្គត្រូវបានពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជប្រគេនសញ្ញាបត្រកិត្តិបណ្ឌិត ផ្នែកមនុស្សសាស្ត្រ (Honorary Doctor's Degree in Humanity)ថ្ងៃទី១០ ខែឧសភា ឆ្នាំ ២០១៦

បំផុតជាអ្នកការពារការសរសេរឈ្មោះភូមិខុសឲ្យមកជាត្រូវតាមការចង់បានរបស់អ្នកភូមិវិញ។ ក្នុងឪកាសនោះ ព្រះករុណាខ្ញុំបាទបានជម្រាបអង្គប្រជុំថា ភូមិព្រះករុណាខ្ញុំបាទមិនមែនជាភូមិថ្មី តម្រូវឲ្យក្រុមប្រឹក្សាជាតិភាសាខ្មែររកឈ្មោះ ឬរកអត្ថន័យនៃឈ្មោះភូមិ ឬសុំឈ្មោះថ្មី ឬរកអត្ថន័យឲ្យនោះទេ។ ម្យ៉ាងទៀត អ្នកស្រុកខ្ញុំបាទតាំងពីបុរាណមកក៏មានអ្នកប្រាជ្ញ មានអ្នកចេះដឹង មានអ្នកប្រាជ្ញ មានព្រះសង្ឃច្រើនអង្គផងដែរ។ ប្រសិនបើពិនិត្យទៅលើសំណង់អគារទៀតសោតដែលសេសសល់មកដល់សព្វថ្ងៃនេះក៏ជាស្នាដៃរបស់អ្នកប្រាជ្ញ អ្នកចេះដឹងដែរ ជាងនេះទៅទៀត ប្រសិនបើឯកឧត្តមលោកជំទាវ អស់លោក ចង់ស្គាល់ស្រុកភូមិទាំងនេះ ខ្ញុំបាទយល់ព្រមទទួលបាយមួយពេលទៅចុះដើម្បីស្រាវជ្រាវកាន់តែច្បាស់ថែមទៀត(អង្គប្រជុំបន្លឺសំឡេងទះដៃបន្លឺ និងសំណើច)។ ភូមិនេះមានឈ្មោះតាំងពីបរមបុរាណ ប៉ុន្តែត្រូវគេប្តូរឈ្មោះឲ្យភ័ន្តភាំងសំណេរ ត្រឹមឆ្នាំ២០០១ ឬ២០០២[217]។

គួររំលឹកដែរ អ្វីដែលខ្ញុំបានជម្រាបជូនអង្គប្រជុំខាងលើនេះ ក៏ព្រោះតែក្នុងឪកាសជជែកវែក ញែកនោះ មានអ្នកប្រាជ្ញខាងអក្សរសាស្ត្រខ្មែរវ័យក្មេងៗខ្លះបានលើកឡើងថា ឈ្មោះភូមិនេះគ្មានហេតុផលណាដែលត្រូវសរសេរថា **ស ម រ** ទេ គឺសរសេរថា ស ម៉ ហ្នឹងទើបត្រូមត្រូវ។លោកបណ្ឌិតបានធ្វើអំណះអំណាងងាយៗថា៖

ទី១-ពាក្យ ស ម រ នេះ មិនទាន់មានគេប្រើប្រាស់ពាក្យនេះទេនាសម័យនោះ។ ពាក្យនេះទើបតែប្រើក្នុងសម័យក្រោយៗមកទេ។

[217] យោងតាមសៀវភៅរបស់ក្រសួងមហាផ្ទៃចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០១

ទី២-លោកបណ្ឌិតមិនជឿថា ប្រជារាស្ត្រខ្មែរសម័យនោះ នៅទីនោះមានប្រាជ្ញាចេះកំណត់យកពាក្យនេះមកប្រើទេ ក៏ដូចគ្នាដែរលោកគិតថា គ្មានស្តេចឯណាទៅធ្វើចម្បាំងនៅទីនោះទេ។ ដូច្នេះលោកថា ភូមិនេះសរសេរថា ស ម៉ ហ្នឹងគឺត្រឹមត្រូវហើយ។ភ្លាមនោះលោក មាយ ប៉ូរ៉ា បណ្ឌិតផ្នែកភាសាវិទ្យា បានឆ្លើយតបទៅប្រសាសន៍ខាងលើថា តាមពិតពាក្យ ស ម រ ត្រូវប្រើតាំងពីសតវត្សទី៦ ឬទី៧ កាលនោះគេហៅថា សមរសេនា (សៈមៈសេណា)។ បន្ទរជាមួយគ្នា លោក លី រស្មី ជាបណ្ឌិតផ្នែកស្ថាបត្យកម្ម និងនគររូបនីយកម្មមួយរូបទៀត ដែរបានបន្ថែមថាលោកគាំទ្របណ្ឌិត មាយ ប៉ូរ៉ា អំពីថាពាក្យសមរសេនានេះមានតាំងពីអំឡុងសតវត្សទី៦ ឬទី៧មែន។ ម៉្យាងទៀត យើងមិនគួរធ្វើការវិភាគរកន័យអ្វីផ្សេងនាំឲ្យខាតពេលទេ ហើយវាជាការនាំឲ្យខុសចិត្តរបស់ម្ចាស់ស្រុក។ ម្ចាស់ស្រុកគេសរសេរយ៉ាងម៉េចស្រេចតែគាត់ចុះប្រសិនបើយើងកែថ្មីវាអាចនាំឲ្យបាត់បង់ស្លាកស្នាមប្រវត្តិសាស្ត្ររបស់គេ។

ជាអវសាន្ត ខ្ញុំបានអំពាវនាវយ៉ាងទទូចដល់អង្គពិភាក្សាទាំងមូលសូមមេត្តាជួយអនុម័តយល់ព្រមនូវការសរសេរឈ្មោះសមរលាវ សមរខ្មែរ សមរមេត្រី ដែលត្រឹមត្រូវនេះមកឲ្យអ្នកស្រុកយើងខ្ញុំវិញដែលវាបានបាត់បង់ភាពត្រឹមត្រូវអស់រយៈពេល១៤ឆ្នាំមកហើយ។ ថ្វីត្បិតតែក្នុងអង្គពិភាក្សានោះ មានការលើកឡើងនូវមតិផ្សេងៗគ្នាក៏ពិតមែន ប៉ុន្តែទីបំផុតសមាជិកបានលើកដៃគាំទ្រសំណូមពររបស់ខ្ញុំ និងផ្អែកតាមកំណត់ហេតុស្រាវជ្រាវភាគច្រើនលើសលប់។ នេះពិតជាមោទនភាពបំផុតសម្រាប់ជីវិតខ្ញុំដែលបានធ្វើប្រយោជន៍ដ៏ធំមួយសម្រាប់ភូមិកំណើតរបស់ខ្លួន។

នាមនៃភូមិសមរលាវ សមរខ្មែរ ដែលសរសេរត្រឹមត្រូវថា ស ម រ លា វ ស ម ខ្មែ រ ស ម មេ ត្រី ត្រូវបានអង្គប្រជុំនៃក្រុមអ្នកប្រាជ្ញខាងអក្សរសាស្ត្រខ្មែរ

នៃរាជបណ្ឌិត្យសភាកម្ពុជាយល់ព្រមតាមសំណើតាមព្រឹត្តិន័យ ឬធម្មានុរូប[218] (Légitimité /Legitimacy) ជូនអ្នកភូមិទាំងបីវិញនៅវេលាម៉ោង៤ និង១៥ នាទីនាថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥នៅអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ(សូមមើលឧបសម្ព័ន្ធទី៤)។

អនុលោមតាមសេចក្តីសម្រេចនេះ ប្រកាសលេខ៩៩៩០ប្រកចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥ ចុះហត្ថលេខាដោយសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានផ្តល់ជូនតាមម្ចាស់សំណើវិញផងដែរ(សូមមើលឧបសម្ព័ន្ធទី៥)។តាមប្រកាសនេះមាត្រា១ចែងថាត្រូវបានប្តូរឈ្មោះភូមិចំនួនពីរ...ត្រង់នេះ ខ្ញុំសូមធ្វើការបញ្ជាក់បន្តិច តាមពិតវាមិនមែនជាការផ្លាស់ប្តូរឈ្មោះអ្វីទេ គ្រាន់តែកែសម្រួលអក្ខរាវិរុទ្ធដែលសរសេរខុសតែប៉ុណ្ណោះ...ដូច្នេះប្រកាសនេះគួរសរសេរថា ត្រូវបានកែសម្រួលការសរសេរឈ្មោះភូមិចំនួនពីរ...កាន់តែប្រពៃ។ ចំណុចមួយទៀតក្នុងមូលបទនៃប្រកាសគឺបានរំលេចឯកសារយោងលិខិតរបស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ។ ករណីនេះ គួរប្រើប្រាស់ឯកសារយោងរបស់ម្ចាស់លិខិត(សូមមើលឧបសម្ព័ន្ធទី១) ថែមទៀតទើបកាន់តែមានអត្ថន័យឆ្លើយតប និងស៊ីចង្វាក់។

រួមសេចក្តីមក ឈ្មោះភូមិសមរលាវ សមរខ្មែរ និងសមរចិន ពិតជាមានអត្ថន័យគ្រប់គ្រាន់ ហើយអ្នកភូមិទាំងចាស់ទាំងក្មេងមិនត្រូវការការផ្លាស់ប្តូរណាមួយឡើយ ជាពិសេសក្នុងសំណេរដើមនេះតែម្តង។ បានសេចក្តីថា ម្ចាស់

---

[218] បានសេចក្តីថា នេះជាការប្រគល់ជូនដល់ម្ចាស់សំណើវិញដោយអ្នកបច្ចេកទេស ទោះបីយ៉ាងណាបញ្ហានេះក្រសួងមហាផ្ទៃមិនទាន់បានទទួលរបាយការណ៍ពីក្រុមប្រឹក្សាជាតិភាសាខ្មែរទេ ដូច្នេះ ក្រសួងមហាផ្ទៃលោកមិនទាន់មានមូលដ្ឋានអ្វីនឹងសម្រេចនៅឡើយ។ ត្រូវរង់ចាំប្រកាសរបស់ក្រសួងជាក្រោយ ។ ដូច្នេះ គេទទួលបានធម្មានុរូប ប៉ុន្តែមិនទាន់មាននីត្យានុកូលភាព។

ស្រុកមិនត្រូវការផ្លាស់ប្ដូរពីការសរសេរខាងលើឲ្យទៅជា សម៉លាវ សម៉ខ្មែរ ឬសម៉មេត្រីអ្វីនោះទេ។ ជាថ្មីម្ដងទៀត ខ្ញុំក៏មិនគាំទ្រចំពោះការបញ្ចូលគ្នារវាងភូមិសមរខ្មែរ និងភូមិសមរចិនដែរ ត្បិតអ្នកស្រុកតែងតែប្រាប់កូនចៅគាត់ជំនាន់ក្រោយថា នៅទីនេះជាភូមិ(សមរចិន) ភូមិនោះជាភូមិសមរខ្មែរ និងភូមិមួយទៀតជាភូមិសមរលាវ ហើយប្រសិនបើថ្ងៃនេះភូមិនេះ វាមិនមានវត្តមានទៀតទេ ចុះថ្ងៃក្រោយបានអ្វីឆ្លើយសំណួរក្មេងៗទៅ?

## ៣-ការប្រែប្រួលឈ្មោះទីតាំងមួយចំនួនដែលបានជួបប្រទះ

តាមភូមិសាស្ត្រខេត្តតាកែវ មានស្រុកព្រៃកប្បាស ឃុំអង្គរបុរី[219]។ ដូចបានបញ្ជាក់ក្នុងលេខយោង (Foot note)ទី១១ខាងលើរួចហើយ ឃុំនេះត្រូវបានប្រែក្លាយទៅជាស្រុកអង្គបុរីវិញតាមសេចក្ដីលេខ១៧០សសរ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៨៨៤។ នៅក្នុងឃុំនេះហើយដែលជាទីតាំងរបស់នគរគោកធ្លក ក្រោយមកទៅជា ហ្វូណនឬនគរភ្នំនៃប្រវត្តិសាស្ត្រខ្មែររហូតមកដល់សព្វថ្ងៃនេះ(សូមរកស្ដាប់បទចម្រៀង ក្សត្រីគោកធ្លាក អង្គរបុរី)។ តើនៅក្នុងព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ននេះ មានទីតាំងប្រវត្តិសាស្ត្រ ភូមិ ឃុំ និងកន្លែងប៉ុន្មានទៅដែលមានការផ្លាស់ប្ដូរសំណេរ ឬការហៅឈ្មោះខុសពីឈ្មោះដើម ហើយដែលយើងហាក់មិនបានចាប់អារម្មណ៍ដល់នោះ? ឧទាហរណ៍ជាក់ស្ដែង **អង្គរបុរី** ពាក្យនេះមកពីពាក្យថា **បុរី** គឺប្រទេស ឬរាជធានី ឬទីក្រុង

219 សូមសរសេរថា អង្គរបុរី មិនមែនសរសេរថា **អង្គរបូរី** ទេ។ ការដែលគ្មានអ្នកណាថា គ្មានអ្នកនិយាយនេះហើយ នាំឲ្យខុសបន្តិចម្ដងៗ ទីបំផុត ខុសទៅជាត្រូវ ត្រូវអាចទៅជាខុសវិញ។ ប៉ុន្តែ ទោះបីយ៉ាងណា បច្ចុប្បន្ននេះ ពាក្យថា អង្គរបុរី ឃើញប្រើនៅក្នុងប្រព័ន្ធអប់រំ(តាមសាលារៀន) រីឯពាក្យ អង្គរបូរី ឃើញប្រើនៅក្នុងប្រព័ន្ធរដ្ឋបាល។ ចង់ថា ពាក្យនេះសរសេរខុស ឬត្រូវ សូមមិត្តអ្នកអាន ក្រឡេកទៅមើល ឈ្មោះ បុរី នានាបច្ចុប្បន្ន តើគេសរសេរ បុរី ឬបូរី? ឧទាហរណ៍ បុរី ប៉េង ហួត ឬបូរី ប៉េង ហួត ។ល។

ឥឡូវដោយគ្មានការបកស្រាយ ឬពន្យល់ច្បាស់លាស់តំបន់មួយនេះ ត្រូវបានសរសេរពីរយ៉ាងគឺខ្លះសរសេរថា **អង្គរបូរី** ខ្លះទៀតសរសេរថា **អង្គរបុរី** តើមានន័យដូចគ្នាឬទេរវាងពាក្យទាំងពីរនេះ? ឬមួយ អង្គរបុរី ត្រូវ និងអង្គរបូរី ខុស? បើសរសេរខុសពីមុនដូច្នេះ ហេតុដូចម្តេចក៏គេនៅតែបន្តសរសេរទៀត? ដូចគ្នានេះ ថ្ងៃក្រោយ ឬចាប់ពីពេលនេះទៅអាចជាករណីភូមិ **សមរលាវ**ទៅជា **សម៉លាវ** ដែរទេ? តើយើងគួរបន្តសរសេរទាំងខុសរបៀបនេះទៀត ឬយ៉ាងណា។ នៅជិតភូមិសមរលាវនេះ មានភូមិមួយឈ្មោះថា ភូមិដង្ហិតសរសេរថាបច្ចុប្បន្នគេសរសេរថាដង្ហឹត។ តាមដឹងពីអ្នកស្រុកថា ភូមិនេះសរសេរថា ដង្ហិត ិ“”គឺមិនមែន **ដង្ហឹត** ឹ“”ទេ។ ប្រសិនបើយកតាមរុក្ខជាតិ គឺសរសេរថា ដង្ហិត ិ“”[220]។ យើងមិនបន្ទោសអ្នកណាទេ នេះជាការប្រើប្រាស់ សំណេរតៗគ្នាមក។ ដូចបានបញ្ជាក់រួចហើយ ពេលស្នើសុំកែប្រែ ឬសរសេរឲ្យបានត្រឹមត្រូវវិញ នោះវាជារឿងមួយដ៏ពិបាក[221]។

យើងសូមនាំអ្នកអានទៅឆ្ងាយពីនេះបន្តិច ៖

១-ភ្នំជីសូរ្យ តាមយោបល់ខ្ញុំគួរតែត្រូវសរសេរបែបនេះ (ភ្នំជីសូរ្យ) ពីព្រោះវាជាព្រះនាមរបស់ព្រះបាទសូរ្យវរ្ម័នទី១[222]ជាអ្នកសាងប្រាសាទភ្នំមួយនេះ។ ប៉ុន្តែការពិតវាមិនមែនដូច្នេះឯណា បង្គោលគីឡូម៉ែត្រចេញពីទីរួមស្រុក

---

[220] សម្តេចព្រះសង្ឃរាជ ជួន ណាត៖ ដង្ហិត ន. ឈ្មោះឈើតូច ស្លឹកប្រើជាថ្នាំស្រែង ដើម និងផ្លែប្រើជាថ្នាំបញ្ចុះ (ដង្ហិតធំ) មានដង្ហិតមួយប្រភេទទៀតហៅថា ដង្ហិតខ្មោច ដើមតូច ស្លឹកក៏តូច។ ភាគទី១-២ ១៩៦៧-១៩៦៨ ទំព័រ ៣២៥។

[221] មិនមែនអ្នកនិពន្ធថាទេ ប៉ុន្តែមានមនុស្សមួយចំនួនតូចយល់ថារឿងហ្នឹងកំប៉ិចកំប៉ុកណាស់ទៅខ្វល់ធ្វើអ្វី ខំតែរកអង្គរប្រេកផ្ទាំងទៅ។

[222] អនុវិទ្យាល័យកំពែងនៃភូមិកំពែង ឃុំកមពែង ស្រុកព្រៃកប្បាស បច្ចុប្បន្ននេះធ្លាប់បានប្រសិទ្ធិនាមថា អនុវិទ្យាល័យសូរ្យវរ្ម័នទី១ នាសម័យក្រោយឯករាជ្យ។

អង្គរបុរីមកកាន់ភ្នំជីសូរ្យកាត់តាមស្រុកព្រៃកប្បាសឃើញសរសេរនៅលើបង្គោលគីឡូម៉ែត្រដំបូងគេថា ភ្នំជីសូ(គ្មានទាំងអក្សរ "រ" ផង) ហើយមានបង្គោលគីឡូម៉ែត្រមួយតាំងនៅថ្នល់ទទឹង(ផ្លូវបត់ចូលទៅកាន់ភ្នំជីសូរ្យកាត់តាមផ្សារបត់រកា)គឺគេសរសេរថា ភ្នំជីសូរ្យ (រៀបចំដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ)ហើយផ្សេងៗទៀតសរសេរថា ភ្នំជីសូរ។

២-កោះទន្សាយ ដែលភាគច្រើនអ្នកទេសចរណ៍បរទេសបានស្គាល់ច្រើនជាងខ្មែរនោះ អ្នកស្រុកមួយចំនួនបាននិយាយថា កោះនេះ ពីដើមគេហៅថា កោះអន្ទាយ ពីព្រោះវាវែងអន្ទេអន្ទាយ តែពេលនេះគេបែរជាហៅថាកោះទន្សាយទៅវិញ។ ខ្ញុំមិនបកស្រាយអំពីករណីនេះទេ។ តែនេះបង្ហាញថាឈ្មោះកោះនេះគ្មានអ្នកណាចាប់អារម្មណ៍ដល់ និងតវ៉ាជាដើម ហើយនាំឲ្យមានការប្រែប្រួលដូច្នេះ។ ទោះបីយ៉ាងណា ឈ្មោះកោះនេះមិនមានការប្រែប្រួលអ្វីទៀតទេ ពីព្រោះគេស្គាល់គ្រប់គ្នាទោះហើយ ម្យ៉ាងទៀតវាក៏មិនអាក្រក់អ្វីទេ។

៣-ប្រាសាទសម្បូរព្រៃគុហ៍ ពីមុនគេសរសេរយ៉ាងដូច្នេះ ហើយមានផ្ទះសំណាក់មួយនៅខាងជើងស្ពានស្ទឹងសែន នាក្រុងស្ទឹងសែននៃខេត្តកំពង់ធំសព្វថ្ងៃក៏សរសេរយ៉ាងដូច្នេះដែរ។ ប៉ុន្តែប៉ុន្មានឆ្នាំចុងក្រោយនេះស្រាប់តែអាជ្ញាធរលើកផ្ទាំងប៉ាណូនៃកាច់ជ្រុងផ្លូវទៅកាន់ខេត្តព្រះវិហារ និងផ្លូវចូលទៅតំបន់ប្រាសាទសម្បូរព្រៃគុហ៍ ដោយសរសេរថា ប្រាសាទសម្បូរព្រៃគុកទៅវិញ បន្ទាប់ពីប្រាសាទនេះត្រូវបានដាក់បញ្ចូលជាសម្បត្តិបេតិកភ័ណ្ឌពិភពលោក ឈ្មោះប្រាសាទនេះ ក៏ត្រូវបានក្លាយជាកម្មវត្ថុនៃការជជែកដេញដោលតាមបណ្ដាញសង្គមហ្វេសប៊ុកយ៉ាងផុសផុលពី អ្នកឆ្ងល់ ហើយក៏ត្រូវបានបកស្រាយពីអ្នកប្រាជ្ញអក្សរសាស្ត្រ និងប្រវត្តិវិទូជាហូរហែដែរ។

៤-ពាក្យ ឧដុង្គ ក៏ឃើញសរសេរមានពីរកន្លែងដែរដែលខុសគ្នាគួរឲ្យកត់សម្គាល់។ នៅតាមផ្លូវជាតិលេខ៥ ពីបាត់ដំបងមកកាន់រាជធានីភ្នំពេញ ចាប់ពីទីក្រុងបាត់ដំបងរហូតដល់ទឹកដីខេត្តពោធិ៍សាត់ កំពង់ឆ្នាំង ឃើញសរសេរលើបង្គោលគីឡូម៉ែត្រថា ឧត្តុង្គ"ត្តុង្គ"។ ប៉ុន្តែនៅពេលមកដល់ម្តុំទឹកដីស្រុកកំពង់ត្រឡាចរហូតមក ទឹកដីស្រុកឧដុង្គនេះតែម្តង គេនាំគ្នាសរសេរថា ឧដុង្គ"ដុង្គ' វិញ។ ពាក្យសរសេរដែលត្រឹមត្រូវ គឺ ឧដុង្គ មិនមែន ឧត្តុង្គ ទេ។ ពាក្យនេះបានចេញមកពីពាក្យ**ឧដុង្គ** មែជ័យ(រឿងរ៉ាវមួយក្នុងប្រវត្តិសាស្ត្រ)។

៥-នៅខេត្តស្វាយរៀង មានវិទ្យាល័យមួយឈ្មោះ វិទ្យាល័យស្វាយជ្រំ (នៅក្លោងទ្វារវិទ្យាល័យ)ប៉ុន្តែពាក្យស្វាយជ្រំនៅលើប៉ាណូពាណិជ្ជកម្ម ឬប្រកាសរដ្ឋបាលខ្លះៗសរសេរថា ស្វាយ**ជ្រុំ** ទៅវិញ។ តើរវាងការសរសេរទាំងពីរនេះមួយណាត្រឹមត្រូវ? តើជាអចេតនា ឬក៏រឿងហ្នឹងវាមិនសំខាន់បានជាចេះតែមានការសរសេរមិនឯកភាពគ្នាសោះយ៉ាងនេះ?

៦-ខ្ញុំខ្លួនឯងមានចម្ងល់ នៅរាជធានីភ្នំពេញមានសង្កាត់មួយឈ្មោះថា សង្កាត់បឹងទំពុន តើឈ្មោះមុនដំបូងនោះ គេហៅយ៉ាងដូច្នេះតែម្តង ឬគេហៅថា **បឹងជប៉ុន**[223] ត្រូវក្លាយទៅជា បឹងទំពុន? ទោះបីយ៉ាងណាក៏ដោយ អាជ្ញាធរបានប្រើជាផ្លូវការថា "**បឹងទំពុន**"។

៧-នៅតាមបណ្តោយផ្លូវត្រើយខាងកើតទន្លេបាសាក់ប្របនឹងផ្លូវជាតិលេខ២១ ក្នុងភូមិសាស្ត្រ ឃុំតាលុន ស្រុកស្អាង ខេត្តកណ្តាល នៅលើក្លោងទ្វារសាលាបឋមសិក្សា អនុវិទ្យាល័យ និងមណ្ឌលសុខភាពផងដែរ សរសេរថា **តាលន់** ទាំងអស់ ប៉ុន្តែក្លោងទ្វារសាលាឃុំ និងក្លោងទ្វារវត្តសរសេរថា **តាលុន**

[223] អ្នកភ្នំពេញខ្លះនិយាយអញចឹង។

ទៅវិញ។ តើអាចមាននឹងមានការកែសម្រួលតែមួយជា តាលន់ ឬ តាលុន ឬ ទេទៅថ្ងៃអនាគតនោះ? ហើយនៅក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូលក៏យើងសង្កេតឃើញការសរសេរមិនឯកភាពគ្នានេះច្រើនកន្លែងដែរ។ ដូចជា ព្រៃល្វា មិនធ្លាប់មាន"រ" ស្រាប់តែឃើញនៅលើបង្គោលគីឡូម៉ែត្រខ្លះពីស្រុកកោះធំខេត្តកណ្តាលកាត់តាមកំពង់ចកទៅកាន់ផ្សារព្រៃល្វាសរសេរមាន"រ" ផងដែរ។

៨- នៅលើក្លោងទ្វារចូលវត្តបានហ្លួងសរសេរថា **បានហ្លួង**។ នៅក្បែរនេះប្រហែល៥០ម៉ែត្រ មានក្លោងទ្វារចូលសាលាសរសេរថា **បាន្លួង**។ រីឯនៅលើបង្គោលគីឡូម៉ែត្រ ឃើញសរសេរមួយបែបទៀតថា **បានលួង**។ តើមួយណាជាពាក្យត្រឹមត្រូវ? ពាក្យថា **បានហ្លួង** តាមការយល់របស់ខ្ញុំជាពាក្យសរសេរដែលត្រឹមត្រូវ គឺមិនមែន **បានលួង** ឬ **បាន្លួង** ដែលត្រូវគេសរសេរដូចរៀបរាប់ខាងលើនោះទេ ប៉ុន្តែក៏មានការអះអាងរបស់ឯកឧត្តម(ករណីនៅក្នុងឃុំចំប៉ា ស្រុកព្រៃកប្បាស)។ **ហ្លួង** នេះមានន័យថា **ស្តេច**។ ឧទាហរណ៍ **ហ្លួងព្រះស្តេចកន**។

៩-ពាក្យ**ជុប** ត្រូវបានសរសេរនៅក្លោងទ្វារចំការកៅស៊ូ (ចំការនៅស៊ូ**ជុប**)និងសាលាបឋមសិក្សា **ជុប** ខណៈដែលសាលាឃុំសរសេរថា (សាលាឃុំ**ជប់**) និងប៉ុស្តិ៍នគរបាលរដ្ឋបាល**ជប់**។ សម្រេចសម្រួចទៅតើគួរកែសម្រួលសរសេរតែមួយទេ?ហើយគួរតែជាសមត្ថកិច្ចរបស់អ្នកណា?

១០-ពាក្យជ្រោយ**ចង្វារ**ក៏កន្លែងខ្លះសរសេរមាន **រ** និងកន្លែងខ្លះសរសេរអត់ **រ** ដែរ។ យើងជឿជាក់ថា ករណីសរសេរអក្ខរាវិរុទ្ធមិនដូចគ្នា ឬខុសនេះមានច្រើនណាស់ទូទាំងប្រទេស ហើយក៏មិនដឹងទៅជម្រាបអ្នកណា

សមត្ថកិច្ចណាឲ្យជួយកែលម្អវិញដែរ ឬមួយក៏បន្តទុកឲ្យខុសយ៉ាងដូច្នេះតទៅទៀត?

១១-នៅអំឡុងឆ្នាំ២០០៧-២០០៨ ខ្មែរយើងមានជម្លោះជាមួយសៀមរឿងប្រាសាទព្រះវិហារ។ ក្នុងប្រធានបទនៃជម្លោះនេះក៏មានការតវ៉ាបញ្ហាហៅឈ្មោះនេះដែរ។ រាជរដ្ឋាភិបាលសម្តេចតេជោ ហ៊ុន សែន បានតវ៉ាយ៉ាងខ្លាំងក្លាមិនអនុញ្ញាតឲ្យសៀមហៅ ប្រាសាទព្រះវិហារ(វិ-ហ៊ា)ថាជាព្រះវិហារ(វិ-ហា)ទេ ហើយតាម រយៈបណ្តឹងរបស់រាជរដ្ឋាភិបាលខ្មែរដែលសុំឲ្យតុលាការយុត្តិធម៌អន្តរជាតិនាទីក្រុងឡាអេ(Hays)ប្រទេសហូឡង់(Holland) បកស្រាយសាលក្រមព្រះវិហារ(ខ្មែរ-សៀម)ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៦២នោះ។ ខ្មែរយើងបានទទួលជោគជ័យទៅលើភាគីសៀមម្តងទៀតជាមួយគ្នានេះ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជាបានចេញសេចក្តីថ្លែងការមួយពាក់ព័ន្ធនឹងរឿងក្តីព្រះវិហារ(វិ-ហ៊ា)នេះដែលមានខ្លឹមសារសំខាន់ៗជាអាទិ៍៖

១-ប្រកាសដោយសំឡេងឯកច្ឆន្ទថា តុលាការមានសមត្ថកិច្ច ដោយផ្អែកតាមមាត្រា៦០ នៃលក្ខន្តិកៈ ដើម្បីសម្រេចលើបណ្តឹងបកស្រាយសាលដីកាឆ្នាំ១៩៦២ដែលប្តឹងដោយព្រះរាណាចក្រកម្ពុជា ហើយទទួលស្គាល់បណ្តឹងនេះអាចទទួលស្គាល់យកមកពិនិត្យ និងដោះស្រាយបាន។

២-ប្រកាសដោយសំឡេងឯកច្ឆន្ទថា ក្នុងក្របខណ្ឌនៃការបកស្រាយសាលដីកានេះថា ព្រះរាណាចក្រកម្ពុជាមានអធិបតេយ្យភាពពេញលេញលើបូរណភាពទឹកដីលើតំបន់ពយភ្នំ (Eper on / Promontory)នៃប្រាសាទព្រះវិហារដូចដែលមានកំណត់នៅក្នុងកថាខណ្ឌទី៩៨នេះសាលដីកានេះ ហើយជាបច្ច័យតុលាការប្រកាសថា ព្រះរាជាណាចក្រថៃមានកាតព្វកិច្ចដកចេញពី

ទឹកដីនេះនូវ គ្រប់កងកម្លាំងប្រដាប់អាវុធ ឬកងនគរបាល ឬអ្នកថែរក្សា ឬឆ្មាំយាមផ្សេងទៀតរបស់ថៃដែលបោះទីតាំងនៅក្នុងទឹកដីនោះ។

នៅចុងបញ្ចប់នៃសេចក្តីថ្លែងការណ៍នេះសម្តេចតេជោក៏បានសម្តែងនូវការរំលឹកដឹងគុណដ៏ជ្រាលជ្រៅបំផុតឧទ្ទិសថ្វាយព្រះវររាជបិតាជាតិ ព្រះបរមរតនកោដ្ឋ សម្តេច នរោត្តម សីហនុ ដែលព្រះអង្គទ្រង់បានបន្សល់ទុកនូវមរតកជាប្រវត្តិសាស្ត្រដ៏មហាថ្លៃថ្លាដល់កូនចៅជំនាន់ក្រោយសម្រាប់ធ្វើជាសំអាងបន្តដោះស្រាយបញ្ហាប្រាសាទព្រះវិហារនេះហើយដែលត្រូវបានតុលាការយុត្តិធម៌អន្តរជាតិយកមកធ្វើជាមូលដ្ឋានក្នុងការធ្វើសេចក្តីសម្រេចរបស់ខ្លួន។ ប្រជារាស្ត្រខ្មែរសូមសំដែងនូវការពេញចិត្តអបអរសាទរ និងកោតសរសើរចំពោះរាជរដ្ឋាភិបាលកម្ពុជាចំពោះការធ្វើឲ្យច្បាស់លាស់នៃការមន្ទិលរបស់ភាគីសៀមនាពេលនោះ។

ជាថ្មីម្តងទៀត យើងនៅតែសង្កេតឃើញបង្គោលគីឡូម៉ែត្រមួយចំនួនតូចតាមដងផ្លូវនានានៃកម្ពុជាទាំងមូលមិនត្រូវបានអាជ្ញាធរយើងណែនាំឲ្យកាប់ឆ្ការព្រៃ(មែកឈើ) ឬស្មៅដើម្បីឲ្យអ្នកដំណើរមើលលេខគីឡូម៉ែត្របានច្បាស់ផង។ គួរជម្រាបដែរ តាមដងផ្លូវជាតិលេខ៦អា(6A )ពីរាជធានីភ្នំពេញទៅខេត្តសៀមរាប ការវាយលេខគីឡូម៉ែត្រលើបង្គោលគីឡូម៉ែត្រមិនស្អាតសោះ ពោលគឺប្រឡាក់ប្រតេកប្រតាក ជាដើម។ ជាមួយគ្នានេះ មន្ត្រីរាជការអ្នកដឹកនាំមូលដ្ឋានចាប់ថ្នាក់ដឹកនាំខេត្តរាជធានីស្រុកខណ្ឌ បើអាចឃុំសង្កាត់នាយកវិទ្យាល័យ ព្រះចៅអធិការវត្ត។ល។ ត្រូវរឹតបន្តឹងការអនុវត្តឲ្យបានតឹងរ៉ឹងក្នុងការសរសេរឈ្មោះទីតាំង ឬឈ្មោះផ្សេងៗឲ្យបានត្រឹមត្រូវ។


95
Odong
56Km
42
Oudong
3Km
PHNOM CHISO TEMPLE
1
Phnom Chi So
6 Km
11
Phnom Chi So
26Km
16
Phume Ban Luong
2 Km
COLLEGE TALUN
SALA KHUM CHUP
ADMISTRATIVE OF POLICE POST CHUP

រូបភាពខ្លះដែលយើងថតបានពីទីកន្លែងនានា ឆ្នាំ២០១៧(រូបទី២៥)

## ៤-ការប្រើប្រាស់សករាជ

**ក-ពុទ្ធសករាជ (ព.ស)៖** ពុទ្ធសករាជត្រូវបានប្រើប្រាស់រហូតមកដល់សព្វថ្ងៃចាប់ពីថ្ងៃពុធ ១រោជ ខែពិសាខ ឆ្នាំម្សាញ់ គឺក្រោយមួយថ្ងៃនៃព្រះសមណគោត្តមទ្រង់បានយាងចូលព្រះបរិនិព្វាននៅថ្ងៃអង្គារ៍ ១៥កើត ខែពិសាខ ឆ្នាំម្សាញ់តរៀងមក។

**ខ-មហាសករាជ (ម.ស)៖** មហាសករាជកើតក្នុងរាជព្រះបាទ សកៈ ឬហៅថា សាលីវាហនៈ នៅក្នុងប្រទេសឥណ្ឌាក្នុងពុទ្ធសករាជ ៦២១ ដែលគេប្រារព្ធយកជ័យជម្នះដ៏ធំរបស់ក្សត្រអង្គនេះជាសម្គាល់ ហៅថា កេណ្ឌ។ តាមរាជពង្សាវតារខ្មែរឲ្យដឹងថាបាទសម្តេច ព្រះវិដ្ឋពលពាហនោ ព្រះកេតុមាលាសូរ្យវង្ស បានតាំងមហាសករាជមួយក្នុងពុទ្ធសករាជ៦២១ឆ្នាំ។ ព្រះបាទសម្តេច ព្រះសិទ្ធពរអមរិន្ទព្រហ្មកិល(ពញាក្រែ) បានតាំងសករាជមួយក្នុងពុទ្ធសករាជ ១១៨១ឆ្នាំ។ តាមព្រះរាជពង្សាវតារក្រុងលាវ ក្រុងឈៀងម៉ៃ ឲ្យដឹងថា ព្រះបាទ ពន្ធុមតិ ក្នុងប្រទេស លង្កា ទ្រង់តាំងមហាសករាជនេះឡើង តែមិនបានបញ្ជាក់ថាឆ្នាំណាទេ។

**គ-គ្រឹស្តសករាជ (គ.ស)៖**គ្រឹស្តសករាជចាប់រាប់ពីថ្ងៃកំណើតរបស់ព្រះយេស៊ូកើត គឺកើតក្រោយពុទ្ធសករាជចំនួន ៥៤៣ឆ្នាំនៅប្រទេសប៉ាឡេស្ទីន គឺនៅត្រង់ប្រទេសអ៊ិស្រាអែលនេះឯង។

**ឃ-ចុល្លសករាជ (ច.ស)៖** គឺស្តេចភូមាព្រះនាម សង្ឃរាជ ឬហៅថា បុព្វសោហេន៍ ជាក្សត្រទី១៩នៃវង្ស សមុទ្ទឫទ្ធិ ទ្រង់បានប្រារព្ធតាំងសករាជ ក្នុងឆ្នាំកុរ រាប់ជាឯកស័ក ក្នុងពុទ្ធសករាជ១១៨១ ឆ្នាំ ដោយយកសុរិយគតិ (ឆ្នាំសកល)ជា កេណ្ឌ។ ច.ស កើតក្រោយ ម.ស ៥៦០ឆ្នាំ។

ចំពោះការប្រើពាក្យ ឯកស័ក ទោស័ក ត្រីស័ក ក៏កើតឡើងក្នុងពេល កើតចុល្លសករាជនេះដែរ ប៉ុន្តែទោះបីស្នាដៃបានចុះកាលបរិច្ឆេទជាជាសករាជ ណាក៏ដោយ អ្នកសិក្សាគួរធ្វើការប្រៀបធៀបមកជាពុទ្ធសករាជ និងគ្រឹស្តសក រាជទៅតាមការនិយមរបស់យើង និងទៅតាមការនិយាយរបស់អន្តរជាតិនា ពេលបច្ចុប្បន្ននេះទៅហោង។ ជាងនេះទៅទៀត អ្នកសិក្សាក៏គួរចេះធ្វើការ ប្រៀបធៀបរវាងសករាជទាំងឡាយដូចខាងក្រោម៖

| | |
|---|---|
| -ព.ស កើតមុន គ.ស ៥៤៣ឆ្នាំ | -គ.ស កើតក្រោយ ព.ស ៥៤៣ឆ្នាំ |
| -ម.ស កើតក្រោយ គ.ស ៧៨ឆ្នាំ | -ម.ស កើតក្រោយ ព.ស ៦២១ឆ្នាំ |
| -ម.ស កើតក្រោយ គ.ស ៦៣៨ឆ្នាំ | -ច.សកើតក្រោយព.ស ១១៨២ឆ្នាំ |

ដូច្នេះ កាលណាយើងដឹងសករាជណាមួយហើយ យើងក៏នឹងអាចរក ឃើញសករាជមួយទៀតបានដោយលេខបូក ឬដកតាមតួលេខខាងលើ។ ប៉ុន្តែត្រូវកត់សម្គាល់ថា ការបូក ឬដក តួលេខនេះ ពេលខ្លះយើងអាចមានការ ខុសគ្នាមួយឆ្នាំ ព្រោះថាក្នុងរយៈពេលខ្លះសករាជមួយបានផុតកំណត់ឆ្នាំចាស់ ដើម្បីចូលឆ្នាំថ្មីរបស់ខ្លួន តែសករាជមួយទៀត ពុំទាន់ផុតកំណត់ឆ្នាំចាស់របស់

ខ្លួនឡើយ។ ឧទាហរណ៍៖ គ្រឹស្តសករាជ ១៩៩៣ គេចាប់រាប់ពីខែមករា គ.ស ១៩៩៣ រហូតដល់ខែធ្នូ គ.ស ១៩៩៣។ ទន្ទឹមនឹងនេះ ប្រសិនបើយើងគិតពីពុទ្ធសករាជវិញ គេរាប់ពីខែមករា គ.ស ១៩៩៣ រហូតដល់ថ្ងៃបុណ្យចូលឆ្នាំខ្មែរនៅខែមេសា ត្រូវនឹងពុទ្ធសករាជ២៥៣៦ពីថ្ងៃចូលឆ្នាំក្នុងខែមេសានេះ រហូតដល់ ខែធ្នូ គ.ស១៩៩៣ ដដែលត្រូវនឹងពុទ្ធសករាជ២៥៣៧[224]។

**៥-របៀបរាប់ឆ្នាំខ្មែរ(ច័ន្ទគតិ)**

ឆ្នាំលេខ១គឺឆ្នាំជូត ឆ្នាំសត្វកណ្តុរ រហូតដល់ឆ្នាំលេខ១២ គឺឆ្នាំកុរ ឆ្នាំសត្វជ្រូក។ សូមចងចាំថា[225]

១-ក្នុងឆ្នាំនីមួយៗ ប្រសិនបើថ្ងៃទី១ ខែមករា ជាថ្ងៃអ្វី នោះថ្ងៃទី៣១ ខែធ្នូក៏ជាថ្ងៃនោះដែរ។ ប៉ុន្តែបើជាឆ្នាំបង្គ្រប់ នោះថ្ងៃទី៣១ ខែធ្នូក៏ត្រូវថែម១ថ្ងៃ ឧទាហរណ៍ទី១ ឆ្នាំ២០១៥ថ្ងៃទី១ខែមករា ជាថ្ងៃព្រហស្បតិ៍ នោះថ្ងៃទី៣១ ខែធ្នូ ក៏ជាថ្ងៃព្រហស្បតិ៍ដែរ។ ឧទាហរណ៍ទី២ ឆ្នាំ២០១៦ ថ្ងៃទី១ខែមករា ជាថ្ងៃសុក្រនោះថ្ងៃទី៣១ ខែធ្នូ ក៏ជាថ្ងៃសៅរ៍ ពីព្រោះជាឆ្នាំបង្គ្រប់។ ឆ្នាំបង្គ្រប់បានសេចក្តីថា ខែកុម្ភៈ មានរយៈពេល២៨ថ្ងៃ ប៉ុន្តែក្នុងរយៈពេល៤ឆ្នាំ ខែកុម្ភៈមានរយៈពេល២៩ថ្ងៃ។ ឆ្នាំបង្គ្រប់ (Année bissextile)គឺឆ្នាំដែលមានលេខចែកដាច់នឹង៤។

២-រឿងដោយមួយទៀត សម្រាប់លោកគ្រូអ្នកគ្រូទាំងឡាយនៅក្នុង

---

[224] ទទួលព័ត៌មានបន្ថែមពីលោក ទី សុផល គ្រូបង្រៀននៅវិទ្យាស្ថានជាតិអប់រំ។

[225] ទទួលព័ត៌មានបន្ថែមពីលោក ភឿក ជ្រុន អតីតគ្រូបង្រៀនស្រុកព្រៃកប្បាស ខេត្តតាកែវ។

ថ្នាក់រៀន ប្រសិនបើមានផែនទី ចូរចងព្យួរនឹងជញ្ជាំងខាងជើងដើម្បីឲ្យក្មួយៗសិស្សានុសិស្សងាយកំណត់ទិសនៅពេលពួកគេអានផែនទីម្តងៗ។

## ៦-បុណ្យដារលាន ឬបុណ្យដារភូមិ[226]

## ក-សេចក្តីផ្តើម

សម្រាប់ប្រជាពលរដ្ឋខ្មែរ ដែលភាគច្រើនជាកសិករ ពួកគាត់តែងតែប្រកាន់យ៉ាងខ្ជាប់ខ្ជួនផងដែរនូវពិធីកម្មព្រះពុទ្ធសាសនា ដោយជារៀងរាល់ឆ្នាំបាននាំគ្នាប្រារព្ធពិធីបុណ្យផ្សេងៗ ផ្អែកទៅតាមរដូវកាល ជំនឿ និងធនធានដែលពួកគាត់មាន។ ជារៀងរាល់ឆ្នាំ ប្រជាកសិករខ្មែរគ្រប់ភូមិ-ស្រុកទូទាំងប្រទេស ក្រោយពីបញ្ចប់ការច្រូតកាត់ បោកបែនស្រូវរួចរាល់ជាស្ថាពរហើយនោះ ចាស់ទុំក្នុងភូមិតែងតែងជជែកពិគ្រោះយោបល់គ្នាដើម្បីលៃលកពេលវេលាសមស្របណាមួយដើម្បីអាចធ្វើបុណ្យដារលានបាន។

ជារួមប្រពៃណីបុណ្យដារលាន ត្រូវបានពុទ្ធបរិស័ទទូទាំងប្រទេស ក៏ដូចជាមន្ត្រីរាជការគ្រប់ក្រសួងស្ថាប័ន ជាពិសេសក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ តែងតែប្រារព្ធឡើងជារៀងរាល់ឆ្នាំក្នុងគោលបំណងរក្សានូវអត្តសញ្ញាណព្រលឹងជាតិខ្មែរឱ្យបានគង់វង្ស ក៏ដូចជាការបង្កឱកាសដល់កសិករឱ្យមានការជួបជុំញាតិមិត្តជិតឆ្ងាយ ដើម្បីចូលរួមផ្លាស់ប្តូរយោបល់គ្នាលើ

[226] អត្ថបទស្រាវជ្រាវដោយលោក វង្ស ភារៈ អតីតព្រះសង្ឃគង់នៅវត្តជាច ភូមិ-ឃុំ ជាច ស្រុកកំចាយមារ ខេត្តព្រៃវែង និងបច្ចុប្បន្នជាមន្ត្រីរាជការនៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងនីតិសម្បទា។

ការងារបង្កបង្កើនផលឆ្នាំកន្លងមកនិងជាពិសេសដើម្បីចូលរួមកម្សាន្តសប្បាយ បន្ទាប់ពីការចំណាយអស់នូវកម្លាំងកាយ កម្លាំងចិត្តគ្រប់បែបយ៉ាងក្រោមកម្ដៅព្រះអាទិត្យ និងភ្លៀងផ្គរយ៉ាង ប្តូរផ្តាច់អស់រយៈពេលមួយរដូវនៃការងារបង្កបង្កើនផលរបស់ខ្លួនកន្លងមក។

## ខ-អត្ថន័យនិងគោលបំណង

បុណ្យដារលានជាពិធីបុណ្យដែលទាក់ទងទៅនឹងជំនឿសាសនា ជាប្រពៃណីមួយ ដែលខ្មែរយើងជឿថា "ធម៌រមែងរក្សាចំពោះបុគ្គលណា ដែលប្រព្រឹត្តនូវធម៌ ៗដែលបុគ្គលសន្សំបានល្អហើយ រមែងនាំមកនូវ សេចក្ដីសុខបុគ្គលអ្នកសន្សំនូវធម៌រមែងបាននូវអានិសង្សមិនខាន ហើយបុគ្គលជាអ្នកសន្សំ នូវធម៌នឹងមិនទៅកាន់នូវទុគតិឡើយ"។ ដារលាន មានន័យថា ការឆ្លងទីដីវាលរលើង។ បុណ្យដារលានអ្នកស្រុកហៅខុសៗគ្នា អាស្រ័យទៅតាមតំបន់នីមួយៗ ដូចជាខ្លះហៅបុណ្យបោសលាន បុណ្យសាមគ្គី បុណ្យកណ្ដាលភូមិ និងបុណ្យដារបាតលាន ជាដើម។ ថ្វីបើបុណ្យនេះមានឈ្មោះខុសគ្នាច្រើនអន្លើក៏ពិតមែន តែគោលបំណងសំខាន់នៃពិធីបុណ្យមានទិសដៅតែម្យ៉ាងគត់គឺដើម្បីរំឭកដឹងគុណម្ចាស់ទឹកម្ចាស់ដីដែលបានបន្សល់ទុកនូវមរតកដ៏ត្រកាលនេះឱ្យកូនចៅជំនាន់ក្រោយប្រកបរបរចិញ្ចឹមជីវិត។ តាមពិតទៅខ្មែរយើងគោរពធម្មជាតិពីរ គឺទឹក និងដី ព្រោះទឹក និងដីមានសារប្រយោជន៍ដល់ការប្រកបរបរកសិកម្ម ជាពិសេសគឺការផ្ដល់នូវភោគផលស្រូវអង្ករដែលបានចិញ្ចឹមពួកគេឱ្យមានជីវិតរស់នៅ និងជាឆ្អឹងខ្នងសេដ្ឋកិច្ចរបស់ជាតិសាសន៍ខ្មែរ

យើង។ ទន្ទឹមនេះ គឺដើម្បីសុំខមាទោសនូវអំពើ ឆ្គាំឆ្គងទាំងឡាយដែលគេបានប្រព្រឹត្ត ប៉ះពាល់ក្នុងរដូវបង្កបង្កើនផល ដូចជាការ បន្ទោរបង់ទឹកមូត្រឬដើរជាន់នៅលើទីវាលស្រែជាដើមព្រោះព្រះធរណីជាប្រភពធ្វើឱ្យស្រូវដុះលូតលាស់។ ព្រឹទ្ធាចារ្យជំនាន់ដើមចាត់ទុកថា ស្រូវអង្ករជាអ្នកមានគុណប្រៀបដូចម្តាយ ហេតុដូច្នេះហើយបានជា មានពាក្យថា "ព្រះមេ" រៀងរហូតមក។ ភាពជាក់ស្តែងនាសម័យដើម គឺនៅពេលមិនទាន់មានម្សៅ ឬទឹកដោះគោបំបៅទារកម្តាយមិនអាចឃ្លាតចាកទៅឆ្ងាយពីកូននៅជាទារកបានយូរឡើយ។ ប្រសិនបើម្តាយបានទទួលអនិច្ចកម្មដោយប្រការណាមួយនោះទារកច្បាស់ជាមិនអាចទ្រាំទ្រជីវិតឱ្យបានរស់នៅតទៅទៀតបានទេ។ ក្នុងស្ថានភាពលំបាកបែបនេះ អ្នកដែលមើលថែទារកតែងតែដោះស្រាយដោយយកអង្ករទៅបបរម្ទាស់បញ្ចុកទារកឱ្យអាចមានជីវិតរស់នៅបានរហូតដល់ពេញរូបរាង។ ចំណែកប្រជារាស្ត្រខ្មែរទាំងអស់ក៏តែងទទួលទានបាយដើម្បីទ្រទ្រង់ជីវិតឱ្យបានរស់នៅស្ថិតស្ថេរដែរ។ ហេតុដូច្នេះហើយបានជាមុននឹងពិសារ"បាយ" ព្រឹទ្ធាចារ្យខ្មែរទាំងអស់តែងតែលើកដៃសំពះសូមអរគុណចំពោះព្រះមេជានិច្ច។ លោកតែងតែពន្យល់កូនចៅឱ្យមានការប្រុងប្រយ័ត្នក្នុងការទទួលទានបាយ គឺកុំឱ្យជ្រុះធ្លាក់រាត់រាយឥតប្រយោជន៍ ដោយពន្យល់ទៀតថា ការជ្រុះឥតប្រយោជន៍នេះនឹងទទួលបាបមិនខាន។ នៅពេលលាងអង្ករ ក៏លោកពន្យល់កុំឱ្យខ្ជះខ្ជាយដែរ គឺសម្រិតទឹកដោយប្រុងប្រយ័ត្ន។ ប្រសិនបើអង្ករដោយតាមទឹកខ្លះនោះ ត្រូវនិយាយសុំទោស ហើយជះទឹកដែលលាងមាន

អង្ករខ្លះនោះទៅឱ្យសត្វមាន់ ចាបស៊ី ដើម្បីបានជាប្រយោជន៍ក្នុងការសាងកុសលផង។ ដោយឡែកពិធីបុណ្យនេះ មានអត្ថន័យដ៏វិសេសវិសាលមួយទៀតគឺដើម្បីរំឭកគុណចំពោះបុព្វការីជនទាំងឡាយដែលបានខិតខំកាប់គាស់ព្រះធរណីដើម្បីឱ្យគេមានដីស្រែធ្វើ និងរំឭកគុណដល់ព្រះភិរុណ ដែលបានបង្អុរមកគ្រប់គ្រាន់ ធ្វើឱ្យដំណាំរបស់គេបានដុះលូតលាស់ និងចេញផ្លែផ្កាបានល្អ។ម្យ៉ាងទៀតក្នុងពិធីបុណ្យនេះក៏បានរៀបចំបួងសួងសែនព្រេងផងដែរដល់ព្រះភូមិ ដែលជាម្ចាស់ទឹកម្ចាស់ដី និងដល់វត្ថុសក្តិសិទ្ធនានា សូមមេត្តាជួយឱ្យគេបានសេចក្តីសុខ ជួយឱ្យបានភោគផលស្រូវទៅថ្ងៃមុខច្រើនបរិបូណ៌។

ម្យ៉ាងទៀត ពិធីនេះក៏បានផ្តល់លទ្ធភាពឱ្យប្រជាកសិករជួបជុំមូលមិត្តជិតឆ្ងាយបានពិភាក្សាគ្នាទៅវិញទៅមកអំពីផលស្រូវ និងរឹតចំណងសាមគ្គីភាព មនោសញ្ចេតនា រវាងញាតិមិត្តជិតឆ្ងាយទាំងអស់ផងដែរ។

**គ-ប្រវត្តិ**

បុណ្យដារលាន បានកើតមានមុនសង្គមខ្មែរដែលប្រកាន់យកជំនឿព្រហ្មញ្ញសាសនាមកម្ល៉េះដោយកាលនោះជនជាតិខ្មែរតែងគោរពជំនឿទស្សនៈជីវចលនិយម។ ប្រវត្តិសាវតារនៃពិធីបុណ្យដារបាតលាន កើតមានយូរយារណាស់មកហើយ ដោយគេមិនដឹងអំពីកាលបរិច្ឆេទច្បាស់លាស់ឡើយ ប៉ុន្តែពិធីបុណ្យដារលានមានការរីកចម្រើននៅក្នុងរជ្ជកាលព្រះបាទជយវរ្ម័នទី៧ ដែលអតីតព្រះមហាក្សត្រអង្គនេះមានព្រះរាជហឫទ័យយកចិត្តទុកដាក់លើវប្បធម៌អារ្យធម៌របស់ខ្មែរយើង។ នៅពេលប្រជាកសិករចាប់ផ្តើមធ្វើស្រែចម្ការ

ពួកគាត់តែងតែមានជំនឿថា កសិផលដែលកើតពីកសិកម្ម មានអាទិទេពជួយថែរក្សា ជួយឱ្យកើត និងធ្វើឱ្យវិនាសផងដែរ។ ដោយសារតែមានជំនឿបែបនេះហើយ ទើបបានជាមនុស្សជំនាន់មុននៅតែរក្សាគោលគំនិតថា ផលដំណាំមានអាទិទេពជួយថែរក្សា មានអ្នកតាគ្រប់គ្រង។ ដូច្នេះហើយ នៅពេលប្រកបរបរធ្វើស្រែចម្ការ ខ្មែរយើងរមែងរៀបរយសែនព្រេង ដើម្បីឱ្យអ្នកតាជួយរក្សាទឹកដីឱ្យផលដំណាំមានភាពចម្រុងចម្រើន។ ចំណែកអ្នកថែទាំទឹកដីមិនមានឈ្មោះប្រាកដនោះទេ ដោយសំអាងទៅលើទម្លាប់ហៅទៅតាមតំបន់នីមួយៗ។ គួរកត់សម្គាល់ផងដែរចំពោះស្រែណាដែលមានអ្នកតាគង់នៅគឺអ្នកស្រុក តែងនិយមរៀបចំសែនព្រេងយ៉ាងអ៊ឹកធឹក ដោយមានរៀបចំជាបាយស្លក សម្លរស្លក ស្រា ហើយពេលសែនព្រេនចប់ អ្នកស្រុកនាំគ្នាផឹកស៊ីយ៉ាងសប្បាយជាកិច្ចផ្តល់កិត្តិយសដល់អ្នកតា។ លុះក្រោយរៀងមក ខ្មែរយើងបានកំណត់យកពិធីសែនព្រេនអ្នកតាក្នុងជំនឿទស្សនៈជីវចលនិយម មកប្រារព្ធជាពិធីបុណ្យដារលានរហូតមកដល់បច្ចុប្បន្ន។

**ឃ-មូលហេតុ**

សេចក្តីដូចបានរៀបរាប់ខាងលើបង្ហាញឱ្យឃើញថា ពិធីបុណ្យដារលានកើតតាំងពីយូរយារណាស់មកហើយ ដែលពុំមានឯកសារណាមួយ ឬនរណាម្នាក់អាចបញ្ជាក់ ឬចាំច្បាស់អំពីកាលបរិច្ឆេទនោះទេ។ ប៉ុន្តែ មូលហេតុគួរឱ្យជឿបាន ដែលធ្វើឱ្យមានពិធីបុណ្យនេះ គឺយើងទទួលបានឯកសារពីវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ និងព្រះគ្រូ សោម សាម៉ន អនុគណស្រុកអង្គរជុំ និង

ជាព្រះគ្រូចៅអធិការវត្តចារឈូករង្សី ដែលមានខ្លឹមសារ និងនិទានកថាដូចតទៅ៖

## ខ-រឿងកសិករឈ្មោះចុល្លកាឡ (អានិសង្សនៃការធ្វើបុណ្យទានក្នុងរដូវធ្វើស្រែ(ឯកសារពីវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ)

កាលពីព្រេងនាយ រាប់អំពីភទ្ទកប្បយើងទៅអតីតកាលចំនួន៩១កប្ប មានព្រះពុទ្ធមួយអង្គព្រះនាម វិបស្សី ទ្រង់ឧប្បត្តិកឡើងក្នុងលោក។ គ្រានោះ មានកុដុម្ពិកៈពីរនាក់ជាបងប្អូនបង្កើតនឹងគ្នាជាកសិករ។ បងឈ្មោះ មហាកាឡ និងប្អូនឈ្មោះ ចុល្លកាឡ មានស្រែស្រូវសាឡីជាច្រើន។ ថ្ងៃមួយ ចុល្លកាឡ ដែលជាអ្នកមានសទ្ធាក្នុងព្រះពុទ្ធសាសនា បានដើរទៅមើលថែទាំស្រូវក្នុងស្រែ បានហែកបង្ហើបស្រូវសាឡីមកទំពារមានរសឆ្ងាញ់ ក៏កើតបុព្វចេតនាចង់ឱ្យទានចំពោះព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ទើបចូលទៅនិយាយប្រាប់មហាកាឡជាបងថា យើងគិតហែកបង្ហើបស្រូវសាឡីកិនចម្អិនលាយ ទឹកដោះថ្វាយព្រះសម្ពុទ្ធ ប្រហែលជាបានបុណ្យច្រើនណាស់។ មហាកាឡ តបថា ម៉េចឯងនិយាយចង្រៃយ៉ាងហ្នឹង! គេមិនដែលធ្វើស្រូវកំពុងជិតចេញផ្លែឱ្យវិនាសដូច្នេះទេ។ ចុល្លកាឡ ចេះតែអង្វរបងជាច្រើនដង បងមិនព្រមសោះ បែរជាត្រឡប់និយាយតបប្អូនវិញថា បើឯងនៅតែចចេសបំផ្លាញស្រូវដូច្នេះ ត្រូវចែកស្រែគ្នាចុះ ស្រែណាជាចំណែកអញ ឯងកុំពាល់ចំណែក ស្រែរបស់ឯង ឯងចង់ធ្វើយ៉ាងណាក៏តាមតែចិត្តរបស់ឯងចុះ។ ចុល្លកាឡមានសេចក្តី

គ្រេកអរណាស់ក៏ប្រាប់បងថា ស្រួលហើយចែកឱ្យខ្ញុំចុះ ដើម្បីខ្ញុំបានធ្វើទានក្នុងពេលឆាប់ៗនេះ កុំឱ្យស្រូវចេញផ្លែទាន់។ លុះបងចែកស្រែឱ្យហើយ ចុល្លកាឡ ក៏នាំមិត្តជាច្រើនទៅជួយហែកបង្អើបស្រូវយកមកកិនចម្អិនលាយទឹកដោះស្រស់ផ្សំដោយសប្បិ ទឹកឃ្មុំ ស្ករក្រាម យកទៅថ្វាយភិក្ខុសង្ឃ ដែលមានព្រះពុទ្ធវិបស្សីជាប្រធាន ហើយប្រាថ្នាថា ទានរបស់ខ្ញុំព្រះអង្គនេះជាទានកើតអំពីស្រូវដំបូងបំផុត ជាទានប្រសើរ ខ្ញុំសូមឱ្យបានត្រាស់ដឹងនូវធម៌ប្រសើរមុនគេក្នុងអនាគតកុំខាន។ ព្រះពុទ្ធវិបស្សី ក៏អនុមោទនាថា សូមអ្នកបានសម្រេចដូចសេចក្តីប្រាថ្នាចុះ។ លុះបានទទួលពរនេះហើយ ក៏ថ្វាយបង្គំលាត្រឡប់ទៅផ្ទះវិញ បានចូលទៅមើលស្រែម្តងទៀត ស្រាប់តែឃើញដើមស្រូវដែលបានហែកហើយនោះបញ្ចេញផ្លែគ្រប់ដើមដូចជា គេចងកណ្តឹង បីតិទាំង៥ក៏កើតមានគំនិតឡើងគិតថា បុណ្យឱ្យផលអញជាក់ស្តែងណាស់តើ ដូច្នេះអញត្រូវលៃធ្វើទានក្នុងរដូវធ្វើស្រែនេះឱ្យបាន៩ដងក្នុងមួយរដូវ។ លុះដល់ស្រូវនោះល្មមធ្វើអំបុកចុល្លកាឡធ្វើទានម្តងទៀតជាលើកទី២ស្រូវក្នុងស្រែជុះវិញដូចដើមដល់ពេលច្រូតកាត់ធ្វើទានម្តងទៀតជាលើកទី៣ ដល់ពេលហាល ដៃធ្វើទានម្តងទៀតជាលើកទី៤ ដល់ពេលចងកណ្តាប់ធ្វើទានម្តងទៀតជាលើកទី៥ ដល់ពេលជញ្ជូនកណ្តាប់ដាក់លានធ្វើទានម្តងទៀតជាលើកទី៦ ដល់ពេលបែនបោកធ្វើទានម្តងទៀតជាលើកទី៧ ដល់ពេលរោយស្រូវចាក់ជារធ្វើទានម្តងទៀតជាលើកទី៨ និងដល់ពេលដឹកស្រូវចាក់ ជង្រុកធ្វើទានម្តងទៀតជាលើកទី៩។ ចុល្លកាឡ បានធ្វើភត្តទានអស់វារៈ៩ដង ក្នុងមួយរដូវធ្វើស្រែ

ដូច្នេះស្រូវ សាឡីចេះតែចម្រើនឡើងឥតមានខូចខាតឡើយ។ ដល់ពេលធ្វើមរណកាលទៅ កសិករចុល្លកាឡ បានទៅសោយសេចក្តីសុខក្នុងទេវលោក និងមនុស្សលោកជាយូរអង្វែង លុះមកខាងចុងនៃកប្បមួយរាប់អំពីភទ្ទកប្បនេះទៅចំនួនមួយសែនកប្ប គាត់បានកើតក្នុងត្រកូលអ្នកមានទ្រព្យម្នាក់ បានធ្វើមហាទានអស់៧ថ្ងៃទៀត ក្នុងសាសនាព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈ ក្នុងនគរហង្សាវត្តី លុះថ្វាយមហាទានហើយ គាត់ចូលទៅក្រាបថ្វាយព្រះបាទានៃព្រះពុទ្ធអង្គនោះ សូមប្រាថ្នាឱ្យបានត្រាស់ដឹងអគ្គធម៌មុនគេទៀត។ លុះមកដល់ភទ្ទកប្បនេះ គាត់បានមកកើតក្នុងត្រកូលព្រាហ្មណ៍ មហាសាលក្នុងស្រុកទោណវត្ថុ ជិតក្រុងកបិលពស្តុ មានឈ្មោះថា កោណ្ឌញ្ញៈ កើតមុនព្រះសម្ពុទ្ធបរមគ្រូចាប់បដិសន្ធិជាច្រើនឆ្នាំ។ កាលមានវ័យធំហើយមាតាបិតាបានឱ្យសិក្សារៀនសូត្ររហូតដល់ចេះចប់គម្ពីរត្រៃវេទ និងតម្រាទាយមហាបុរិសលក្ខណៈ។ ទីបំផុតធម៌ទេសនាក្រោយបានស្តាប់ធម្មទេសនារបស់ព្រះពុទ្ធ កោណ្ឌញ្ញភិក្ខុ បានសម្រេចសោតាបត្តិផលមុនគេក្នុងលោក ទើបព្រះសម្ពុទ្ធទ្រង់បន្លឺឧទានថា "អញ្ញាសិវតកោ កោណ្ឌញ្ញោ អញ្ញាសិ វត កោ កោណ្ឌញ្ញ" ប្រែថា កោណ្ឌញ្ញៈ បានដឹងធម៌ហើយហ្ន៎ៗ។ អាស្រ័យព្រះឧទាននេះ ទើបមានពាក្យថា ធញ្ញកោណ្ឌញ្ញ ជាប់ជានាមរបស់លោកតមកក្នុងប្រវត្តិពុទ្ធសាសនា។ ដោយបានយល់នូវសាច់រឿង (អានិសង្សនៃការធ្វើទានក្នុងរដូវធ្វើស្រែ)រួចមក ទើបកសិករខ្មែរចាប់ផ្តើមរៀបចំពិធីបុណ្យដារលាននេះឡើង។

## ច-រឿងស្នេហាកំឡោះក្រមុំក្នុងជង្រុកស្រូវ

និទានកថារបស់ព្រះគ្រូ សោម សាម៉ន តាមប្រវត្តិរឿងព្រេងទាក់ទងពិធីបុណ្យដារលានរបស់បងប្អូនប្រជាពលរដ្ឋនៅខេត្តសៀមរាប ជាពិសេសតាមសង្ឃដីការបស់ព្រះគ្រូ សោម សាម៉ន អនុគណស្រុកអង្គរជុំ និងជាព្រះគ្រូចៅអធិការវត្តចារឈូករង្សី បាននិទានថា ពិធីបុណ្យដារលាន មានតាំងពីមុនសម័យពុទ្ធកាលមកម្ល៉េះ ដែលតាមការនិទានតៗគ្នាមកថា ទង្វើនេះកាលណាធ្វើហើយតែងតែទទួលបានផលល្អ ហើយនិងមានជំនឿថា បើបានធ្វើបុណ្យដារលានហើយ ឆ្នាំក្រោយនឹងកើតភោគផលកាន់តែច្រើនជាងឆ្នាំនេះទៅទៀត[227]។ រឿងនិទានតែងដំណាលថា នៅសម័យមុនពុទ្ធកាលនោះ ស្រូវដែលបានយកទៅសាបព្រោះលើព្រះធរណីហើយ តែងតែដុះលូតលាស់និងផ្តល់ផលផ្កាផ្លែដោយឯកឯងរហូតដល់ពេលប្រមូលផល មិនបាច់ទៅច្រូតកាត់បោកបែន និងដឹកជញ្ជូនមកផ្ទះទេ គឺម្ចាស់ស្រែគ្រាន់តែយកសំណែនដែលមានបង្អែមចង្ហាបផ្សេងៗទៅ សែនព្រេននៅឯវាលស្រែ ហើយគ្រាន់តែឧទ្ទិសប្រាប់ព្រលឹងស្រូវថា “ជង្រុកស្រូវបានរៀបចំនៅឯផ្ទះរួចហើយ សូមផលស្រូវហោះដើរទៅចូលជង្រុកនោះចុះ”ជាការស្រេច។ ផលស្រូវតែងតែហោះហើរចូលជង្រុកដោយខ្លួនឯង(មានជំនឿថា កាលនោះគ្រាប់ស្រូវមានស្លាប)។ ប៉ុន្តែមានសម័យយប់មួយក្នុងគ្រួសារមួយដែលមានកូនក្រមុំព្រហ្មចារីនីម្នាក់បានណាត់ជាមួយសង្សាររបស់ខ្លួនចូលទៅសាសងស្នេហាក្នុងជង្រុកស្រូវចំ

[227]ឯកសារដដែល

ពេលដែលផល ស្រូវកំពុងហោះហើរចូលក្នុងជង្រុករំខានដល់ការសាសង របស់គួសង្ក្រារ ធ្វើឱ្យក្រមុំកំលោះទាំងពីរខឹងសម្បាហើយក៏ជេរប្រទេចផ្ដាសារ ផលស្រូវដែលកំពុងហោះហើរចូលជង្រុកនោះ។

ផលស្រូវបានឮពាក្យជេរប្រទេចយ៉ាងដូច្នេះ ក៏ខឹងមួរម៉ៅយ៉ាងខ្លាំង ឥតឧបមា ហើយក៏ស្រែកតបតមកថា "ចាប់ពីពេលនេះទៅ បើមិនយកវត្ថុអ្វី ទាក់កអញទេ អញមិនហោះហើរចូលក្នុងជង្រុកទៀតឡើយ" ហើយចាប់ពី ពេលនោះមក ពេលស្រូវទុំល្មមនឹងប្រមូលផល យើងទាំងអស់ត្រូវទៅច្រូត ដោយយកកណ្ដៀវកាត់ ហើយចងជាកណ្ដាប់ និងបោកបែនដឹកជញ្ជូនចូលជ ង្រុកទើបមានផលស្រូវក្នុងជង្រុកបាន។ ទោះបីយ៉ាងនេះក៏ដោយ ដើម្បីឱ្យ ផលស្រូវបានគង់វង្សនិងកើនឡើងថែមទៀតនៅឆ្នាំក្រោយនោះ ប្រជាកសិករ តែងប្រារព្ធធ្វើពិធីបុណ្យដារលានអន្ទងព្រលឹងស្រូវឱ្យសណ្ឋិតក្នុងជង្រុក ក្រោយពេលប្រមូលផល និងដឹកជញ្ជូនស្រូវចូលក្នុងជង្រុករួចរាល់ជារៀង រហូតមកទល់ពេលបច្ចុប្បន្នកាលនេះ។

## ពិធីហៅព្រលឹងស្រូវ

ពិធីហៅព្រលឹងស្រូវមានគោលបំណងសុំខមាទោសស្រូវដែលគូ សង្សារបានជេរប្រទេចផ្ដាសារ។ពិធីនេះត្រូវរៀបចំរកស្រីក្រមុំព្រហ្មចារីនីចំនួន ៦នាក់ និងកំលោះព្រហ្មចារីចំនួន៦នាក់ (ជំនឿនេះតាមព្រហ្មញ្ញសាសនា) កាន់កញ្ជើដាក់កណ្ដាប់ស្រូវ។ត្រូវមានយាយម្នាក់កាន់កញ្ជើស្រូវនាងគង់ ជញ្ជាត់ហៅព្រលឹងស្រូវ ហើយស្រែកថា១-២-៣-៤-៥-៦-៧-៨-៩ រហូតដល់

១៩សព្វគ្រប់បរិបូណ៌ឱ្យព្រលឹងស្រូវមកសណ្ឋិតឱ្យបានភោគផលសម្បូររុងរឿងនៅឆ្នាំក្រោយ។ មានលោកអាចារ្យម្នាក់ទៀត យកដើមឫស្សីវែងធ្វើជាត្រកដាក់នំចំណីដែលធ្វើពីស្រូវដោតដាក់កណ្តាលស្រែរួចនិយាយថាសត្វស្រមោច សង្ការបក្សាបក្សីទាំងឡាយអើយមកទទួលយកទៅសេពសោយចុះនូវសំណែនទាំងអស់នេះ ពីព្រោះមនុស្សមិនបានយកស្រូវមកដាក់ក្នុងជង្រុកអស់ទេ សូមអ្នកទទួលយកសំណែនទាំងនេះទៅបរិភោគ ហើយឱ្យសព្វសាធុការពរដល់ប្រជាកសិករដែលជាម្ចាស់ភោគផលបានសុខសប្បាយ គង់ទ្រព្យគង់សម្បត្តិ គង់យស គង់សក្តិ គង់ប្រាក់ គង់មាសជានិច្ចនិរន្តរ៍រៀងទៅ។

## ឆ-ពេលវេលា និងកិច្ចដំណើរការពិធីបុណ្យ

ការកំណត់រៀបចំពិធីបុណ្យនេះយោងតាមការសន្មតក្នុងភូមិ និងតំបន់នីមួយៗ ក្រោយពេលគេប្រមូលភោគផលស្រូវបានចប់គ្រប់គ្នាអស់ហើយ។ ប៉ុន្តែមានស្រុកខ្លះគេធ្វើនៅពេលស្រូវចេញ ដើម្បីអបអរសាទរចំពោះផលស្រូវដែលបានចេញជាផ្លែផ្កា។ ជាទូទៅនៅតំបន់ដាំដុះស្រូវ រដូវវស្សាដោយពឹងផ្អែកទឹកភ្លៀង គេច្រើនប្រារព្ធពិធីនេះនៅក្នុងខែធ្នូ ឬ ខែមករា (មិគសិរ-បុស្ស) បន្ទាប់ពីប្រមូលផលរួចរាល់។ ដោយឡែកនៅតំបន់តាមដងទន្លេ ដែលមានផ្ទៃដីដាំដុះដំណាំស្រូវតែរដូវប្រាំងវិញនោះ គេច្រើនប្រារព្ធពិធីបុណ្យដារលាននៅក្នុងខែឧសភា-មិថុនា(ពិសាខ-ជេស្ឋ)បន្ទាប់ពីបានប្រមូលផលស្រូវរួចរាល់។ ចំពោះកាលបរិច្ឆេទដាក់លាក់នៃពិធីបុណ្យ កាលពីសម័យដើមជនជាតិខ្មែរនិយមធ្វើបុណ្យដារលានដោយកំណត់ថ្ងៃប្រារព្ធពិធីបុណ្យពី

ព្រះសង្ឃប៉ុន្តែនាសម័យបច្ចុប្បន្ន កាលបរិច្ឆេទនៃពិធីបុណ្យត្រូវបានកំណត់ដោយចាស់ទុំក្នុងភូមិជាអ្នកសម្រេច ក្រោយពេលពិគ្រោះយោបល់គ្នាដើម្បីលៃលកឱ្យចំពេលទំនេររបស់អ្នកភូមិ ជាពិសេសឱ្យចំថ្ងៃសៅរ៍ ឬអាទិត្យ ដើម្បីទុកលទ្ធភាព ឱ្យកូនចៅដែលធ្វើការនៅឆ្ងាយមានឱកាសបានចូលរួមក្នុងពិធីនេះ។ មុននឹងដំណើរការពិធី គេត្រូវរៀបចំទីតាំងនៅលើដីវាលស្រែណាមួយសិន ដោយត្រូវជម្រះគល់ជញ្ជ្រាំងស្រូវឱ្យដីរាបស្មើរួចយកលា មកគោស្រស់លាយទឹក ហើយលាយដីដំបូកឱ្យជ្រាយល្មម ចាក់ពង្រាយ លើបរិវេណដីដែលបានជម្រះស្អាតហើយនោះ។ បន្ទាប់មកគេយករនាស់ដៃរុញឱ្យស្មើរហូតដល់ស្ងួតបែស ដែលគេហៅថា "ឡើងលាន"។ កម្មវិធីនៃពិធីដារលានមិនមានភាពស្មុគស្មាញអ្វីច្រើនទេ តែមានភាពអឺកធឹកដោយសារមានវង់តន្ត្រីពិណពាទ្យកំដរ និងអ្នកស្រុកក្នុងភូមិទាំងអស់ឯកភាពគ្នាជួបជុំយ៉ាងច្រើនកុះករ។ នៅពេលព្រឹក អ្នកស្រុករួមភូមិមកជួបជុំគ្នាដើម្បីរៀបចំរណ្តាប់ផ្សេងៗសម្រាប់ថ្វាយដល់គុណព្រះរតនត្រៃព្រះភូមិ[228]។ ជាមួយគ្នានេះដែរ គេបានយកម្ហូបអាហាររៀងៗខ្លួនសម្រាប់ប្រគេនព្រះសង្ឃ និងសម្រាប់ហូបចុកជួបជុំគ្នាក្នុងការរឹតចំណងសាមគ្គីភាព។ កម្មវិធីជាបន្តគឺព្រះសង្ឃនិមន្តមកសូត្រមន្តប្រោះព្រំប្រសិទ្ធពរជ័យដល់ភូមិ និងអ្នកភូមិ បន្ទាប់មកគេវេរភត្តា ហារប្រគេនព្រះសង្ឃឆាន់។ ជាមួយគ្នានេះដែរ គេក៏ត្រូវរៀបចំសែនព្រេនដល់ព្រះភូមិដែលជាម្ចាស់ទឹក ម្ចាស់ដី និងដល់វត្ថុសក្តិសិទ្ធិ សូមមេត្តាជួយឱ្យគេបានសេចក្តីសុខ

---

[228] ឯកសារដដែល

ជួយឱ្យបានភោគផលស្រូវទៅថ្ងៃមុខ ច្រើនបរិបូណ៌ដោយកុំឱ្យមានសត្វល្អិតសត្វកណ្ដុរ ឬចាប សេក ស៊ីបំផ្លាញស្រូវឱ្យសោះ។ គេក៏មិនអាច បំភ្លេចបានដែរនូវការបន់ស្រន់សុំខមាទោសពីព្រះមេ សូមមេត្តាអនុគ្រោះចំពោះអំពើឆាំឆ្ង ដែលតែងតែកើតមានដោយថាហេតុណាមួយ។ ពិធីជាបន្ត គឺជាការដារឆ្លងបុណ្យ និងប្រោះព្រំទឹកមន្តដល់អ្នកដែលបានចូលរួម។ ដើម្បីជាកិច្ចបញ្ចប់កម្មវិធីគឺការលៀងភោជនាហារ។ ពិធីជាផ្លូវការនៃការដារលានបានបញ្ចប់មែនតែការកំដរជីវិតក្រោយពេលបំពេញការងារយ៉ាងផ្លូវផ្ដាច់អស់មួយរដូវកន្លងមក ទ្រាំទ្រក្រោមកម្ដៅថ្ងៃ ឬតំណក់ទឹកភ្លៀងនោះ បានធ្វើឱ្យគេមានការនឿយហត់យ៉ាងខ្លាំង។ដូច្នេះឱកាសនេះ គេត្រូវការសម្រាកកម្សាន្តខ្លះដែរ។ ការសម្រាកកម្សាន្តនៃអ្នករស់នៅជនបទ គឺគេប្រមូលគ្នាដោយណាត់ទីមកកន្លែងដារលាននេះក្នុងពេលព្រលប់ ត្រដាក់ដើម្បីរាំកម្សាន្ត។ គេក៏អាចណាត់គ្នា នៅទីធ្លាកណ្ដាលភូមិ ឬនៅមុខផ្ទះនរណាម្នាក់ដែលមានធ្លាធំអាចដំណើរការបានស្រួលដែរ។ ពិធីដារលាន និងការរាំកម្សាន្តក្រោយពេលបំពេញការងារ ដែលយើងបានរៀបរាប់មកនេះ វាគ្រាន់តែជាការតំណាងឱ្យពិធីដទៃផ្សេងទៀតដែលខ្មែរយើងតែងនិយមរៀបចំក្រោយបំពេញភារកិច្ច ដោយមិនសូវអាក់ខានឡើយ។ កិច្ចប្រារព្ធពិធីទាំងអស់នេះ គឺជាប្រពៃណី ជាទម្លាប់ ឬជាសីលធម៌ដែលខ្មែរតែងរៀបចំ ដើម្បីដឹងគុណចំពោះអ្នកដែលមានគុណទាំងឡាយ និងដើម្បីសម្រាកកម្សាន្តសប្បាយ ឬដើម្បីភ្ជាប់មនោសញ្ចេតនាសាមគ្គីភាពរវាងញាតិមិត្តជិតឆ្ងាយទាំងអស់។ ម្យ៉ាងទៀតការរៀបចំពិធីនីមួយៗ នោះ មិន

មានអ្នកជំហរចេញប្រាក់កាសទេ តែកើតដោយចិត្តសទ្ធាជ្រះថ្លារៀងៗខ្លួន ដែលគេមានជំនឿក្នុងការកសាងកុសលដោយមិនមើល បំណាំថា អ្នកណាចេញច្រើន អ្នកណាចេញតិចឡើយ។ គេតែងអនុគ្រោះឱ្យគ្នាទៅវិញទៅមកតាមលទ្ធភាពក្នុងគ្រួសារម្នាក់ៗហើយប្រមូលផ្តុំម្ហូបអាហារចែកចាយគ្នាហូបជារង់ព័ទ្ធជុំវិញម្ហូបអាហារដ៏ពោរពាស។ ចំពោះសិល្បៈសម្រាប់ការកម្សាន្តពេលរាត្រីក៏កើតមានឡើងដោយការស្រុះស្រួលគ្នា គឺគេចាត់ចែងយ៉ាងណាឱ្យមានដោយខានមិនបាន ព្រោះប្រជារាស្ត្រខ្មែរច្រើនតែជាអ្នកមាននិស្ស័យសិល្បៈ។

## ជ-សេចក្តីសន្និដ្ឋាន

មនុស្សគ្រប់រូបមិនថាជាតិសាសន៍ណា ឬជនជាតិណាឡើយ សុទ្ធតែមានមនោសញ្ចេតនាជក់ជាប់យ៉ាងជ្រាលជ្រៅនឹងមាតុភូមិរបស់ខ្លួន(មាតុ+ភូមិ=ភូមិកំណើតទឹក/ដីកំណើត)។ ទោះបីអ្នកខ្លះនៅពេលធំពេញវ័យមានការប្រែប្រួល ឬផ្លាស់ប្តូរលំនៅដ្ឋានទៅរស់នៅដល់ទីណាក្តីក៏ទឹកចិត្តរបស់យើងនៅតែនឹកដល់អនុស្សាវរីយ៍ និងសកម្មភាពទាំងឡាយតាំងពីអតីតកាលរហូតដល់បច្ចុប្បន្នដែរ ជាពិសេសក្នុងមជ្ឈឹមវ័យរបស់ពួកយើងម្នាក់ៗ។ អតីតកាលតែងតែចាប់អង្រួនបេះដូងយើងឲ្យនឹកឃើញជានិច្ចនូវមនោសញ្ចេតនាស្នេហា សប្បាយ ការស្រងេះស្រងោច ឬភាពអាណិតអាសូរភូមិស្រុក ឬស្រុកទេសរបស់យើងជានិច្ច។ យើងមិនអាចបំភ្លេចបានទេរាល់អ្វីៗទាំងអស់ដែលយើងបានជួបប្រទះក្នុងស្រុកភូមិរបស់យើងកាលវ័យកុមារ។ យើងតែងតែនឹក

ឃើញនិងឮសំឡេងមាន់រងាវសត្វយំ សូរទឹកភ្លៀងធ្លាក់លើដំបូលផ្ទះទេសភាព វាលស្រែចំការនានៃពេលថ្ងៃរះ និងផ្ទៃមេឃនាពេលអស្តង្គតនៅខាងកើត និង ខាងលិចភូមិរបស់យើង។ ការនឹករលឹកស្រុកកំណើត ការចេះព្រួយបារម្ភពី ស្រុកកំណើតការចង់ឲ្យស្រុកកំណើតមានសេចក្តីសុខក្សេមក្សាន្តមានការ អភិវឌ្ឍចម្រុងចម្រើន។ល។ តើមាននរណាខ្លះដែលមិនខ្វល់ពីសុខទុក្ខ របស់ស្រុកកំណើតនោះ? កុំថាឡើយខ្លួនយើងឃ្លាតឆ្ងាយពីស្រុកកំណើតដ៏ សែនឆ្ងាយ ឬត្រូវគេមានគេដណ្តើមបាត់នោះសូម្បីតែមានគេនិយាយមិនល្អពី ស្រុកកំណើតក៏មិនចង់ឮផង។ ការប្រើសំណេរនៃឈ្មោះភូមិខុសមួយរយៈ កន្លងទៅ បានធ្វើឲ្យខ្ញុំគិតច្រើនណាស់ ហើយទីបំផុតខ្ញុំបានសម្រេចចិត្តរិះរក មធ្យោបាយដើម្បីសុំការកែប្រែពីការសរសេរខុសនេះ ទោះបីជាត្រូវឆ្លងកាត់ រយៈពេលយូរបន្តិចក៏ដោយចុះ។ ដោយមិនបង្អង់យូរ ខ្ញុំខិតខំស្រាវជ្រាវ ព័ត៌មាន និងស្វែងរកភស្តុតាងផ្សេងៗដើម្បីទុកជាមូលដ្ឋានក្នុងដំណើរការ ស្នើសុំកែប្រែនេះ។ សៀវភៅស្រីហិតោបទេសបានសរសេរថា "គ្មានសត្វម្រឹក ឯណារត់ចូលមាត់សឹង្ហដែលកំពុងតែដេកនោះទេ " ។

សុភាសិតបារាំងមួយឃ្លាថា"Le résultat indique lemoyen" "លទ្ធ ផលវាបង្ហាញឲ្យយើងដឹងអំពីមធ្យោបាយ"។

ខ្ញុំពិតជាមានមោទនភាពយ៉ាងខ្លាំងដោយសំណើរបស់ខ្ញុំដែលសុំកែ ប្រែសំណេរឈ្មោះភូមិសមរលាវ សមរខ្មែរ ពីខុសឲ្យមកត្រូវវិញបានសម្រេច។ ឥឡូវនេះឈ្មោះភូមិទាំងបីនេះបានសរសេរត្រូវដូចដើមវិញហើយ សូមកូនចៅ

ជំនាន់ជួយថែរក្សាទុកផង ចៀសវាងមានការខុសឆ្គងម្តងទៀត។

តាមរយៈសៀវភៅដ៏ស្តើងនេះ បានបង្ហាញយ៉ាងច្បាស់ចំពោះការប្រើប្រាស់សំណេរទាំងអស់មិនថា នៅស្ថាប័នឯកជន ឬសាធារណៈរបស់យើង ក្នុងការសរសេរឈ្មោះមនុស្ស បុគ្គល ឬភូមិឃុំស្រុកខណ្ឌខេត្តនានាត្រូវប្រុងប្រយ័ត្ន និងជៀសវាងការសរសេរអក្សរខុសដូចករណីភូមិសមរលាវ សមរខ្មែរនេះស្រាប់ជាមួយគ្នានេះសាមីខ្លួន សាមីបុគ្គល ឬស្ថាប័នក៏ត្រូវពិនិត្យមើល និងសុំតវ៉ាឲ្យបានជាមុនទាន់រឿងនេះមិនទាន់ត្រូវបានចុះក្នុងបញ្ជី ឬឯកសារផ្លូវការ ហើយធ្វើឲ្យប្រាកដថា ឈ្មោះខុសនោះត្រូវបានកែរួចរាល់។ ដូចគ្នាដែរ អាជ្ញាធរមានសមត្ថកិច្ចត្រូវបំពេញតួនាទីប្រកបដោយមនសិការ និងការទទួលខុសត្រូវជានិច្ច។

ដូចបានឃើញហើយ ការលើកឡើងក្នុងឧទាហរណ៍ខ្លះៗទាក់ទងនឹងការសរសេរខុសឈ្មោះបុគ្គល ទីតាំង ឬតំបន់ផ្សេងៗដែលបានរៀបរាប់សៀវភៅនេះ។ ជាការពិតណាស់ បញ្ហាខាងលើប្រសិនបើយើងក្រឡេកមួយភ្លែតវាមិនមែនជារឿងធំដុំទេ ប៉ុន្តែវាជាបញ្ហាមួយមិនអាចមើលរំលងជាដាច់ខាត។ នៅពេលមានការសរសេរខុស ហើយការខុសនេះក្លាយជាផ្លូវការហើយនោះ ទើបយើងនាំគ្នាស្តាយក្រោយ ហើយអ្នកស្រុក ម្ចាស់ស្ថាប័ន ឬសាមីខ្លួនតែងតែតាំងជាសំណួរថា តើរឿងនេះខុសតាំងពីពេលមក?អ្នកណាជាអ្នកផ្តើមបង្កើតកំហុសនេះ? គ្មាននរណាម្នាក់ចេញមុខទទួលខុសទេ។ ប្រវត្តិសាស្ត្រតែងតែបង្រៀនយើងឲ្យធ្វើត្រូវ។

យើងក៏សង្កេតឃើញអ្នកសារព័ត៌មាន អ្នកលេងបណ្ដាញសង្គមមួយចំនួនតូចក៏មានការអាន ការប្រើ ភាសានិយាយ ភាសាសរសេរមិនត្រឹមត្រូវដែរ ទាំងប្រព័ន្ធប្រព័ន្ធផ្សព្វផ្សាយវិទ្យុ ទូរទស្សន៍ កាសែត បណ្ដាញសង្គមហ្វេសប៊ុក ឬប៉ាណូផ្សាយពាណិជ្ជកម្មផ្សេងៗ សូម្បីអ្នកកាសែតអាជីព( Professional Journalism) ខ្លះនៅតែប្រើប្រាស់ពាក្យពេជន៍មិនទាន់ត្រឹមត្រូវមួយរយភាគរយនៅឡើយទេ ដូចជា ទីក្រុងភ្នំពេញ សាលាក្រុងភ្នំពេញ ខណៈដែលភ្នំពេញមិនមែនជាក្រុងទៀតទេ គឺជារាជធានី។ ខេត្តតាកែវ អ្នកខ្លះអានថា តាកេវ... កែវ អានថា កេវ..តួអក្សរខ្លះ ឬឈ្មោះទីតាំង ឬបង្គោលគីឡូម៉ែត្រខ្លះក៏ត្រូវសរសេរខុស ហើយពុំមានការកែប្រែនៅឡើយដែរ។ នៅប្រទេសយើង ការសរសេរឈ្មោះទីតាំងភូមិសាស្ត្រនីមួយៗ ពីស្រុកមួយទៅស្រុកមួយ ពីខេត្តមួយទៅខេត្តមួយគួរតែដាក់ឈ្មោះឲ្យបានច្រើនតាមតែអាចធ្វើទៅបានដើម្បីឲ្យអ្នកដំណើរឆ្ងាយៗបានស្គាល់ភូមិសាស្ត្រ ឬឈ្មោះកន្លែងណាមួយផង។ បង្គោលគីឡូម៉ែត្រនៅតាមដងផ្លូវនានាមួយចំនួនតូចត្រូវបាំងស្លឹកឈើ ស្មៅ ឬដើមទន្រ្ទានខេត្តជុះជិតតែម្ដងនាំឲ្យបាំងលេខបង្គោលគីឡូម៉ែត្រមើលមិនឃើញ។ ប្រជាពលរដ្ឋ សកម្មដែលរស់នៅចំទីតាំងទាំងនោះគួរត្រូវបានលើកទឹកចិត្តឲ្យចូលរួមជួយការងារសាធារណៈមួយនេះក្នុងការកាប់ស្ការឲ្យបានស្អាតផង។

សព្វថ្ងៃនេះក្រុមប្រឹក្សាជាតិភាសាខ្មែរនៃរាជបណ្ឌិត្យសភាកម្ពុជាបាននឹងកំពុងដើរតួនាទីយ៉ាងសំខាន់ធ្វើការពិភាក្សា វែកញែក និងអនុម័តវាក្យ-ស័ព្ទខ្មែរយើងពាក្យបច្ចេកទេសតាមវិស័យនីមួយៗដើម្បីកាន់តែភាសាខ្មែរ

កាន់តែសម្បូរបែបថែមទៀត។

ការស្រាវជ្រាវ និងសរសេរឲ្យទៅជាប្រវត្តិមួយជាក់លាក់ និងគ្រប់ជ្រុងជ្រោយបាននោះ វាជាការពិបាកខ្លាំងណាស់ ពីព្រោះទី១ អ្នកនិពន្ធទាមទារឲ្យប្រមូលព័ត៌មានបានគ្រប់គ្រាន់ ទី២ ត្រូវមានការសហការពីគ្រប់ប្រភព ឬដៃគូដែលស្គាល់ច្បាស់លាស់ពីប្រវត្តិរឿងរ៉ាវនានាដែលកើតមានលើទឹកដីនៃភូមិទាំងបី និងទី៣ យើងមិនអាចសរសេរដំណឹងមួយល្អឥតខ្ចោះដោយមិនមានឯកសារបន្ទាល់ ឬឯកសារយើងបានឡើយ។ នៅពេលប្រមូលបានដំណឹងផ្សេងៗគ្រប់គ្រាន់ហើយ ការសរសេរទៀតសោតក៏នៅមានកម្រិតដែរ ត្បិតថាពេលវេលាយើងក៏មិនសម្បូរហូរហៀសម្រាប់ធ្វើរឿងនេះតែមួយនោះក៏ទេដែរជាមួយគ្នានេះ អ្នកនិពន្ធពិបាកនិងគេចឲ្យផុតពីភាពខ្វះខាត និងការលម្អៀងផ្សេងៗជាយថាហេតុណាស់។ ដូច្នេះហើយ វត្តមាននៃការបោះពុម្ពផ្សាយសៀវ ភៅនេះលើកទី១ គុណភាពនៃសំណេរនៅមានកម្រិត ហើយយើងសង្ឃឹមថាសម្រាប់ការបោះពុម្ពលើកក្រោយៗនឹងមានការចូលរួមច្រើនពីប្រភពនានាក៏ដូចជាមតិយោបល់របស់ព្រះតេជគុណ ព្រឹទ្ធាចារ្យ អ្នកចេះដឹងជាច្រើនទៀតដើម្បីកែលម្អខ្លឹមសារនិងអត្ថន័យសៀវភៅនេះកាន់ល្អប្រសើរឡើងថែមទៀត ឆ្លងតាមរយៈការស្រាវជ្រាវ និងសរសេរសៀវភៅនេះអស់រយៈពេលច្រើនឆ្នាំមក យើងសូមធ្វើការវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលនានាដែលកើតមាននៅក្នុងទឹកដីភូមិសាស្ត្រនៃភូមិទាំងបីនេះ។ ទាំងអស់នេះមិនមានជាស្នាដៃរបស់អ្នកណាម្នាក់ផ្តាច់មុខឡើយ ប៉ុន្តែវាជាស្នាព្រះហស្តរបស់ព្រះតេជ

គុណគ្រប់ព្រះអង្គ លោកមេភូមិ លោកមេឃុំ លោកអភិបាលស្រុក អភិបាលខេត្ត លោកគ្រូ អ្នកគ្រូ នគរបាល កងរាជអាវុធហត្ថ អាជ្ញាធរ ដែនដី ដៃគូអភិវឌ្ឍពាក់ព័ន្ធ និងប្រជាពលរដ្ឋយើងពីមួយជំនាន់ទៅមួយជំនាន់ដែលជានិច្ចកាលលោកបាន សហការ សាមគ្គីគ្នាជាធ្លុងមួយថែរក្សា និងកសាងឥតឈប់ឈរទាំងហេដ្ឋារចនាសម្ព័ន្ធទន់ និងរឹងស្របតាមគោលនយោបាយ និងប្រពៃណីទំនៀមទម្លាប់ វប្បធម៌ និងអរិយធម៌ជាតិរបស់យើង។

ព្រះពុទ្ធព្រះបរមគ្រូនៃយើង បានមានបន្ទូលមុននឹងព្រះអង្គចូលព្រះនិព្ពានថា *អ្វីៗដែលកើតឡើងហើយ រមែងវិនាសទៅវិញវាជារឿងធម្មតា ចូរអ្នកបានចម្រើនដោយធម៌មិនប្រមាថ* ។ ព្រះបន្ទូលនេះពិតជាបានដក់ជាប់ក្នុងក្រអៅបេះដូងរបស់ពុទ្ធសាសនិកជនគ្រប់ៗរូបមិនខាន។ បានសេចក្តីថា អ្វីៗគ្រប់យ៉ាង ប្រសិនបើកើតឡើងហើយ វាគង់តែវិនាសបាត់បង់ទៅវិញនៅវេលាថ្ងៃណាមួយទេ ក្នុងករណីយើងខ្វះការប្រុងប្រយ័ត្ន ខ្វះការពិចារណា។ល។ ដូច្នេះ ចូរម្នាលពុទ្ធបរិស័ទទាំងអស់ កុំធ្វេសប្រហែស កុំប្រមាថ កុំគិតងាយជាក់ស្តែងដូចឈ្មោះភូមិរបស់យើងនេះស្រាប់។ប្រសិនបើយើងសរសេរដោយមិនបានគិតថាសំខាន់ មិនបានរក្សាឲ្យខ្ជាប់តាមសំណេរដើម តាមន័យដើមទេនោះវានឹងអាចរលុបបាត់នាពេលណាមួយរហូតធ្វើបាត់បង់ស្លាកស្នាមប្រវត្តិទៀតជាមិនខាន។ សូមកុំចាំបាច់ទាល់តែរបស់បាត់ទើបនាំគ្នាស្តាយ។ ការថែទាំទ្រព្យសម្បត្តិសាធារណៈជាកាតព្វកិច្ចរបស់ពលរដ្ឋទាំងអស់គ្នា។

# លិខិតចំហ
# ក្ដីស្រមៃរបស់ខ្ញុំ

*ព្រះតេជគុណ លោកតា លោកយាយ អ៊ំ ពូ មីង មា អស់លោក លោកស្រី ប្អូនៗ ក្មួយៗជាទីគោរពសក្ការៈ និងមេត្រី !*

ភូមិទាំងបី[ សមរលាវ សមរខ្មែរ សមរចិន] ជាកេរមរតកពីដូនតាដែលយើងជាកូនចៅបានរស់នៅយ៉ាងសុខក្សេមក្សាន្តតាំងពីយូរលង់ណាស់មកហើយរហូតមកដល់សព្វថ្ងៃនេះ។ តើយើងធ្លាប់បាននឹកគិតទេថា ថ្ងៃណាមួយនាពេលអនាគតភូមិស្ថានរបស់យើងក្លាយជាទីកន្លែងដែលមានគេចង់ស្គាល់ចង់មកទស្សនាទាំងអ្នករស់នៅក្នុងតំបន់ និងទីនានានៃដែនកម្ពុជាព្រមទាំងជនទេសចរបរទេសផងដែរ ?

**[ សមរភូមិលាវ សមរភូមិខ្មែរ សមរភូមិចិន]** តើកត្តាអ្វីខ្លះដែលអាចជំរុញឲ្យបំណងប្រាថ្នា និងក្ដីស្រមៃខាងលើនេះក្លាយជាការពិត ?ក្ដីស្រមៃខាងលើអាចក្លាយជាការពិត ប្រសិនបើអ្នកពាក់ព័ន្ធ( ប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋាន )ចូលរួមធ្វើជាមួយគ្នា។ ការប្រែក្លាយភូមិស្ថានយើងឲ្យទៅជាឧទ្យាន ឬរមណីយដ្ឋានទេសចរណ៍ធម្មជាតិ ឬកែច្នៃឲ្យស្រស់បំព្រងមួយបាន លុះត្រាតែអ្នកភូមិយើងចូលរួម និងអនុវត្តធ្វើកិច្ចការសំខាន់ៗដូចខាងក្រោម៖

១-ក្នុងទីអារាមៈ គ្រប់វត្តនីមួយៗត្រូវមានទីធ្លាស្អាត ថែទាំ រៀបចំឲ្យមានសួនច្បារផ្កាចម្រុះពណ៌ ដើមឈើធំៗប្រព័ន្ធទឹកស្រោចស្រព ទីធ្លាសម្រាប់មហោស្រព( បើអាច ) ទីធ្លាសម្រាប់កំសាន្ត ចំណតយានយន្ត កន្លែងដុត ឬកែច្នៃសំរាម បង្គន់អនាម័យ។ល។ ព្រះវិហារ សាលាធម្មសភា កុដិផ្សេងៗសាងសង់ឡើងឲ្យមានក្បូរក្បាច់រចនា ឬរចនាបទឲ្យបានត្រឹមត្រូវទៅតាមទស្សនៈ

(សម័យបុរាណ ឬទំនើប)។ សូមធ្វើឲ្យមានគុណភាព(សំណង់សាធារណៈ) ចៀសវាងកសាងរួចមិនបានប៉ុន្មានឆ្នាំផងវាយចោលធ្វើម្តងទៀត ដែលវាអាចជាការចំណាយថវិកាខ្ជះខ្ជាយ និងពេលវេលា។

២-សាលារៀនៈ ទីធ្លាសាលារៀនគ្រប់ភូមិសិក្សាត្រូវមានការថែទាំឲ្យបានទៀងទាត់ពីសិស្សានុសិស្សប្រកបដោយមនសិការការទទួលខុសត្រូវខ្ពស់ក្រោមការដឹកនាំរបស់លោកគ្រូ អ្នកគ្រូ និងថ្នាក់ដឹកនាំសាលា។

៣-ភូមិស្ថានៈ ទាំងបច្ចុប្បន្ន និងអនាគត ភូមិយើងត្រូវបង្កើតឲ្យមានបរិស្ថានស្អាតរុក្ខជាតិខៀវស្រងាត់ស្រស់បំព្រងប្រកបដោយផាសុកភាព។ ប្រជាពលរដ្ឋក្រោមការដឹកនាំរបស់អាជ្ញាធរគ្រប់ជាន់ថ្នាក់ត្រូវចូលរួមអនុវត្តគោលនយោបាយជាតិសាធារណៈដើម្បីធ្វើឲ្យហេដ្ឋារចនាសម្ព័ន្ធផ្សេងៗមានជាអាទិ៍ សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ អនាម័យទូទៅ បង្គន់អនាម័យ ការវេចខ្ចប់ទុកដាក់សំរាម ប្រព័ន្ធលូទឹក និងជាភូមិដែលគ្មានសំរាម គ្មានដង់ប្លាស្ទិក១០០ភាគរយ។

៤-នៅក្នុងភូមិទាំងឡាយត្រូវចលនាពង្រីកផ្លូវឲ្យបានធំៗតាមដែលអាចធ្វើកើត[229]។ គ្រប់ផ្លូវចរាចរណ៍ឆ្លងកាត់ត្រូវតែជាផ្លូវដែលរថយន្តពន្លត់អគ្គិសភ័យឆ្លងកាត់បានជាផ្លូវក្រាលក្រាលបេតុង ឬចាក់កៅស៊ូ។ តម្លើងបង្គោលភ្លើងប្រើថាមពលអគ្គិសនី ឬព្រះអាទិត្យ(តាមសង្គមទំនើបស៊ីវិល័យ) ដាំជាជួរតាមខ្នាត តាមប្លង់ដែលគូសវាសដោយស្ថាបត្យករ អ្នកជំនាញប្រកបដោយសោភ័ណភាពយ៉ាងប្រណីតនៅក្នុងបរិវេណភូមិនីមួយៗ។ ជាភូមិដែល

[229] ពង្រីកធំនេះ នៅសងខាងផ្លូវត្រូវមានលូប្រព័ន្ធបង្ហូរទឹកត្រឹមត្រូវ ត្រូវចាក់បេតុង ឬកៅស៊ូឲ្យធំប៉ុននឹងការពង្រីកដែរ។ ចៀសវាងពង្រីកធំ ប៉ុន្តែដល់តែចាក់បេតុង ឬកៅស៊ូតូចវិញ។

មិនមានខ្សែភ្លើង ឬ កាបអុបទិកគ្រប់ប្រភេទនៅលើអាកាស ពោលគឺខ្សែកប់ក្នុងដីទាំងអស់។

៥-អ្នកស្រុករបស់យើងមានរបរជាអ្នកចិញ្ចឹមសត្វ ជ្រូក គោ[230]មាន់ ទា ក៏ទាមទារឲ្យមានការរៀបចំធ្វើអនាម័យជាប្រចាំ គ្មានសំរាម គ្មានលាកសត្វ គ្មានក្លិនស្អុយ ឆ្អេះឆ្អាប ជាដើម។ ក្នុងភូមិនីមួយៗត្រូវមានរបៀបរបបនៃការរស់នៅស្អាតប្រកបដោយសណ្ដាប់ធ្នាប់ល្អស្របទៅតាមកម្មវិធីអភិវឌ្ឍជាតិរបស់រាជរដ្ឋាភិបាល។

ត្រូវបំផុសស្មារតីជាតិនិយម និងជាកាតព្វកិច្ចដោយការលើកទង់ជាតិនៅគ្រប់មុខលំនៅដ្ឋានឲ្យស្រុះគ្នាសម្រាប់ឱកាសចូលរួមអបអរសាទរក្នុងបុណ្យជាតិធំៗ ឬបុណ្យប្រពៃណីជាតិខ្មែរម្ដងៗ ដូចជា បុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា ទិវារំដោះ៧មករា បុណ្យចូលឆ្នាំខ្មែរ ឬបុណ្យភ្ជុំបិណ្ឌ ជាដើម។ ការនេះមិនមែនធ្វើចំពោះតែគេហដ្ឋានណាដែលស្ថិតនៅជាប់ផ្លូវធំនោះទេ។ ទង់ជាតិ ទង់សាសនា ទង់ផ្កាលា ។ល។ ត្រូវផ្លាស់ប្ដូរថ្មី ជៀសវាងស្លេក ហើរពណ៌ ឬរហែកអស់ទើបនឹកឃើញប្ដូរ។ ប្រជាពលរដ្ឋត្រូវចេះដំណាំរួមផ្សំ មានស្លឹកគ្រៃ ម្ទេស ជី ខ្ទឹម ផ្កាចម្រុះពណ៌គួរឲ្យគយគន់តាមលំនៅដ្ឋានគ្រប់ៗគ្នាដែលអាចទាក់ទាញបានការចាប់អារម្មណ៍ពីមនុស្សទូទៅ។ ខ្ញុំមានសេចក្ដីស្រមៃថា ភូមិរបស់យើងជារឿយៗមានទេសចរបរទេស ចេញចូល តើវានឹងល្អយ៉ាងណាដែរប្រសិនបើយើងមានរទេះគោចាំដឹកភ្ញៀវពីកន្លែងមួយទៅកន្លែងមួយទៀតនោះ តើវានឹងរឹតតែល្អប្រសើរថែមទៀតទេឬ? ថ្ងៃនេះភូមិយើងចាប់ផ្ដើមធ្វើបាន ចុះថ្ងៃអនាគតប្រសិនបើយើងធ្វើបានដូច្នេះទូទាំងប្រទេសវិញ តើ

---

230 ភូមិនេះមិននិយមចិញ្ចឹមក្របីទេ។

ប្រទេសជាតិយើងមានសោភ័ណភាពល្អយ៉ាងណាទៅ? និយាយទៅក្ដីស្រមៃរបស់ខ្ញុំហាក់បីដូចជាធំគួរឲ្យចង់សើចបន្តិច ប៉ុន្តែខ្ញុំជឿជាក់ថា អ្នកភូមិនឹងយល់ ហើយធ្វើបាន។ និយាយបែបមហិច្ឆតាបន្តិចខ្ញុំចេតនាឲ្យភូមិស្រុកយើងក្លាយជាតំបន់ទេសចរណ៍ធម្មជាតិ ឬកែច្នៃនាពេលអនាគត។

តើភ្ញៀវទេសចរជាអ្នកណាដែលនឹងអាចមកទស្សនាភូមិទាំងបីខាងលើនេះ? តាមខ្ញុំមិនខ្វះទេអ្នកចង់ឃើញ ចង់ស្គាល់ ចង់ទៅមើល ឲ្យតែកន្លែងយើងមានរៀបចំបានស្អាតបាត និងមានទេសភាពល្អនោះ។ ភូមិសាស្ត្រភូមិទាំងបីនេះមានផ្លូវធ្វើដំណើរចេញពីភ្នំជីសូរ្យឆ្ពោះទៅទិសខាងកើតមានចម្ងាយប្រមាណជាបី ទៅបួនគីឡូម៉ែត្រភ្ញៀវទេសចរអាចធ្វើដំណើរបត់ទៅខាងឆ្វេងដៃដើម្បីចូលទស្សនាភូមិតម្បាញសូត្រដ៏ល្បីល្បាញនៃប្រជារាស្ត្រស្រុកព្រៃ-កប្បាស ខេត្តតាកែវបាន ដូចជា ៖ ភូមិជីនៀង ភូមិកែវចំរើន (វត្តភ្នំចចក) ភូមិវាល ភូមិក្បម ភូមិសម្ដេចពាន់។ល។ សុទ្ធតែជាភូមិធ្វើតម្បាញវវៃសូត្រ[231]។

ភូមិទាំងរបស់យើងអាចធ្វើការលម្អដោយរុក្ខជាតិតូចធំពីលើអ្វីៗដែលមានស្រាប់ និងដាំថ្មីបន្ថែមតាមការគូសវាសចង្អុលបង្ហាញពីស្ថាបត្យករ(តាមប្លង់)។ មកដល់ថ្ងៃនេះមានដើមឈើមួយចំនួនដូចជា ម៉ែសាក់ បេង ក្រញូងឈើទាល ដូងបែម កកោះ គគីរ (ក្នុងវត្ត និងសាលារៀន) ត្នោត ដូង ស្វាយអំពិល ស្ដៅ គ ព្រីង សង្កែ រលួស[232] អូញម៉ូញ (ក្នុងភូមិ)។ល។នៅក្នុងភូមិ

---

[231] ថ្វីត្បិតតែផលិតផលនៃរបរត្បាញវវៃបច្ចុប្បន្ននេះមិនសូវកាក់កប គ្មានតម្លៃទីផ្សារសម្រាប់សិប្បកររបស់យើងក្ដី តែអាជ្ញាធរក៏ត្រូវគិតគូរដើម្បីអភិរក្សតំបន់ខាងលើជាកន្លែងប្រពៃណីត្បាញវវៃសម្រាប់ទេសចរបានស្វែងយល់ផងដែរ។

[232] ដើមរលួសនេះផ្កាពណ៌ក្រហមល្អណាស់ ខ្ញុំបាននិពន្ធចម្រៀងមួយបទមានចំណងជើងថា ផ្ការលួសចង្វាក់រាំក្បាច់(សូមមើលឧបសម្ព័ន្ធទី)

របស់យើងស្រាប់ដោយមិនចាំបាច់ធ្វើដំណើរទៅកាន់តំបន់ឆ្ងាយ ឬព្រៃភ្នំ ទោះបីយ៉ាងណាម្ចាស់ផ្ទះនីមួយៗត្រូវអភិរក្ស និងថែទាំឲ្យស្អាតប្រែក្លាយជាម្លប់អាចជ្រកបានផង។

គេហដ្ឋានអ្នកភូមិទាំងអស់រុំព័ទ្ធទៅដោយបុប្ផាចម្រុះពណ៌ រុក្ខជាតិតូចធំ។ សាយ័ណ្ហសម័យ ! សំឡេងបក្សាបក្សី មាន់ទា ក្អែក តាវ៉ៅ ចាប លលកព្រាប សារិកា បន្លឺសំឡេងយ៉ាងខ្មៀវខ្មាអឺងកង...យូរៗម្ដងគេឮសំឡេងគោស្រែកដង្ហោយហៅរកមេរបស់វា អឹមម៉ ! អឹមម៉ ! អឹមម៉ ! ។ សំឡេងមាន់រងាវចេញពីផ្ទឹមចម្បើងអ្នកភូមិ រៃកណ្ដឹងស្រែកបញ្ចេញសូរស័ព្ទទម្លាក់សំឡេងពីលើដើមស្វាយនាវេលាថ្ងៃត្រង់ដូចចាប់អង្រួនអារម្មណ៍យើងឲ្យនឹកភ្នកកាលនៅវ័យកុមារ។

ប្រសិនបើយើងចេះប្រើប្រាស់អារម្មណ៍ដើម្បីស្ដាប់យូរបន្តិច សំឡេងទាំងនេះ វាហាក់បីដូចជាវត្ថុទិព្វធម្មជាតិដែលប្រៀបបានទៅនឹងតូរ្យតន្ត្រីដែលទេវតាប្រទានដល់មនុស្សលោកដូច្នេះដែរ។ អ្វីដែលបានរៀបរាប់ខាងលើនេះជាអ្វីដែលភូមិយើងរកបាន។

តើនៅសល់អ្វីដែលយើងត្រូវរៀបចំឲ្យឆ្លើយតបនឹងលក្ខណៈសម្បត្តិខាងលើបន្ថែមទៀតនោះ? គឺឥរិយាបថ សីលធម៌ សុជីវធម៌ ការទំនាក់ទំនងរស់រាយរាក់ទាក់ ការសំដែងមនោសញ្ចេតនារាប់អាន ស្មោះត្រង់ ការទទួលខុសត្រូវខ្លះៗទៀតប៉ុណ្ណោះ ដែលជាទ្រព្យសម្បត្តិដ៏ពិសិដ្ឋរបស់មុខងារអ្នកធ្វើបដិសណ្ឋារកិច្ចចំពោះភ្ញៀវទេសចរ។ ការបំពេញតួនាទីជាម្ចាស់ផ្ទះល្អ ជាម្ចាស់ស្រុកស៊ីវិល័យ ហើយក៏ជាកាតព្វកិច្ចរបស់អ្នកភូមិទេសចរណ៍ផងដែរ។

ខ្ញុំមានកត្តាចម្បងមួយទៀតដើម្បីធ្វើឲ្យមហិច្ឆតាឲ្យភូមិស្រុកយើងឲ្យក្លាយជាតំបន់ទេសចរណ៍ប្រវត្តិសាស្ត្របានជោគជ័យ? មូលដ្ឋានសំខាន់ខាង

ក្រោមនេះអាចជាគុណសម្បត្តិដ៏វិសេសវិសាលដែលអាចជួយឲ្យបំណងប្រាថ្នារបស់យើងក្លាយជាការពិត ៖

១-យើងមានរមណីយដ្ឋានប្រវត្តិសាស្ត្រភ្នំជីសូរ្យដ៏អស្ចារ្យបំផុតរបស់ខេត្តតាកែវ។ ថ្វីបើបច្ចុប្បន្ននេះមិនទាន់បានរៀបចំតាមស្តង់ដារទេសចរណ៍ធម្មជាតិ ដែលមានសមត្ថភាពទាក់ទាញភ្ញៀវទេសចរបានច្រើនក៏ដោយចុះ។ ប៉ុន្តែនៅថ្ងៃអនាគតយើងជឿជាក់ថា ទីនេះនឹងពិតជាមានការរៀបចំ និងមានសក្តានុពលបំផុតមួយរបស់ខេត្តតាកែវមិនខានឡើយ។

២-យើងមានប្រាសាទភ្នំដា ភ្នំបុរីនាស្រុកអង្គរបុរីជាប់ព្រំដែនខ្មែរភាគខាងត្បូងប្រទេស។ តើនរណាខ្លះដែលមិនចង់ដឹង ចង់ស្គាល់ ភ្នំដា ឬស្រុកអង្គរបុរី ជាទីតាំងកំណើតនៃនគរគោកធ្លក(ហ្វូណន) ឬកម្ពុជានោះ?

គួររំលឹកថាគ្រាន់តែរយៈពេល១១ខែ(មករា-វិច្ឆិកា)ឆ្នាំ២០១៥ប៉ុណ្ណោះ មានភ្ញៀវទេសចរអន្តរជាតិជាជាតិសាសន៍ផ្សេងៗគ្នា៥២សញ្ជាតិ[233] ចំនួន១០៩.២៧២នាក់មកទស្សនារមណីយដ្ឋានប្រវត្តិសាស្ត្រវត្តភ្នំ ជាទីតាំងកំណើតនៃរាជធានីភ្នំពេញ។ ចុះទម្រាំរមណីយដ្ឋានភ្នំដាក្នុងស្រុកអង្គរបុរីជាទីតាំងកំណើតនៃប្រទេសកម្ពុជានោះ មិនអាចក្លាយជាគោលដៅនៃអ្នកទេសចរបាន?

៣-ពីរមណីយដ្ឋានប្រវត្តិសាស្ត្រភ្នំជីសូរ្យទៅកាន់ប្រាសាទភ្នំដា ស្រុកអង្គរបុរីមានចម្ងាយតែជាង២០គីឡូម៉ែត្រប៉ុណ្ណោះ។ ប្រសិនបើភូមិទាំងបីរបស់យើងជាភូមិធ្លាប់មានពាក់ព័ន្ធបែបប្រវត្តិសាស្ត្រស្រាប់ ហើយមានផ្លូវគមនាគមន៍ចូលស្រួលអស់ទៅហើយ ៗភូមិនេះមានការរៀបចំជារមណីយ-

[233] ប្រភពព័ត៌មាន៖ មន្ទីរទេសចរណ៍រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៥

ដ្ឋានភូមិទេសចរណ៍ ដែលមានប្រជារាស្ត្ររស់នៅប្រកប ដោយភាពរីករាយ រាក់ទាក់ដូចបានរៀបរាប់ខាងលើរួចហើយនៅក្រោមផ្ទះប្រជាពលរដ្ឋយើង មានការតាំងលម្អឧបករណ៍កសិកម្មរបស់កសិករដូចជា ត្បាល់បុកស្រូវ ត្បាល់បុកអង្ករ(ត្បាល់ជាន់) ត្បាល់ កិនស្រូវ ត្បាល់កិនម្សៅ អង្រុក ឈ្នាង ស្នាចបាចទឹក រហាត់ទឹក។ល។ ដែលសុទ្ធតែជាឧបករណ៍ប្រើប្រាស់បុរាណរបស់បុព្វបុរសខ្មែរ (ប្រសិនបើមិនប្រើប្រាស់ក្នុងជីវភាពកសិករសព្វថ្ងៃក៏អាចឧបករណ៍សម្រាប់បង្ហាញក្មេងៗជំនាន់ក្រោយ និងភ្ញៀវទេសចរជាតិ និងអន្តរជាតិដែរ) យើងបានស្គាល់ បានស្វែងយល់ ហើយធ្វើការផ្សព្វផ្សាយឲ្យគេដឹងតាមរយៈក្រដាសព័ត៌មាន(Procure)មគ្គុទេសក៏ទេសចរ(Guide) តាំងពីតំបន់ភ្នំជីសូរ្យឯណោះ? ម៉្យាងទៀត ទឹកដីនេះឮដំណឹងថា ក៏ធ្លាប់ជាទីតាំងនៃសមរភូមិរបស់ជនជាតិបី (ខ្មែរ លាវ ចិន) ទៀតនោះ តើអ្នកទេសចរជាតិ និងអន្តរជាតិណាមិនចង់ទៅទស្សនានោះ? នៅពេលមានមនុស្សច្រើនទៅស្គាល់តំបន់របស់យើង តើនឹងបានផលចំណេញអ្វីខ្លះដល់អ្នកភូមិ? អ្នកណាខ្លះស្ម័គ្រចិត្តធ្វើនំបញ្ចុក ស្រស់ៗ គុយទាវម្ជូរក្តៅៗជ្រលក់ទឹកត្រី នំគ្រួក នំខ្ទក់ នំក្រៀប នំក្រូច នំកង នំលត? ទឹកត្នោតជូរ ទឹកត្នោតផ្អែម រម្ងាស់ស្ករត្នោត ចំណីចំណុកហូបចុក[234]។ អ្នកស្រុកត្រូវបានលើកទឹកចិត្តឲ្យចិញ្ចឹម មាន់ ទា គោ តាមបែបធម្មជាតិ។ មានផ្ទះសំណាក់ មានវត្ថុអនុស្សាវរីយ៍ដែលជាស្នាដៃរបស់ចាស់ទុំក្នុងភូមិជាអ្នកផលិតឲ្យភ្ញៀវ ដំណាំដាំដុះ បន្លែ បង្ការសុទ្ធតែប្រើជីធម្មជាតិសម្រាប់ឲ្យអ្នកទេសចរ ទិញ ឬទស្សនា។ ដើម្បីឲ្យទៅដល់គោលដៅដូចខាង

---

[234] ទម្រាំតែភូមិនេះត្រូវបានប្រែក្លាយទៅជាភូមិនៃប្រវត្តិសាស្ត្រធម្មជាតិអាចរកមនុស្សឡើងត្នោត ធ្វើនំចំណីដូចរៀបរាប់ខាងលើលែងបានពីព្រោះយុវជនសម័យឥឡូវលោកចូលចិត្តស្វែងរកវិជ្ជានៅថ្នាក់ឧត្តមសិក្សាអស់ទៅហើយ។

លើដំបូងបង្អស់ខ្ញុំពិតជាចង់ឲ្យភូមិយើងមានពណ៌ខៀវស្រងាត់ខួបប្រាំងខួប វស្សាជាមួយនឹងដើមឈើធំៗ ខ្ពស់ៗជិតដល់មេឃដុះជាជួរតាមដងផ្លូវ និងទីធ្លាសាធារណៈ។

*ព្រះករុណា លោកយាយ លោកតា បងប្អូន ជាទីគោរពសក្ការៈ និងរាប់អាន !*

តើធ្វើដូចម្តេចដើម្បីឲ្យភូមិស្រុកយើងសម្បូរត្រី ? តាំងពីដើមមកត្រពាំងបឹងបួរស្រះព្រៃកប្រឡាយយើងមិនសូវរីងស្ងួតហួតហែងទេ ជាពិសេសទន្លេភ្នំ[235] គឺៈមិនធ្លាប់រីងស្ងួតហួតហែងតែម្តង ? នេះហើយជាប្រភពមច្ឆាជាតិដ៏ធំរបស់យើង។ ប៉ុន្តែបច្ចុប្បន្ននេះ កន្លែងខ្លះបានរីងស្ងួតជារៀងរាល់ឆ្នាំ។ តាមដឹងគ្រប់ត្រពាំង បឹងបួរ ស្រះ ព្រៃក ប្រឡាយក្នុងបណ្តាភូមិស្រុករបស់យើង ត្រូវតែស្តារឲ្យបានជ្រៅឡើងវិញ ដើម្បីឲ្យទឹកមានដក់ជាប់ទាំងរដូវប្រាំងទាំងរដូវវស្សា។ នៅខែប្រាំ(ពីខែមករាដល់ខែឧសភា) ប្រសិនបើម្ចាស់ស្រះត្រពាំង បឹងបួរ ទាំងឡាយកុំធ្វើនេសាទដោយបូមទឹកចេញឲ្យរីងស្ងួតហួតហែងឲ្យ សោះ នោះវានិងនាំឲ្យត្រី ឬមច្ឆាគ្រប់ប្រភេទស្លាប់ផុតពូជគ្មានសល់។ គួរដឹងដែរថា មច្ឆាទាំងឡាយដែលកំពុងរស់នៅក្នុងស្រះ ថ្លុកត្រពាំង បឹងបួរនារដូវប្រាំងនេះ នឹងគ្មានរស់ជាតិគួរឲ្យចង់ហូបប៉ុន្មានទេ ពីព្រោះវាស្គម និងធ្លាបខ្លាំងណាស់។នៅពេលរដូវវស្សាចាប់ផ្តើមវារមែងនឹងមានភ្លៀងធ្លាក់មក (ភ្លៀង ដើមឆ្នាំ/ផ្គរលាន់ដើមឆ្នាំ)ខ្លះមិនខាន ទឹកភ្លៀងនេះគឺប្រាកដវានឹងនាំឲ្យសត្វជាមច្ឆាទាំងនោះអាចបន្តជីវិតបានតទៅទៀត ហើយមិនយូរប៉ុន្មានភ្លៀងនឹងបន្តធ្លាក់ជាហូរហែរត្រី ខ្យង ខ្ចៅ ក្តាម កង្កែប ។ល។ ដែលកប់ ឬរស់

---

[235] ទន្លេ ឬបឹងនៅជាប់ភ្នំបុរី

នៅទីនោះស្រាប់ វានឹងចេញមកក្រៅ ត្រីដែលខំលាក់ខ្លួននៅក្នុងត្រពាំង បឹង ឬទាំងនោះនឹងហែលឡើងឆ្លងទៅរស់នៅក្នុងវាលស្រែដែលមានទឹកល្ហល្ហាច វិញម្តង។ ពេលនោះ ពួកគេនឹងបង្កកំណើតបានជាកូនរាប់រយពាន់លានជីវិត។ អាជ្ញាធរត្រូវមានវិធានការចេញបញ្ជាតឹងរ៉ឹងបំផុតចំពោះអ្នកនេសាទត្រីដោយឧបករណ៍ឆក់។ ប្រសិន បើធ្វើយ៉ាងនេះបាន ស្រុកភូមិយើងនឹងមិនប្រឈមមុខនឹងការខ្វះត្រីសាច់ដូចសព្វថ្ងៃពេកទេ និយាយដោយឡែក និងជារួមប្រទេសជាទីស្នេហារបស់យើងធ្វើដូច្នេះបានដែរ វានឹងសម្បូរត្រី ឬមច្ឆាជាតិគ្រប់ប្រភេទឡើងវិញមិនខាន យ៉ាងហោចណាស់ក៏ជួយបានមួយចំណែកណាដែរ។ ជាមួយគ្នានេះ ខ្ញុំសង្កេតឃើញថា សព្វថ្ងៃកសិករយើងបានប្រើប្រាស់ជីគីមី ថ្នាំបាញ់សម្លាប់សត្វល្អិត ស្មៅ ក្រៅពីបង្កគ្រោះថ្នាក់ដល់ជីវិតមនុស្ស សត្វ វាក៏បានដើរតួយ៉ាងសំខាន់ក្នុងការសម្លាប់សត្វក្នុងទឹក និងប្រព័ន្ធអ័រម៉ូនបន្តពូជរបស់សត្វក្នុងទឹកគ្រប់ភេទដែរ ហើយនឹងបំផ្លាញជីវិតមនុស្សផងដែរ។

សូមលោកពូ អ្នកមីង និងបងប្អូនអ្នកភូមិតាំងចិត្តធ្វើឲ្យបានគ្រប់គ្នា ទោះបីវាត្រូវប្រើប្រាស់ពេលវេលាយូរយ៉ាងណា ប៉ុន្តែបើយើងមិនសុខចិត្តចុះចាញ់ យើងនឹងឈ្នះ។ ប្រជារាស្ត្រយើងអាចរួបរួមគ្នាផ្តួចផ្តើមជាមួយអាជ្ញាធរមូលដ្ឋានបណ្តើរៗដោយមានការជួយយ៉ាងខ្លាំងពីស្ថាបត្យករ ឬអ្នកជំនាញផ្តល់បច្ចេកទេសចំពោះការងារឯកជន(លំនៅដ្ឋានមួយៗ) រីឯការងារសាធារណៈ ប្រាកដណាស់ផ្លូវថ្នល់ លូ សួនច្បារចាំបាច់ត្រូវមានអាជ្ញាធរថ្នាក់លើ (រាជរដ្ឋាភិបាល)ជាអ្នកដឹកនាំចេញបញ្ជា ផ្តល់អនុសាសន៍ ឬថវិកា។

សង្ឃឹមថា ប្រជារាស្ត្រខ្មែរទាំងអស់ លោកបានយល់ច្បាស់អំពីបញ្ហា

នេះ ហើយចូលរួមទាំងអស់គ្នា យើងពិតជាអាចដោះស្រាយបានមួយផ្នែក ដើម្បីចូលរួមអភិវឌ្ឍសេដ្ឋកិច្ចជាតិរបស់យើង។

នៅពេលដែលប្រជារាស្ត្រក្នុងភូមិយើងទាំងអស់បានយល់កិច្ចការនេះហើយ យើងមិនពិបាកទៀតទេដើម្បីចង់បានអ្វីមួយនោះ។ សុភាសិតបារាំងមួយនិយាយថា Vouloire c´est pouvoire "គ្មានអ្វីដែលយើងចង់ហើយ ធ្វើមិនបាននោះទេ"។ "ភូមិកំណើតរបស់យើង ប្រសិនបើយើងមិនចេះស្រឡាញ់ មិនចេះថែរក្សា តើឲ្យអ្នកដទៃណាគេមកស្រឡាញ់ គេមកថែរក្សាជំនួសយើងនោះ"។ "ចង់បានផលពីការអប់រំមិនមែនរង់ចាំមួយថ្ងៃ មួយខែ មួយឆ្នាំទេ ប៉ុន្តែ គឺជាការប្រើប្រាស់ពេលវេលាមួយជីវិត"។

សូមវិលត្រឡប់មកជួយស្រុកភូមិរបស់យើងវិញ អ្នកណារៀនចេះជំនាញអ្វី យកជំនាញនោះមកជួយភូមិស្រុក។ "សាមគ្គីរស់បែកបាក់សាមគ្គីស្លាប់"សូមអ្នកភូមិគ្រប់ជំនាន់កុំចេះតែធម៌សាមគ្គីគ្នា ប៉ុន្តែត្រូវចេះធម៌ដែលនាំឲ្យបែកបាក់ផង។

ត្រូវបន្តសកម្មភាពល្អៗរបស់យើងបន្តទៀត ដូចជា ការជួបជុំពិភាក្សាអភិវឌ្ឍ ឬ ការសប្បាយរាំច្រៀងកំសាន្តក្នុងឱកាសចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ រដូវភ្ជុំបិណ្ឌ។ល។ សូមកុំរើសរើសអើងគ្នាដែលជាបញ្ហាយនាំឲ្យមានការបែកបាក់។

ជាអវសាន **ទោះបីអ្នកភូមិជាទីស្រឡាញ់ទាំងអស់លោកប្រើប្រាស់ទឹកត្រពាំងណាក៏ដោយ ជ្រកក្រោមម្លប់នៃដើមឈើណាក៏ដោយ ក៏សូមកុំបែរខ្នងដាក់គ្នាឲ្យសោះ។ សូមសំឡឹងមុខគ្នាឲ្យចំហើយគិតឲ្យយូរ ដើម្បីប្រយោជន៍ភូមិស្រុករបស់យើងដ៏យូរអង្វែងជាអមតៈតទៅ។**

# ឯកសារគន្ថនិទ្ទេស

-កាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃអង្គារ៍ ទី៨ ខែកញ្ញា ឆ្នាំ២០១៨(ព័ត៌មានជាតិ)

-ក្រសួងមហាផ្ទៃ៖ ចំនួនឈ្មោះខេត្ត-ក្រុង ស្រុក-ខណ្ឌ ឃុំ-សង្កាត់ ភូមិទូទាំងព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០១

-ក្រុមប្រឹក្សារដ្ឋមន្ត្រី៖សេចក្តីសម្រេចលេខ១៧០សសរ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៨៨៤។

-ក្រសួងអប់រំ យុវជន និងកីឡា៖ ប្រកាសលេខ៥៦អយកប្រក ស្តីពីការទទួលស្គាល់អនុវិទ្យាល័យ សមរលោវចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៩៩

-ក្រសួងអប់រំ យុវជន និងកីឡា៖ ភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣ ឆ្នាំ២០១៥

-ជុន ច័ន្ទបុត្រ៖ នាទីប្រវត្តិសាស្ត្រនៅអំឡុងឆ្នាំ២០១០ និង២០១១ និងត្រូវបានចាក់ផ្សាយឡើងក្នុងគ្រាបន្តបន្ទាប់មក។

-ជូ ច័ន្ទដារី ចាន់ ប៊ុន្នី ឡៅ សុផល ស៊្រុន ប៊ុណ្ណារិទ្ធ៖ ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ឆ្នាំ២០១០

-សម្តេចព្រះសង្ឃរាជ ជួន ណាត៖ វចនានុក្រមខ្មែរ ភាគទី ភាគទី២ ឆ្នាំ១៩៦៧-១៩៦៨

-សារព័ត៌មានគរជំ ប្រចាំថ្ងៃ ឆ្នាំទី២១ លេខ ៩៣៣ ចេញផ្សាយថ្ងៃសុក្រទី០៤ ខែកញ្ញា ឆ្នាំ២០១៥

-សេង ប៊ុនធឿន៖ រដ្ឋធម្មនុញ្ញ និងការផ្លាស់ប្តូររបបនយោបាយ ឆ្នាំ២០១៥

-វចនានុក្រមខ្មែរ(Khmer Dictionary)រោងពុម្ពនគរជំ ឆ្នាំ២០១០

-វិទ្យុបារាំងផ្សាយថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ វេលាម៉ោង៧យប់ -អេង សុត៖ ឯកសារមហាបុរសខ្មែរ ភាគ១-២ Adhemard Leclère: Histoire du Cambodge, បោះពុម្ពលើកទី១ 1914, និងបោះពុម្ពលើកទី២ 2006,

-Michael Vickerry: History of Cambodia, 2001-2002

# ឧបសម្ព័ន្ធទី១

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

*រាជធានីភ្នំពេញ* ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៥

**សូមគោរពជូន**

**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

*សម្តេចក្រឡាហោមជាទីគោរពដ៏ខ្ពង់ខ្ពស់ !*

ជាបឋម ខ្ញុំបាទមានកិត្តិយសដ៏ខ្ពង់ខ្ពស់ សូមសំដែងនូវមនោសញ្ចេតនាអបអរសាទរយ៉ាងខ្លាំងក្លាចំពោះសម្តេច ដែលត្រូវបាន **ព្រះករុណាព្រះបាទព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់សព្វព្រះរាជហឫទ័យប្រោសព្រះរាជទានគោរមងារជា **សម្តេចក្រឡាហោម** តាមព្រះរាជក្រឹត្យនស/រកត/០៦១៥/៦៣៤ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៥កន្លងទៅនេះ។

ព្រះរាជគោរមងារជា **សម្តេចក្រឡាហោម** ដែលព្រះករុណាជាអម្ចាស់ជីវិតលើត្បូងជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់បានប្រោសព្រះរាជទានជូនសម្តេចនាឱកាសនេះ ពិតជាស័ក្តិសមបំផុតនឹងគុណបំណាច់ដ៏ឧត្តុង្គឧត្តមរបស់សម្តេចដែលជានិច្ចកាលសម្តេចជាឥស្សរជនខ្មែរមួយរូបបានធ្វើពលិកម្មគ្រប់បែបយ៉ាងតាំងពីយុវវ័យប្រកបដោយវីរភាពអង់អាចក្លាហានក្នុងមនសិការស្នេហាជាតិបរិសុទ្ធ ទទួលខុសត្រូវ យុត្តិធម៌ និងឧត្តមគតិដើម្បីបុព្វហេតុសេចក្តីសុខក្សេមក្សាន្តនៃប្រជារាស្ត្រខ្មែរ ជាតិមាតុភូមិក្រោមមគ្គុទេសក៍ដឹកនាំដ៏ឈ្លាសវៃនៃ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

ជាបញ្ចប់ ខ្ញុំបាទសូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ ព្រមទាំងបារមីនៃវត្ថុសក្តិសិទ្ធិទាំងឡាយក្នុងលោក សូមជួយតាមបីបាច់អភិបាល **សម្តេចក្រឡាហោម** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លោកជំទាវ ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី សូមទទួលបាននូវសុខភាពល្អបរិបូណ៌ ជន្មាយុយឺនយូរ បញ្ញាញាណវាងវៃ និងជួបតែព្រះពុទ្ធពរទាំងឡាយបួនប្រការគឺ អាយុ វណ្ណៈ សុខ និងពលៈកុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចក្រឡាហោម** មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។
សេចក្តីគួរពុំគួរ សូម **សម្តេចក្រឡាហោម** មេត្តាខន្តីអភ័យទោសដោយសេចក្តីសណ្តោសប្រណី។

បណ្ឌិត សេង ប៊ុនធឿន
សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យជាតិគ្រប់គ្រង

# ឧបសម្ព័ន្ធទី២

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

919
28-06-2015
09 ព្រឹក

*រាជធានីភ្នំពេញ* ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៥

ទទួល ថ្ងៃទី 29 ខែ 06 ឆ្នាំ 15 ម៉ោង........
បញ្ជូន ថ្ងៃទី 30 ខែ 06 ឆ្នាំ 15 ម៉ោង........

**សូមគោរពជូន**

**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**កម្មវត្ថុ៖** សំណើសុំជួយអន្តរាគមន៍ដើម្បីសរសេរឈ្មោះភូមិតាមសំណេរដើមវិញដែលជាសំណេរត្រឹមត្រូវ។

សេចក្តីដូចបានគោរពជម្រាបជូនក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ សេង ប៊ុនធឿន កើតនៅភូមិសមរលាវ ឃុំពោធិ៍រំចាក ស្រុកព្រៃកប្បាស ខេត្តតាកែវ និងបច្ចុប្បន្នជាសាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យជាតិគ្រប់គ្រងមានកិត្តិយស សូមគោរពជម្រាបជូនសម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រីមេត្តាជ្រាប ភូមិសមរលាវ(សមរ+លាវ) មានអាយុជិត៤០០ឆ្នាំមកហើយ។ នៅក្នុងឃុំពោធិ៍រំចាកពីមុនមានភូមិបីគឺភូមិសមរលាវ ភូមិសមរខ្មែរ និងភូមិសមរចិន។ តាមការស្រាវជ្រាវ អ្នកស្រុកបាននិយាយតៗគ្នាមកថា ទីនេះគឺជាសមរភូមិនៃជនជាតិបី(ចិន លាវ និងខ្មែរ) ធ្លាប់មានជម្លោះទាស់ទែងនឹងគ្នា។ មានន័យថា ជាសមរភូមិនៃជនជាតិទាំងបី។ ហេតុដូច្នេះឈ្មោះភូមិទាំងបីនេះត្រូវបានសរសេរថា ភូមិសមរលាវ ភូមិសមរខ្មែរ និងភូមិសមរចិនដែលមានអត្ថន័យគ្រប់គ្រាន់។ ទើបតែនៅប៉ុន្មានឆ្នាំចុងក្រោយនេះមន្ត្រីអាជ្ញាធរថ្នាក់ក្រោមជាតិ(ឃុំពោធិ៍រំចាក ស្រុកព្រៃកប្បាស ខេត្តតាកែវ) និងភូមិសមរលាវខ្លួនឯងផង បានប្រែទៅជាសរសេរឈ្មោះភូមិនេះថា សម៉រលាវ ឬ សាម៉រលាវ សម៉រខ្មែរ ឬ សម៉រ... តាមរយៈឯកសារអត្តសញ្ញាណប័ណ្ណ និងក្រដាសស្នាមរដ្ឋបាលគ្រប់ប្រភេទទៅវិញ។ ការសរសេរនេះមិនដឹងផ្តើមចេញពីប្រភពណាពិតប្រាកដ ហើយបានបណ្តាលឲ្យបាត់អត្ថន័យទាំងស្រុងពីខ្លឹមសារដើមដែលអ្នកស្រុកធ្លាប់សរសេរ។ ផ្អែកតាមការផ្លាស់ប្តូរនៃការសរសេរនេះ បានធ្វើឲ្យសិស្សានុសិស្ស យុវជន និងបញ្ញវន្តក្មេងៗភាគច្រើន រួមទាំងរូបខ្ញុំបាទផងដែរ ដែលមានស្រុកកំណើតពីក្នុងភូមិទាំងបីនេះមានការរកាំចិត្ត ហើយមិនចង់ឃើញការសរសេរខុសបែបនេះបន្តកើតមានតទៅទៀតទេ។

អាស្រ័យហេតុនេះសូមសម្តេចឧបនាយករដ្ឋមន្ត្រីមេត្តាពិនិត្យ និងអន្តរាគមន៍តាមសំណើដោយក្តីអនុគ្រោះ។

សូមសម្តេចក្រឡាហោមឧបនាយករដ្ឋមន្ត្រីមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

បណ្ឌិត សេង ប៊ុនធឿន

អ្នកមានស្រុកកំណើតពីភូមិសមរលាវ

# ឧបសម្ព័ន្ធទី៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ: ១៥៤១ សជណា

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ សីហា ឆ្នាំ២០១៥

**សូមជម្រាបជូន**

**ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាំ ម៉ុល ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ**

**កម្មវត្ថុ** : ស្តីពីសំណើសុំជួយអន្តរាគមន៍ដើម្បីសរសេរឈ្មោះភូមិតាមសំណេរដើមវិញដែលជាសំណេរត្រឹមត្រូវ។

**យោង** : -ប្រកាសលេខ ៤៩៣ ប្រ.ក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០១ របស់ក្រសួងមហាផ្ទៃ ស្តីពីការកំណត់ចំនួន ឈ្មោះ និងព្រំប្រទល់ឃុំ សង្កាត់ ទូទាំងព្រះរាជាណាចក្រកម្ពុជា

-លិខិតចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៥ របស់លោកបណ្ឌិត សេង ប៊ុនធឿន សាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប ឯកឧត្តម បណ្ឌិតសភាចារ្យប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ ជ្រាបថា ឈ្មោះភូមិជាផ្លូវការត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធនៃប្រកាសលេខ ៤៩៣ ប្រ.ក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០១ របស់ក្រសួងមហាផ្ទៃ ស្តីពីការកំណត់ចំនួន ឈ្មោះ និងព្រំប្រទល់ឃុំ សង្កាត់ ទូទាំងព្រះរាជាណាចក្រកម្ពុជា។ លោក សេង ប៊ុនធឿន សាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង បានធ្វើលិខិតមកក្រសួងមហាផ្ទៃស្នើសុំជួយអន្តរាគមន៍ឲ្យផ្លាស់ប្តូរឈ្មោះភូមិពី "សម៉លាវ" មក "សមរលាវ" វិញដោយផ្អែកលើប្រវត្តិនៅតំបន់នោះស្ថិតនៅក្នុងឃុំពោធិ៍វិចាក ស្រុកព្រៃកប្បាស ខេត្តតាកែវ។

ពាក់ព័ន្ធនឹងករណីនេះ ខ្ញុំសូមស្នើឯកឧត្តម បណ្ឌិតសភាចារ្យ ជួយពិនិត្យ និងសិក្សាស្រាវជ្រាវចំពោះការផ្លាស់ប្តូរសំណេរឈ្មោះភូមិពី "សម៉រលាវ" មក "សមរលាវ"ឲ្យបានត្រឹមត្រូវ ដើម្បីក្រសួងមហាផ្ទៃមានមូលដ្ឋានគ្រប់គ្រាន់ និងច្បាស់លាស់ក្នុងការពិនិត្យ និងសម្រេច។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមបណ្ឌិតសភាចារ្យ** ជ្រាប និងចាត់ចែងអនុវត្ត តាមការគួរ។

សូម **ឯកឧត្តម** ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅ អំពីខ្ញុំ។

**ឧ. រដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

សក់_សេដ្ឋា

**ចម្លងជូន**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
(ដើម្បីជូនជ្រាប)
-លោក សេង ប៊ុនធឿន
(ដើម្បីជ្រាប)
-ឯកសារ-កាលប្បវត្តិ

ទីស្តីការក្រសួងមហាផ្ទៃ លេខ ២៧៥ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣
ទូរសារ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣ email: moi@interior.gov.kh Web: www.interior.gov.kh

# ឧបសម្ព័ន្ធទី៤

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

3

**ក្រុមប្រឹក្សាជាតិភាសាខ្មែរ**

## របាយការណ៍
## ស្តីពី
## ការចុះស្រាវជ្រាវឈ្មោះភូមិ សមរលាវ

I- **ទីតាំងភូមិសាស្ត្រ**

ភូមិសមរលាវ ជាភូមិមួយដែលស្ថិតក្នុងចំណោមភូមិទាំង១១នៃឃុំពោធិ៍រំចាក ស្រុកព្រៃកប្បាស ខេត្តតាកែវ។ ឃុំពោធិ៍រំចាកមានទីតាំងដូចខាងក្រោម៖

- ខាងកើតទល់នឹង ឃុំ កំពង់រាប ស្រុកព្រៃកប្បាស និង ឃុំ ព្រៃកស្ដី ស្រុកកោះធំ ខេត្តកណ្ដាល
- ខាងលិចទល់នឹង ឃុំ កំពែង ស្រុកព្រៃកប្បាស
- ខាងត្បូងទល់នឹង ឃុំ ព្រៃកប្បាស ស្រុកព្រៃកប្បាស
- ខាងជើងទល់នឹង ឃុំ ចំប៉ា និង ឃុំ បានកាម ស្រុកព្រៃកប្បាស

ឈ្មោះភូមិទាំង១១គឺ

១- ភូមិ សម៉លាវ ២- ភូមិ សម៉ខ្មែរ

៣- ភូមិ ថ្នល់បត់ ៤- ភូមិ គោកក
ញ្ចាប
៥- ភូមិ គរ ៦- ភូមិ ក្ដីតាហុក
៧- ភូមិ អង្គសង្កែ ៨- ភូមិ ក្រសាំង
៩- ភូមិ ស្វាយសំរោង ១០- ភូមិ គោកអង្គ
ង់ និង
១១- ភូមិ ព្រៃតាពង

**ផែនទីរដ្ឋបាលនៃស្រុកព្រៃកប្បាស**






## II- ហេតុដែលនាំឱ្យមានការស្រាវជ្រាវ

យោងលិខិតលេខ១៥៤១ សជណ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ របស់ក្រសួងមហាផ្ទៃ ដែលបានស្នើសុំក្រុមប្រឹក្សាជាតិភាសាខ្មែរ( ក.ជ.ភ.ខ ) ជួយអន្តរាគមន៍ដើម្បីសរសេរឈ្មោះភូមិតាមសំណេរដើមវិញដែលជាសំណេរត្រឹមត្រូវ។ ហេតុនេះ ក.ជ.ភ.ខ បានចេញលិខិតបញ្ជាបេសកកម្មលេខ៣០៥/១៥ ក.ជ.ភ.ខ. ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ចាត់តាំងសមាសភាពចំនួន០៥រូបឱ្យបំពេញកិច្ចការនេះដូចខាងក្រោម៖

| | |
|---|---|
| ១- ឯកឧត្តមបណ្ឌិត នៅ ស៊ុន | ប្រធាន |
| ២- ឯកឧត្តមបណ្ឌិត សន ពៅ | សមាជិក |
| ៣-ឯកឧត្តមបណ្ឌិត ហ៊ោ គឿន | សមាជិក |
| ៤- ឯកឧត្តម ប៊ុត សុម៉េត | សមាជិក |

៥- លោក លាង សុភាព សមាជិក

ក្រុមការងារស្រាវជ្រាវបានចុះដល់ភូមិសមរលាវ ឬ សម៉លាវ ដោយបានជួបសាកសួរព័ត៌មានផ្ទាល់ជាមួយព្រះចៅអធិការវត្ត, សមាជិកក្រុមប្រឹក្សាឃុំ, គណៈកម្មការវត្ត, អតីតគ្រូបង្រៀន, គ្រូបង្រៀន, មេភូមិ និង ចាស់ព្រឹទ្ធាចារ្យក្នុងភូមិ ដែលមានដើមកំណើត និង បានរស់នៅក្នុងភូមិសមរលាវ ឬ សម៉លាវ តាំងពីតូចមក។

## III- **ការសិក្សាស្រាវជ្រាវ**

### **ក-ការស្រាវជ្រាវមួយឯកសាររស់**

ក្រោយពីក្រុមការងារបានជួប និងសាកសួរព័ត៌មានផ្ទាល់ជាមួយ ព្រះចៅអធិការវត្ត, សមាជិកក្រុមប្រឹក្សាឃុំ, គណៈកម្មការវត្ត, អតីតគ្រូបង្រៀន, គ្រូបង្រៀន, មេភូមិ និង ចាស់ព្រឹទ្ធាចារ្យក្នុងភូមិ ដែលមានដើមកំណើត និងរស់នៅក្នុងភូមិសមរលាវ ឬ សម៉លាវ យើងទទួលបានព័ត៌មានដូចខាងក្រោម ៖

១- លោក **មួយ គុនអេង** មេភូមិសមរលាវបានលើកឡើងថា ឈ្មោះដើមរបស់ភូមិនេះ កាលដើមឡើយសរសេរ **សមរលាវ** ប៉ុន្តែប្រហែលនៅក្នុងឆ្នាំ២០០១ ក្រសួងមហាផ្ទៃបានចុះធ្វើអត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋ ពេលនោះគេក៏បានដូរការសរសេរឈ្មោះភូមិ**សមរលាវ** មកជា ភូមិ**សម៉លាវ** វិញ ដែលខុសពីសំណេរដើម។ ក្រោយមកក៏មានការតវ៉ាផងដែរពីអ្នកភូមិ តែមន្ត្រីចុះមកធ្វើអត្តសញ្ញាណប័ណ្ណបានឆ្លើយថា មិនអាចកែបានទេ ដោយឈ្មោះភូមិនេះបានកំណត់រួចហើយនៅក្នុងកម្មវិធីកុំព្យូទ័រ។

២- លោកតា **សៅ ស៊ុន** មានអាយុ៧៥ឆ្នាំ ជាប្រធានគណៈកម្មការវត្តសមរលាវ បានលើកឡើងថា កាលពីគាត់រៀននៅកុមារដ្ឋាន គាត់បានរៀន

នៅក្នុងវត្តសមលាវ ជាមួយព្រះចៅអធិការវត្ត ដែលនៅពេលនោះព្រះចៅអធិការវត្ត បានសួរថាហេតុអ្វីបានជា**សមរ** សរសេរដាក់ **រ**? ព្រះអង្គក៏បានឆ្លើយថា ការដែលសរសេរដាក់ **រ** នេះ មកពីទីនេះជាសមរភូមិចម្បាំងរវាងលាវ ខ្មែរ និង ចិន។

៣- លោកតា **សៅ ឈឿង** បានលើកថា កាលពីឆ្នាំ១៩៤៤ គាត់បានរៀននៅវត្តសមរមេត្រី កាលនោះគាត់ឆ្ងល់ថា ហេតុអ្វីបានជាឈ្មោះ**ភូមិសមរ** សរសេរមាន **រ** នៅខាងចុង? ពេលនោះលោកគ្រូរបស់គាត់ឈ្មោះ **គីង វណ្ណថា** ក៏បាននិទានប្រាប់គាត់ថា ក្នុងសម័យកាលមួយ យើងមានចម្បាំងរវាងលាវនិងខ្មែរ ហើយលាវបានច្បាំងឈ្នះខ្មែរមកដល់ភូមិលាវសព្វថ្ងៃ។ ពេលនោះស្តេចខ្មែរបានទៅពឹងមហាអំណាចចិនឱ្យជួយកាត់ក្តី ហើយចិនក៏បានមកនៅភូមិខាងកើត រួចគេបានហៅថា **សមរចិន**ខាងកើតរៀងមក។ ចំណែកខ្មែរនៅភូមិម្ខាងក៏បានហៅថា ភូមិសមរខ្មែរដែរ។ លោកតាក៏បានបញ្ជាក់ទៀតថា ចម្បាំងក្នុងសម័យនោះមានប្រើអាវុធដូចជា ស្នា ព្រួញ លំពែង និង ធ្នូ ជាដើម។ ទាហានលាវដែលស្លាប់បានយកទៅកប់នៅស្រះតាអែ ហើយបើទាហានខ្មែរស្លាប់ គេយកទៅកប់នៅស្រះតៀម។ នៅខាងកើតស្រះតៀមមានស្រែត្រពាំងមួយហៅថា ត្របាំងកោះស្នា។ ត្រពាំងនេះជាកន្លែងព័ទ្ធខ្មែរលាងអាវុធយុទ្ធភ័ណ្ឌដែលប្រឡាក់ ឈាមមាន ដាវ លំពែង ស្នា ធ្នូ ជាដើម។ ចម្បាំងជាមួយគ្នាចុះឡើងខ្មែរបានទៅប្រសិទ្ធីគ្រូនៅក្រោមដើមពោធិ៍ និងបានចាក់សាក់ផងនោះ ទើបគេហៅថា ភូមិពោធិ៍ចាក់សាក់រហូតដល់សព្វថ្ងៃនេះ ពេលចាក់សាក់ហើមសាច់ ខ្មែរបានទៅដេកនៅទួលអូរសព្វថ្ងៃហៅថា ភូមិអូរ។ ដល់ពេលសង្គ្រាមយូរទៅលាវក៏បានបាក់ទ័ពរត់ចេញពីភូមិសមរលាវទៅដល់ភូមិខាងជើង ខ្មែរបានដេញមកដល់ស្រះត្រពាំងមួយហៅស្រះត្រពាំងនោះថាស្រះ

ត្រពាំងមានជ័យ ឬត្រពាំងជ័យ ព្រោះពេល នោះខ្មែរបានស្រែកថាមានជ័យជម្នះ ហើយបន្ទាប់មកក៏បានដេញមកដល់ភូមិបន្ទាយរៀង(បន្ទាយរបស់ចិននៅ)ដែលហៅថាភូមិបន្ទាយរៀងសព្វថ្ងៃនេះ។ នៅទីនោះមានស្រះត្រពាំងមួយដែលចិនបានកាត់ក្តីឱ្យខ្មែរឈ្នះលាវ ក៏បានហៅស្រះនោះថា ត្រពាំងឈ្នះ ហើយលាវក៏បានដកចេញរហូតមក។ នៅក្បែរត្រពាំងឈ្នះមានត្រពាំងមួយទៀតឈ្មោះត្រពាំងប្រីយ៍។

៤- លោកតា **ហុក ខេង** អាយុ៦៥ឆ្នាំ មានប្រសាសន៍ថា តាមទម្លាប់តាំងពីដើមរៀងមកឈ្មោះភូមិនេះសរសេរ **សមរលាវ** តែមកដល់បច្ចុប្បន្នបែរជាសរសេរ **សម៉** វិញ គាត់ដូចជាចម្លែកចិត្ត។ ប៉ុន្តែនៅទីនេះមានរោងលោកយាយមួយដែលគេហៅ លោកយាយលាវ(អ្នកដូន)នៅពេលបន់ស្រន់ពេលមានខុសមាត់ខុសក គេតែងសែនដង្វាយជាបាយដំណើប និង ប្រហុកដុតថ្វាយលោកយាយលាវ។

៥- លោកតា **ប៊ី ស៊ន** អាយុ៦៨ឆ្នាំ ជាអ្នកធ្លាប់បួសរៀននៅវត្តសមរលាវនេះដែរ បានមានប្រសាន៍ថា តាំងពីគាត់រៀននៅវ័យក្មេង គាត់ឃើញសរសេរឈ្មោះភូមិនេះតែ **សមរ** ប៉ុណ្ណោះ។

៦- លោកតា **សុខ ឈួន** អាយុ៦៧ឆ្នាំ មានប្រសាសន៍ថា តាំងពីគាត់រៀនមក ប្រហែលឆ្នាំ១៩៥៦ ឬឆ្នាំ១៩៥៧ លោកគ្រូរបស់គាត់(គ្រូជាព្រះសង្ឃ)ឱ្យគាត់សរសេរលើក្របសៀវភៅឈ្មោះភូមិ**សមរ** បើសរសេរខុសត្រូវលោកគ្រូវ៉ៃ។

៧-លោកតា **ឡាក់ គួយ** អតីតមេភូមិបានមានប្រសាសន៍ថា គាត់សរសេរ សម៉ មានដាក់មូសិកទន្ត ពេលនោះគ្រូ(ព្រះសង្ឃ)របស់គាត់បានចាប់អុកដៃគាត់ ដោយប្រាប់ឱ្យគាត់សរសេរថា **សមរ** វិញ។

៨-ព្រះតេជគុណ **ឡាក់ ហំ(ហៅហ៊ីម)** បច្ចុប្បន្នជាព្រះចៅអធិការវត្តសមរលាវ មានថេរដីកាថា ពាក្យនេះ អាត្មាភាពឃើញសរសេរ**សមរ**បែបនេះយូរហើយ។ ព្រះអង្គបានបន្ថែមថេរដីកាទៀតថា អាត្មាភាពឮចាស់ដំណាលថា កាលសម្តេចព្រះសង្ឃរាជ ជួន ណាត មានព្រះជន្មនៅឡើយ ប្រជាជនដែលរស់នៅក្នុងភូមិនោះ បាននិមន្តសម្តេចមកទេសនានៅពេលឆ្លងចេតីយ៍កុងពេជ្រ (លោកតា ពេជ្រ)ក្នុងឆ្នាំ១៩៦៤ ពេលនោះពួកគាត់បានសួរទៅសម្តេចសង្ឃអំពីឈ្មោះភូមិសមរនេះ ហើយសម្តេចឆ្លើយថា ទីកន្លែងនេះជាទីសមរភូមិដែលខ្មែរច្បាំងជាមួយលាវ។

៩- លោក ប្រាក់ សម្បត្តិ ជាសមាជិកក្រុមប្រឹក្សាឃុំពោធិ៍រំចាក បានមានប្រសាសន៍ថា ឈ្មោះភូមិ សមរលាវដែលបានសរសេរដូចសព្វថ្ងៃនេះ សម៉ហ្នឹង មិនត្រឹមត្រូវទេ។ លោកបានធ្វើការតវ៉ាដល់សាលាស្រុក និងខេត្តទៀត ដោយឲ្យមានការកែប្រែជា សមរ វិញ។ ប៉ុន្តែមិនទទួលបានលទ្ធផលអ្វីសោះ។

១០-លោកឡាច ស្រ៊ី ជានាយកសាលាបឋមសិក្សាតាកាហាស៊ីសមរមេត្រី បានមានប្រសាសន៍ ថា លោកមិនអស់ចិត្តនឹងការកែប្រែនេះសោះ។ សរសេរខុសហើយសុំឲ្យជួយកែវិញ កែមិនបាន។ ដូច្នេះ លោកសូមសំណូមពរដល់ថ្នាក់លើ សុំជួយកែពី សម៉ មក សមរ វិញផង។ ពីព្រោះលោកមានការពិបាកណាស់ បញ្ជីឈ្មោះក្នុងសាលាសរសេរថា សមរ(លាវ-ខ្មែរ) ប៉ុន្តែដល់ពេលសំបុត្រកំណើតសិស្សសរសេរថាសម៉(លាវ-ខ្មែរ)ទៅវិញ។ អញ្ចឹងឈ្មោះក្នុងរដ្ឋបាលសរសេរផ្សេង ឈ្មោះក្នុងសាលាផ្សេង កន្លែងតែមួយសោះសរសេរពីរបែប។ ក្រៅពីការស្រាវជ្រាវភូមិសមរលាវ

លោក **ស្រី ហ៊ត** ដែលជាមេភូមិសមរខ្មែរ ក៏បានស្នើសុំឱ្យក្រុមការងាររបស់យើងជួយដោះស្រាយដូរឈ្មោះភូមិរបស់គាត់ពីភូមិ**សម៉ខ្មែរ** ទៅជា ភូមិ**សមរខ្មែរ** ដូចដើមវិញផង។ ក្រោយពីការសន្ទនា យើងបានដឹងថា អ្នកទាំងអស់ដូចមានឈ្មោះខាងលើ ចង់រក្សាសំណេរនៃឈ្មោះភូមិនោះ ដូចដើមគឺ **ភូមិសរមលាវ ភូមិសមរខ្មែរ**។

## ខ-ការស្រាវជ្រាវផ្អែកលើទិដ្ឋភាព និងស្ថានភាពមួយចំនួន

ការបង្កើតឈ្មោះភូមិស្រុក ឬស្ថាននាមវិទ្យាខ្មែរ យើងមានលទ្ធភាពច្រើនបែប។

### ១- ទិដ្ឋភាពឈ្មោះបែបប្រវត្តិសាស្ត្រ

**១.១.ឈ្មោះស្រុក មានដូចជា** ស្រុកអង្គរបុរី ស្រុកបាទី ក្រុងដូនកែវ ស្រុកបុរីជលសារ ស្រុកកោះអណ្តែត។

**១.២.ឈ្មោះឃុំ មានដូចជា** ឃុំកំពែង ឃុំតាំងយ៉ាប ឃុំបានកាម ឃុំកំពង់រាប។

**១.៣. ឈ្មោះភូមិ មានដូចជា** ភូមិអង្គ ភូមិត្រពាំងទា ភូមិសំចត ភូមិសម្តេចពាន់ ភូមិបាំងបាត់ ភូមិអង្គរវាយ ភូមិសេដ្ឋី ភូមិបានយ ភូមិពេជចង្វា សមរលាវ សមរខ្មែរ...។

### ២- ទិដ្ឋភាពឈ្មោះដែលសរសេរលើផែនទី

ផែនទីរដ្ឋបាលនៃស្រុកព្រៃកប្បាស មានសរសេរឈ្មោះ ភូមិសមរលោវ ដែលមានកត់ជាអក្សរឡាតាំង S a mo r l e a v ។

## ៣- ទិដ្ឋភាពឈ្មោះយកតាមឈ្មោះរុក្ខជាតិ និងស្ថានភាពភូមិសាស្ត្រ

ទន្ទឹមនឹងការពិនិត្យពីទិដ្ឋភាពស្ថាននាមនៅនឹងកន្លែង យើងក៏បានពិនិត្យពីស្ថាននាមតំបន់មួយចំនួនទៀតដែលស្ថិតនៅក្នុងតំបន់ក្បែរៗគ្នា ដែលបង្ហាញថា ឈ្មោះភាគច្រើនរបស់ភូមិ ឃុំ ស្រុក មួយចំនួនបានយកឈ្មោះរុក្ខជាតិធ្វើជាឈ្មោះភូមិ ឃុំ ស្រុករបស់ខ្លួនផងដែរ មានដូចជា៖

**៣.១.ឈ្មោះស្រុកមានដូចជា** ស្រុកព្រែកប្បាស (សំដៅដល់ឈ្មោះដើមកប្បាស), ស្រុកគិរីវង់(ស្រុមានភ្នំព័ទ្ធវង់កេលកុងតាមលំដាប់លមដោយគ្នា [ ជួន ណាត] ) ស្រុកទ្រាំង ស្រុកត្រាំកក់ ស្រុកសំរោង។

**៣.២.ឈ្មោះឃុំ មានដូចជា** ឃុំព្រៃល្វា (សំដៅដល់ឈ្មោះដើមល្វា) ឃុំចំប៉ា«ចម្ប៉ា» (សំដៅដល់ឈ្មោះដើមចម្ប៉ា) ឃុំព្រៃផ្ដៅ (សំដៅដល់ឈ្មោះវល្លិ៍ផ្ដៅ) ឃុំអង្គាញ់ (សំដៅដល់ឈ្មោះដើមអង្គាញ់), ឃុំស្នោ (សំដៅដល់ឈ្មោះដើមស្នោ) ឃុំចារ(សំដៅដល់ឈ្មោះដើមចារ)...។

**៣.៣.ឈ្មោះភូមិ មានដូចជា** ភូមិក្រសាំង (សំដៅដល់ឈ្មោះដើមក្រសាំង) ភូមិអង្គសង្កែ(សំដៅដល់ឈ្មោះដើមសង្កែ) ភូមិគរ (សំដៅដល់ឈ្មោះដើមគរ) ភូមិព្រៃតាពង (សំដៅដល់ឈ្មោះព្រៃ) ភូមិព្រីង (សំដៅដល់ឈ្មោះដើមព្រីង) ភូមិអង្គាញ់(សំដៅដល់ឈ្មោះដើមអង្គាញ់) ភូមិអំពិលរៀង (សំដៅដល់ឈ្មោះដើមអំពិល) ភូមិល្វាត្នោត (សំដៅដល់ឈ្មោះដើមល្វា និងដើមត្នោត) ភូមិរកា(សំដៅដល់ឈ្មោះដើមរកា) ភូមិកំពង់ស្រម៉ (សំដៅដល់ឈ្មោះដើមសម៉[236])ភូមិអំពិលលិច(សំដៅឈ្មោះដើមអំពិល) ភូមិស្រែពោធិ៍

[236] សម្ដេចព្រះសង្ឃរាជ ជួន ណាត៖ ជាឈ្មោះឈើព្រៃ ផ្លែមានរសល្វីង, ប្រើជាថ្នាំបញ្ចុះឬប្រើបរិភោគផ្ទាប់នឹងផ្អកត្រីប្រែជាដើមក៏បាន។ សម៉មានឈ្មោះច្រើនយ៉ាងមាន សម៉ក្អែក, សម៉ក្ដុក, សម៉ពិភេក ឬ សម៉ពិភេទក៍ ជាដើម។

(សំដៅដល់ស្រែដែលមានដើមពោធិ៍ដុះ) ភូមិព្រៃភ្វី(សំដៅដល់ព្រៃដែលមានផ្កាភ្វី) ភូមិព្រៃឈើទាល(សំដៅដល់ឈ្មោះដើមឈើទាល)...។

### ៤- ទិដ្ឋភាពជាក់ស្តែង

ក្រោយពីទទួលបាននូវព័ត៌មានខាងលើ ក្រុមការងារស្រាវជ្រាវបានរកឃើញភស្តុតាងជាច្រើនដែលទាក់ទិនជាមួយការសរសេរឈ្មោះភូមិសមរលោរ ដូចជាខ្លោងទ្វារវត្ត, សាលារៀន, អត្តសញ្ញាណបណ្ណធ្វើនៅឆ្នាំ២០០១ និងលិខិតស្នាមបញ្ជាក់ផ្សេងៗទៀត ដែលបានធ្វើមុនឆ្នាំ២០១២ កន្លងមក។ បើយោងទៅតាមប្រវត្តិសាស្ត្រ ឈ្មោះនៃទីកន្លែងនេះក៏បានបង្ហាញថា ភូមិនេះធ្លាប់ជា សមរភូមិចម្បាំងរវាងលាវ និងខ្មែរ ផងដែរ។ យើងមើលលើផែនទី សំណេរឈ្មោះភូមិនេះ គឺសរសេរ«**សមរ**» គឺ**ភូមិសរម**នេះឯង។ ក្រៅពីនេះ ក្រុមការងារយើងឃើញសំណេរភូមិសមរលោរនេះ សរសេរនៅតាមទីកន្លែងសំខាន់ៗជាច្រើនមាន សាលាបឋមសិក្សាតាកាហាស៊ីសមរមេត្រី សាលាបឋមសិក្សាសមរលោរ អនុវិទ្យាល័យសមរលោរ វិទ្យាល័យសមរលោរ វត្តសមរមេត្រី និងវត្តសមរលោរ ជាដើម។

# សាលាបឋមសិក្សាតាកាហាស៊ី សមរមេត្រី




# វិទ្យាល័យសមរលាភ



# ស្តូបស្រះតៀម



## អាស្រមចាស់លោកយាយលាង (ទទួលជង្វាយតែបាយដំណើប និង ប្រហុកដុត



## អាស្រមថ្មីលោកយាយ លាង
រៀបចំធ្វើថ្មីដោយបណ្ឌិត សេង ប៊ុនធឿន និងព្រះតេជគុណ ព្រះចៅអធិការវត្ត


100701274
គោត្តនាមនិងនាម: សេង វណ្ណា
SENG VANNA
ថ្ងៃខែឆ្នាំកំណើត: ២៥.០៨.១៩៩៦ ភេទ: ប្រុស កំពស់: ១៦០ ស.ម
ទីកន្លែងកំណើត: ឃុំពោធិចាក ស្រុកព្រៃកប្បាស តាកែវ
អាសយដ្ឋាន: ផ្ទះ:០០៣A
ឃុំពោធិចាក ស្រុកព្រៃកប្បាស តាកែវ
សុពលភាព: ២៤.១០.២០១២ ដល់ថ្ងៃ ២៣.១០.២០២២
IDKHM1007012746<<<<<<<<<<<<<<<
9608258M2210230KHM<<<<<<<<<<<8
SENG<<VANNA<<<<<<<<<<<<<<<<<<<


100731659
គោត្តនាមនិងនាម: ហោ ស្រីទូច
HOR SREYTOUCH
ថ្ងៃខែឆ្នាំកំណើត: ០៦.១០.១៩៩២ ភេទ: ស្រី កំពស់: ១៥០ ស.ម
ទីកន្លែងកំណើត: ឃុំពោធិចាក ស្រុកព្រៃកប្បាស តាកែវ
អាសយដ្ឋាន: ផ្ទះ:០០២A
ឃុំពោធិចាក ស្រុកព្រៃកប្បាស តាកែវ
សុពលភាព: ១៤.១២.២០១២ ដល់ថ្ងៃ ១៣.១២.២០២២
IDKHM1007316592<<<<<<<<<<<<<<<
9210066F2212131KHM<<<<<<<<<<<0
HOR<<SREYTOUCH<<<<<<<<<<<<<<<<


100731603
គោត្តនាមនិងនាម: ហោ ចាន់ឌីប
HOR CHANKDEB
ថ្ងៃខែឆ្នាំកំណើត: ១៥.០៧.១៩៩៤ ភេទ: ប្រុស កំពស់: ១៥៨ ស.ម
ទីកន្លែងកំណើត: ឃុំពោធិចាក ស្រុកព្រៃកប្បាស តាកែវ
អាសយដ្ឋាន: ផ្ទះ:០០២A
ឃុំពោធិចាក ស្រុកព្រៃកប្បាស តាកែវ
សុពលភាព: ១៤.១២.២០១២ ដល់ថ្ងៃ ១៣.១២.២០២២
IDKHM1007316031<<<<<<<<<<<<<<<
9407152M2212131KHM<<<<<<<<<<<0
HOR<<CHANKDEB<<<<<<<<<<<<<<<<<



រូបភាព

កុដិហោត្រ័យ និងសកម្មភាពសមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរជួបសម្ភាសន៍ជាមួយព្រះចៅអធិការវត្ត សមាជិកក្រុមប្រឹក្សាឃុំប្រធាន គណៈកម្មការវត្ត អតីតគ្រូបង្រៀន និង ចាស់ព្រឹទ្ធាចារ្យក្នុងភូមិសមរលោរ និងសមរខ្មែរ។



## I V- សន្និដ្ឋាន

ក្រុមការងារសម្រេចរក្សាសំណោរនៃឈ្មោះភូមិដូចដើមដដែល គឺ **ភូមិសមរលោរ** និង **ភូមិសមរខ្មែរ** អនុលោមតាមការស្រាវជ្រាវលើទិដ្ឋភាពប្រវត្តិសាស្ត្រ ផែនទី អាជ្ញាធរដែនដី ម្ចាស់ស្រុក (ចាស់ព្រឹទ្ធាចារ្យ) ព្រះសង្ឃ ។រក្សាសំណោរដើម សមរ នេះតម្រូវតាមទម្លាប់ការរៀន និងការសរសេររបស់ ប្រជាជនដែលរស់ នៅទីនោះផង និងមានសំណោរ សមរ នៅលើផែនទី លើខ្លោងទ្វារវត្ត លើខ្លោងទ្វារសាលារៀនថែមទៀត បានធ្វើឲ្យពួកគាត់សប្បាយចិត្តជាខ្លាំង ព្រោះនេះជាអត្តសញ្ញាណមួយរបស់ពួកគាត់ផងដែរ។

រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៥

**អ្នកធ្វើរបាយការណ៍**

**ប៊ុត សុម៉េត**

**បានឃើញ និង ឯកភាព**

**ជ. ប្រធានក្រុម**

បណ្ឌិត **សន ពៅ**

# ឧបសម្ព័ន្ធទី៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ


ទីស្តីការគណៈរដ្ឋមន្ត្រី
ក្រុមប្រឹក្សាជាតិភាសាខ្មែរ
អាសយដ្ឋាន : មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ,
ទូរសារ : ០២៣ ៨៦ ២២ ០៧, E-mail : info@nckl.gov.kh

National Council of Khmer Language
Conseil National de la Langue Khmère
ទូរស័ព្ទ : ០១៦ ៤៧ ៣៧ ០១, ០១២ ៥០ ២៥ ៨៥
គេហទំព័រ : www.nckl.gov.kh


**កំណត់ហេតុ**
**ប្រជុំក្រុមពិសេសលើកទី២នៃក្រុមប្រឹក្សាជាតិភាសាខ្មែរ (ក.ជ.ភ.ខ.)**
(ថ្ងៃពុធ ទី២៣ ខែកញ្ញា ឆ្នាំ២០១៥)

នៅឆ្នាំពីពាន់ដប់ប្រាំ ខែកញ្ញា ថ្ងៃពុធ ទីម្ភៃបី វេលាម៉ោងពីរសាមសិបនាទីរសៀល នៅសាលប្រជុំនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ មានការប្រជុំ ក.ជ.ភ.ខ. ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិតសភាចារ្យ **ទិច សំណាង** ប្រធានស្តីទី ក.ជ.ភ.ខ.នេះ ដើម្បីពិនិត្យរបៀបវារៈ ដូចតទៅ៖

១- ពិនិត្យនិងអនុម័តសំណើរបស់ក្រសួងមហាផ្ទៃ ស្តីពីសំណើសុំជួយអន្តរាគមន៍ផ្លាស់ប្តូរឈ្មោះភូមិពី«សម៉រលោរ» មកជា«សមរលោរ» ដែលជាសំណេរត្រឹមត្រូវវិញ,

២- ពិនិត្យនិងអនុម័តសំណើរបស់អាជ្ញាធរអប្សរា ស្តីពីសំណើសុំជួយពិនិត្យនិងកែតម្រូវកំហុសអក្ខរាវិរុទ្ធជាភាសាខ្មែរនិងអក្សរឡាតាំងអំពីឈ្មោះប្រាសាទចំនួន៩១ មានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ដើម្បីយកទៅប្រើប្រាស់ជាផ្លូវការនៅក្នុងតំបន់អង្គរ។

ចំពោះសមាជិកដែលចូលរួមប្រជុំ សូមមើលបញ្ជីវត្តមានដែលមានភ្ជាប់ជាមួយកំណត់ហេតុនេះ។

ជាកិច្ចចាប់ផ្តើម ឯកឧត្តមប្រធានអង្គប្រជុំបានស្វាគមន៍សមាជិកទាំងអស់ ដែលចូលរួមប្រជុំនៅពេលនោះ ដើម្បីពិនិត្យនិងអនុម័តរបៀបវារៈទី១ ដែលជាសំណើរបស់ក្រសួងមហាផ្ទៃ។

ក្រោយពីបានពិភាក្សា ផ្តល់យោបល់គ្នាទៅវិញមកយ៉ាងល្អិតល្អន់ ដោយផ្អែកលើមូលដ្ឋានមួយចំនួនដូចជា ការស្នើសុំរបស់អ្នកស្រុក រឿងព្រេងទាក់ទងនឹងប្រវត្តិសាស្ត្រ ការសរសេរឈ្មោះនៅតាមខ្លោងទ្វារវត្ត សាលារៀន ការសរសេរនៅលើផែនទីដែលរៀបរៀងឡើងវិញដោយនាយកដ្ឋានភូមិសាស្ត្រនៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៦ និង របាយការណ៍ស្រាវជ្រាវឈ្មោះភូមិ«សមរលោរ» របស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ អង្គប្រជុំបានសម្រេចដូចខាងក្រោម៖

១- **«ភូមិសម៉រលោរ»** សរសេរបែបនេះ ផ្លាស់ទៅជា **«ភូមិសមរលោរ»**

២- **«ភូមិសម៉រខ្មែរ»** សរសេរបែបនេះ ផ្លាស់ទៅជា **«ភូមិសមរខ្មែរ»** វិញ។

ដោយបានការអនុម័តសម្រេចក្នុងសម័យប្រជុំនៃ ក.ជ.ភ.ខ. សុំឱ្យប្តូរឈ្មោះ**«ភូមិសម៉រលោរ»** ដែលសរសេរបែបនេះផ្លាស់ទៅជា **«ភូមិសមរលោរ»** ចប់សព្វគ្រប់ ឯកឧត្តមប្រធានអង្គប្រជុំបានបញ្ចប់របៀបវារៈទី១នេះនៅថ្ងៃខែឆ្នាំដដែលក្នុងបរិយាកាសស្និទ្ធស្នាលនិងរីករាយ។

បានឃើញនិងឯកភាព
ប្រធានអង្គប្រជុំ
បណ្ឌិតសភាចារ្យ **ទិច សំណាង**

លេខាកត់ត្រា
**មាឃ ប៊ូរ៉ា**

# ឧបសម្ព័ន្ធទី៥

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខ: [illegible]

## ប្រកាស
## ស្តីពី
## ការប្តូរឈ្មោះភូមិ នៃឃុំពោធិ៍រំចាក ស្រុកព្រៃកប្បាស ខេត្តតាកែវ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកត/១០៩៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០២០ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងលិខិតលេខ ៣៦១/១៥ ក.ជ.ភ.ខ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៥ របស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ។

## សម្រេច

**ប្រការ ១.-**

ត្រូវបានប្តូរឈ្មោះភូមិចំនួន ០២ នៃឃុំពោធិ៍រំចាក ស្រុកព្រៃកប្បាស ខេត្តតាកែវ ដូចខាងក្រោម ៖

- **ភូមិសម៉ណោរ** ត្រូវបានប្តូរឈ្មោះទៅជា **ភូមិសមរណោរ**
- **ភូមិសម៉ខ្មែរ** ត្រូវបានប្តូរឈ្មោះទៅជា **ភូមិសមរខ្មែរ** ។

**ប្រការ ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ ៣.-**

អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រុមប្រឹក្សាខេត្តតាកែវ អភិបាល នៃគណៈអភិបាលខេត្តតាកែវ និងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ,ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

កន្លែងទទួល:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងផែនការ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ក្រុមប្រឹក្សាជាតិភាសាខ្មែរ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- ដូចក្នុងប្រការ ៣ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៦

## ឈ្មោះជាភាសារៀ

| ល.រ | ឈ្មោះជាភាសាខ្មែរ[336] | តណាមជំនាន់បារាំង | មុនឆ្នាំ ១៩៧៥ | សព្វថ្ងៃ |
|---|---|---|---|---|
| ១ | ព្រះត្រពាំង | ត្រាវិញ/ខ្លះថា (ត្រាយិញ) | វិញបិញ | គីវឡុង |
| ២ | ខេត្តឃ្លាំង | សុកទ្រាំង | សុកទ្រាំង | ហូវយ៉ាង |
| ៣ | មាត់ជ្រូក | ចូវដុក | ឡុងស្វៀង | អានយ៉ាង |
| ៤ | ក្រមួនស | រ៉ាជ្សា | | |
| ៥ | ពលលាវ | បាក់លីវ | បាស្វៀង | |
| ៦ | ទឹកខ្មៅ | កាម៉ៅ | អានស្វៀង | មិញហាយ |
| ៧ | ពាម(ពាមបន្ទាយមាស) | ហាទៀង | | |
| ៨ | ព្រែកឫស្សី | កាន់បឺ | ផុងឌិញ | |

[336] *សូ អឿ ៖ ប្រវត្តិសាស្ត្រព្រះរាជាណាចក្រកម្ពុជាជាមួយអាណ្ណាម និងសៀមចាប់ពីសតវត្សទី១៦ ឆ្នាំ១៩៩៥ ទំព័រ១០៨-១០៩។*

| | | | | |
|---|---|---|---|---|
| ៩ | លង់ហោ | វិញឡុង | វិញឡុង | វិញឡុង |
| ១០ | ពាមប៉ារាជ | ឡុងស្មៀង (Long Xuyen) | | |
| ១១ | រោងដំរី | តៃនិញ | តៃនិញ | តៃនិញ |
| ១២ | ព្រៃនគរ | សាយហ្គន | សាយហ្គន | ហូជីមិញ |
| ១៣ | ទួលតាមោក | ធូយ៉ូវមោក | ប៊ីញឡុង | សុងប៊ែរ |
| ១៤ | ផ្សារដែក | សាដែក | | |
| ១៥ | ចង្វាត្រពាំង ស្រកាត្រី | ប៊ិនហោ(Bien Hoa) | | |
| ១៦ | មេ ស | មីថូ (My Tho) | | |
| ១៧ | ព្រះសួគ៌ា | បារៀ | | |
| ១៨ | កោះគង | ហ្គូកុង | | |
| ១៩ | កំពង់ឫស្សី | បិនតេ(Ben Tre) | | |
| ២០ | អូកាប់ | កាប់សាំងហ្សាក់ | វង់តាវ | វង់តាវ |
| ២១ | កំពង់ក្របី | | | |

ក្រៅពីនេះមានកោះត្រល់វៀតណាមហៅថា ភូកុក (Phu Quoc) និងកោះត្រឡាច វៀតណាម ហៅថា ខុងដៅ(Con Dao) ជាដែនដីកោះ

មិនរាប់ជាខេត្តទេដែលបានបាត់ទៅខាងវៀតណាមដែរ។ ប្រភព ព័ត៌មានបន្ថែមដោយលោក ចៅ មុនីខេមរា និពន្ធនាយកវិទ្យុខ្មែរក្រោមអភិវឌ្ឍន៍(KKD Radio) និងជាប្រធានក្រុមស្រាវជ្រាវនៃមជ្ឈមណ្ឌលស្រាវជ្រាវអាមេរិកាំ

# ឧបសម្ព័ន្ធទី៧

## ទឹកដីខ្មែរដែលបាត់បង់ទៅខាងប្រទេសសៀមមានទំហំជាង ៦០,០០០គម²មានចំនួន១២ខេត្ត

| ល.រ | ឈ្មោះខេត្ត | ផ្សេងៗ |
|---|---|---|
| ១ | នគររាជសីមា | |
| ២ | សិរីសាកេត | |
| ៣ | បុរីរម្យ | |
| ៤ | សុរិន្ទ | |
| ៥ | ធនបុរី | |
| ៦ | ស្ទឹងជ្រៅ | |
| ៧ | ចន្ទបុរី | |
| ៨ | គោកខណ្ឌ | |
| ៩ | បស្ទឹមបុរី | |
| ១០ | ក្រាត(ត្រាត) | |
| ១១ | សង្គិត | |
| ១២ | អ៊ូប៊ុន | |

# ឧបសម្ព័ន្ធទី៨

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

លេខ: ៥៧ អយក. សាជ៧

**សេចក្តីជូនដំណឹង**

**ស្តីពី**

**លទ្ធផលនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ និងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឆ្នាំសិក្សា ២០១៩-២០២០**

អនុវត្តតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ពាក់ព័ន្ធនឹងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និងការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ឆ្នាំសិក្សា ២០១៩-២០២០ ក្រសួងអប់រំ យុវជន និងកីឡាកំណត់ឱ្យ "ជាប់ជាស្ថាពរ" ចំពោះ "បេក្ខជនទាំងអស់ ដែលបានចុះឈ្មោះប្រឡង" ដោយគ្មានការកំណត់និទ្ទេស។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា បុគ្គលិកអប់រំ មាតាបិតា អ្នកអាណាព្យាបាល សិស្សានុសិស្សគ្រប់រូប មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ ពុធ ៧ រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**

- សាលារាជធានី ខេត្ត
- គ្រប់អគ្គនាយកដ្ឋាន
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
- សមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
  "ដើម្បីជូនជ្រាប និងសហការ"
- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋានរដ្ឋបាល

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៤៣ / ២២០ ៣០៨ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

# ឧបសម្ព័ន្ធទី៩
# រូបភាពប្លង់ក្លោងទ្វារវត្តសមរលាភ






# ឧបសម្ព័ន្ធទី១០
# បទចម្រៀងអនុស្សាវរីយ៍

## ១-ព្រៃល្វាអនុស្សាវរីយ៍

I-ព្រៃល្វាទីធ្លាប់តែសង្ឃឹមទុក ថ្ងៃនេះទៅមុខបានសុខក្សេមក្សាន្ត
ប្រាថ្នានៃបនិត្យភ្ជាប់និស្ស័យប្រាណ ចិត្តគិតកល្យាណគ្មានពេលលោះថ្ងៃ។
II-ឱ!ព្រៃកប្បាសដែនស្ថានជម្រក បុប្ផាគោកធ្លកបេះដូងយុវវ័យ
បងលួចស្នេហ៍អូនពេញដួងហរទ័យ ស្នេហ៍មិនប្រណីបានត្រឹមយល់តែក
ក្ត្រ។
R-វេលាឃ្លាតទៅបងមានទុក្ខធំ ព្រោះឃ្លាតទ្រនំឆ្ងាយលែងជួបស្រី
បេះដូងសោកសៅមិនបានថ្មមបី ខានឃើញកក្រ្តថ្លៃ ក្នុងចិត្តខ្វល់ខ្វាយ។
III-ភ្លើងស្នេហាបងជាកង្វល់ធំ រាល់ថ្ងៃឆេះងំមិនបាត់រសាយ
ចិត្តតែងស្រមៃត្បិតបងឃ្លាតឆ្ងាយ ទីទៃតែកាយតែចិត្តនៅនឹក។/

*រាជធានីភ្នំពេញ* ថ្ងៃអាទិត្យទី១៧ ខែកក្កដា ឆ្នាំ២០១១

និពន្ធដោយ **សេង ប៊ុនធឿន** និពន្ធបទភ្លេង **ឯល ប៊ុនណា** ច្រៀងដោយ **ឯក ស៊ីដេ**


Slow
F Am Dm C F F7 B♭ C
F B♭ F F Dm B♭ C7 Dm
F A7 Dm B♭ F D7 Gm G7 C7 F C7
1.
2.
F Gm C7 F F7 B♭ C7 F B♭
Music.
F D Bm G D Gm C7 F F7
(R)
B♭ D7 Gm G7 C F Dm B♭ C7
Dm F A7 Dm B♭ F C7 F B♭ F
F F F B♭ C7 F
Rall.

## ២-ឆ្នាំថ្មីរីករាយ

I-ខែចេត្រចូលឆ្នាំរបាំត្រុតប្របកៃ    កីសវង់ស្គរដៃប្រជាប្រិយខ្មែរ

II- បោះអង្គុញលាក់កន្សែងទាញព្រ័ត្រហូរហែ    ចាប់កូនខ្លែងផងដែរបោលឈូងឆ្នាំថ្មី។

សូមជូនពរជ័យឆ្នាំថ្មីរីករាយ !

II-អង្គរសង្ក្រាន្តតែងបានប្រារព្ធ    ទាំងថ្ងៃទាំងយប់ជួបជុំប្រុសស្រី

និស្សិតប្អូនបងសាកលវិទ្យាល័យ    ជាតិគ្រប់គ្រងឈ្មោះល្បីលែរៀបចំដែរ។

សូមជូនពរជ័យឆ្នាំថ្មីរីករាយ !

R-ឱ ! មិត្តយើងអើយចូលរួមគ្រប់ប្រាណ    កុំឲ្យខកខានសង្ក្រាន្តរបស់ខ្មែរ

មួយឆ្នាំមានម្តងជនបទស្រុកស្រែ    នាំគ្នាអភិរក្សថែវត្តស្រុកកំណើត។

សូមជូនពរជ័យឆ្នាំថ្មីរីករាយ !

III-កេរពីបុរាណវប្បធម៌ខេមរា    ទម្លាប់ដូនតាយើងធ្វើឲ្យកើត

ឆ្នាំថ្មីមកដល់ទោះនោចខ្ទើត    តុបតែងល្អធើតសង្ក្រាន្តឆ្នាំថ្មី។

សូមជូនពរជ័យឆ្នាំថ្មីរីករាយ !

*រាជធានីភ្នំពេញ* ថ្ងៃព្រហស្បតិ៍ ទី៣១ ខែសីហា ឆ្នាំ២០១៧

និពន្ធបណ្ឌិត **សេង ប៊ុនធឿន** និពន្ធបទភ្លេង **ឯល ប៊ុនណា** ច្រៀងដោយ **ឱ ប៉ាវ៉ែន**


(Drum)
C C C C F Em
Am Em Am Am C F C
Em Am Am C A7 Dm G
G Em Am (ឡើកទី២) Dm Dm Em Am Am
(Music)
Am Dm G C C F F
(R)
C A7 Dm G G Em Am Dm
G Em Am Am C F C Em
Am Am C A7 Dm G G Em Am
Dm Dm Em Am Am Am G Am
(Music)
D.S. al Coda
C C C F Em Am Em Am Am

## ៣-បុណ្យភ្ជុំឆ្នាំនេះ (ចង្វាក់ តាលុង)

I-ភ្លៀងរដូវភ្ជុំនៅម្តុំភូមិស្រី ស្រូវស្រែលាស់ខ្ចីដីព្រែកប្បាស

កុលាបរូបល្អដែនដីចំណាស់ បងចងចាំច្បាស់វាចាពុំងារ។

II-បុណ្យភ្ជុំឆ្នាំនេះវត្តគោកកញ្ជប ចំប៉ារាប់បាតកាន់បិណ្ឌរួមគ្នាជ្រោយ

ជម្លូពេជ្រសមរមេត្រី សមរលោវស្រីចិត្តភក្តីណាស់។

R-ភក្ត្រាញញឹម ញញឹមថ្ពាល់ស្រីខួចផង មើលចំម្តងៗបេះដូងវិល្លាសវាចា

ពីរោះកាយវិកាសមណាស់ ចិត្តមិនប្រែផ្លាស់លួចស្នេហ៍នួនល្អង។

III-សាច់សស្រីសមសូត្រខ្មែរពស្ត្រា គាប់គន់នេត្រាផាម្លូងបៃតង

ស្រឡាញ់អូនណាស់ណាកែវមាសបង ស្នេហ៍គ្រាដំបូងស្មោះស្ម័គ្ររក្សា។

*រាជធានីភ្នំពេញ* ថ្ងៃព្រហស្បតិ៍ ទី២៣ ខែកក្កដា ឆ្នាំ២០១១

បណ្ឌិត **សេង ប៊ុនធឿន** បទភ្លេង **ឯល ប៊ុនណា** ច្រៀងដោយ **ឯក ស៊ីដេ**


ស្គរ 3
Gm Gm B♭
8
Cm Cm Dm Gm Dm Gm
14
Gm Gm Gm Gm Dm Cm
20
Cm E♭ Dm Gm Dm
25
Gm B♭ B♭ Dm Gm
Music
30
Dm Gm Gm Gm E♭ E♭
1.
2.
36
B♭ B♭ Gm Gm B♭ B♭
42
Cm F Gm Dm Gm Gm
48
B♭ B♭ Dm Gm Dm Gm
rall.

## ៤-ឱភ្នំជីសូរ្យ

I -ឱ ! ភ្នំជីសូរ្យរមណីយដ្ឋានចាស់ បងអូនពីរនាក់ដឹកដៃគ្នាឡើង
ដល់ទីសំចតនៃជណ្តើរម្ខាង យើងទាំងពីរប្រាណឈប់លំហែកាយ
I I -វាយោត្រជាក់ទេសភាពស្ងប់ស្ងាត់ អារម្មណ៍រសាត់អណ្តែតទៅឆ្ងាយ
បងឱបថើបអូនក្រេបក្លិនមិនណាយ ស្នេហ៍មិនបានកាយប្រែជានិរាស។
R-ថ្ងៃ១៩ ខែកក្កដា អូនប្រាប់បងថាជាប់ហើយសម្ភាសន៍
ឈប់នៅស្រុកខ្មែរទៅស្រុកផ្សេងទៀត ស្នេហាប្តូរស្មៀតអូនលាបង្គង។
I I I -កាលអូនស្មោះបងពៅបានសន្យា មិនផ្លាស់ស្នេហាមេត្តាតែបង
ឥឡូវប្តូរចិត្តកែល្បិចប្រែខ្នង អាមេរិកដែនឆ្លងពង្រាត់ស្នេហ៍ខ្ញុំ។

*រាជធានីភ្នំពេញ* ថ្ងៃច័ន្ទ ទី២៥ ខែកក្កដា ឆ្នាំ២០១១
និពន្ធដោយ **សេង ប៊ុនធឿន** និពន្ធបទភ្លេង **ឯល ប៊ុនណា**
ច្រៀងដោយ **ឯក ស៊ីដេ**


Slow - Bolero
C Em7 Am Dm G7 C
C C F Em7 A7 Dm G7
C G+ C A7 Dm D7 G G+ D7 G7 C F
C F G7 C F
C A7 Dm D7 C G+ C F
Em7 A7 Dm G7 C G+ C A7 D7 G7 C G7
C A7 D7 C D7 G7 C Fm6 Cmaj7

## ៥-ភូមិសមរលាវ

I -ញាតិមិត្តជិតឆ្ងាយរីករាយជួបជុំ កំលោះក្រមុំផ្ទុំរាំកំសាន្ត
ជំនោរត្រជាក់ឡើងរាំគ្រប់ប្រាណ ចិត្តអស់រំខានបានរាំនឹងវរមិត្ត។
I I -ភូមិសមរលាវឈ្មោះពីបុរាណ ភូមិធ្លាប់សុខសាន្តរាំឲ្យបានស្និទ្ធ
ភូមិសមរចិនសមរចិនខ្មែរជាមិត្ត រាំតាមស្ម័គ្រចិត្តភាតរារាប់អាន។
R-រាំវង់ភូមិយើងរាំទាំងប្រុសស្រី ជយភូមិទាំងបីជីសុខក្សេមក្សាន្ត
អត្ថន័យពីរោះសមរស្ថាន គ្រប់ញាតិសន្តានស្មោះស្ម័គ្រស្នេហា។
I I I -អូនរីករាយណាស់រាំគូនួនល្អង ដួងចិត្តគួចផ្សងលួចស្នេហ៍ជីវ៉ា
ជាប់ស្នេហ៍បងហើយចង់រួមវាសនា ចង់ថ្នមកាយាបងមួយជីវិត។

*រាជធានីភ្នំពេញ* ថ្ងៃពុធ ទី២០ ខែមេសា ឆ្នាំ២០១៦

និពន្ធ **សេង ប៊ុនធឿន** បទភ្លេង **ឯល ប៊ុនណា** ច្រៀងដោយ **ពេជ្រ ចរិយា**


រាំវង់
ស្គរ ដី
G G Bm Em
C6 D7 G Em D7 C6 G
Bm Em Bm C6 D7 G
D7 G C D7 G G Bm Bm
1.
2.
Music
Em D7 D7 C D7 G D7
G C D7 G G C D7 G
Music
D.S. al Coda

## ៦-រលួសចេញផ្កា

I-ឳ ! ភ្លៀងធ្លាក់ដើមឆ្នាំ ផ្គាំទៅក្លាមខ្យង

ទឹកដក់ឳណាទឹកដក់ស្រែបង ក្លាមខ្យងសប្បាយក្រៃ។

II-ឳ ! រលួសចេញផ្កា សារិកាឆ្លើយឆ្លង ចឹកផ្កាឳណា

ចឹកផ្កាហើយផ្សង អ៊ាងអើយនួនល្អងបុប្ផាស្រី។

R-ឳ ! រលួសផ្កាអើយ ក្រហមប្រពៃក្រហមឳណា

ក្រហមផ្កាព្រៃ អ៊ាងអើយលុះក្ស័យបងសូមស្នេហា។

III-ឳ ! សមរលោរភូមិ អើយ ជួយខ្ញុំជាសាក្សី

បងសុំឳណាបងសុំស្នេហ៍ស្រី ថ្ងមបីអ៊ាងអើយកន្និដ្ឋាស្រីហើយ។

*រាជធានីភ្នំពេញ* ថ្ងៃពុធ ទី២០ ខែមេសា ឆ្នាំ២០១៦

និពន្ធ **សេង ប៊ុនធឿន** បទភ្លេង **ឯល ប៊ុនណា** ច្រៀង **ឯក ស៊ីដេ**


ក្បាច់
G Bm C D7 G
G G Em G Bm Em
D7 G D7 G G Bm Em Em
1.
Em G D Em G C D7
2.
G Bm Em Em G Em
G Bm Em D7 G D7 G G Bm
Em Em G D7 G G
D.S. al Coda

## ៧-សារ៉ាវ៉ាន់ភូមិយើង

I-ស្រណោះភ្លៀងខ្លាំងទឹកហូរកាត់ភូមិ ហ៊ីងច្រៀងរាំងហែលទឹកកំសាន្ត
ទឹកលិចជន់ជោរត្រពាំងកល្យាណ ហូរកាត់ភូមិស្ពានហ៊ីងរកចំណី

តឹតៗ តារ៊ឺត តឹត។

II-ឱ!សមរលោវភូមិយើងថ្កើងថ្កាន ប្រជាប្រុងប្រាណក្ដួរាស់ដាស់ដី
ផ្គរលាន់ដើមឆ្នាំនាំទឹកភ្លៀងថ្មី លិចភូមិលិចព្រៃស្រីដើរឆ្លងស្ពាន។

តឹតៗ តារ៊ឺត តឹត។

R-អើយពូម៉ីងអ៊ុំគ្រប់គ្នាឡើងរាំ កំឡោះក្រមុំឡើងរាំសារ៉ាវ៉ាន់
រាំតាមចង្វាក់ភ្លេងហើយចំណាំ កុំច្រឡំភាន់សារ៉ាវ៉ាន់ភូមិយើង

តឹតៗ តារ៊ឺត តឹត។

III-ក្រោយចូលឆ្នាំថ្មីបងនឹងប្រាប់ម៉ែ មានជំនួនដៃរសុំជណ្ដើរឡើង
ស្ដីដណ្ដឹងអូនតាមប្រពៃណីយើង ឲ្យបានថ្កុំថ្កើងទម្លាប់ដូនតា។

តឹតៗ តារ៊ឺត តឹត។

*រាជធានីភ្នំពេញ* ថ្ងៃព្រហស្បតិ៍ ទី២៨ ខែមេសា ឆ្នាំ២០១៦

និពន្ធបណ្ឌិត **សេង ប៊ុនធឿន** និពន្ធបទភ្លេង **ឯល ប៊ុនណា** ច្រៀងដោយ **ឌី ថាវ៉េន**


សារ៉ាវ៉ាន់
(Drum)
D Bm Em A7
D Em A7 D G A7 D
D D G A7 D B7 Em Em
A7 Bm A7 Bm Em A7
1.
A7 D Bm D B7 Em Em
2.
A7 Bm A7 Bm Em A7
D G A7 D D D G A7
D B7 Em Em A7 Bm A7
Bm Em A7 A Em D
D.S. al Coda

## ៨-សំឡីកប្បាស

I -ឱ! ផ្កាកប្បាសផ្លែផ្លាស់ចាស់ខ្ចី ផ្លែទុំសំឡីច្នៃជាផាហ៊ុំ
កប្បាសមានផ្កាផ្លែក្តិបចាស់ទុំ ប្រេះបែកកញ្ចុំធ្លាក់សំបកចាស់។
I I -សំឡីកប្បាសច្នៃប្រយោជន៍ធំ ត្បាញក្រមាម៉ុមមានអត្ថន័យណាស់
ឲ្យអូនជូតខ្លួនដណ្តប់ប្តូរផ្លាស់ ប្រុសស្រីក្មេងចាស់ប្រើគ្រប់និគម។
R-ស្រុកព្រៃកប្បាសដីចាស់បុរាណ កំណើតកល្យាណសែនសុខភិរម្យ
ដែនដីដំបូងខេមរាទ្រនំ បងសុំស្នេហ៍ម៉ុមសន្យាស្មោះស្ម័គ្រ ។
I I I -ឱ!ព្រៃកប្បាសវាលចំការស្រែ ក្រោមពន្លឺខែសន្សើមត្រជាក់

ស្រឡាញ់អូនណាស់ណាកែវសមរ[238] បងនឹងថ្នមថ្នាក់ជាគូស្នេហា។
*រាជធានីភ្នំពេញ*ថ្ងៃពុធ ទី២០ ខែមេសា ឆ្នាំ២០១៦
និពន្ធបណ្ឌិត **សេង ប៊ុនធឿន** និពន្ធបទភ្លេង **ឯល ប៊ុនណា** ច្រៀងដោយ **រ័ត្ន សុភក្រ្តា**

238 សូមអានថា *សាក់ម៉ាក់រ៉ាក់*


ឡាំលាវ
A5 A5 A C♯m D E7
A D E7 A Bm E7 A C♯m
Bm Bm D E7 A Bm E7
A D E7 A A C♯m D
1. 2.
A Bm E7 A F♯m D E7
A Bm E7 A Bm E7 A C♯m
Bm Bm D E7 A Bm E7
A D E7 A A Bm E7 A
D.S. al Coda

## ៩-ថ្កាល់ខួចមន្តស្នេហ៍

I-សង្ក្រាន្តឆ្នាំថ្មីបងរាំជាមួយនឹងអូន រាំនឹងមាសស្ងួនរាំ

កំសាន្តលេយើងរាំជាក្រុមប្រុសស្រីចាស់ក្មេង តាមចង្វាក់ភ្លេងរាំម៉ាឌីហ្សុន ។

II-យើងរាំរាំទាំងអស់គ្នា រាំគ្រប់អង្គាអញ្ជើញរួសរាន់

ប្រុសស្រីរាំហើយភ្នែកលួចគយគន់ រាំម៉ាឌីហ្សុនទាំងចាស់ទាំងក្មេង ។

R-យើងជាគូស្នេហ៍ហាត់រាំឲ្យស្ទាត់ រាំតាមបែបបទតាមចង្វាក់ភ្លេង

គូយើងគូគេរាំទាន់នៅក្មេង ងាកស្តាំងាកឆ្វេងរាំម៉ាឌីហ្សុន ។

III-បោះជើងស្រុះគ្នារាំក្រោមដួងខែ ថ្កាល់ខួចមន្តស្នេហ៍រំលេចសោភ័

ញាក់ស្មាឲ្យត្រូវស្តាប់ភ្លេងឲ្យទាន់ រាំម៉ាឌីហ្សុនសមរលាវយើង ។

*រាជធានីភ្នំពេញ* ថ្ងៃអាទិត្យ ទី១២ ខែមេសា ឆ្នាំ២០២០

**និពន្ធដោយ**បណ្ឌិត សេង ប៊ុនធឿន **បទភ្លេង** ឯល ប៊ុនណា **ច្រៀង** រ័ត្ន សុភក្ត្រា

**Madison**



## ១០-ដើមត្នោតភូមិអូន

I -ដើមត្នោតភូមិអូនសម្បត្តិពីកេរ អូនត្រូវរិះរេខំថែរក្សា
ថែឲ្យគង់វង់ដើមត្នោតខេមរា ដូចស្នេហ៍បុប្ផាបងឥតងាករេ។
I I -រសៀលទន់ទាបអូនរង់ចាំបង ម្លប់ត្នោតនួនល្អងតាំងពីបុព្វេ
យួរបំពង់ទឹកទៅជួបមាសមេ ថ្នាក់ថ្នមម្ចាស់ស្នេហ៍តាមតែចិន្តា។
R-ចៅសូមសំពះលំឪនកាយហៅ ភូមិសមរលោវយាយថែរក្សា
ជួយស្នេហ៍ជួបជុំប្រណម្យផ្កាស្លា រូបចៅទេ្វហាប្តូរផ្តាច់ជីវី។
I I I -យាយលាវលោកមានបារមីពូកែ ប្រទានពរស្នេហ៍យុវទាំងពីរ
ឲ្យបានជួបជុំសុខសាន្តរមេណី ស្លាម្លូផ្កាភ្ញីចៅសូមថ្វាត់ថ្វាយ។

*រាជធានីភ្នំពេញ* ថ្ងៃសៅរ៍ ទី២៨ ខែមករា ឆ្នាំ២០១៧
និពន្ធដោយបណ្ឌិត **សេង ប៊ុនធឿន** និពន្ធបទភ្លេង **ឯល ប៊ុនណា** ច្រៀងឯក **ស៊ីដេ**


Rumba
E♭ C7 Fm A♭ B♭ B♭
E♭ G7 Cm A♭ B♭ E♭ A♭ E♭ Fm
1.
B♭ B♭ Fm B♭ E♭ A♭ E♭ Cm B♭
2.
Bolero
E♭ A♭ C7 Fm F7 B♭ E♭ G7
Cm A♭ B♭ E♭ A♭ E♭ Fm B♭ E♭
Cm B♭ E♭ A♭ B♭ E♭
E♭ E♭ Fm B♭ E♭ Fm B♭ E♭
D.S. al Coda

## ១១-ក្សត្រីគោកធ្លកអង្គបុរី ( Slow lent ) ( ចិត្តរួច )

| | |
|---|---|
| I -ក្សត្រីគោកធ្លកអង្គបុរី | ព្រះថោងតោងស្បៃនាងនាគទេវី |
| ប្រវត្តិស្នេហ៍បឋមក្សត្រភូមី | ហ៊ុនទៀនលីវយីព្រហ្មលិខិតចារ។ |
| I I -បងដាំដើមធ្លកក្នុងវិទ្យាល័យ | ហ៊ុនសែនអង្គរបុរីទឹកដីភ្នំដា |
| អនុស្សាវរីយ៍ដាំដើមព្រឹក្សា | ជាប់ចិត្តបុប្ផាដីរាជធានី។ |
| R-វត្តកំពង់ហ្លួងអង្គរព្រៃកផ្ទោល | បុរាណតម្កល់សារមន្ទីរ |
| មាត់ស្ទឹងរំលឹកស្នេហ៍យើងទាំងពីរ | ម្លប់ច័ន្ទន៍គិរីនៅវត្តគំនូរ។ |
| I I I -អាស្រមឥសីប្រាសាទភ្នំដា | ជំនោរវស្សាបក់ឮរ៉ូៗ |
| វត្តភ្នំបុរីប្រៀបបានឋានសួគ៌ | ផ្សងស្នេហ៍ជាគូតោងស្បៃអូនហើយ។ |

ថ្ងៃសៅរ៍ ៩កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ពស២៥៦៤

*រាជធានីភ្នំពេញ* ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២០

និពន្ធបណ្ឌិត **សេង ប៊ុនធឿន** បទភ្លេង **ឯល ប៊ុនណា** ច្រៀងដោយ **ឌី ថាវ៉េន**


A F♯m Bm E7 D E7
A D A D E7 A F♯m C♯m
F♯m E7 A F♯m Bm E7 A C♯m F♯m
1.
Bm E7 A Bm E7 A D A
2.
(Music)
(R)
A F♯m Bm E7 F♯m E7 A F♯m Bm
E7 A D E7 A F♯m C♯m
F♯m E7 A F♯m Bm E7 A D A
A Bm E7 A Bm E7 A Dm A
3

## ១២-រំដួលខេមា(ថតរួច)

I -រំដួលខេមរា អា…អើយ…ផ្កាដុះលើថ្មរំដួលអង្គរអើ…អឺយអ៊ាងអឺយ…អឺយអ៊ាង អឺយ… ស្រស់ល្អសោភា រសគន់ពិដោសព្វល្អ…អ៊ាងអើយ…គន្ធា ដូចស្រី…អឺអើយ…ស្រីង្គារ ដូចស្រីស្រីង្គារនាសួគ៌ាឋាន។ II -សោភ័ណស ម្កស្សអឺយពុំទាស់ទ័យាអ៊ាងអើយ…គាប់ភ្នែកទស្សនា…អឺ…អ៊ាង អើយ…មិនរង្គាសបាន មន្តស្នេហ៍រំដួលឆាបឆួលអ៊ាងអើយ…ពេញប្រាណគ្មានថ្ងៃអឺ…អ៊ាងអើយអវសានត្តៗក្នុង ឋានលោកិយ៍។ និពន្ធទំនុកច្រៀង ដោយ **បណ្ឌិត សេង ប៊ុនធឿន** សម្រួលតន្ត្រីដោយលោក **ណាំ ប៊ុនណារ័ត្ន** ច្រៀង ដោយអ្នកស្រី **អ៊ុក ម៉ាលីស** រាជធានីភ្នំពេញ ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១៩


Dm Gm Dm Am Dm Dm Dm Dm Gm
17
1.
2.
(បន្ទរ)
Gm F Dm B♭ Am Dm Am Dm Gm
24
(បន្ទរ)
Dm Am Dm Dm Dm F F
30
F F B♭ Am Dm Am Dm
36
D.S. al Coda
Dm Gm Dm Dm Dm
41

## ១៣-សម្រស់បុប្ផាជាតិ(ថតរួច)

(ប)I -សម្បត្តិវប្បធម៌សម្បូរណ៌ស្អេកស្កះ ប្រភេទច្រើនណាស់សម្បត្តិខេមរា វប្បធម៌យើងថ្កើងពូជសាសន៍ថ្លៃថ្លា មានប្រាង្គសិលាណាចក្រអច្ឆរិយៈ មានប្រាង្គសិលាណាចក្រអច្ឆរិយៈ។(បន្ទរ)

(ស)I I -បុប្ផារំដួលក្លិនធួលឈ្ងុយឈ្ងប់ គន្ធាសាយសព្វសក្តិសមយសស័ក្តិ ក្លិនមិននិរាសមិនប្រែអប្បលក្ខណ៍ ខេមរាប្រក្សក្សចាំជាទំនុក ខេមរាប្រក្សក្សចាំជាទំនុក។ (បន្ទរ)

(ប)R-រូបផ្កាសែនល្អជាតិខ្មែរប្រណី ក្រាំងមាសបុរីយកអ្នកធ្លាក់ទុកអត្តសញ្ញាណជាតិខ្មែរតំណាងស្រុក ផែនដីបានសុខសន្តិភាពអង្វែងទៅ ផែនដីបានសុខសន្តិភាពអង្វែងទៅ(បន្ទរ)

(រួម)I I I -ឱមិត្តយើងអើយធនធានខេមរា ត្រូវតែដឹងថាជាតិខ្មែរគង់នៅជ្រោងកិត្តិស័ព្ទខ្ពស់សមយសពង្សផៅ ជាប់ក្លិនជ្រាលជ្រៅសម្រស់បុប្ផាជាតិ ជាប់ក្លិនជ្រាលជ្រៅសម្រស់បុប្ផាជាតិ(បន្ទរ)

និពន្ធដោយ **បណ្ឌិត សេង ប៊ុនធឿន** និពន្ធបទភ្លេង **ឯល ប៊ុនណា** សម្រួលតន្ត្រីដោយ លោក **ណាំ ប៊ុនណារ័ត្ន** ច្រៀងដោយ**លោក រ័ត្ន សុកត្រា** និង **អ្នកស្រី ពេជ្រ ថាវី**

*រាជធានីភ្នំពេញ* ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩




បទរំដួលអង្គរ និងសម្រស់បុប្ផាជាតិត្រូវបានច្រៀងបញ្ចូលគ្នាធ្វើជារបាំមានដំណង ដើងថា សម្រស់បុប្ផាជាតិ ទទួលបានពានរង្វាន់លេខ ១ ក្នុងមហោស្រពយុវជនទូទាំងប្រទេសអបអរសាទរទិវាវប្បធម៌ជាតិ ៣មីនា លើកទី២២ ឆ្នាំ២០២០។

## **១៤-រាំវង់អិនយូអឹម** (ចង្វាក់ រាំវង់)

I-(**ប**)អិនយូអឹមពិរោះមានន័យ សាកលវិទ្យាល័យជាតិគ្រប់គ្រងសូម

ឡើងរាំនិស្សិតបងប្អូន អ្នកគ្រប់គ្រងផងរាំសមអើយសែនសម។

II-(**ស**)សូមមិត្តនិស្សិតប្រុសស្រី សាស្ត្រាចារ្យមន្ត្រីឧត្តម

រាំដោយរីករាយឥតមានបង្ខំ សប្បាយឡើងរាំ រាំវង់អិនយូអឹម។

R-(**ប-ស**)អិនយូអឹមមហាសាមគ្គី យើងរាំមូលមីរទឹកមុខញញឹម

ប្រពៃណីខ្មែររីកស្រស់ប៉ប្រឹម អនាគតសង្ឃឹមភ្លឺថ្លាត្រចះ។

III-(**ប-ស**)យើងអបអរសាទរពិធី អិនយូអឹមសាមគ្គីភាតរៈ

អញ្ជើញរាំតាមចិន្តាស្ម័គ្រ ក្រោមម្លប់ត្រជាក់មហាគ្រួសារខ្មែរ។

*រាជធានីភ្នំពេញ* ថ្ងៃសុក្រ ទី ១ ខែមិនា ឆ្នាំ ២០១៩និពន្ធដោយ **បណ្ឌិត សេង ប៊ុនធឿន**

និពន្ធបទភ្លេង **ឯល ប៊ុនណា** សម្រួលតន្ត្រីដោយលោក **ណាំ ប៊ុនណារ័ត្ន**

ច្រៀងដោយ**លោក រ័ត្ន សុភត្រា** និង **អ្នកស្រី ពេជ្រ ថាវី**


F Dm F Gm
5
Gm C Dm Dm F F
11
Gm Dm Gm Gm Am Dm
17
Gm Gm Am Dm Gm Gm
music
23
Am Dm Dm Dm F B♭
1.
1.
29
C7 F Dm Dm C7
34
Dm Gm Gm C Dm Dm
music
40
Gm Gm Am Dm
rall.

## ១៥-ដួលក្រអូបគន្ធបុប្ផាជាតិ

ប-ឪ ! ផ្ការំដួលធួលក្លិនឈ្ងុយឈ្ងប់ ទោះថ្ងៃទោះយប់ក្លិនមិនរសាយ
បានស្គាល់ក្លិនហើយចិត្តនឹកមិនណាយ ចង់ឃើញឆោមឆាយតើស្រស់យ៉ាងណា
ស-រំដួលក្រអូបគន្ធបុប្ផាជាតិ ជិតឆ្ងាយផៅញាតិជាប់ចិត្តរូបផ្កា
មានសម្រស់ល្អជាតិខ្មែរកត់ត្រា ក្នុងដែនខេមរាផ្កាល្បីខ្ចរខ្ចាយ។
ប-ឪ ! ផ្ការំដួលរំដួលចិត្តបង ផ្កាជាតិគ្រប់គ្រងរន្ទឺសុះសាយ
ថ្មៃរបាំជាតិល្បីទីជិតឆ្ងាយ រំលេចរូបកាយស្នាដៃយុវវ័យ។
ប-ស-ឪ ! រំដួលអើយរីកក្នុងរបង នៅជាតិគ្រប់គ្រងសាកលវិទ្យាល័យ
មរតករបាំល្វតល្វន់ឥតបី របាំប្រពៃណីសម្រស់បុប្ផាជាតិ។

ថ្ងៃអាទិត្យ ១២រោច ខែមាឃ ឆ្នាំច សំរិទ្ធិស័ក ព.ស. ២៥៦២
*រាជធានីភ្នំពេញ* ថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៩

និពន្ធបណ្ឌិត សេង ប៊ុនធឿន ភ្លេង ឯល ប៊ុនណា ច្រៀង ឌី ថារ៉េន និង ពេជ្រ ចរិយា


ពីក្បាច់
F G7 C Dm G7 C
C F C C F C A7
Dm G G+ C Dm G G
1.
2.
Dm G7 C F C Am Dm G7 C
F C C F D G
G C F C A7 Dm
G G+ C Dm G7 C F C
D.S. al Coda
C Dm G7 C F C F C
rall....

## អំពីអ្នកនិពន្ធ



លោក សេង ប៊ុនធឿន កើតថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៧២ នៅភូមិសមរលោរ ឃុំពោធិ៍រំចាក ស្រុកព្រៃកប្បាស ខេត្តតាកែវ។ លោកបានចូលសិក្សាបន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យដួលរលំនៅសាលាកម្រិតសិក្សាទី១ (បឋមសិក្សា) សមរលោរ ក្នុងឆ្នាំ១៩៨១ សាលាមធ្យមសិក្សាកម្រិត១(ឱប្ញម) ព្រៃល្វា(ទីរួមស្រុកព្រៃកប្បាស)ក្នុងឆ្នាំ១៩៨៥។ លោកត្រូវបានបងជីទួតមួយនាំយកទៅឲ្យរៀននៅសាលាបំពេញវិជ្ជាក្រៅម៉ោងធ្វើការនៃវិទ្យាល័យតាកែវ (បច្ចុប្បន្នវិទ្យាល័យ ជាស៊ីម តាកែវ) ពីឆ្នាំ១៩៨៨ដល់ឆ្នាំ១៩៩២ដើម្បីសិក្សាយកសញ្ញាបត្រមធ្យមសិក្សាកម្រិត២(BACII)។ លោកជានិស្សិតអាហារូបករណ៍ ហើយទទួលបានបរិញ្ញាបត្រ នីតិសាស្ត្រ ពីមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច (បច្ចុប្បន្នសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច) នាឆ្នាំ១៩៩៨ និងនៅឆ្នាំ២០០១ ទទួលបានបរិញ្ញាបត្រ ប្រវត្តិវិទ្យា ពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ ឆ្នាំ២០០៤ លោកទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ នីតិសាស្ត្រ ពីសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ហើយនៅឆ្នាំ២០០៩ លោកទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែក អប់រំវិធីសាស្ត្របង្រៀនភាសាអង់គ្លេស (MEd-TESOL) ពីសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជាដដែល។ នៅឆ្នាំ២០១២ លោកទទួលបានសញ្ញាបត្របណ្ឌិតទស្សនៈវិជ្ជាផ្នែកនីតិសាស្ត្រ (PhD in Law) ពីរាជបណ្ឌិត្យសភាកម្ពុជា។

មុខជំនាញសិក្សាវគ្គខ្លីៗជាច្រើនដែលលោកបានសិក្សា ជាពិសេស វិជ្ជាជីវៈសារព័ត៌មាន (Professional Journalism) នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ឧបត្ថម្ភដោយមូលនិធិអាស៊ី (Asia Foundation)។ ធ្លាប់បានឧនសម្បទានៅថ្ងៃ១១រោច ខែចេត្រ ឆ្នាំម្សាញ់ ត្រីស័ក ព.ស២៥៤៥ ត្រូវនឹងថ្ងៃទី៨ ខែមេសា គ.ស២០០២។

ចំពោះបទពិសោធន៍ការងារ លោកធ្លាប់បម្រើការងារជាជំនួយការឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ជានាយកខុទ្ទកាល័យ ជាគ្រូបង្រៀននៅតាមអង្គការ និងគ្រឹះស្ថានឧត្តមសិក្សានានាក្នុងព្រះរាជាណាចក្រកម្ពុជា។ បច្ចុប្បន្ន លោកជាសាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង និងជាសមាជិកសមាគមអ្នកប្រវត្តិសាស្ត្រកម្ពុជា។

*វចនានុក្រមខ្មែរ (Khmer Dictionary) ដែលបោះពុម្ពដោយនគរធំឆ្នាំ២០១០ទំព័រ១២៦៦បានចារិកថា **សមរ** (១) [សៈ មៈ រៈ សៈ ម៉ៈ រៈ] ន. (សំ.បា.)សង្គ្រាមទ័ព។ **សមរ** (២) [សៈ ម៉ៈ ] ន. (សំ.ស្មរ.ស្មរ) ការរលឹក, ការចងចាំ, ដំណើរនឹកឃើញមិនចេះភ្លេច, សេចក្តីស្រឡាញ់អស់ពីចិត្ត។ គុ. ជាទីស្រឡាញ់អស់ពីចិត្ត,ដែលស៊ូស្លាប់ស៊ូរស់ជាមួយគ្នា(ប្រើក្នុងពាក្យកាព្យចំពោះតែលើស្ត្រី)។ ឧទាហរណ៍ សមរថ្លៃ សមរមេត្រី ខ្លួនសមរ កែវសមរ មាសសមរ។ល។ ព. កា.) ហៃកែវសមរមិត្រ ចូរកុំគិតពីក្តីក្រ ព្រោះយើងប្រព្រឹត្តល្អ តំណារសុខមុខតែមាន។*

*សម្តេចព្រះសង្ឃរាជ ជួន ណាត អានថា សៈម៉ មានន័យថា ជាទីតាំងប្រយុទ្ធរបស់សត្រូវ ជាសមរភូមិ។ រីឯ ភូមិ មានន័យថា ទីកំណើត ស្រុកកំណើត ឬភូមិកំណើត។ **ភូមិសមរលាវ** ជាសមរភូមិរបស់លាវ ភូមិ**សមរខ្មែរ** ជាសមរភូមិរបស់ខ្មែរ និង**ភូមិសមរចិន** ជាសមរភូមិរបស់ចិន ឬសមរ អាចមានន័យថា ជាការនឹករលឹក ការស្រឡាញ់រាប់អានគ្នា ការមិនបំភ្លេចគ្នា ការស៊ូស្លាប់ ស៊ូរស់ជាមួយគ្នា នៃខ្មែរ លាវ ចិន ឬនៃអ្នកភូមិទាំងបី។*

*វានឹងបង្កើតបានជាវិប្បដិសារីដ៏ធំមួយ ប្រសិនបើយើងបន្តនៅស្ងៀមស្ងាត់ជាមួយនឹងកំហុស ដែលយើងក៏បានដឹងដែរថា វាអាចនឹងផ្តល់ផលវិបាកយ៉ាងខ្លាំងដល់អនាគតរបស់យើង។*

***គាំទ្រថវិកាលើការរៀបរៀង និពន្ធ និងកែលម្អដោយ***

***ក្រសួងអប់រំ យុវជន និងកីឡា***

***មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍***

CAMBODIA

រក្សាសិទ្ធិគ្រប់យ៉ាង

2021

9 789996 381027

ISBN 978999-63-810-2-7